
ហេរី ផៅតធ័រ
និង
បន្ទប់
សម្ងាត់
J. K. ROWLING

# ហេរី ផោតទ័រ

## និង បន្ទប់សម្ងាត់

*(រចនាក្របដោយ៖ ហេង ពិសិដ្ឋ)*

និពន្ធដោយ J. K. ROWLING

*ប្រែសម្រួលជាខេមរភាសាដោយ៖*

- ✓ *សៀ លីហ្សង*
- ✓ *សុភក្តិ ម៉ារ៉ា*
- ✓ *ហេង ពិសិដ្ឋ*
- ✓ *ង៉ុយ គាឡុង*
- ✓ *គៀន ហ្វកហ្វីដែល*
- ✓ *អ៊ឹង ទីរឿង*

# មាតិការឿង


| | | |
|---|---|---|
| វគ្គ ១ | ថ្ងៃខួបកំណើតដ៏អាក្រក់បំផុត | ទំ. ១ |
| វគ្គ ២ | ការដាស់តឿនរបស់ដុបប៊ី | ទំ. ៨ |
| វគ្គ ៣ | នៅប៊ូរ៉ូ | ទំ. ១៧ |
| វគ្គ ៤ | នៅហាងហ្លារីស និងប្លត់ | ទំ. ៣០ |
| វគ្គ ៥ | ដើមឈើ វ៉ុមភីង វីឡូ | ទំ. ៤៦ |
| វគ្គ ៦ | ហ្គីលដឺរ៉យ ឡុក់ហាត | ទំ. ៦១ |
| វគ្គ ៧ | ឈាមកខ្វក់ និងពាក្យខ្សឹបខ្សៀវ | ទំ. ៧៣ |
| វគ្គ ៨ | ពិធីជប់លៀងបុណ្យសព | ទំ. ៨៦ |
| វគ្គ ៩ | សំណេរលើជញ្ជាំង | ទំ. ១០០ |
| វគ្គ ១០ | បាល់ប្លាត់ជឺរអំណាច | ទំ. ១១៦ |
| វគ្គ ១១ | ក្រុមប្រយុទ្ធតាំង | ទំ. ១៣១ |
| វគ្គ ១២ | ទឹកថ្នាំបំលែងកាយ | ទំ. ១៤៦ |
| វគ្គ ១៣ | សៀវភៅកំណត់ហេតុដ៏សំងាត់ | ទំ. ១៦១ |
| វគ្គ ១៤ | ខននីល្យូស ហ្វូដជ៍ | ទំ. ១៧៦ |
| វគ្គ ១៥ | អារ៉ាហ្គក | ទំ. ១៨៧ |
| វគ្គ ១៦ | បន្ទប់សម្ងាត់ | ទំ. ១៩៩ |
| វគ្គ ១៧ | ទាយាទស្លីធើរីន | ទំ. ២១៥ |
| វគ្គ ១៨ | អំណោយសំរាប់ដុបប៊ី | ទំ. ២៣០ |

## វគ្គ I



# ថ្ងៃខួបកំណើតដ៏អាក្រក់បំផុត

មិនមែនត្រឹមតែលើកដំបូងនោះទេ ដែលជម្លោះប្រកែកតែងតែកើតឡើង នៅពេលទទួលទានអាហារពេលព្រឹកឯមហាវិថីប្រាយវេដ ជ្រាយ ផ្ទះលេខបួន។ លោកវើរណុន ឌើស្លីត្រូវបានដាស់ឲ្យភ្ញាក់ពីដំណេកតាំងពីព្រលឹមម្ល៉េះ ដោយសារសំឡេងទីទុយយំដ៏ថ្លង់ចេញពីបន្ទប់ក្មួយប្រុសរបស់គាត់ ឈ្មោះហេរី។

- បីដងហើយក្នុងមួយសប្តាហ៍នេះ!- គាត់គ្រហឹម។ - ប្រសិនជាឯងគ្រប់គ្រងទីទុយនោះមិនបានទេ យើងនឹងបណ្តេញវាចេញហើយ!

ហេរីព្យាយាមពន្យល់ម្តងហើយម្តងទៀត។

- វាធុញណ៎ា- វាបាននិយាយ។ - វាធ្លាប់តែចេញហើរជុំវិញនៅខាងក្រៅ។ ប្រសិនបើខ្ញុំអាចឲ្យវាចេញហើរនៅពេលយប់បាននោះ...

- តើអញមើលទៅដូចមនុស្សភ្លើរឺ?- លោកមាវើរណុនគ្រហឹម ដោយមានកំទេចពងទាចៀនសំយុងចុះពីពុកមាត់ស្រមូវរបស់គាត់។ - ស្មានថាអញមិនដឹងរឺ ថានឹងមានអ្វីកើតឡើង ប្រសិនជាហ៊ានតែអោយអាទីទុយនោះចេញក្រៅ...

គាត់ផ្លាស់ប្តូរនូវទឹកមុខខ្មោងងឹតជាមួយនឹងប្រពន្ធរបស់គាត់ ពីទូនៀ។

ហេរីព្យាយាមឈ្លោះតបវិញ ប៉ុន្តែ ពាក្យសម្តីរបស់វាទាំងអម្បាលម៉ានត្រូវរលាយទៅវិញដោយសំឡេងភើដ៏ខ្លាំងចេញពីកូនរបស់គ្រួសារឌើស្លី គឺដាត់លី។

- ខ្ញុំត្រូវការដុំខ្លាញ់ប្រឡាក់ទៀត។

- មានទៀតនៅក្នុងខ្ទះចៀន កូន សម្លាញ់- អ្នកមីងពីទូនៀស្រដី ដោយ បែរក្រសែភ្នែកដ៏ស្រអាប់ដាក់កូនប្រុសកន្ធាត់របស់គាត់។ - យើងត្រូវតែចិញ្ចឹមកូនខណៈពេលដែលយើងនៅមានឱកាស....ម៉ាក់មិនចូលចិត្តម្ហូបអាហារនៅសាលានោះសោះ...

- គ្មានបានការទេ ពីទូនៀ បងមិនដែលឃ្លានម្តងណាឡើយនៅពេលដែលបងរៀននៅ ស្មែលទីង្គ នោះ- លោកមាវើរណុននិយាយយ៉ាងពេញចិត្តពេញថ្លើម។ - ដាត់លីទទួលបានល្មមគ្រប់គ្រាន់ហើយ មែនទេ កូនប្រុស?

ដាត់លី ដែល មានមាឌធំក្រអាញ គូទរបស់វាទ្រោមទៅលើជ្រុងទាំងសងខាងកៅអី បាន សើចស្ញេញ ហើយ បែរទៅរកហេរី។

- យកខ្ទះចៀនបន្តិចមើល៎។

- ឯងភ្លេចពាក្យវេទមន្តហើយ - ហេរីនិយាយយ៉ាងមួម៉ៅជាខ្លាំង។

ការជះឥទ្ធិពលនៃប្រយោគដ៏សាមញ្ញនេះទៅលើមនុស្សក្នុងគ្រួសារឌើស្លីពិតជាមិនគួរឲ្យជឿទាល់តែសោះ៖ ដាត់ លីដង្ហក់ដង្ហើម ហើយ ធ្លាក់ចុះពីកៅអីរបស់វាដោយបន្លឺសូរទង្គិច ធ្វើឲ្យរញ្ជួយផ្ទះបាយទាំងមូល ឯ អ្នកស្រីឌើស្លីបានបន្លឺសម្រែកដ៏តូចមួយហើយយកដៃខ្ទប់មាត់របស់គាត់ រីឯ លោកឌើស្លីវិញបានក្រោកឈរឡើង ឃើញសរសៃឈាមកំពុងតែលោតផ្លោតៗនៅក្នុងសៀតផ្ការបស់គាត់។

- ខ្ញុំចង់មានន័យថា «សូមមេត្តា»! - ហេរីបានស្រដីយ៉ាងរហ័ស។ - ខ្ញុំមិនមែនមានន័យថា...

- តើយើងបានប្រាប់ឯងយ៉ាងម៉េចខ្លះ- លោកមារបស់វាបានស្រែក ខ្ទាតទឹកមាត់ពេញលើតុ - ពីរឿងនិយាយពាក្យ "វ៉" នៅក្នុងផ្ទះរបស់យើង?

- ប៉ុន្តែ ខ្ញុំ...

- ឯងថ្លើមធំហ៊ានគំរាមដាត់លីផងរឺ!- លោកមាវើរណុនបានគ្រហឹម ដោយដំតុនឹងកណ្តាប់ដៃរបស់គាត់។

- អញសូមព្រមានឯង! អញនឹងមិនអនុញ្ញាតឲ្យនិយាយពីភាពមិនធម្មតារបស់ឯងនៅក្រោមដំបូលផ្ទះនេះទេ!

ហេរីសម្លឹងមើលពីមុខពណ៌ផ្កាឈូករបស់លោកមាវើរណុនទៅអ្នកមីងរបស់វា ដែលស្លេកស្លាំង ហើយ កំពុងតែព្យាយាមលើកដាត់លីឲ្យក្រោកឈរឡើង។

- បាន- ហេរីនិយាយ - មិនអីទេ...

លោកមាវើរណុនក៏អង្គុយចុះវិញ ដោយ ដកដង្ហើមដូចជារមាសដែលហត់គឃុស ហើយសម្លឹងមើលហេរីយ៉ាងជាប់នឹងជ្រុងម្ខាងនៃភ្នែកដ៏តូច និងមុតស្រួចរបស់គាត់។

តាំងពីពេលដែលហេរីត្រលប់មកផ្ទះវិញនៅវិស្សមកាលរដូវក្តៅ លោក មាវើរណុនបានចាត់ទុកហេរីដូចជាគ្រាប់បែកមួយដែលអាចនឹងផ្ទុះគ្រប់ពេល ពី ព្រោះហេរីមិនមែនជាក្មេងធម្មតាម្នាក់នោះទេ។ តាមពិតទៅ វាមិនមែនធម្មតាដូចសំបកក្រៅរបស់វាឡើយ។

ហេរី ផោតធ័រ គឺជាវេទគូម្នាក់...ជានិស្សិតវេទគូមកពីសាលាហុកវ៉ាតឆ្នាំទីមួយ។ ហើយ ប្រសិនបើក្រុមគ្រួសារឌើស្លីមិនពេញចិត្តនឹងឲ្យវាមកវិញនៅថ្ងៃឈប់សម្រាក ក៏គ្មានអ្វីប៉ះពាល់ដល់អារម្មណ៍របស់វាដែរ។

វានឹកសាលាហុកវ៉ាតខ្លាំងណាស់ ដូចជាការចុកពោះមិនចេះបាត់អញ្ចឹង។ វា នឹកប្រាសាទ ដែល មានច្រកផ្លូវសម្ងាត់ ហើយនិងខ្មោច មេរៀន របស់វា (ទោះជាវាមិនចូលចិត្តគ្រូឱសថ ស្នេព ក៏ ដោយ) សំបុត្រផ្ញើតាមទីទុយ ការ ទទួលទានអាហារក្នុងពិធីជប់លៀងនៅក្នុងមហាសាល ដេកក្នុងគ្រែមានបង្គោលបួននៅក្នុងប៉មសយនដ្ឋាន ការ ទៅសួរសុខទុក្ខឆ្មាំប្រមាញ់ ហាគ្រ៊ីដ ក្នុងផ្ទះរបស់គាត់នៅលើដីជាប់នឹងព្រៃហាមឃាត់ ហើយ ជាពិសេស បំផុតនោះ គឺកីឡាឃ្វីដឌីច្ច ដែល ជាកីឡាដ៏ពេញនិយមបំផុតនៅក្នុងពិភពវេទមន្ត (បង្គោលខ្ពស់ៗប្រាំមួយ បាល់ហោះបួន ហើយនិងកីឡាករជប់បួននាក់នៅលើដងអំបោស)។

## ថ្ងៃខួបកំណើតដ៏អាក្រក់បំផុត

សៀវភៅវេទមន្ត ចង្កឹះ វេទមន្ត អាររ៉ូប ថ្លា ង និង ដងអំបោសនីមប៊ូស២០០០ចំនាត់ថ្នាក់កំពូលរបស់ហេរីទាំងអស់ត្រូវចាក់សោទុកក្នុងបន្ទប់ក្រោមជណ្តើរដោយលោកមាវើរណុនពេលដែលហេរីមកដល់ផ្ទះភ្លាម។ មាន អ្វី ដែលក្រុមគ្រួសារឌើស្លីត្រូវខ្វាយខ្វល់ប្រសិនបើហេរីបាត់បង់តំណែងរបស់វានៅក្នុងក្រុមឃ្វីដឌីច្ចដោយសារតែវាមិនបានហាត់សមពេញមួយរដូវក្តៅនោះ? មានអ្វីត្រូវខ្វល់ប្រសិនបើហេរីត្រលប់ទៅសាលាវិញដោយមិនបានធ្វើកិច្ចការសាលាបន្តិចសោះនោះ? ក្រុមគ្រួសារឌើស្លីគឺជាអ្វីដែលពួកវេទគូហៅថាពួកលោកិយ (គ្មានសូម្បីតែឈាមវេទមន្តមួយតំនក់នៅក្នុងសរសៃឈាមរបស់ពួកគេ) តាមដែលពួកគេដឹង ការមានវេទគូនៅក្នុងគ្រួសារគឺជាបញ្ហាអាម៉ាស់មុខជាខ្លាំង។ លោក មាវើរណុនថែមទាំងបានចាក់សោទីទុយរបស់ហេរី ឈ្មោះ ហ៊ីដវីក នៅ ក្នុងទ្រុងរបស់វាទៀតផង ដើម្បីកុំឲ្យវានាំសារទៅកាន់នរណាម្នាក់នៅក្នុងពិភពវេទមន្តបាន។

ហេរីមើលទៅមិនដូចជាសមាជិកនៅក្នុងគ្រួសារនេះទេ។ លោក មាវើរណុនមានមាឌធំ ហើយ ស្ទើរតែគ្មានក ដោយ មានពុកមាត់ពណ៌ខ្មៅដ៏ធំសំបើម ឯអ្នកមីងពីទូនៀមានមុខដូចសេះ ហើយ សុទ្ធតែឆ្អឹង រីឯ ដាត់លីវិញសក់ពណ៌ទង់ដែង ផ្កា ឈូក និង ធាត់ដូចជ្រូក។ ផ្ទុយស្រលះពីគ្នា ហេរី មានរាងតូច ហើយ ស្គម ដោ យមានភ្នែកពណ៌បៃតងដ៏មុតថ្លា និង សក់ខ្មៅស្រិលដែលតែងតែរញ៉េរញ៉ៃ។ វាពាក់វ៉ែនតារាងមូល ហើយនៅលើថ្ងាសរបស់វាមានស្នាមសម្លាករាងដូចផ្លេកបន្ទោរដ៏ស្តើងមួយ។

ស្លាកស្នាមនេះហើយដែលធ្វើឲ្យហេរីមិនធម្មតាដែលខុសប្លែកពីគេឯង សូម្បី តែវេទគូក្តី។ ស្នាម នេះជាសញ្ញាណតែមួយគត់នៃអតីតកាលដ៏អាថ៌កំបាំងរបស់ហេរី នៃ មូលហេតុ ដែលវាត្រូវបានគេទុកចោលនៅលើផ្លូវដើរទៅកាន់ទ្វារមុខផ្ទះរបស់គ្រួសារឌើស្លីកាលពីដប់មួយឆ្នាំមុន។

ទោះបីជាយ៉ាងណាក៏ដោយ នៅអាយុមួយឆ្នាំ ហេរីបានទទួលនូវសិល្ប៍បណ្តាសាពីវេទគូងងឹតដ៏ខ្លាំងអស្ចារ្យម្នាក់មិនចេះសាបរលាប គឺវ៉ុលដឹម៉រ ដែល ឈ្មោះរបស់គេ មេធ្មប់ និង វេទគូស្ទើរតែទាំងអស់នៅតែខ្លាចមិនហ៊ាននិយាយ។ ឪពុកម្តាយរបស់ហេរីស្លាប់ដោយសារការវាយប្រហាររបស់វ៉ុលដឹម៉រ ប៉ុន្តែ ហេរីបានគេចខ្លួនជាមួយនឹងស្នាមផ្លេកបន្ទោររបស់វា ហើយ ទោះបីជាយ៉ាងណាក៏ដោយ ... គ្មាននរណាម្នាក់ដឹងថាហេតុអ្វីនោះទេ ...បានជាថាមពលរបស់វ៉ុលដឹម៉រត្រូវបានបំផ្លាញខណៈពេលដែលគាត់បរាជ័យក្នុងការសម្លាប់ហេរី។

ដូច្នេះហេរីត្រូវបានរើសយកមកចិញ្ចឹមដោយបងស្រីរបស់ម្តាយវា ដែលបានចែកឋានទៅ ហើយ និងប្តីរបស់គាត់។ វា បានចំនាយពេលដប់ឆ្នាំរស់នៅជាមួយនឹងគ្រួសារឌើស្លី ដោយ មិនដឹងថា ហេតុអ្វីបានជាវាធ្វើឲ្យរឿងរ៉ាវចម្លែកៗកើតឡើងជាបន្តបន្ទាប់ដោយគ្មានចេតនា ថែមទាំងជឿរឿងរបស់គ្រួសារឌើស្លីដែលថា វាមានស្នាមនេះដោយសារការក្រឡាប់ឡានដែលបានសម្លាប់ឪពុកម្តាយរបស់វា។

ហើយបន្ទាប់មក យ៉ាង ជាក់លាក់កាលពីមួយឆ្នាំកន្លងទៅ សាលាហុកវ៉ាតបានសរសេរសំបុត្រមកហេរី ហើយ រឿងរ៉ាវទាំងមូលបានធ្លាយចេញមក។ ហេរីបានទៅរៀននៅសាលាវេទមន្ត ដែល វា និង ស្នាមសម្លាករបស់វាមានភាពល្បីល្បាញ...ប៉ុន្តែឥលូវឆ្នាំសិក្សាត្រូវបានបញ្ចប់ហើយ ហើយវាត្រូវត្រលប់មកគ្រួសារឌើស្លីវិញនៅរដូវក្តៅ ពោលគឺត្រលប់មកឲ្យគេចាត់ទុកជាសុនខដែលដើរតួក្នុងរឿងអាក្រក់។

គ្រួសារឌើស្លីថែមទាំងមិនចាំថាថ្ងៃនេះជាថ្ងៃបុណ្យខួបកំណើតទីដប់ពីររបស់ហេរីផងនោះទេ។ ជា ការពិតណាស់ ក្តីសង្ឃឹមរបស់វាមិនជាខ្ពស់ណាស់ណាទេ ពួកគេមិនដែលឲ្យវានូវអំណោយសមរម្យម្តងណាឡើយ គឺអោយត្រឹមតែនំមួយប៉ុណ្ណោះ ... រួចមកក៏ព្រងើយកន្តើយនឹងវាទាំងស្រុង...

នៅខណៈនោះ លោកមាជើរណុនបានជម្រះបំពង់ករបស់គាត់ដូចជាមានការសំខាន់ ហើយនិយាយថា៖

- ឥលូវ ដូចដែលយើងដឹងស្រាប់ហើយ ថ្ងៃនេះជាថ្ងៃសំខាន់ណាស់។

ហេរីងើយមើល ដោយពិបាកនឹងហ៊ានជឿ។

- នេះជាថ្ងៃដ៏ល្អបំផុត ដែលខ្ញុំធ្វើកិច្ចសន្យាដ៏ធំមួយពីការងាររបស់ខ្ញុំ- លោកមាជើរណុនស្រដី។

ហេរីត្រលប់ទៅរកនំប៉័ងអាំងរបស់វាវិញ។ ជា ការពិតណាស់ វា សញ្ជឹងគិតទាំងល្វីងជូរចត់ លោក មាជើរណុនកំពុងតែនិយាយពីពិធីជប់លៀងអាហារពេលល្ងាចដ៏គ្មានបានការនោះ។ គាត់គ្មាននិយាយអ្វីក្រៅពីរឿងហ្នឹងអស់ពីរសប្តាហ៍មកហើយ។ អ្នកសាងសង់ដែលធូរធារគួរសមម្នាក់ និងប្រពន្ធរបស់គាត់នឹងមកបរិភោគអាហារពេលល្ងាច ហើយលោកមាជើរណុនកំពុងតែសង្ឃឹមថានឹងទទួលបាននូវការបញ្ជាទិញដ៏ធំមួយពីគាត់ (ក្រុមហ៊ុនរបស់លោកមាជើរណុនផលិតម៉ាស៊ីនខួង)។

- ខ្ញុំគិតថាយើងគួរតែហាត់សមពាក្យសម្តីម្តងទៀត- លោកមាជើរណុននិយាយ។ - យើងទាំងអស់គ្នាគួរតែទៅកាន់តំនែងរៀងៗខ្លួននៅម៉ោងប្រាំបី។ ពីទូនៀ អូននឹងនៅ...?

- ក្នុងបន្ទប់ទទួលភ្ញៀវ- អ្នកមីងពីទូនៀស្រដីយ៉ាងរហ័ស - រង់ចាំស្វាគមន៍ពួកគេយ៉ាងគួរសមមកកាន់ផ្ទះរបស់យើង។

- ល្អៗ។ ហើយដាត់លីវិញ?

- ខ្ញុំនឹងរង់ចាំបើកទ្វារ។- ដាត់លីបញ្ចេញស្នាមញញឹមល្ងីល្ងើគួរអោយចង់សើច - តើខ្ញុំអាចយកអាវធំក្រៅរបស់អ្នកបានទេលោក និងអ្នកស្រីមេសាន់?

- ពួកគេនឹងស្រលាញ់វាជាមិនខានឡើយ!- អ្នកមីងពីទូនៀស្រែកយ៉ាងសប្បាយចិត្ត។

- ល្អណាស់ ដាត់លី- លោកមាជើរណុនពោល។ បន្ទាប់មកគាត់បែរមករកហេរី។ - ហើយចុះឯងវិញ?

- ខ្ញុំនឹងនៅក្នុងបន្ទប់ដេករបស់ខ្ញុំ មិនបន្លឺសំឡេងមិនម៉ាត់ ហើយធ្វើពុតជាខ្ញុំមិននៅទីនេះឡើយ- ហេរីនិយាយខ្សាវៗ។

- ប្រាកដជាអញ្ចឹងហើយ- លោកមាជើរណុននិយាយយ៉ាងកាច។ - ខ្ញុំនឹងនាំផ្លូវពួកគេចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ណែនាំអូន ពីទូនៀ ហើយចាក់ភេសជ្ជៈឲ្យគេផឹក។ នៅម៉ោងប្រាំបីដប់ប្រាំនាទី...

- អូននឹងប្រកាសអាហារពេលល្ងាច- អ្នកមីងពីទូនៀនិយាយ។

- ហើយដាត់លី កូននិយាយថា...

- តើខ្ញុំអាចនាំអ្នកស្រីទៅបន្ទប់ទទួលទានអាហារបានដែរឬទេ អ្នក ស្រីមេសាន់?- ដាត់លីស្រដី ដោយ ហុចដៃកន្ធាត់របស់វាទៅកាន់ស្ត្រីម្នាក់ដែលមើលមិនឃើញ។

- សុភាពបុរសតូចដ៏អស្ចារ្យរបស់ខ្ញុំ!- អ្នកមីងពីទូនៀឧទានឡើងស្ទើរមិនដកដង្ហើម។

- ហើយចុះឯងវិញ?- លោកមាជើរណុននិយាយទៅកាន់ហេរីយ៉ាងកាចសាហាវ។

- ខ្ញុំនឹងនៅក្នុងបន្ទប់ដេករបស់ខ្ញុំ មិនបន្លឺសំឡេងមួយម៉ាត់ ហើយធ្វើពុតជាខ្ញុំមិននៅទីនេះឡើយ- ហេរីនិយាយយ៉ាងធុញទ្រាន់។

- ច្បាស់ជាអញ្ចឹងហើយ។ ឥលូវ យើង គួរតែសំដៅរកការសរសើរល្អៗពីរបីរឿងនៅពេលអាហារពេលល្ងាចហើយ។ ពីទូនៀ មានគំនិតអីទេ?

- ផើរណុនប្រាប់ខ្ញុំថាលោកគឺជាអ្នកវាយកូនគោលដ៏អស្ចារ្យម្នាក់ លោក មេសាន់...ប្រាប់ខ្ញុំមកមើល ថាតើអ្នកទិញរ៉ូបរបស់អ្នកនៅឯណា អ្នកស្រីមេសាន់...

- ល្អណាស់...ដាត់លី?

- យ៉ាងម៉េចដែរប្រសិនជាខ្ញុំនិយាយថា៖ "យើងត្រូវសរសេរសំនេរអំពីវីរៈបុរសរបស់យើងនៅឯសាលា លោកមេសាន់ ហើយខ្ញុំបានសរសេរអំពីលោក។"

រឿងនេះមានអត្ថន័យច្រើនពេកហើយសម្រាប់ទាំងហេរី និងអ្នកមីងពីទូនៀ។ អ្នកមីងពីទូនៀស្រែកយំដោយរំភើបចិត្ត ហើយចាប់ឱបក្រសោបកូនប្រុសរបស់គាត់ ខណៈពេលដែលហេរីឱនចុះក្រោមតុ អញ្ចឹងពួកគេនឹងមិនឃើញវាសើចនោះទេ។

- ហើយចុះឯងវិញ អាច្រមក់?

ហេរីបង្ខំចិត្តធ្វើទឹកមុខរបស់វាឲ្យនៅធម្មតាខណៈពេលដែលវាងើបឡើង។

- ខ្ញុំនឹងនៅក្នុងបន្ទប់របស់ខ្ញុំ ដោយមិនបន្លឺសំឡេងមួយម៉ាត់ ហើយធ្វើពុតជាខ្ញុំមិននៅទីនេះឡើយ- វានិយាយ។

- ឯងនឹងធ្វើអញ្ចឹងប្រាកដណាស់- លោកមាផើរណុននិយាយទាំងបង្ខំចិត្ត។ - គ្រួសារមេសាន់មិនដឹងរឿងអ្វីពីឯងនោះទេ ហើយវានឹងនៅតែអញ្ចឹងតទៅទៀត។ នៅពេលដែលអាហារពេលល្ងាចត្រូវបានបញ្ចប់ អូននាំអ្នកស្រីមេសាន់ទៅបន្ទប់ទទួលភ្ញៀវវិញដើម្បីពិសាកាហ្វេ ពីទូនៀ ហើយ បងនឹងយកប្រធានបទទាក់ទងនឹងម៉ាស៊ីនខួងមកនិយាយ។ ប្រសិន បើមានសំណាង បងនឹងទទួលបានការចុះហត្ថលេខាលើកិច្ចសន្យា ហើយ បានសម្រេចមុនពត៌មានចេញផ្សាយនៅម៉ោងដប់។ យើងនឹងទៅដើរទិញអីវ៉ាន់សម្រាប់យកទៅផ្ទះវិស្សមកាល់សម្រាកនៅកោះ ម៉ាចរកា ថ្ងៃស្អែកពេលនេះ។

ហេរីគ្មានអារម្មណ៍រំភើបអ្វីអំពីរឿងនេះទេ។ វា មិនគិតថា គ្រួសារឌើស្លីនឹងចូលចិត្តវានៅកោះ ម៉ាចរកា ជាជាងនៅមហាវិថីប្រាយវេដ ដ្រាយនោះទេ។

- ល្អ...បងនឹងចុះទៅក្រុងរកមើលទិញអាវធំទទួលទានអាហារពេលល្ងាចសម្រាប់ដាត់លី ហើយនិងបង។ ហើយឯង- គាត់គ្រហឹមដាក់ហេរី - ឯងមិនឃើញអ្នកមីងឯងកំពុងតែសម្អាតទេវី? ឆាប់ចេញភ្លាម...

ហេរីចេញតាមទ្វារក្រោយ។ នេះជាថ្ងៃមង្គល និងជាថ្ងៃល្អ។ វាដើរកាត់វាលស្មៅ ទម្លាក់ខ្លួនចុះលើបង់សួនច្បារ ហើយច្រៀងតិចៗថា៖

- រីករាយថ្ងៃកំណើត...រីករាយថ្ងៃកំណើត...

គ្មានកាត គ្មាន អំនោយ ហើយ វានឹងចំនាយពេលមួយល្ងាចដោយធ្វើពុតថាគ្មានរូបវា។ វា សម្លឹងមើលយ៉ាងវេទនាទៅដើមឈើដែលដុះជាជួរ។ វាមិនដែលមានអារម្មណ៍ថាឯកោអ្វីម្ល៉េះទេ។ ច្រើន ជាងអ្វីៗនៅសាលាហុកវ៉ាត ថែម ទាំងច្រើនជាងការលេងកីឡាឃ្វីដឌីច្ឆទៅទៀត ហេរីនឹកមិត្តដ៏ជិតស្និទ្ធិបំផុតរបស់វា រ៉ុន វីស្លី និងហឺម៉ាយអូនី ហ្គ្រេនជឺរ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេហាក់ដូចជាមិននឹកវាទាល់តែសោះ។ គ្មាននរណាម្នាក់ក្នុងចំនោមពួកគេ សរសេរសំបុត្រមកវាទាល់តែសោះពេញមួយរដូវក្តៅហើយ ទោះបីជារ៉ុនបាននិយាយថាវានឹងស្នើសុំឲ្យហេរីមកស្នាក់នៅជាមួយក៏ដោយ។

អស់វេលាជាច្រើនរាប់មិនអស់ដែល ហេរី ធ្លាប់គិតប្រុងនឹងចាក់សោបើកទ្រុងរបស់ ហ៊ីដវីក ដោយវេទមន្ត រួចបញ្ជូនវាទៅ រ៉ុន និង ហឺម៉ាយអូនី ជាមួយនឹងសំបុត្រមួយច្បាប់ ប៉ុន្តែវាមិនដល់ថ្នាក់ប្រថុយនឹងគ្រោះថ្នាក់នេះទេ។ វេទគូមិនគ្រប់អាយុមិនអនុញ្ញាតឲ្យប្រើប្រាស់វេទមន្តនៅក្រៅសាលានោះទេ។ ហេរីមិនបានប្រាប់គ្រួសារឌើស្លីពីរឿងនេះទេ។ វាដឹងថា កុំតែពួកគេខ្លាចវាជប់ពួកគេឲ្យទៅ

ជាសត្វចង្រិតទាំងអស់ កុំ  អីពួកគេចាក់សោឃុំវាទុកក្នុងបន្ទប់ក្រោមជណ្ដើរដូច ចង្កឹះ  វេទមន្ត និង  អំបោសហោះរបស់វាបាត់ទៅហើយ។ នៅ ពីរសប្ដាហ៍ដំបូងពេលត្រលប់មកវិញ ហេរី ពេញចិត្តនឹងការនិយាយរអ៊ូរទាំនូវពាក្យសម្ដីមិនបានការតិចៗ ធ្វើឲ្យដាត់លីភ័យរត់ចេញពីបន្ទប់យ៉ាងលឿនសឹងនឹងហោះ។ ប៉ុន្ដែការបាត់ដំណឹងដ៏យូរពី រ៉ុន និង ហឺម៉ាយអូនី បានធ្វើឲ្យ ហេរី មានអារម្មណ៍ថាត្រូវបានដាច់ចេញពីពិភពវេទមន្ដ ដែលថាសូម្បីតែការចំអកឡកឡឺយដាក់ ដាត់លី ក៏លែងសូវសប្បាយទៀតដែរ ... ហើយឥលូវរ៉ុន និងហឺម៉ាយអូនីបានភ្លេចថ្ងៃខួបកំណើតរបស់វាទៀត។

ឥលូវ តើ មានអ្វីទៅ ដែលវាមិនហ៊ានលះបង់ដើម្បីដោះដូរនឹងសារមួយច្បាប់ពីសាលាហុកវ៉ាតនោះ? ពីមេធ្មប់ រឺក៏វេទគូណាម្នាក់នោះ? ប្រសិនបើបានឃើញសត្រូវស៊ូពូជរបស់វា គឺ ដ្រាកូ មេលហ្វ៉យ  ក៏វារាងសប្បាយចិត្តបន្តិចដែរ ដើម្បីបញ្ជាក់ថា រឿងរ៉ាវដែលកើតឡើងកន្លងមកនេះមិនមែនគ្រាន់តែជាសុបិននោះទេ...

មិនមែនថាពេញមួយឆ្នាំរបស់វានៅឯសាលាហុកវ៉ាតសុទ្ធតែសប្បាយទាំងអស់នោះទេ។ នៅ ពេលហៀបនឹងជិតចប់ឆមាសចុងក្រោយ  ហេរីបានប្រឈមមុខជាមួយនឹង  គ្មាននរណាក្រៅពី  វ៉ុលដឺម៉រ  ដោយខ្លួនវាផ្ទាល់នោះទេ។ វ៉ុលដឺម៉រ   ប្រហែលជាបានបំផ្លាញរាងកាយពីអតីតរបស់គាត់ដោយផ្ទាល់ដៃមែន ប៉ុន្តែ គាត់នៅតែធ្វើឲ្យគេភ័យខ្លាច នៅ តែមានល្បិចកល នៅ តែប្ដេជ្ញាចិត្តក្នុងការដណ្ដើមយកថាមពលឡើងវិញ។  ហេរីបានឆ្លងផុតពីអន្ទាក់របស់វ៉ុលដឺម៉រជាលើកទីពីរហើយ  ប៉ុន្ដែវាគេចខ្លួនទាំងប្រផិតប្រផើយតែប៉ុណ្ណោះ ហើយសូម្បីតែឥលូវ ហេរីនៅតែភ្ញាក់ឡើងនៅពេលយប់ ដោយទទឹកជោកក្នុងអាវរងាដ៏ត្រជាក់ ឆ្ងល់ថាតើឥលូវ វ៉ុលដឺម៉រនៅឯណា ដោយចងចាំនូវទឹកមុខដ៏ខឹងសម្បា ព្រមទាំងភ្នែកដ៏ព្រៃផ្សៃធំៗរបស់គាត់...

ភ្លាមនោះហេរីអង្គុយត្រង់ខ្លួនភ្លឹងនៅលើបង់សួនច្បារ។ វា កំពុងតែសម្លឹងមើលទៅដើមឈើ  ដែលដុះជាជួរដោយទឹកមុខភ័ន្តភាំង  ...  ហើយដើមឈើដែលដុះជាជួរនោះស្រាប់តែសម្លឹងមើលមកវាវិញ។ ភ្នែក ពណ៌បៃតងធំៗពីរបានលេចឡើងក្នុងចំនោមស្លឹកឈើទាំងនោះ។

ហេរីក្រោកឈរឡើងខណៈពេលដែលសំឡេងសើចចំអកអណ្ដែតកាត់វាលស្មៅ។

- ខ្ញុំដឹងថាថ្ងៃនេះជាថ្ងៃអ្វីហើយ- ដាត់លីច្រៀង ដោយដើរទ្រេតទ្រោតៗសំដៅមករកវា។

ភ្នែកដ៏ធំទាំងពីរនោះព្រិច ហើយក៏លោយបាត់ទៅ។

- អីគេ?- ហេរីនិយាយ ដោយមិនគ្រវាសភ្នែកចេញពីកន្លែងនោះឡើយ។

- ខ្ញុំដឹងថាថ្ងៃនេះជាថ្ងៃអ្វីហើយ- ដាត់លីនិយាយម្ដងទៀត ដោយដើរឡើងសំដៅមករកវា។

- ល្អណាស់- ហេរីបាននិយាយ។ - អញ្ចឹងចុងបញ្ចប់ឯងបានរៀនថ្ងៃក្នុងសប្ដាហ៍ចាំអស់ហើយ។

- ថ្ងៃនេះជាថ្ងៃខួបកំណើតរបស់ឯង-  ដាត់លីនិយាយមើលងាយ។ - ម៉េចក៏ឯងមិនទទួលបានកាតអីសោះអញ្ចឹង? តើឯងគ្មានមិត្តនៅកន្លែងចម្លែកនោះទេរឺ?

- យល់ល្អកុំឲ្យម៉ាក់របស់ឯងដឹងថាឯងនិយាយពីសាលារបស់ខ្ញុំអី- ហេរីនិយាយយ៉ាងសោះកក្រោះ។

ដាត់លីលើកខោរបស់វាឡើង ដែលកំពុងតែរអិលចុះក្រោមគូទកន្ទាត់របស់វា។

- ហេតុអ្វីបានជាឯងសម្លឹងមើលដើមឈើដែលដុះជាជួរនោះ?- វានិយាយទាំងសង្ស័យ។

- ខ្ញុំកំពុងតែព្យាយាមសម្រេចចិត្តថាតើគួរប្រើពាក្យវេទមន្តណាដើម្បីបញ្ឆេះវា- ហេរីនិយាយ។

ដាត់លីដើរថយក្រោយភ្លាមមួយរំពេច ដោយមានសភាពស្លន់ស្លោរនៅលើមុខកន្ទាត់របស់វា។

- ឯងមិន ... មិនអាច ... ប៉ាបានប្រាប់ឯងថាមិនឲ្យប្រើប្រាស់វេទមន្តនោះទេ...គាត់និយាយថាគាត់នឹងគ្រវែងឯងចេញពីផ្ទះ...ហើយឯងគ្មានកន្លែងដែលត្រូវទៅទៀតទេ...ឯងគ្មានមិត្តភក្តិមកយកឯងនោះទេ...

- *ជីកឆ័រី ផក់ឃើរី!-* ហេរីនិយាយយ៉ាងសាហាវ។ - ហូខស់ ផូខស់...ស្គីកគ្លី វីកគ្លី...

- ម៉ាកកកកក់!- ដាត់លីស្រែក ព្រមទាំងជំពប់ជើងខ្លួនឯងខណៈពេលដែលវាបែរត្រលប់ក្រោយទៅផ្ទះវិញ។ -ម៉ាកកក់! វាកំពុងតែធ្វើអ្វីដែលម៉ាក់ដឹងស្រាប់ហើយ!

ហេរីត្រូវរងគ្រោះយ៉ាងធ្ងន់ដោយសារតែការសប្បាយមួយភ្លែតរបស់វា។ ដោយដាត់លី រី ក៏ដើមឈើដែលដុះជាជួរគ្មានខូចខាតអ្វី អ្នក មីងពីទូនៀដឹងថាវាមិនមែនប្រើវេទមន្តមែនទែននោះទេ ប៉ុន្តែ វាត្រូវតែឱនចុះខណៈពេលដែលគាត់តម្រង់គប់ឆ្នាំងខ្ទះប្រឡាក់សាប៊ូមករកក្បាលវា។ បន្ទាប់ មកគាត់ឲ្យការងារវាធ្វើសន្ធឹក ដោយឲ្យសន្យាថាវានឹងមិនហូបអ្វីឡើយលុះត្រាតែវាធ្វើការងារចប់សព្វគ្រប់។

ខណៈពេលដែលដាត់លីកំពុងតែដើរទ្រេតទ្រោតតាមមើលបណ្តើរ ញ៉ាំការ៉េមបណ្តើរ ហេរីនៅសម្អាតបង្អួច លាងឡាន ច្រូតស្មៅ លំអ សួនផ្កា កាត់និង ស្រោចផ្កាកុលាប ហើយ លាបពណ៌ថ្នាំបង់សួនច្បារឡើងវិញ។ ព្រះអាទិត្យ កំពុងតែឆាបឆេះនៅពីលើក្បាល ធ្វើឲ្យកខាងក្រោយរបស់វាក្តៅឡើងចង់ខ្លោច។ ហេរីដឹងថា វាមិនគួរលើកយកសម្តីឌឺដងរបស់ដាត់លីមកគិតនោះទេ ប៉ុន្តែដាត់លីបាននិយាយនូវអ្វីដែលហេរីកំពុងតែគិត...ប្រហែលជាវាគ្មានមិត្តនៅសាលាហុកវ៉ាតនោះទេ...

- មើលទៅមើល៍ ថាតើហេរី ផោតផ័រដ៏ល្បីល្បាញឥឡូវធ្លាក់ខ្លួនយ៉ាងណា- វាគិតយ៉ាងខឹងសម្បា ខណៈពេលដែលវាបាចដីទៅលើសួនផ្កា ខ្នងរបស់វាកំពុងតែឈឺចាប់ ញើសហូរស្រក់ចុះមុខរបស់វាតក់ៗ។

- ចូលមកក្នុងនេះមក! ហើយដើរលើក្រដាសកាសែតទៅ!

ហេរី ធ្វើដំណើរយ៉ាងត្រេកអរទៅក្នុងម្លប់នៃផ្ទះបាយដែលភ្លឺចិញ្ចែងចិញ្ចាច។ នៅ ខាងលើទូទឹកកកមានបង្អែមពូឌិញសំរាប់យប់នេះ៖ គំនរការ៉េមដ៏ធំមួយ និងតំណាប់ស្វាយដាក់ស្ករ។ សាច់ជ្រូកខ្វៃមួយដុំកំពុងតែចំអិននៅក្នុងឡ។

- ស៊ីឲ្យលឿនឡើងទៅ! គ្រួសារមេសាន់នឹងមកទីនេះក្នុងពេលឆាប់ៗនេះហើយ!- អ្នកមីងពីទូនៀនិយាយម៉ាត់ៗ ដោយចង្អុលទៅនំប៉័ងពីរដុំ ហើយនិងប្រូម៉ាស់មួយដុំនៅលើតុផ្ទះបាយ។ គាត់ស្លៀករ៉ូបពណ៌ផ្កាឈូករួចទៅហើយ។

ហេរីលាងដៃរបស់វា ហើយ លេបអាហារពេលយប់របស់វាយ៉ាងគ្រមង់គ្រមោច។ នៅ ពេលដែលវាហូបរួច អ្នក មីងពីទូនៀយកចានរបស់វាចេញ។ - ឡើងទៅលើទៅ! លឿនឡើង!

ខណៈពេលដែលវាដើរកាត់ទ្វារទៅកាន់បន្ទប់ទទួលភ្ញៀវ ហេរី ក្រលេកឃើញលោកមាវើរណុន និង ដាត់លីពាក់ក្រវ៉ាត់ករាងកោង និង អាវធំសម្រាប់អាហារពេលល្ងាច។ វា ទើបតែទៅដល់កាំជណ្តើរចុងក្រោយស្រាប់តែកណ្តឹងទ្វារផ្ទះរោទិ៍ឡើង ហើយ មុខដ៏ខឹងសម្បារបស់លោកមាវើរណុនលេចឡើងនៅឯមាត់ជណ្តើរ។

- ចាំណាំ អាច្រមក់ ... ហ៊ានតែបន្លឺសំឡេងអ្វីមួយនោះ...

ហេរីដើរទៅបន្ទប់របស់វាដោយលបៗ ចូលទៅក្នុង បិទទ្វារ ហើយបែរទៅផ្តួលខ្លួនលើគ្រែរបស់វា។

បញ្ហាគឺថា មាននរណាម្នាក់កំពុងតែអង្គុយនៅលើគ្រែបាត់ទៅហើយ។

**វគ្គ II**



# ការដាស់តឿនរបស់ដុបប៊ី

ហេរី ទប់ខ្លួនឯងមិនឲ្យស្រែកសឹងតែមិនទាន់។ សត្វ នៅលើគ្រែនោះមានស្លឹកត្រចៀកដូចសត្វប្រជៀវដ៏ធំៗមួយគូ និង ភ្នែកពណ៌បៃតងកំប៉ោងពីរគ្រាប់ប៉ុនគ្រាប់បាល់តិន្នីស។ ហេរី ដឹងភ្លាមថា នេះហើយជាអ្វីដែលបានមើលវានៅដើមឈើដែលដុះជាជួរក្នុងសួនច្បារខាងក្រៅកាលពីព្រឹកនោះ។

ខណៈពេលដែលពួកគេសម្លឹងមើលគ្នាទៅវិញទៅមក ហេរីឮសំឡេងរបស់ដាត់លីពីផ្លូវរបៀង។

- តើខ្ញុំអាចកាន់អាវក្រៅជំនួសអ្នកទាំងពីរបានទេ លោកនិងអ្នកស្រីមេសាន់?

សត្វនេះរអិលខ្លួនចុះពីលើគ្រែ ហើយ ឱនយ៉ាងទាបដែលធ្វើឲ្យចុងច្រមុះស្ដើងដ៏វែងរបស់វាប៉ះទៅនឹងកម្រាលព្រំ។ ហេរីកត់សម្គាល់ឃើញថា វាកំពុងតែស្លៀកពាក់អ្វីម្យ៉ាងដូចជាស្រោមខ្នើយ ដែលកាត់ដៃ និងប្រហោងជើងចេញ។

- អឺ...សួស្ដី- ហេរីស្រដីយ៉ាងភ័យខ្លាច។

- ហេរី ផោតធ័រ!- សត្វនោះនិយាយ ដោយសំឡេងស្រួយស្រែស ដែលហេរីដឹងច្បាស់ណាស់ថានឹងឮទៅដល់ជាន់ក្រោម។ - ដុបប៊ីពិតជាចង់ជួបលោកជាយូរណាស់មកហើយ ទាន...ពិតជាមានកិត្តិយសមែន...

- អរ...អរគុណឯងហើយ- ហេរីបានស្រដី ដោយរំកិលខ្លួនតាមជញ្ជាំង ហើយបន្ទន់ខ្លួនទៅលើកៅអីរបស់វា ជាប់នឹងហ៊ីដវីកដែលដេកលក់នៅក្នុងទ្រុង។ វាចង់សួរថា៖ "តើឯងជាអ្វី?" ប៉ុន្តែគិតថាស្ដាប់ទៅដូចជាមិនគួរសម អញ្ចឹងជំនួសវិញ វាក៏និយាយថា៖ - តើឯងជានរណា?

- ដុបប៊ី ទាន។ គ្រាន់តែជាដុបប៊ីប៉ុណ្ណោះ។ ដុបប៊ីជាម្រេញគង្វាល- សត្វនោះស្រដី។

- អូ...មែនរឺ?- ហេរីនិយាយ។ - អឺ...មិនមែនមិនចង់គួរសម រឺក៏អ្វីនោះទេ ប៉ុន្តែ ...នេះមិនមែនជាពេលល្អសម្រាប់ខ្ញុំក្នុងការមានម្រេញគង្វាលនៅក្នុងបន្ទប់គេងរបស់ខ្ញុំនោះទេ។

សំណើចក្លែងក្លាយដ៏ខ្លាំងរបស់អ្នកមីងពីទូនៀបានបន្លឺឡើងពេញបន្ទប់។ ម្រេញគង្វាលធ្វើក្បាលងឹងើ។

- មិនមែនថាខ្ញុំមិនរីករាយនឹងជួបឯងនោះទេ- ហេរីស្រដីយ៉ាងរហ័ស - ប៉ុន្តែ អឺ ...តើមានហេតុផលសំខាន់អ្វីដែលតម្រូវឲ្យឯងនៅទីនេះដែររឺទេ?

## ការដាស់តឿនរបស់ដុបប៊ី

- អូ! បាទ ទាន- ដុបប៊ីនិយាយយ៉ាងម៉ត់ចត់។ - ដុបប៊ីមកដើម្បីប្រាប់លោក ទាន...វាពិបាកណាស់ ទាន...ដុបប៊ីមិនដឹងជាត្រូវចាប់ផ្ដើមពីត្រឹមណាទៅនោះទេ...

- អង្គុយចុះទៅ- ហេរីស្រដីយ៉ាងគួរសម ដោយចង្អុលទៅលើគ្រែ។

ដោយភាពតក់ស្លុតរបស់វា ម្រេញគង្វាលនោះក៏ស្រែកយំ...គឺជាសម្រែកយំដ៏គួរឲ្យថ្លង់មួយ។

- អង...អង្គុយចុះ!- វាទ្រហោយំ។ - មិនដែល...មិនដែលធ្លាប់...

ហេរីបានគិតថាវាឮសំឡេងនៅជាន់ក្រោមមានការរអាក់រអួល។

- ខ្ញុំសុំទោស- វាខ្សឹប - ខ្ញុំគ្មានចេតនានឹងមើលងាយឯងរឺក៏អ្វីនោះទេ។

- មើលងាយដុបប៊ី!- ម្រេញគង្វាលនោះឈ្លក់។ - ដុបប៊ីមិនដែលត្រូវបានស្នើសុំឲ្យអង្គុយចុះដោយវេទគូណាម្នាក់នោះទេ...ដូចជាមានឋានៈស្មើគ្នា...

ដោយព្យាយាមនិយាយថា «ស្ហូ!» និងធ្វើចិត្តឲ្យនឹងធឹងក្នុងពេលតែមួយ ហេរីបានបង្ហាញកន្លែងឲ្យដុបប៊ីអង្គុយលើគ្រែ រួចវាក៏អង្គុយចុះហើយត្អើក មើលទៅហាក់ដូចជាតុក្កតាដ៏ធំមួយយ៉ាងគគ្រិច។ ចុង ក្រោយវាក៏គ្រប់គ្រងខ្លួនឯងបាន ហើយ អង្គុយដោយសម្លឹងមើលហេរី តាមខ្សែភ្នែកធំៗពោរពេញដោយទឹកភ្នែក ដើម្បីសំដែងក្ដីគោរព។

- ឯងមិនដែលធ្លាប់ជួបវេទគូចេះគួរសមច្រើននោះទេ- ហេរីបានស្រដី ដោយព្យាយាមលើកទឹកចិត្តវាឡើង។

ដុបប៊ីគ្រវីក្បាលរបស់វា។ បន្ទាប់មក ដោយគ្មានប្រាប់អ្វីជាមុន វាក៏លោតឡើង ហើយចាប់ផ្ដើមបោកក្បាលរបស់វាយ៉ាងខឹងសំបាទៅនឹងបង្អួច ដោយស្រែកថា៖ - ដុបប៊ីអាក្រក់! ដុបប៊ីអាក្រក់!

- កុំ ... តើឯងកំពុងធ្វើអ្វីហ្នឹង?- ហេរីលោតឡើង ហើយ ទាញដុបប៊ីត្រលប់ទៅលើគ្រែវិញ។ ហ៊ី ដវីកបានភ្ញាក់ឡើងជាមួយនឹងសូរដឹតៗច្រេចៗដ៏ខ្លាំងយ៉ាងមិនធម្មតាមួយ ហើយបានទទះស្លាបរបស់វាយ៉ាងសាហាវប៉ះនឹងរបារទ្រុងរបស់វា។

- ដុបប៊ីត្រូវតែដាក់ទណ្ឌកម្មខ្លួនឯង ទាន- ម្រេញគង្វាលនោះស្រដី ភ្នែករបស់វាប្រែជាស្រទ្បេវ។ - ដុបប៊ីស្ទើរតែនិយាយអាក្រក់ពីគ្រួសាររបស់ខ្លួនទៅហើយ ទាន...

- គ្រួសាររបស់ឯងរឺ?

- គ្រួសារវេទគូដែលដុបប៊ីបម្រើ ទាន...ដុបប៊ីគឺជាម្រេញគង្វាល...មកបម្រើផ្ទះមួយ និងគ្រួសារមួយជារៀងរហូត...

- តើពួកគេដឹងថាឯងនៅទីនេះដែររឺទេ?- ហេរីសួរដោយចង់ដឹង។

ដុបប៊ីញ័រខ្លួន។

- អូ! ទេ ទាន អត់ទេ...ដុបប៊ីនឹងត្រូវតែដាក់ទណ្ឌកម្មខ្លួនឯងយ៉ាងធ្ងន់ធ្ងរបំផុតក្នុងការមកជួបលោក ទាន។ ដុបប៊ីនឹងត្រូវតែគាបត្រចៀកក្នុងទ្វារឡសំរាប់រឿងនេះ។ ប្រសិនបើពួកគេដឹង ទាន...

- ប៉ុន្តែតើពួកគេនឹងមិនកត់សម្គាល់ទេរឺប្រសិនបើឯងគាបត្រចៀករបស់ឯងទៅក្នុងទ្វារឡនោះ?

- ដុបប៊ីក៏ឆ្ងល់ពីរឿងនេះដែរ ទាន។ ដុបប៊ី តែងតែត្រូវដាក់ទណ្ឌកម្មខ្លួនឯងសំរាប់រឿងអ្វីមួយ ទាន។ ពួក គេឲ្យដុបប៊ីបន្តធ្វើរឿងនោះ ទាន។ ជួនកាលពួកគេរំលឹកខ្ញុំឲ្យធ្វើទណ្ឌកម្មបន្ថែមទៀត...

- ប៉ុន្តែហេតុអ្វីបានជាឯងមិនចាកចេញ? រឺក៏គេចខ្លួន?

- ម្រេញគង្វាលគួរតែមានសេរីភាព ទាន។ ហើយគ្រួសារនោះនឹងមិនដែលឲ្យដុបប៊ីមានសេរីភាពនោះទេ...ដុបប៊ីនឹងត្រូវតែបម្រើគ្រួសារនោះរហូតទាល់តែស្លាប់ ទាន...

ហេរីសម្លឹងមើលមិនដាក់ភ្នែក។

- ខ្ញុំគិតថាមានតែខ្ញុំទេដែលសំណាងអាក្រក់ត្រូវស្នាក់នៅទីនេះបួនសប្ដាហ៍ទៀត- វាបាននិយាយ។ - ប្រៀបធៀបនឹងបញ្ហារបស់ឯង គ្រួសារឌើស្លីក៏ប្រហែលជាមិនអាក្រក់ដល់ថ្នាក់ហ្នឹងដែរ។ តើគ្មាននរណាអាចជួយឯងបានទេរឺក៏អី? តើខ្ញុំមិនអាចទេរឺ?

ស្ទើរតែមួយរំពេច ហេរីបានប្រាថ្នាថាវាមិនបាននិយាយទៅចុះ។ ដុបប៊ីបានប្រែក្លាយទៅជាទ្រហោយំដោយការដឹងគុណ។

- សូមអង្វរ- ហេរីខ្សឹបដោយរំជើបរំជួលយ៉ាងខ្លាំង - សូមស្ងាត់បន្តិចទៅ។ ប្រសិន បើគ្រួសារឌើស្លីឮសំឡេងអ្វីមួយនោះ ប្រសិនបើគេដឹងថាឯងនៅទីនេះនោះ...

- ហេរីសួរថាតើគាត់អាចជួយអ្វីដល់ដុបប៊ីបាន...ដុបប៊ីធ្លាប់បានឮពីភាពមហស្ចារ្យរបស់លោក ទាន ប៉ុន្តែ ចំពោះសប្បុរសធម៌របស់លោកវិញ ដុបប៊ីមិនដែលដឹងទេ...

ហេរី ដែលកំពុងមានអារម្មណ៍ថាក្ដៅក្រហាយ និយាយថា៖

- អ្វីក៏ដោយដែលឯងបានឮពីភាពមហស្ចារ្យរបស់ខ្ញុំគឺគ្រាន់តែជាសំរាមមួយដុំប៉ុណ្ណោះ។ ខ្ញុំ ថែមទាំងមិនមែនជាសិស្សពូកែនៅសាលាហុកវ៉ាតនោះទេ នោះគឺហឺម៉ាយអូនីទេ នាង...

ប៉ុន្តែវាបញ្ឈប់យ៉ាងរហ័ស ពីព្រោះការគិតពីហឺម៉ាយអូនីធ្វើឲ្យវាឈឺចាប់ណាស់។

- ហេរី ផោតធ័រចេះដាក់ខ្លួន- ដុបប៊ីស្រដីយ៉ាងគួរសម ភ្នែក ដូចភូគោលរបស់វាបញ្ចេញពន្លឺព្រឹមៗ។ - ហេរី ផោតធ័រ មិននិយាយពីជ័យជំនះរបស់លោកទៅលើ អ្នកដែលមិនត្រូវហៅឈ្មោះនោះទេ។

- វ៉ុលដឺម៉ររឺ?- ហេរីស្រដី។

ដុបប៊ីយកដៃខ្ទប់ត្រចៀកប្រជៀវទាំងពីររបស់វា ហើយស្រែកថ្ងូរថា៖

- អា! កុំនិយាយឈ្មោះនេះ ទាន! កុំនិយាយឈ្មោះនេះឲ្យសោះ!

- សុំទោស- ហេរីបាននិយាយយ៉ាងរហ័ស។ - ខ្ញុំដឹងថាមនុស្សជាច្រើនមិនចូលចិត្តវានោះទេ...មិត្តភក្តិរបស់ខ្ញុំ រ៉ុន...

វាឈប់ម្ដងទៀត។ ការគិតអំពីរ៉ុនក៏ឈឺចាប់ណាស់ដែរ។

ដុបប៊ីឱនទៅរកហេរី ភ្នែករបស់វាធំៗដូចជាក្បាលអំពូល។

- ដុបប៊ីឮគេប្រាប់- វានិយាយយ៉ាងស្អក - ថាហេរី ផោតធ័រ បានជួបវេទគួងងឹតជាលើកទីពីរ ទើប តែប៉ុន្មានសប្ដាហ៍កន្លងទៅ...ថាហេរី ផោតធ័របានគេចខ្លួនម្ដងទៀត។

ហេរីងក់ក្បាល ហើយភ្នែករបស់ដុបប៊ីបញ្ចេញពន្លឺដោយទឹកភ្នែកភ្លាម។

- អា! ទាន- វានិយាយទាំងដង្ហក់ ដោយ ជូតសើៗលើមុខរបស់វានឹងជ្រុងស្រោមខ្នើយដ៏កខ្វក់ ដែលវាកំពុងតែស្លៀក។ - ហេរី ផោតធ័រមានភាពក្លាហាន ហើយអង់អាច! លោកបានប្រឈមមុខនឹងគ្រោះថ្នាក់ជាច្រើនរួចមកហើយ! ប៉ុន្តែដុបប៊ីមកនេះដើម្បីការពារហេរី ផោតធ័រ ដើម្បីដាស់តឿនលោក សូម្បី តែត្រូវគាបត្រចៀកទាំងពីរនៅក្នុងទ្វារឡនៅពេលក្រោយក៏ដោយ...*ហេរី ផោតធ័រមិនត្រូវត្រលប់ទៅសាលាហុកវ៉ាតវិញនោះទេ។*

## ការដាស់តឿនរបស់ដុបប៊ី

ភាពស្ងៀមស្ងាត់បានកើតឡើង ឮតែសំឡេងរណ្តំតិចៗនៃកាំបិត និង សមពីជាន់ក្រោម ហើយ និងសូរទន្ទឹកពីចម្ងាយនៃសំឡេងរបស់លោកមាវើណុន។

- ស៊ី...ស៊ីគេ?- ហេរីនិយាយជាប់ៗ។ - ប៉ុន្តែខ្ញុំត្រូវតែត្រលប់ទៅវិញ...ឆមាសចាប់ផ្តើមនៅថ្ងៃមួយកញ្ញានេះហើយ។ រឿងទាំងអស់ហ្នឹងហើយដែលញ៉ាំងខ្ញុំឲ្យទៅ។ ឯង មិនដឹងថា នៅទីនេះវាយ៉ាងម៉េចនោះទេ។ ខ្ញុំ មិនមែនជាមនុស្សនៅទីនេះទេ។ ខ្ញុំជាមនុស្សនៅក្នុងពិភពរបស់ឯង ឯសាលាហុកវ៉ាត។

- ទេៗ- ដុបប៊ីបន្លឺសូរង៉ឹតៗ ដោយគ្រវីក្បាលរបស់វាយ៉ាងខ្លាំងរហូតដល់ធ្វើឲ្យត្រចៀករបស់វាទទះផ្លាប់ៗ។ - ហេរី ផោតធ័រត្រូវតែនៅកន្លែងដែលមានសុវត្ថិភាព។ លោក អស្ចារ្យពេកហើយ ល្អ ពេកហើយ មិនអាចចាញ់បានទេ។ ប្រសិន បើហេរី ផោតធ័រត្រលប់ទៅសាលាហុកវ៉ាតវិញ លោកនឹងស្ថិតនៅក្នុងគ្រោះថ្នាក់ ដែលអាចបណ្តាលឲ្យស្លាប់បាន។

- ហេតុអ្វី?- ហេរីសួរដោយងឿងឆ្ងល់។

- មានគម្រោងការសម្ងាត់មួយ ហេរី ផោតធ័រ។ គំរោងការមួយដែលធ្វើឲ្យរឿងអាក្រក់ជាច្រើនកើតឡើងនៅឯសាលាវេទមន្តហុកវ៉ាតនាឆ្នាំនេះ- ដុបប៊ីខ្សឹប ភ្លាម នោះវាស្រាប់តែញ័រខ្លួនចំប្រប់។ - ដុបប៊ីបានដឹងរឿងនេះអស់ជាច្រើនខែមកហើយ ទាន។ ហេរី ផោតធ័រ មិនត្រូវយកខ្លួនទៅប្រថុយក្នុងគ្រោះថ្នាក់នោះទេ។ លោកសំខាន់ណាស់ ទាន!

- រឿងអាក្រក់អ្វីទៅ?- ហេរីនិយាយភ្លាមមួយរំពេច។ - តើនរណាជាអ្នករៀបចំគម្រោងទាំងនេះ?

ដុបប៊ីបន្លឺនូវសំឡេងឈ្លក់ដ៏គួរឲ្យអស់សំណើចមួយ ហើយបន្ទាប់មកក៏បោកក្បាលរបស់វាយ៉ាងឆ្គួតលីលាទៅនឹងជញ្ជាំង។

- មិនអីទេ!- ហេរីបានស្រែក ដោយចាប់ដៃរបស់ម្រេញគង្វាលនោះជាប់ដើម្បីបញ្ឈប់វា។ - ឯងមិនអាចនិយាយបានទេ ខ្ញុំយល់។ ប៉ុន្តែហេតុអ្វីបានជាឯងមកដាស់តឿនខ្ញុំ?- គំនិតមិនរីករាយភ្លាមៗមួយបានធ្វើឲ្យវាគាំង។ - ឈប់សិន រឿងនេះមានពាក់ព័ន្ធនឹងវ៉ុល...សុំទោស...នឹង អ្នកដែលឯងស្គាល់ មែន ទេ? ឯងគ្រាន់តែគ្រវី រី ក៏ងក់ក្បាលទៅបានហើយ- វានិយាយបន្ថែមយ៉ាងរហ័សខណៈពេលដែលក្បាលរបស់ដុបប៊ីផ្អៀងយ៉ាងគួរឲ្យព្រួយបារម្ភទៅជិតនឹងជញ្ជាំងម្តងទៀត។

ដុបប៊ីបានគ្រវីក្បាលរបស់វាយ៉ាងយឺតៗ។

- មិនមែនទេ...មិនមែន អ្នកដែលមិនត្រូវហៅឈ្មោះ នោះទេ ទាន។

ប៉ុន្តែភ្នែករបស់ដុបប៊ីបើកធំៗ ហាក់ ដូចជាកំពុងតែព្យាយាមប្រាប់ហេរីនូវសញ្ញាណអ្វីមួយ។ ទោះ បីជាយ៉ាងណាក៏ដោយហេរីនៅកណ្តាលមហាសាគរទាំងស្រុង។

- គាត់មានបងប្អូនប្រុសដែរឺទេ?

ដុបប៊ីគ្រវីក្បាលរបស់វា ភ្នែករបស់វាបើកធំៗជាមុន។

- អញ្ចឹង ខ្ញុំ គិតមិនឃើញថាមាននរណាទៀតដែលមានឱកាសក្នុងការបង្កើតរឿងអាក្រក់ៗ ឲ្យកើតឡើងនៅឯសាលាហុកវ៉ាតនោះទេ- ហេរីបានស្រដី។ - ខ្ញុំចង់និយាយថា ណាមួយ មានដាំប៊័លដ័រហើយ ឯងដឹងថាតើដាំប៊័លដ័រជានរណាហើយមែនទេ?

ដុបប៊ីបានឱនក្បាលរបស់វា។

- អាល់ប៊ូស ដាំប៊័លដ័រគឺជានាយកសាលាដ៏អស្ចារ្យបំផុតដែលសាលាហុកវ៉ាតមិនធ្លាប់មាន។ ដុបប៊ី ដឹងរឿងនេះ ទាន។ ដុបប៊ីធ្លាប់បានឮពីថាមពលរបស់លោក ដាំប៊័លដ័រ ប្រកួតនឹងថាមពលរបស់ អ្នកដែលមិនត្រូវហៅឈ្មោះ រហូតដល់ចំណុចកំពូល

នៃកម្លាំងរបស់គាត់។ ប៉ុន្តែ ទាន- សំឡេងរបស់ដុបប៊ីបានធ្លាក់ទៅសំឡេងខ្សឹបជាបន្ទាន់មួយ - មានថាមពលដែលលោកដាំប័លដ័រគ្មាន...ថាមពលដែលវេទគូត្រឹមត្រូវ...

ហើយមុនពេលដែលហេរីអាចបញ្ឈប់វាបាន ដុប ប៊ីបានលោតចុះពីលើគ្រែ ចាប់ តុដាក់អំពូលរបស់ហេរី ហើយ ចាប់ផ្ដើមបោកក្បាលរបស់វា ព្រមទាំងបន្លឺនូវសម្រែកថ្លង់ស្ទើរបែកក្រដាសត្រចៀក។

ភាពស្ងៀមស្ងាត់ភ្លាមៗមួយបានធ្លាក់ទៅជាន់ក្រោម។ ពីរ វិនាទីក្រោយមក ហេរី បេះ ដូងលោតយ៉ាងខ្លាំង បាន ឮលោកមាវើរណុនចូលមកក្នុងផ្លូវរបៀង ដោយស្រែកថា៖

- ដាត់លីច្បាស់ជាភ្លេចបិទទូរទស្សន៍ទៀតហើយ អាកំហូចនេះ!

- ឲ្យលឿនឡើង! ទៅក្នុងទូដាក់ខោអាវទៅ!- ហេរីនិយាយ ដោយញាត់ដុបប៊ីចូលទៅក្នុង បិទ ទ្វារ ហើយគ្រវែងខ្លួនរបស់វាទៅលើគ្រែខណៈពេលដែលទ្វាររបើកឡើង។

- តើឯងកំពុងធ្វើរឿងខ្មោចយក៍ស្អីហ្នឹង? - លោកមាវើរណុនស្រដីទាំងសង្កៀតធ្មេញ មុខរបស់គាត់ស្ទើរតែប៉ះនឹងមុខហេរី។ - ឯងទើបតែបំផ្លាញរឿងកំប្លែងអំពីអ្នកលេងកូនគោលជនជាតិជប៉ុនអំបាញ់មិញនេះទេ...អោយតែឮសំឡេងតែម្ដងទៀត បន់អោយហើយទៅថាឯងមិនបានកើតមកទេ យីអាក្មេងកំហូចនេះ!

គាត់ដើរយ៉ាងធ្ងន់ៗនឹងជើងកន្ទាត់របស់គាត់ចេញពីបន្ទប់នោះ។

ដោយញ័រខ្លួន ហេរីឲ្យដុបប៊ីចេញពីទូដាក់ខោអាវ។

- ឃើញទេថាវាដូចស្អីនៅទីនេះ?- វាបាននិយាយ។ - ឃើញទេថាតើហេតុអ្វីបានជាខ្ញុំត្រូវត្រលប់ទៅសាលាហុកវ៉ាតវិញ? វាជាកន្លែងតែមួយគត់ដែលខ្ញុំមាន...ខ្ញុំគិតថាខ្ញុំមានមិត្តភក្តិ។

- មិត្តភក្តិដែលថែមទាំងមិនសរសេរសំបុត្រមកហេរី ផោតធ័រផងនោះរឺ?- ដុបប៊ីបានស្រដីបែបលេងសើច។

- ខ្ញុំពឹងទុកថាពួកគេគ្រាន់តែ...ឈប់សិន- ហេរីបាននិយាយ ដោយ ចងចិញ្ចើម។ - តើឯងម៉េចនឹងដឹងថាមិត្តភក្តិរបស់ខ្ញុំមិនបានសរសេរសំបុត្រមកខ្ញុំនោះ?

ដុបប៊ីដើរអូសជើងរបស់វា។

- ហេរី ផោតធ័រមិនត្រូវខឹងជាមួយនឹងដុបប៊ីនោះទេ...ដុបប៊ីធ្វើនេះដើម្បីឲ្យល្អទេតើ...

*- តើឯងបានបញ្ឈប់សំបុត្ររបស់ខ្ញុំមែនទេ?*

- ដុបប៊ីមានសំបុត្រនៅទីនេះទាំងអស់ ទាន- ម្រេញគង្វាលនោះបានស្រដី។ ដោយ ឈានជើងយ៉ាងប៉ិនប្រសប់ចេញពីការឈោងដល់របស់ហេរី វា បានទាញនូវបាច់ស្រោមសំបុត្រដ៏ក្រាស់មួយដុំពីខាងក្នុងស្រោមខ្នើយដែលវាកំពុងតែពាក់។ ហេរី អាចមើលដឹងពីសំនេរយ៉ាងមានរបៀបរៀបរយរបស់ហឺម៉ាយអូនី ការ សរសេរច្រងាច់ច្រងូវដែលគ្មានសណ្ដាប់ធ្នាប់របស់រ៉ុន ហើយ ថែមទាំងការសរសេរខ្វៀកដែលមើលទៅហាក់ដូចជាផ្ញើមកពីឆ្មាំប្រមាញ់នៅសាលាហុកវ៉ាតគឺ ហាហ្គ្រីដ។

ដុបប៊ីធ្វើភ្នែកព្រឹមៗយ៉ាងអន្ទះសាដាក់ហេរី។

- ហេរី ផោតធ័រ មិនត្រូវខឹងនោះទេ...ដុបប៊ីបានសង្ឃឹមថា...ប្រសិនជាហេរី ផោតធ័រ គិតថាមិត្តភក្តិរបស់គាត់បានបំភ្លេចគាត់ចោលទៅហើយ...ហេរី ផោតធ័រប្រហែលជានឹងមិនវិលត្រលប់ទៅសាលាហុកវ៉ាតវិញនោះទេ ទាន...

ហេរីមិនស្ដាប់នោះទេ។ វាបានយកដៃកញ្ឆក់សំបុត្រទាំងនោះ ប៉ុន្តែដុបប៊ីលោតចេញទាន់មិនឲ្យឈោងដល់។

- ហេរី ផោតធ័រ នឹងទទួលបានសំបុត្រទាំងនេះ ទាន ប្រសិន បើលោកនិយាយថាលោកនឹងមិនវិលត្រលប់ទៅសាលាហុកវ៉ាតវិញនោះទេ។ អ៊ា ! ទាន នេះ គឺជាគ្រោះថ្នាក់មួយដែលលោកមិនត្រូវប្រឈមមុខនោះទេ! និយាយថាលោកនឹងមិនទៅវិញទេទាន!

- ទេ- ហេរីបានស្រដីយ៉ាងខឹងសម្បា។ - ឲ្យសំបុត្រមិត្តភក្តិរបស់ខ្ញុំមក!

- អញ្ចឹងហេរី ផោតធ័រគ្មានទុកជម្រើសឲ្យដុបប៊ីនោះទេ- ម្រេញគង្វាលនោះបាននិយាយយ៉ាងកើតទុក្ខ។

មុនពេលដែលហេរីអាចកម្រើកខ្លួនបាន ដុបប៊ី បានបោះពួយទៅទ្វារបន្ទប់ដេក ទាញ ទ្វារឲ្យបើកឡើង ហើយ រត់រ៉ុយចុះទៅជាន់ក្រោម។

មាត់ស្ងួត ពោះ កូរគ្រូកៗ ហេរីបានលោតតាមវា ដោយ ព្យាយាមមិនបន្លឺសំឡេងឡើយ។ វា បានលោតរំលងកាំជណ្តើរប្រាំមួយចុងក្រោយ ដូចជាឆ្មា មកលើកម្រាលព្រំផ្លូវរបៀង ភ្នែកសម្លឹងរកមើលដុបប៊ីជុំវិញ។ ពី បន្ទប់ទទួលទានអាហារ វាបានឮលោកមាវើរណុននិយាយថា៖

-...ប្រាប់ពីទូនៀនូវរឿងកំប្លែងពីជាងបំពង់ទឹកជនជាតិអាមេរិចទាំងនោះទៅ លោក មេសាន់ នាង ចង់ស្តាប់ជិតស្លាប់ទៅហើយ...

ហេរីបានរត់ឡើងមកផ្លូវរបៀងទៅក្នុងផ្ទះបាយ ហើយមានអារម្មណ៍ថា ប្រហោងពោះធ្លុង ។

ស្នាដៃឯកនៃការធ្វើនំពូឌិញរបស់អ្នកមីងពីទូនៀ គំនរ ការ៉េម និង តំណាប់ស្វាយដាក់ស្ករ កំពុង តែអណ្តែតឡើងនៅជិតនឹងពិតាន។ ដុបប៊ីកំពុងតែឱននៅជ្រុងទូដាក់ចានឆ្នាំង។

- ទេ- ហេរីស្រដីគ្រលរៗ។ -សូមអង្វរ...ពួកគេនឹងសម្លាប់ខ្ញុំ...

- ហេរី ផោតធ័រត្រូវតែនិយាយថាលោកនឹងមិនត្រលប់ទៅសាលាវិញនោះទេ...

- ដុបប៊ី...សូមអង្វរ...

- និយាយទៅ ទាន...

- ខ្ញុំនិយាយមិនរួចទេ!

ដុបប៊ីបង្ហាញនូវទឹកមុខដ៏សោកសង្វេគមួយ។

- អញ្ចឹងដុបប៊ីត្រូវតែធ្វើរឿងនេះហើយ ទាន ដើម្បីជាប្រយោជន៍ផ្ទាល់របស់ហេរី ផោតធ័រ។

នំពូឌិញបានធ្លាក់ទៅលើកម្រាលឮសូរគ្រាំងស្ទើរតែធ្វើអោយគាំងបេះដូង។ ការ៉េម ខ្ទាយពេញបង្អួច និង ជញ្ជាំងខណៈពេលដែលចានបែកជាបំនែកតូចៗ។ ដុបប៊ីបានរលាយបាត់ខ្លួន ដោយបន្លឺសូរផសដូចស្នូររំពាត់។

មានសំឡេងស្រែកពីបន្ទប់ទទួលទានអាហារ ហើយ លោកមាវើរណុនស្ទុះទៅក្នុងផ្ទះបាយក៏ឃើញហេរី ដែល រឹងឆ្អឹងដោយការស្រឡាំងកាំង ខ្លួនគ្របដណ្តប់ពីក្បាលដល់ចុងជើងនូវនំពូឌិញរបស់អ្នកមីងពីទូនៀ។

មុនដំបូង មើលទៅ ហាក់ដូចជាលោកមាវើរណុននឹងលៃលកពន្យល់រឿងរ៉ាវទាំងមូល ("គ្រាន់តែជាក្មួយប្រុសរបស់ពួកយើងប៉ុណ្ណោះ...ពិតជាគួរឲ្យរំខានណាស់...ជំនួបគ្នាជាមួយនឹងមនុស្សចម្លែកធ្វើឲ្យវាមិនសប្បាយចិត្តឡើយ អញ្ចឹង ពួកយើងក៏ទុកវានៅជាន់លើទៅ...") គាត់បាននាំគ្រួសារមេសាន់ដែលស្រឡាំងកាំងត្រលប់ទៅបន្ទប់ទទួលទានអាហារវិញ ដោយ សន្យានឹងហេរីថាគាត់

នឹងពន្លាត់ស្បែករបស់វាម្តងមួយសង់ទីម៉ែតៗនៅពេលដែលគ្រួសារមេសាន់ចេញទៅ ហើយ យកគ្រឿងដុសលាងក្តារឲ្យវា។ អ្នក មីងពីទូនៀបានដួសការ៉េមមួយចំនួនពីក្នុងទូទឹកកក ហើយហេរី ដែលនៅតែញ័រខ្លួន ចាប់ផ្តើមដុសលាងសម្អាតផ្ទះបាយ។

លោកមាផើរណុនប្រហែលជានៅតែអាចមានលទ្ធភាពធ្វើកិច្ចព្រមព្រៀងរបស់គាត់បាននៅឡើយទេ ... ប្រសិនបើគ្មានសត្វទីទុយទេ។

អ្នកមីងពីទូនៀទើបតែកាន់ជុំវិញដៃនូវប្រអប់ស្ករគ្រាប់បន្ទាប់ពីអាហារពេលល្ងាចរួច ស្រាប់តែទីទុយជង្រុកដ៏ធំមួយបានហើរឆាបកាត់តាមបង្អួចបន្ទប់ទទួលទានអាហារ ទម្លាក់សំបុត្រមួយច្បាប់លើក្បាលរបស់អ្នកស្រីមេសាន់ ហើយ ហើរចេញទៅវិញ។ អ្នកស្រីមេសាន់បានស្រែកដូចជាខ្មោចប៉ៃនស៊ី ហើយរត់ចេញពីផ្ទះ ស្រែករឡេរឡប្រហែលនឹងមនុស្សឆ្កួត។ លោក មេសាន់នៅឲ្យបានយូរល្មមគ្រប់គ្រាន់នឹងប្រាប់គ្រួសារឌើស្លីថាប្រពន្ធរបស់គាត់ពិតជាខ្លាចបក្សីគ្រប់រូបរាង និងទំហំទាំងអស់ ហើយ សួរថាតើនេះជាគំនិតកំប្លែងរបស់ពួកគេមែនរឺក៏អត់។

ហេរីឈរនៅក្នុងផ្ទះបាយ ដោយ ក្តាប់គ្រឿងដុសលាងដើម្បីជួយទប់ទល់ខណៈពេលដែលលោកមាផើរណុនសំដៅមករកវាពន្លឺចាំងភ្លែតៗដ៏គម្រក់មួយនៅក្នុងកែវភ្នែកតូចៗរបស់គាត់។

- អានវាទៅ!- គាត់បានបន្លឺសូរស៊ើៗយ៉ាងកំណាច ដោយគ្រវីសំបុត្រដែលសត្វទីទុយបានចែកឲ្យ។ - ទៅ...អានវាទៅ!

ហេរីបានយកវា។ ក្នុងនោះគ្មានសរសេរពាក្យជូនពរថ្ងៃកំណើតទេ។

*សួស្តីលោកផោតធ័រ*

*យើងបានទទួលនូវពត៌មានថា វេទមន្ត មិនប្រាកដប្រជាមួយ ត្រូវបានប្រើប្រាស់នៅកន្លែងអ្នកស្រុករបស់លោកនាល្ងាចនេះប្រហែលជាម៉ោងប្រាំបួនដប់ពីរនាទី។*

*ដូចដែលលោកដឹងស្រាប់ហើយ វេទគូ មិនទាន់គ្រប់អាយុ មិនត្រូវអនុញ្ញាតឲ្យប្រើប្រាស់វេទមន្តនៅក្រៅសាលានោះទេ ហើយការប្រើប្រាស់វេទមន្តផ្សេងទៀតនៅទីកន្លែងរបស់លោក ប្រហែលជានឹងឈានទៅដល់ ការបណ្តេញចេញពីសាលាដូចដែលបានចែងរួចស្រាប់ហើយ (ក្រឹត្យស្តីអំពីបំរាមត្រឹមត្រូវចំពោះវេទគូមិនគ្រប់អាយុ ឆ្នាំ១៨៧៥ កថាខណ្ឌ គ)។*

*យើងក៏ស្នើឲ្យលោកចងចាំថា សកម្មភាពវេទមន្តណាមួយ ដែលអាចនឹងត្រូវកត់សម្គាល់ពីសមាជិកនៃសហគមន៍គ្មានវេទមន្ត (ពួកលោកិយ) គឺជាការប្រមាថដ៏ធ្ងន់ធ្ងរមួយ យោងទៅតាមមាត្រាទី១៣ ស្តីអំពីការសម្ងាត់របស់សម្ព័ន្ធអន្តរជាតិវេទមន្ត។*

*សូមរីករាយនឹងថ្ងៃឈប់សម្រាករបស់លោកចុះ!*

*ដោយក្តីស្មោះត្រង់*

*ម៉ាហ្វាល់ដា ហុបឃើក*

*ការិយាល័យផ្នែកការប្រើប្រាស់មិនត្រឹមត្រូវនៃវេទមន្ត*

*ក្រសួងវេទមន្ត*

ហេរីងើយមើលពីសំបុត្រហើយលេបទឹកមាត់ក្អឹក។

- ឯងមិនបានប្រាប់យើងថា ឯងមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់វេទមន្តនៅក្រៅសាលានោះទេ- លោកមាវើរណុនបាននិយាយ ហើយ ពន្លឺដ៏ខឹងសម្បាមួយកំពុងឆេះនៅក្នុងកែវភ្នែករបស់គាត់។ - ភ្លេចបញ្ជាក់ពីរឿងនេះហ្អេ ... ឡប់សតិ យើង ហ៊ាននិយាយថា...

គាត់ដើរទៅរកហេរីដូចជាឆ្កែកាចសាហាវដ៏ធំសំបើម ធ្មេញរបស់គាត់ទាំងអស់បញ្ចេញឡើង។ - ល្អ ខ្ញុំមានដំណឹងប្រាប់ឯងអាប្រមក់ ... ខ្ញុំនឹងចាក់សោឃុំឯងទុក ... ឯងនឹងមិនត្រលប់ទៅសាលានោះវិញទេ ... មិនដែលទេ ... ហើយប្រសិនបើឯងព្យាយាមប្រើវេទមន្តដើម្បីរំដោះខ្លួនឯងចេញនោះ...ពួកគេនឹងបណ្ដេញក្បាលឯងចេញជាមិនខាន!

គាត់បាននាំហេរីទៅជាន់លើវិញ ហើយសើចដូចជាមនុស្សឆ្កួត។

លោកមាវើរណុនពិតជាអាក្រក់ដូចសម្ដីរបស់គាត់មែន។ នៅ ព្រឹកបន្ទាប់ គាត់ បានជួលបុរសម្នាក់ឲ្យវាយក្ដារបិទបង្អួចបន្ទប់ហេរីទាំងអស់ គាត់ដាក់ប្រហោងសំរាប់ឆ្មាមួយដោយខ្លួនគាត់ផ្ទាល់នៅក្នុងទ្វារបន្ទប់ដេក អញ្ចឹងចំនួនអាហារដ៏តិចតួចនោះអាចរុញចូលទៅខាងក្នុងបីដងក្នុងមួយថ្ងៃបាន។ ពួក គេអនុញ្ញាតឲ្យហេរីចេញទៅប្រើប្រាស់បង្គន់នៅពេលព្រឹក និង ពេលល្ងាច។ ក្រៅពីនេះ វាត្រូវចាក់សោជាប់នៅក្នុងបន្ទប់របស់វាទាំងយប់ទាំងថ្ងៃ។

★

បីថ្ងៃក្រោយមក គ្រួសារឌើស្លីមិនបានបង្ហាញសញ្ញាណនៃការបន្ធូរចិត្តនោះទេ ហើយ ហេរីកមិនឃើញវិធីចេញពីស្ថានភាពរបស់វាឥលូវនេះឡើយ។ វា ផ្ដេកខ្លួននៅលើគ្រែសម្លឹងមើលព្រះអាទិត្យលិចពីក្រោយរបារបង្អួច ហើយ មានការមន្ទិលសង្ស័យយ៉ាងវេទនាថាតើនឹងមានរឿងអ្វីកើតឡើងចំពោះវា។

តើមានប្រយោជន៍អ្វីដែរទេ ដែលប្រើវេទមន្តដើម្បីរំដោះខ្លួនវាចេញពីបន្ទប់របស់វាប្រសិនបើ សាលាហុកវ៉ាត នឹងបណ្ដេញវាចេញក្នុងការធ្វើដូចនេះនោះ? ជីវិតនៅមហាវិថីប្រាយវេដ្រាយបានឈានដល់កំរិតទាបបំផុតមិនចេះស្រាកស្រាន្តឡើយ។ ឥលូវគ្រួសារឌើស្លីបានដឹងថាពួកគេនឹងមិនអាចត្រូវជប់អោយក្លាយទៅជាសត្វប្រជៀវបាននោះទេ ហេរី ក៏បានបាត់បង់នូវអាវុធតែមួយគត់របស់វាដែរ។ ដុបប៊ីប្រហែលជាបានជួយសង្គ្រោះវាឲ្យរួចផុតពីគ្រោះកំណាចនៅឯសាលាហុកវ៉ាតមែន ប៉ុន្តែបើតាមវិធីនេះ វាប្រហែលជានឹងអាចឃ្លានស្លាប់។

ប្រហោងសំរាប់សត្វឆ្មាបន្លឺសូរក្រិកៗ ហើយ ដៃរបស់អ្នកមីងពីទូនៀបានលេចឡើង ដោយ រុញចានសម្លដ៏តូចមួយចានទៅក្នុងបន្ទប់។ ហេរី ដែល នៅខាងក្នុងខ្លួនកំពុងតែឈឺចាប់ដោយគម្លាននោះ បានលោតចុះពីលើគ្រែ ហើយ កញ្ឆក់យកចាននោះមក។ សម្លនោះត្រជាក់ដូចដុំថ្ម ប៉ុន្តែ វាគ្រាន់តែផឹកមួយក្អឹកអស់ពាក់កណ្ដាលបាត់ទៅហើយ។ បន្ទាប់ មកវាដើរកាត់បន្ទប់ទៅរកទ្រុងរបស់ហ៊ីដវីក ហើយ ចាក់បន្លែដែលទទឹកជោកនៅឯបាតចានទៅក្នុងថាសអាហារទទេរបស់វា។ វា បានធ្វើស្លាបរបស់វាអង្កាញ់ៗ ហើយ បង្ហាញទឹកមុខដូចជាស្អប់ខ្ពើមយ៉ាងខ្លាំង។

- វាគ្មានប្រយោជន៍ទេដែលបែរចំពុះរបស់ឯងចេញពីអាហារនេះនោះ យើង មានតែប៉ុណ្ណឹងទេ- ហេរីបានស្រដីទាំងមុខក្រញ៉ូវ។

វាបានទុកចានទទេទៅលើកម្រាលជិតប្រហោងឆ្មាវិញ ហើយ ផ្ដេកខ្លួនទៅលើគ្រែ ទោះបី ជាយ៉ាងណាក៏ដោយក៏នៅតែឃ្លានជាងមុនពេលញ៉ាំសម្លទៅទៀត។

## ការដាស់តឿនរបស់ដុបប៊ី

ឧបមាថារស់នៅរស់បានបួនសប្តាហ៍ទៀត តើនឹងមានរឿងអ្វីកើតឡើងប្រសិនបើវាមិនបានត្រលប់ទៅសាលាហុកវ៉ាតវិញនោះ? តើគេនឹងបញ្ជូននរណាម្នាក់ឲ្យមកមើលថាតើហេតុអ្វីបានជាវាមិនត្រលប់ទៅវិញដែរឬទេ? តើពួកគេនឹងមានសមត្ថភាពក្នុងការបង្ខំឲ្យគ្រួសារឌើស្លីអនុញ្ញាតឲ្យវាទៅដែរឬទេ?

បន្ទប់កាន់តែងងឹតឡើងៗ។ ដោយ អស់កម្លាំង ពោះ កំពុងតែកូរ សតិ វិលវល់តែនឹងសំនួរដែលមិនអាចឆ្លើយតបបានដដែលៗ ហេរីក៏លង់លក់នូវដំនេកដ៏មិនសុខស្រួល។

វាបានយល់សប្តិថាវានៅលើឆាកក្នុងសួនសត្វមួយ ដោយមានកាតមួយថា «វេទគូមិនទាន់គ្រប់អាយុ» ភ្ជាប់ទៅនឹងទ្រុងរបស់វា។ មនុស្ស ម្នាក្រលេកមើលតាមរបារខណៈពេលដែលវាផ្តេកខ្លួន ឃ្លាន ហើយ ខ្សោយកម្លាំង នៅ លើពំនូកចំបើង។ វា បាន ឃើញមុខរបស់ដុបប៊ីនៅក្នុងហ្វូងមនុស្ស ហើយក៏ស្រែកហៅអោយជួយ ប៉ុន្តែដុបប៊ីបានស្រែកមកវិញថា៖ - ហេរី ផោត ធ័រមានសុវត្ថិភាពហើយនៅទីនោះ ទាន!- ហើយក៏រលាយបាត់ខ្លួនទៅ។ បន្ទាប់ មកគ្រួសារឌើស្លីបានលេចឡើង ហើយ ដាត់លីបានអង្រួនរបារទ្រុង ដោយសើចដាក់វា។

- ឈប់ទៅ- ហេរីនិយាយខ្សាវៗ ខណៈ ពេលដែលសំឡេងអង្រួនបន្លឺសូររន្ទាន់ៗនៅក្នុងក្បាលដ៏ឈឺរបស់វា។ - កុំរំខានខ្ញុំ...ឈប់ទៅ...ខ្ញុំកំពុងតែព្យាយាមដេក...

វាបានបើកភ្នែករបស់វា។ ពន្លឺ ព្រះចន្ទកំពុងតែចែងចាំងកាត់តាមរបារនៅលើបង្អួច។ ហើយ នរណាម្នាក់កំពុងតែសម្លឹងមើលវាតាមរបារនោះ៖ មនុស្សម្នាក់ដែលមានមុខសុទ្ធតែអាចម៍រុយ សក់ពណ៌ក្រហម និងមានច្រមុះវែង។

រ៉ុន វីស្លីនៅខាងក្រៅបង្អួចរបស់ហេរី។

## វគ្គ III



## នៅប៊ឺរ៉ូ

- រ៉ុន!- ហេរីនិយាយទាំងដង្ហក់ ដោយលបៗទៅបង្អួច ហើយរុញបង្អួចឡើង អញ្ចឹងពួកគេអាចនិយាយគ្នាតាមរបារបាន។ - រ៉ុន... តើឯង...ហើយចុះនេះ...?

មាត់របស់ហេរីចំហផ្លូងចំពោះទិដ្ឋភាពស្លែងៗនៅចំពោះមុខវា។ រ៉ុន កំពុងតែផ្អែកចេញពីបង្អួចខាងក្រោយនៃឡានពណ៌ខៀវលាយបៃតងដ៏កញ្ចាស់មួយគ្រឿង ដែល ត្រូវបានចតនៅលើវេហាស៍។ អ្នក ដែលសើចស្វេញដាក់ហេរីគឺហ្វ្រេដ និង ចច ដែល ត្រូវជាបងប្រុសភ្លោះរបស់រ៉ុន។

- មិនអីទេរឺ ហេរី?

- តើមានរឿងអ្វីកើតឡើង?- រ៉ុនបាននិយាយ។ - ហេតុអ្វីបានជាឯងមិនឆ្លើយតបនឹងសំបុត្ររបស់ខ្ញុំ? ខ្ញុំបានស្នើសុំឲ្យឯងមកនៅផ្ទះខ្ញុំអស់ដប់ពីរដងទៅហើយ ហើយ បន្ទាប់មកលោកប៉ាខ្ញុំក៏មកផ្ទះ ហើយ និយាយថាឯងទទួលបាននូវការព្រមានជាផ្លូវការមួយដោយសារការប្រើប្រាស់វេទមន្តនៅមុខពួកលោកិយ...

- នោះមិនមែនខ្ញុំទេ...ហើយគាត់ដឹងយ៉ាងម៉េចទៅ?

- គាត់ធ្វើការឲ្យក្រសួង- រ៉ុនបានស្រដី។ - ឯងដឹងហើយថាគេមិនឲ្យយើងប្រើវេទមន្តនៅក្រៅសាលានោះទេ...

- ឯងដូចរាងមានគ្រាន់បើដែរតើ- ហេរីបានស្រដី ដោយសម្លឹងមើលឡានដែលកំពុងអណ្តែត។

- អូ! នេះគេមិនរាប់ថាមាននោះទេ- រ៉ុនបាននិយាយ។ - ពួកយើងគ្រាន់តែខ្ចីវាមកទេ វា ជារបស់ប៉ាខ្ញុំ យើងមិនបានដាក់វេទមន្តលើវានោះទេ។ ប៉ុន្តែការប្រើវេទមន្តនៅពីមុខពួកលោកិយទាំងនោះដែលឯងរស់នៅជាមួយ...

- ខ្ញុំបានប្រាប់ឯងហើយ ខ្ញុំ មិនបានធ្វើទេ...រឿងហ្នឹងវាវែងឆ្ងាយណាស់។ មើល ចុះ តើ ឯងអាចពន្យល់ដល់ពួកគេនៅឯសាលាហុកវ៉ាតថាគ្រួសារឌើស្លីបានចាក់សោឃុំខ្ញុំទុក ហើយ មិនអនុញ្ញាតឲ្យខ្ញុំត្រលប់ទៅវិញ ហើយ ច្បាស់ណាស់ខ្ញុំមិនអាចប្រើវេទមន្តដើម្បីរំដោះខ្លួនចេញបានទេ ពីព្រោះថាក្រសួងនឹងគិតថានោះគឺជាវេទមន្តទីពីរដែលខ្ញុំបានប្រើក្នុងរយៈពេលបីថ្ងៃនេះ អញ្ចឹង...

- កុំនិយាយពាសវាលពាសកាលពេក- រ៉ុនពោលកាត់ - យើងមកយកឯងទៅនៅផ្ទះជាមួយពួកយើងហើយ។

- ប៉ុន្តែឯងក៏មិនអាចប្រើវេទមន្តរំដោះខ្ញុំចេញបានដែរ...

- យើងមិនចាំបាច់នោះទេ- រ៉ុនបានស្រដី ដោយញោចក្បាលរបស់វាទៅកៅអីខាងមុខ ហើយសើចស្ញេញ។ - ឯងភ្លេចថាខ្ញុំនាំអ្នកណាមកហើយរឺ។

- ចងអានោះជុំវិញរបារទៅ- ហ្វ្រេដបាននិយាយ ដោយគ្រវែងចុងខ្សែពួរទៅឲ្យហេរី។

- ប្រសិនបើគ្រួសារឌើស្លីភ្ញាក់ឡើងនោះ ខ្ញុំ ច្បាស់ជាស្លាប់ហើយ- ហេរីបានស្រដី ខណៈ ពេលដែលវាចងខ្សែពួរយ៉ាងតឹងជុំវិញរបារមួយ ហើយហ្វ្រេដក៏បង្កើនល្បឿនឡាន។

- កុំបារម្ភអី- ហ្វ្រេដបាននិយាយ - ហើយឈរថយក្រោយបន្តិចទៅ។

ហេរីបានរំកិលខ្លួនទៅក្រោយក្នុងទីងងឹត ឈរជិតហ៊ីដវីក។ ហ៊ីដវីកហាក់ដូចជាដឹងថារឿងនេះវាសំខាន់យ៉ាងណា ហើយនៅស្ងៀមមិនកំរើក។ ឡាននោះបានបង្កើនល្បឿនកាន់តែខ្លាំងឡើងៗ ហើយភ្លាមនោះ ជាមួយនឹងសំឡេងគ្រូបៗ របារត្រូវបានទាញចេញយ៉ាងស្អាតពីបង្អួចខណៈពេលដែល ហ្វ្រេដ បើកឡើងត្រង់ទៅក្នុងអាកាស...ហេរី បានរត់ត្រលប់មកបង្អួចវិញដើម្បីមើលរបារនៅរយើងរយោងពីរបីម៉ែតពីលើដី។ រ៉ុន បានលើករបារនោះមកទុកក្នុងឡាន។ ហេរី ផ្ទៀងត្រចៀកស្តាប់យ៉ាងព្រួយបារម្ភ ប៉ុន្តែ គ្មានសំឡេងពីបន្ទប់ដេករបស់គ្រួសារឌើស្លីនោះទេ។

នៅពេលដែលរបារស្ថិតនៅកន្លែងអង្គុយខាងក្រោយយ៉ាងមានសុវត្ថិភាពជាមួយនឹងរ៉ុនហើយ ហ្វ្រេដ បានថយឡានឲ្យបានជិតនឹងបង្អួចរបស់ហេរីតាមដែលអាចធ្វើបាន។

- ចូលមកក្នុងមក- រ៉ុនបានស្រដី។

- ប៉ុន្តែវត្ថុប្រើប្រាស់នៅសាលាហុកវ៉ាតរបស់ខ្ញុំ...ចង្កឹះវេទមន្តរបស់ខ្ញុំ...អំបោសរបស់ខ្ញុំ...

- តើទុកនៅឯណា?

- ជាប់សោនៅក្នុងបន្ទប់ក្រោមជណ្តើរឯនោះ ហើយខ្ញុំមិនអាចចេញពីបន្ទប់នេះបានទេ...

- គ្មានបញ្ហាទេ- ចចបាននិយាយពីកៅអីអង្គុយអ្នកដំណើរខាងមុខ។ - សុំផ្លូវមួយ ហេរី។

ហ្វ្រេដ និងចចបានឡើងតាមបង្អួចទៅក្នុងបន្ទប់របស់ហេរីយ៉ាងប្រុងប្រយ័ត្ន។ រឿងប៉ុណ្ណឹងៗទុកចិត្តពួកគេចុះ ហេរីបានគិតខណៈពេលដែលចចយកតង្កៀបសក់ធម្មតាមួយពីក្នុងហោប៉ៅរបស់វា ហើយចាប់ផ្តើមកាន់មេសោ។

- វេទគូជាច្រើនគិតថា គឺជាការខ្ជះខ្ជាយពេលវេលា ក្នុងការស្វែងយល់ពីល្បិចពួកលោកិយរបៀបៗនេះ- ហ្វ្រេដបានស្រដី - ប៉ុន្តែយើងមានអារម្មណ៍ថាជំនាញរបស់ពួកគេមានតម្លៃនឹងគួរតែស្វែងយល់ ទោះបីជាយឺតបន្តិចមែន។

មានសំឡេងគ្រិកមួយបន្លឺឡើង ហើយទ្វារក៏របើកឡើង។

- អញ្ចឹង...យើងនឹងទៅយកវ៉ាលិសរបស់ឯង...ឯងយកអ្វីៗដែលឯងត្រូវការពីបន្ទប់របស់ឯង ហើយប្រគល់វាទៅអោយរ៉ុនចុះ- ចចបានខ្សឹប។

- ប្រយ័ត្នជើងកាំជណ្តើរផង វា ឮសូរក្រេតក្រតៗ- ហេរីបានខ្សឹបដាក់វិញ ខណៈ ពេលដែលកូនភ្លោះទាំងពីរបាត់ខ្លួនចុះតាមជណ្តើរដែលងងឹតសូន្យសុង។

ហេរីរត់ឆ្លេឆ្លាពេញបន្ទប់ ប្រមូល របស់វាដាក់ម៉ូ ហើយ យកចេញក្រៅបង្អួចទៅឲ្យរ៉ុន។ បន្ទាប់ មកវាបានទៅជួយហ្វ្រេដ និងចចលើកវ៉ាលិសរបស់វាឡើងលើជណ្តើរ។ ហេរីបានឮសូរសំឡេងក្អករបស់លោកមាវើណុន។

ចុងបញ្ចប់ ទាំងហត់គឃូស ពួកគេបានទៅដល់ក្បាលជណ្ដើរ បន្ទាប់មកក៏យូរវ៉ាលិសនោះកាត់បន្ទប់ហើរីទៅបង្អួចដែលបើកចំហ។ ហ្វ្រេដបានឡើងត្រលប់ទៅក្នុងឡានវិញដើម្បីជួយទាញរ៉ុន ចំនែកឯហេរី និងចចជួយរុញពីម្ខាងបន្ទប់ដេក។ វ៉ាលិសនោះរអិលតាមបង្អួចបន្តិចម្ដងៗ។ លោកមាវើរណុនបានក្អកម្ដងទៀត។

- បន្តិចទៀត- ហ្វ្រេដនិយាយទាំងដង្ហក់ ដែលកំពុងតែទាញពីខាងក្នុងឡាន - រុញមួយទំហឹងទៀតផុតហើយ...

ហេរី និងចចបានគ្រវែងស្មារបស់ពួកគេទល់នឹងវ៉ាលិស ហើយវ៉ាលិសនោះក៏រអិលចេញពីខាងក្រៅបង្អួចទៅក្នុងកៅអីខាងក្រោយឡាន។

- អញ្ចឹងទៅ- ចចបានខ្សឹប។

ប៉ុន្តែខណៈពេលដែលហេរីឡើងលើទ្វារបង្អួច មានសូរងឺតៗច្រេចៗដ៏ខ្លាំងរហ័សមួយមកពីខាងក្រោយវា ពេលនោះសំឡេងដូចផ្គរលាន់របស់លោកមាវើរណុនផ្ទុះមកពីខាងក្រោយ។

- អាទីទុយគំរក់នោះ!

- ខ្ញុំភ្លេចយកហ៊ីដវីកហើយ!

ហេរីបានរត់លឿនស្លេវមកក្នុងបន្ទប់វិញខណៈពេលដែលភ្លើងនៅកាំជណ្ដើរបានបើកឡើង។ វាបានកញ្ឆក់យកទ្រុងរបស់ហ៊ីដវីក រត់រឹងទៅបង្អួច ហើយហុចវាចេញក្រៅឲ្យរ៉ុន។ វាកំពុងតែវារប្រវេប្រវាទៅលើទូខោទ្រនាប់នៅពេលដែលលោកមាវើរណុនដំដៃផាំងៗទៅលើទ្វារដែលមិនបានចាក់សោ...ហើយវាក៏របើកឡើង។

មិនដល់មួយវិនាទីផង លោកមាវើរណុនមកដល់ទ្វារចូលបន្ទប់ទៅហើយ បន្ទាប់មកគាត់ក៏បន្លឺនូវសម្រែកមួយដូចគោឆ្កួត ហើយបោះពួយទៅរកហេរី ដោយចាប់វាបានត្រង់កែងជើង។

រ៉ុន ហ្វ្រេដ និងចចបានចាប់ដៃរបស់ហេរី ហើយទាញយ៉ាងខ្លាំងតាមដែលពួកគេអាចធ្វើបាន។

- ពីទូនៀ!- លោកមាវើរណុនបានគ្រហឹម។ - វាកំពុងតែលួចរត់ហើយ! វាកំពុងតែលួចរត់ហើយ!

បងប្អូនត្រកូលវីស្លីបានទាញយ៉ាងខ្លាំង ហើយជើងរបស់ហេរីក៏របូតចេញពីដៃរបស់លោកមាវើរណុន។ ពេលដែលហេរីនៅក្នុងឡាន ហើយបានទាញទ្វារបិទភ្លាម រ៉ុនបានស្រែកថា៖

- ដាក់ជើងរបស់បងឯងចុះទៅ ហ្វ្រេដ!

ហើយឡានបានបើកត្រង់រឹងឆ្ពោះទៅរកព្រះចន្ទ។

ហេរីស្ទើរតែមិនជឿ...វាមានសេរីភាពហើយ។ វាបានបើកកញ្ចក់ឡាន ខ្យល់រាត្រីបក់សក់របស់វារវិចៗ។ វាសម្លឹងមើលទៅដំបូលដែលកំពុងតែរួញតូចនៃមហាវិថីប្រាយវេដដ្រាយ។ លោកមាវើរណុន អ្នកមីងពីទូនៀ និងដាត់លីទាំងអស់គ្នាកំពុងតែតោងរយើងរយោង ដោយស្រឡាំងកាំង ចេញក្រៅបង្អួចរបស់ហេរី។

- ជួបគ្នានៅរដូវក្ដៅឆ្នាំក្រោយ!- ហេរីបានស្រែក។

គ្រួសារវីស្លីបានគ្រហឹមដោយអស់សំណើច ហើយហេរីក៏ផ្អែកមកកៅអីអង្គុយរបស់វាវិញ ចូលរួមញញឹមស្ញេញស្ញាញនឹងគេដែរ។

- ឲ្យហ៊ីដវីកចេញទៅក្រៅទៅ- វាបានប្រាប់រ៉ុន - វាអាចហើរពីក្រោយយើងបាន។ វាគ្មានឱកាសដើម្បីត្រដាងស្លាបរបស់វាជាយូរមកហើយ។

ចចបានហុចតង្កៀបសក់ទៅឲ្យរ៉ុន ហើយមួយស្របក់ក្រោយមក ហ៊ុដវីកបានហោះឡើងយ៉ាងរីករាយចេញពីក្រៅបង្អួចទៅ ហើរសំកាំងនៅម្ខាងពួកគេដូចជាខ្មោចអញ្ចឹង។

- អញ្ចឹង...រឿងវាយ៉ាងម៉េចទៅ ហេរី?- រ៉ុនបានស្រដីទាំងមិនអត់ធ្មត់។ - តើមានរឿងអីកើតឡើង?

ហេរីបានប្រាប់ពួកគេពីរឿងរបស់ដុបប៊ីទាំងអស់ ព្រមទាំងការដាស់តឿនដែលវាបានផ្ដល់មកឲ្យហេរី ហើយនិងមហន្តរាយនៃពូឌិញតំណាប់ស្វាយ។ មានភាពស្ងៀមស្ងាត់ដោយស្រទ្បាំងកាំងដ៏យូរមួយនៅពេលដែលវាបានបញ្ចប់។

- ពិតជាគួរឲ្យសង្ស័យមែន- ហ្វ្រេដបានស្រដីចុងក្រោយ។

- ប្រាកដជាការប្រើល្បិចហើយ- ចចបានយល់ស្របតាម។ - អញ្ចឹងវាថែមទាំងមិនប្រាប់ឯងថាតើនរណារៀបចំនូវរឿងទាំងអស់នេះទេវី?

-  ខ្ញុំមិនគិតថាវាអាចនិយាយបាននោះទេ- ហេរីបាននិយាយ។ - ខ្ញុំបានប្រាប់ឯងហើយ រាល់ពេលដែលវាជិតភ្លាត់មាត់និយាយរឿងអ្វីមួយនោះ វាក៏ចាប់ផ្ដើមបោកក្បាលរបស់វាទៅនឹងជញ្ជាំងភ្លាម។

វាបានឃើញហ្វ្រេដ និងចចសម្លឹងមើលមុខគ្នាទៅវិញទៅមក។

- ស្អីគេ ឯងគិតថាវាកំពុងតែកុហកខ្ញុំវី?- ហេរីបានស្រដី។

- អញ្ចេះវិញ- ហ្វ្រេដបាននិយាយ - សាកគិតតាមវិធីនេះមើល...ម្រេញគង្វាលប្រចាំផ្ទះមានថាមពលវេទមន្តផ្ទាល់ខ្លួនរបស់ពួកគេ ប៉ុន្តែជាធម្មតាវាមិនអាចប្រើប្រាស់វេទមន្តបានដោយគ្មានការអនុញ្ញាតពីម្ចាស់របស់វាឡើយ។ ខ្ញុំគិតថាដុបប៊ីចំនាស់នោះត្រូវគេបញ្ជូនមកដើម្បីឃាត់ឃាំងឯងមិនឲ្យត្រលប់ទៅសាលាហុកវ៉ាតវិញ។ ជាគំនិតកំប្លែងរបស់នរណាម្នាក់។ តើឯងមានគិតឃើញថាមាននរណាម្នាក់នៅសាលាច្រណែននឹងឯងដែរវីទេ?

- មាន- ហេរី និងរ៉ុនស្រដីព្រមៗគ្នា ភ្លាមមួយរំពេច។

- ដ្រាកូ មេលហ្វ័យ- ហេរីបានពន្យល់។ - វាស្អប់ខ្ញុំ។

- ដ្រាកូ មេលហ្វ័យវី?- ចចបាននិយាយ ដោយបែរជុំវិញ។ - កុំប្រាប់ថាជាកូនប្រុសរបស់លូស៊ីស មេលហ្វ័យណ៎ា?

- ប្រាកដជាមែនហើយ វាមិនមែនជាឈ្មោះធម្មតានោះទេ មែនទេ?- ហេរីបានស្រដី។ - ហេតុអ្វី?

- ខ្ញុំបានឮប៉ានិយាយពីគាត់- ចចបាននិយាយ។ - គាត់គឺជាអ្នកគាំទ្រដ៏ធំមួយរបស់អ្នកដែលឯងស្គាល់។

- ហើយនៅពេលដែលអ្នកដែលឯងស្គាល់បានបាត់ខ្លួនទៅ- ហ្វ្រេដបានស្រដី ដោយងើតមករកហេរី - លូស៊ីស មេលហ្វ័លបានត្រលប់មកវិញដោយនិយាយថាគាត់គ្មានពាក់ព័ន្ធនឹងរឿងហ្នឹងនោះទេ។ ភូតទាំងស្រុង ... ប៉ាខ្ញុំបានដឹងតាំងពីយូរមកហើយថាគាត់ចូលដៃជើងជាមួយអ្នកដែលឯងស្គាល់។

ហេរីធ្លាប់បានឮពីពាក្យចចាមអារ៉ាមអំពីគ្រួសាររបស់មេលហ្វ័យទាំងនេះពីមុនមកដែរ ហើយពួកគេមិនធ្វើឲ្យវាភ្ញាក់ផ្អើលអ្វីបន្តិចសោះ។ បើប្រៀបធៀបនឹង ដ្រាកូ មេលហ្វ័យ ដាត់លី ខេស្លីមើលទៅដូចជាក្មេងប្រុសដែលមានសុភវិនិច្ឆ័យ ចេះពិចារណាវែងឆ្ងាយ និងមានសន្ដានចិត្តល្អជាងផង។

- ខ្ញុំមិនដឹងថាតើគ្រួសារមេលហ្វ័យមានម្រេញគង្វាលវីក៏អត់នោះទេ...- ហេរីបាននិយាយ។

- អ្នកណាក៏ដោយដែលមានសត្វប្រភេទនេះនឹងក្លាយជាគ្រួសារវេទគូដ៏ចំនាស់មួយ ហើយពួកគេនឹងមានស្តុកស្តម្ភ- ហ្វ្រេដបានស្រដី។

- មែនហើយ ម៉ាក់ខ្ញុំតែងតែប្រាថ្នាថាយើងមានម្រេញគង្វាលប្រចាំផ្ទះមួយទុកគ្រាន់ប្រើអ៊ុតខោអាវ- ចចបាននិយាយ។ - ប៉ុន្តែអ្វីដែលយើងមានឲ្យពិតប្រាកដនោះ គឺជាខ្មោចកញ្ជាស់ដ៏អាក្រក់នៅក្នុងស្តាក ហើយនិងមនុស្សកន្លើនៅពេញសួនច្បារ។ ម្រេញគង្វាលប្រចាំផ្ទះនាំចូលមកនូវលាភសំណាង គេហដ្ឋានស្តុកស្តម្ភ ហើយនិងប្រាសាទ ព្រមទាំងគ្រឿងមង្គលផ្សេងៗទៀត ចំនែកឯងវិញច្បាស់ជាចាប់មិនបានមួយឡើយនៅក្នុងផ្ទះរបស់ពួកយើង...

ហេរីនៅស្ងៀម។ បើគិតឲ្យសព្វៗទៅ ជាធម្មតា ដ្រាកូ មេលហ្វ័យ មានរបស់ល្អលើសគេគ្រប់យ៉ាង អញ្ចឹងគ្រួសាររបស់វាច្បាស់ជាកំពុងតែរមៀលលើគំនរមាសវេទគួហើយ។ ឥឡូវ វាស្រមៃដល់ មេលហ្វ័យ កំពុងតែដើរពើងទ្រូងនៅជុំវិញគេហដ្ឋានស្តុកស្តម្ភដ៏ធំស៊ឹមស្កៃមួយ។ ការបញ្ជូនអ្នកបម្រើក្នុងគ្រួសារមកបញ្ឈប់ហេរីមិនឲ្យត្រលប់ទៅសាលាហុកវ៉ាតស្តាប់ទៅក៏ដូចជាប្រភេទនៃរឿងដែលមេលហ្វ័យនឹងធ្វើនោះដែរ។ តើហេរីភ្លើភ្លើរីដែលត្រូវទៅជឿដុបប៊ីទាំងស្រុងនោះ?

- និយាយអញ្ចឹង យើងរីករាយណាស់ដែលបានមកយកឯង- រ៉ុនបាននិយាយ។ - ខ្ញុំពិតជាព្រួយបារម្ភខ្លាំងណាស់នៅពេលដែលមិនឃើញឯងឆ្លើយតបសំបុត្ររបស់ខ្ញុំ។ មុនដំបូង ខ្ញុំគិតថាវាជាកំហុសរបស់អេរ៉ូល...

- តើនរណាគេអេរ៉ូល?

- ជាទីទុយរបស់យើង។ វាបុរាណណាស់។ មិនមែនត្រឹមតែជាលើកទីមួយទេដែលវាដួលសន្លប់នៅពេលធ្វើការចែកចាយសំបុត្រនោះ។ អញ្ចឹង បន្ទាប់មកខ្ញុំក៏សាកល្បងខ្ចីហឺមែស...

- នរណាគេ?

- ទីទុយដែលម៉ាក់ និងប៉ាទិញឲ្យពើរស៊ីនៅពេលដែលគេប្រគល់តំណែងជាប្រធានឲ្យគាត់- ហ្វ្រេដបានស្រដីមកពីខាងមុខ។

- ប៉ុន្តែពើរស៊ីមិនព្រមឲ្យវាមកខ្ញុំខ្ចីនោះទេ- រ៉ុនបាននិយាយ - ដោយយកលេសថាគាត់ត្រូវការវា។

- ពើរស៊ីពិតជាសំដែងអាកប្បកិរិយាប្លែកៗណាស់នៅរដូវក្តៅនេះ- ចចបានស្រដី ដោយចងចិញ្ចើម។ - ហើយគាត់បានផ្ញើសំបុត្រជាច្រើន ហើយចំនាយពេលមួយគំនរបិទទ្វារនៅក្នុងបន្ទប់របស់គាត់...ខ្ញុំចង់មានន័យថា គាត់ច្បាស់ជានៅក្នុងបន្ទប់ចំនាយពេលដុសខាត់ផ្លាកសញ្ញាប្រធានសិស្សហើយមើលទៅ...ឯងទៅទិសខាងលិចឆ្ងាយពេកហើយ ហ្វ្រេដ- វាបានបន្ថែម ដោយចង្អុលទៅត្រីវិស័យមួយនៅលើប៉ាណូនាឡិកា។ ហ្វ្រេដក៏កាច់ចង្កូចឡាន។

- អញ្ចឹង តើប៉ារបស់ឯងដឹងថាឯងយកឡានមកដែរឬទេ?- ហេរីបាននិយាយ ដោយរកនឹកមើលចម្លើយ។

- អឺ...ទេ- រ៉ុនបានស្រដី - គាត់ត្រូវធ្វើការនៅយប់នេះ។ ជាឱកាសល្អ យើងនឹងអាចយកវាទៅទុកក្នុងយានដ្ឋានវិញបានដោយមិនឲ្យម៉ាក់ដឹងថាពួកយើងបានបង្ហោះវានោះទេ។

- និយាយអញ្ចឹង តើប៉ារបស់ឯងធ្វើការអ្វីដែរនៅក្រសួងវេទមន្តនោះ?

- គាត់ធ្វើការនៅក្នុងអគារដែលគួរឲ្យធុញទ្រាន់ជាទីបំផុត- រ៉ុនបាននិយាយ។ - ការិយាល័យផ្នែកការប្រើប្រាស់មិនត្រឹមត្រូវនៃឧបករណ៍ពួកលោកិយ។

- ស្អីគេ?

- ការងារក្នុងផ្នែកហ្នឹងគឺ គេដាក់វេទមន្តលើរបស់ដែលបង្កើតឡើងដោយពួកលោកិយ ឯងដឹងទេ ក្នុងករណីដែល របស់ទាំងនោះត្រូវយកមកប្រើនៅក្នុងហាងរឺផ្ទះពួកលោកិយតទៅទៀត។ ដូចជា កាលពីឆ្នាំមុន មេធ្មប់ដ៏ចំនាស់ម្នាក់បានស្លាប់ ហើយប្រដាប់

ចាក់តែរបស់គាត់ត្រូវបានលក់ទៅហាងលក់វត្ថុបុរាណមួយ។ ស្ត្រីលោកិយម្នាក់នេះបានទិញវា យកវាទៅផ្ទះ ហើយសាកល្បងប្រើ ប៉ាន់តែនោះបំរើតែឲ្យមិត្តភក្តិរបស់នាង។ វាគឺជាសុបិនអាក្រក់មួយ...ប៉ាខ្ញុំត្រូវធ្វើការហួសម៉ោងអស់ជាច្រើនសប្តាហ៍ឯណោះ។

- តើមានរឿងអ្វីកើតឡើង?

- ប៉ាន់តែនោះស្រាប់តែឆ្កួត ហើយបាញ់ទឹកតែពុះពេញទីកន្លែង ហើយបុរសម្នាក់បានមកមន្ទីរពេទ្យដោយមានតង្កៀបចាប់ស្ករពីតភ្ជាប់នឹងច្រមុះរបស់គាត់។ ប៉ាទៅជាឆ្កួតអស់ហើយ មានតែគាត់ និងគ្រូមន្តអាគមចំនាស់ម្នាក់ដែលហៅថាភើឃីនប៉ុណ្ណោះនៅក្នុងការិយាល័យ ហើយពួកគាត់ត្រូវតែប្រើសិល្បកំទេចការចងចាំ និងអាគមគ្រប់ប្រភេទទាំងអស់ដើម្បីបិទបាំងរឿងទាំងអស់នេះ...

- ប៉ុន្តែប៉ារបស់ឯង...ឡាននេះ...

ហ្វ្រេដបានសើច។ - មែនហើយ ប៉ាខ្ញុំឆ្កួតអំពីអ្វីៗគ្រប់យ៉ាងរបស់ពួកលោកិយ ផ្ទើររបស់យើងសុទ្ធតែពេញទៅដោយរបស់របរពួកលោកិយទាំងអស់។ គាត់យកវាទៅដាក់ដាច់ពីគ្នា ដាក់វេទមន្តលើវា ហើយដាក់វាចូលគ្នាម្តងទៀត។ ប្រសិនបើគាត់ចូលទន្ទ្រានផ្ទះរបស់ពួកយើង មានតែគាត់ខ្លួនឯងប៉ុណ្ណោះជាអ្នកចាប់ខ្លួនឯងយកទៅឃុំឃាំង។ វាធ្វើឲ្យម៉ាក់ខ្ញុំឆ្កួតអស់ហើយ។

- នោះហើយជាផ្លូវធំ- ចចបានស្រដី ដោយសម្លឹងមើលចុះទៅក្រោមតាមបង្អួចឡានខាងមុខ។ - យើងនឹងទៅដល់ទីនោះនៅពេលដប់នាទីទៀត...ហេងវិញ វាចាប់ផ្តើមមានពន្លឺហើយ...

ពន្លឺសន្ទៅពណ៌ផ្កាឈូកព្រាងៗមួយបានលេចឡើងតាមជើងមេឃទៅទិសខាងកើត។

ហ្វ្រេដបន្ទាបឡានឲ្យកាន់តែទាបចុះ ហើយហេរីបានឃើញវាលស្រែចំការដ៏ងងឹតមួយ និងគុម្ពឈើជាច្រើន។

- យើងចេញឆ្ងាយពីភូមិបន្តិចហើយ- ចចបាននិយាយ។ - អតធើរី មហារិចី ខាច់ប៉ូល...

ឡានហោះកាន់តែទាបទៅៗ។ គែមព្រះទិវៃពណ៌ក្រហមដ៏ល្អមួយឥលូវកំពុងតែបញ្ចេញពន្លឺកាត់តាមដើមឈើ។

- ចុះចតហើយ!- ហ្វ្រេដបានស្រដី ខណៈពេលដែល ពួកគេបានបុកទៅនឹងដី ជាមួយនឹងការទង្គិចយ៉ាងស្រាលមួយ ។ ពួកគេបានចុះចតជាប់ទៅនឹងយានដ្ឋានកញ្ចាស់នៅក្នុងធ្លាតូចមួយ ហើយហេរីបានមើលចេញទៅក្រៅជាលើកដំបូងឯផ្ទះរបស់រ៉ុន។

ផ្ទះនោះមើលទៅដូចធ្លាប់ជាទ្រុងជ្រូកធ្វើពីថ្មដ៏ធំមួយ ប៉ុន្តែបន្ទប់ត្រូវបានគេបន្ថែមនៅទីនេះបន្តិច នៅទីនោះបន្តិចរហូតទាល់តែមានកំពស់ជាច្រើនជាន់ ហើយវាមើលទៅដូចជាបត់បែនច្រើនណាស់ហាក់ដូចជាផ្ទះនេះត្រូវបានធ្វើឡើងដោយប្រើវេទមន្ត (ដែលហេរីបានរំលឹកខ្លួនឯងថា វាប្រហែលជាអញ្ចឹងហើយ)។ បំពង់ផ្សែងបួនប្រាំត្រូវបានគេដាក់បន្តុបលើដំបូលផ្ទះពណ៌ក្រហម។ ផ្លាកសញ្ញាផ្អៀងម្ខាងដែលជាប់នឹងដីជិតផ្លូវចូលអានថា "ប៊ូរ៉ូ"។ នៅជុំវិញទ្វារមុខផ្ទះមានស្បែកជើងឃ្លុបរញ៉េរញ៉ៃជាច្រើន ហើយនិងថ្លាងដំច្រេះចាប់មួយ។ កូនមាន់ពណ៌ត្នោតធាត់ៗជាច្រើនកំពុងតែកកាយដីនៅជុំវិញធ្លាផ្ទះ។

- វាមិនល្អណាស់ណានោះទេ- រ៉ុនបានស្រដី។

- វាល្អណាស់- ហេរីបាននិយាយយ៉ាងរីករាយ ដោយគិតទៅដល់មហារិចីប្រាយវេដដ្រាយ។

ពួកគេបានចេញពីឡាន។

- ឥលូវ យើងនឹងទៅជាន់លើយ៉ាងស្ងៀមស្ងាត់ជាទីបំផុត- ហ្វ្រេដបានស្រដី - ហើយរង់ចាំឲ្យម៉ាក់ហៅពួកយើងញ៉ាំអាហារពេលព្រឹក។ បន្ទាប់មករ៉ុន ឯងចុះមកជាន់ក្រោមហើយនិយាយថា "ម៉ាក់ មើលហ្ន៎! នរណាគេមកទាំងព្រលប់ហ្នឹង!" គាត់នឹងរីករាយដែលបានជួបហេរី ហើយនិងគ្មាននរណាម្នាក់ដឹងថាយើងបានបង្ហោះឡាននោះទេ។

- ត្រូវហើយ- រ៉ុនបាននិយាយ។ -ឲ្យលឿនឡើង ហេរី ខ្ញុំដេកនៅ...

ទឹកមុខរ៉ុនបានប្រែទៅជាពណ៌បៃតងស្រងាត់ដ៏គួរឲ្យខ្លាច ភ្នែករបស់វាសម្លឹងជាប់ទៅនឹងផ្ទះ។ បីនាក់ទៀតបង្វិលខ្លួនបែរមកមើលដែរ។

អ្នកស្រីវីស្លីកំពុងតែដើរដូចចលនាទំពកាត់ធ្លា ធ្វើឲ្យកូនមាន់ភ័យរត់បែកខ្ញែកអស់ ហើយបើគិតដល់ថាគាត់ជា ស្ត្រីម្នាក់រាងទាប មាឌធាត់ និងទឹកមុខប្រកបដោយសន្ដានចិត្ត មិននឹកស្មានថាពេលនេះគាត់មើលទៅដូចជាខ្លាបញ្ចេញចង្កូមអញ្ចឹង។

- តែប៉ុណ្ណេះចប់ហើយ!- ហ្វ្រេដបានស្រដី។

- អូ៎! ច្បាស់ជាស្លាប់មិនខានទ្បើយ- ចចបាននិយាយ។

អ្នកស្រីវីស្លីបានមកឈរស្ងៀមនៅពីមុខពួកគេ ដៃរបស់គាត់ច្រត់ចង្កេះ សម្លឹងមើលមុខម្នាក់ម្ដងៗ។ គាត់កំពុងតែស្លៀកអៀមលំអដោយផ្កាដោយមានចង្កឹះវេទមន្តលៀនចេញពីហោប៉ៅ។

- អញ្ចឹង- គាត់បានស្រដី។

- អរុណសួស្តី ម៉ាក់- ចចបាននិយាយ ដោយគិតថាវានឹងមិនអីនោះទេ។

- តើឯងមិនដឹងថាម៉ាក់បារម្ភពីឯងយ៉ាងណាទេ?- អ្នកស្រីវីស្លីបានស្រដីខ្សឹបៗប្រកបដោយគ្រោះថ្នាក់។

- សុំទោស ម៉ាក់ ប៉ុន្តែមើលទៅ យើងត្រូវតែ...

កូនប្រុសរបស់អ្នកស្រីទាំងបី មានកំពស់ខ្ពស់ជាងគាត់ទៅទៀត ប៉ុន្តែពួកគេត្រូវតែរួញបន្ទាបខ្លួនខណៈពេលដែលកំហឹងរបស់គាត់បានធ្វើឲ្យពួកគេបាក់ស្បាត។

*- គ្រែទទេស្អាត! គ្មានសារ! បាត់ឡាន...អាចត្រូវក្រឡាប់...ត្រូវព្រួយចិត្តបារម្ភនឹងពួកឯង...តើឯងមានខួរល់ទេ ?...មិនដែលទេ ម៉ាក់ប្រាកដជាត្រូវព្រួយចិត្តស្លាប់ដោយសារតែពួកឯងហ្នឹងហើយ...ចាំប៉ាឯងមកផ្ទះវិញនឹងដឹងដៃគ្នាហើយ យើងមិនដែលមានបញ្ហាបែបនេះពីប៊ីល វីឆាលី វីក៏ពឿរស៊ីនោះទេ...*

- ពឿរស៊ីល្អរហូត- ហ្វ្រេដបានរអ៊ូ។

- បើឯងអាចរៀនសូត្របានមួយចំនែកពីពឿរស៊ីនោះ ទុកថាប្រពៃណាស់ហើយ!- អ្នកស្រីវីស្លីបានស្រែក ដោយរុញម្រាមដៃមួយទៅលើទ្រូងរបស់ហ្វ្រេដ។ - ឯងអាចស្លាប់ ឯងអាចត្រូវគេមើលឃើញ ឯងអាចធ្វើឲ្យប៉ារបស់ឯងបាត់បង់ការងារ...

វាហាក់ដូចជាបន្តទៅអស់ជាច្រើនម៉ោង។ អ្នកស្រីវីស្លីបានស្រែករហូតទាល់តែខ្លួនគាត់ស្អកកមុនពេលដែលគាត់បែរទៅរកហេរី ដែលកំពុងតែដើរថយក្រោយ។

- មីងពិតជារីករាយណាស់ដែលបានជួបឯង ហេរី ក្មួយសម្លាញ់- គាត់បានស្រដី - ចូលមកក្នុង ហើយស្រស់ស្រូបអាហារពេលព្រឹកខ្លះទៅ។

គាត់បានបែរ ហើយដើរត្រលប់ទៅក្នុងផ្ទះ ឯហេរីបានដើរតាមគាត់ ក្រោយពីសម្លឹងយ៉ាងគួរឲ្យខ្លាចដាក់រ៉ុន ដែលបានងក់ក្បាលយ៉ាងពេញចិត្តពេញថ្លើម។

ផ្ទះបាយមានសភាពតូច ហើយពិតជាទើសទែងមែន។ មានតុ និងកៅអីធ្វើពីឈើដែលបានដុសលាងរួចស្អាត នៅចំកណ្ដាល ហើយហេរីបានអង្គុយចុះលើគែមកៅអីរបស់វា សម្លឹងមើលជុំវិញ។ វាមិនដែលនៅក្នុងផ្ទះវេទគូពីមុនមកទេ។

នាឡិកានៅលើជញ្ជាំងទល់មុខវាមានតែទ្រនិចមួយតែប៉ុណ្ណោះ ហើយគ្មានលេខឡើយ។ ពាក្យសរសេរនៅគែមនោះមានដូចជា "ពេលឆុងតែ" "ពេលឲ្យចំណីមាន់" និង "ឯងយឺតពេលហើយ"។ សៀវភៅត្រូវបានគរជាបីគំនរនៅលើជើងក្រានគ្រួះ សៀវភៅ

ទាំងនោះមានចំណងជើងដូចជា *ដាក់វេទមន្តលើនរនិតរបស់អ្នក ការដាក់វេទមន្តក្នុងការដុតនំប៉័ង* និង *ការរៀបចំអាហារពេលល្ងាចក្នុងពេលមួយនាទី-វាជាវេទមន្ត!* ហើយបើហេរីស្តាប់មិនច្រលំទេ វិទ្យុកញ្ចាស់ដែលនៅជាប់នឹងស្នូកទឹកបានផ្សាយថា កម្មវិធីបន្ទាប់គឺ "ម៉ោងវេទមន្ត ជាមួយនឹងតារាចំរៀងវេទគូដ៏មានប្រជាប្រិយភាព ឃិលេសទីណា វ៉ាបិក"។

អ្នកស្រីវីស្លីកំពុងតែដើររអ៊ូរទាំជុំវិញ ចំអិនអាហារពេលព្រឹកដោយធ្វេសប្រហែសបន្តិចបន្តួច ថែមទាំងចោលនូវទឹកមុខដ៏អាក្រក់ដាក់កូនៗរបស់គាត់ខណៈពេលដែលគាត់គ្រវែងសាច់ក្រកទៅក្នុងខ្ទះចៀន។ ម្តងម្កាល គាត់បានរអ៊ូរទាំនូវពាក្យសម្តីដូចជា "មិនដឹងជាពួកឯងកំពុងតែគិតអ្វី" និង "ស្ទើរតែមិនជឿសោះ"។

- មីងមិនបានថាឲ្យឯងទេ ក្មួយសម្លាញ់- គាត់បានអះអាង ដោយដាក់សាច់ក្រកប្រាំបីប្រាំបួនទៅលើចានរបស់វា។ - អស់សឺ និងមីងក៏ព្រួយបារម្ភអំពីឯងណាស់ដែរ។ ទើបតែយប់មិញទេ ដែលយើងកំពុងតែនិយាយគ្នាថា យើងនឹងមកយកឯងដោយផ្ទាល់ប្រសិនបើឯងមិនបានសរសេរសំបុត្រតបមកវិញនៅថ្ងៃសុក្រនោះទេ។ ប៉ុន្តែពិតមែន- (ឥលូវគាត់កំពុងតែបន្ថែមពងទាចៀនបីគ្រាប់ទៀតដាក់ចានរបស់វា) - ការបង្ហោះឡានខុសច្បាប់ឆ្លងកាត់ប្រទេស...អាចមាននរណាម្នាក់មើលឯងឃើញបាន...

គាត់បានរលាស់ចង្កឹះវេទមន្តសំដៅចាននៅក្នុងស្នូកទឹក ដែលចាប់ផ្តើមលាងសម្អាតដោយឯងៗ លឺសូរក្លិកៗយ៉ាងថ្នមៗនៅពីក្រោយ។

- យប់មិញមានពពកច្រើនណាស់ ម៉ាក់!- ចចបានស្រដី។

- បិទមាត់ទៅពេលដែលឯងកំពុងតែញ៉ាំ!- អ្នកស្រីវីស្លីនិយាយម៉ាត់ៗ។

- ពួកគេបានបង្អត់អាហារហេរីណា ម៉ាក់!- ចចបានស្រដី។

- ហើយឯងក៏អញ្ចឹងដែរ!- អ្នកស្រីវីស្លីបាននិយាយ ប៉ុន្តែសម្តីនេះហាក់ដូចជាទន់បន្តិចដែលគាត់បានចាប់ផ្តើមកាត់នំប៉័ងឲ្យហេរី ហើយដាក់ប័រឲ្យវា។

នៅពេលនោះ ស្រាប់តែមានរឿងហេតុតូចមួយកើតឡើង។ រូបរាងមនុស្សសក់ក្បាលពណ៌ក្រហមស្លៀកសម្លៀកបំពាក់ដ៏វែងមួយ ដែលបានលេចឡើងនៅក្នុងផ្ទះបាយ បានផ្តល់នូវសម្រែកដ៏តូចមួយ ហើយបានរត់ចេញទៅម្តងទៀត។

- គីជីននី- រ៉ុនបានស្រដីតិចៗប្រាប់ហេរី។ - ប្អូនស្រីរបស់ខ្ញុំ។ នាងនិយាយពីឯងពេញមួយរដូវក្តៅទៅហើយ។

- មែនហើយ នាងចង់បានហត្ថលេខារបស់ឯងខ្លាំងណាស់ ហេរី- ហ្វ្រេដបានសើចស្ញេញ ប៉ុន្តែវាបានប្រទះភ្នែកម្តាយរបស់វា ហើយក៏ឱនមុខចុះទៅលើចានរបស់វាវិញដោយគ្មានស្តីមួយម៉ាត់។ គ្មានអ្វីទៀតដែលត្រូវនិយាយទេរហូតដល់ចានទាំងបួនត្រូវស្អាត ដែលចំនាយពេលយ៉ាងខ្លីដ៏គួរឲ្យភ្ញាក់ផ្អើល។

- អ៊ំា! ខ្ញុំនឿយហត់ណាស់- ហ្វ្រេដបានស្ងាប ដោយទម្លាក់កាំបិត និងសមរបស់វាជាលើកចុងក្រោយ។ - ខ្ញុំគិតថាខ្ញុំនឹងទៅដេក ហើយ...

- មិនឲ្យឯងទៅដេកទេ- អ្នកស្រីវីស្លីបាននិយាយម៉ាត់ៗ។ - វាជាកំហុសរបស់ឯងដែលឯងអត់ដេកពេញមួយយប់។ ឯងនឹងត្រូវទៅបណ្តេញពួកមនុស្សកន្លើចេញពីសួនច្បារឲ្យម៉ាក់ ពួកវាកំពុងតែបង្ករឿងរំខានម្តងទៀតហើយ។

- អូ! ម៉ាក់...

- ហើយមានឯងទាំងពីរនាក់ទៀត- គាត់បានស្រដី ដោយសម្លឹងមើលរ៉ុន និងហ្វ្រេដ។ - ក្មួយអាចទៅដេកបាន ក្មួយសម្លាញ់- គាត់បានបន្ថែមទៅហេរី។ - ឯងមិនបានស៊ុមគ្រលុំជាមួយពួកគេក្នុងការបង្ហោះឡានកញ្ចាស់នោះទេ។

ប៉ុន្តែហេរី ដែលមានអារម្មណ៍ថាស្វាងទាំងស្រុងហើយនោះ បាននិយាយយ៉ាងរហ័ស - ខ្ញុំនឹងជួយរ៉ុន ខ្ញុំមិនដែលឃើញការបណ្តេញពួកមនុស្សកន្លើនោះទេ...

- ក្មួយពិតជាចិត្តល្អមែន ក្មួយសម្លាញ់ ប៉ុន្តែវាជាការងារធុញទ្រាន់ណាស់- អ្នកស្រីវីស្លីបានស្រដី។ - ឥលូវ ចាំមើលថាតើឡក់ហាតនិយាយអ្វីខ្លះចំពោះប្រធានបទនេះ។

ហើយគាត់បានទាញសៀវភៅដ៏ធ្ងន់មួយពីគំនរសៀវភៅនៅលើជើងក្រានគ្រួ។ ចចបានរអ៊ូរទាំ។

- ម៉ាក់ យើងដឹងថាត្រូវធ្វើយ៉ាងម៉េចដើម្បីបណ្តេញពួកមនុស្សកន្លើចេញពីសួនច្បារហើយ។

ហេរីបានមើលទៅលើក្របសៀវភៅរបស់អ្នកស្រីវីស្លី។ សរសេរនៅលើក្របនោះជាអក្សរពណ៌មាសភ្លឺផ្លេកគឺពាក្យ "លំនែនាំរបស់ ហ្គីលដីរ័យឡក់ហាត ចំពោះរបស់របរក្នុងផ្ទះដែលចង្រៃ"។ មានរូបថតដ៏ធំមួយនៅក្របមុខ ជារូបវេទគូដ៏សង្ហាម្នាក់ ដែលមានសក់ពណ៌ទង់ដែងបក់រិចៗ ហើយនិងភ្នែកពណ៌ខៀវថៃងចាំង។ វេទគូ ដែលហេរីគិតថាជាហ្គីលដីរ័យ ឡក់ហាតនោះ បានបន្តព្រិចភ្នែកយ៉ាងឈ្លើយដាក់ពួកគេទាំងអស់គ្នា។ អ្នកស្រីវីស្លីបានញញឹមយ៉ាងរីករាយដាក់គាត់។

- អូ! គាត់ពិតជាអស្ចារ្យណាស់- គាត់បានស្រដី - គាត់ដឹងពីរបស់របរចង្រៃៗក្នុងផ្ទះរបស់គាត់ ល្អ វាជាសៀវភៅដ៏អស្ចារ្យមួយ...

- ម៉ាក់យល់ថាគាត់គួរឲ្យទាក់ទាញ- ហ្វ្រេដបាននិយាយខ្សឹបៗ ដែលស្ទើរតែមិនអាចឮបាន។

- កុំនិយាយមិនទំនងពេក ហ្វ្រេដ- អ្នកស្រីវីស្លីបានស្រដី ថ្ពាល់របស់គាត់ប្រែពណ៌ផ្កាឈូក។ - ល្អ ប្រសិនបើឯងគិតថាឯងដឹងច្រើនជាងឡក់ហាតនោះ ឯងទៅធ្វើការចុះ ហើយច្បាស់ជារឿងហើយប្រសិនបើមានមនុស្សកន្លើតែម្នាក់នៅក្នុងសួនច្បារនោះ នៅពេលដែលម៉ាក់ចេញទៅក្រៅពិនិត្យមើល។

ដោយស្វាប និងរអ៊ូរទាំ ក្រុមវីស្លីបានដើរទៅក្រៅដោយមានហេរីនៅពីក្រោយពួកគេ។ សួនច្បារនោះមានទំហំធំ ហើយ នៅក្នុងភ្នែករបស់ហេរី នេះទើបសក្តិសមជាសួនច្បារពិតប្រាកដ។ គ្រួសារឌើស្លីមិនចូលចិត្តសួនច្បាររបៀបនេះទេ...មានរុក្ខជាតិដែលឥតបានការជាច្រើន និងស្មៅដែលត្រូវការកាត់ចេញ...ប៉ុន្តែមានដើមឈើដែលមានថ្នាំងច្រើននៅជុំវិញជញ្ជាំងទាំងអស់ រុក្ខជាតិដែលហេរីមិនដែលបានឃើញលូតចេញពីសួនផ្ការ ហើយនិងត្រពាំងដ៏ធំមួយដែលពោរពេញទៅដោយកង្កែប។

- ពួកលោកិយក៏មានពួកមនុស្សកន្លើក្នុងសួនច្បារដែរ ពួកឯងដឹងទេ- ហេរីបានប្រាប់រ៉ុនខណៈពេលដែលពួកគេឆ្លងកាត់ផ្លាស្មៅ។

- មែនហើយ ខ្ញុំបានឃើញរបស់ទាំងនោះហើយ ដែលគេហៅថាពួកមនុស្សកន្លើនោះ- រ៉ុនបាននិយាយ ដោយឱនក្បាលអើតមើលទៅក្នុងគុម្ពផ្កាភីអូនី។ - ដូចជាលោកតាណូអែលតូចកន្ទាត់ដែលមានកាន់ដងសន្ទូចហ្នឹងហ្អី..

មានសំឡេងប្រវាយប្រតប់គ្នាដ៏ថ្លង់គួរឲ្យសាហាវមួយ គុម្ពផ្កាភីអូនីក៏ញ័រ ហើយរ៉ុនក៏ងើបខ្លួនត្រង់ឡើង។ - នេះជាមនុស្សកន្លើមួយក្បាល- វាស្រដីយ៉ាងម៉ត់ចត់។

- លែងខ្ញុំ! លែងខ្ញុំ!- មនុស្សកន្លើនោះបានបន្លឺសូរញ៉េកៗ។

វាពិតជាមិនដូចលោកតាណូអែលអ្វីបន្តិចសោះឡើយ។ វាមានរាងតូច ហើយមើលទៅដូចជាស្បែកសត្វ ដោយមានក្បាលទំពែក និងពកដ៏ធំមួយពិតជាដូចដំឡូងបារាំងណាស់។ រ៉ុនបានកាន់សត្វនោះឲ្យនៅឆ្ងាយអស់មួយដៃ ខណៈពេលដែលវាខំប្រឹងរើបម្រះចេញដោយប្រើជើងតូចៗដូចស្នែងរបស់វា។ រ៉ុនបានចាប់វាយ៉ាងតឹងជុំវិញកជើងហើយសំយុងក្បាលវាចុះក្រោម។

- នេះហើយជាអ្វីដែលឯងត្រូវធ្វើ- វាបានស្រដី។ វាបានលើកមនុស្សកន្លើនោះឡើងខ្ពស់ផុតលើក្បាលរបស់វា ( "លែងខ្ញុំ!") ហើយចាប់ផ្តើមគ្រវីយ៉ាងខ្លាំងដូចជាគ្រវីខ្សែ។ ដោយមើលឃើញទឹកមុខស្រឡាំងកាំងរបស់ហេរី រ៉ុនក៏បន្ថែមៈ

- ពួកវាអត់ឈឺទេ...ឯងត្រូវតែធ្វើឲ្យពួកវាវិលមុខខ្លាំង អញ្ចឹងពួកវាមិនអាចរកឃើញផ្លូវត្រលប់ទៅរន្ធរបស់វាទៀតទេ។

វាក៏ព្រលែងកជើងរបស់មនុស្សកន្លើនោះ វាហោះប្រាំមួយម៉ែតទៅក្នុងខ្យល់ ហើយធ្លាក់ចុះមកវិញដោយបន្លឺសូរក្តូកនៅក្នុងទីវាលកន្លែងដើមឈើដុះជាជួរ។

- ពិតជាគួរឲ្យអាណិតមែន- ហ្វ្រេដបានស្រដី។ - ខ្ញុំហ៊ានភ្នាល់ថាខ្ញុំអាចចាប់បានរបស់ខ្ញុំនៅដង្គត់ឈើខាងណោះ។

ហេរីបានស្វែងយល់យ៉ាងឆាប់រហ័សថាមិនត្រូវមានអារម្មណ៍សោកស្តាយចំពោះមនុស្សកន្លើនោះទេ។ វាបានសម្រេចចិត្តថានឹងទម្លាក់អាទីមួយដែលវាចាប់បានលើដើមឈើដែលដុះជាជួរ ប៉ុន្តែមនុស្សកន្លើនោះ ដែលមើលទៅដូចជាខ្សត់ខ្សោយទេ ស្រាប់តែបានពន្លិចធ្មេញមុតដូចប្រដាប់កោរពុកមាត់ ទៅក្នុងម្រាមដៃរបស់ហេរី ហើយមានការលំបាកខ្លាំងណាស់ទំរាំតែរលាស់វាចេញបាន រហូតទាល់តែ...

- អស្ចារ្យមែន ហេរី...វាប្រាកដជាដប់ប្រាំមួយម៉ែតហើយ...

មិនយូរប៉ុន្មាន ផ្ទៃមេឃទាំងមូលពោរពេញទៅដោយមនុស្សកន្លើដែលកំពុងតែហោះ។

- ឃើញទេ ពួកវាមិនសូវឆ្លាតទាល់តែសោះ- ចចបាននិយាយ ដោយចាប់បានមនុស្សកន្លើបួនប្រាំក្នុងពេលតែមួយភ្លែតសោះ។ - ពេលដែលពួកវាដឹងថាការបណ្តេញពួកវាចេញកំពុងតែកើតឡើងហើយ វាក៏លើកគ្នាទាំងហ្វូងដើម្បីមកមើល។ ឯងនឹងគិតថាឥលូវ ពួកវាទទួលបានមេរៀនហើយ។

មិនយូរប៉ុន្មានហ្វូងមនុស្សកន្លើនៅក្នុងទីវាលបានចាប់ផ្តើមដើរចេញទៅឆ្ងាយជាជួរៗ ព្រមទាំងញាក់ស្មាតូចៗរបស់ពួកវាធ្វើដូចឆ្ងល់។

- ពួកវានឹងត្រលប់មកវិញ- រ៉ុនបានស្រដី ខណៈពេលដែលពួកគេសម្លឹងមើលពួកមនុស្សកន្លើ ដែលបាត់ខ្លួនទៅក្នុងដើមឈើដែលដុះជាជួរនៅទីវាលម្ខាងទៀត។ - ពួកវាចូលចិត្តនៅទីនេះ ... ប៉ាចិត្តទន់ដាក់ពួកវាពេកហើយ គាត់គិតថាពួកវាគួរឲ្យអស់សំណើច...

ស្រាប់តែក្រោយមក ទ្វារមុខផ្ទះក៏បិទយ៉ាងខ្លាំង។

- គាត់ត្រលប់មកវិញហើយ!- ចចបាននិយាយ។ - ប៉ាមកផ្ទះវិញហើយ!

ពួកគេប្រញាប់ប្រញាល់រត់កាត់តាមសួនច្បារ ហើយចូលទៅក្នុងផ្ទះវិញ។

លោកវីស្លីបានអង្គុយលើកៅអីក្នុងផ្ទះបាយដោយដោះវ៉ែនតាចេញ ហើយបិទភ្នែករបស់គាត់។ គាត់គឺជាបុរសស្គមម្នាក់ដែលចាប់ផ្តើមទំពែកក្បាល ប៉ុន្តែសរសៃសក់បន្តិចបន្តួចដែលគាត់មាន ពណ៌ក្រហមដូចជាកូនៗគាត់អញ្ចឹងដែរ។ គាត់កំពុងតែស្លៀករ៉ូបធ្វើដំនើរពណ៌បៃតងវែងមួយដែលពេញដោយធូលី។

- យប់នេះរវល់មែនទែន- គាត់និយាយតិចៗ ដោយរាវរកប៉ាន់តែខណៈពេលដែលពួកគេទាំងអស់អង្គុយចុះនៅជុំវិញគាត់។ - ការវាយប្រហារលើកទីប្រាំបួនហើយ។ ទីប្រាំបួន! ហើយតាកញ្ចាស់ម៉ាន់ដាន់ហ្គាស ហ្វិតឆឺនោះព្យាយាមដាក់អាគមមកលើខ្ញុំនៅពេលដែលខ្ញុំបែរខ្នង...

លោកវីស្លីបានផឹកតែមួយក្អឹក ហើយក៏ដកដង្ហើមធំ។

- មានរកអ្វីឃើញទេ ប៉ា?- ហ្វ្រេដបាននិយាយដោយចង់ដឹង។

- អ្វីដែលប៉ារកឃើញគឺជាកូនសោទ្វារដែលកំពុងតែរួញតូចពីរបី និងកំសៀវយ៉ាងមុតមួយ- លោកវីស្លីបានស្ងាប។ - ទោះបីជាយ៉ាងណាក៏ដោយ មានរបស់សាហាវៗស្អាតៗមួយចំនួនដែលមិនមែនត្រូវផ្នែកនាយកដ្ឋានរបស់ប៉ា។ ម៉ិតលេកត្រូវបានគេយកចេញទៅសួរចម្លើយអំពីសំពោចស្បូវយ៉ាងចម្លែកមួយចំនួន ប៉ុន្តែអ្នកទទួលបន្ទុកខាងចំណោទសួរ គឺជាគណៈកម្មាធិការផ្នែកវេទមន្តពិសោធឯណោះទៅវិញទេ អរគុណព្រះជាម្ចាស់...

- ហេតុអ្វីបានជាគេទៅខ្វល់ខ្វាយធ្វើឲ្យសោទ្វាររួញតូចធ្វើអ្វី?- ចចបាននិយាយ។

- ធ្វើឲ្យពួកលោកិយគ្នាខ្វល់ខ្វាយអត់អំពើ- លោកវីស្លីបានដកដង្ហើមធំ។ - លក់ឲ្យពួកគេនូវកូនសោដែលចេះតែរួញទៅរហូតដល់រលាយបាត់ អញ្ចឹងពួកគេមិនអាចរកវាឃើញនោះទេនៅពេលដែលពួកគេត្រូវការវា...ជាការពិតណាស់ វាពិតជាពិបាកក្នុងការដាក់ទោសនរណាម្នាក់ឲ្យប្រាកដណាស់ ពីព្រោះគ្មានពួកលោកិយណាសុខចិត្តឲ្យកូនសោរបស់គេចេះតែរួញនោះទេ ... ពួកគេនឹងទទូចថាពួកគេកំពុងតែបាត់បង់វាបន្តិចម្តងៗ។ ព្រះអើយ ពួកគេសុខចិត្តនឹងទៅទោះជាដល់ទីណាក៏ដោយ ដើម្បីកុំឲ្យវីរវល់នឹងរឿងវេទមន្ត ទោះជាវាកើតឡើងនៅចំពោះមុខពួកគេក៏ដោយ...ប៉ុន្តែចំនែកវត្ថុដែលក្រុមពួកយើងបានយកមកដាក់វេទមន្តនោះ ពួកឯងច្បាស់ជាមិនជឿឡើយថា...

- ដូចជាឡានរឺ?

អ្នកស្រីវីស្លីបានបង្ហាញខ្លួនឡើង ដោយកាន់ដែកឆ្កឹះរងើកភ្លើងដ៏វែងមួយដូចជាដាវ។ ភ្នែករបស់លោកវីស្លីក៏កន្រ្តាក់ឡើង។ គាត់បានសម្លឹងមុខប្រពន្ធរបស់គាត់បែបលាក់ពុតកំហុស។

- ឡ-ឡានឬ ម៉ូលី អូនសម្លាញ់?-

- ចាស អស់សឺ ឡាន- អ្នកស្រីវីស្លីបានស្រដី ភ្នែករបស់គាត់បញ្ចេញពន្លឺភ្លឹបភ្លែត។ - ស្រមៃមើលថាមានវេទគូម្នាក់ទិញឡានកញ្ចាស់ដ៏ច្រេះចាប់មួយ ហើយប្រាប់ប្រពន្ធរបស់គាត់ថា គាត់គ្រាន់តែចង់យកវាទៅដាក់មួយឡែកដើម្បីមើលថាវាដំណើរការយ៉ាងម៉េចខ្លះ តែតាមការពិតគាត់កំពុងតែលួចដាក់វេទមន្តលើឡាននោះឲ្យវាចេះហោះសោះ។

លោកវីស្លីបានព្រិចភ្នែក។

- អឺ...អូនសម្លាញ់ បងគិតថាអូននឹងយល់ឃើញថាគាត់ម្នាក់នោះធ្វើដោយស្របច្បាប់បំផុត ទោះបីជា...អឺ...ប្រហែលជាប្រសើរជាង...អឺម..បើគាត់ប្រាប់ប្រពន្ធរបស់គាត់ពីការពិត...រឿងគ្រប់យ៉ាងវាមិនចេះតែដូចតាមការចែងនៅក្នុងច្បាប់នោះទេ អូននឹងយល់...តែបើកាលណាគាត់គ្មានចេតនានឹងបង្ហោះឡាននោះទេ រឿងដែលថាឡាននោះអាចហោះបានច្បាស់ជាមិន...

- អស់សឺ វីស្លី បងច្បាស់ជានិយាយថារឿងគ្រប់យ៉ាងមិនដូចតាមអ្វីដែលសរសេរក្នុងច្បាប់ហើយ!- អ្នកស្រីវីស្លីបានស្រែក។ - ច្បាស់ណាស់ តាមទ្រឹស្តីនេះ បងនឹងអាចបន្តធ្វើការឥតប្រយោជន៍ជាមួយនឹងសំរាមពួកលោកិយទាំងនោះនៅក្នុងរោងជាងរបស់បង! ហើយប្រាប់បងឲ្យដឹងរឿងមួយចុះ ហេរីបានមកដល់នៅពេលព្រឹកនេះក្នុងឡានដែលបងគ្មានបំនងនឹងបង្ហោះនោះ!

- ហេរី?- លោកវីស្លីបានស្រដីទាំងមិនដឹងខ្យល់។ - ហេរីនរណាគេ?

គាត់សម្លឹងមើលជុំវិញ បានឃើញហេរី ហើយក៏លោតកញ្ឆេងឡើង។

- ព្រះជាម្ចាស់អើយ តើនេះរឺជាហេរី ផោតធ័រ ? ពិតជារីករាយដែលបានជួបឯងណាស់ រ៉ុនបានប្រាប់ពួកយើងច្រើនណាស់អំពី...

- *កូនប្រុសរបស់បងបានបង្ហោះឡាននោះទៅកាន់ផ្ទះរបស់ហេរី ហើយត្រលប់មកវិញកាលពីម្សិលមិញ!*- អ្នកស្រីវីស្លីបានស្រែក។ - តើបងមានពាក្យអ្វីចង់និយាយទៀត ហ្ពាស?

- តើឯងពិតជាបានបង្ហោះឡានមែន?- លោកវីស្លីបានស្រដីដោយចង់ដឹងចង់ឮ។ - តើវាដំណើរការល្អទេ? ប៉ា...ប៉ាចង់មានន័យថា- គាត់បានអោក់អរួល ខណៈពេលដែលមានផ្កាភ្លើងភ្លឺព្រាតៗចេញពីក្រសែភ្នែករបស់អ្នកស្រីវីស្លី - នោះពិតជាមិនត្រឹមត្រូវទេក្មេងៗ...ពិតជាខុសមែន...

- ឲ្យពួកគាត់រវល់នឹងរឿងហ្នឹងចុះ- រ៉ុនបាននិយាយរអ៊ូរទាំដាក់ហេរី ខណៈពេលដែលអ្នកស្រីវីស្លីឡើងប៉ោងដូចជាសត្វសុនក។ - តោះ ខ្ញុំនឹងបង្ហាញបន្ទប់របស់ខ្ញុំដល់ឯង។

ពួកគេដើរលបៗចេញពីផ្ទះបាយ ហើយចុះទៅក្រោមច្រកផ្លូវចង្អៀតមួយ ទៅកាន់ជណ្តើរកាំមិនស្មើគ្នា ដែលកាច់ចុះកាច់ឡើងទៅលើតាមទ្រង់ទ្រាយផ្ទះនោះដែរ។ នៅកាំជណ្តើរទីបី ទ្វារមួយនៅចំហបន្តិច។ ហេរីបានប្រទះឃើញភ្នែកពណ៌ត្នោតដែលភ្លឺចិញ្ចាចមួយគូដែលសម្លឹងមើលមកវា មុនពេលដែលទ្វារនោះបិទដោយបន្លឺសំឡេងឮសូរគ្រឹប។

- ជីននី- រ៉ុនបាននិយាយ។ - ការអៀនខ្មាសរបស់នាងដូចជាប្លែកៗដល់ហើយ នាងមិនដែលបិទទ្វារតាមធម្មតានោះទេ...

ពួកគេឡើងកាំជណ្តើរពីរទៀតទំរាំពួកគេទៅដល់ទ្វារមួយដោយមានថ្នាំពណ៌របក និងមានសន្លឹកលោហធាតុនៅលើវាសរសេរថា "បន្ទប់របស់រ៉ូណាល់"។

ហេរីបានបោះជំហានចូលទៅក្នុង ក្បាលរបស់វាស្ទើរតែប៉ះនឹងពិតានដែលជ្រាលទៅហើយ ហើយបានព្រិចភ្នែក។ វាដូចជាការដើរចូលទៅក្នុងចង្ក្រានអញ្ចឹង៖ ស្ទើរតែគ្រប់អ្វីៗដែលនៅក្នុងបន្ទប់របស់រ៉ុនហាក់ដូចជាម្លប់ដើមក្រូចដ៏ស្អុកស្រមូមស្រមាមមួយអញ្ចឹង៖ កម្រាលពូក ជញ្ជាំង ហើយថែមទាំងពិតានទៀតផង។ បន្ទាប់មកហេរីបានដឹងថារ៉ុនបានគ្របស្ទើរតែគ្រប់សង់ទីម៉ែតនៃក្រដាសបិតជញ្ជាំងរយីករយាកជាមួយនឹងប័ណ្ណក្រដាសនៃរូបមេធ្មប់ និងវេទគូប្រាំពីរដូចៗគ្នា សុទ្ធតែស្លៀករ៉ូបពណ៌ទឹកក្រូចទាំងអស់ កាន់ដងអំបោស ហើយបក់ដៃយ៉ាងស្វាហាប់។

- ក្រុមឃ្វីដឌីច្ចរបស់ឯងរឺ?- ហេរីបានស្រដី។

- ជឹ ឆាត់លី កាណុង- រ៉ុនបាននិយាយ ដោយចង្អុលទៅកម្រាលពូកពណ៌ទឹកក្រូច ដែលត្រូវបានលម្អដោយអក្សរ *Cs* ពណ៌ខ្មៅធំៗពីរ និងគ្រាប់កាំភ្លើងធំដែលកំពុងតែបង្កើនល្បឿនមួយ។ - ទីប្រាំបួននៅក្នុងសម្ព័ន្ធ។

សៀវភៅវេទមន្តរបស់រ៉ុនត្រូវបានគរយ៉ាងគ្មានសណ្តាប់ធ្នាប់នៅជ្រុងម្ខាង ជាប់នឹងគំនររឿងរូបភាព ដែលសុទ្ធតែជាប្រភេទរឿង ដំណើរផ្សងព្រេងរបស់ម៉ាទីន មីកស៍ ពួកលោកិយឆ្កួតលីលា។ ចង្កឹះវេទមន្តរបស់រ៉ុនស្ថិតនៅលើកំពូលអាងត្រីដែលពោរពេញទៅដោយពងកង្កែបនៅលើទ្វារបង្អួច នៅជាប់នឹងកណ្តុរពណ៌ប្រផេះដ៏ធាត់របស់វា ស្កេបប៊ើរ ដែលកំពុងតែដេកនៅក្រោមចំណិតនៃពន្លឺព្រះអាទិត្យ។

ហេរីបានបោះជំហានទៅលើកញ្ចប់បៀរសាប់ដោយឯងៗនៅលើកម្រាល ហើយមើលចេញទៅក្រៅបង្អួចដ៏តូចនោះ។ នៅក្នុងទីវាលយ៉ាងឆ្ងាយខាងក្រោម វាអាចឃើញក្រុមពួកមនុស្សកន្ទ្បៀកំពុងតែលបចូល ម្តងមួយៗ ត្រលប់ទៅកាន់ដើមឈើដែលដុះជាជួររបស់គ្រួសារវីស្លីវិញ។ បន្ទាប់មកវាក៏បែរទៅមើលរ៉ុន ដែលកំពុងតែសម្លឹងមើលវាយ៉ាងភ័យខ្លាច ហាក់ដូចជាកំពុងតែរង់ចាំនូវការបញ្ចេញគំនិតរបស់វា។

- វាតូចបន្តិចហើយ- រ៉ុនបានស្រដីយ៉ាងឆាប់រហ័ស។ - មិនដូចបន្ទប់ដែលឯងនៅជាមួយនឹងពួកលោកិយនោះទេ។ ហើយខ្ញុំស្ថិតនៅខាងក្រោមពួកមនុស្សកន្លៀក្នុងបន្ទប់តូចក្រោមដំបូលផ្ទះ វាតែងតែបោកក្បាលនឹងបំពង់ ហើយថ្ងូរតែរហូតហ្នឹង...

ប៉ុន្តែហេរី ដែលញញឹមយ៉ាងអស់ពីចិត្តពីថ្លើម បាននិយាយថា៖

- នេះគឺជាផ្ទះដ៏ល្អបំផុតដែលខ្ញុំធ្លាប់នៅ។

ត្រចៀករបស់រ៉ុនប្រែជាពណ៌ផ្កាឈូក។

**វគ្គ IV**



## នៅឯហាងហ្គារីស និងប្លត់

ជីវិតនៅប្ញវ៉្យអាចខុសប្លែកពីជីវិតនៅ ប្រាយវេដ ដ្រាយ។ គ្រួសារឌើស្លីចូលចិត្តអ្វីៗដែលរៀបចំបានស្អាត និងមានសណ្តាប់ធ្នាប់។ ផ្ទះរបស់គ្រួសារ វីស្លីពោរពេញទៅដោយរឿងចម្លែកៗ និងនឹកស្មានមិនដល់។ ហេរីតក់ស្លុតនៅពេលដំបូងដែលវាបានមើលទៅក្នុងកញ្ចក់លើផ្ទើរនៃឡកំដៅក្នុងផ្ទះបាយ ហើយឮវាស្រែកៈ

- ជីបអាវរបស់ឯងឲ្យស្រួលទៅ រញ៉េរញ៉ៃមែន!

សត្វប្រេតនៅក្នុងស្តាកនោះបានស្រែកលូ និងទម្លាក់បំពង់ចោលជារៀងរាល់ពេលឲ្យតែកាលណាវាគិតថាស្ងប់ស្ងាត់ពេក ហើយសម្លេងបន្ទុះតិចៗចេញពីបន្ទប់គេងរបស់ចច និងហ្វ្រេដគឺជារឿងធម្មតាទៅហើយ។ ទោះបីជាយ៉ាងណាក្តី អ្វីដែលហេរីបានជួបប្រទះយ៉ាងចម្លែកបំផុតក្នុងជីវិតនៅផ្ទះរបស់រ៉ុននោះគឺ មិនមែនកញ្ចក់ចេះនិយាយរឺប្រេតដែលមានសម្លេងច្រាវៗនោះទេៈ វាគឺជាការពិតមួយដែលថា អ្នកទាំងអស់នៅទីនោះហាក់ដូចជាចូលចិត្តវា។

លោកស្រីវីស្លីយកចិត្តទុកដាក់តាំងពីសភាពនៃស្រោមជើងរបស់វា ហើយព្យាយាមបង្ខំវាឲ្យញុំាបួនចានរាល់ពេលទទួលទានអាហារម្តងៗ។ លោកវីស្លីចូលចិត្តឲ្យហេរីអង្គុយក្បែរគាត់នៅតុអាហារពេលល្ងាច ដូច្នេះគាត់អាចជជីកសួរវានូវសំណួរជាច្រើនអំពីជីវិតរស់នៅជាមួយពួកលោកិយ ស្នើឲ្យវាពន្យល់ថាតើវត្ថុដូចជាឌុយភ្លើង និងសេវាកម្មប្រៃសណីយ៍ ដំណើរការទៅយ៉ាងដូចម្តេច។

- គួរឲ្យចាប់អារម្មណ៍មែន!- គាត់តែងនិយាយ ពេលហេរីនិយាយប្រាប់គាត់ពីបំរើបំរាស់ទូរស័ព្ទ។ - វិធីទំនាក់ទំនងគ្នាទាំងប៉ុន្មាន ដែលពួកលោកិយបានរកឃើញដោយមិនប្រើវេទមន្តពិតជាប៉ិនប្រសប់មែន។

ហេរីបានទទួលដំណឹងពីសាលា ហុកវ៉ាត នាព្រឹកព្រហាមមួយប្រហែលជាមួយសប្តាហ៍ក្រោយពីវាបានមកដល់ ប្ញវ៉្យ។ វា និងរ៉ុនបានចុះទៅញុំាអាហារពេលព្រឹក ជួបលោក និងលោកស្រីវីស្លី ព្រមទាំងជីននីដែលកំពុងអង្គុយរួចស្រេចនៅឯតុផ្ទះបាយ។ ខណៈពេលដែលនាងបានឃើញហេរី ជីននីបានធ្វើឲ្យធ្លាក់ចានបបររបស់នាងដោយចៃដន្យទៅលើកំរាលឥដ្ឋដោយសម្លេងលឺយ៉ាងខ្លាំងមួយ។ ជីននីហាក់ដូចជាឆាប់ធ្វើឲ្យរបស់របរធ្លាក់បែក នៅពេលណាក៏ដោយ ដែលហេរីចូលក្នុងបន្ទប់។ នាងលូនចូលក្រោមតុដើម្បីរកចានគោមនោះ ហើយងើបមកវិញជាមួយនឹងមុខក្រហមដូចពន្លឺព្រះអាទិត្យ។ ដោយធ្វើពុតជាមិនឃើញ ហេរីបានអង្គុយចុះ ហើយយកនំប៉័ងអាំងដែលលោកស្រីវីស្លីឲ្យវា។

- សំបុត្រពីសាលាមក- លោកវីស្លីនិយាយ ហុចឲ្យហេរី និងរ៉ុននូវស្រោមសំបុត្រក្រដាសស្បែកចៀមពណ៌លឿងខ្ចីដូចគ្នា និងបានចុះអាស័យដ្ឋានជាទឹកប៊ិចពណ៌បៃតង។

- ដាំប៉លដ័រ ដឹងហើយថាឯងនៅទីនេះ ហេរី។ លាក់ស្អីជាមួយគាត់ហ្នឹងមិនជិតទេ។ ឯងទាំងពីរក៏មានសំបុត្រដែរ- គាត់ពោលបន្ថែម នៅពេលហ្រ្វេដ និងចចដើរយឺតៗចូលមក ក្នុងសម្លៀកបំពាក់គេងរបស់ពួកគេនៅឡើយ។

មានភាពស្ងប់ស្ងាត់មួយភ្លែតនៅទីនោះ ពេលដែលពួកវាទាំងអស់បានអានសំបុត្ររបស់ពួកគេ។ សំបុត្ររបស់ហេរីបាន ប្រាប់វាឲ្យជិះរថភ្លើង ហុកវ៉ាតល្បឿនលឿន ដូចធម្មតាពីស្ថានីយ៍ ឃីញក្រុស នៅដើមខែកញ្ញា។ ហើយក៏មានបញ្ជីសៀវភៅថ្មីមួយដែរ ដែលវាត្រូវការសម្រាប់ឆ្នាំនេះ។

សិស្សឆ្នាំទីពីរនឹងត្រូវមានៈ

- សៀវភៅ គំរូនៃមន្តអាគមកំរិត ២ ដោយ មីរ៉ាន់ដា ហ្គូសហក។
- សៀវភៅ បំបែកព្រលឹង ដោយ ហ្គីលដឺរ័យ ឡក់ហាត
- សៀវភៅ ការធ្វើដំណើរជាមួយប្រែត ដោយ ហ្គីលដឺរ័យ ឡក់ហាត
- សៀវភៅ វិស្សមកាលជាមួយស្ត្រីមេធ្មប់ ដោយ ហ្គីលដឺរ័យ ឡក់ហាត
- សៀវភៅ ការធ្វើដំនើរជាមួយមនុស្សចម្លែក ដោយ ហ្គីលដឺរ័យ ឡក់ហាត
- សៀវភៅ ដំនើរតាមសមុទ្រជាមួយព្រាយជញ្ជក់ឈាម ដោយ ហ្គីលដឺរ័យ ឡក់ហាត
- សៀវភៅ ដំនើរគ្មានគោលដៅជាមួយមនុស្សចចក ដោយ ហ្គីលដឺរ័យ ឡក់ហាត
- សៀវភៅ រយៈពេលរស់នៅជាមួយមនុស្សព្រិលគួរឲ្យខ្ពើម ដោយ ហ្គីលដឺរ័យ ឡក់ហាត

ហ្រ្វេដដែលបានមើលបញ្ជីរបស់វារួចហើយ ក៏បែរមកមើលបញ្ជីរបស់ហេរី។

- ឯងក៏ត្រូវបានប្រាប់ឲ្យទិញសៀវភៅរបស់ ឡក់ហាត ទាំងអស់ដែរ!- វានិយាយ។ - គ្រូមុខវិជ្ជា ការពារប្រឆាំងនឹងមន្ត អាគមងងឹតថ្មីនោះ ប្រាកដជាអ្នកគាំទ្រម្នាក់របស់គាត់ហើយ...ភ្នាល់ទេថាគេគឺជាវេទគួស្រី។

ត្រង់ចំនុចនេះ ហ្រ្វេដបានប្រទាក់ភ្នែកម្តាយរបស់វា ហើយក៏ប្រញាប់ញ៉ាំដំណាប់ក្រូចយ៉ាងលឿន។

- សៀវភៅទាំងអស់នោះមិនថោកទេ- ចចនិយាយដោយសម្លឹងមើលយ៉ាងលឿនទៅឪពុកម្តាយរបស់វា។ - សៀវភៅរបស់ ឡក់ហាត ពិតជាថ្លៃណាស់...

- អឺ ពួកយើងនឹងចាត់ចែង- លោកស្រី វីស្លី និយាយ ប៉ុន្តែគាត់ដូចជាបារម្ភណាស់។ - ខ្ញុំគិតថាយើងនឹងទិញរបស់របរជជុះ ឲ្យជីននីបានច្រើន។

- អូ៎! តើនាងនឹងចូលរៀននៅសាលាហុកវ៉ាតឆ្នាំនេះរឺ?- ហេរីសួរជីននី។

នាងងក់ក្បាល មុខប្រែជាក្រហមដូចពណ៌សក់របស់នាង ហើយបានដាក់កែងដៃរបស់នាងចូលក្នុងចានបបរ។ សំនាងល្អ ដែលគ្មាននរណាឃើញ លើកលែងហេរី ពីព្រោះអំបាញ់មិញនេះ ពើរស៊ី បងប្រុសរបស់រ៉ុន បានដើរចូលមក។ វាបានស្លៀកពាក់រួច ហើយ ហើយផ្លាកសំគាល់ដ៏ស្រស់ស្អាត ហុកវ៉ាត របស់វាក៏បានខ្ទាស់នឹងអាវចាក់វាលក្លៀករបស់វារួចដែរ។

- អរុណសួស្តី អ្នកទាំងអស់គ្នា- ពើរស៊ីនិយាយយ៉ាងរហ័ស។ - ពិតជាថ្ងៃល្អមែន។

វាបានអង្គុយចុះលើកៅអី ដែលនៅសល់តែមួយប៉ុណ្ណោះ ប៉ុន្តែវាលោតឡើងស្ទើរតែភ្លាមៗ ដោយបានទាញចេញពីក្រោម គូទវាមកនូវរោមសត្វពណ៌ប្រផេះ...ដំបូងហេរីគិតថាវាគ្រាន់តែជារោមសត្វប៉ុណ្ណោះ ស្រាប់តែឃើញថាវាចេះដកដង្ហើម។

## នៅម៉ោងហ្ការីស និងប្លត់

- អេរ៉ូល!- រ៉ុននិយាយ យកសត្វទីទុយដ៏ទន់ខ្សោយនោះពី ពៀរស៊ី ហើយបានដកយកសំបុត្រមួយច្បាប់ពីក្រោមស្លាបរបស់វា។ - ជាចុងក្រោយ...វាទទួលបានការឆ្លើយតបរបស់ ហឺម៉ាយអូនីហើយ។ ខ្ញុំបានសរសេរទៅនាង ដោយប្រាប់ថា ពួកយើងនឹងព្យាយាមជួយសង្គ្រោះឯងពីគ្រួសារ ឌើស្លី។

វាបានយក អេរ៉ូល ទៅទ្រុងនៅខាងក្នុងទ្វារផ្ទះក្រោយ ហើយព្យាយាមឲ្យវាឈរលើទ្រុងនោះ ប៉ុន្តែអេរ៉ូលធ្លាក់ចុះមកទៀត ដូច្នេះ រ៉ុន ទុកវានៅលើទូដាក់ចានជំនួសវិញ ដោយនិយាយតិចៗថា៖

- ពិតជាគ្មានបានការមែន។

ក្រោយមក វាហែកសំបុត្ររបស់ ហឺម៉ាយអូនីមើលរួចអានឮៗ៖

*រ៉ុនជាទីនឹករលឹក និងហេរីប្រសិនបើឯងនៅទីនោះដែរ*

*ខ្ញុំសង្ឃឹមថា គ្រប់យ៉ាងមិនអីទេ ហើយហេរីបានសុខសប្បាយ ថែមទាំងសង្ឃឹមថា ឯងមិនបានធ្វើអ្វីខុសច្បាប់ ដើម្បីទៅយកហេរីចេញមក រ៉ុន ព្រោះថា រឿងនេះក៏អាចនាំបញ្ហាឲ្យវាផងដែរ។ ខ្ញុំពិតជាព្រួយបារម្ភណាស់ ហើយប្រសិនបើ ហេរី មិនអីនោះ សូមឯងប្រាប់ឲ្យខ្ញុំដឹងភ្លាម ប៉ុន្តែប្រហែលជាប្រសើរជាង បើឯងប្រើទីទុយផ្សេងមួយទៀត ពីព្រោះខ្ញុំគិតថា បើប្រើវានាំសារមកទៀតនោះ អាចធ្វើឲ្យវាអស់កំលាំងណាស់។*

*ជាការពិតណាស់ ខ្ញុំរវល់ជាមួយកិច្ចការសាលាខ្លាំងមែនទែន។*

- តើនាងអាចធ្វើបានយ៉ាងម៉េចទៅ?- រ៉ុននិយាយដោយភ្ញាក់ផ្អើល។ - ពួកយើងកំពុងវិស្សមកាលណា!

*ហើយពួកយើងនឹងនៅទីក្រុងឡុងនៅថ្ងៃពុធក្រោយ ដើម្បីទិញសៀវភៅថ្មី។ ហេតុអ្វីក៏ពួកយើងមិនទៅជួបគ្នានៅផ្លូវកាត់ទទឹងទៅ?*

*សូមឲ្យខ្ញុំដឹងនូវអ្វីដែលកំពុងកើតឡើងកាន់តែឆាប់តាមដែលឯងអាច។ ដោយក្តីស្រឡាញ់ពី ហឺម៉ាយអូនី។*

- អឺ ធ្វើអញ្ចឹងហើយទើបល្អ ពួកយើងក៏អាចទៅទិញរបស់របរទាំងអស់របស់ពួកឯងនៅពេលនោះដែរ- លោកស្រីវីស្លីនិយាយ ចាប់ផ្តើមសំអាតតុ។ - តើពួកឯងនឹងធ្វើអ្វីខ្លះថ្ងៃនេះ?

ហេរី រ៉ុន ហ្វ្រេដ និងចចមានគំរោងឡើងភ្នំដើម្បីទៅក្រោលចិញ្ចឹមសេះតូចមួយដែលគ្រួសារវីស្លីជាម្ចាស់។ ក្រោលសេះនោះត្រូវបានព័ទ្ធជុំវិញទៅដោយដើមឈើ ដែលបាំងជិតមើលមិនឃើញទេសភាពភូមិនៅខាងក្រោម ដូចនេះហើយពួកគេអាចហ្វឹកហាត់កីឡាឃ្វីដឌីចនៅទីនោះយូរប៉ុណ្ណាក៏បាន បើពួកគេមិនហោះទៅខ្ពស់ពេក។ ពួកគេមិនអាចប្រើបាល់ ឃ្វីដឌីច ពិតបានទេ ដែលអាចនឹងលំបាកប្រសិនបើពួកគេត្រូវគេច ហើយហោះឆ្ងាយនៅពីលើភូមិ។ ពួកគេបានគ្រវែងផ្លែប៉ោមទៅគ្នាដើម្បីចាប់ជំនួសវិញ។ ពួកគេ

ប្អូនវែនគ្នាម្តងម្នាក់ជិះអំបោស នីមប៊ូស ២០០០ របស់ហេរី ដែលជាអំបោសដ៏ល្អបំផុត។ សូម្បីតែមេអំបៅក៏ហោះលឿនជាង អំបោសផ្កាយរន្ទះ ចាស់របស់រ៉ុនដែរ។

ប្រាំនាទីក្រោយមក ពួកគេដើរជាក្បួនឡើងទៅភ្នំ ដាក់អំបោសហោះលើស្មារបស់ពួកគេ។ ពួកគេបានសួរ ពឿរស៊ី ថាតើវាចង់ចូលរួមជាមួយពួកគេរឺទេ ប៉ុន្តែវានិយាយថាវារវល់។ ហេរីបានជួប ពឿរស៊ី នៅពេលញ៉ាំអាហារតែប៉ុណ្ណោះ រហូតមកដល់ពេលនេះ។ វានៅតែក្នុងបន្ទប់បិទជិតរបស់វាប៉ុណ្ណោះក្រៅពីពេលនោះ។

- ខ្ញុំសង្ស័មថាបានដឹងនូវរឿងអ្វីដែលវាបានជួបប្រទះ- ហ្វ្រេដនិយាយទាំងចងចិញ្ចើម។ - វាមិនដូចជាខ្លួនវាទៀតទេ។ លទ្ធផលប្រលងរបស់វាបានចេញមុនថ្ងៃដែលពួកឯងបានប្រលង។ វាធ្វើ ក.ប.វ.ក.ស. បានដប់ពីរពិន្ទុ ហើយវាស្ទើរតែមិនមើលទៅដោយភាពពេញចិត្តទាល់តែសោះ។

- ពាក្យពេញគឺ ការប្រលងវេទមន្តកំរិតសាមញ្ញ- ចចពន្យល់ដោយឃើញនូវការមិនយល់របស់ហេរី។ - ប៊ីលក៏ទទួលបានដប់ពីរដែរ។ ប្រសិនបើពួកយើងមិនប្រយ័ត្នទេ យើងនឹងមានអនុរក្សក្រុមសិស្សច្បងម្នាក់ទៀតនៅក្នុងគ្រួសារហើយ។ ខ្ញុំមិនគិតថា ខ្ញុំអាចទ្រាំទ្រនូវភាពអាម៉ាសនោះទេ។

ប៊ីលគឺជាបងប្រុសគេបង្អស់ក្នុងត្រកូលវីស្លី។ គាត់ និងបងប្រុសបន្ទាប់ ឆាលី បានឈប់រៀននៅសាលា ហុកវ៉ាតហើយ។ ហេរីមិនដែលបានជួបម្នាក់សោះក្នុងចំនោមពួកគេ ប៉ុន្តែវាដឹងថាឆាលីនៅប្រទេសរ៉ូម៉ានី កំពុងសិក្សាពីសត្វនាគ ហើយនិងប៊ីលនៅប្រទេសអេហ្ស៊ីប កំពុងធ្វើការឲ្យធនាគាររបស់វេទគូ ហ្គ្រីង្គហុត។

- ខ្ញុំមិនដឹងថាតើម៉ាក់ និងប៉ានឹងលៃលកយ៉ាងណាចំពោះសំភារៈសិក្សារបស់ពួកយើងទាំងអស់គ្នានៅឆ្នាំនេះទេ- ចចនិយាយនៅមួយសន្ទុះក្រោយមក។ - សៀវភៅរបស់ ឡក់ហាត ទាំងប្រាំប្រភេទ! ហើយជីននីត្រូវការរ៉ូប និងចង្កឹះវេទមន្តមួយដើមហើយនៅអ្វីៗគ្រប់យ៉ាងទៀត...

ហេរីមិននិយាយអ្វីសោះ។ វាមានអារម្មណ៍ខ្មាសអៀនបន្តិច។ អ្វីដែលស្តុកទុកក្នុងបន្ទប់ក្រោមដីនៅហ្គ្រីង្គហុតទីក្រុងឡុង គឺជាទ្រព្យសម្បត្តិដែលឪពុកម្តាយវាបានបន្សល់ទុកឲ្យវា។ ពិតណាស់ វាមានលុយបានតែនៅក្នុងពិភពវេទមន្តប៉ុណ្ណោះ។ អ្នកមិនអាចចាយលុយហ្កាលទ្បូន ស៊ីកគ័ល និងណាត់ក្នុងហាងពួកលោកិយបានទេ។ វាមិនដែលនិយាយពីគណនីក្នុងធនាគារហ្គ្រីងហុតប្រាប់ដល់គ្រួសារវេឌីស្លីទេ។ វាមិនបានគិតថា ភាពភ័យខ្លាចរបស់ពួកគេចំពោះអ្វីៗដែលទាក់ទងនឹងវេទមន្តនោះអាចនឹងទាមទារវិញនូវមាសមួយពំនូកធំនោះទេ។

លោកស្រីវីស្លីបានដាស់ពួកគេទាំងអស់គ្នាឲ្យភ្ញាក់តាំងពីព្រលឹមនៅថ្ងៃពុធក្រោយមក។ បន្ទាប់ពីម្នាក់ៗបានញ៉ាំសាន់វិចសាច់ជ្រូកអស់ប្រាំមួយដុំយ៉ាងលឿនរួចមក ពួកគេបានពាក់អាវធំ ហើយអ្នកស្រីវីស្លីបានយកជើងផ្កាមួយចេញពីលើធ្នើរឡកំដៅក្នុងផ្ទះបាយ និងអើតមើលទៅខាងក្នុង។

- ពួកយើងជិតប្រើវាអស់ហើយ អស់សី- គាត់ដកដង្ហើមធំ។ - យើងត្រូវទិញថែមទៀតនៅថ្ងៃនេះ...អ៎ា! មែនហើយ ភ្ញៀវមុន! ត្រូវឯងមុន ហេរីក្មួយសម្លាញ់!

គាត់បានឲ្យជើងផ្កានោះទៅវា។

ហេរីសម្លឹងទៅពួកគេទាំងអស់ដែលកំពុងមើលវា។

- ត...តើខ្ញុំនឹងត្រូវធ្វើអ្វីទៅ?- វានិយាយជាប់ៗ។

- វាមិនដែលធ្វើដំនើរដោយប្រើម្សៅភ្លូទេ- រ៉ុននិយាយភ្លាម។ - សុំទោស ហេរី ខ្ញុំភ្លេចទៅ។

- មិនដែលទេរឺ?- លោកវីស្លីនិយាយ។ - ប៉ុន្តែ តើឯងទៅផ្លូវកាត់ទទឹងដើម្បីទិញសំភារៈសិក្សារបស់ឯងកាលពីឆ្នាំមុនដោយសារអ្វីទៅ?

- ខ្ញុំបានទៅតាមផ្លូវក្រោមដី...

- ពិតរឺ?- លោកវីស្លីនិយាយទាំងចាប់អារម្មណ៍។ - តើមានជណ្តើរយន្តទេ? តើវាប្រាកដ...

- មិនមែនពេលនេះទេ អស់សឺ- លោកស្រីវីស្លីនិយាយ។ - ក្មួយសម្លាញ់ ម្សៅភ្លូគឺលឿនជាងច្រើនណាស់ ប៉ុន្តែពុទ្ធោ! ប្រសិនបើឯងមិនដែលប្រើវាពីមុន...

- វានឹងមិនអីទេណា ម៉ាក់- ហ្វ្រេដនិយាយ។ - ហេរី ចាំមើលពួកយើងមុនណា។

វាយកម្សៅភ្លីបន្តិចចេញពីក្នុងផើង ឈានចូលទៅក្នុងភ្លើង ហើយបាចម្សៅនោះទៅក្នុងអណ្តាតភ្លើង។

ដោយមានស្នូរមួយបន្លឺឡើង ភ្លើងបានប្រែជាពណ៌បៃតងភ្លឺ ហើយផ្ទុះឡើងខ្ពស់ជាង ហ្វ្រេដ ដែលបានឈានជើងចូលក្នុងនោះអំបាញ់មិញ រួចស្រែកថា៖ - ផ្លូវកាត់ទទឹង!- ហើយក៏បាត់ខ្លួនទៅ។

- ក្មួយសម្លាញ់ ឯងត្រូវនិយាយឲ្យច្បាស់ៗ- លោកស្រីវីស្លីប្រាប់ហេរីនៅពេលដែលចចបានដាក់ដៃរបស់វាចូលទៅក្នុងផើង។ - ហើយដែលសំខាន់គឺចេញទៅដល់កន្លែងត្រឹមត្រូវនោះ...

- ត្រឹមត្រូវអ្វីទៅ?- ហេរីនិយាយទាំងមិនដឹងអី ពេលដែលភ្លើងបានផ្ទុះសូរ ហើយនាំចចចេញពីកន្លែងនោះផងដែរ។

- អឺ ឯងដឹងទេថា មានភ្លើងវេទមន្តអាក្រក់នៅចំរុះគ្នាជាច្រើនដែលត្រូវជ្រើសរើស ប៉ុន្តែយ៉ាងណាក៏ដោយឲ្យតែឯងនិយាយឲ្យបានច្បាស់...

- វានឹងមិនអីទេ ម៉ូលី កុំបារម្ភអី- លោកវីស្លីនិយាយ កំពុងតែយកម្សៅភ្លូសម្រាប់ខ្លួនគាត់ដែរ។

- ប៉ុន្តែបងសម្លាញ់ ប្រសិនបើវាវង្វេងនោះ តើពួកយើងនឹងត្រូវពន្យល់ពូមីងរបស់វាយ៉ាងម៉េចទៅ?

- ពួកគាត់មិនប្រកាន់ទេ- ហេរីបញ្ជាក់ឲ្យគាត់ទុកចិត្ត។ - ដាត់លីនឹងគិតថាវាជារឿងកំប្លែងដ៏អស្ចារ្យមួយប្រសិនបើខ្ញុំវង្វេងក្នុងបំពង់ផ្សែងមួយនោះ កុំបារម្ភពីរឿងនោះអី។

- អឺ...មែនហើយ...មីងទៅបន្ទាប់ពីអស់សឺ- អ្នកស្រីវីស្លីនិយាយ។ - ឥឡូវ ពេលដែលឯងចូលទៅក្នុងភ្លើង ត្រូវនិយាយឈ្មោះទីកន្លែងដែលឯងនឹងទៅ...

- ហើយដាក់កែងដៃរបស់ឯងចូលក្នុង- រ៉ុនផ្តល់យោបល់។

- ហើយភ្នែករបស់ឯងបិទ- អ្នកស្រីវីស្លីនិយាយ។ - ម្រែងភ្លើង...

- នៅឲ្យស្ងៀម- រ៉ុននិយាយ។ - បើមិនអញ្ចឹងទេ ឯងអាចនឹងធ្លាក់ចេញទៅឡចង្ក្រានផ្សេង...

- ប៉ុន្តែកុំភ័យ ហើយកុំចេញទៅលឿនពេក រង់ចាំរហូតទាល់តែឯងជួប ហ្វ្រេដ និងចច។

ដោយព្យាយាមយ៉ាងខ្លាំងដើម្បីចងចាំចំនុចទាំងអស់នេះក្នុងចិត្ត ហេរីបានយកម្សៅភ្លូបន្តិច ហើយដើរទៅឈរមុខភ្លើង។ វាដកដង្ហើមធំ បាចម្សៅទៅក្នុងអណ្តាតភ្លើង ហើយឈានជើងសំដៅទៅ។ ភ្លើងហាក់ដូចជាខ្យល់ដ៏កក់ក្តៅមួយ។ វាបើកមាត់របស់វា ហើយភ្លាមៗនោះវាបានលេបផេះក្តៅយ៉ាងច្រើន។

- ផ...ផ្លូវ...កាត់ ទទឹង- វាបានក្អក។

# នៅហាងហ្គារីស និងប្លត់

វាមានអារម្មណ៍ហាក់ដូចជា វាបានកំពុងត្រូវធាក់ចេញពីប្រហោងខុយភ្លើងដ៏ធំមួយ។ វាហាក់ដូចជាត្រូវបង្វិលយ៉ាងលឿន ...សម្លេងពាទឹក្នុងត្រចៀករបស់វាកំពុងធ្វើឲ្យហឹង...វាព្យាយាមបើកភ្នែករបស់វា ប៉ុន្តែចលនាយ៉ាងរហ័សនៃអណ្តាតភ្លើងពណ៌បៃតងធ្វើឲ្យវាឈឺ...វត្ថុរឹងមួយបានបុកកែងដៃរបស់វា ហើយរុញវាចូលវិញ នៅតែបង្វិលហើយបង្វិលទៀត...ឥឡូវ វាមានអារម្មណ៍ដូចជាមានដៃត្រជាក់កំពុងទះមុខរបស់វា...ដោយបើកភ្នែកមើលព្រឹមៗតាមវ៉ែនតារបស់វា វាបានឃើញឡកំដៅមួយក្នុងសភាពព្រិលៗ និងគ្រលៀសភ្នែកមួយភ្លែតទៅឃើញបន្ទប់នៅខាងមុខ ... នំសាន់វិចសាច់ជ្រូករបស់វាកំពុងតែរើក្នុងក្រពះ ... វាបិទភ្នែកម្តងទៀត បន់ឲ្យឈប់ ហើយបន្ទាប់មក វាបានដួលផ្កាប់មុខទៅលើថ្មត្រជាក់ ហើយក៏ធ្លាក់វ៉ែនតាបែក។

ដោយវិលមុខ និងមានស្នាមជាំ ហើយប្រលាក់សុទ្ធតែផេះទៀតនោះ វាបានកំរើកជើងរបស់វាថ្មមៗ កាន់វ៉ែនតាបែករបស់វាយកមកមើល។ វានៅតែម្នាក់ឯងគត់ ប៉ុន្តែកន្លែងដែលវានៅ វាមិនស្គាល់ទេ។ វាអាចនិយាយប្រាប់បានថា វាកំពុងតែឈរនៅក្នុងថ្មឡកំដៅ ដែលមើលទៅដូចជាហាងរបស់វេទគួយ៉ាងងងឹតមួយ... ប៉ុន្តែគ្មានអ្វីនៅទីនេះដែលមានដូចក្នុងបញ្ជីសាលាហុក្វាតសោះ។

ប្រអប់កែវមួយនៅជិតនោះដែលមានដាក់ប្រអប់ដៃក្រិនម្ខាងនៅលើខ្នើយទ្រាប់ បៀក្នុងហ៊ូដែលមានស្នាមឈាមមួយហ៊ូ និងភ្នែកសិប្បនិម្មិតមួយចំហៀង។ របាំងមុខដ៏អាក្រក់ជាច្រើនដាក់បន្តុបនៅជាប់ជញ្ជាំងបែរទៅក្រោម....ល្បាយនៃឆ្អឹងមនុស្សបានដាក់នៅលើតុតាំងទំនិញ ហើយមានច្រែះស៊ី និងឧបករណ៍ផ្សេងទៀតព្យួរនៅលើពិតាន។ អាក្រក់ជាងនេះទៅទៀត ផ្លូវតូចចង្អៀតដ៏ងងឹតនោះ ដែលហេរីអាចមើលឃើញតាមបង្អួចហាងសុទ្ធតែធូលី គឺពិតជាមិនមែននៅផ្លូវកាត់ទទឹងទេ។

ជាការប្រសើរ វាបានចេញពីទីនោះយ៉ាងឆាប់។ ច្រមុះវានៅតែឈឺត្រង់កន្លែងបុកនឹងបាតឡកំដៅ។ ហេរីដើរចេញយ៉ាងរហ័សស្ងាត់ៗសំដៅទៅទ្វារ ប៉ុន្តែមុនពេលវាដើរបានពាក់កណ្តាលផ្លូវ បុរសពីរនាក់បានបង្ហាញខ្លួននៅខាងប៉ែកមួយទៀតនៃកញ្ចក់...ម្នាក់ក្នុងចំនោមពួកគេគឺជាមនុស្សតែម្នាក់គត់ដែលហេរីមិនចង់ជួបនៅពេលវាវង្វេង ហើយមានប្រលាក់សុទ្ធតែផេះ និងពាក់វ៉ែនតាបែកទៀតនោះ គឺដ្រាកូ មេលហ្វ័យ។

ហេរីសំឡឹងមើលជុំវិញយ៉ាងលឿន ហើយបានរកឃើញទូពណ៌ខ្មៅធំមួយនៅខាងឆ្វេងវា។ វាស្ទុះចូលទៅក្នុងនោះ ហើយទាញទ្វារបិទដោយទុកប្រហោងតូចមួយសម្រាប់មើលមកក្រៅ។ បន្តិចក្រោយមក កណ្តឹងមួយបានរោទិ៍ឡើង ហើយមេលហ្វ័យក៏បានឈានជើងចូលក្នុងហាង។

បុរសម្នាក់ដែលដើរតាមនោះមានតែឪពុកវាប៉ុណ្ណោះ។ គាត់មានសំបុរសដូចវា មុខស្រួច និងភ្នែកពណ៌ប្រផេះស្រាលស្មើរតែដូចគ្នាបេះបិត។ លោកមេលហ្វ័យឆ្លងកាត់ហាង សំលឹងមើលយឺតៗទៅទំនិញនៅ លើតុតាំង ហើយបានចុចកណ្តឹងនៅលើតុតាំងទំនិញនោះ ក្រោយមកក៏បែរមករកកូនប្រុស ហើយនិយាយថា៖

- កុំប៉ះអ្វីអោយសោះ ដ្រាកូ។

មេលហ្វ័យ ដែលហៀបនឹងឈោងយកកែវភ្នែកកញ្ចក់ទៅហើយនោះ ក៏តបវិញ៖

- ខ្ញុំគិតថាប៉ានឹងទិញអំណោយឲ្យខ្ញុំមួយ។

- ប៉ានិយាយថាប៉ានឹងទិញអំបោសប្រកួតមួយឲ្យឯង- ប៉ារបស់វានិយាយ គោះម្រាមដៃរបស់គាត់នៅលើតុនោះ។

- តើនោះមានអ្វីល្អទៅ បើកូនមិននៅក្នុងក្រុមម្ចាស់ផ្ទះផង?- មេលហ្វ័យនិយាយ មើលទៅដោយមិនសប្បាយចិត្ត និងខឹងយ៉ាងខ្លាំង។ - ហេរី ផោតធ័រ ទទួលបានអំបោសនីមប៊ូស ២០០០ កាលពីឆ្នាំមុន។ ដោយមានការអនុញ្ញាតជាពិសេសពី ដាំប័លដ័រ

ដូច្នេះវាអាចលេងឲ្យក្រុមហ្វ្រីហ្វិនដ័របាន។ វាមិនល្អអីណាស់ណាទេ។ ក៏ព្រោះតែមកពីវាល្បី...ល្បីដោយសារតែមានស្លាកស្នាមដ៏ឆ្កួតៗមួយនៅ លើថ្ងាសរបស់វា...

មេលហ្វ័យអានមើលផ្ទើរមួយពេញទៅដោយឆ្អឹង។

-...អ្នករាល់គ្នាគិតថាវាឆ្លាតណាស់ ផោតផ័រដ៏អស្ចារ្យជាមួយនឹងស្លាកស្នាមរបស់វា និងអំបោសរបស់វា...

- ឯងបានប្រាប់ប៉ានូវរឿងនេះយ៉ាងហោចណាស់ដប់ពីរដងមកហើយ- លោកមេលហ្វ័យនិយាយ ដោយទឹកមុខសង្ស័យមើលទៅកូនប្រុសរបស់គាត់ - ហើយប៉ាក៏ចង់រំលឹកឯងដែរថា...ចាំស្តាប់នែ៎...មិនត្រូវបង្ហាញអោយគេឃើញថាឯងស្អប់ហេរី ផោតផ័រខ្លាំងពេកនោះទេ ពីព្រោះពេលនេះ ពួកវេទគូភាគច្រើនចាត់ទុកវា ដូចជាវីរបុរសដែលបានធ្វើឲ្យមេវេទគួងងឹតរលាយបាត់ខ្លួន...អ៊ា! លោក បូហ្គីន។

បុរសខ្នងកោងម្នាក់បានលេចមុខពីក្រោយតុតាំងទំនិញ កំពុងតែរ៉េកពង្រាបសក់ដែលមានប្រេងរបស់គាត់ចេញពីមុខរបស់គាត់។

- លោកមេលហ្វ័យ រីករាយណាស់ដែលបានជួបលោកម្តងទៀត- លោកបូហ្គីននិយាយក្នុងសំឡេងយ៉ាងរអិលព្រាល់ដូចសក់របស់គាត់។ - ពិតជារីករាយណាស់...មានទាំងលោកម្ចាស់មេលហ្វ័យដ៏វ័យក្មេងផងដែរ...គួរអោយស្រឡាញ់ណាស់។ តើលោកមានការអ្វីដែរ? ខ្ញុំត្រូវតែបង្ហាញលោក ត្រឹមតែក្នុងថ្ងៃនេះនិងតំលៃសមរម្យបំផុត...

- ខ្ញុំមិនទិញអ្វីទេថ្ងៃនេះ លោកបូហ្គីន ប៉ុន្តែលក់- លោកមេលហ្វ័យនិយាយ។

- លក់រឺ?- ស្នាមញញឹមបានបាត់បន្តិចម្តងៗពីមុខរបស់លោកបូហ្គីន។

- តាមពិតទៅ លោកបានឮថា ក្រសួងកំពុងតែដឹកនាំការចុះត្រួតពិនិត្យកាន់តែច្រើនឡើង- លោកមេលហ្វ័យនិយាយដោយយកក្រដាសស្បែកចៀមមួយដុំពីខាងក្នុងហោប៉ៅរបស់គាត់ ហើយបានស្រាយវាឲ្យលោកបូហ្គីនអាន។ - ខ្ញុំមាន...អា...មុខទំនិញពីរបីនៅផ្ទះដែលអាចធ្វើឲ្យខ្ញុំអាម៉ាស់ ប្រសិនបើក្រសួងត្រូវហៅ...

លោកបូហ្គីនតំរូវវ៉ែនតាឲ្យស្រួលមកច្រមុះរបស់គាត់ ហើយពិនិត្យបញ្ជីនោះ។

- ក្រសួងពិតជាហ៊ានបង្កបញ្ហាដល់លោកប្រាកដមែនរឺ?

បបូរមាត់របស់លោកមេលហ្វ័យឡើងរួញ។

- ខ្ញុំនៅមិនទាន់បានទៅមើលនៅឡើយ។ ឈ្មោះមេលហ្វ័យនៅសក្តិសមនឹងទទួលបាននូវការគោរពដ៏ពិតប្រាកដមួយ តែក្រសួងប្រែជាចូលចិត្តជ្រៀតជ្រែកខ្លាំងឡើង។ មានពាក្យចចាមអារ៉ាមពីសកម្មភាពការពាររបស់ពួកលោកិយថ្មីមួយ...គ្មានអ្វីត្រូវសង្ស័យពីបញ្ហាបន្តិចបន្តួចនោះទេ គឺ អស់ស៊ី វីស្លី ឆ្កួតដែលស្រឡាញ់ពួកលោកិយ នៅពីក្រោយរឿងនោះ...

ហេរីមានអារម្មណ៍ខឹងកញ្ជ្រោលឡើងមួយ។

-...ហើយដូចដែលលោកឃើញស្រាប់ហើយ ធាតុពិតនៃថ្នាំពុលទាំងនេះអាចធ្វើឲ្យលេចឡើង...

- ខ្ញុំយល់ហើយ លោក ប្រាកដណាស់- លោកបូហ្គីននិយាយ - ទុកឲ្យខ្ញុំមើល...

- តើខ្ញុំអាចយកអានេះបានទេ?- ដ្រាកូនិយាយកាត់ ចង្អុលទៅប្រអប់ដៃក្រិននោះនៅលើខ្នើយទ្រាប់របស់វា។

- អា! ដៃនៃភាពរុងរឿង!- លោកបូហ្គីនឧទានឡើង បោះបញ្ជីរបស់លោកមេលហ្វ៊យចោល ហើយដើរយ៉ាងលឿនទៅដ្រាកូ។ - បញ្ចូលទៀនមួយទៅ ហើយវានឹងផ្តល់ពន្លឺដល់ត្រឹមតែអ្នកកាន់វាប៉ុណ្ណោះ! មិត្តដ៏ល្អបំផុតរបស់ចោរ! កូនប្រុសរបស់លោកមានចំនូលចិត្តខ្លាំងណាស់ លោក។

- ខ្ញុំសង្ឃឹមថាកូនប្រុសរបស់ខ្ញុំនឹងមានឥទ្ធិពលលើសពីចោរម្នាក់ទៅទៀត បូហ្គីន- លោកមេលហ្វ៊យនិយាយទាំងសោះកក្រោះ ហើយលោកបូហ្គីននិយាយយ៉ាងលឿនថា៖ - កុំប្រកាន់អី លោក កុំប្រកាន់ថា...

- ទោះជាយ៉ាងណាក្តី បើពិន្ទុនៅសាលារបស់វាមិនឡើងនោះទេ- លោកមេលហ្វ៊យនិយាយទាំងនៅតែសោះកក្រោះ - អញ្ចឹងមុខរបរលួចប្លន់នេះប្រហែលជាសក្តិសមនឹងវាហើយ។

- វាមិនមែនជាកំហុសរបស់ខ្ញុំទេ- ដ្រាកូឆ្លើយតបយ៉ាងលឿន។ - គ្រូទាំងអស់មានអ្នកដែលគេពេញចិត្ត ហឺម៉ាយអូនីហ្គ្រេនជឺរ ស្អីគេនោះ...

- ប៉ាបានគិតថាឯងនឹងត្រូវអាម៉ាស់ដោយសារក្មេងស្រីនៃគ្រួសារធម្មតាម្នាក់នោះផ្តួលឯងរាល់ការប្រលងហើយ- លោកមេលហ្វ៊យនិយាយម៉ាត់ៗ។

- ហា!- ហេរីនិយាយតិចៗ ដោយសប្បាយរីករាយក្នុងការឃើញដ្រាកូស្ថិតក្នុងសភាពឲ្យអាម៉ាស់មុខ និងមានកំហឹង។

- វាគឺដូចគ្នាតែទាំងអស់ហ្នឹង!- លោកបូហ្គីននិយាយក្នុងសំឡេងយ៉ាងរអិលព្រាល់របស់គាត់។ - ឈាមជ័រវេទគួកំពុងតែមានចំនួនតិចទៅៗគ្រប់ទីកន្លែង...

- មិនដោយទាំងខ្ញុំទេ- លោកមេលហ្វ៊យនិយាយ រន្ធច្រមុះវែងៗរបស់គាត់រីកធំបន្តិចម្តងៗ។

- ទេ លោក ក៏មិនដោយទាំងខ្ញុំដែរ លោក- លោកបូហ្គីននិយាយដោយអោនបន្ទាបខ្លួន។

- បើអញ្ចឹងហើយ យើងប្រហែលជាអាចងាកមកមើលបញ្ជីរបស់ខ្ញុំវិញ- លោកមេលហ្វ៊យនិយាយយ៉ាងខ្លី។ - ខ្ញុំកំពុងតែប្រញាប់ បូហ្គីន ខ្ញុំត្រូវធ្វើមុខជំនួញសំខាន់ៗនៅកន្លែងផ្សេងទៀតនាថ្ងៃនេះ។

ពួកគេចាប់ផ្តើមតថ្លៃ។ ហេរីបានមើលទាំងភ័យខ្លាច នៅពេលដ្រាកូធ្វើចលនាកាន់តែជិតទៅៗមករកកន្លែងលាក់ខ្លួនរបស់វា កំពុងពិនិត្យមើលរបស់ប្រើប្រាស់សំរាប់លក់។ វាឈប់មួយភ្លែតដើម្បីមើលខ្សែពួរសំរាប់ឃាតករមួយចង្វាយវែង និងពិនិត្យមើលបន្ទះមួយមានទ្រខ្សែកត្បូងសដ៏ស្រស់ស្អាតមួយខ្សែ៖ បំរាម "ហាមប៉ះពាល់។ មានបណ្តាសា...បានទាក់យកជីវិតម្ចាស់ជាពួកលោកិយអស់ដប់ប្រាំបួននាក់ហើយអាស្រ័យទៅតាមកាលបរិច្ឆេទ។"

ដ្រាកូបែរមកមើល ហើយបានឃើញទូនោះភ្លាមនៅពីមុខវា។ វាដើរសំដៅទៅ...វាឈោងដៃទាញដៃទ្វារទូនោះ...

- រួចរាល់ហើយ- លោកមេលហ្វ៊យនិយាយនៅតុតាំងទំនិញ។ - មក ដ្រាកូ!

ហេរីយកដៃជូតថ្ងាសរបស់វានៅពេលដែលដ្រាកូបញ្ឈប់សកម្មភាពទៅ។

- សូមឲ្យមានសំណាងល្អ លោកបូហ្គីន ខ្ញុំសង្ឃឹមថាលោកនឹងទៅភូមិគ្រឹះនោះនៅថ្ងៃស្អែកដើម្បីយកទំនិញ។

ខណៈនោះទ្វារបានបិទ លោកបូហ្គីនបញ្ឈប់នូវឫកពាសុភាពគួរសមរបស់គាត់។

- សូមឲ្យសំណាងល្អ លោកមេលហ្វ៊យ ហើយបើរឿងរ៉ាវទាំងនោះវាពិតមែន លោកមិនដែលបានលក់ឲ្យខ្ញុំសូម្បីតែពាក់កណ្តាលនូវអ្វីដែលបានលាក់ទុកក្នុងភូមិគ្រឹះនោះផង...

ដោយនិយាយរអ៊ូរទាំអស់យ៉ាងច្រើន លោកបូហ្គីនបានរលាយបាត់ខ្លួនទៅតាមបន្ទប់ខាងក្រោយ។

## នៅហាងហ្គារីស និងប្លត់

ក្រោយមក ហេរីបានរង់ចាំបន្តិច រួចវាបានចេញមកយ៉ាងស្ងាត់ៗតាមដែលវាអាចដោយដើរលបៗចេញពីក្នុងទូនោះ ដើរកាត់ប្រអប់កែវ ហើយចេញទៅតាមទ្វារហាង។

ដោយក្តាប់វ៉ែនតាបែករបស់វាយកមកដាក់ពីមុខ វាបានពិនិត្យមើលជុំវិញ។ វាបានដើរចូលតាមផ្លូវតូចចង្អៀតមួយដ៏កខ្វក់ដែលឃើញហាក់ដូចជាហាងទាំងអស់ត្រូវបានប្រមូលផ្តុំដើម្បីបូជាឲ្យមន្តអាគមងងឹត។ ហាងមួយដែលវាទើបនឹងចេញមកនោះគឺហាង បូហ្គីន និងប៊ឹក ដូចជាធំជាងគេ ប៉ុន្តែនៅទល់មុខនោះគឺមានការដាក់តាំងបង្ហាញតាមបង្អួចយ៉ាងគគ្រិចនូវក្បាលមនុស្សរួមតូច ហើយទ្វារពីរនៅខាងក្រោមមានទ្រុងដ៏ធំមួយដែលមានដាក់សត្វពីងពាងខ្មៅនៅរស់ដ៏ធំសំបើមពីរក្បាល។ វេទគូមុខអាក្រក់ពីរនាក់កំពុងតាមមើលវាពីស្រមោលនៃផ្លូវដើរមួយ កំពុងខ្សឹបខ្សៀវគ្នា។ ដោយមានអារម្មណ៍ភ័យខ្លាច ហេរីតាំងចិត្ត ហើយព្យាយាមពាក់វ៉ែនតារបស់វាឲ្យត្រង់ និងសង្ឃឹមថាវានឹងអាចរកឃើញផ្លូវមួយចេញពីទីនេះ។

ផ្លាកសញ្ញានៅតាមផ្លូវធ្វើពីឈើដ៏ចាស់មួយបានព្យួរពីលើហាងមួយដែលលក់ទៀនមានជាតិពុល ប្រាប់ឲ្យវាដឹងថាវាស្ថិតនៅក្នុងផ្លូវរាត្រី។ នេះមិនបានជួយអ្វីទេ ព្រោះហេរីមិនធ្លាប់បានឮឈ្មោះកន្លែងណាមួយនោះទេ។ វាគិតថា វាមិនបាននិយាយចេញឲ្យបានច្បាស់ត្រឹមត្រូវតាមមាត់ដែលពេញដោយផេះរបស់វានៅក្នុងភ្នក់ភ្លើងរបស់វីស្លី។ ដោយព្យាយាមនៅស្ងៀមស្ងាត់ វាបានគិតនូវអ្វីដែលត្រូវធ្វើ។

- តើឯងមិនវង្វេងទេរឺ ក្មួយសម្លាញ់?- សម្លេងមួយបន្លឺឡើងក្នុងត្រចៀករបស់វាធ្វើឲ្យវាភ្ញាក់ព្រើត។

វេទគូចាស់ម្នាក់បានឈរនៅពីមុខវា កាន់ថាសមួយដែលមើលទៅគួរឲ្យខ្ពើមដូចក្រចកដៃមនុស្សទាំងស្រុង។ គាត់សម្លឹងមើលវា បង្ហាញនូវធ្មេញដែលមានស្លែ។ ហេរីបានបែរក្រោយខិតទៅឆ្ងាយ។

- ខ្ញុំមិនអីទេ អរគុណ- វានិយាយ។ - ខ្ញុំគ្រាន់តែ...

- ហេរី! តើឯងគិតថាឯងកំពុងទៅធ្វើអ្វីនៅទីនោះ?

បេះដូងរបស់ហេរីលោតញាប់ ឯវេទគូនោះក៏អញ្ចឹងដែរ។ ក្រចកដៃដ៏ច្រើនបានធ្លាក់មកលើជើងរបស់គាត់ ហើយគាត់បានជេរនៅពេលរូបរាងដ៏ធំសម្បើមនៃហាហ្គ្រីដ អ្នកឆ្មាំប្រមាញ់នៅសាលាហុកវ៉ាត បង្ហាញឡើងក្នុងជំហានវែងៗសំដៅទៅរកពួកគេ ដោយក្រសែភ្នែកដូចសត្វល្អិតម្យ៉ាងពណ៌ខ្មៅកំពុងបញ្ចេញពន្លឺពីលើពុកចង្កាដ៏ស្រមូមរបស់គាត់។

- ហាហ្គ្រីដ!- ហេរីបន្លឺឡើងដោយភាពកក់ក្តៅ។ - ខ្ញុំបានវង្វេង...ម្សៅភ្លូ...

ហាហ្គ្រីដចាប់ហេរីចំកញ្ចឹងក និងទាញវាចេញឲ្យឆ្ងាយពីវេទគូនោះ គោះថាសនោះភ្លាមឲ្យចេញពីដៃរបស់គាត់។ សំរែកដ៏គ្រលួចរបស់គាត់នៅបន្លឺតាមពីក្រោយពួកគេពេញតាមបណ្តោយផ្លូវតូចចង្អៀត បត់បែនចេញទៅផ្លូវមានពន្លឺព្រះអាទិត្យចាំងចែង។ ហេរីបានឃើញអគារធ្វើពីថ្មកែវពណ៌សក្បុសមួយពីចម្ងាយ៖ ធនាគារហ្គ្រីង្គហុត។ ហាហ្គ្រីដបានបណ្តើរវាទៅផ្លូវកាត់ទទឹង។

- ឯងឆ្កួតហើយ!- ហាហ្គ្រីដនិយាយយ៉ាងតឹងសរសៃក រួចសំអាតផេះចេញពីមុខហេរីខ្លាំងៗ។ គាត់ស្ទើរតែធ្វើឲ្យវាដួលចូលក្នុងធុងលាមកសត្វនាគនៅខាងក្រៅហាងលក់ឱសថមួយទៅហើយ។ - ពេលកំពុងដើរក្រឡឹងជុំវិញផ្លូវរាត្រី ខ្ញុំមិនបានដឹង...កន្លែងគ្រោះថ្នាក់ ហេរី...មិនត្រូវឲ្យនរណាម្នាក់ឃើញឯងនៅទីនោះទេ...

- ខ្ញុំដឹងរឿងនោះហើយ- ហេរីនិយាយ អោនក្បាលគេចនៅពេលហាហ្គ្រីដរកសំអាតផេះចេញឲ្យវាម្តងទៀត។ - ខ្ញុំបានប្រាប់លោកហើយ ខ្ញុំបានវង្វេង...ចុះលោកនៅធ្វើអីទីនោះដែរ?

- ខ្ញុំកំពុងទៅរកមើល ថ្នាំបណ្ដេញខ្យងស៊ីសាច់ - ហាហ្គ្រីដនិយាយដោយខឹងតិចៗ។ - ពួកវាកំពុងបំផ្លាញស្ពៃក្ដោបនៅសាលាហើយ។ ឯងមកតែម្នាក់ឯងទេរឺ?

- ខ្ញុំកំពុងស្នាក់នៅជាមួយគ្រួសាររ៉ីស្លី ប៉ុន្តែពួកយើងបានបែកគ្នា- ហេរីពន្យល់។ - ខ្ញុំត្រូវតែទៅរកពួកគេភ្លាម...

ពួកគេធ្វើដំណើររួមគ្នានៅតាមផ្លូវ។

- ហេតុអ្វីបានជាឯងមិនដែលសរសេរសំបុត្រតបមកខ្ញុំវិញអញ្ចឹង?- ហាហ្គ្រីដនិយាយ នៅពេលដែលហេរីរត់ត្រឹកៗតាមក្បែរគាត់ (វាត្រូវដើរបីជំហានដើម្បីឲ្យទាន់ជំហានវែងៗនៃស្បែកជើងកវែងដ៏ធំរបស់ហាហ្គ្រីដមួយៗ)។ ហេរីបានប្រាប់រឿងរ៉ាវទាំងអស់ពីដុបប៊ី និងឌើស្លី។

- ពួកលោកិយឃោរឃៅទាំងអស់នេះពិតជាចំមែន- ហាហ្គ្រីដបញ្ចេញកំហឹង។ - ប្រសិនបើខ្ញុំបានដឹង...

- ហេរី! ហេរី! នៅទីនេះ!

ហេរីក្រឡេកមើលទៅឃើញ ហឺម៉ាយអូនី ហ្គ្រេនជឺរ កំពុងឈរនៅលើចុងជណ្ដើរពណ៌សឡើងទៅធនាគារហ្គ្រីងហ្គុត។ នាងបានរត់ចុះមកដើម្បីជួបពួកគេ សក់ពណ៌ត្នោតដ៏ស្ដើងរបស់នាងបានយោលយោកនៅពីក្រោយនាង។

- តើវ៉ែនតារបស់ឯងកើតអីហ្នឹង? សួស្ដី ហាហ្គ្រីដ...អូ! វាពិតជាអស្ចារ្យណាស់ដែលបានជួបអ្នកទាំងពីរម្ដងទៀត...តើឯងនឹងចូលទៅហ្គ្រីងហ្គុតរឺ ហេរី?

- បន្តិចទៀតនៅពេលខ្ញុំរកគ្រួសាររ៉ីស្លីឃើញ- ហេរីនិយាយ។

- ឯងនឹងមិនបាច់ចាំយូរទៀតទេ- ហាហ្គ្រីដសើចស្ញេញ។

ហេរី និងហឺម៉ាយអូនីរកមើលជុំវិញ។ អ្នកដែលរត់លឿនកាត់ហ្វូងមនុស្សនោះគឺ រ៉ុន ហ្វ្រេដ ចច ពឿរស៊ី និងលោករ៉ីស្លី។

- ហេរី- លោករ៉ីស្លីនិយាយទាំងដង្ហក់។ - ពួកយើងគិតថាឯងនឹងទៅដល់កន្លែងមួយដ៏ឆ្ងាយ...- គាត់ជូតកន្លែងទំពែកដ៏រលោងលើក្បាលរបស់គាត់។ - ម៉ូលីព្រួយបារម្ភខ្លាំងណាស់...នាងនឹងមកដល់ឥឡូវហើយ។

- តើឯងបានចេញទៅដល់កន្លែងណា?- រ៉ុនសួរ។

- ផ្លូវរាត្រី- ហាហ្គ្រីដនិយាយទាំងមុខក្រញ៉ូវ។

- អស្ចារ្យណាស់!- ហ្វ្រេដ និងចចនិយាយព្រមគ្នា។

- ពួកយើងមិនដែលត្រូវបានអនុញ្ញាតឲ្យចូលទេ- រ៉ុននិយាយទាំងច្រណែន។

- ខ្ញុំគួរតែនិយាយថាខ្ញុំមិនគិតដូច្នោះទេ- ហាហ្គ្រីដនិយាយទាំងខឹងតិចៗ។

ឥឡូវលោកស្រីរ៉ីស្លីបានរត់មកយ៉ាងលឿនដូចហោះ កាបូបយួរដៃរបស់គាត់គ្រវីគ្រវាត់យ៉ាងខ្លាំងនៅក្នុងដៃម្ខាង ជីននីកាន់ដៃម្ខាងទៀត។

- អូ! ហេរី...អូ! ក្មួយសម្លាញ់...ឯងអាចទៅដល់កន្លែងណាមួយ...

ដោយដកដង្ហើមទាំងដង្ហក់ គាត់បានទាញយកក្រណាត់ជូតធំមួយចេញពីកាបូបរបស់គាត់ ហើយចាប់ផ្ដើមសំអាតផេះដែលហាហ្គ្រីដមិនបានសំអាតចេញអស់នៅឡើយ។ លោករ៉ីស្លីយកវ៉ែនតារបស់ហេរីមក គោះវាតិចៗដោយចង្កឹះវេទមន្តរបស់គាត់ ហើយធ្វើឲ្យវាល្អដូចថ្មីអញ្ចឹង។

- អី នែក...ទៅចុះ- ហាហ្គ្រីដបាននិយាយពេលលោកវីស្លីសំដែងការស្វាគមន៍ដោយចាប់លោក់ដៃរបស់គាត់ (ផ្លូវរាត្រីណា! ប្រសិនបើលោកមិនបានឃើញវាទេ មិនដឹងជាមានរឿងអ្វីកើតឡើងនោះទេ ហាហ្គ្រីដ!) ។ - ជួបគ្នានៅហុកវ៉ាត!- ហើយគាត់បោះជំហានវែងៗយ៉ាងលឿន ក្បាលនិងស្មារបស់គាត់ខ្ពស់ជាងអ្នកឯទៀតនៅផ្លូវដ៏កកកុញនោះ។

- ទាយមើល៍ តើខ្ញុំបានឃើញនរណានៅហាង បូហ្គីននិងប៊ឺក?- ហេរីបានសួររ៉ុន និងហឺម៉ាយអូនីនៅពេលពួកគេឡើងជណ្តើរ ហ្គ្រីង្គហុត។ - មេលហ្វ័យ និងឪពុករបស់វា។

- តើលូស៊ីស មេលហ្វ័យមានទិញអ្វីទេ?- លោកវីស្លីនិយាយភ្លាមនៅពីក្រោយពួកគេ។

- ទេ គាត់កំពុងទៅលក់វិញតើ។

- ដូច្នេះគាត់បារម្ភហើយ- លោកវីស្លីនិយាយដោយភាពសប្បាយចិត្តបង្កប់ការព្រួយ។ - អូ! ខ្ញុំចង់ទិញរបស់មួយចំនួនពីលូស៊ីស មេលហ្វ័យ...

- បងត្រូវប្រយ័ត្ន អស់សឺ- លោកស្រីវីស្លីនិយាយនៅពេលពួកគេត្រូវបានបង្ហាញកន្លែងចូលទៅក្នុងធនាគារដោយម្រេញគង្វាលម្នាក់ដែលកំពុងអោនគោរពនៅមាត់ទ្វារ។ - គ្រួសារនោះមិនស្រួលទេណា។ ឃើញដំរីជុះ កុំជុះតាមដំរី។

- អញ្ចឹងអូនគិតថាបងគឺជាដៃគូរបស់លូស៊ីស មេលហ្វ័យទេរឺ?- លោកវីស្លីនិយាយទាំងខឹងចិត្ត ប៉ុន្តែគាត់បែកអារម្មណ៍មួយរំពេច ដោយសារឃើញគ្រួសាររបស់ហឺម៉ាយអូនី ដែលកំពុងឈរដោយភាពងឿងឆ្ងល់នៅឯគុតាំងទំនិញ ដែលលាតសន្ធឹងពេញសាលធ្វើពីថ្មកែវដ៏ធំនោះ កំពុងរង់ចាំឲ្យហឺម៉ាយអូនីណែនាំពួកគាត់។

- ប៉ុន្តែពួកអ្នកគឺជាពួកលោកិយ!- លោកវីស្លីនិយាយដោយរីករាយ។ - ពួកយើងត្រូវតែរកអីផឹកសិនទៅ! តើពួកអ្នកទៅទីនេះធ្វើអ្វីដែរ? អូ! អ្នកកំពុងដូរលុយពួកលោកិយផង។ មូលី មើលនែក!- គាត់ចង្អុលដោយភាពរំភើបទៅក្រដាសប្រាប់ដប់ផោននៅក្នុងដៃរបស់លោកហ្គ្រេនជឺរ។

- ជួបគ្នាវិញនៅទីនេះ- រ៉ុននិយាយទៅកាន់ហឺម៉ាយអូនីនៅពេលគ្រួសារវីស្លី និងហេរីត្រូវបាននាំផ្លូវចូលទៅបន្ទប់ក្រោមដីដោយម្រេញគង្វាលនៅហ្គ្រីង្គហុតម្នាក់ផ្សេងទៀត។

បន្ទប់ក្រោមដីនោះត្រូវបានទៅដល់ដោយប្រើមធ្យោបាយតាមទូរថភ្លើងតូចមួយ បើកបរដោយពួកម្រេញគង្វាលដែលបង្កើនល្បឿនលើផ្លូវរថភ្លើងដ៏តូចកាត់តាមផ្លូវក្រោមដីរបស់ធនាគារនោះ។ ហេរីរីករាយនឹងការធ្វើដំណើរយ៉ាងលឿនស្លេវចុះទៅបន្ទប់សុវត្ថិភាពរបស់វីស្លី ប៉ុន្តែវាមានអារម្មណ៍មិនល្អទេ គឺមិនល្អខ្លាំងជាងពេលវានៅផ្លូវរាត្រី ទៅទៀត ពេលទ្វារបន្ទប់សុវត្ថិភាពបើកឡើង។ មានគំនរនៃប្រាក់សីកគ័លដ៏តូចមួយនៅខាងក្នុង ហើយមានតែហ្កាលុនមាសមួយប៉ុណ្ណោះ។ លោកស្រីវីស្លីបានចូលភ្លាមនៅតាមផ្លូវកាច់ជ្រុងហើយញាត់ប្រាក់ទាំងប៉ុន្មានចូលក្នុងកាបូបរបស់គាត់។ ហេរីមានអារម្មណ៍រឹតតែមិនល្អ នៅពេលពួកគេបានទៅដល់បន្ទប់សុវត្ថិភាពរបស់វា។ វាព្យាយាមបិទបាំងវត្ថុនៅក្នុងប្រអប់ពីអ្នកទាំងអស់ នៅពេលវាដាក់កាក់ដែលមាននៅក្នុងដៃយ៉ាងប្រញាប់ចូលទៅក្នុងកាបូបស្បែកមួយ។

ត្រឡប់មកខាងក្រៅលើជណ្តើរថ្មកែវវិញ ពួកគេទាំងអស់គ្នាបានបែកគ្នា។ ពឿរស៊ីនិយាយរអ៊ូតិចៗចង់បានស្លាបប៉ាកាថ្មី។ ហ្វ្រេដ និងចចចំណាំបានមិត្តភក្តិរបស់ពួកគេម្នាក់នៅហុកវ៉ាតគឺ លី ចចដាន់។ អ្នកស្រីវីស្លី និងជីននីកំពុងទៅហាងលក់រ៉ូបជជុះមួយ។ លោកវីស្លីទទូចចង់នាំគ្រួសារហ្គ្រេនជឺរទៅផឹកអីនៅហាង លីគី កូលដ្រុន។

## នៅហាងហ្វ្លារីស និងប្លត់

- ពួកយើងទាំងអស់នឹងជួបគ្នាវិញនៅឯហាង ហ្វ្លារីស និងប្លត់ក្នុងរយៈពេលមួយម៉ោង ដើម្បីទិញសៀវភៅសិក្សារបស់ពួកឯង- លោកស្រីវីស្លីនិយាយរួចដើរចេញទៅជាមួយជីននី។ - ហើយមិនឲ្យឈានជើងមួយជំហានទៅផ្លូវរាត្រីដាច់ខាត!- គាត់ស្រែកទៅបងប្អូនភ្លោះដែលកំពុងដើរបកក្រោយ។

ហេរី រ៉ុន និងហឺម៉ាយអូនីដើរលំហែតាមដងផ្លូវដែលក្រាលដោយថ្ម និងមានខ្យល់បក់រំភើយ។ ថង់មាស ប្រាក់ និងសំរឹទ្ធិកំពុងទង្គិចឮសូរច្រាវៗយ៉ាងរណ្តំក្នុងហោប៉ៅរបស់ហេរី ដែលទាមទារឲ្យវាត្រូវចំនាយ ដូច្នេះវាបានទិញផ្លែស្ត្របឺរីធំបីផ្លែ និងការ៉េមប័រសណ្តែកដី រួចពួកគេបានទំពារឮសូរគ្រូបៗយ៉ាងរីករាយនៅពេលពួកគេដើរយឺតៗតាមដងផ្លូវចង្អៀត និងសម្លឹងមើលតាមកញ្ចក់ហាងដែលគួរឲ្យចាប់អារម្មណ៍ជាច្រើន។ រ៉ុនសម្លឹងមើលយ៉ាងជក់ចិត្តទៅរ៉ូបឆាត់លី កាណុងមួយឈុតតាមកញ្ចក់នៃហាង ផ្គត់ផ្គង់សំភារៈកីឡាឃ្វីដឌីចគ្រប់ប្រភេទ រហូតទាល់តែហឺម៉ាយអូនីត្រូវបង្ខំអូសពួកគេចេញដើម្បីទៅទិញទឹកខ្មៅ និងក្រដាសស្បែកចៀមនៅហាងបន្ទាប់។ ក្នុងហាង ប្រដាប់លេងសំរាប់វេទគូហ្គមបូល និងចេប ពួកគេបានជួបហ្វ្រេដ ចច និងលី ចចដាន់ដែលកំពុងទិញឧបករណ៍ធ្វើឲ្យទឹកដ៏អស្ចារ្យរបស់ដុកទ័រហ្វីលីបាសទ័រ និងកាំជ្រួចគ្មានកំដៅ ជាច្រើន ហើយនៅក្នុងហាងលក់របស់ឡែឡុងតូចមួយដែលពោរពេញទៅដោយចង្កឹះវេទមន្តបាក់ៗ ជញ្ជីងរង្គើរង្គើធ្វើពីទង់ដែង និងអាវខ្លុកចាស់ៗគ្របដណ្តប់ដោយស្នាមប្រលាក់ ពួកគេបានឃើញពឿរស៊ី កំពុងតែជក់ចិត្តយ៉ាងខ្លាំងលើសៀវភៅតូចមួយដែលគួរឲ្យធុញទ្រាន់មានចំនងជើងថា ប្រធានសិស្សដែលមានអំណាច។

- ការសិក្សាមួយរបស់សិស្សច្បងក្នុងសាលាហុកវ៉ាត និងមុខងាររបស់ពួកគេបន្តបន្ទាប់ទៀត- រ៉ុនបានអានឮៗពីក្របខាងក្រោយ។ - ស្តាប់ទៅគួរឲ្យចាប់អារម្មណ៍ដែរ...

- ចេញឲ្យឆ្ងាញទៅ- ពឿរស៊ីនិយាយទាំងគំរោះគំរើយ។

- ពិតណាស់ វាមានមហិច្ឆតាខ្លាំងណាស់ ពឿរស៊ី វាបានរៀបចំគំរោងការរួចអស់ទៅហើយ...វាចង់ធ្វើជារដ្ឋមន្ត្រីក្រសួងវេទមន្ត...- រ៉ុនប្រាប់ហេរី និងហឺម៉ាយអូនីស្ងាត់ៗនៅពេលពួកគេចាកចេញពីពឿរស៊ី។

មួយម៉ោងក្រោយមក ពួកគេបានដើរសំដៅទៅហ្វ្លារីស និងប្លត់។ មានតែពួកគេប៉ុណ្ណោះដែលធ្វើដំណើរទៅហាងលក់សៀវភៅ។ ពេលដែលពួកគេជិតទៅដល់ទីនោះ ពួកគេបានឃើញយ៉ាងភ្ញាក់ផ្អើលនូវហ្វូងមនុស្សដ៏ធំកំពុងប្រជ្រៀតគ្នានៅខាងក្រៅទ្វារដើម្បីព្យាយាមចូលទៅក្នុង។ មូលហេតុនៃរឿងនេះគឺមានការប្រកាសជាសាធារណៈដោយទាញបដាដ៏ធំមួយកាត់តាមបង្អួចខាងលើជាច្រើន៖

**ហ្គីលដឺរ៉យ ឡក់ហាត**
**នឹងចុះហត្ថលេខាលើសៀវភៅស្វ័យជីវប្រវត្តិរបស់គាត់**
**វេទមន្តនៃខ្ញុំ**
**ថ្ងៃនេះពីម៉ោង ១២:៣០ - ៤:៣០ ល្ងាច**

- ពួកយើងប្រាកដជាអាចជួបគាត់!- ហឺម៉ាយអូនីបន្លឺសំឡេងញ៉ែតៗ។ - ខ្ញុំចង់មានន័យថា គាត់បានសរសេរស្ទើរតែគ្រប់សៀវភៅក្នុងបញ្ជីសៀវភៅសាលាទៅហើយ!

ហ្វូងមនុស្សនោះហាក់ដូចជាត្រូវបានរៀបចំជាជួរ ដែលភាគច្រើនបំផុតនៃវេទគូទាំងនោះមានអាយុប្រហែល អ្នកស្រី វីស្លី។ វេទគូដែលមើលទៅគួរឲ្យរំខានម្នាក់បានឈរនៅកៀកទ្វារ និយាយថា៖

- សូមស្ងៀមស្ងាត់ សូមស្ត្រីទាំងឡាយ...កុំរុញគ្នា មាន...កុំប្រកាន់នឹងសៀវភៅទាំងនោះអី ឥឡូវនេះ...

ហេរី រ៉ុន និងហឺម៉ាយអូនីបានប្រជ្រៀតចូលទៅខាងក្នុង។ ជួរដ៏វែងមួយបានបោលចូលទៅតាមក្រោយហាងដែលជាកន្លែងដែលហ្គីលដឺរ៉យ ឡក់ហាតកំពុងចុះហត្ថលេខាលើសៀវភៅរបស់គាត់។ ពួកគេម្នាក់ៗបានកញ្ឆក់យកសៀវភៅ ការប្រយុទ្ធជាមួយនឹងខ្មោចប៊ែនស្ទី ហើយលួចចូលតាមជួរស្ងាត់ៗនៅកន្លែងដែលសមាជិកគ្រួសារវីស្លីឯទៀតកំពុងឈរជាមួយលោក និងលោកស្រីហ្គ្រេនជឺរ។

- អូ ពួកឯងនៅទីនេះទេ ល្អ- លោកស្រីវីស្លីនិយាយ។ គាត់បន្លឺសំឡេងស្ទើរតែមិនដកដង្ហើម និងអង្អែលតិចៗលើសក់របស់គាត់។ - ពួកយើងនឹងអាចជួបគាត់នៅពេលបន្តិចទៀតនេះ...

ហ្គីលដឺរ៉យ ឡក់ហាតដើរមកយឺតៗកាត់ហ្វូងមនុស្ស បានអង្គុយនៅឯតុមួយព័ទ្ធជុំវិញទៅដោយរូបភាពធំៗនៃមុខរបស់គាត់ផ្ទាល់ដែលកំពុងមិចភ្នែក និងបញ្ចេញពន្លឺសស្វាញចេញពីធ្មេញសរបស់គាត់យ៉ាងគួរឲ្យទាក់ទាញទៅកាន់ហ្វូងមនុស្ស។ លោកឡក់ហាតពិតនៅខាងក្រៅស្លៀករ៉ូបនៃផ្កា បំភ្លេចមិនបាន ពណ៌ខៀវដែលពិតជាត្រូវគ្នានឹងពណ៌ភ្នែករបស់គាត់។ មួកវេទគូស្រួចរបស់គាត់ត្រូវបានបំពាក់នៅត្រង់កន្លែងដ៏ទាក់ទាញមួយនៅលើសក់រួញដូចទឹករលករបស់គាត់។

បុរសឆេវឆាវទាបម្នាក់កំពុងឈរផ្អៀងថតរូបដោយប្រើម៉ាស៊ីនថតរូបពណ៌ខ្មៅធំមួយ ដែលបញ្ចេញផ្សែងពណ៌ស្វាយហុយមកជាមួយពន្លឺចែងចាំង។

- ជៀសចេញពីទីនោះ- គាត់និយាយទាំងកំហឹងទៅរ៉ុន រួចត្រឡប់ទៅថតរូបថ្មីមួយទៀត។ - នេះគឺសំរាប់កាសែតសារព័ត៌មានប្រចាំថ្ងៃសំរាប់វេទគូ។

- អញ្ចឹងវាយ៉ាងម៉េច- រ៉ុននិយាយ វាជុសជើងរបស់វាដែលជាងថតរូបនោះបានដើរជាន់។

ហ្គីលដឺរ៉យ ឡក់ហាតបានឮវា។ គាត់រកមើល។ គាត់បានឃើញរ៉ុន..ហើយបន្ទាប់មកឃើញហេរី។ គាត់សំឡក់។ បន្ទាប់មកគាត់ក៏ក្រោកឈរភ្លែត រួចស្រែកយ៉ាងភ្ញាក់ផ្អើលៈ

- វាមិនអាចជាហេរី ផោតធ័រទេ មែនទេ?

ហ្វូងមនុស្សបានបែកចេញហើយខ្សឹបខ្សៀវគ្នាយ៉ាងភ្ញាក់ផ្អើល។ ឡក់ហាតហក់សំដៅទៅចាប់ដៃរបស់ហេរី ហើយទាញវាទៅខាងមុខ។ ហ្វូងមនុស្សបានទះដៃអបអរសាទរ។ មុខរបស់ហេរីឡើងក្រហមពេលឡក់ហាតចាប់លោក់ដៃរបស់វា បែរទៅជាងថតរូបដែលកំពុងចុចម៉ាស៊ីនថតឮសូរក្រឹកយ៉ាងហ័សដោយមានផ្សែងខ្មួលខ្មាញ់រសាត់ទៅលើគ្រួសារវីស្លី។

- ញញឹមអោយស្រស់ណ៎ា ហេរី- ឡក់ហាតនិយាយតាមរយៈធ្មេញដ៏ភ្លឺចែងចាំងរបស់គាត់។ - ទាំងអស់គ្នា ឯងនិងខ្ញុំស្ថិតនៅលើក្របមុខដ៏សំខាន់។

នៅពេលគាត់ឈប់កាន់ដៃរបស់ហេរី ហេរីពិបាកនឹងកំរើកម្រាមដៃរបស់វាខ្លាំងណាស់។ វាព្យាយាមដើរសំដៅត្រលប់ទៅវីស្លីវិញ ប៉ុន្តែឡក់ហាតលើកដៃម្ខាងដាក់លើស្មារបស់វាទាំងពីរ ហើយក្រៀកវាយ៉ាងជាប់នឹងខ្លួនគាត់។

- សុភាពនារី និងសុភាពបុរសទាំងឡាយ- គាត់និយាយឮៗ និងគ្រវីដៃឲ្យស្ងៀមស្ងាត់។ - ឱកាសអ្វីក៏ពិសេសម្ល៉េះ! ឱកាសដ៏ល្អឥតខ្ចោះសំរាប់ខ្ញុំដើម្បីធ្វើការប្រកាសបន្តិច ដែលខ្ញុំបានអង្គុយរង់ចាំអស់យូរមកហើយ!

- នៅពេលដែលក្មេងប្រុសហេរីនេះបានឈានជើងចូលក្នុងហាងហ្គារីស និងប្លត់នៅថ្ងៃនេះ វាគ្រាន់តែចង់មកទិញសៀវភៅស្វ័យជីវប្រវត្តិរបស់ខ្ញុំតែប៉ុណ្ណោះ...ដែលខ្ញុំគួរតែរីករាយនឹងប្រគល់ឲ្យវាឥឡូវនេះ ដោយមិនបាច់បង់ថ្លៃ...- ហ្វូងមនុស្សបានអបអរ

សាទរម្តងទៀត - វាមិនគិតថា- ឡក់ហាតបន្ត រួចចាប់អង្រួនហេរីដែលធ្វើឲ្យវ៉ែនតារបស់វារអិលធ្លាក់មកដល់ចុងច្រមុះរបស់វា - ក្នុងពេលដ៏ខ្លីកន្ទុចញ៉ុចនេះ វានឹងទទួលបាននូវអ្វីដែលលើសលប់ជាងសៀវភៅ វេទមន្តនៃខ្ញុំ របស់ខ្ញុំទៅទៀត។ តាមការពិត វានិងមិត្តនៅសាលារបស់វានឹងទទួលបានសៀវភៅវេទមន្តនៃខ្ញុំច្បាប់ដើមតែម្តង។ បាទ សុភាពនារី និងសុភាពបុរសទាំងឡាយ ខ្ញុំមានសេចក្តីរីករាយនិងមោទនៈក្រៃលែងក្នុងការប្រកាសថា នៅខែកញ្ញានេះ ខ្ញុំនឹងត្រូវទៅបំពេញការងារជាគ្រូការពារប្រឆាំងនឹងមន្តអាគមងងឹតនៅសាលាហុកវ៉ាតហើយ!

ហ្វូងមនុស្សរីករាយ និងទះដៃ ហើយហេរីដឹងខ្លួនថា វាកំពុងត្រូវបានបង្ហាញខ្លួនជាមួយនឹងការងារទាំងមូលរបស់ហ្គីលដឺរ៍យ ឡក់ហាតហើយ។ ដោយដំណើរទ្រេតទ្រោតតិចៗ ក្រោមទំងន់របស់ពួកគេទាំងនោះ វាបានរកផ្លូវចេញពីការយកចិត្តទុកដាក់របស់អ្នកកាសែតទៅចុងនៃបន្ទប់ដែលជីននីកំពុងឈរក្បែរថ្លាងថ្មីរបស់នាង។

- នាងយកសៀវភៅទាំងនេះទៅ- ហេរីនិយាយរហឹមៗទៅនាង វាបានដាក់សៀវភៅចូលទៅក្នុងថ្លាងនោះ។ - ខ្ញុំនឹងទិញដោយខ្លួនឯង...

- ខ្ញុំភ្នាល់ថាឯងចូលចិត្តបែបនោះ មែនទេ ផោតធ័រ?- សំឡេងមួយបន្លឺឡើងដែលហេរីមិនពិបាកក្នុងការចំណាំនោះទេ។ វាតំរង់ខ្លួនហើយមកប្រឈមមុខនឹងដ្រាកូ មេលហ្វ័យដែលកំពុងបញ្ចេញស្នាមញញឹមបែកមាក់ងាយជាធម្មតារបស់វា។

- ហេរី ផោតធ័រដ៏ល្បីល្បាញ- មេលហ្វ័យនិយាយ។ - មិនអាចចូលសូម្បីតែក្នុងហាងលក់សៀវភៅមួយបើគ្មានការថតរូបដាក់ទំព័រមុខនោះទេ។

- ចេញឲ្យឆ្ងាយពីគាត់ទៅ គាត់មិនមែនចង់ធ្វើរឿងទាំងអស់នោះទេ!- ជីននីនិយាយ។ វាជាលើកដំបូងហើយដែលនាងនិយាយនៅពីមុខហេរី។ នាងមើលទាំងខឹងយ៉ាងខ្លាំងចំពោះមេលហ្វ័យ។

- ផោតធ័រ ឯងមានមិត្តស្រីខ្លួនឯងទៅហើយ!- មេលហ្វ័យនិយាយបង្អូស។ ជីននីប្រែជាក្រហមមុខនៅពេលរ៉ុន និងហឺម៉ាយអូនីរែកផ្លូវចូលមក ទាំងពីរនាក់ដោយមានកាន់គំនរសៀវភៅរបស់លោកឡក់ហាត។

- អូ! គឺឯង- រ៉ុននិយាយ សំឡឹងមើលទៅមេលហ្វ័យចំពេលកំពុងតែមានអ្វីមិនស្រួលនៅនឹងបាតស្បែកជើងរបស់វា។ - យើងភ្នាល់ថាឯងភ្ញាក់ផ្អើលណាស់ដែលបានឃើញហេរីនៅទីនេះ ប៉ា?

- មិនភ្ញាក់ផ្អើលដូចដែលខ្ញុំឃើញនៅក្នុងហាងតូចមួយនោះទេ វីស្លី- មេលហ្វ័យតបទៅវិញយ៉ាងលឿន។ - ខ្ញុំគិតថាឪពុកម្តាយរបស់ឯងនឹងត្រូវអត់ឃ្លានរយៈពេលមួយខែដើម្បីចំនាយច្រើនលើរបស់ទាំងនោះ។

រ៉ុនប្រែជាមុខក្រហមដូចជីននីដែរ។ វាទំលាក់សៀវភៅរបស់វាចូលក្នុងថ្លាងដែរ ហើយសំឡក់មេលហ្វ័យ ប៉ុន្តែហេរី និងហឺម៉ាយអូនីបានកញ្ឆក់ទាញអាវរងាពីក្រោយខ្នងវា។

- រ៉ុន!- លោកវីស្លីនិយាយ ស្ទុះចេញមកជាមួយហ្វ្រេដ និងចច - តើឯងកំពុងធ្វើអីហ្នឹង? វាមិនសមទេនៅទីនេះ តោះចេញទៅក្រៅ។

- ម៉េចហើយ...អស់សឺ វីស្លី។

នោះគឺលោកមេលហ្វ័យ។ គាត់ឈរដោយដាក់ដៃលើស្មារបស់ដ្រាកូ បញ្ចេញស្នាមញញឹមចំអកក្នុងកាយវិការតែមួយ។

- លូស៊ីស- លោកវីស្លីនិយាយ រួចងក់ក្បាលទាំងមិនពេញចិត្ត។

- ខ្ញុំឮថាលោករវល់ណាស់នៅក្រសួង- លោកមេលហ្វ័យនិយាយ។ -ការវាយឆ្មក់អស់ទាំងនោះ...ខ្ញុំសង្ឃឹមថាពួកគេនឹងឲ្យលុយលោកច្រើនចំពោះការងារបន្ថែមម៉ោង មិនថាអញ្ចឹងរឺ?

គាត់បានលូកដៃចូលទៅក្នុងថ្លាងរបស់ជីននី ហើយយកចេញពីក្នុងចំនោមសៀវភៅរលោងៗរបស់ឡក់ហាតនូវសៀវភៅដ៏ចាស់មើលមិនយល់មួយក្បាលមានចំណងជើងថា ការណែនាំកំរិតទីមួយអំពីមុខវិជ្ជានិម្មិតកម្ម។

- មិនពិតនោះទេ- គាត់និយាយ។ - សម្លាញ់ តើបានប្រយោជន៍អ្វីទៅ ក្នុងការធ្វើជាភាពអាម៉ាស់ដល់ឈ្មោះវេទគូប្រសិនបើគេមិនទាំងបង់ថ្លៃឲ្យលោកខ្ពស់ផងហ្នឹង?

លោកវីស្លីប្រែជាមុខក្រហមខ្លាំងជាងរ៉ុន រឺជីននីទៅទៀត។

- ពួកយើងមានគំនិតខុសពីគ្នាចំពោះអ្វីដែលធ្វើឲ្យអាម៉ាស់ដល់ឈ្មោះវេទគូ មេលហ្វ័យ- គាត់និយាយ។

- ច្បាស់ណាស់- លោកមេលហ្វ័យនិយាយ ភ្នែកសព្រៀតរបស់គាត់បែរសំឡឹងទៅលោក និងលោកស្រីហ្គ្រេនជឺរដែលកំពុងមើលមកទាំងព្រួយបារម្ភ។ - ក្រុមហ៊ុនដែលលោកគ្រប់គ្រងនោះ វីស្លី....ហើយខ្ញុំគិតថាគ្រួសាររបស់លោកអាចនឹងធ្លាក់ចុះដុនដាបមិនខាន...

មានសំឡេងលោហៈមួយធ្លាក់ឮសូរក្តុក ខណៈពេលដែលថ្លាងរបស់ជីននីកំពុងហោះ។ លោកវីស្លីបានរុញខ្លួនគាត់ទៅបុកលោកមេលហ្វ័យ ផ្តួលគាត់ឲ្យដួលផ្ងារក្រោយចូលទៅក្នុងធ្នើរសៀវភៅមួយ។ សៀវភៅពាក្យបាលីធ្ងន់ៗជាច្រើនក្បាលបានធ្លាក់ចុះឮសូរយ៉ាងខ្លាំងមកលើក្បាលរបស់ពួកគេទាំងអស់គ្នា។ មានសំរែកមួយបន្លឺឡើង - វាយគាត់ទៅ ប៉ា!- ពីហ្វ្រេដ និងចច។ លោកស្រីវីស្លីស្រែកខ្លាំងៗ៖

- ទេ អស់សឺ ទេ!

ហ្វូងមនុស្សរត់ប្រសេចប្រសាចសំដៅទៅខាងក្រោយ បុកធ្នើរអស់ជាច្រើនថែមទៀត។

- សុភាពបុរស សូម...សូម!- អ្នកជំនួយការហាងបានស្រែក ហើយក្រោយមក ឮខ្លាំងតែម្តង - បញ្ឈប់ភ្លាម សុភាពបុរសនៅទីនោះ ត្រូវបញ្ឈប់ភ្លាម...

ហាហ្គ្រីដបានដើរកាត់លើសៀវភៅដ៏ច្រើនសំដៅទៅរកពួកគេ។ ភ្លាមៗនោះ គាត់បានទាញលោកវីស្លី និងមេលហ្វ័យចេញពីគ្នា។ លោកវីស្លីបានដាច់បបូរមាត់ និងលោកមេលហ្វ័យត្រូវបានវាយចំភ្នែកដោយសៀវភៅ *សព្វវចនាធិប្បាយអំពីឧបករណ៍ប្រើប្រាស់* មួយក្បាល។ គាត់នៅតែកាន់សៀវភៅ និម្មិតកម្ម ដ៏ចាស់របស់ជីននី។ គាត់បានហុចវាទៅឲ្យនាងវិញ...វាគឺជារបស់ល្អបំផុតដែលឪពុករបស់នាងអាចផ្តល់ឲ្យនាងបាន...

ដោយរើបំរះចេញពីការចាប់របស់ហាហ្គ្រីដ គាត់បានបក់ដៃហៅដ្រាកូ ហើយចេញពីហាងយ៉ាងលឿន។

- លោកគួរតែកុំរវល់នឹងគេអី អស់សឺ- ហាហ្គ្រីដនិយាយ ស្ទើរតែលើកលោកវីស្លីឡើងលើនៅពេលគាត់ទាញតម្រង់រ៉ូបរបស់គាត់។ - អ្នករាល់គ្នាដឹងថាគ្រួសារនោះទាំងមូលមានឈ្មោះស្អុយរលួយណាស់។ មេលហ្វ័យគ្មានយកត្រចៀកស្តាប់ទេ។ ឈាមជ័រអាក្រក់គឺវាអញ្ចឹងហើយ។ ឥឡូវឆាប់ឡើង...តោះចេញពីទីនេះ។

ជំនួយការហាងនោះសំឡឹងមើលហាក់ដូចជាចង់ឃាត់ពួកគេមិនឲ្យចេញទៅ ប៉ុន្តែគាត់គ្រាន់តែដើរមកជិតចង្កេះរបស់ហាហ្គ្រីដ ហើយក៏ប្រែគំនិតវិញភ្លាម។ ពួកគេធ្វើដំណើរយ៉ាងប្រញាប់លើផ្លូវ គ្រួសារហ្គ្រេនជឺរភ័យញ័រ ឯលោកស្រីវីស្លីមានកំហឹងយ៉ាងខ្លាំងនៅក្នុងខ្លួនគាត់។

## នៅហាងហ្គារីស និងប្លត់

- ជាឧទាហរណ៍ល្អមួយទុកឲ្យកូនរបស់បង...ការវាយតប់គ្នានៅទីសាធារណៈ...អ្វីដែលឡក់ហាតនឹងគិតនោះគឺ...

- គាត់រីករាយទេ- ហ្វ្រេដនិយាយ។ - តើម៉ាក់មិនឮគាត់និយាយពេលយើងកំពុងដើរចេញទេវឺ? គាត់បានកំពុងសួរបុរសម្នាក់ដែលមកពីសារពត៌មានប្រចាំថ្ងៃសំរាប់វេទគូថា តើគាត់អាចនឹងសរសេរពីការវាយគ្នានេះចូលក្នុងរបាយរបស់គាត់បានរឺទេ...រួចផ្សាយវាជាសាធារណៈទៅ។

ប៉ុន្តែនោះគឺជាក្រុមមិនអស់ចិត្តមួយ ដែលបានធ្វើដំណើរត្រលប់ទៅកន្លែងឡចង្ក្រានវិញនៅ លីគី កូលដ្រុន។ ហេរី វីស្លី និងអីវ៉ាន់របស់ពួកគេទាំងអស់នឹងត្រូវធ្វើដំណើរត្រលប់ទៅ ប៊្យូរ វិញ ដោយប្រើម្សៅភ្លូ។ ពួកគេបាននិយាយលាគ្រួសារហ្គ្រេនជឺរ ដែលកំពុងចាកចេញពីតៀមទៅផ្លូវពួកលោកិយវិញនៅម្ខាងទៀត។ លោកវីស្លីចាប់ផ្តើមសួរពួកគេពីដំណើរការនៃចំណតរថយន្ត ប៉ុន្តែពួកគេត្រូវបញ្ឈប់យ៉ាងលឿន ពេលឃើញមុខរបស់លោកស្រីវីស្លី។

ហេរីដោះវ៉ែនតាវាចេញ ហើយដាក់យ៉ាងថ្នមៗចូលទៅក្នុងហោប៉ៅរបស់វាមុនពេលវាប្រើម្សៅភ្លូ។ ពិតជាមិនមែនជាមធ្យោបាយធ្វើដំនើរ ដែលវាពេញចិត្តនោះទេ។

## វគ្គ V



# ដើមឈើ ទុំមតីង វីឡូ

ចុងបញ្ចប់នៃវិស្សមកាលរដូវក្តៅបានមកដល់ឆាប់ពេកហើយសំរាប់ហេរី។ វាបានទន្ទឹងរង់ចាំដើម្បីទៅ សាលាហុកវ៉ាត វិញមែន ប៉ុន្តែរយៈពេលប៉ុន្មានខែរបស់វានៅប៊្រូគឺជាពេលដ៏រីករាយបំផុតនៃជីវិតរបស់វា។ វាពិបាកក្នុងការមិនច្រណែននឹងរ៉ុនពេលវាបានគិតទៅដល់គ្រួសារឌើស្លី និងរបៀបនៃការស្វាគមន៍ដែលវាគិតថា នឹងកើតឡើងលើកក្រោយពេលវាត្រលប់ទៅនៅវិថីប្រាយវេដដ្រាយវិញ។

នៅល្ងាចចុងក្រោយរបស់ពួកគេ លោកស្រីវីស្លីបានប្រើសិល្ប៍ជប់ជាអាហារពេលល្ងាចដ៏អធិកអធមមួយដែលរួមមានទាំងរបស់ទាំងអស់ដែលហេរីចូលចិត្ត និងចុងក្រោយគឺនំប៉ាំស៊ីរ៉ូដែលធ្វើឲ្យស្រក់ទឹកមាត់មួយចាន។ ហ្វ្រេដ និងចចបានបញ្ចប់នៅពេលល្ងាចនោះដោយការបង្ហាញកាំជ្រួចហ្វីលីបាសទ័រ។ ពួកគេតុបតែងផ្ទះបាយដោយផ្កាយពណ៌ក្រហម និងខៀវ ដោយលោតចុះឡើងពីលើពិតានទៅជញ្ជាំង យ៉ាងហោចណាស់អស់មួយម៉ោងកន្លះ។ ក្រោយមក ដល់ពេលផឹកទឹកសូកូឡាក្តៅមួយពែងធំចុងក្រោយហើយចូលគេង។

វាចំនាយពេលយូរដើម្បីចាប់ផ្តើមចូលដល់ព្រឹកបន្ទាប់។ ពួកគេបានក្រោកនៅពេលព្រះអាទិត្យរះ ប៉ុន្តែមិនដឹងជាយ៉ាងម៉េចទេ ពួកគេហាក់ដូចជានៅមានកិច្ចការច្រើនត្រូវធ្វើទៀត។ អ្នកស្រីវីស្លីបានស្ទុះទៅរកស្រោមជើង និងស្លាបប៉ាកាដែលបានត្រៀមទុកទាំងអារម្មណ៍មិនល្អ ពួកគេបានរត់ប៉ះគ្នានៅលើជណ្តើរ ទាំងមានសម្លៀកបំពាក់មិនទាន់ត្រឹមត្រូវ និងនំប៉័ងអាំងបន្តិចនៅក្នុងដៃរបស់ពួកគេ ហើយលោកវីស្លីស្ទើរតែបាក់ក ដោយដួលលើមាន់វង្វេងផ្លូវមួយក្បាល ពេលគាត់ដើរកាត់ទីធ្លាយួរវ៉ាលិសរបស់ជីននីទៅដាក់ឡាន។

ហេរីមិនយល់សោះថាតើមនុស្សប្រាំបីនាក់ វ៉ាលិសប្រាំមួយធំៗ ទីទុយពីរក្បាល និងសត្វកណ្តុរមួយក្បាលអាចនឹងសមល្មមចូលទៅក្នុងឡាន ហ្វត អ៊ែងគ្លៀ បានយ៉ាងដូចម្តេចនោះទេ។ ពិតណាស់ វាបានប៉ាន់ស្មានដោយមិនគិតទាំងរបស់របរពិសេសជាច្រើនទៀតដែលលោកវីស្លីបានបន្ថែមទៀតនោះទេ។

- កុំនិយាយប្រាប់មូលីអី- គាត់ខ្សឹបដាក់ហេរី ពេលបើកឃ្លុបឡានខាងក្រោយ ហើយបង្ហាញថាតើឡានត្រូវបានពង្រីកដោយប្រើវេទមន្តតាមរបៀបណា ដើម្បីឲ្យវ៉ាលិសទាំងនោះអាចដាក់បានយ៉ាងស្រួល។

ចុងក្រោយពួកគេទាំងអស់បានស្ថិតនៅក្នុងឡាន លោកស្រីវីស្លីមើលទៅកៅអីខាងក្រោយ ដែលហេរី រ៉ុន ហ្វ្រេដ ចច និង ជៀរស៊ីទាំងអស់គ្នាកំពុងអង្គុយយ៉ាងស្រួលបន្តបន្ទាប់គ្នា ហើយគាត់និយាយថាៈ

- ពួកលោកិយពិតជាដឹងរឿងច្រើនជាងការដែលពួកយើងសរសេរទៅទៀត មែនទេ?- គាត់ និងជីននីចូលទៅអង្គុយនៅកៅអីមុខដែលត្រូវបានទាញ ដែលវាមើលទៅដូចជាកៅអីអង្គុយនៅសួនច្បារអញ្ចឹង។ - ខ្ញុំចង់មានន័យថា ឯងមិនដឹងទេថា វាគឺធំទូលាយពេលមើលពីខាងក្រៅ មែនទេ?

លោកវីស្លីបញ្ឆេះម៉ាស៊ីន ហើយពួកគេបានធ្វើដំណើរយឺតៗចេញពីទីធ្លា ហេរីងាកក្រោយបែរទៅមើលផ្ទះនោះជាលើកចុងក្រោយ។ វាគ្រាន់តែគិតថា វាអាចមកមើលផ្ទះនោះបានម្តងទៀតពេលពួកគេត្រូវបកមកវិញៈ ចចបានភ្លេចប្រអប់កាំជ្រួចហ្វីលីបាសទ័ររបស់វា។ ប្រាំនាទីក្រោយមក ពួកគេត្រូវឈប់ឡាននៅលើទីធ្លាផ្ទះម្តងទៀត ដើម្បីអោយចចរត់ចូលទៅយកអំបោសហោះរបស់វា។ ពួកគេធ្វើដំណើរជិតទៅផ្លូវថ្នល់ទៅហើយ ពេលជីននីស្រែកយ៉ាងខ្លាំងថា នាងបានភ្លេចសៀវភៅកំណត់ហេតុរបស់នាង។ ត្រឹមពេលដែលនាងតោងចូលក្នុងឡានវិញ ពួកគេកំពុងយឺតពេលច្រើនណាស់ ហើយកំហឹងក៏កាន់តែខ្លាំងឡើងៗដែរ។

លោកវីស្លីមើលទៅនាឡិកាដៃរបស់គាត់ ហើយមើលទៅប្រពន្ធរបស់គាត់។

- មូលី អូនសំឡាញ់...

- ទេ អស់សឺ។

- គ្មាននរណាម្នាក់អាចឃើញទេ។ គ្រាប់ចុចតូចមួយនៅទីនេះ គឺជាឧបករណ៍បំបាំងកាយមួយដែលបងបានដាក់...នោះវានឹងនាំយើងឡើងទៅលើអាកាស...បន្ទាប់មក ពួកយើងនឹងហោះលើពពក។ ពួកយើងនឹងទៅដល់ទីនោះក្នុងពេលដប់នាទី ហើយគ្មានមធ្យោបាយណាដែលឆ្លាតជាងនេះទៀតទេ...

- អូនថាទេគឺទេហើយ អស់សឺ មិនត្រូវប្រើវេទមន្តទាំងកណ្តាលថ្ងៃត្រង់អញ្ចឹងនោះទេ។

ពួកគេបានទៅស្ថានីយ៍ ឃីញក្រុស នៅម៉ោងដប់សែសិបប្រាំនាទី។ លោកវីស្លីរត់ឆ្លងផ្លូវយ៉ាងលឿនដើម្បីទៅយករទេះរុញសំរាប់ដាក់វ៉ាលិសរបស់ពួកគេ ហើយពួកគេទាំងអស់គ្នាបានប្រញាប់ចូលក្នុងស្ថានីយ៍នោះ។

ហេរីបានជិះរថភ្លើងល្បឿនលឿនរបស់សាលាហុកវ៉ាតកាលពីឆ្នាំមុន។ មានភាពរញ៉េរញ៉ៃបន្តិចដើម្បីចូលទៅច្រកផ្លូវប្រាំបួនបីភាគបួន ដែលមិនអាចមើលឃើញដោយភ្នែកពួកលោកិយបានទេ។ អ្វីដែលអ្នកត្រូវធ្វើគឺដើរបុករបាំងដ៏រឹងមាំដែលចែករវាងច្រកផ្លូវលេខប្រាំបួននិងលេខដប់។ វាមិនធ្វើឲ្យឈឺអ្វីទេ ប៉ុន្តែត្រូវធ្វើវាដោយប្រុងប្រយ័ត្នទើបគ្មានពួកលោកិយណាម្នាក់អាចកត់សំគាល់បានពេលអ្នកកំពុងរលាយបាត់ខ្លួន។

- ពៀរស៊ីទៅមុនគេ- អ្នកស្រីវីស្លីនិយាយ គាត់មើលទាំងមិនស្រួលចិត្តទៅនាឡិកានៅខាងលើដែលបង្ហាញថាពួកគេមានពេលត្រឹមតែប្រាំនាទីប៉ុណ្ណោះដើម្បីរត់ចូលដូចធម្មតាតាមរបាំងនោះ។

ពៀរស៊ីបានបោះជំហានយ៉ាងស្វាហាប់សំដៅទៅមុខ ហើយក៏រលាយបាត់ទៅ។ លោកវីស្លីទៅបន្ទាប់ ហ្វ្រេដ និងចចទៅតាមក្រោយ។

- ខ្ញុំនឹងនាំជីននីទៅ ហើយឯងទាំងពីរចូលទៅភ្លាមបន្ទាប់ពីពួកយើង- លោកស្រីវីស្លីប្រាប់ហេរី និងរ៉ុន រួចកញ្ចក់ដៃជីននីហើយចូលទៅ។ តែមួយប៉ប្រិចភ្នែកពួកគេក៏ទៅបាត់។

- តោះទៅជាមួយគ្នា យើងមានពេលតែមួយនាទីប៉ុណ្ណោះ- រ៉ុននិយាយទៅហេរី។

ហេរីប្រាកដថាទ្រុងរបស់ហ៊ីដវីកត្រូវបានសៀតចូលទៅលើវ៉ាលិសរបស់វាដោយសុវត្ថិភាព ហើយវាបានរុញរទេះរបស់វាឲ្យចំមុខរបាំងនោះ។ វាមានទំនុកចិត្តយ៉ាងខ្លាំង នេះគឺមិនមែនស្ទើរតែមិនមានសុវត្ថិភាពដូចការប្រើម្សៅភ្លូនោះទេ។ ពួកគេទាំងពីរបានបង្អោនខ្លួនឲ្យទាបជាងដងរទេះរុញរបស់ពួកគេ ហើយដើរយ៉ាងជឿជាក់សំដៅទៅរបាំងនោះដោយបង្កើនល្បឿនព្រមគ្នា។ សល់តែពីរបីជំហានទៀតពីរបាំង ពួកគេបានរត់បុកចូលទៅ ហើយ...

ផាំង

រទេះរុញទាំងពីរបានបុករបាំងនោះ ហើយបានខ្ទាតមកវិញ។ វ៉ាលិសរបស់រ៉ុនជ្រុះធ្លាក់មកឮយ៉ាងខ្លាំង ហេរីបានបុកដួលត្រូវជើង ហើយទ្រុងរបស់ហ៊ីដវីកបានខ្ទាតទៅលើកំរាលឥដ្ឋដ៏ភ្លឺរលោងរួចវាបានរមៀលទៅឆ្ងាយ វាស្រែកយ៉ាងឮដោយកំហឹង។ មនុស្សម្នាដែលនៅជុំវិញពួកគេបានសម្លឹងមើល ហើយសន្តិសុខម្នាក់នៅក្បែរនោះបានស្រែកៈ

- តើពួកឯងកំពុងធ្វើស្អីឆ្កួតៗហ្នឹង?

- ទប់រទេះមិនជាប់- ហេរីនិយាយទាំងដង្ហក់។ វាអោបឆ្អឹងជំនីររបស់វាពេលក្រោកឡើង។ រ៉ុនរត់ទៅរើសយកហ៊ីដវីក បង្កើតនូវទស្សនីយភាពមួយបង្កឲ្យមានការខ្សឹបខ្សៀវគ្នាពីសំនាក់មហាជនទាក់ទងនឹងភាពឃោរឃៅចំពោះសត្វ។

- ហេតុអ្វីបានជាយើងមិនអាចឆ្លងកាត់បាន?- ហេរីនិយាយតិចៗទៅរ៉ុន។

- ខ្ញុំមិនដឹងទេ...

រ៉ុនបានក្រឡេកមើលជុំវិញទាំងកំហឹង។ មនុស្សដែលចង់ដឹងរឿងដប់ពីរនាក់នៅតែមើលពួកគេ។

- ពួកយើងនឹងខករថភ្លើងហើយ- រ៉ុនខ្សឹប។ - ខ្ញុំមិនយល់ទេថាហេតុអ្វីបានជាច្រកចូលត្រូវបានបិទដោយឯងៗដូច្នេះ...

ហេរីមើលទៅនាឡិកាយក្សជាមួយនឹងអារម្មណ៍មិនស្រួលក្នុងក្រពះរបស់វា។ ដប់វិនាទី...ប្រាំបួនវិនាទី...

វាបានរុញរទេះរបស់វាទៅមុខដោយប្រុងប្រយ័ត្ន រហូតទាល់តែទៅដល់ទល់នឹងរបាំងនោះ ហើយរុញយ៉ាងខ្លាំងអស់ពីលទ្ធភាពរបស់វា។ លោហៈនោះនៅតែរឹងមាំដដែល។

បីវិនាទី...ពីរវិនាទី...មួយវិនាទី...

- វាហួសពេលហើយ- រ៉ុននិយាយដោយសំឡេងតក់ស្លុត។ - រថភ្លើងបានចេញហើយ។ តើធ្វើយ៉ាងម៉េចទៅបើប៉ានិងម៉ាក់មិនអាចត្រលប់មករកពួកយើងវិញនោះ? តើឯងមានលុយពួកលោកិយខ្លះទេ?

ហេរីសើចទាំងអស់កម្លាំង។ - គ្រួសារឌើស្លីមិនបានឲ្យលុយខ្ញុំដាក់ហោប៉ៅអស់ប្រាំមួយឆ្នាំមកហើយ។

រ៉ុនផ្ទឹបត្រចៀកវាទៅនឹងរបាំងត្រជាក់នោះ។

- មិនអាចឮអ្វីសោះ- វានិយាយទាំងព្រួយបារម្ភ។ - តើពួកយើងគិតធ្វើអ្វីទៅ? ខ្ញុំមិនដឹងថាតើវានឹងចំនាយពេលយូរប៉ុណ្ណាដើម្បីឲ្យម៉ាក់ និងប៉ាត្រលប់មករកពួកយើងវិញនោះទេ។

ពួកគេក្រឡេកមើលជុំវិញ។ មនុស្សម្នានៅតែមើលពួកវា ជាពិសេសក៏ព្រោះតែហ៊ីដវីកបន្តបន្លឺសំឡេងងីតៗ។

- ខ្ញុំគិតថាពួកយើងគួរតែទៅចាំជិះឡានវិញល្អជាង- ហេរីនិយាយ។ - ពួកយើងកំពុងទាក់ទាញការចាប់អារម្មណ៍ច្រើនពេកហើយ...

- ហេរី!- រ៉ុននិយាយ ភ្នែករបស់វាបង្ហាញភាពរីករាយ។ - ឡាននោះ!

- វាយ៉ាងម៉េច?

- ពួកយើងអាចជិះឡានហោះទៅសាលាហុកវ៉ាតបានណា!

- ប៉ុន្តែខ្ញុំគិតថា...

- ពួកយើងអស់ផ្លូវហើយ មែនទេ? ហើយពួកយើងត្រូវការទៅដល់សាលារៀន មែនទេ? ហើយប្រសិនបើវាគឺជារឿងបន្ទាន់មួយពិតមែននោះ ក៏វេទគូក្រោមអាយុត្រូវបានអនុញ្ញាតឲ្យប្រើវេទមន្តបានដែរ មាត្រាទីដប់ប្រាំបួន ក្នុងលក្ខខណ្ឌហាមឃាត់ឡប់ៗស្អីគេនោះ...

ហេរីកំពុងតែមានអារម្មណ៍ភ័យខ្លាចក៏ប្រែជារីករាយវិញភ្លាមៗ។

- តើឯងអាចបង្ហោះឡាននោះបានទេ?

- គ្មានបញ្ហាទេ- រ៉ុននិយាយ បង្វិលរទេះរបស់វាបែរទៅច្រកចេញវិញ។ - ឆាប់ឡើង តោះយើងទៅ! ប្រសិនបើយើងប្រញាប់ទៅ យើងអាចនឹងទៅតាមទាន់រថភ្លើងល្បឿនរបស់សាលាហុកវ៉ាត។

រួចហើយពួកគេក៏ដើរដោយរឹងប៉ឹងកាត់ហ្វូងពួកលោកិយដែលចង់ដឹងរឿងទាំងនោះ ចេញពីស្ថានីយ៍ ហើយត្រលប់ទៅតាមផ្លូវម្ខាងទៀតដែលឡាន ហ្វត អ៊ែងគ្លៀ ដ៏ចាស់ត្រូវបានយកទៅចត។

រ៉ុនបានបើកសោឃ្លុបដាក់តវ៉ាន់ដ៏ធំជ្រៅ ដោយប្រើចង្កឹះវេទមន្តគោះពីលើ។ ពួកគេបានលើកវ៉ាលិសរបស់ពួកគេដាក់ចូលទៅក្នុង និងដាក់ហ៊ីដវីកនៅកន្លែងអង្គុយខាងក្រោយ ហើយពួកគេចូលទៅអង្គុយខាងមុខ។

- មើលទៅគ្មាននរណាម្នាក់កំពុងមើលមកទៀតទេ- រ៉ុននិយាយ វាបញ្ឆេះម៉ាស៊ីនដោយប្រើចង្កឹះវេទមន្តរបស់វាគោះតិចៗម្តងទៀត។ ហេរីបានអើតក្បាលចេញក្រៅបង្អួចៈ ចរាចរណ៍កំពុងតែមមាញឹកនៅលើមហាវិថីខាងមុខនោះ ប៉ុន្តែពួកគេគ្មានជម្រើសទេ។

- តោះទៅ- វានិយាយ។

រ៉ុនបានចុចប៊ូតុងពណ៌ប្រាក់ដ៏តូចមួយនៅលើចង្កូត។ ផ្ទៃឡានក៏រលាយបាត់...ហើយពួកគេក៏អញ្ចឹងដែរ។ ហេរីមានអារម្មណ៍ថាកៅអីអង្គុយកំពុងញ័រនៅពីក្រោមវា វាឮសំឡេងម៉ាស៊ីន រួចវាដាក់ដៃលើជង្គង់ និងវ៉ែនតាលើច្រមុះ ប៉ុន្តែអ្វីដែលវាអាចមើលឃើញដោយបើកគ្រាប់ភ្នែកទាំងគូនោះគឺវាកំពុងអណ្តែតជើងផុតពីដីតាមផ្លូវកខ្វក់មួយពេញដោយឡានចត។

- តោះយើងទៅ- រ៉ុននិយាយនៅពីខាងស្តាំដៃរបស់វា។

នៅលើដី និងអគារកខ្វក់ទាំងនោះដែលនៅសងខាងផ្លូវបានឃ្លាតឆ្ងាយទៅៗ ចេញផុតពីចក្ខុនៅពេលឡានបានឡើងទៅលើ។ មួយភ្លែតក្រោយមក ទីក្រុងឡុងទាំងមូលបានគ្របដណ្តប់ដោយផ្សែង និងបញ្ចេញពន្លឺភ្លឺចិញ្ចាចនៅពីក្រោមពួកគេ។

ក្រោយមកមានសំឡេងផ្ទុះផស់ៗត្រូវនឹងឡាន ហេរី និងរ៉ុនក៏លេចខ្លួនឡើងវិញ។

- អុ អូ- រ៉ុននិយាយ។ វាចុចលើប៊ូតុងបំបាំងកាយយ៉ាងរហ័ស។ - វាមានបញ្ហាហើយ...

ពួកគេទាំងពីរបានចុចជាច្រើនដងលើវា។ ឡានបានបាត់រូបភ្លាមៗ។ ក្រោយមកវាបានបញ្ចេញភ្លើងភ្លឹបភ្លែតមកវិញម្តងទៀត។

- ចាំបន្តិចទៅ!- រ៉ុនបានស្រែក រួចវាបានយកជើងវារុញយ៉ាងខ្លាំងទៅលើឧបករណ៍បង្កើនល្បឿន។ ពួកគេធ្វើដំណើរបាញ់ឆ្ពោះទៅក្នុងពពកទាបៗមានរាងដូចរោមចៀម ហើយអ្វីៗគ្រប់យ៉ាងប្រែជាស្រអាប់ និងមានអ័ព្ទច្រើន។

- ឥឡូវធ្វើយ៉ាងម៉េចទៀត?- ហេរីនិយាយ វាធ្វើភ្នែកព្រិចៗមើលទៅផ្ទាំងពពកដ៏ក្រាស់កំពុងគ្របដណ្តប់លើពួកគេគ្រប់កន្លែង។

- ពួកយើងត្រូវរករថភ្លើងឲ្យឃើញដើម្បីដឹងថាត្រូវទៅតាមទិសណា- រ៉ុននិយាយ។

- ចុះក្រោមវិញម្តងទៀត...លឿនឡើង...

ពួកគេបានធ្វើដំណើរចុះក្រោមពពក និងប្រែខ្លួនលើកន្លែងអង្គុយរបស់ពួកគេ រួចបើកភ្នែកព្រឹមៗមើលទៅខាងក្រោម...

- ខ្ញុំមើលឃើញវាហើយ!- ហេរីស្រែក។ - នៅខាងមុខនោះ...នៅទីនោះ!

រថភ្លើងល្បឿនលឿនរបស់សាលាហុកវ៉ាតកំពុងធ្វើដំណើរយ៉ាងលឿននៅពីក្រោមពួកគេ ហាក់ដូចជាពស់ពណ៌ក្រហមឆ្អិនឆ្អៅមួយ។

- តាមទិសខាងជើងច្បាស់ណាស់- រ៉ុននិយាយ។ វាពិនិត្យមើលត្រីវិស័យនៅលើចង្កូតឡាន។ - មែនហើយ ពួកយើងនឹងគ្រាន់តែត្រូវពិនិត្យមើលវារៀងរាល់មួយម៉ោងកន្លះ រឺច្រើនជាងនេះម្តង។ នៅឲ្យស្ងៀម...- រួចហើយពួកគេបានធ្វើដំណើរឆ្ពោះទៅកាត់តាមពពក។ មួយភ្លែតក្រោយមក ពួកគេបានចូលទៅក្នុងកន្លែងដែលមានពន្លឺព្រះអាទិត្យចែងចាំង។

វាគឺជាពិភពដ៏ខុសគ្នាមួយ។ កង់ឡានរអិលពីលើពពកទន់ៗដែលមានពន្លឺព្រិចៗ ផ្ទៃមេឃភ្លឺពណ៌ខៀវគ្មានទីបញ្ចប់ នៅពីក្រោមព្រះអាទិត្យដ៏ភ្លឺចិញ្ចាចចិញ្ចែង។

- អ្វីដែលយើងត្រូវតែបារម្ភនៅពេលឥឡូវនេះគឺយន្តហោះ- រ៉ុននិយាយ។

ពួកគេមើលមុខគ្នារួចចាប់ផ្តើមសើច អស់យ៉ាងយូរ ពួកគេនៅតែសើចមិនឈប់។

វាហាក់ដូចជាពួកគេត្រូវបានធ្លាក់ចូលទៅក្នុងសុបិនដ៏អស្ចារ្យមួយ។ ហេរីគិតថានេះប្រាកដជាផ្លូវតែមួយគត់ដើម្បីធ្វើដំណើរៈ ដោយត្រូវឆ្លងកាត់គំនួច និងដុំពពកព្រិលតូចៗជាច្រើន នៅក្នុងឡានគ្របដណ្តប់ដោយពន្លឺព្រះអាទិត្យភ្លឺចែងចាំងដ៏សែនក្តៅ និងមានកញ្ចក់ស្ករសូកូឡាដ៏ធំមួយនៅក្នុងប្រអប់ដាក់ឥវ៉ាន់ខាងមុខ ហើយនិងការទន្ទឹងរង់ចាំមើលមុខច្រណែនរបស់ហ្វ្រេដ និងចច នៅពេលពួកគេបានចុះចតដោយស្រួលជាពិសេសនៅលើវាលស្មៅគ្មានចន្លោះនៅពីមុខប្រាសាទសាលាហុកវ៉ាត។

ពួកគេបានពិនិត្យតាមដានយ៉ាងជាប់លើរថភ្លើងនៅពេលពួកគេហោះគាន់តែឆ្ងាយទៅៗទៅទិសខាងជើង រាល់ការចុះក្រោមពពកម្តងៗ គឺបានបង្ហាញពួកគេនូវទេសភាពខុសៗគ្នា។ ទីក្រុងឡុងពេលនេះស្ថិតនៅខាងក្រោយឆ្ងាយពីពួកគេ ហើយត្រូវជំនួសទៅដោយវាលពណ៌បៃតងស្រស់ស្អាតវិញ ខ្ពង់រាបពណ៌ស្វាយដ៏ធំល្វឹងល្វើយ មានភូមិដែលមានព្រះវិហារកាតូលិកតូចៗ និងទីក្រុងដ៏ធំមួយពេញដោយឡានដូចជាស្រមោចចំរុះពណ៌។

ទោះបីជាយ៉ាងណាក៏ដោយ អស់រយៈពេលជាច្រើនម៉ោងដែលគ្មានអ្វីកើតក្រោយមក ហេរីត្រូវតែទទួលស្គាល់ថាសំណើចខ្លះៗត្រូវបានបញ្ឈប់។ ស្ករសូកូឡាបានធ្វើឲ្យពួកគេស្រេកទឹកយ៉ាងខ្លាំង ហើយពួកគេគ្មានអ្វីផឹកនោះទេ។ វា និងរ៉ុនបានទាញយកអាវរងារបស់ពួកគេ ប៉ុន្តែអាវយឺតរបស់ហេរីបានជាប់ស្អិតទៅនឹងខាងក្រោយកៅអីអង្គុយរបស់វា ហើយវ៉ែនតារបស់វានៅតែរអិលធ្លាក់មកចុងច្រមុះសុទ្ធតែញើសរបស់វា។ ឥឡូវនេះ ហេរីឈប់ចាប់អារម្មណ៍លើរូបរាងពពកដ៏អស្ចារ្យនោះទៀតហើយ វាកំពុងគិតយ៉ាងយូរពីចម្ងាយដ៏ឆ្ងាយនៃផ្លូវរថភ្លើងនៅខាងក្រោមដែលជាកន្លែងអ្នកអាចទិញទឹកផ្លែល្ពៅត្រជាក់ខ្លាំងពីរទេះរុញមួយ រុញដោយស្ត្រីវេទគូម្នាក់រាងធាត់បន្តិច។ ហេតុអ្វីបានជាពួកគេមិនអាចចូលក្នុងតាមច្រកផ្លូវប្រាំបួនបីភាគបួនបាន?

- វាមិនអាចឆ្ងាយជាងទេ មែនទេ?- រ៉ុននិយាយគ្រលរៗ អស់ច្រើនម៉ោងក្រោយមកនៅតែដដែល ដល់ពេលព្រះអាទិត្យចាប់អស្តង្គតចូលទៅក្នុងផ្ទាំងពពក ហើយប្រែពណ៌ជាពណ៌ផ្កាឈូកលាស់។ - តើគេធ្វើការពិនិត្យនៅលើរថភ្លើងហើយរឺនៅ ន់?

## ដើមឈើ ទុំមតីខ វីឡូ

វានៅតែស្ថិតនៅខាងក្រោមពួកគេ វាបត់បែនតាមផ្លូវរបស់វាដោយឆ្លងកាត់ភ្នំព្រិលមួយ។ វាកាន់តែងងឹតទៅៗក្រោមដំបូលដុំពពក។

រ៉ុនយកជើងរបស់វាជាន់លើឧបករណ៍បង្កើនល្បឿន ហើយបើកឡើងទៅលើម្តងទៀត ប៉ុន្តែពេលវាធ្វើដូច្នេះ គ្រឿងម៉ាស៊ីនចាប់ផ្តើមបញ្ចេញសំឡេងចម្លែក។

ហែរី និងរ៉ុនមើលមុខគ្នាទាំងងឿងឆ្ងល់។

- វាទំនងជាគ្រាន់តែអស់កំលាំងប៉ុណ្ណោះ- រ៉ុននិយាយ - វាមិនដែលអញ្ចឹងទេពីមុនមក...

ពួកគេទាំងពីរធ្វើពុតជាមិនឮសំឡេងចម្លែកនោះដែលកាន់តែឮឡើងៗនៅពេលមេឃនៅតែងងឹតមិនប្រែប្រួល។ ហ្វូងតារាកំពុងបញ្ចេញពន្លឺក្នុងសភាពខ្មៅងងឹត។ ហែរីបានទាញយកអាវរងារបស់វាមកដណ្តប់ និងព្យាយាមមិនខ្វល់នឹងសកម្មភាពរបស់ផ្លិតទឹកនៅខាងមុខដែលកំពុងបក់រវិចៗយ៉ាងខ្សោយដូចជាស្ថិតក្នុងភាពបញ្ច្រាស។

- មិនឆ្ងាយទេ- រ៉ុននិយាយទៅឡានច្រើនជាងទៅកាន់ហែរី។ - មិនឆ្ងាយទៀតទេ- រួចវាទះលើចង្កូតទាំងព្រួយបារម្ភ។

នៅពេលពួកគេហោះក្រោមពពកអស់ពេលមួយភ្លែតក្រោយមក ពួកគេត្រូវតែបើកភ្នែកព្រឹមៗមើលទៅកន្លែងមួយដែលពួកគេចំណាំបាន។

- ទីនោះហើយ!- ហែរីស្រែកធ្វើឲ្យរ៉ុននិងហ៊ីដវីកភ្ញាក់ព្រើត។ - ទៅខាងមុខភ្លាមទៅ!

ដោយស្ថិតជាស្រមោលនៅឯជើងមេឃខ្មៅងងឹត នៅលើផ្ទាំងថ្មខ្ពស់ផុតពីបឹងនោះ វាបានបង្ហាញឡើងនូវកំពូលនិងប៉មតូចៗនៃប្រាសាទសាលាហុកវ៉ាត។

ប៉ុន្តែឡានចាប់ផ្តើមញាក់ញ័រ ហើយលែងបង្កើនល្បឿនបាន។

- ឆាប់ឡើង- រ៉ុននិយាយទាំងលួងលោម វាកាច់ចង្កូចឡានរាងញ័របន្តិច - ជិតដល់ទីនោះហើយ ឆាប់ឡើង...

ម៉ាស៊ីនឡានបានបញ្ចេញសំឡេងថ្ងូរ។ ចំហាយតិចៗបានភាយចេញពីគំរបម៉ាស៊ីនឡាន។ ហែរីដឹងខ្លួនវាកំពុងកាន់តែមកៅអីអង្គុយរបស់វាយ៉ាងជាប់ពេលពួកគេហោះសំដៅទៅបឹងនោះ។

ឡាននោះបានរង្គើយ៉ាងខ្លាំង។ ក្រឡេកមើលទៅក្រៅកញ្ចក់របស់វា ហែរីបានឃើញផ្ទៃទឹកថ្លាមានពណ៌ខ្មៅរលោងស្រិលនៅជាមួយគីឡូម៉ែតខាងក្រោមនោះ។ ក្រញាំដៃរបស់រ៉ុនឡើងស្លេកស្លាំងនៅលើចង្កូតឡាន។ ឡាននោះបានរង្គើម្តងទៀត។

- លឿនឡើង- រ៉ុននិយាយខ្សឹបៗ។

ពួកគេស្ថិតនៅពីលើបឹងនោះ...ប្រាសាទស្ថិតនៅខាងមុខ...រ៉ុនដាក់ជើងវាចុះក្រោម។

មានសំឡេងទង្គិចដ៏ខ្លាំងមួយនិងសំឡេងផ្ទុះផស់ៗ រួចហើយម៉ាស៊ីនឡានបានគាំងទាំងស្រុង។

- ពុទ្ធោ- រ៉ុននិយាយស្ងាត់ៗ។

ផ្នែកខាងមុខឡានបានដាំចុះ។ ពួកគេកំពុងធ្លាក់ចុះដោយល្បឿនព្រមគ្នាសំដៅត្រង់ទៅជញ្ជាំងប្រាសាទដ៏រឹងមាំនោះ។

- ទេ!- រ៉ុនស្រែក បង្វិលចង្កូតឡានជុំវិញ ពួកគេបានបុកនឹងជញ្ជាំងថ្មខ្មៅជាច្រើនដងនៅពេលឡានប្រែជាកោងដូចធ្នូដ៏ធំមួយ សំកាំងពីលើផ្ទាំងកញ្ចក់ក្រាស់ៗ ហើយក្រោយមកធ្លាក់មកលើចំការបន្លែ និងបន្ទាប់មកចេញមកលើវាលស្មៅខ្មៅ រួចធ្លាក់ចុះមកបន្តទៀត។

រ៉ុនបានទៅចាប់កាច់ចង្កូតយ៉ាងជាប់ រួចទាញយកចង្កឹះវេទមន្តរបស់វាចេញពីហោប៉ៅក្រោយមក។

- ឈប់! ឈប់!- វាស្រែក វាទះលើចង្កូតឡាននិងកញ្ចក់មុខ ប៉ុន្តែពួកគេនៅតែបន្តធ្លាក់ចុះមកក្រោម ហើយជិតធ្លាក់ដល់ដីហើយ...

- ប្រយ័ត្នដើមឈើនោះ!- ហេរីស្រែកយ៉ាងខ្លាំង។ វាហក់ទៅចាប់ចង្កូត ប៉ុន្តែយឺតពេលហើយ...

ប៉ូក

ពួកគេបានបុកនឹងមែកឈើដ៏ធំមួយ ហើយធ្លាក់ចុះមកក្រោយដោយកក្រើកយ៉ាងខ្លាំងជាមួយនឹងសំឡេងនៃគ្រឿងលោហៈបុកនឹងឈើដ៏ព្ទខ្លាំងមួយ។ ចំហាយបានកំពុងភាយចេញពីក្រោមគំរបម៉ាស៊ីនដែលខ្ទេចខ្ទីអស់។ ហ៊ីដវីកកំពុងស្រែកយ៉ាងគ្រលួចក្នុងសភាពភ័យខ្លាច ស្នាមពកមួយដុំបានលេចឡើងឈឺខ្ទោកៗនៅលើក្បាលរបស់ហេរី ដែលវាបានបុកនឹងកញ្ចក់មុខ ហើយនៅខាងស្តាំដៃវាវិញគឺរ៉ុនបានស្រែកថ្ងូរតិចៗទាំងអស់សង្ឃឹម។

- តើឯងមិនអីទេរឺ?- ហេរីនិយាយទាំងបន្ទាន់។

- ចង្កឹះវេទមន្តរបស់ខ្ញុំ- រ៉ុននិយាយដោយសំឡេងខ្សាវៗ។ - មើលចង្កឹះខ្ញុំទៅ។

វាត្រូវបានបាក់ស្ទើរតែដាច់ជាពីរកំណាត់ ចុងរបស់វាកំពុងសំយុងចុះយ៉ាងទន់ និងយោលតិចៗ ហាក់ដូចជាបាក់ជាបំនែកតូចៗពីរបី។

ហេរីហើបមាត់និយាយថាវាជឿជាក់ ពួកគេនឹងអាចជួសជុលវាវិញបាននៅសាលា ប៉ុន្តែវាមិនដែលធ្លាប់បានសាកល្បងម្តងទេ។ រំពេចនោះ ស្រាប់តែមានអ្វីម្យ៉ាងបានបុកនឹងឡានរបស់វា ដោយកំហឹងដូចសត្វពាហនៈបោលមក ធ្វើឲ្យវាទ្រេតខ្លួនទៅលើរ៉ុនដែលអាចស្មើនឹងកំលាំងបុកដ៏ខ្លាំងមួយទៅលើដំបូល។

- មានរឿងអីហ្នឹង...?

រ៉ុនដង្ហក់ សំឡឹងមើលទៅកញ្ចក់មុខ ហើយហេរីសំលឹងមើលជុំវិញដោយនៅពេលនោះវាឃើញមែកឈើមួយដ៏ធំដូចពស់ថ្លាន់មួយក្បាលបុកទំលុះចូលមក។ ដើមឈើដែលពួកគេបានបុកនោះកំពុងវាយប្រហារពួកគេវិញ។ មែករបស់វាត្រូវបានពត់ស្ទើរចេញជាពីរ ហើយមែកដែលមានពកៗច្រើនរបស់វាបានកំពុងវាយវាត់មកលើឡានគ្រប់ទីកន្លែងទាំងអស់ ឲ្យតែឈោងដល់។

- អាក...!- រ៉ុនឧទានឡើងពេលមានមែកឈើដ៏ធំមួយផ្សេងទៀតបានបុកទំលុះចូលធ្វើឲ្យមានស្នាមកំពិតនៅទ្វាររបស់វា។ កញ្ចក់មុខនៅពេលនោះបានរង្គើស្អិតនៅក្រោមការវាយប្រហារជាច្រើនដងពីគន្លាក់មែកឈើតូចៗ ហើយមានមែកឈើមួយធំដូចដំបងកំពុងវាយដោយកំហឹងយ៉ាងខ្លាំងពីលើដំបូលដែលហាក់ដូចជានឹងត្រូវស្រុតចុះ...

- រត់ចេញទៅ!- រ៉ុនស្រែករួចបញ្ចេញកម្លាំងអស់ពីខ្លួនបុកនឹងទ្វាររបស់វា ប៉ុន្តែក្រោយមកវាត្រូវដួលមកក្រោយវិញទៅលើភ្លៅរបស់ហេរីដោយសារការបុកទំលុះដ៏ខ្លាំងនៅ ខាងលើពីមែកឈើមួយផ្សេងទៀត។

- ចប់ហើយតែប៉ុណ្ណេះ!- រ៉ុនថ្ងូរនៅពេលពិតានបានធ្លាក់ ប៉ុន្តែភ្លាមៗនោះ បាតឡានបានរង្គើ...ម៉ាស៊ីនឡានបានឆេះឡើងវិញ។

- ត្រលប់ក្រោយទៅ!- ហេរីស្រែក ហើយឡានក៏ត្រលប់ក្រោយយ៉ាងលឿន។ ដើមឈើនោះនៅតែព្យាយាមវាយលុកពួកគេ។ ពួកគេអាចឮរឹសរបស់វាបញ្ចេញសំឡេងក្រេតក្រតៗស្ទើរតែធ្វើឲ្យរបើកខ្លួនវា រួចគ្រវីគ្រវាត់ពួកគេនៅពេលពួកគេបង្កើនល្បឿនដើម្បីចេញឲ្យផុត។

- វា- រ៉ុនដង្ហក់ - ជួយយើង។ ធ្វើបានល្អមែន ឡាននេះ។

## ដើមឈើ ទុំមតីខ ទីឡូ

ទោះបីជាយ៉ាងណាក៏ដោយ ឡាននោះបានបញ្ចេញអស់កម្លាំងរលីង។ ដោយសូរគ្រាំងពីរ ទ្វារបានបើកចេញ ហើយហេរីដឹងថាវាបានធ្លាក់ចេញឆ្ងាយពីកៅអីអង្គុយៈ រឿងបន្ទាប់ដែលវាដឹងគឺវាត្រូវដេកសន្ធឹងនៅលើដីសើម។ សូរក្អុកយ៉ាងឮប្រាប់ឲ្យដឹងថាឡាននោះបានគ្រវែងវ៉ាលិសរបស់ពួកគេចេញពីឃ្លុបឡាន។ ទ្រុងរបស់ហ៊ីដវីកហោះឡើងទៅលើ ហើយរបើកចេញ។ វាបានខ្ទាតចេញពីទ្រុងដោយសំរែកទាំងកំហឹងយ៉ាងលឺ ហើយបានបង្កើនល្បឿនហោះចេញទៅ សំដៅទៅប្រាសាទដោយគ្មានបកក្រោយមើលសោះ។ ក្រោមមក ដោយមានស្នាមកំពិត ស្នាមឆូត និងចំហាយភាយចេញ ឡាននោះបានបើកចេញទៅលាន់សូរសន្ធឹកចូលក្នុងទីងងឹត ចង្កៀងភ្លើងក្រោយរបស់វាកំពុងបញ្ចេញពន្លឺយ៉ាងខ្លាំងទៅទាំងកំហឹង។

- ត្រលប់មកវិញមក៏!- រ៉ុនស្រែកក្រោយពីឡានចេញទៅ រួចវាគ្រវីចង្កឹះបាក់របស់វា។ - ប៉ានឹងសម្លាប់ខ្ញុំហើយ!

ប៉ុន្តែឡាននោះបានចេញទៅបាត់ស្រមោលដោយបញ្ចេញផ្សែងដ៏ខ្លាំងចុងក្រោយមួយចេញមក។

- តើឯងអាចជឿថា នេះជាសំណាងរបស់ពួកយើងរឺ?- រ៉ុននិយាយទាំងមិនសប្បាយចិត្ត វាអោនទៅរើសកណ្តុរស្កេបបើរ។ - អញ្ចឹងរាល់ដើមឈើទាំងអស់ដែលយើងអាចបុកនោះ យើងនឹងត្រូវតែទទួលការវាយបកវិញ។

វាបានក្រឡេកមើលទៅដើមឈើបុរាណនោះដែលនៅតែបោកបក់មែករបស់វាដោយភាពព្រមាន។

- លឿនឡើង!- ហេរីនិយាយទាំងអស់កម្លាំង។ - ពួកយើងគួរតែក្រោកឡើងទៅសាលាវិញប្រសើរជាង...

វាមិនមែនជាការមកដល់ដោយសប្បាយរីករាយដូចដែលពួកគេបានស្រមៃសោះ។ ពួកគេបានចាប់តែមវ៉ាលិសរបស់ពួកគេ ហើយចាប់ផ្តើមអូសវាតាមជំរាលដែលមានស្មៅ ទាំងស្ពឹកខ្លួន រងា និងមានស្នាមជាំ សំដៅទ្វារមុខដែលមានដើមសែនដ៏ធំមួយ។

- ខ្ញុំគិតថាពិធីជប់លៀងត្រូវបានចាប់ផ្តើមរួចហើយ- រ៉ុននិយាយ រួចវាទំលាក់វ៉ាលិសរបស់វាចុះទៅបាតជណ្តើរខាងមុខ ហើយដើរឆ្លងទៅយ៉ាងស្ងាត់ៗ ដើម្បីមើលតាមបង្អួចដ៏មានពន្លឺភ្លឺចែងចាំងមួយ។ - ហេ! ហេរី មកមើលមក៏...វាគឺជាពិធីបែងចែកអគារទេតើ!

ហេរីបានប្រញាប់ទៅ ហើយទាំងអស់គ្នា វានិងរ៉ុនបានមើលទៅក្នុងមហាសាល។

ទៀនដ៏ច្រើនរាប់មិនអស់កំពុងសំកាំងលើអាកាសពីលើតុវែងៗបួនដែលមានមនុស្សច្រើនអង្គុយ ធ្វើឲ្យចានមានពន្លឺពណ៌មាសនិងកែវដេញពន្លឺផ្លេកៗ។ នៅខាងលើវិញ មានពិតានគួរឲ្យទាក់ចិត្តដែលតែងតែឆ្លុះទៅនឹងផ្ទៃមេឃនៅខាងក្រៅដែលមានពន្លឺផ្កាយភ្លឺផ្លេក។

ដោយមិនខ្វល់ពីមួកហុកវ៉ាត ពណ៌ខ្មៅស្រួច ហេរីបានឃើញពួកសិស្សឆ្នាំទីមួយមួយជួរវែងដែលប្រកបដោយភាពភ្ញាក់ផ្អើលទាំងភ័យខ្លាចកំពុងដើរជាជួរចូលទៅក្នុងសាល។ ជីននីស្ថិតក្នុងចំនោមពួកគេនោះ ដែលងាយស្រួលនឹងមើលឃើញដោយសារសក់ពណ៌ឆេតនៃត្រកូលវីស្លីរបស់នាង។ នៅក្នុងកំឡុងពេលនោះ អ្នកស្រីសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល គឺជាស្ត្រីវេទគូដែលពាក់វ៉ែនតាម្នាក់និងសក់របស់គាត់បួងទៅក្រោយលើកឡើងលើ កំពុងដាក់មួកសិល្ប៍សាលាហុកវ៉ាតដ៏ល្បីល្បាញនៅលើជើងម៉ាមួយមុននឹងពួកសិស្សថ្មីមកដល់។

ជារៀងរាល់ឆ្នាំ មួកចាស់ដែលមានស្នាមបំណះរសាត់ដាច់សាច់ និងគគ្រិចមួយនេះបានរៀបចំសិស្សថ្មីចូលទៅក្នុងក្រុមទាំងបួនរបស់សាលាហុកវ៉ាត (ហ្គ្រីហ្វីនដ័រ ហាហ្វ៊លផហ្វ រ៉ាវីនក្លាហ្វ និងស្លីតឺរីន)។ ពិតណាស់ កាលមួយឆ្នាំកន្លងទៅ ហេរី នៅចាំយ៉ាងច្បាស់ថាវាបានដាក់មួកនោះលើក្បាល ហើយរង់ចាំទាំងភ័យខ្លាចយ៉ាងខ្លាំង ចំពោះការសម្រេចចិត្តរបស់មួកសិល្ប៍ ដែលនិយាយខ្សាវៗយ៉ាងឮៗដាក់ត្រចៀករបស់វា។ អស់រយៈពេលពីរបីនាទីយ៉ាងរន្ធត់ វាភ័យខ្លាចថាមួកនោះនឹងដាក់វាទៅក្នុងក្រុម

ស្លីតឺរីន ដែលជាក្រុមមានវត្តមានពួកវេទគូស្រីប្រុសចិត្តអាក្រក់ៗច្រើនជាងក្រុមដទៃទៀត...ប៉ុន្តែវាបានឈានចូលក្នុងក្រុមហ្គ្រីហ្វិនដ័ររួមជាមួយ រ៉ុន ហឺម៉ាយអូនី និងត្រកូលវីស្លីទាំងអស់។ ចុងក្រោយ ហេរី និងរ៉ុនបានជួយឲ្យក្រុមហ្គ្រីហ្វិនដ័រឈ្នះជើងឯកប្រចាំឆ្នាំដោយបានផ្តួលក្រុមស្លីតឺរីនជាលើកដំបូងក្នុងរយៈពេលប្រាំពីរឆ្នាំមកហើយ។

ក្មេងប្រុសសក់ពណ៌ត្នោតស្រអាប់តូចម្នាក់ត្រូវបានហៅទៅខាងមុខដើម្បីពាក់មួកនោះនៅលើក្បាលរបស់វា។ ភ្នែករបស់ហេរីក្រឡេកយ៉ាងលឿនកាត់ក្មេងនោះសំដៅទៅកន្លែង ដែលលោកសាស្ត្រាចារ្យដាំប៊័លដ័រ ដែលជានាយកសាលាកំពុងអង្គុយមើលទៅពិធីបែងចែកអគារពីតុឈើ ពុកចង្កាពណ៌ប្រាក់ដ៏វែងរបស់គាត់ និងវ៉ែនតារាងចំណិតព្រះខែកំពុងបញ្ចេញពន្លឺយ៉ាងភ្លឺតបនឹងពន្លឺភ្លើងទៀន។ កន្លែងអង្គុយជាច្រើននៅតាមបណ្តោយនោះ ហេរីបានឃើញលោក ហ្គីលដឺរ៉យ ឡក់ហាតស្លៀករ៉ូបពណ៌បៃតងមរកត។ នៅខាងចុងទីនោះគឺហាហ្គ្រីដជាមនុស្សមាឌធំ និងមានរោមច្រើនកំពុងផឹកទឹកយ៉ាងច្រើនពីកែវរបស់គាត់។

- ចាំមួយភ្លែត...- ហេរីនិយាយតិចៗទៅកាន់រ៉ុន។ - មានកៅអីទំនេរមួយនៅតុសាស្ត្រាចារ្យ...តើស្នេពនៅឯណា?

លោកសាស្ត្រាចារ្យសេវេរូស ស្នេពគឺជាគ្រូដែលហេរីចូលចិត្តតិចបំផុត។ ហេរីក៏ជាសិស្សដែលស្នេពចូលចិត្តតិចបំផុតដែរ។ ស្នេពបង្រៀនផ្នែកឱសថដែលជាគ្រូកាច ចូលចិត្តចំអកនិងមិនគួរឲ្យចូលចិត្តពីអ្នករាល់គ្នា លើកលែងតែសិស្សមកពីក្រុមគាត់ផ្ទាល់ (ស្លីតឺរីន)។

- ប្រហែលជាគាត់ឈឺហើយ!- រ៉ុននិយាយយ៉ាងជឿជាក់។

- ប្រហែលជាគាត់ត្រូវចាកចេញហើយ- ហេរីនិយាយ - ពីព្រោះតែគាត់គ្មានឱកាសសម្រាប់ការងារជាគ្រូបង្រៀនមុខវិជ្ជាការពារប្រឆាំងនឹងមន្តអាគមងងឹតម្តងទៀត!

- រឺមួយគាត់អាចត្រូវបានគេបណ្តេញចេញ!- រ៉ុននិយាយយ៉ាងត្រេកអរ។ - ខ្ញុំចង់មានន័យថា អ្នករាល់គ្នាស្អប់គាត់...

- រឺប្រហែលជា- សំលេងដ៏ស្រាលមួយបន្លឺឡើងនៅពីក្រោយពួកគេ - គាត់កំពុងរង់ចាំដំណឹងថាហេតុអ្វីបានជាពួកឯងទាំងពីរមិនបានមកជិះក្នុងរថភ្លើងសាលា។

ហេរីបានបែរមកក្រោយ។ លោកសាស្ត្រាចារ្យ សេវេរូស ស្នេព បានឈរនៅទីនោះក្នុងសំលៀកបំពាក់រ៉ូបពណ៌ខ្មៅ របស់គាត់ដែលមានស្នាមរហែក។ គាត់គឺជាបុរសស្គមម្នាក់ដែលមានស្បែកលឿងព្រឿងៗច្រមុះកោង មានខ្លាញ់ច្រើន ហើយមានសក់ខ្មៅវែងត្រឹមស្មា។ នៅខណៈនោះ គាត់បានញញឹមក្នុងន័យប្រាប់ហេរីថា វានិងរ៉ុនស្ថិតនៅក្នុងបញ្ហាដ៏ធ្ងន់ធ្ងរមួយហើយ។

- តាមខ្ញុំមក- ស្នេពនិយាយ។

ដោយមិនហ៊ានសូម្បីតែមើលមុខគ្នា ហេរី និងរ៉ុនដើរតាមស្នេពឡើងជណ្តើរចូលទៅទ្វារចូលសាលដ៏ធំមួយស្រដៀងនឹងគ្នានោះ ដែលបំភ្លឺដោយពិលយ៉ាងភ្លឺ។ ក្លិនអាហារដ៏ឈ្ងុយកំពុងបង្ហើរចេញមកពីសាលដ៏ធំនោះ ប៉ុន្តែស្នេពបាននាំពួកគេចេញទៅឆ្ងាយពីកន្លែងកក់ក្តៅ និងមានពន្លឺនោះចុះទៅតាមជណ្តើរថ្មចង្អៀតដែលនាំទៅកាន់គុកងងឹតវិញ។

- ចូលទៅ!- គាត់និយាយ គាត់បានបើកទ្វារមួយត្រឹមពាក់កណ្តាល នៅតាមច្រកដ៏ត្រជាក់ ហើយចង្អុលទៅ។

ពួកគេបានចូលទៅក្នុងការិយាល័យរបស់ស្នេពទាំងភាពញើញ័រ។ ស្រមោលតាមជញ្ជាំងស្ថិតនៅខាងក្នុងជាមួយធ្នើរដាក់កែវធំៗដែលបណ្តែតរាល់វត្ថុអាក្រក់ៗទាំងអស់ដែលហេរីពិតជាមិនចង់ស្គាល់ឈ្មោះឡើយនៅពេលនោះ។ ឡចង្ក្រានមានសភាពងងឹត និងទទេរស្អាត។ ស្នេពបានបិទទ្វារ ហើយបែរមកមើលពួកគេ។

- មានន័យថា- គាត់និយាយយ៉ាងស្រទន់ - រថភ្លើងនោះវាមិនល្អគ្រប់គ្រាន់សម្រាប់ហេរី ផោតធ័រដ៏ល្បីល្បាញ និងមិត្តវីស្លីដែលចេះជួយយកអាសា និងស្មោះត្រង់របស់គេនោះទេ ពួកឯងត្រូវការធ្វើដំណើរមកដល់ដោយមានការចាប់អារម្មណ៍មែនទេ ហ៎ា?

- ទេ លោកសាស្ត្រាចារ្យ វាដោយសារតែរបាំងនៅស្ថានីយ៍ឃីញក្រុស វា...

- ស្ងាត់ទៅ!- ស្នេពនិយាយទាំងគំរោះគំរើយ។ - តើពួកឯងបានធ្វើអ្វីខ្លះជាមួយឡាននោះ?

រ៉ុនលេបទឹកមាត់ក្អឿក។ នេះមិនមែនជាលើកដំបូងទេ ដែលស្នេពផ្តល់ឲ្យ ហេរី នូវគំនិតមួយយល់ថា គាត់ចេះមើលចិត្តមនុស្សធ្លុះ។ ប៉ុន្តែមួយភ្លែតក្រោយមក វាបានយល់នៅពេលស្នេពពន្លាតក្រដាសកាសែតស៊ីពីព័ត៌មានថ្ងៃនេះនៃសារពត៌មានផេទគូពេលល្ងាច។

- ពួកឯងត្រូវបានគេឃើញហើយ- គាត់បន្លឺសំឡេងលឺសូរស៊ីៗ គាត់បង្ហាញពួកគេពីចំណងជើងធំៗ៖ ឡានហោះម៉ាក ហ្វត អ៊ែងគ្លៀធ្វើឲ្យពួកលោកិយស្រឡាំងកាំង។ គាត់ចាប់ផ្តើមអានឮៗ។ - ពួកលោកិយពីរនាក់នៅទីក្រុងឡុងដឿថាពួកគេបានប្រទះឃើញឡានចាស់មួយបានកំពុងហោះហើរពីលើអាគារការិយាល័យប្រៃសណីយ៍...នៅពេលថ្ងៃត្រង់នៅក្នុងតំបន់ ណ័រហ្វុក អ្នកស្រី ហេធី បៃលីស ខណៈពេលកំពុងហាលខោអាវរបស់គាត់...លោក អេនហ្គុស ហ្លីត នៃត្រកូល ភីបបល បានរាយការណ៍ប្រាប់ប៉ូលីស...សរុបទៅមានពួកលោកិយប្រាំមួយរឺប្រាំពីរនាក់។ ខ្ញុំជឿជាក់ថា ប៉ារបស់ឯងធ្វើការនៅក្នុងនាយកដ្ឋានផ្នែកការប្រើប្រាស់មិនត្រឹមត្រូវនៃវត្ថុពួកលោកិយ មែនទេ?- គាត់និយាយ ដោយមើលទៅរ៉ុន ហើយនៅតែញញឹមដែលកាន់តែអាក្រក់ឡើងៗ។ - ពុទ្ធោ ពុទ្ធោ...កូនប្រុសរបស់គាត់...

ហេរី មានអារម្មណ៍ដូចជាវាទើបតែត្រូវបានវាយចំក្រពះដោយមែកឈើមួយក្នុងចំណោមមែកឈើធំៗរបស់ដើមដ៏ឆ្កួតមួយនោះ។ ប្រសិនបើមាននរណាម្នាក់បានឃើញលោកវីស្លីប្រើវេទមន្តលើឡាននោះ...គាត់មិនបាច់គិតដល់...

- ខ្ញុំបានពិនិត្យកំឡុងពេលដើរមើលក្នុងឧទ្យានរបស់ខ្ញុំឃើញថាមានការបំផ្លាញដ៏ធ្ងន់ធ្ងរនោះហាក់ដូចជាត្រូវបានកើតឡើងចំពោះដើមឈើដ៏មានតម្លៃមួយគឺដើម វ៉ុមភីង វីឡូ- ស្នេពបានបន្ត។

- ដើមឈើនេះបានវាយប្រហារមកលើពួកយើងច្រើនជាងពួកយើង...- រ៉ុនរបូតមាត់និយាយចេញមក។

- ស្ងាត់ទៅ!- ស្នេពនិយាយយ៉ាងគំរោះគំរើយម្តងទៀត។ - សំណាងល្អហើយដែលពួកឯងមិននៅក្នុងក្រុមរបស់ខ្ញុំ ហើយការសំរេចចិត្តបណ្តេញពួកឯងចេញនោះមិនត្រូវបានសំរេចដោយរូបខ្ញុំ។ ខ្ញុំគួរតែទៅនាំមនុស្សម្នាក់ ដែលមានសមត្ថភាពអាចធ្វើបែបនោះមក។ ពួកឯងត្រូវរង់ចាំនៅទីនេះ។

ហេរី និងរ៉ុនសម្លឹងមើលគ្នាដោយទឹកមុខស្លេកស្លាំង។ ហេរីមិនមានអារម្មណ៍ឃ្លានទៀតទេ។ ឥឡូវ វាមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំងទៅវិញ។ វាព្យាយាមមិនមើលទៅអ្វីធំម្យ៉ាងដែលមានរាងតូចអណ្តែតក្នុងទឹកពណ៌ខៀវ នៅលើធ្នើរខាងក្រោយតុរបស់ស្នេព។ ប្រសិនបើស្នេពបាននាំអ្នកស្រីសាស្ត្រាចារ្យ ម៉ាកហ្កូណាហ្កាល ដែលជាប្រធានក្រុម ហ្គ្រីហ្វីនដ័រ មកនោះ ពួកគេពិបាកនឹងសប្បាយដូចមុនណាស់។ គាត់អាចនឹងមានហេតុផលជាងស្នេព ប៉ុន្តែគាត់នៅតែម៉ឺងម៉ាត់ដដែល។

ដប់នាទីក្រោយ ស្នេពបានត្រលប់មកវិញ ហើយប្រាកដណាស់ដែលមានលោកស្រីសាស្ត្រាចារ្យ ម៉ាកហ្កូណាហ្កាល អមដំណើរជាមួយគាត់មក។ ហេរីធ្លាប់បានឃើញលោកស្រីសាស្ត្រាចារ្យ ម៉ាកហ្កូណាហ្កាល ខឹងជាច្រើនលើកមកហើយ ប៉ុន្តែវាភ្លេចទាំងមាត់ដ៏ស្តើងរបស់គាត់និយាយរបៀបម៉េច រឺក៏វាមិនធ្លាប់ឃើញគាត់ខឹងដូចនេះទេពីមុនមក។ គាត់បានលើកចង្កឹះវេទមន្តរបស់

គាត់ឡើងនៅពេលគាត់បានចូលមក។ ហេរី និងរ៉ុនក្រញេងខ្លួនទាំងពីរនាក់ ប៉ុន្តែគាត់គ្រាន់តែតំរង់វាទៅឡកំដៅទេនោះ ដែលភ្លាមៗនោះមានអណ្តាតភ្លើងឆេះឡើង។

- អង្គុយចុះ- គាត់និយាយ ហើយពួកគេទាំងពីរបែរមកអង្គុយលើកៅអីនៅក្បែរភ្លើងនោះ។

- បកស្រាយមក- គាត់និយាយ វ៉ែនតារបស់គាត់មានចាំងពន្លឺភ្លែតៗគួរឲ្យខ្លាច។

រ៉ុនចាប់ផ្តើមរៀបរាប់ពីដំណើររឿងចាប់ពីរបាំងស្ថានីយ៍រថភ្លើងដែលរារាំងពួកគេមិនឲ្យឆ្លងកាត់បាន។

- ...ដូច្នេះហើយ ពួកយើងគ្មានជំរើសទេ អ្នកគ្រូ ពួកយើងមិនអាចឡើងជិះរថភ្លើងបានទេ។

- ហេតុអ្វីបានជាពួកឯងមិនផ្ញើសំបុត្រមកពួកយើងតាមសត្វទីទុយទៅ? ខ្ញុំច្បាស់ណាស់ថាឯងមានទីទុយមួយក្បាល មែនទេ?- លោកស្រីសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល និយាយទៅហេរីទាំងសោះកក្រោះ។

ហេរី សម្លឹងគាត់ទាំងចំហមាត់។ នៅពេលដែលគាត់និយាយដល់រឿងនេះ ទើបយល់ថាវាពិតជារឿងដែលគួរតែធ្វើណាស់នៅពេលនោះ។

- ខ្ញុំ...ខ្ញុំមិនបានគិត...

- រឿងនោះ- លោកស្រីសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល និយាយ - គឺប្រាកដណាស់។

មានសំឡេងគោះទ្វារ ហើយស្នេពដែលមើលទៅរាងសប្បាយចិត្តជាងមុននោះ បានទៅបើកទ្វារ។ អ្នកដែលឈរនៅទីនោះគឺលោកនាយក លោកសាស្ត្រាចារ្យដាំប៊័លដ័រ។

រាងកាយទាំងមូលរបស់ហេរីប្រែជាស្ពឹកអស់។ ដាំប៊័លដ័របានកំពុងមើលមកដោយម៉ឺងម៉ាត់ខុសពីធម្មតា។ គាត់បានសម្លឹងមើលទៅពួកគេមិនដាក់ភ្នែកជាមួយនឹងច្រមុះកោងរបស់គាត់ ហើយភ្លាមៗនោះ ហេរីដឹងថាខ្លួនឯងកំពុងចង់ឲ្យវានិងរ៉ុននៅតែត្រូវបានវាយប្រហារដោយដើម វ៉ុមភីង វីឡូ នោះដដែល។

មានភាពស្ងប់ស្ងាត់អស់យ៉ាងយូរ។ ក្រោយមក ដាំប៊័លដ័រនិយាយៈ

- ចូរបកស្រាយមកថាហេតុអ្វីពួកឯងធ្វើដូច្នេះ។

វាអាចនឹងមានភាពប្រសើរ ប្រសិនបើវាបានស្រែកលឺៗនោះ។ ហេរីស្អប់នូវការខកចិត្តក្នុងសំឡេងរបស់វាណាស់។ សំរាប់ហេតុផលមួយចំនួន វាមិនអាចមើលលោកដាំប៊័លដ័រចំភ្នែកបាន ហើយនិយាយពីកំហុសរបស់វានោះទេ។ វាបានប្រាប់លោកដាំប៊័លដ័រគ្រប់យ៉ាងលើកលែងតែថាលោកវីស្លីជាម្ចាស់ឡានវេទមន្តនោះ ធ្វើឲ្យគេយល់ថាដូចជាវា និងរ៉ុនបានស្វែងរកឡានហោះមួយចតនៅខាងក្រៅស្ថានីយ៍។ វាដឹងថា ដាំប៊័លដ័រអាចយល់រឿងនេះភ្លាមៗ ប៉ុន្តែដាំប៊័លដ័រមិនបានសួរនាំពីរឿងឡាននោះទេ។ នៅពេលហេរីនិយាយចប់ គាត់មិនបន្តមើលមកពួកគេតាមវ៉ែនតារបស់គាត់ទៀតនោះឡើយ។

- ពួកយើងនឹងទៅយកឥវ៉ាន់របស់ពួកយើង- រ៉ុននិយាយក្នុងសំឡេងអស់សង្ឃឹម។

- តើឯងកំពុងនិយាយពីអ្វីហ្នឹង វីស្លី?- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលស្រែកគំហក។

- បាទ អ្នកគ្រូកំពុងបណ្តេញពួកយើងហើយ មែនទេ?- រ៉ុននិយាយ។

ហេរីសម្លឹងមើលយ៉ាងលឿនទៅលោក ដាំប៊័លដ័រ។

- មិនមែនថ្ងៃនេះទេ លោកវីស្លី- ដាំប័លដ័រនិយាយ។ - ប៉ុន្តែខ្ញុំត្រូវសរសើរពួកឯងទាំងពីរវិញទេចំពោះសភាពប្រកបដោយគ្រោះថ្នាក់នៃអ្វីដែលពួកឯងបានធ្វើ។ ខ្ញុំនឹងត្រូវសរសេរសំបុត្រទៅគ្រួសាររបស់ពួកឯងនៅយប់នេះ។ ខ្ញុំក៏ត្រូវតែហាមពួកឯងដែរថា ប្រសិនបើពួកឯងធ្វើរឿងផ្សេងដូចនេះម្តងទៀត ខ្ញុំនឹងគ្មានជំរើសក្រៅពីបណ្តេញពួកឯងចេញនោះទេ។

ស្នេពមើលទៅប្រៀបដូចជាពិធីបុណ្យណូអែលត្រូវបានលុបចោល។ គាត់គ្រហែមរួចនិយាយៈ

- សាស្ត្រាចារ្យដាំប័លដ័រ ក្មេងប្រុសទាំងពីរនេះបានមើលងាយដល់ក្រិតក្រមនៃការហាមឃាត់ចំពោះវេទគូមិនទាន់គ្រប់អាយុ បង្កឲ្យមានការបំផ្លាញយ៉ាងធ្ងន់ធ្ងរទៅលើដើមឈើចាស់ដ៏មានតម្លៃមួយដើម...ពិតណាស់ ការប៉ះពាល់ទៅដល់ធម្មជាតិ...

- វានឹងត្រូវទុកឲ្យសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល ធ្វើការសំរេចចិត្តដាក់ទណ្ឌកម្មលើក្មេងប្រុសទាំងពីរនាក់នេះចុះ សេវេរូស- ដាំប័លដ័រនិយាយយ៉ាងស្ងៀមស្ងាត់។ - ពួកគេស្ថិតនៅក្នុងក្រុមរបស់គាត់ ហើយដូច្នេះវាជាការទទួលខុសត្រូវរបស់គាត់។- គាត់បែរទៅសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល ។ - ខ្ញុំត្រូវត្រលប់ទៅពិធីជប់លៀងវិញហើយ មីណែរវ៉ា ខ្ញុំត្រូវចេញទៅផ្តល់ការប្រកាសពីរបី។ មក សេវេរូស មាននំដុតឆ្ងាញ់ៗដែលខ្ញុំចង់ភ្លក្ស។

ស្នេពបាញ់កែវភ្នែកដោយកំហឹងសុទ្ធសាធទៅហេរី និងរ៉ុន នៅពេលគាត់ត្រូវទៅសំអាតការិយាល័យរបស់គាត់ដោយខ្លួនឯង ទុកពួកគេឲ្យនៅជាមួយសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល ដែលនៅតែសំលឹងពួកគេប្រៀបដូចជាឥន្ទ្រីដែលពោរពេញដោយកំហឹងមួយក្បាល។

- ឯងគួរតែទៅអគារមន្ទីរពេទ្យប្រសើរជាង វីស្លី ឯងកំពុងតែចេញឈាមហើយ។

- មិនអីទេ- រ៉ុននិយាយ វាប្រញាប់ជូតស្នាមមុតលើភ្នែករបស់វានោះដោយដៃរបស់វាចេញ។ - អ្នកគ្រូ ខ្ញុំចង់ទៅមើលប្អូនស្រីខ្ញុំដែលកំពុងជ្រើសតាំងដាក់ក្រុម...

- ពិធីជ្រើសតាំងនោះបានចប់ហើយ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយ។ - ប្អូនស្រីរបស់ឯងក៏ស្ថិតនៅក្នុងក្រុមហ្គ្រីហ្វីនដ័រដែរ...

- អូ! ល្អមែន- រ៉ុននិយាយ។

- ហើយនិយាយដល់ក្រុមហ្គ្រីហ្វីនដ័រវិញ...- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយយ៉ាងលឿន ប៉ុន្តែហេរីបានកាត់សម្តីៈ

- អ្នកគ្រូ នៅពេលពួកយើងបានជិះឡាននោះ ពេលសិក្សាមិនទាន់ចាប់ផ្តើមនោះទេ អញ្ចឹង...អញ្ចឹងក្រុមហ្គ្រីហ្វីនដ័រពិតជាមិនគួរត្រូវបានដកពិន្ទុចេញនោះទេ មែនទេ?- វាឈប់និយាយ ហើយមើលទៅគាត់ទាំងព្រួយបារម្ភ។

សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលមើលទៅវាដោយក្រសែភ្នែកមុតមាំ ប៉ុន្តែវាជឿជាក់ថា គាត់បានញញឹមខ្លះទៅហើយ។ ម្យ៉ាងទៀត មាត់របស់គាត់មើលទៅរាងស្តើងអន់ស្តើងបន្តិច។

- ខ្ញុំនឹងមិនដកពិន្ទុពីក្រុមហ្គ្រីហ្វីនដ័រទេ- គាត់និយាយ រួចហើយធ្វើឲ្យបេះដូងរបស់ហេរីបានធូរស្រាលយ៉ាងខ្លាំង។ - ប៉ុន្តែឯងទាំងពីរនាក់ត្រូវទទួលទណ្ឌកម្មមួយ។

វាមានភាពប្រសើរជាងអ្វីដែលហេរីបានរំពឹងទុក។ ចំពោះសំបុត្ររបស់ ដាំប័លដ័រ សរសេរឲ្យឌឺស្លីនោះ វាគ្មានបញ្ហាអីនោះទេ។ ហេរីបានដឹងយ៉ាងច្បាស់ថា ពួកគេនឹងគ្រាន់តែត្រូវខកចិត្តដែលដើមរ៉ុមភីង វីឡូមិនបានកំទេចវាឲ្យខ្ទេច។

សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលលើកចង្កឹះ វេទមន្តរបស់គាត់ឡើងម្តងទៀត ហើយតំរង់ទៅតុរបស់ស្នេព។ នំសាន់វិចមួយចានធំ កែវមានជើងពណ៌ប្រាក់ពីរ និងទឹកល្ពៅត្រជាក់មួយថូ បានលេចឡើងដោយសំឡេងផ្ទុះផស់ៗ។

- ពួកឯងត្រូវញ៉ាំនៅទីនេះ ហើយបន្ទាប់មកត្រូវឡើងទៅសយនដ្ឋានរបស់ពួកឯង- គាត់និយាយ។ - ខ្ញុំត្រូវតែត្រឡប់ទៅពិធីជប់លៀងវិញហើយ។

នៅពេលទ្វារបានបិទ ក្រោយពេលគាត់ចេញទៅ រ៉ុនស្រែកហួចតិចៗយ៉ាងយូរ។

- ខ្ញុំគិតថាពួកយើងត្រូវតែញ៉ាំវាហើយ- វានិយាយរួចកាន់នំសាន់វិចមួយ។

- ខ្ញុំក៏អញ្ចឹងដែរ- ហេរីនិយាយរួចយកមួយដែរ។

- និយាយអញ្ចឹង តើឯងអាចជឿលើសំណាងពួកយើងទេ?- រ៉ុននិយាយស្អកៗតាមមាត់ដែលពេញដោយសាច់មាន់ និងសាច់ជ្រូកបីជាន់។ - ហ្វ្រេដ និងចចត្រូវបើកឡានហោះនោះប្រាំរឺប្រាំមួយដងមកហើយ ប៉ុន្តែគ្មានពួកលោកិយណាធ្លាប់បានឃើញពួកគេហោះ។- វាលេបទឹកមាត់ ហើយខាំនំមួយម៉ាត់ទៀតអស់យ៉ាងធំ។ - ហេតុអ្វីក៏ពួកយើងមិនអាចឆ្លងកាត់របាំងថ្មនោះបាន?

ហេរីញាក់ស្មា។ - ទោះបីជាយ៉ាងណាក្តី ពួកយើងនឹងត្រូវតែពិនិត្យពីសកម្មភាពរបស់ពួកយើងពីឥឡូវនេះទៅ- វានិយាយរួចផឹកទឹកល្ពៅអស់យ៉ាងច្រើន។ - សង្ឃឹមថាពួកយើងអាចនឹងបានទៅអបអរក្នុងពិធីជប់លៀង...

- គាត់មិនបានចង់ឲ្យពួកយើងធ្វើឲ្យគេសរសើរទេ- រ៉ុននិយាយទាំងភាពវៃឆ្លាត។ - មិនចង់ឲ្យមនុស្សគិតថាវាគឺជាការឈ្លាសវៃក្នុងការធ្វើដំនើរមកដល់ដោយឡានហោះនោះទេ។

នៅពេលពួកគេបានញ៉ាំនំសាន់វិចអស់យ៉ាងច្រើនតាមដែលពួកគេអាច (ចាននោះបានបញ្ចេញនំមកម្តងទៀតដោយខ្លួនវា) ពួកគេបានក្រោកឡើង ហើយចាកចេញពីការិយាល័យ ដើរលើផ្លូវលំដែលងាយស្រួលចំណាំនោះទៅកាន់អគារក្រុមហ្គ្រីហ្វីនដ័រ។ អគារនោះមានភាពស្ងប់ស្ងាត់ វាហាក់ដូចជាថាពិធីជប់លៀងត្រូវបញ្ចប់ហើយ។ ពួកគេបានដើរកាត់រូបភាពជាច្រើនដែលកំពុងខ្សឹបខ្សាវគ្នា និងអាវក្រោះដែលបន្លឺសំឡេងងឺតងត ហើយដើរឡើងទៅលើជណ្តើរថ្មហោះដ៏ចង្អៀតជាច្រើនដំណាក់រហូតដល់ចុងក្រោយដែលពួកគេបានទៅដល់ច្រកមួយនោះ ជាច្រកចូលសំងាត់ទៅអគារក្រុមហ្គ្រីហ្វីនដ័រ ដែលត្រូវបានលាក់នៅពីក្រោយរូបគំនូរប្រេងមួយនៃស្ត្រីកន្ធាត់ម្នាក់ក្នុងសម្លៀកបំពាក់សូត្រពណ៌ផ្កាឈូកមួយសំរាប់។

- ពាក្យសម្ងាត់?- គាត់និយាយនៅពេលពួកគេដើរសំដៅទៅ។

- អឺ...- ហេរីនិយាយ។

ពួកគេមិនបានដឹងពីពាក្យសម្ងាត់ឆ្នាំថ្មីនោះទេ ហើយមិនទាន់បានជួបសិស្សច្បងនៃក្រុមហ្គ្រីហ្វីនដ័រម្នាក់ណាឡើយ ប៉ុន្តែមានជំនួយមកដល់ស្ទើរតែភ្លាមៗនោះ។ ពួកគេបានឮសំរឹបជើងយ៉ាងញាប់ៗពីក្រោយពួកគេ ហើយបែរទៅឃើញហឺម៉ាយអូនីកំពុងរត់យ៉ាងលឿនសំដៅមករកពួកគេ។

- ពួកឯងនៅទីនេះទេ! តើពួកឯងបានទៅណា? ពាក្យចចាមអារ៉ាមដ៏ឆ្កួតលីលាបំផុត...មានមនុស្សម្នាក់បាននិយាយថាពួកឯងត្រូវបានគេបណ្តេញចេញដោយសារការបុកទង្គិចដោយឡានហោះមួយគ្រឿង។

- អឺ ពួកយើងមិនត្រូវបានគេបណ្តេញចេញនោះទេ- ហេរីអះអាងប្រាប់នាង។

- ពួកឯងនឹងមិនប្រាប់ខ្ញុំថាពួកឯងបានហោះហើរនៅទីនេះទេ មែនទេ?- ហឺម៉ាយអូនីនិយាយ ស្តាប់ទៅហាក់ដូចជាធ្ងន់ធ្ងរស្ទើរតែដូចសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយដែរ។

- កុំធ្វើដូចជាសាស្ត្រាចារ្យអី- រ៉ុននិយាយទាំងម៉ួម៉ៅ - ហើយប្រាប់ពួកយើងពីពាក្យសម្ងាត់ថ្មីមក។

- វាគឺ "បក្សីឈើ"- ហឺម៉ាយអូនីនិយាយទាំងម៉ួរម៉ៅដែរ - ប៉ុន្តែកុំថាពិន្ទុនោះ...

# ដើមឈើ ទុំមភីង វីឡូ

ទោះជាយ៉ាងណាក៏ដោយ ពាក្យសំដីរបស់នាងត្រូវបានកាត់ខ្លី នៅពេលរូបគំនូរនៃស្រីកន្ទាត់នោះបានបែរត្រលប់ក្រោយ ហើយមានសំឡេងទះដៃយ៉ាងខ្លាំងមួយភ្លាមៗនោះ។ វាមើលទៅហាក់ដូចជាថាក្រុមហ្គ្រីហ្វីនដ័រទាំងមូលនៅមិនទាន់ដេកនៅឡើយ ពួកគេបានរៀបចំបន្ទប់ឲ្យក្លាយជាបន្ទប់រាងរង្វង់មូលធម្មតា ហើយឈរនៅលើតុធំមួយ និងមានកៅអីភ្នាក់ដៃបាក់បែកជាច្រើន ដែលកំពុងរង់ចាំពួកគេមកដល់។ ដៃជាច្រើនបានឈោងតាមប្រហោងរូបគំនូរដើម្បីទាញហេរី និងរ៉ុនចូលទៅក្នុង រួចទុកឲ្យហឺម៉ាយអូនីត្រូវតោងចូលក្រោយគេ។

- ពិតជាអស្ចារ្យមែន!- លី ចចដាន់បានស្រែក - រំភើបមែន! រឿងដ៏ថ្មីមួយ! បើកឡានហោះទៅបុកដើមរ៉ុមភីង វីឡូ មនុស្សម្នានឹងនិយាយពីរឿងនេះមិនតិចឆ្នាំទេ!

- ពួកឯងធ្វើបានល្អណាស់- សិស្សឆ្នាំទីប្រាំម្នាក់បាននិយាយ ដែលហេរីមិនដែលនិយាយជាមួយសោះ មនុស្សម្នាក់បានទះស្មាវាតិចៗពីក្រោយដូចជាវាទើបតែបានឈ្នះការរត់ម៉ារ៉ាតុងអ៊ីចឹង។ ហ្វ្រេដ និងចចបានវែកផ្លូវរបស់ពួកគេដើម្បីចូលទៅមុខហ្វូងមនុស្ស ហើយនិយាយព្រមគ្នាៈ

- ហេតុអ្វីបានជាពួកឯងមិនហៅពួកយើងឲ្យមកវិញ ហ្អាស?

រ៉ុនប្រែជាមុខក្រហម រួចសើចស្ងាញទាំងខ្មាសអៀន ប៉ុន្តែហេរីអាចឃើញមនុស្សម្នាក់ដែលមើលទៅហាក់មិនសប្បាយចិត្តទាល់តែសោះ។ ពឿរស៊ីអាចមើលរំលងពីលើក្បាលពួកសិស្សឆ្នាំទីមួយដែលកំពុងសប្បាយរីករាយមួយចំនួន ហើយវាហាក់ដូចជាព្យាយាមចូលមកជិតបន្តិចដើម្បីស្ដីបន្ទោសពួកគេ។ ហេរីបានកេះរ៉ុន នឹងកែងដៃត្រង់ឆ្អឹងជំនីរ ហើយបែរក្បាលទៅក្នុងទិសដៅរបស់ពឿរស៊ី។ រ៉ុនបានដឹងពីមូលហេតុមួយរំពេច។

- ត្រូវឡើងទៅខាងលើហើយ...អស់កំលាំងបន្តិចហើយ- វានិយាយ ហើយពីរនាក់ក្នុងចំណោមពួកគេទាំងនោះចាប់ផ្ដើមវែកផ្លូវសំដៅទៅទ្វារនៅផ្នែកមួយផ្សេងទៀតនៃបន្ទប់ដែលភ្ជាប់ទៅជណ្ដើរកោង និងសយនដ្ឋាន។

- រាត្រីសួស្ដី- ហេរីប្រាប់ទៅហឺម៉ាយអូនីវិញដែលកំពុងចងចិញ្ចើមដូចពឿរស៊ីអំបាញ់មិញដែរ។

ពួកគេបានសម្រេចទៅកន្លែងផ្សេងពីបន្ទប់រួមនោះ ដោយនៅតែមានគេទះខ្នងពីក្រោយ ហើយបានទៅដល់មាត់ជណ្ដើរ។ ពួកគេប្រញាប់ឡើងទៅ ទៅឲ្យដល់ខាងលើ ហើយចុងក្រោយពួកគេបានទៅដល់មាត់ទ្វារនៃសយនដ្ឋានចាស់របស់ពួកគេដែលឥឡូវមានផ្លាកសំគាល់មួយនៅលើនោះដោយនិយាយថាៈ "ឆ្នាំទី២"។ ពួកគេដើរចូលទៅក្នុងបន្ទប់រាងរង្វង់មូលដែលងាយស្រួលចំនាំដោយសាររូបបួនជ្រុងប្រាំសន្លឹកនៅទីនោះបិតនឹងជញ្ជាំងជាមួយនឹងកាំម្ទីពណ៌ក្រហម និងបង្អួចតូចខ្ពស់។ វ៉ាលិសរបស់ពួកគេត្រូវបាននាំយកឡើងមកឲ្យពួកគេ ហើយបានដាក់នៅចុងគ្រែរបស់ពួកគេ។

រ៉ុនញញឹមតិចៗដាក់ហេរីទាំងដែលធ្វើខុស។

- ខ្ញុំដឹងខ្ញុំមិនគួរសប្បាយរីករាយចំពោះរឿងនោះអ្វីផ្សេងឡើយ ប៉ុន្តែ...

ទ្វារសយនដ្ឋាននោះបានបើកចំហ ហើយមានក្មេងប្រុសក្នុងក្រុមហ្គ្រីហ្វីនដ័រឆ្នាំទីពីរផ្សេងទៀតបានចូលមកគឺ ស៊ីម្យុស ហ្វីនីហ្គេន ឌីន ថូម៉ាស និង នេវីល ឡុងបត់ថម។

- ពិតជាមិនគួរឲ្យជឿមែន!- ស៊ីម្យុសញញឹមយ៉ាងរីករាយ។

- ពិតជាឡូយមែន- ឌីននិយាយ។

- គួរឲ្យភ្ញាក់ផ្អើលណាស់- នេវីល និយាយយ៉ាងចាប់អារម្មណ៍។

ហើរមិនអាចនិយាយអ្វីបានទេ។ វាក៏ញញឹមតិចៗដែរ។

## វគ្គ VI



# ហ្គីលដឺរ៉យ ឡុក់ហាត

ទោះបីជាយ៉ាងណាក៏ដោយ នៅថ្ងៃបន្ទាប់មក ហេរីត្រូវញញឹមម្តងៗទាំងពិបាក។ រឿងរ៉ាវបានចាប់ផ្តើមអាក្រក់ឡើងៗចាប់ពីពេលញ៉ាំអាហារពេលព្រឹកក្នុងមហាសាល។ តុវែងបួននៅក្នុងសាលនោះបានដាក់យ៉ាងច្រើនទៅដោយចានបបរ ត្រីប្រឡាក់ នំប៉ុងអាំង និងស៊ុត ហើយនិងសាច់ជ្រូកប្រលាក់ នៅពីក្រោមពិតានវេទមន្ត (ថ្ងៃនេះមេឃស្រទំមិនភ្លឺទេ)។ ហេរី និងរ៉ុនអង្គុយនៅតុក្រុមហ្គ្រីហ្វិនដ័រ ក្បែរហឺម៉ាយអូនីដែលកំពុងមើលសៀវភៅដំណើរតាមសមុទ្រជាមួយព្រាយជញ្ជក់ឈាមដោយបើកដាក់ទល់នឹងកែវទឹកដោះគោ។ វាមានការលំបាកបន្តិចនៅពេលនាងនិយាយថា "អរុណសួស្តី" ដែលប្រាប់ហេរីថា នាងនៅតែមិនពេញចិត្តពីវិធីដែលនាំពួកគេមកដល់សាលាដដែល។ ម្យ៉ាងវិញទៀត នេវីល ឡុងបត់ថមបានស្វាគមន៍ពួកគេយ៉ាងកក់ក្តៅ។ នេវីលគឺជាក្មេងប្រុសម្នាក់មានមុខមូល ហើយសស្លេកសស្លក់ជាមួយនឹងការចងចាំអន់ជាងគេបំផុតក្នុងចំនោមអ្នកដែលហេរីធ្លាប់បានជួប។

- សេវាប្រៃសណីយ៍នឹងមកដល់នូវប៉ុន្មាននាទីនេះហើយ...ខ្ញុំគិតថាលោកយាយនឹងផ្ញើរបស់ពីរបីដែលខ្ញុំបានភ្លេច។

ជាការពិតណាស់ ហេរីទើបតែចាប់ផ្តើមញ៉ាំបបររបស់វាដែលនៅពេលនោះមានសម្លេងបន្ទាន់មួយនៅខាងលើ និងមានសត្វទីទុយរាប់រយក្បាលហើរចូលមកយ៉ាងលឿនព័ទ្ធជុំវិញសាល ហើយទំលាក់សំបុត្រនិងកញ្ចប់ជាច្រើនទៅក្នុងហ្វូងមនុស្សដែលកំពុងហូរកញ្ច្រៀវ។ កញ្ចប់មួយដុំធំបានធ្លាក់ចូលមកក្នុងកែវរបស់ហឺម៉ាយអូនី ធ្វើឲ្យខ្ទាតទឹកដោះគោ និងស្លាបសត្វមកលើពួកគេពេញ។

- អេរ៉ូល!- រ៉ុននិយាយ រួចយកទីទុយដែលប្រឡាក់ប្រឡូសនោះចេញមកដោយទាញជើងវា។ អេរ៉ូលបានធ្លាក់ចុះមក ហើយសន្លប់តតដឹងខ្លួននៅលើតុ ជើងរបស់វាបះឡើងលើ ហើយមានស្រោមសំបុត្រមួយពណ៌ក្រហមសើមបន្តិចនៅក្នុងចំពុះរបស់វា។

- អូ! ទេ- រ៉ុនដង្ហក់។

- វាមិនអីទេ វានៅរស់នៅឡើយ- ហឺម៉ាយអូនីនិយាយរួចចាក់អេរ៉ូលថ្នមៗដោយចុងម្រាមដៃរបស់នាង។

- វាមិនមែនរឿងនេះទេ...វាគឺរឿងនេះ។

រ៉ុនបានចង្អុលទៅស្រោមសំបុត្រពណ៌ក្រហមនោះ។ វាមើលទៅដូចជាសាមញ្ញចំពោះហេរី ប៉ុន្តែរ៉ុន និងនេវីលទាំងពីរនាក់កំពុងសម្លឹងមើលទៅស្រោមសំបុត្រនោះដែលពួកគេបានគិតថាវានឹងផ្ទុះចេញ។

- មានបញ្ហាអីហ្នឹង?- ហេរីនិយាយ។

- គាត់បាន...គាត់បានផ្ញើសំបុត្រស្ដីបន្ទោសមួយឲ្យខ្ញុំ- រ៉ុននិយាយយ៉ាងខ្សោយ។

- ឯងគួរបើកវាមើលទៅ រ៉ុន- នេវីលនិយាយខ្សឹបៗរាងកំសាក។ - វានឹងមិនល្អទេ ប្រសិនបើឯងមិនបើកមើលនោះ។ លោកយាយរបស់ខ្ញុំបានផ្ញើឲ្យខ្ញុំម្ដងដែរ ហើយខ្ញុំមិនអើពើនឹងវា ហើយ...- វាលេបទឹកមាត់ក្អឿក - វាគួរឲ្យរន្ធត់ណាស់។

ហេរីមើលពីទឹកមុខភ័យខ្លាចរបស់ពួកគេទៅស្រោមសំបុត្រពណ៌ក្រហមនោះ។

- តើអ្វីទៅជាសំបុត្រស្ដីបន្ទោសនោះ?- វានិយាយ។

ប៉ុន្តែអារម្មណ៍ទាំងមូលរបស់រ៉ុនផ្ដោតតែទៅលើស្រោមសំបុត្រនោះដែលចាប់ផ្ដើមមានផ្សែងចេញនៅតាមជ្រុង។

- បើកវាមើលទៅ- នេវីលជំរុញ។ - តែពីរបីនាទីប៉ុណ្ណោះវាអស់អីហើយ...

រ៉ុនលើកយកដៃកំពុងញ័រចេញមក ហើយលូកយកស្រោមសំបុត្រពីចំពុះរបស់អេរ៉ូលរួចហែកវាមើល។ នេវីលញ៉ុកដៃរបស់វាចូលក្នុងត្រចៀក។ ហេរីដឹងពីមូលហេតុមួយរំពេច។ វាបានគិតមួយសន្ទុះក្រោយពេលស្រោមសំបុត្របានផ្ទុះចេញមក។ សូរសម្លេងដ៏ខ្លាំងមួយបានលាន់លឺពេញសាលទាំងមូលព្រមជាមួយនឹងធូលីហុយចេញពីពិតានមក។

-...លួចយកឡានមក យើងនឹងមិនភ្ញាក់ផ្អើលទេ បើគេបណ្ដេញឯងនោះ តែជួបមុខឯងកាលណានឹងដឹងគ្នាហើយ យើងហ៊ានភ្នាល់ថាពេលនោះឯងគ្មាននឹកគិតដល់ថាតើយើង និងប៉ាឯងត្រូវឆ្លងកាត់ឧបសគ្គប៉ុណ្ណានោះទេនៅពេលដែលបាត់ឡាននោះទៅ...

សម្រែករបស់អ្នកស្រីវីស្លីបានបន្លឺឡើងឮជាងសម្រែកធម្មតារាប់រយដងធ្វើឲ្យចាន និងស្លាបព្រាទង្គិចគ្នានៅលើតុ ហើយសម្លេងនោះបានឮសូរខ្ទរមកវិញយ៉ាងខ្លាំង។ មនុស្សពេញទាំងសាលបានងាកមកមើលអ្នកដែលបានទទួលសំបុត្រស្ដីបន្ទោស ហើយរ៉ុនបានពន្លិចខ្លួនចុះយ៉ាងទាបនៅកៅអីរបស់វាដែលអាចមើលឃើញត្រឹមតែថ្ងាសក្រហមរបស់វាប៉ុណ្ណោះ។

-...សំបុត្រពីលោកដាំប៍លដ័រកាលពីយប់មិញ...យើងគិតថា ប៉ារបស់ឯងប្រាកដជានឹងត្រូវស្លាប់ដោយសារតែការអាម៉ាស់មុខជាមិនខានឡើយ យើងមិនបានអប់រំឯងឲ្យមានចរិតដូច្នេះទេ ឯង និងហេរីទាំងពីរនាក់អាចនឹងស្លាប់ណា...

ហេរីកំពុលឆ្ងល់នៅពេលឮឈ្មោះរបស់វាបានលើកឡើង។ វាព្យាយាមយ៉ាងខ្លាំងដើម្បីធ្វើដូចជាមិនបានឮសម្លេងនោះដែលកំពុងធ្វើឲ្យក្រដាសត្រចៀកវាឈឺខ្ទោកៗ។

-...ពិតជាចម្រៃណាស់ ប៉ារបស់ឯងកំពុងប្រឈមមុខនឹងការស៊ើបអង្កេតមួយនៅកន្លែងធ្វើការ វាគឺជាកំហុសរបស់ឯងទាំងស្រុង ហើយប្រសិនបើឯងធ្វើឲ្យមានកំហុសអ្វីផ្សេងទៀត យើងនឹងនាំឯងឲ្យត្រលប់មកផ្ទះវិញភ្លាម។

សម្លេងឮច្បាស់មួយនោះបានស្ងាត់ទៅវិញ។ ស្រោមសំបុត្រក្រហមដែលបានធ្លាក់ចេញពីដៃរបស់រ៉ុនបានឆេះក្នុងអណ្ដាតភ្លើងរហូតក្លាយទៅជាផេះ។ ហេរី និងរ៉ុនបានអង្គុយភ្លឹកដូចជាត្រូវរលកជោរមករំលងពួកគេអញ្ចឹង។ មនុស្សពីរបីនាក់បានសើច ហើយចុងក្រោយ សម្លេងជជែកគ្នាកោកកាកបានបន្លឺឡើងម្ដងទៀត។

ហឺម៉ាយអូនីបានបិទសៀវភៅ "ដំណើរតាមសមុទ្រជាមួយព្រាយជញ្ជក់ឈាម" ហើយសម្លឹងមើលទៅរ៉ុនបែកមាក់ងាយ។

- អឺ ខ្ញុំមិនដឹងនូវអ្វី ដែលឯងបានរំពឹងទុកទេ រ៉ុន ប៉ុន្តែឯង...

- កុំប្រាប់ខ្ញុំថាខ្ញុំសក្ដិសមនឹងបែបនេះអោយសោះ- រ៉ុននិយាយម៉ាត់ៗ។

ហេរីរុញបបររបស់វាចេញ។ ខាងក្នុងខ្លួនរបស់វាកំពុងតែឆាបឆេះទៅដោយកំហុស។ លោកវីស្លីកំពុងប្រឈមមុខនឹងការស៊ើបអង្កេតនៅកន្លែងធ្វើការ។ សរុបទៅ លោក និងអ្នកស្រីវីស្លីទទួលរ៉ាប់រងរឿងវាទាំងអស់ពេញមួយរដូវក្ដៅនេះ...

ប៉ុន្តែវាគ្មានពេលសម្រាប់គិតពីរឿងនេះទេ។ សាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល បានកំពុងធ្វើដំណើរតាមបណ្ដោយតុក្រុមហ្គ្រីហ្វីនដ័រដោយកាន់មកនូវតារាងកាលវិភាគ។ ហេរីបានយកកាលវិភាគរបស់វា ហើយឃើញថាពួកគេមានម៉ោងភូតគាមសាស្ត្រឌុបជាមួយនឹងក្រុម ហាហ្វ៊លផហ្វ ដំបូងគេ។

ហេរី រ៉ុន និងហឺម៉ាយអូនី បានចាកចេញពីប្រាសាទរួមគ្នា រួចឆ្លងកាត់ចំការបន្លែ ហើយសំដៅទៅផ្ទះកញ្ចក់ ជាកន្លែងដែលរុក្ខជាតិទិព្វត្រូវបានរក្សាទុក។ យ៉ាងហោចណាស់ក៏សំបុត្រស្ដីបន្ទោសបានធ្វើរឿងល្អមួយដែរៈ ហឺម៉ាយអូនីហាក់ដូចជាគិតថា ពួកគេឥឡូវត្រូវបានដាក់ទណ្ឌកម្មគ្រប់គ្រាន់ហើយ ហើយកំពុងតែទទួលបានការរាក់ទាក់យ៉ាងល្អម្ដងទៀត។

នៅពេលពួកគេស្ថិតនៅក្បែរផ្ទះកញ្ចក់ ពួកគេបានឃើញអ្នកឯទៀតក្នុងថ្នាក់កំពុងឈរនៅខាងក្រៅរង់ចាំសាស្ត្រាចារ្យសប្រ៉ោត។ ហេរី រ៉ុន និងហឺម៉ាយអូនីទើបតែចូលរួមជាមួយពួកគេនៅពេលដែលគាត់កំពុងបោះជំហានវែងៗចូលមកឆ្លងកាត់វាលស្មៅដែលអមដោយលោក ហ្គីលដឺរ័យ ឡុក់ហាត។ ដៃរបស់សាស្ត្រាចារ្យ សប្រ៉ោត ពេញដោយបង់រុំរបួស និងរបួសសើស្បែកប៉ុន្មានកន្លែងទៀត។ ហេរីមើលឃើញដើមរ៉ុមភីង វីឡូពីចម្ងាយ មែករបស់វាជាច្រើនឥឡូវស្ថិតក្នុងសភាពគ្រវែងគ្រវាត់។

សាស្ត្រាចារ្យ សប្រ៉ោត គឺជាវេទគូតូចកន្ទុលម្នាក់ ពាក់មួកមានបំណះច្រើនមួយនៅពីលើសក់សរសៃឆ្មារៗរបស់គាត់។ ជាធម្មតាមានធូលីដីច្រើននៅលើសំលៀកបំពាក់របស់គាត់ ហើយក្រចកដៃរបស់គាត់អាចធ្វើឲ្យអ្នកមីង ពីទូនៀ សន្លប់បាន។ ទោះជាយ៉ាងណាក៏ដោយ ហ្គីលដឺរ័យ ឡុក់ហាតបានស្លៀករ៉ូបពណ៌ខៀវបៃតងដ៏ថ្មីថៃស សក់ពណ៌មាសរបស់គាត់បញ្ចេញពន្លឺចែងចាំងពីក្រោមមួកពណ៌ខៀវបៃតង ដែលស្ថិតក្នុងទីតាំងដ៏សក្តិសមមួយជាមួយនឹងការតុបតែងដោយមាស។

- អូ! សួស្ដី!- ឡុក់ហាតបាននិយាយដោយញញឹមយ៉ាងរីករាយនៅជុំវិញបណ្ដុំសិស្ស។ - គ្រាន់តែមកបង្ហាញសាស្ត្រាចារ្យសប្រ៉ោតពីវិធីដ៏ត្រឹមត្រូវក្នុងការព្យាបាលដើម រ៉ុមភីង វីឡូ តែប៉ុណ្ណោះ! ប៉ុន្តែខ្ញុំមិនចង់ឲ្យពួកឯងចេញទៅដោយមានគំនិតថាខ្ញុំពូកែខាងភូតគាមសាស្ត្រនោះទេ! ខ្ញុំទើបតែចាប់ផ្ដើមប្រទះឃើញរុក្ខជាតិចម្លែកទាំងនេះជាច្រើនក្នុងការធ្វើដំណើររបស់ខ្ញុំ...

- ថ្ងៃនេះទៅផ្ទះកញ្ចក់លេខបី ទាំងអស់គ្នា!- សាស្ត្រាចារ្យសប្រ៉ោតនិយាយ ទឹកមុខមិនសូវពេញចិត្តខុសពីអាការធម្មតារបស់គាត់។

មានសម្លេងខ្សឹបខ្សៀវដ៏គួរអោយចាប់អារម្មណ៍មួយ។ ពួកគេធ្លាប់តែធ្វើការក្នុងផ្ទះកញ្ចក់ទីមួយប៉ុណ្ណោះកាលពីមុន...ផ្ទះកញ្ចក់ទីបីទុកដាក់រុក្ខជាតិដែលមានគ្រោះថ្នាក់ និងគួរឲ្យចាប់អារម្មណ៍ច្រើនជាងឆ្ងាយណាស់។ សាស្ត្រាចារ្យសប្រ៉ោតយកសោដ៏ធំមួយចេញពីខ្សែក្រវ៉ាត់របស់គាត់ ហើយចាក់សោទ្វារនោះ។ ហេរីធុំក្លិនដីសើម និងជីផ្សំជាមួយក្លិនទឹកអប់ឆ្អួលនៃផ្កាទំហំប៉ុនឆ័ត្រធំៗមួយចំនួនរយើងរយោងពីពិតានចុះមក។ វាហៀបនឹងទៅ តាមរ៉ុន និងហឺម៉ាយអូនីចូលទៅក្នុង ស្រាប់តែដៃរបស់ឡុក់ហាតចង្អុលមក។

- ហេរី! ខ្ញុំចង់និយាយបន្តិច...អ្នកមិនប្រកាន់ទេរឺបើវាទៅយឺតពីរបីនាទី មែនទេ សាស្ត្រាចារ្យសប្រ៉ោត?

ការកាត់សេចក្ដីដោយការចងចិញ្ចើមរបស់សាស្ត្រាចារ្យ សប្រ៉ោត គឺគាត់ប្រកាន់ ប៉ុន្តែឡុក់ហាតនិយាយបញ្ចើចៈ

- អ្នកធ្វើបានល្អណាស់ ...- ហើយបានបិទទ្វារផ្ទះកញ្ចក់នៅចំពោះមុខគាត់។

- ហេរី- ឡុក់ហាតនិយាយ ធ្មេញពណ៌សធំរបស់គាត់ភ្លឺចាំងក្នុងពន្លឺព្រះអាទិត្យនៅពេលគាត់អោបក្បាលរបស់គាត់។ - ហេរី ហេរី ហេរី។

ដោយភាពភ្ញាក់ផ្អើលយ៉ាងខ្លាំង ហេរីមិននិយាយអ្វីសោះ។

- នៅពេលខ្ញុំបានឮ...អឺ ពិតណាស់ វាគឺជាកំហុសរបស់ខ្ញុំទាំងអស់។ គួរតែត្រូវបន្ទោសខ្ញុំ។

ហេរីមិនយល់ពីអ្វីដែលគាត់កំពុងនិយាយទេ។ វាទំនងជាចង់និយាយនៅពេលឡក់ហាតបន្តនិយាយៈ

- មិនដឹងថាពេលណាដែលខ្ញុំធ្លាប់តក់ស្លុតជាងនេះឡើយ។ បើកឡានហោះមកសាលាហុកវ៉ាត! អឺ តាមពិតទៅ ខ្ញុំដឹងភ្លាមថាហេតុអ្វីបានជាឯងធ្វើរឿងនេះ។ ធ្វើដំណើរបានលឿន។ ហេរី ហេរី ហេរី។

វាគឺអស្ចារ្យណាស់ដែលថាគាត់អាចបង្ហាញគ្រប់ធ្មេញមួយៗក្នុងចំណោមធ្មេញដ៏ស្រស់ស្អាតទាំងនោះចេញមក ទោះបីជាពេលគាត់មិនកំពុងនិយាយក៏ដោយ។

- ខ្ញុំបានធ្វើឲ្យឯងភ្លក្សរសជាតិនៃប្រជាប្រិយភាព មិនថាអ៊ីចឹង?- ឡក់ហាតនិយាយ។ - នាំអោយឯងខូចអស់រលីង។ ឯងបានស្ថិតនៅលើទំព័រមុខនៃកាសែតជាមួយខ្ញុំ ហើយឯងមិនអាចរង់ចាំបានក្នុងការធ្វើវាម្តងទៀត។

- អូ...ទេ លោកសាស្ត្រាចារ្យ មើល...

- ហេរី ហេរី ហេរី- ឡក់ហាតនិយាយ រួចច្របាច់ស្មារបស់វា។ - ខ្ញុំយល់។ ធម្មតាទេដែលចង់សាកទៀតពេលបានភ្លក្សរសជាតិម្តងហើយនោះ ... ខុសមកពីខ្ញុំ ដោយសារតែរឿងនោះបានជាធ្វើឲ្យខួរក្បាលឯងចេះតែវិលវល់មិនដាច់ស្រលះ។ ...ប៉ុន្តែចាំស្តាប់នែ៎! អ្នកកម្លោះ ឯងមិនអាចចេះតែដើរបង្ហោះឡាន ដើម្បីគ្រាន់តែចង់ទាក់ទាញការចាប់អារម្មណ៍នោះទេ។ ធ្វើចិត្តឲ្យស្ងប់ទៅ បានទេ? ឯងមានពេលច្រើនណាស់សម្រាប់ធ្វើរឿងអស់ទាំងនោះពេលធំឡើង។ មែន មែន ខ្ញុំដឹងនូវអ្វីដែលឯងកំពុងគិត! "វាគ្មានអ្វីទេសម្រាប់គាត់ គាត់គឺជាវេទគូដែលល្បីល្បាញជាអន្តរជាតិមួយរូបទៅហើយ!" ប៉ុន្តែនៅពេលខ្ញុំអាយុដប់ពីរឆ្នាំ ខ្ញុំត្រឹមតែជាមនុស្សមិនសំខាន់ម្នាក់ដូចជាឯងពេលនេះអញ្ចឹង។ តាមពិត ខ្ញុំថាខ្លួនខ្ញុំអន់ជាងមនុស្សមិនសំខាន់ទៅទៀត! អ្វីដែលខ្ញុំចង់និយាយនោះគឺ មានមនុស្សមិនច្រើនទេដែលដឹងឮពីរូបឯង មែនទេ? គឺអំពីរឿងវ៉ារទាក់ទងនឹង អ្នកដែលមិនត្រូវហៅឈ្មោះ!- គាត់ចោលកន្ទុយភ្នែកមើលទៅស្លាកស្នាមផ្លេកបន្ទោរនៅលើថ្ងាសរបស់ហេរី។ - ខ្ញុំដឹង ខ្ញុំដឹង វាមិនល្អដូចជាការឈ្នះរង្វាន់ស្នាមញញឹមដ៏មានមន្តស្នេហ៍បំផុតរបស់ពួកវេទគូប្រចាំសប្តាហ៍ប្រាំលើកបន្តបន្ទាប់គ្នានោះទេ ដូចដែលខ្ញុំទទួលបាននោះទេ...ប៉ុន្តែវាគឺជាការចាប់ផ្តើមមួយ ហេរី វាគឺជាការចាប់ផ្តើមមួយ។

គាត់បានមិចភ្នែកដាក់ហេរីដោយភាពកក់ក្តៅមួយ ហើយបោះជំហានវែងៗចេញទៅ។ ហេរីឈរស្រឡាំងកាំងអស់មួយភ្លែតបន្ទាប់មក ដោយចាំថាវាត្រូវទៅផ្ទះកញ្ចក់ វាបានបើកទ្វារ ហើយប្រញាប់ចូលទៅខាងក្នុង។

សាស្ត្រាចារ្យស្ព្រោតកំពុងឈរពីក្រោយកៅអីវែងជើងគ្រោងមួយនៅចំកណ្តាលនៃផ្ទះកញ្ចក់។ មានប្រដាក់ពាក់ការពារត្រចៀកពណ៌ខុសៗគ្នាប្រហែលម្ភៃគូ ដាក់តំរៀបគ្នាលើកៅអីវែងនោះ។ នៅពេលហេរីមកអង្គុយកន្លែងរបស់វាដែលនៅចន្លោះរ៉ុន និងហឺម៉ាយអូនី គាត់និយាយៈ

- ពួកយើងនឹងដាក់ដាំដើម ម៉ានដ្រេក ឡើងវិញនៅថ្ងៃនេះ។ ឥឡូវតើនរណាអាចប្រាប់ខ្ញុំពីគុណសម្បត្តិនៃរុក្ខជាតិ ម៉ានដ្រេកនេះបាន?

មិនបាច់ភ្ញាក់ផ្អើលនោះទេ ច្បាស់ជាហឺម៉ាយអូនីលើកដៃឆ្លើយមុនគេជាមិនខាន។

- ម៉ានដ្រេក រឺ ម៉ានដ្រេហ្គូរ៉ា គឺជារុក្ខជាតិមួយដែលជួយឲ្យមានកម្លាំងខ្លាំងក្លាឡើងវិញ- ហឺម៉ាយអូនីសូត្រចាំរត់មាត់ហាក់ដូចជានាងបានយកសៀវភៅពុម្ពទៅដាំទឹកផឹកអញ្ចឹង។ - វាត្រូវបានប្រើប្រាស់សម្រាប់នាំមនុស្សដែលត្រូវបានគេប្តូររូប រឺត្រូវបណ្តាសាឲ្យត្រលប់មករកសភាពដើមរបស់ពួកគេវិញ។

- ល្អណាស់។ ដប់ពិន្ទុបានទៅក្រុមហ្វ្រីហ្វឹនដ័រ- សាស្ត្រាចារ្យសប្រ៉ោតនិយាយ។ - ម៉ានដ្រេក ដើរតួជាផ្នែកដ៏សំខាន់មួយនៃថ្នាំបន្សាបភាគច្រើន។ ទោះជាយ៉ាងណាក៏ដោយ វាក៏មានគ្រោះថ្នាក់ផងដែរ។ តើនរណាអាចប្រាប់ខ្ញុំបានទេថាហេតុអ្វីទៅ?

ដៃរបស់ហឺម៉ាយអូនីប៉ិះនឹងត្រូវប៉ះវ៉ែនតារបស់ហេរីពេលនាងលើកវាឡើងម្ដងទៀត។

- សំរែកយំនៃដើម ម៉ានដ្រេក គឺមានគ្រោះថ្នាក់ដល់ជីវិតចំពោះនរណាម្នាក់ដែលបានលឺវា- នាងឆ្លើយយ៉ាងរហ័ស។

- ប្រាកដណាស់។ ទទួលបានដប់ពិន្ទុទៀត- សាស្ត្រាចារ្យសប្រ៉ោតនិយាយ - ឥលូវដើម ម៉ានដ្រេក ដែលយើងមាននៅ ទីនេះគឺនៅខ្ចីខ្លាំងណាស់។

គាត់បានចង្អុលទៅស្ពកជ្រៅៗមួយជួរ នៅពេលគាត់និយាយ ហើយអ្នកទាំងអស់គ្នាបានដើរអូសជើងសំដៅទៅមើលឲ្យច្បាស់។ រុក្ខជាតិតូចៗដែលមានស្មៅដុះចាក់រឹសរាប់រយ រឺច្រើនជាងនេះ ពណ៌បៃតងលាយស្វាយខ្ចីបានកំពុងលូតលាស់នៅទីនោះជាជួរៗ។ ពួកគេមើលហៅរីដូចជាគ្មានអ្វីគួរឲ្យចាប់អារម្មណ៍សោះ ដែលវាគ្មានចម្ងល់ពីអ្វីដែលហឺម៉ាយអូនីចង់មានន័យពី "សំរែកយំ" នៃដើម ម៉ានដ្រេក នោះ។

- អ្នករាល់គ្នាយកប្រដាប់ពាក់ការពារត្រចៀកម្នាក់មួយគូមក- សាស្ត្រាចារ្យសប្រ៉ោតនិយាយ។

មានភាពច្របូកច្របល់មួយពេលសិស្សទាំងអស់គ្នាព្យាយាមចាប់យកម្នាក់មួយគូ ដែលមិនមែនជាពណ៌ផ្កាឈូក និងទន់ល្មើយនោះទេ។

- នៅពេលខ្ញុំប្រាប់ពួកឯងឲ្យពាក់វា ត្រូវប្រាកដថាត្រចៀកពួកឯងត្រូវបានបិទជិតទាំងស្រុង- សាស្ត្រាចារ្យសប្រ៉ោតនិយាយ។ - នៅពេលវាមានសុវត្ថិភាពដើម្បីឲ្យដោះចេញវិញបាន ខ្ញុំនឹងលើកមេដៃឡើងទៅពួកឯង។ ឥឡូវ...បំពាក់ប្រដាប់ការពារភ្លាម។

ហេរីទាញប្រដាប់ការពារពាក់លើត្រចៀករបស់វា។ វាមិនបានឮសម្លេងទាំងស្រុង។ សាស្ត្រាចារ្យសប្រ៉ោតបានពាក់ប្រដាប់ការពារមួយគូពណ៌ផ្កាឈូកទាន់ល្មើយពីលើត្រចៀករបស់គាត់ផ្ទាល់រួចមូរដៃអាវរ៉ូបរបស់គាត់ឡើង ចាប់កាន់មួយក្នុងចំនោមរុក្ខជាតិមានស្មៅចាក់រឹសទាំងនោះយ៉ាងជាប់ ហើយលើកឡើងទាំងលំបាក។

ហេរីបញ្ចេញនូវសម្លេងភ្ញាក់ផ្អើលមួយដែលគ្មាននរណាម្នាក់ស្ដាប់ឮទេ។

ជំនួសឲ្យរឹស កូនឈើខ្ចីដ៏កខ្វក់ពេញដោយភក់តូចមួយដើមលេចចេញពីក្នុងដី។ ស្លឹកកំពុងលូតលាស់ភ្លាមៗពេញពីកំពូលវា។ វាមានសំបកពណ៌បៃតងខ្ចីចំរុះ ហើយស្រែកយំយ៉ាងអស់មួយទំហឹង។

សាស្ត្រាចារ្យសប្រ៉ោតបានយកផើងដាក់រុក្ខជាតិធំមួយពីក្រោមតុ ហើយដាក់ដើម ម៉ានដ្រេក ទៅក្នុងនោះ ហើយកប់វាទៅក្នុងដីជ្រៅខ្មៅរហូតសូម្បីតែស្មៅក៏កប់បាត់ដែរ។ សាស្ត្រាចារ្យសប្រ៉ោតបោសសំអាតដៃរបស់គាត់ ហើយលើកដៃជាសញ្ញាទៅពួកគេទាំងអស់គ្នា និងដោះប្រដាប់ការពារត្រចៀករបស់គាត់ចេញ។

- នៅពេលដើម ម៉ានដ្រេក របស់ពួកយើងទើបតែបណ្ដុះ សំរែករបស់ពួកវានឹងមិនទាន់អាចសម្លាប់យើងបាននៅឡើយទេ- គាត់និយាយអះអាង ដូចជាគាត់មិនបានធ្វើអ្វីឲ្យភ្ញាក់ផ្អើលជាជាងស្រោចទឹកផ្កាចំរុះពណ៌នោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកវានឹងធ្វើឲ្យពួកឯងសន្លប់ជាច្រើនម៉ោង ហើយខ្ញុំជឿជាក់ថា មិនមាននរណាម្នាក់ក្នុងចំនោមពួកឯងចង់អវត្តមាននៅថ្ងៃចូលរៀនដំបូងឡើយ ត្រូវប្រាកដថាប្រដាប់ការពារត្រចៀករបស់ពួកឯងមានសុវត្ថិភាព ខណៈពេលដែលពួកឯងធ្វើការ។ ខ្ញុំនឹងធ្វើឲ្យពួកឯងចាប់អារម្មណ៍នៅពេលវាដល់ពេលត្រូវបញ្ចប់។

- ប្តូនដើមដាក់ក្នុងមួយស្តក...មានផើងជាច្រើនដែលផ្តល់ឲ្យនៅទីនេះ ... ដីនៅក្នុងបាវនៅទីនោះ ... ហើយត្រូវប្រយ័ត្ន ចំពោះដើម ចិនថាយ្យូឡាមានពិស ព្រោះវាកំពុងតែដុះធ្មេញហើយ។

គាត់បានទះមួយដៃយ៉ាងធ្ងន់ទៅលើរុក្ខជាតិពណ៌ក្រហមជាំរឹងមួយ ពេលគាត់និយាយ ធ្វើឲ្យរុក្ខជាតិនោះទាញសសៃវិញ្ញាណវែងៗរបស់វាដែលកំពុងពន្លូតពីលើស្មារបស់គាត់សន្សឹមៗ ចូលទៅវិញ។

ហេរី រ៉ុន និងហឺម៉ាយអូនីត្រូវសិស្សប្រុសសក់រួញអង្កាញ់ម្នាក់នៅក្រុម ហាហ្វ៊លផហ្វ ចូលរួមជាក្រុម។ ម្នាក់នេះ ហេរីធ្លាប់ស្គាល់ដោយចៃដន្យប៉ុន្តែមិនដែលនិយាយគ្នាទេ។

- ចាស់ស្ទីន ហ្វីន-ហ្វ្លិតឈ្លី- វានិយាយដោយរីករាយរួចចាប់ដៃហេរី។ - តាមពិតទៅ ខ្ញុំស្គាល់ថាឯងជានរណាហើយ ហេរីផោតធ័រដ៏ល្បីល្បាញ...ហើយនាងគឺហឺម៉ាយអូនី ហ្គ្រេនជឺរ...តែងតែឈានទៀងដល់កំពូលគ្រប់យ៉ាង...- (ហឺម៉ាយអូនីញញឹមរីករាយពេលនាងបានចាប់ដៃគេ) - និងរ៉ុន វីស្លី។ តើឡានហោះនោះជារបស់ឯង មិនអញ្ចឹងរឺ?

រ៉ុនមិនបានញញឹមទេ។ កំហឹងនៅ តែមានក្នុងចិត្តរបស់វាយ៉ាងប្រាកដ។

- លោក ឡក់ហាត នោះមានភាពអស្ចារ្យ មែនទេ?- ចាស់ស្ទីននិយាយដោយរីករាយពេលពួកគេចាប់ផ្តើមបំពេញផើងរុក្ខជាតិរបស់ពួកគេដោយជីអាចម៍នាគ។ - បុរសដ៏ក្លាហាន។ តើឯងបានអានសៀវភៅរបស់គាត់ទេ? ខ្ញុំអាចនឹងភ័យស្លាប់ បើខ្ញុំត្រូវគេធ្វើមិនឲ្យរើរួចនៅក្នុងទូទូរស័ព្ទមួយដោយមនុស្សចចកម្នាក់ ប៉ុន្តែគាត់នៅស្ងៀម ហើយ...វាយប្រហារយ៉ាងលឿន...ពិតជាអស្ចារ្យ។

- ឯងដឹងទេ ឈ្មោះរបស់ខ្ញុំត្រូវបាត់ពាក្យ អេតុន ខ្ញុំមិនអាចប្រាប់ឯងថា តើខ្ញុំរីករាយប៉ុណ្ណាទេដែលខ្ញុំបានមកទីនេះ។ ពិតណាស់ ម្តាយខ្ញុំមានការអន់ចិត្តបន្តិច ប៉ុន្តែតាំងពីខ្ញុំឲ្យគាត់អានសៀវភៅរបស់ឡក់ហាតមក ខ្ញុំគិតថាគាត់ក៏ចាប់ផ្តើមមើលឃើញ ពីសារៈប្រយោជន៍ក្នុងការមានវេទគូទទួលការហ្វឹកហ្វឺនពេញលេញម្នាក់នៅក្នុងគ្រួសារ...

ក្រោយមកពួកគេមិនមានឱកាសជជែកគ្នាច្រើនទេ។ ប្រដាប់ពាក់ការពារត្រចៀករបស់ពួកគេត្រូវពាក់ឡើងវិញ ហើយពួកគេត្រូវផ្ចង់ស្មារតីទៅលើដើម ម៉ានដ្រេក។ សាស្ត្រាចារ្យ សប្រ៉ោត បានធ្វើឲ្យវាមើលទៅហាក់ដូចជាងាយស្រួលខ្លាំងណាស់ ប៉ុន្តែវាមិនអញ្ចឹងនោះទេ។ ដើម ម៉ានដ្រេក មិនចង់ចេញពីក្នុងដី ប៉ុន្តែក៏ដូចជាមិនចង់ត្រលប់ចូលក្នុងដីវិញដែរ។ ពួកវាកំរើករវើកៗ ជាក់ រលស់កណ្តាប់ដៃតូចៗដ៏មុតស្រួចរបស់ពួកវា ហើយសង្គ្រឹតធ្មេញរបស់វា ហេរី ចំនាយពេលដប់នាទីពេញព្យាយាមសង្កត់ដើមដែលធំជាងគេមួយចូលទៅក្នុងផើង។

នៅពេលចប់ម៉ោងនោះ ហេរីក៏ដូចជាអ្នកឯទៀតដែរ បានបែកញើស ចុកខ្លួន ហើយប្រលាក់សុទ្ធតែដី។ ពួកគេដើរទ្រេតទ្រោតត្រលប់ទៅប្រាសាទវិញដើម្បី លាងសំអាតខ្លួនឲ្យលឿន និងបន្ទាប់មកក្រុមហ្គ្រីហ្វីនដ័រត្រូវប្រញាប់ទៅម៉ោងរៀនមុខវិជ្ជានិម្មិត។

ម៉ោងបង្រៀនរបស់អ្នកស្រីសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល តែងតែជាម៉ោងលំបាក ប៉ុន្តែថ្ងៃនេះកាន់តែលំបាកជាងមុនទៅទៀត។ អ្វីៗដែលហេរីបានរៀនកាលពីឆ្នាំមុនហាក់ដូចជាត្រូវបានបាត់ចេញពីក្នុងខួរក្បាលរបស់វាអស់ក្នុងកំឡុងពេលរដូវក្តៅ។ វាទំនងជាត្រូវប្រែរូបសត្វល្អិតម្យ៉ាងមួយក្បាលឲ្យទៅជាឡេវមួយ ប៉ុន្តែវាត្រឹមតែធ្វើអោយសត្វល្អិតនោះរត់ប្រញាយជើងនៅលើតុ ព្រោះតែចង់គេចពីចង្កឹះរបស់ហេរី។

រ៉ុនកំពុងមានបញ្ហាអាក្រក់ជាច្រើន។ វាបានជួសជុលចង្កឹះវេទមន្តរបស់វាដោយប្រើស្កុត ខ្ចីពីគេ ប៉ុន្តែវាហាក់ដូចជាត្រូវខូចទៅហើយក្រោយពេលជួសជុលរួច។ វានៅតែបាក់ ហើយបែកផ្កាភ្លើងយ៉ាងចម្លែក ហើយរាល់ពេលដែលរ៉ុនសាកល្បងប្រែរូបសត្វល្អិតរបស់វា វាបែរជាមានផ្សែងពណ៌ប្រផេះហុយព័ទ្ធជុំវិញវាទៅវិញ ដែលមានក្លិនដូចស៊ុតស្អុយ។ ដោយមិនអាចមើលនូវអ្វីដែលវា

បានកំពុងធ្វើនោះ រ៉ុនបានសង្កត់សត្វល្អិតរបស់វាដោយចៃដន្យដោយកែងដៃរបស់វា ហើយវាត្រូវសុំសត្វថ្មីមួយទៀត។ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលមិនពេញចិត្តនោះទេ។

ហេរី មានអារម្មណ៍ធូរស្រាលពេលឮសូរកណ្ដឹងអាហារថ្ងៃត្រង់។ ខួរក្បាលរបស់វាហាក់ដូចជាដុំកៅស៊ូទន់រមូរចូលគ្នា។ សិស្សទាំងអស់បានដើរជាជួរចេញពីថ្នាក់រៀនលើកលែងតែវា និងរ៉ុនដែលកំពុងវាយបំបាក់ចង្កឹះវេទមន្តរបស់វាទាំងកំហឹងនៅលើតុ។

- អារបស់...ឆ្កួត...ឥតបានការ...

- សរសេរសំបុត្រទៅផ្ទះសុំមួយទៀតទៅ- ហេរីផ្ដល់យោបល់ នៅពេលដែលចង្កឹះវេទមន្តនោះផ្ទុះឮសូរផ្ទុងផាំងដូចផាវ។

- អូ! មែនហើយ ហើយក៏ទទួលសំបុត្រស្ដីបន្ទោសមួយមកទៀតដែរ- រ៉ុននិយាយ ហើយញាត់ចង្កឹះវេទមន្តដែលកំពុងបញ្ចេញសម្លេងតិចៗចូលក្នុងកាតាបរបស់វា។ - វាគឺជាកំហុសរបស់ឯងដែលចង្កឹះវេទមន្តរបស់ឯងបាក់...

ពួកគេបានចុះទៅកន្លែងញ៉ាំអាហារថ្ងៃត្រង់។ អារម្មណ៍របស់រ៉ុនមិនល្អទេ ពេលហឺម៉ាយអូនី បង្ហាញពួកគេនូវឡេវអាវមួយក្ដាប់ដៃដ៏ល្អឥតខ្ចោះដែលនាងជប់បាននៅក្នុងម៉ោងរៀនវិជ្ជានិម្មិតកម្ម។

- តើពួកយើងរៀនអ្វីនៅរសៀលនេះ?- ហេរីនិយាយផ្លាស់ប្តូរប្រធានបទយ៉ាងរហ័ស។

- ការការពារប្រឆាំងនឹងមន្តអាគមងងឹត- ហឺម៉ាយអូនីនិយាយភ្លាមៗ។

- ហេតុអ្វី- រ៉ុនសម្លុត ដោយកញ្ឆក់យកកាលវិភាគរបស់នាង - បានជានាងដាក់សញ្ញាសំគាល់នៅម៉ោងបង្រៀនរបស់ឡក់ហាតទាំងអស់ជារូបបេះដូងដូច្នេះ?

ហឺម៉ាយអូនីកញ្ឆក់យកកាលវិភាគមកវិញ មុខនាងឡើងក្រហមដោយខឹងក្រេវក្រោធ។

ពួកគេញ៉ាំអាហារថ្ងៃត្រង់រួចហើយ ក៏ចេញទៅលេងខាងក្រៅសំដៅទៅទីធ្លាក្រោមផ្ទៃមេឃស្រទំ។ ហឺម៉ាយអូនី អង្គុយចុះលើផ្ទាំងថ្មមួយ ហើយយក សៀវភៅដំណើរតាមសមុទ្រជាមួយព្រាយជញ្ជក់ឈាម មកមើលទៀត។ ហេរី និងរ៉ុនឈរជជែកពីកីឡាឃ្វីដឌីច្ចអស់ជាច្រើននាទីមុនពេលហេរីដឹងថាវាកំពុងតែត្រូវគេឃ្លាំមើល។ ពិនិត្យមើលទៅ វាបានឃើញក្មេងប្រុសសក់រញ៉េរញ៉ៃដ៏តូចម្នាក់ ដែលវាធ្លាប់ឃើញ ពេលពាក់មួកវេទមន្តកាលពីយប់មិញនោះកំពុងសម្លឹងមើល ហេរី មិនដាក់ភ្នែកទាំងមិនកំរើកខ្លួន។ វាកំពុងកាន់វត្ថុម្យ៉ាងដែលមើលទៅដូចជាម៉ាស៊ីនថតរូបធម្មតារបស់ពួកលោកិយ ហើយខណៈនោះ ហេរីមើលទៅវា វាក៏ក្រហមមុខ។

- មែនហើយ ហេរី? ខ្ញុំគឺ...ខ្ញុំគឺ ខូលីន គ្រីវី- វានិយាយស្ទើរតែមិនដកដង្ហើម វាបោះជំហានទាំងស្ទាក់ស្ទើរមកមុខ។ - ខ្ញុំក៏នៅក្នុងក្រុម ហ្គ្រីហ្វិនដ័រ ដែរ។ តើឯងគិតថា...វាមិនអីទេរឺប្រសិនបើ...តើខ្ញុំអាចថតរូបមួយបានទេ?- វានិយាយ រួចលើកម៉ាស៊ីនថតឡើងដោយជឿជាក់។

- ថតរូបមួយរឺ?- ហេរីថាតាមទាំងមិនយល់។

- ទាល់តែអញ្ចឹង ទើបខ្ញុំអាចបញ្ជាក់ប្រាប់គេបានថា ខ្ញុំធ្លាប់ជួបឯង- ខូលីន គ្រីវី និយាយទាំងកំពុងចង់យ៉ាងខ្លាំង វាបង្អិតទៅឆ្ងាយបន្តិចម្ដងៗ។ - ខ្ញុំដឹងទាំងអស់ពីឯង។ អ្នកទាំងអស់គ្នាបានប្រាប់ខ្ញុំ។ អំពីថាតើឯងអាចរស់រានមានជីវិតបានដោយរបៀបណាពេល អ្នកដែលឯងស្គាល់ ព្យាយាមសម្លាប់ឯង ហើយស្នាមផ្លេកបន្ទោរនៅលើថ្ងាសរបស់ឯងវាយ៉ាងម៉េច- (ភ្នែករបស់វាទេរទៅមើលជើងសក់របស់ហេរី) - ហើយក្មេងប្រុសម្នាក់ក្នុងសយនដ្ឋានរបស់ខ្ញុំនិយាយថា ប្រសិនបើខ្ញុំផ្តិតរូបថតឲ្យបានត្រឹមត្រូវនោះ រូបភាពនឹងមានចលនា។- ខូលីន សំដែងនូវភាពរំភើបឡើងញ័រខ្លួនយ៉ាងខ្លាំងហើយនិយាយៈ

- វាអស្ចារ្យណាស់នៅទីនេះ មែនទេ? ខ្ញុំមិនដែលដឹងថា រឿងរ៉ាវចម្លែកៗទាំងឡាយដែលខ្ញុំបង្កឡើង គឺជាវេទមន្តនោះឡើយ

រហូតដល់ពេលខ្ញុំបានទទួលសំបុត្រពីហុកវ៉ាត ទើបបានដឹង។ ឪពុករបស់ខ្ញុំគឺជាអ្នកបំផើទឹកដោះគោតាមផ្ទះម្នាក់ គាត់ក៏សឹងតែមិនជឿដែរ។ ដូច្នេះខ្ញុំកំពុងថតរូបជាច្រើនដើម្បីផ្ញើទៅផ្ទះឲ្យគាត់។ ហើយវានឹងពិតជាល្អប្រសើរ បើខ្ញុំបានថតរូបជាមួយឯង...- វាមើលទៅហេរីដោយភាពអង្វរ -...តើមិត្តរបស់ឯងអាចជួយថតរូបយើងពីរនាក់បានទេ? ហើយបន្ទាប់មក តើឯងអាចចុះហត្ថលេខាលើរូបថតហ្នឹងបានទេ?

- រូបថតមានចុះហត្ថលេខា? ឯងអោយរូបថតមានចុះហត្ថលេខាតាំងពីអង្កាល់ហើយ ប៉ា ផោតធ័រ?

សម្លេងរិះគន់ដ៏លឺៗរបស់ដ្រាកូ មេលហ្វ័យឮសូរខ្ទរជុំវិញទីធ្លា។ វាបានឈប់ភ្លាមនៅពីក្រោយ ខូលីន វាត្រូវមានគេឈរអមដូចដែលវាតែងតែធ្វើនៅហុកវ៉ាតដោយបក្សពួកកោងកាចធំៗរបស់វាគឺ ក្រេប និង ហ្គយល៍។

- អ្នកទាំងអស់គ្នាចូលជួរ!- មេលហ្វ័យស្រែកទៅហ្វូងមនុស្ស។ - ហេរី ផោតធ័រកំពុងចែករូបថតចុះហត្ថលេខានែក!

- ទេ ខ្ញុំមិនមែនចែកទេ- ហេរីនិយាយដោយកំហឹង វាក្តាប់ដៃវាយ៉ាងណែន។ - បិទមាត់ឯងទៅ មេលហ្វ័យ។

- ឯងគ្រាន់តែច្រណែនប៉ុណ្ណោះ- ខូលីន និយាយកាត់។ ខ្លួនវាទាំងមូលយ៉ាងច្រើនណាស់ប៉ុនត្រឹមកក្រេបតែប៉ុណ្ណោះ។

- ច្រណែនរឺ?- មេលហ្វ័យនិយាយដោយមិនបាច់ត្រូវស្រែកទៀតទេ។ មនុស្សពាក់កណ្តាលនៅទីធ្លាកំពុងស្តាប់។ - ពីអ្វីទៅ? ខ្ញុំមិនចង់បានស្លាកស្នាមឆ្កួតមួយនៅលើក្បាលរបស់ខ្ញុំទេ អរគុណហើយ។ ខ្ញុំខ្លួនឯងមិនគិតថា ការធ្វើឲ្យក្បាលរបស់ឯងមានរបួសអាចធ្វើឲ្យឯងពិសេសយ៉ាងនេះសោះ។

ក្រេប និងហ្គយល៍កំពុងសើចចំអកយ៉ាងឆ្កួតលីលា។

- មេលហ្វ័យចង្រៃ- រ៉ុននិយាយទាំងកំហឹង។ ក្រេបឈប់សើច ហើយចាប់ផ្តើមត្រដុសកាច់ម្រាមដៃរបស់វាក្នុងន័យគំរាម។

- ប្រយ័ត្នផង វីស្លី- មេលហ្វ័យនិយាយមើលងាយ - ឯងមិនចង់បង្កបញ្ហាទៀតទេ បើមិនអញ្ចឹងទេម្តាយរបស់ឯងនឹងត្រូវមកយកឯងចេញពីសាលាហើយ- វាបាននិយាយក្នុងសម្លេងដ៏មុតស្រួចស្រួយមួយ។ - ប្រសិនបើឯងធ្វើអ្វីផ្សេងទៀតដែលខុសវិន័យ...

សិស្សមួយក្រុមតូចនៃក្រុម ស្លីតឺរីន ឆ្នាំទីប្រាំនៅក្បែរនោះសើចខ្លាំងៗចំពោះរឿងនេះ។

- វីស្លីចង់បានរូបថតចុះហត្ថលេខាមួយដែរ ផោតធ័រ- មេលហ្វ័យចំអកឲ្យ។ - វាទំនងជាមានតម្លៃជាងផ្ទះទាំងមូលរបស់គ្រួសារវាទៅទៀត។

រ៉ុនទាញ ចង្កឹះវេទមន្តបិតស្កុតរបស់វាចេញមក ប៉ុន្តែ ហឺម៉ាយអូនីបានបិទ សៀវភៅដំណើរតាមសមុទ្រជាមួយនឹងព្រាយជញ្ជក់ឈាម ដោយលឺសូរគ្រាំង ហើយខ្សឹបៈ

- មើលន៎!

- តើនេះមានរឿងអី ហ្នឹង មានរឿងអីហ្នឹង?- ហ្គីលដឺរ័យ ឡក់ហាត កំពុងបោះជំហានយ៉ាងលឿនសំដៅទៅពួកគេ រ៉ូបពណ៌ត្បូងមរកតរបស់គាត់ផាយផាត់ពីក្រោយគាត់។ - តើនរណាចែករូបថតចុះហត្ថលេខា?

ហេរី ចាប់ផ្តើមនិយាយ ប៉ុន្តែវាត្រូវឡក់ហាតកាត់សំដី ពេលគាត់គ្រវាត់ដៃដាក់ជុំវិញស្មារបស់វា ហើយសំដែងភាពរីករាយយ៉ាងខ្លាំងៈ

- មិនគួរសួរអ្វីទេ! យើងត្រូវជួបគ្នាម្តងទៀតហើយ ហេរី!

ដោយត្រូវកៀកជាប់នឹងខ្លួនរបស់ឡក់ហាត និងកំពុងមានភាពអាម៉ាស់ផងនោះ ហេរីបានឃើញ មេលហ្វ័យ បែរទៅសើចរបៀបចំអកឲ្យទៅក្នុងហ្វូងមនុស្ស។

- លឿនឡើងមក លោកគ្រីវ- ឡក់ហាតនិយាយ ញញឹមយ៉ាងរួសរាយដាក់ ខូលីន ។ - រូបភាពពីរនាក់ មិនអាចនិយាយថាវាល្អជាងនោះទេវី ហើយពួកយើងទាំងពីរនឹងចុះហត្ថលេខាលើវាឲ្យឯង។

ខូលីន កាន់ម៉ាស៊ីនថតរបស់វាទាំងឆ្គង ហើយថតរូបនោះចំពេលដែលកណ្ដឹងរោទិ៍ពីក្រោយពួកគេ ជាសញ្ញាប្រាប់ថាដល់ពេលចាប់ផ្ដើមចូលរៀននៅពេលរសៀលហើយ។

- ពួកឯងចេញទៅ ដើរតាមទីនោះ- ឡក់ហាតប្រាប់ទៅហ្វូងសិស្ស ហើយគាត់ដើរត្រលប់ទៅប្រាសាទជាមួយហេរី ដែលត្រូវគាត់ក្រៀកជាប់នឹងខ្លួន។ ហេរីបន់អោយតែចេះបាលីបំបាំងកាយនោះទេ។

- ខ្ញុំសូមផ្ដល់ដំបូន្មានល្អមួយណ៎ា ហេរី- ឡក់ហាតនិយាយដូចឪពុកប្រដៅកូន ពេលដែលពួកគេចូលទៅអគារ ដោយឆ្លងកាត់ទ្វារមួយ។ - គឺខ្ញុំជួយលាក់បាំងរឿងឯងជាមួយក្មេង គ្រីវី ។ ប្រសិនបើវាថតរូបខ្ញុំដែរ មិត្តភក្ដិរបស់ឯងនឹងមិនគិតថាឯងកំពុងលើកតំកើងខ្លួនឯងពេកនោះទេ...

ដោយមិនតាំងចិត្តស្ដាប់នូវសំដីរដាក់រដុបរបស់ហេរី ឡក់ហាត បានរុញវាទៅតាមផ្លូវរបៀងឆ្លងកាត់ពួកសិស្សដែលកំពុងសម្លឹងមើលមក ហើយឡើងតាមជណ្ដើរមួយទៅ។

- ខ្ញុំគ្រាន់តែនិយាយថា ការចែកចាយ រូបថតចុះហត្ថលេខា ក្នុងដំនាក់កាលនៃអាជីពរបស់ឯងនេះមិនសមរម្យទេ...បើនិយាយឲ្យត្រង់ទៅ ហេរី ការធ្វើបែបនេះដូចជាលេចមុខលេចមាត់ពេកហើយ។ អាចនឹងមានពេលណាមួយដែល...ដូចជាខ្ញុំអញ្ចឹង...ឯងនឹងត្រូវការយករូបថតមួយគំនរទុកតាមខ្លួនពេលទៅណាមកណា ប៉ុន្តែ...- គាត់សើចបន្តិច - ខ្ញុំមិនគិតថា ឯងមិនទាន់ដល់អាយុហ្នឹងទេ។

ពួកគេបានទៅដល់ថ្នាក់រៀនរបស់ឡក់ហាត ហើយគាត់ទុកឲ្យហេរីចូលទៅក្រោយគេ។ ហេរីកន្ត្រាក់រ៉ូបរបស់វាឲ្យត្រង់ ហើយសំដៅរកកន្លែងអង្គុយនៅខាងក្រោយគេបង្អស់នៃថ្នាក់ ដែលវាកំពុងរវល់នឹងគរសៀវភៅទាំងប្រាំពីររបស់ ឡក់ហាត ទាំងអស់នៅពីមុខវា ដូច្នេះហើយ វាអាចគេចវេសពីពួកគេទាំងនោះបាន។

អ្នកឯទៀតនៅក្នុងថ្នាក់កំពុងបង្កើតសម្លេងក្រោកក្រាក ហើយ រ៉ុន និង ហឺម៉ាយអូនី បានអង្គុយចុះនៅក្បែរហេរី។

- មុខរបស់ឯងពេលនោះឡើងក្រហមសឹងនឹងអាចចៀនពងទាបាន - រ៉ុននិយាយ។ - ឯងគួរតែសង្ឃឹមថា គ្រីវី មិនបានជួបជីននីឡើយ បើមិនអញ្ចឹងទេ ពួកគេនឹងបើក ក្លឹបគាំទ្រហេរី ផោតធ័រ ហើយ។

- បិទមាត់ទៅ- ហេរីនិយាយម៉ាត់ៗ វាមិនចង់អោយ ឡក់ហាត លឺឃ្លាថា "ក្លឹបគាំទ្រហេរី ផោតធ័រ" ទេ។

នៅពេលសិស្សពេញមួយថ្នាក់ត្រូវបានឲ្យអង្គុយចុះ ឡក់ហាតជម្រះបំពង់ករបស់គាត់យ៉ាងលឺ ហើយស្ងាត់ទៅវិញ។ គាត់ដើរសំដៅទៅយកសៀវភៅ ការធ្វើដំណើរជាមួយប្រែត របស់ នេវីល ឡុងបត់ថម ហើយលើកវាឡើងដើម្បីបង្ហាញរូបថតមិចភ្នែករបស់គាត់ផ្ទាល់ដែលស្ថិតនៅក្របមុខ។

- ខ្ញុំ- គាត់និយាយ ចង្អុលទៅរូបនោះ ហើយមិចភ្នែកយ៉ាងស្អាត - ហ្គីលដឺរ័យ ឡក់ហាត ជាខ្សែស្រឡាយត្រកូលមើលីនថ្នាក់ទីបី សមាជិកកិត្តិយសនៃក្របខណ្ឌការគាំពារប្រឆាំងនឹងកំលាំងងងឹត និងជាអ្នកឈ្នះពានរង្វាន់ប្រាំលើកនៃស្នាមញញឹមដ៏មានមន្តស្នេហ៍បំផុតក្នុងចំនាត់ថ្នាក់វេទគូប្រចាំសប្ដាហ៍...ប៉ុន្តែខ្ញុំមិននិយាយពីរឿងនោះទេ។ ខ្ញុំមិនបានកំចាត់ខ្មោច ប៊ែនដុន បានស្ទើដោយការញញឹមឡើយ!- គាត់ចាំឲ្យពួកគេសើច។ សិស្សពីរបីនាក់ញញឹមតិចៗ។

- ខ្ញុំឃើញអ្នកទាំងអស់គ្នាបានទិញសៀវភៅរបស់ខ្ញុំគ្រប់ប្រភេទរួចអស់ហើយ...ល្អណាស់។ ខ្ញុំគិតថា ពួកយើងចាប់ផ្ដើមរៀនថ្ងៃនេះដោយធ្វើសំនួរបន្តិច។ គ្មានអ្វីត្រូវបារម្ភទេ...គ្រាន់តែសាកល្បងថាតើពួកឯងបានអានវាច្រើនប៉ុណ្ណា តើពួកឯងស្រាវជ្រាវបានច្រើនប៉ុណ្ណា...

នៅពេលគាត់ចែកក្រដាសប្រលងរួច គាត់ត្រលប់ទៅខាងមុខថ្នាក់ ហើយនិយាយថា៖

- ពួកឯងមានរយៈពេល៣០នាទី ចាប់ផ្ដើមឥឡូវនេះ!

ហេរីពិនិត្យលើក្រដាសរបស់វា ហើយអាន៖

១. តើពណ៌អ្វីដែល ហ្គីលដឺរ័យ ឡុក់ហាត ចូលចិត្ត?

២. តើមហិច្ឆតាសម្ងាត់របស់ ហ្គីលដឺរ័យ ឡុក់ហាត ជាអ្វី?

៣. ក្នុងគំនិតរបស់អ្នក តើអ្វីជាជោគជ័យធំបំផុតរបស់ ហ្គីលដឺរ័យ ឡុក់ហាត រហូតមកដល់សព្វថ្ងៃនេះ។

បន្តបន្ទាប់មកទៀត ប្រហែលជាជាងបីផ្នែកនៃក្រដាសរហូតដល់៖

៥៤. តើខួបកំណើតរបស់ ហ្គីលដឺរ័យ ឡុក់ហាត នៅពេលណា ហើយតើអំនោយដែលគាត់ចង់បានបំផុតជាអ្វី?

កន្លះម៉ោងក្រោយមក ឡុក់ហាត បានប្រមូលសន្លឹកកិច្ចការ ហើយពិនិត្យមើលក្រដាសម្ដងមួយៗនៅពីមុខថ្នាក់។

- ទេ ទេ...ស្ទើរតែគ្មានអ្នកណាម្នាក់ក្នុងចំណោមពួកឯងចាំថាពណ៌ដែលខ្ញុំចូលចិត្តគឺពណ៌ស្វាយព្រលែត។ ខ្ញុំនិយាយដូច្នេះក្នុងសៀវភៅ ឆ្នាំនៃមនុស្សព្រៃកំណាច។ ហើយពួកឯងពីរបីនាក់ត្រូវអានសៀវភៅ ដំណើរតាមសមុទ្រជាមួយមនុស្សចចក ឲ្យម៉ត់ចត់បន្តិច...ខ្ញុំបានពោលយ៉ាងច្បាស់ក្នុងជំពូកដប់ពីរថាអំនោយថ្ងៃខួបកំនើតដែលត្រូវខ្ញុំចង់បានបំផុតនោះគឺភាពចុះសំរុងគ្នារវាងមនុស្សមានវេទមន្ត និងអ្នកគ្មានវេទមន្តទាំងអស់...ទោះជាយ៉ាងនេះក្ដី ខ្ញុំក៏មិនបដិសេធថាខ្ញុំមិនចង់បានស្រា វីស្គីក្ដៅបុរាណរបស់អចដិន មួយដបធំដែរ!

គាត់បានមិចភ្នែកគួរឲ្យចង់សើចម្ដងទៀត។ ឥឡូវ រ៉ុន កំពុងសំឡក់ឡុក់ហាតដោយភាពមិនជឿនៅលើមុខរបស់វា។ ស៊ីម្មុស ហ្វីននីហ្គេន និង ឌីន ថូម៉ាស ដែលកំពុងអង្គុយនៅខាងមុខកំពុងចាប់ដៃគ្នាសើចស្ងាត់ៗ។ ឯ ហឺម៉ាយអូនីវិញ កំពុងស្ដាប់ឡុក់ហាតយ៉ាងជក់ចិត្ត ហើយក៏ភ្ញាក់ព្រើតនៅពេលគាត់និយាយដល់ឈ្មោះនាង។

-...ប៉ុន្តែកញ្ញាហឺម៉ាយអូនី ហ្គ្រេនជឺដឹងពីមហិច្ឆតាសម្ងាត់របស់ខ្ញុំគឺ កំចាត់ពិភពបិសាច និងបញ្ចេញលក់នូវប្រភេទទឹកថ្នាំថែរក្សាសក់របស់ខ្ញុំផ្ទាល់...ក្មេងស្រីឆ្លាត! ជាការពិត...- គាត់បានត្រលប់ក្រដាសនាងឡើង - ពិន្ទុពេញ! តើកញ្ញាហឺម៉ាយអូនីនៅឯណា?

ហឺម៉ាយអូនីលើកដៃទាំងញ័រឡើង។

- ល្អណាស់!- ឡុក់ហាតញញឹម។ - ល្អណាស់! យកដប់ពិន្ទុសម្រាប់ក្រុមហ្គ្រីហ្វីនដ័រ! ហើយដូច្នេះ ដើម្បីបន្តទៅទៀត...

គាត់បានអោនចុះនៅពីក្រោយតុរបស់គាត់ ហើយបានលើកទ្រុងថ្មីធំមួយមកដាក់លើវា។

- ឥលូវ...ត្រូវប្រយ័ត្ន! វាគឺជាការងាររបស់ខ្ញុំដែលត្រូវផ្ដល់អាវុធដល់ពួកឯងដើម្បីទប់ទល់នឹងសត្វដ៏អាក្រក់បំផុត...ពួកឯងត្រូវប្រឈមមុខនឹងភាពភ័យខ្លាចអាក្រក់បំផុតរបស់ពួកឯងក្នុងបន្ទប់នេះដោយផ្ទាល់។ ដឹងត្រឹមតែថា គ្មានទុក្ខទោសអ្វីអាចបង្កដល់ពួកឯងខណៈពេលដែលខ្ញុំនៅទីនេះទេ។ អ្វីទាំងអស់ដែលខ្ញុំស្នើគឺសូមឲ្យពួកឯងរក្សាភាពស្ងប់ស្ងាត់។

ដោយទ្បេក ហើរីបានបង្វែងខ្លួនជុំវិញគំនរសៀវភៅរបស់វាដើម្បីមើលទ្រុងនោះឲ្យបានច្បាស់។ ឡក់ហាតបានដាក់ដៃលើក គំរបទ្រុង។ ឌីន និង ស៊ីម្យុស ឈប់សើចហើយតលូវ។ នេវីលកំពុងធ្វើក្រញោនៗនៅកៅអីជួរមុខរបស់វា។

- ខ្ញុំតំរូវឲ្យពួកឯងកុំស្រែក- ឡក់ហាតនិយាយខ្សោយៗ - វាអាចនឹងធ្វើឲ្យពួកវាខឹង។

នៅពេលថ្នាក់ទាំងមូលស្ងាត់ជ្រៀបស្ទើរតែមិនដកដង្ហើមនោះ ឡក់ហាតបានវាយគំរបទ្រុង។

- មែនហើយ- គាត់និយាយភ្លាមៗ។ - នេះជា សត្វម្រេញគង្វាលរបិុលរប៉ុចដែលចាប់បានស្រស់ៗ។

ស៊ីម្យុស ហ្វីនីហ្គេនមិនអាចម្ចាស់ការលើខ្លួនវាបានឡើយ។ វាបានផ្ទុះសំណើចយ៉ាងលឺចេញមកដែលសូម្បីតែ ឡក់ហាត ក៏មិនអាចប្រឡំថា ជាសម្រែកនៃភាពភ័យខ្លាចដែរ។

- មានរឿងអី?- គាត់ញញឹមដាក់ស៊ីម្យុស។

- អឺ ពួកវាមិន...ពួកវាមិន...គ្រោះថ្នាក់ខ្លាំងទេ មែនទេ?- វានិយាយទាំងឈ្លក់។

- កុំប្រាកដពេកអី- ឡក់ហាតនិយាយ គ្រវីម្រាមដៃមួយទាំងម៉ូម៉ៅបន្តិចដាក់ស៊ីម្យុស។ - ពួកវាគឺជា សត្វបំផ្លិចបំផ្លាញតូចៗពោរពេញដោយល្បិចមួយរយជំពូក!

សត្វចម្លែកទាំងនោះ មានពណ៌ខៀវដូចអគ្គិសនី ហើយប្រហែលជាកំពស់ប្រាំបីអ៊ីង មានមុខស្រួច និងសម្លេងដ៏ស្រួយស្រែស ដូចជាកំពុងស្តាប់គេឈ្លោះគ្នាបែកផ្សែងអញ្ចឹង។ ខណៈនោះគំរបទ្រុងបានរបើក ពួកវាចាប់ផ្តើមចេចចាច និងហោះជុំវិញ បន្លឺសូរក្រិកៗនឹងបន្ទះដែក ហើយធ្វើមុខប្លែកៗដាក់សិស្សដែលនៅជិតពួកវាបំផុត។

- អញ្ចឹង- ឡក់ហាតនិយាយឮៗ។ - ចាំមើលតើពួកឯងនឹងធ្វើអ្វីចំពោះវា!- ហើយគាត់បានបើកទ្រុងនោះ។

មានសម្លេងទ្រហឹងអឹងកងកើតឡើង។ សត្វចម្លែកហោះស្ទុយចេញទៅគ្រប់ទិសទីដូចរ៉ុកកែត។ ពួកវាពីរនាក់បានចាប់ត្រចៀកនេវីល ហើយលើកវាបោះឡើង។ ជាច្រើនក្បាលទៀតហោះប្រុយទៅតាមបង្អួច ទម្លាក់អំពូល បែកខ្ទេចនៅជួរខាងក្រោយ។ នៅសល់ពីនេះ បានបន្តបំផ្លាញថ្នាក់រៀនខ្លាំងជាងរមាសកំពោលចូលមួយក្បាលទៅទៀត។ ពួកវាហោះឆាបយកដបទឹកខ្មៅ ហើយចាក់ពេញថ្នាក់ ហែកសៀវភៅ និងក្រដាស ទម្លាក់រូបភាពពីជញ្ជាំង ផ្តួលធុងសំរាម ឆាបយកកាតាប និងសៀវភៅ ហើយគ្រវែងចោលតាមបង្អួច។ ក្នុងពេលមួយភ្លែតនោះ សិស្សពាក់កណ្តាលថ្នាក់បានក្រាបចុះក្រោមតុ ហើយនេវីលកំពុងជាប់នៅនឹងចង្កៀងដែលព្យួរលើពិតាន។

- ឆាប់ឡើងមក ព័ទ្ធពួកវា ពួកវាគ្រាន់តែជាសត្វចម្លែកប៉ុណ្ណោះ...- ឡក់ហាតបានស្រែក។

គាត់បានមូរដៃអាវឡើង គ្រវីចង្កឹះវេទមន្ត ហើយស្រែកៈ

- *ភេសគីភីគស៊ី ភេសទ័រនូមី!*

វាពិតជាគ្មានឥទ្ធិពលបន្តិចសោះ មួយក្បាលក្នុងចំនោមសត្វចម្លែកទាំងនោះបានចាប់ចង្កឹះវេទមន្តរបស់ឡក់ហាត ហើយគ្រវែងចោលតាមបង្អួចដែរ។ ឡក់ហាតលេបទឹកមាត់ក្អឿក ហើយលោតចូលក្រោមតុរបស់គាត់ ប៉ិះនឹងត្រូវសំប៉ែតដោយនេវីល ដែលបានធ្លាក់មកតាមក្រោយបន្តិច ពេលដែលចង្កៀងដាច់ធ្លាក់មក។

កណ្តឹងបានរោទិ៍ ហើយហ្វូងសិស្សបានស្ទុះចេញយ៉ាងប្រញាប់សំដៅទៅច្រកចេញ។ ស្ថិតក្នុងសភាពស្ងប់ស្ងាត់បន្តិចក្រោយមក ឡក់ហាតងើបឡើង ចាប់ហើរី រ៉ុន និងហឺម៉ាយអូនី ដែលជិតទៅដល់ទ្វារហើយ ហើយនិយាយៈ

- អឺ ខ្ញុំនឹងស្នើឲ្យឯងទាំងបីជាអ្នកចាប់ពួកវាដែលនៅសល់ចូលក្នុងទ្រុងរបស់ពួកវាវិញ។- គាត់បានចេញទៅ ហើយបិទទ្វារយ៉ាងលឿនពីក្រោយគាត់។

- តើពួកឯងអាចជឿគាត់ទេ?- រ៉ុនគំហក នៅពេលសត្វចម្លែកមួយក្បាលដែលនៅសល់ខាំវាឡើងចុកលើត្រចៀក។

- គាត់គ្រាន់តែចង់ផ្តល់ឲ្យយើងនូវបទពិសោធផ្ទាល់ប៉ុណ្ណោះ- ហឺម៉ាយអូនីនិយាយ ពេលកំពុងធ្វើឲ្យសត្វចម្លែកពីរក្បាលទៅណាលែងរួចភ្លាមដោយបាលីបង្អក ហើយរុញពួកវាចូលទៅក្នុងទ្រុងរបស់ពួកវាវិញ។

- ផ្ទាល់រឺ?- ហេរីនិយាយ កំពុងព្យាយាមឈោងចាប់សត្វចម្លែកមួយក្បាលកំពុងហើរចុះឡើងលៀនអណ្តាតចេញមក។ - ហឺម៉ាយអូនី គាត់មិនបានគិតដល់អ្វីដែលគាត់កំពុងធ្វើនោះទេ។

- ឆ្កួត- ហឺម៉ាយអូនីនិយាយ - ឯងបានអានសៀវភៅគាត់ហើយ...មើលទៅរឿងអស្ចារ្យដែលគាត់បានធ្វើទាំងអស់នោះទៅ...

- គាត់ចេះតែនិយាយថាគាត់បានធ្វើតែប៉ុណ្ណឹង- រ៉ុននិយាយតិចៗ។

## វគ្គ VII



# ឈាមកខ្វក់ និងពាក្យខ្សឹបខ្សៀវ

ហេរីបានចំនាយពេលជាច្រើននាប៉ុន្មានថ្ងៃបន្ទាប់នោះ ដើម្បីតែគេចចេញពីក្រសែភ្នែករបស់ ហ្គីលដឺរ័យ ឡក់ហាត នៅពេលដែលគាត់ចុះមកផ្លូវរបៀងម្តងៗ។ កាន់តែពិបាកគេចទៀតនោះគឺ ខូលីន គ្រីវី ដែលហាក់ដូចជាចាំស្ទាត់ខ្ទេចនូវកាលវិភាគសិក្សារបស់ហេរី។ ហាក់ដូចជាគ្មានអ្វីដែលធ្វើឲ្យ ខូលីន រំភើបចិត្តជាជាងបាននិយាយថា "មិនអីទេរី ហេរី?" ប្រាំមួយប្រាំពីរដងក្នុងមួយថ្ងៃ ព្រមទាំងស្តាប់ឮ "សួស្តី ខូលីន" តបមកវិញនោះទេ ទុកជាហេរីនិយាយបែបក្រេវក្រោធម៉េចក៏ដោយ។

ហ៊ិដវីកនៅមិនទាន់បាត់ខឹងនឹងហេរីអំពីដំណើរតាមឡានយ៉ាងមហាគ្រោះថ្នាក់នោះនៅឡើយទេ ចំនែកចង្កឹះវេទមន្តរបស់រ៉ុនក៏មិនទាន់ប្រើការបានដែរ ហើយថែមទាំងបានបញ្ចេញមហិទ្ធិឫទ្ធិហួសកម្រិតនៅព្រឹកថ្ងៃសុក្រ ដោយរបូតក្តុចចេញពីដៃរបស់រ៉ុនក្នុងម៉ោងរៀនវេទមន្ត ព្រមទាំងខ្ទាតទៅប៉ះចំសាស្រ្តាចារ្យ ហ្លីតវីក ចំនាស់មាឌល្អិតប៊ិះត្រូវភ្នែកទៀតផង។ ការនេះធ្វើឲ្យមានស្នាមខ្នុះពណ៌បៃតងដ៏ធំមួយនៅចន្លោះភ្នែកទាំងពីររបស់លោកសាស្រ្តាចារ្យ។ ដោយសារតែរឿងអញ្ចេះអញ្ចុះមិនចេះចប់មិនចេះហើយទាំងអស់ហ្នឹងហើយ ដែលធ្វើឲ្យហេរីបន់ឲ្យតែដល់ថ្ងៃចុងសប្តាហ៍។ វា រ៉ុន និងហឺម៉ាយអូនីមានគំរោងថានឹងទៅលេងហាហ្គ្រីដនៅព្រឹកថ្ងៃសៅរ៍។ ទោះជាយ៉ាណាក្តី ហេរីត្រូវបាន ដំបង អង្រួនដាស់ឲ្យភ្ញាក់តាំងពីជាច្រើនម៉ោងមុន ខុសពីទម្លាប់ដេករបស់វា។

\- មានការអី?- ហេរីនិយាយទាំងរងឹររងើ។

\- ទៅហាត់សមកីឡាឃ្វីដឌីច្ច!- ដំបងឧទានឡើង។ - ឲ្យលឿនឡើង!

ហេរី បើកភ្នែកព្រឹមៗមើលទៅបង្អួច។ មានអ័ព្ទដ៏ស្តើងមួយ កំពុងតែរសាត់ព័ទ្ធកណ្តាលមេឃពណ៌ផ្កាឈូកលាយមាស។ ឥឡូវវាភ្ញាក់ទៅហើយ ប៉ុន្តវានៅតែមិនអាចយល់បានថា តើវាអាចដេកលក់បាននៅក្រោមសូរកងរំពងបន្លឺឡើងដោយបក្សាបក្សីម៉េចនឹងកើតទៅ។

\- ដំបង- ហេរីនិយាយគ្រលរៗ។ - ទើបនឹងថ្ងៃចាប់រះទេតើ។

\- ប្រាកដហើយ- ដំបងពោលតប។ ពេលនោះ វាជាសិស្សឆ្នាំទីប្រាំមួយ ព្រមទាំងមានរាងផៅខ្ពស់ស្រឡះ និងមាឌមាំមួន ឯភ្នែករបស់វាបញ្ចេញពន្លឺព្រិចៗដោយសេចក្តីត្រេកត្រអាលឡើងចង់ទៅជាឆ្កួត។

- វាជាផ្នែកមួយនៅក្នុងកម្មវិធីហាត់សមថ្មីរបស់ពួកយើង។ ប្រញាប់ឡើង ឆាប់ទៅយកអំបោសឯងមក រួចហើយ តោះទៅ- ដំបងស្រដីយ៉ាងរាក់ទាក់។ - ក្រុមផ្សេងៗទៀតមិនទាន់បានចាប់ផ្ដើមហ្វឹកហាត់នៅឡើយទេ។ ពួកយើងច្បាស់ជាទទួលពិន្ទុខ្ពស់ជាងគេហើយឆ្នាំនេះ...

ដោយស្ងាប និងរលាស់ខ្លួនបន្តិច ហេរីក៏ងើបចេញពីគ្រែ ហើយព្យាយាមរកមើលអាវរ៉ូបលេងកីឡាឃ្វីដឌីច្ចរបស់វា។

- ពិតជាក្មេងល្អមែន- ដំបងបន្លឺឡើង។ - ចាំជួបឯងនៅទីលានកីឡាដ្ឋានដប់ប្រាំនាទីក្រោយ។

នៅពេលដែលវារកឃើញអាវក្រុមពណ៌ក្រហមច្រាបរបស់វា ព្រមទាំងស្លៀកបន្ថែមអាវខូកពីលើដើម្បីឲ្យមានភាពកក់ក្ដៅ វាក៏សរសេរខ្សៀកនូវសំបុត្រមួយទុកឲ្យរ៉ុនដោយពន្យល់ពីទីកន្លែងដែលវាទៅ រួចចុះតាមជណ្ដើររិលទៅកាន់សាលរួម ថែមទាំងមានលីអំបោសនីមប៊ូស ២០០០ ដាក់លើស្មារបស់វា។ វាទើបតែទៅដល់ចន្លោះប្រហោងចេញពីបន្ទប់នោះ ស្រាប់តែឮសូរសម្លេងក្រោកក្រាកពីក្រោយវា ហើយក៏ឃើញ ខូលីន គ្រីវី រត់ត្រហេបត្រហបចុះតាមកាំជណ្ដើររិល ឯម៉ាស៊ីនថតរបស់វាវិញវិលរណោងរណោងជុំវិញករបស់វា ព្រមទាំងមានក្ដាប់ណែនអ្វីមួយយ៉ាងជាប់នៅក្នុងដៃ។

- ខ្ញុំបានឮនរណាម្នាក់និយាយឈ្មោះរបស់ឯងនៅជាន់លើនោះ ហេរី! មើលណែ៎ តើខ្ញុំមានអ្វី! ខ្ញុំបានយកទៅផ្តិតហើយ ខ្ញុំចង់បង្ហាញឲ្យឯងមើល...

ហេរីសម្លឹងមើលយ៉ាងភ័ន្តភាំងទៅរូបថតដែលខូលីនកំពុងតែគ្រវីចុះឡើងពីក្រោមច្រមុះរបស់វា។

រូបលោកឡក់ហាតពណ៌ខ្មៅសដែលមានចលនាកំពុងតែទាញដៃមួយយ៉ាងខ្លាំងដែលហេរីចំនាំបានថាជាដៃរបស់វា។ វាពិតជារីករាយណាស់ដែលបានឃើញថា រូបរបស់វាកំពុងតែរើបំរះចេញ ហើយក៏គ្មានបង្ហាញឲ្យឃើញក្នុងរូបថតនោះដែរ។ ខណៈដែលហេរីសម្លឹងមើល ឡក់ហាតក៏ព្រមចុះចាញ់ ហើយក៏អង្គុយចុះផ្អែកនឹងគែមពណ៌សនៃរូបថត ទាំងដកដង្ហើមមិនត្រូវគ្នា។

- តើឯងនឹងចុះហត្ថលេខាលើវាដែររឺទេ?- ខូលីនសួរទាំងចង់ដឹង។

- ទេ- ហេរីតបវិញបែបហី ព្រមទាំងក្រឡេកមើលជុំវិញដើម្បីពិនិត្យមើលថា តើក្នុងបន្ទប់នោះមានមនុស្សនៅរឺក៏អត់។ - សុំទោស ខូលីន ខ្ញុំប្រញាប់ខ្លាំងណាស់...ត្រូវទៅហ្វឹកហាត់លេងឃ្វីដឌីច្ចផង...

និយាយរួច វាក៏ឡើងវារតាមចន្លោះប្រហោងចេញទៅក្រៅ។

- អូ! វ៉ូវ! ចាំខ្ញុំផង! ខ្ញុំមិនដែលធ្លាប់មើលកីឡាឃ្វីដឌីច្ចពីមុនមកទេ!

ខូលីនក៏វារឡើងតាមចន្លោះប្រហោងនោះពីក្រោយហេរី។

- វានឹងច្បាស់ជាធុញទ្រាន់មិនខានទេ- ហេរីនិយាយយ៉ាងរហ័ស ប៉ុន្តែខូលីនមិនខ្វល់ទេ មុខរបស់វាចែងចាំងទៅដោយក្ដីរំភើប។

- ឯងគឺជាអ្នកលេងកីឡាឃ្វីដឌីច្ចក្មេងជាងគេនៅក្នុងកាលមួយរយឆ្នាំនេះ មែនទេ ហេរី? មែនទេ?- ខូលីនបន្លឺឡើង ដោយដើរតត្រុកជិតវា។ - ឯងប្រាកដជាលេងបានល្អណាស់ហើយ។ ខ្ញុំមិនដែលធ្លាប់ហោះទេ។ តើវាងាយស្រួលរឺទេ? តើនោះជាអំបោសផ្ទាល់ខ្លួនរបស់ឯងរឺ? តើវាជាអំបោសល្អជាងគេមែនទេ?

ហេរីមិនដឹងជាត្រូវដកខ្លួនចេញពីវាដោយវិធីណានោះទេ។ វាហាក់ដូចជាស្រមោលអន្ទោលតាមប្រាណអញ្ចឹង។

- ខ្ញុំពិតជាមិនយល់អំពីកីឡាឃ្វីដឌីច្ចទាល់តែសោះ- ខូលីននិយាយស្ទើរអត់ដង្ហើម។ - តើពិតទេដែលថាមានបាល់បួនគ្រាប់នោះ? ហើយប្រាកដមែនរឺដែលថា មានបាល់ពីរគ្រាប់ហោះទៅហោះមកដើម្បីបុកទម្លាក់កីឡាករពីលើអំបោសហោះរបស់ពួកគេ?

- ហ្នឹងហើយ- ហារីនិយាយសង្កត់ពាក្យមួយៗ ដោយខំទប់ចិត្តមិនពន្យល់អំពីច្បាប់ដ៏ស្មុគស្មាញនៅក្នុងកីឡាឃ្វីដឌីច្ច។ - ពួកវាហៅថា ប្លាត់ជឺរ។ មានកីឡាករប្រយុទ្ធពីរនាក់នៅតាមក្រុមមួយៗដែលកាន់ដំបងទុកចាំវាយបាល់ប្លាត់ជឺរឲ្យទៅឆ្ងាយពីខាងពួកគេ។ ហ្វ្រេដ និង ចច វីស្លី គឺជាកីឡាករប្រយុទ្ធនៅក្រុមហ្គ្រីហ្វិនដ័រ។

- ហើយចុះបាល់ផ្សេងៗទៀតទុកធ្វើអី?- ខូលីនសួរ ដោយដើរចុះជណ្តើរម្តងពីរកាំ ដោយសារតែវារវល់តែភ្លឹកមើលហារីទាំងច្រហមាត់ឆ្លុង។

- បាល់ ឃ្វ័ព...វាជាបាល់ពណ៌ក្រហមធំជាងគេ...គឺជាបាល់សម្រាប់ស៊ុតបញ្ចូលទី។ កីឡាករប្រដេញបីនាក់នៅក្រុមម្ខាងៗគ្រវែងបាល់ ឃ្វ័ពភ័ល ទៅឲ្យគ្នាទៅវិញទៅមក ហើយព្យាយាមបញ្ចូលវាទៅបង្គោលទីនៅខាងចុងទីលាន...ពួកវាគឺជាបង្គោលវែងៗបីដើម មានវណ្ណមូលៗនៅខាងចុង។

- ហើយចុះបាល់ទីបួនវិញ...

- ...គឺជាស្នីតមាស- ហារីនិយាយកាត់ - ហើយវាពិតជាតូចណាស់ ឯល្បឿនក៏លឿន ថែមទាំងពិបាកចាប់ទៀតផង។ ប៉ុន្តែនោះហើយគឺជាតួនាទីរបស់កីឡាករដេញចាប់បាល់ ពីព្រោះថាកីឡាឃ្វីដឌីច្ចនឹងមិនត្រូវបញ្ចប់ទេ លុះត្រាតែស្នីតមាសត្រូវគេចាប់បាន។ ហើយកីឡាករដេញចាប់បាល់ក្រុមណាមួយ ចាប់បានស្នីតមាសមុនគេ នឹងទទួលបានពិន្ទុបន្ថែមមួយរយហាសិបពិន្ទុ។

- ហើយឯងគឺជាកីឡាករដេញចាប់បាល់ក្នុងក្រុមហ្គ្រីហ្វិនដ័រ មែនទេ?- ខូលីននិយាយបែបស្ញើច។

- មែនហើយ- ហារីពោលតប ខណៈពេលដែលពួកគេចាកចេញពីប្រាសាទ ហើយចាប់ផ្តើមដើរកាត់វាលស្មៅដែលទទឹកជោកជាំដោយទឹកសន្សើម។ - ហើយក៏មានអ្នកចាំទីផងដែរ។ គេមាននាទីយាមបង្គោលទី។ អស់ហើយ តែប៉ុណ្ណឹងឯង។

ប៉ុន្តែ ខូលីន មិនព្រមឈប់សួរហារីទាល់តែសោះតាមផ្លូវពេលដើរកាត់វាលស្មៅរាងទេរសំដៅទៅទីលានប្រកួតកីឡាឃ្វីដឌីច្ច ហើយហារីទើបតែអាចរំដោះខ្លួនចេញពីវាបាននៅពេលដែលវាដើរទៅដល់បន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់។ ខូលីនបានស្រែកហៅវាពីក្រោយដោយសំឡេងយ៉ាងគ្រលួចថា៖

- ខ្ញុំនឹងទៅរកមើលកន្លែងអង្គុយឲ្យស្រួលបួលមួយណា៎ ហារី!

ថារួចក៏ប្រញាប់ចុះទៅរកជើងម៉ាអង្គុយ។

កីឡាករផ្សេងៗទៀតនៅក្នុងក្រុមហ្គ្រីហ្វិនដ័រស្ថិតនៅក្នុងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់រួចទៅហើយ។ មានតែ ដំបង ម្នាក់គត់ដែលមើលទៅហាក់ស្វាងទាំងស្រុងតែម្តង។ ហ្វ្រេដ និង ចច វីស្លី កំពុងតែអង្គុយ ភ្នែកឡើងហើម ឯសក់ញក់ញីឡើងរញ៉េរញ៉ៃ នៅជិតអាលីស្យា ស្ពីនណេត ដែលហាក់ដូចជាកំពុងតែលង់លក់ដោយផ្អែកខ្លួនទៅនឹងជញ្ជាំងពីក្រោយនាង។ កីឡាករប្រដេញដែលត្រូវជាភឿនរបស់នាង ឈ្មោះ ឃែតធី បេល និង អេនជីលីណា ចនសុន កំពុងតែអង្គុយជិតគ្នាស្ងាបមួបៗ។

- មកហើយតើ ហារី! ហេតុអីក៏យូរម្ល៉េះ?- ដំបងស្រដីយ៉ាងរហ័ស។ - ឥឡូវ ខ្ញុំចង់និយាយជាមួយពួកឯងមួយភ្លែត មុននឹងពួកយើងត្រូវចេញទៅទីលាន ពីព្រោះខ្ញុំបានចំនាយពេលវិស្សមកាលរដូវក្តៅឆ្នាំមុនដើម្បីតែរកនឹកបង្កើតកម្មវិធីហ្វឹកហាត់ថ្មី ដែលខ្ញុំពិតជាគិតថានឹងធ្វើឲ្យមានភាពខុសគ្នាដាច់ស្រឡះតែម្តង...

# ឈាមកន្លះ និងពាក្យខ្សឹបខ្សៀវ

ដំបង កំពុងតែលើកកាន់ដ្យាក្រាមដ៏ធំមួយបង្ហាញរូបទីលានប្រកួតកីឡាឃ្វីដឌីច្ឆ ដែលមានគូសវាសបន្ទាត់ជាច្រើន ថែមទាំងមានសញ្ញាព្រួញ និងសញ្ញាខ្វែងដោយប្រើពណ៌ផ្សេងៗគ្នា។ វាបានយកចង្កឹះវេទមន្តរបស់វាចេញមក រួចគោះនឹងបន្ទះក្តារនោះបន្តិច ហើយសញ្ញាព្រួញក៏ចាប់ផ្តើមបំរះខ្ញីកៗនៅពីលើដ្យាក្រាមដូចជាដង្កូវមេអំបៅ។ ខណៈពេលដែល ដំបង ចាប់ផ្តើមថ្លែងសុន្ទរកថាអំពីយុទ្ធសាស្ត្រប្រយុទ្ធថ្មីរបស់វា ស្រាប់តែក្បាលរបស់ ហ្វ្រេដ វីស្លី ធ្លាក់ខ្ពកចំពីលើស្មារបស់ អាលីស្យា ស្ពីនណេត ហើយវាចាប់ផ្តើមស្រមុកខុរៗ។

បន្ទះក្តារទីមួយចំនាយពេលជិតម្ភៃនាទីទំរាំតែពន្យល់ចប់ ប៉ុន្តែនៅមានបន្ទះក្តារនៅពីក្រោមនោះមួយទៀត ថែមទាំងមានអាទីបីពីក្រោមទៀតផង។ ហេរីចាប់ផ្តើមកាន់តែស្រឡាំងកាំង ខណៈដែល ដំបង បន្លឺសូរហ៊ឹមៗហូតទៅ។

- ដូច្នេះ- ដំបងនិយាយពេលពន្យល់ចប់ ធ្វើឲ្យហេរីកន្ត្រាក់អារម្មណ៍ចេញពីគំនិតរវើរវាយយ៉ាងលន្លង់លន្លោចថា តើពេលហ្នឹងវានឹងបានញុំាអ្វីជាអាហារពេលព្រឹកទៅនៅឯប្រាសាទនោះ។ - តើច្បាស់លាស់ទេ ប៉ុណ្ណឹង? មានសំនួរអ្វីចង់សួរទេ?

- ដំបង ខ្ញុំមានសំនួរមួយចង់សួរ- ចចបន្លឺឡើង ដែលទើបតែរាងស្វាងបន្តិច។ - ហេតុអ្វីបានជាឯងមិនព្រមប្រាប់ពួកយើងទាំងអស់គ្នាឲ្យហើយកាលពីម្សិលមិញទៅ នៅពេលដែលពួកយើងមិនទាន់ទៅដេកនោះ?

ដំបងមិនសូវជាសប្បាយចិត្តប៉ុន្មានឡើយ។

- ឥឡូវ ចាំស្តាប់ណ៎ា អ្នកទាំងអស់គ្នា- វានិយាយ ដោយសម្លឹងមើលទាំងចងចិញ្ចើមដាក់ពួកគេទាំងអស់គ្នា។ - ពួកយើងគួរតែបានឈ្នះពានរង្វាន់ឃ្វីដឌីច្ឆតាំងពីឆ្នាំមុនម៉្លេះ។ ពួកយើងគឺជាក្រុមដ៏ល្អបំផុត។ ប៉ុន្តែជាអកុសល...ដោយបានពើបប្រទះនឹងស្ថានការណ៍ដែលពួកយើងមិនអាចគ្រប់គ្រងបាន...

ហេរីផ្លាស់ប្តូរកន្លែងអង្គុយរបស់វាទាំងអាម៉ាស់មុខនឹងកំហុសខ្លួន។ វាបានសន្លប់បាត់ស្មារតីនៅក្នុងគិលានដ្ឋានកំឡុងពេលការប្រកួតចុងក្រោយនៅឆ្នាំមុន ដែលមានន័យថា ក្រុមហ្គ្រីហ្វិនដ័រខ្វះកីឡាករម្នាក់ ហើយក៏ទទួលនូវបរាជ័យដ៏សែនឈឺចាប់បំផុតនៅពេលបីរយឆ្នាំនេះ។

ដំបង ចំនាយពេលមួយស្របក់ទំរាំនឹងរៀបឥរិយាបថមកធម្មតាវិញ។ ជាក់ស្តែងណាស់ ការបរាជ័យលើកចុងក្រោយរបស់ពួកគេនៅតែដាក់ទណ្ឌកម្មចំពោះវានៅឡើយនោះទេ។

- អញ្ចឹងក្នុងឆ្នាំនេះ ពួកយើងនឹងហ្វឹកហ្វាត់ឲ្យកាន់តែខ្លាំងក្លាជាងឆ្នាំមុនៗទៅទៀត...យល់ព្រម តោះទៅអនុវត្តទ្រឹស្តីបទថ្មីៗរបស់ពួកយើង!- ដំបងស្រែក ដោយចាប់កាន់អំបោសហោះរបស់វា ហើយនាំផ្លូវចេញពីបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់កីឡា។ ដោយជើងស្ពឹកស្រពន់ និងនៅតែស្វាបមាត់ម្ហូបៗនៅឡើយ ក្រុមរបស់វាក៏ដើរតាមពីក្រោយ។

ពួកគេនៅក្នុងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់កីឡាអស់យូរណាស់ រហូតដល់ព្រះអាទិត្យរះចាំងថ្ងៃទៅហើយ ទោះជាមាននៅសល់ទឹកសន្សើមសាចពេញវាលស្មៅក្នុងកីឡាដ្ឋានក៏ដោយ។ ខណៈពេលដែលហេរីដើរទៅកាន់វាលប្រកួត វាក៏ឃើញ រ៉ុន និង ហឺម៉ាយអូនីកំពុងតែអង្គុយលើជើងម៉ា។

- ឯងមិនទាន់ហាត់ចប់ទេរឺ?- រ៉ុនស្រែកហោះទាំងងឿងឆ្ងល់។

- មិនទាន់ទាំងចាប់ផ្តើមផង- ហេរីពោលតប ដោយសម្លឹងមើលយ៉ាងច្រណែនទៅនំប៉័ង និងដំណាប់ផ្លែឈើដែល រ៉ុន និង ហឺម៉ាយអូនីយកចេញពីមហាសាល។ - ដំបងរវល់តែបង្រៀនពួកយើងអំពីយុទ្ធសាស្ត្រថ្មីៗ។

## ឈាមកខ្វក់ និងពាក្យខ្សឹបខ្សៀវ

វាចាប់ឡើងលើដងអំបោសហោះ រួចធាក់ដីបង្ហោះខ្លួនឡើងទៅក្នុងអាកាស។ ខ្យល់អាកាសត្រជាក់ពេលព្រឹកបក់ផាត់ផើយកាត់មុខរបស់វា ដែលដាស់វាឲ្យស្វាងយ៉ាងមានប្រសិទ្ធិភាពជាជាងការថ្លែងសុន្ទរកថាដ៏វែងរបស់ ដំបង ទៅទៀត។ ពិតជាមានអារម្មណ៍ថាអស្ចារ្យណាស់ដែលបានត្រលប់មកលើទីលានប្រកួតកីឡាឃ្វីដឌីចម្តងទៀត។ វាហោះជុំវិញកីឡាដ្ឋានដោយបង្កើនល្បឿនពេញៗតែម្តង ដើម្បីប្រណាំងជាមួយ ហ្វ្រេដ និង ចច។

- តើសំឡេងក្រិកៗចុះឡើងនោះមកពីណា?- ហ្វ្រេដ ស្រែកពំរងឡើងខណៈដែលពួកគេបោះពួយជុំវិញគែមកីឡាដ្ឋាន។ ហេរីសម្លឹងមើលទៅជើងម៉ាអង្គុយ។ ខូលីនកំពុងតែអង្គុយពីលើជើងម៉ាខ្ពស់បំផុត ឯកាមេរ៉ារបស់វាលើកឡើង ថតរូបជាបន្តបន្ទាប់បន្លឺសូរសំឡេងកាន់តែខ្លាំងឡើងៗយ៉ាងចម្លែកនៅក្នុងកីឡាដ្ឋានដែលគ្មានមនុស្ស។

- មើលនុះ! ហេរី! ទីនេះ!- វាស្រែកឡើងយ៉ាងស្រួយ។

- តើនោះជានរណា?- ហ្វ្រេដស្រដី។

- មិនដឹងដែរ- ហេរីកុហក ដោយកាន់តែបន្ថែមល្បឿនចេញឲ្យឆ្ងាយពីខូលីនតាមដែលអាចធ្វើទៅបាន។

- តើមានរឿងអ្វីកើតឡើង?- ដំបងឧទានឡើង ទាំងចងចិញ្ចើម ខណៈដែលវាបោះពួយកាត់អាកាសសំដៅមករកពួកគេ។ - ហេតុអ្វីបានជាសិស្សឆ្នាំទីមួយម្នាក់នោះចេះតែថតរូបអញ្ចឹង? ខ្ញុំមិនចូលចិត្តទេ។ វាអាចជាចារជនរបស់ក្រុមស្លីតឺរីន ដែលចង់ដឹងអំពីកម្មវិធីហ្វឹកហាត់ថ្មីរបស់ពួកយើងទេដឹង?

- វានៅក្នុងក្រុមហ្គ្រីហ្វីនដ័រទេតើ- ហេរីតបវិញយ៉ាងញាប់មាត់។

- ហើយក្រុមស្លីតឺរីនមិនត្រូវការចារជននោះទេ ដំបង- ចចនិយាយ។

- តើឯងមានអ្វីអះអាងបានជានិយាយដូច្នោះ?- ដំបងសួរវិញបែបម៉ូម៉ៅ។

- ព្រោះអី ពួកគេលើកទ័ពមកជួបដោយផ្ទាល់តែម្តង - ចចស្រដី ថែមទាំងលើកដៃចង្អុលផង។

មានមនុស្សពាក់អាវរ៉ូបពណ៌បៃតងជាច្រើនកំពុងតែចេញមកវាលប្រកួត ព្រមទាំងមានកាន់អំបោសក្នុងដៃផង។

- ខ្ញុំមិនជឿទេ!- ដំបងនិយាយទាំងមិនពេញចិត្តដោយក្រោធខឹង។ - ខ្ញុំបានកក់ទីលាននេះមុនហើយ! ច្បាស់ជាដឹងដៃគ្នាមិនខាននោះទេ!

ដំបងបោះពួយត្រង់សំដៅទៅដី រួចទម្លាក់ខ្លួនចុះពេញមួយទំហឹងទៅតាមកំហឹងរបស់វា ថែមទាំងទ្រេតទ្រោតខ្លួនបន្តិចផងខណៈដែលវាចុះពីលើអំបោស។ ហេរី ហ្វ្រេដ និង ចច ទៅតាមពីក្រោយ។

- ហ្វ្លីនត៍!- ដំបងស្រែកដាក់មេក្រុមស្លីតឺរីន។ - នេះជាពេលហាត់សមរបស់ពួកយើង! ពួកយើងទទួលបានការអនុញ្ញាតជាពិសេសណា៎! យកល្អ ឯងគួរតែចេញទៅ!

ម៉ាកកើស ហ្វ្លីនត៍ គ្រាន់តែមាឌ ធំជាងដំបងបាត់ទៅហើយ។ វាមានមុខមាត់ដូចជាប្រេត ពេលដែលវាឆ្លើយតបថាៈ

- ដំបង នៅទីនេះមានកន្លែងទំនេរច្រើនណាស់សម្រាប់ពួកយើងទាំងអស់គ្នា។

អេនជីលីណា អាលីស្យា និង ឃែតធីក៏បានចុះមកដើរ។ គ្មានមនុស្សស្រីនៅក្រុមស្លីតឺរីននោះទេ។ ពួកប្រុសៗឈរផ្អែកស្មាគ្នាទៅវិញទៅមក ទល់មុខនឹងក្រុមហ្គ្រីហ្វីនដ័រ ដោយមៀងមើលទៅបុរសម្នាក់។

- ប៉ុន្តែខ្ញុំបានកក់ទីលាននេះមុនហើយ!- ដំបងឧទានឡើង ឥឡូវកំពុងតែឆាបឆ្កួលដោយកំហឹងឆាលរាលពេញខ្លួនតែម្តង។ - ខ្ញុំកក់វាទុកមុនហើយ!

- អា!- ហ្វ្លីនត៍ស្រដីតប។ - ប៉ុន្តែខ្ញុំមានលិខិតដែលបានចុះហត្ថលេខាជាពិសេសពីលោកសាស្ត្រាចារ្យស្នេព។ "ខ្ញុំសាស្ត្រាចារ្យស្នេព សូមផ្តល់ឲ្យក្រុមស្លីតឺរីននូវការអនុញ្ញាតដើម្បីហ្វឹកហាត់នាថ្ងៃនេះ លើទីលានប្រកួតកីឡាឃ្វីដឌីច្ឆ ដោយហេតុត្រូវការបង្វឹកកីឡាករដេញចាប់បាល់ថ្មីរបស់ពួកគេ។"

- ឯងមានកីឡាករដេញចាប់បាល់ថ្មីរឺ?- ដំបងនិយាយទាំងស្មារតីមិនមូល។ - នៅឯណា?

ហើយពីក្រោយមនុស្សមាឌធំៗទាំងប្រាំមួយនាក់នោះ បានប្រាកដឡើងនូវក្មេងប្រុសមាឌតូចទីប្រាំពីរម្នាក់ ដែលកំពុងតែញញឹមចំអកពេញផ្ទៃមុខស្លេកស្លាំងដ៏ស្រួចជ្រលេមរបស់វា។ វាគឺ ដ្រាកូ មេលហ្វ័យ។

- តើឯងរឺជាកូនប្រុសរបស់ លូសៀស មេលហ្វ័យនោះ?- ហ្វ្រេដសួរ ដោយសម្លឹងមើលមេលហ្វ័យទាំងទោមនស្ស។

- ពិតជាគួរឲ្យចង់សើចមែន ដែលឯងនិយាយពីឪពុករបស់ដ្រាកូនោះ- ហ្វ្លីនត៍ ពោលតបខណៈក្រុមស្លីតឺរីនទាំងមូលនៅតែញញឹមពព្រាយ។ - ចាំមើលណ៎ា យើងនឹងបង្ហាញពួកឯងអំពីអំណោយដ៏សប្បុរសដែលវាបានផ្តល់ដល់ក្រុមស្លីតឺរីនយើង។

ថារួច ពួកគេទាំងប្រាំពីរនាក់លើកអំបោសខ្លួនឡើង។ គឺជាអំបោសទាំងប្រាំពីរដែលត្រូវបានដុសខាត់យ៉ាងស្អាត មានដងកាន់ម៉ាកថ្មីៗ ថែមទាំងអក្សរពណ៌មាសចែងចាំងពាក្យថា នីមប៊ូស ២០០១ បញ្ចេញពន្លឺភ្លឺចិញ្ចាចពីក្រោមច្រមុះរបស់ក្រុមហ្គ្រីហ្វីនដ័រទាំងព្រឹកព្រលឹម។

- គឺជាម៉ាកចុងក្រោយបង្អស់។ ទើបតែចេញលក់កាលពីខែមុនទេ- ហ្វ្លីនត៍ស្រដីទាំងធ្វេសប្រហែស ដោយផ្ទាត់ធូលីមួយគ្រាប់ចេញពីចុងអំបោសរបស់វា។ - ខ្ញុំជឿថា វាច្បាស់ជាឈ្នះដាច់អាស៊េរី នីមប៊ូស ២០០០ មុនរាប់រយដងឯណោះ។ ហើយចំនែកអាស៊េរី ឃ្លីនស្វីព កញ្ចាស់ៗវិញ- វាសើចញឹមៗដាក់ហ្វ្រេដ និង ចច ដែលទាំងពីរនាក់សុទ្ធតែកាន់អំបោស ឃ្លីនស្វីព ជំនាន់ទីប្រាំ - បើជិះពួកវាច្បាស់ជារបើកក្តារអស់មិនខាន។

គ្មានពួកក្រុមហ្គ្រីហ្វីនដ័រណាម្នាក់រកនឹកឃើញថាត្រូវនិយាយអ្វីតបវិញទេ។ មេលហ្វ័យវិញ កំពុងតែញញឹមចំអកដាក់យ៉ាងពព្រាយរហូតដល់ភ្នែកសស្លាំងរបស់វាត្រូវរួញតូចនៅសល់តែស្នាមកាត់តូចៗពីរ។

- អូ! មើលនុះ- ហ្វ្លីនត៍ស្រដី។ - អាពួកមកឈ្លានពានទីលានប្រកួតទេតើ។

រ៉ុន និងហឺម៉ាយអូនីកំពុងតែដើរកាត់វាលស្មៅដើម្បីមកមើលថាតើមានរឿងអ្វីកើតឡើង។

- តើមានរឿងអ្វីកើតឡើង?- រ៉ុនសួរហេរី។ - ហេតុអ្វីបានជាឯងមិនហាត់ទៅ? ហើយចុះ គេមកធ្វើអ្វីនៅទីនេះដែរ?

វាកំពុងតែសម្លឹងមកមេលហ្វ័យ ដែលពាក់រ៉ូបកីឡាឃ្វីដឌីច្ឆក្រុមស្លីតឺរីន។

- ខ្ញុំគឺជាកីឡាររដេញចាប់បាល់ថ្មីរបស់ក្រុមស្លីតឺរីនណ៎ា វីស្លី- មេលហ្វ័យស្រដីបែបឡឺត។- អ្នករាល់គ្នាកំពុងតែកោតសរសើរអំបោសដែលឪពុករបស់ខ្ញុំបានទិញឲ្យក្រុមរបស់ពួកយើង។

រ៉ុនច្រហមាត់ឆ្លុងសម្លឹងមើលអំបោសហោះដ៏ល្អវិសេសទាំងប្រាំពីរនៅពីមុខវា។

- ល្អណាស់ មែនទេ?- មេលហ្វ័យនិយាយយ៉ាងប្រសប់។ - ប៉ុន្តែប្រហែលជាក្រុមហ្គ្រីហ្វីនដ័រមានលទ្ធភាពនឹងរើអង្កៀសមាសមួយចំនួនដើម្បីទិញអំបោសថ្មីដែរហើយ។ អំបោសឃ្លីនស្វីពជំនាន់ប្រាំនោះ គ្រាន់តែគេចាប់ឆ្នោត ក៏បានទៅហើយ។ ខ្ញុំរំពឹងទុកថា សារមន្ទីរនឹងត្រូវការដេញថ្លៃទិញអំបោសអស់ហ្នឹងយកទៅតាំងហើយ។

ក្រុមស្លីតឺរីននាំគ្នាសើចគឹល។

- យ៉ាងហោចណាស់ក៏គ្មាននរណាម្នាក់ចូលក្នុងក្រុមហ្គ្រីហ្វីនដ័រតាមផ្លូវទឹកប្រាក់នោះដែរ- ហឺម៉ាយអូនីបន្លឺឡើងយ៉ាងគ្រលួច។ - ពួកគេសុទ្ធតែចូលក្រុមដោយប្រើទេពកោសល្យពិតៗ។

ភាពក្អេងក្អាងនៅលើទឹកមុខរបស់មេលហ្វ័យចាប់ផ្ដើមរង្គោះរង្គើ។

- គ្មាននរណាសួរឯងនោះទេ នាងម៉ាត់ប្លាត់កខ្វក់មាឌល្អិតអើយ- វាស្ដីឲ្យឡើងញាប់មាត់ដោយខឹងសម្បារ។

ហេរីដឹងភ្លាមថា មេលហ្វ័យច្បាស់ជាបាននិយាយពាក្យអ្វីមួយមិនសមគួរហើយ ដោយសារតែមានសូរសព្ទទ្រហឹងអឹងកងភ្លាមៗបន្លឺឡើងនៅពេលដែលវានិយាយចប់។ ហ្វ្លីនត៍ត្រូវបោះពួយទៅពីមុខមេលហ្វ័យដើម្បីឃាត់កុំឲ្យ ហ្វ្រេដ និង ចច ហក់មករកវា ឯអាលីស្យា ស្រែកឡើងថាៈ

- ឯងហ៊ានម្ល៉េះ!

ចំនែករ៉ុនវិញ លូកដៃចូលទៅក្នុងអាវរ៉ូបរបស់វា រួចទាញចង្កឹះវេទមន្តរបស់វាឡើង ព្រមទាំងស្រែកថាៈ

- ឯងច្បាស់ជាទទួលសំណងវិញចំពោះពាក្យសម្ដីរបស់ឯង មេលហ្វ័យ!

ថារួច វាក៏ចង្អុលចង្កឹះវេទមន្តរបស់វាយ៉ាងខឹងក្រេវក្រោធពីក្រោមដៃរបស់ហ្វ្លីនត៍ សំដៅទៅមុខរបស់មេលហ្វ័យ។

មានសូរផ្ទុះមួយយ៉ាងខ្លាំងបន្លឺឡើងទ្រហឹងអឹងកងនៅជុំវិញកីឡាដ្ឋាន ហើយមានពន្លឺភ្លើងពណ៌បៃតងបាញ់ចេញពីដើមចង្កឹះរបស់រ៉ុន រត់ទៅប៉ះត្រូវវាត្រង់ពោះ និងបំប៉ោងវាទាំងទទ្រេតទទ្រោតខ្ទាតទៅលើវាលស្មៅ។

- រ៉ុន! រ៉ុន! តើឯងមិនអីទេរឺ?- ហឺម៉ាយអូនីស្រែកសួរ។

រ៉ុនបង្ហើបមាត់របស់វារកនិយាយ ប៉ុន្តែនិយាយមិនចេញ។ ផ្ទុយទៅវិញ វាស្រាប់តែព្រួសចេញខ្យងជាច្រើនទៅលើភ្លៅរបស់វា។

ក្រុមស្លីធើរីនត្រូវសើចឡើងរឹងពោះ។ ហ្វ្លីនត៍សើចលើសហ្នឹងទៅទៀត ធ្វើឲ្យវាត្រូវទប់នឹងដងអំបោសថ្មីរបស់វាកុំឲ្យដួល។ ឯមេលហ្វ័យត្រូវក្រាបខ្ពកលើដី ដោយយកកណ្ដាប់ដៃរបស់វាដំទៅនឹងដីផូងៗ។ ក្រុមហ្គ្រីហ្វីនដ័របានប្រមូលផ្ដុំគ្នាជុំវិញរ៉ុន ដែលចេះតែក្អួតចេញខ្យងភ្លឺផ្លេកធំៗ។ គ្មាននរណាហាក់ជាចង់ទៅប៉ះវាឡើយ។

- យកល្អ ពួកយើងគួរតែនាំវាទៅឲ្យហាហ្គ្រីដមើលទៅ ព្រោះនៅជិតជាងគេ- ហេរីនិយាយទៅកាន់ហឺម៉ាយអូនី ដែលងក់ក្បាលយល់ព្រមយ៉ាងក្លៀវក្លា ហើយពួកគេទាំងពីរក៏ចាប់ទាញដៃរ៉ុនឡើងមក។

- តើមានរឿអ្វីកើតឡើង ហេរី? តើមានរឿងអី? តើគេឈឺមែនទេ? ប៉ុន្តែឯងអាចព្យាបាលគេបាន មិនថាអ៊ីចឹងរឺ?- ខូលីនបានរត់ចុះពីលើជើងម៉ារបស់វា ហើយឥឡូវកំពុងតែរត់ឆ្វេលចុះឡើងជុំវិញពួកគេ ពេលដែលពួកគេចេញពីទីលាន។ រ៉ុនក្អួតកាន់តែខ្លាំង ហើយមានខ្យងកាន់តែច្រើនឡើងៗហូរហៀរទៅលើដីខាងមុខវា។

- អ៊ូ...- ខូលីនស្រដី ដោយចាប់អារម្មណ៍ និងកំពុងតែលើកម៉ាស៊ីនថតវាឡើង។ - តើឯងអាចទប់គេឲ្យនឹងបន្តិចបានទេ ហេរី?

- ចេញឲ្យឆ្ងាយមើល៍ ខូលីន!- ហេរីឧទានឡើងទាំងខឹង។ វា និងហឺម៉ាយអូនីគ្រាហ៍រ៉ុនចេញពីកីឡាដ្ឋាន ហើយដើរសំដៅទៅកាន់គែមព្រៃ។

- ជិតទៅដល់ហើយ រ៉ុន- ហឺម៉ាយអូនីបញ្ជាក់ ខណៈដែលផ្ទះរបស់ឆ្មាំប្រមាញ់ប្រាកដឡើងមកចំពោះមុខ។ - បន្តិចទៀត ឯងនឹងមានអាការធម្មតាវិញហើយ...ជិតដល់ហើយ...

ពួកគេនៅប្រហែលជាម៉្ភៃហ្វីតពីផ្ទះរបស់ហាហ្រ្គីដ នៅពេលដែលទ្វារមុខផ្ទះរបើកឡើង ប៉ុន្តែមិនមែនជាហាហ្រ្គីដទេដែលចេញមកនោះ។ គឺលោកហ្គីលដឺរ៉យ ឡក់ហាតទេតើ ដែលបោះជំហានវែងៗចេញមកក្រៅ នៅថ្ងៃនេះ គាត់ស្លៀកអាវរ៉ូបពណ៌ផ្កាត្របែកព្រៃរាងស្រលែត ។

- លឿនឡើង មកពួនពីក្រោយនេះមក់- ហេរីនិយាយតិចៗ ដោយចាប់ទាញរ៉ុនទៅពីក្រោយគុម្ពោតជិតនោះ។ ហឺម៉ាយអូនីទៅតាម ប៉ុន្តែហាក់ដូចជារាងស្ទាក់ស្ទើរ។

- វាជាបញ្ហាសាមញ្ញនោះទេប្រសិនបើលោកដឹងថាលោកកំពុងតែធ្វើអ្វីនោះ!- ឡក់ហាតឧទានឡើងខ្លាំងៗដាក់ហាហ្រ្គីដ។ -ប្រសិនបើលោកត្រូវការជំនួយ លោកដឹងថា ខ្ញុំនៅកន្លែងណាហើយ! ខ្ញុំ នឹងឲ្យច្បាប់ចម្លងសៀវភៅរបស់ខ្ញុំទៅលោក។ ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ដែលលោកមិនទាន់មានមួយក្បាលនោះ ... ខ្ញុំនឹងចុះហត្ថលេខារបស់ខ្ញុំអោយនៅយប់នេះ រួចនឹងបញ្ជូនមកឲ្យលោក។ អញ្ចឹង លាសិនហើយ!- បន្ទាប់មក គាត់ក៏បោះជំហានចេញឆ្ពោយសំដៅទៅប្រាសាទ។

ហេរីរង់ចាំរហូតដល់លោក ឡក់ហាត ចេញផុតពីក្រសែភ្នែក បន្ទាប់មក ក៏ទាញរ៉ុនចេញពីគុម្ពោត និងដើរឡើងទៅកាន់ទ្វារមុខផ្ទះហាហ្រ្គីដ។ ពួកគេគោះទ្វារជាបន្ទាន់។

ហាហ្រ្គីដបង្ហាញខ្លួនឡើងភ្លាមតែម្តង មើលទៅរាងម៉ូម៉ៅក្តៅក្រហាយ ប៉ុន្តែទឹកមុខរបស់គាត់ស្រស់ស្រាយឡើងវិញនៅពេលដែលឃើញថានរណាគេមកគោះទ្វារ។

- ចេះតែឆ្ងល់ថា មិនដឹងជាឯងមកលេងខ្ញុំវីក៏អត់...ចូលមក ចូលក្នុងមក...ស្មានថាជាលោកសាស្រ្តាចារ្យ ឡក់ហាតត្រលប់មកវិញម្តងទៀតហើយ...

ហេរី និងហឺម៉ាយអូនីនៅឈរទប់រ៉ុនពីលើផ្លូវចូលទៅក្នុងផ្ទះមានបន្ទប់តែមួយនោះ ដែលមានគ្រែដ៏ធំមហិមាមួយនៅជ្រុងម្ខាង ឯភ្លើងកំពុងតែបន្លឺសូរផ្ទុះប្រែសៗយ៉ាងសប្បាយរីករាយនៅជ្រុងម្ខាងទៀត។ មើលទៅ ហាហ្រ្គីដមិនសូវជាខ្វល់ចិត្តអំពីបញ្ហាខ្យងរបស់រ៉ុនប៉ុន្មានទេ ដែលហេរីបានពន្យល់រ៉ាយរាប់ប្រាប់យ៉ាងរហ័ស ខណៈពេលដែលវាបន្ទាបរ៉ុនចុះអង្គុយលើកៅអីមួយ។

- យកល្អ គួរតែយកចេញក្រៅប្រសើរជាងទុកនៅក្នុង- គាត់និយាយលួងលោម ដោយទម្លាក់ផុងទឹកធ្វើពីស្ពាន់ដ៏ធំមួយព្ឋសូរព្រួសទៅលើដីពីមុខគាត់។ - ក្អួតចេញឲ្យអស់មក រ៉ុន។

- ខ្ញុំមិនគិតថា មានវិធីអ្វីក្រៅពីរង់ចាំរហូតដល់វាបញ្ឈប់ដោយខ្លួនឯងនោះទេ- ហឺម៉ាយអូនីនិយាយទាំងអន្ទះអន្ទែង ដោយសម្លឹងមើលរ៉ុនកំពុងតែទម្រេតខ្លួនពីលើផុងទឹក។ - វាពិតជាបាលីបណ្តាសាដ៏ខ្លាំងមួយ ដែលគួរតែប្រើនៅពេលនោះណាស់ ប៉ុន្តែបើប្រើជាមួយចង្កឹះបាក់វិញនោះ...

ហាហ្រ្គីដកំពុងតែជាប់រវល់ឆុងតែឲ្យពួកគេ។ ឆ្កែរបស់គាត់ គឺអាចង្កូម កំពុងតែហៀរទឹកមាត់កខ្វាក់ពីលើខ្លួនហេរី។

- តើលោក ឡក់ហាត ចង់បានអ្វីពីលោកទៅ ហាហ្រ្គីដ?- ហេរីចោទជាសំនួរ ដោយអេះត្រចៀកអាចង្កូមបណ្តើរ។

- គឺផ្តល់ដំបូន្មានឲ្យខ្ញុំទៅយកខ្មោចទឹកចេញពីអណ្តូងហ្នឹងណា- ហាហ្រ្គីដនិយាយបែបសំឡុត ដោយយកមាន់ឈ្មោលបោចរោមអស់ពាក់កណ្តាលចេញពីតុដែលគាត់បានដុសលាង រួចដាក់ប៉ាន់តែចុះ។ - ធ្វើដូចខ្ញុំមិនដឹងខ្យល់អីអញ្ចឹង។ ហើយក៏ចាប់ផ្តើមអួតក្អេងក្អាងអំពីខ្មោច ប៊ែនស្ទី ប៉ុន្មានក្បាលដែលគាត់បានបណ្តេញចេញ។ ប្រសិនបើពាក្យមួយម៉ាត់ណាជាការពិតមែននោះ ខ្ញុំនឹងទំពាកំសៀវរបស់ខ្ញុំឲ្យមើល។

វាពិតជាមិនទំនងទាល់តែសោះដែលថា ហាហ្គ្រីដរិះគន់អំពីគ្រូបង្រៀនសាលាហុកវ៉ាតនោះ ហើយហេរីសម្លឹងមើលគាត់ទាំងភ្ញាក់ផ្អើល។ ទោះជាយ៉ាងណាក្តី ហឺម៉ាយអូនី និយាយដោយសំឡេងបែបខ្លាំងជាងធម្មតា៖

- ខ្ញុំគិតថា លោកកំពុងតែលំអៀងបន្តិចហើយ។ លោកសាស្រ្តាចារ្យ ដាំប៊ែលដ័រ ពិតជាគិតថា គាត់គឺជាមនុស្សល្អបំផុតសម្រាប់ឲ្យធ្វើការងារនេះ...

- គាត់គឺជាមនុស្សតែម្នាក់គាត់ដែលទទួលយកការងារនេះ- ហាហ្គ្រីដស្រដី ថែមទាំងហុចស្ករក្រាមរង្វង់ឲ្យគេមួយចានពេញ ខណៈពេលដែលរ៉ុនក្អកឡើងនិយាយលែងចេញ បែរមុខទៅធុងទឹករបស់វា។ - ខ្ញុំចង់និយាយថា រកបានតែគាត់ម្នាក់ហ្នឹងទេ។ ពិតជាលំបាកខ្លាំងណាស់ក្នុងការរកនរណាម្នាក់ឲ្យបង្រៀនមុខវិជ្ជាផ្នែក មន្តអាគមងងឹត នោះ។ ពួកគេដូចជាខ្លាចអរាមិនចង់ទទួលយកការងារនេះសោះ ដូចដែលឯងឃើញស្រាប់ហើយ។ ពួកគេចាប់ផ្តើមមានគំនិតរវើរវាយថាតំណែងហ្នឹងត្រូវបានគេដាក់បណ្តាសា។ គ្មានគ្រូណាម្នាក់នៅបង្រៀនបានយូរនោះទេ។ អញ្ចឹងប្រាប់ខ្ញុំមក- ហាហ្គ្រីដនិយាយ ដោយងាកក្បាលឆ្ពោះទៅរករ៉ុន។ - តើវាចង់ដាក់បណ្តាសាលើអ្នកណាគេ?

- មេលហ្វ៊យបានហៅហឺម៉ាយអូនីថាអ្វីម្យ៉ាង ខ្ញុំមិនដឹងដែរ។ ប៉ុន្តែខ្ញុំដឹងថា វាច្បាស់ជាអាក្រក់ណាស់ហើយ ពីព្រោះថាអ្នករាល់គ្នាសុទ្ធតែមានប្រតិកម្មទាំងអស់។

- វាពិតជាអាក្រក់មែន- រ៉ុនបន្លឺឡើងទាំងស្អក ដោយងើបមកពោបលើតុ ទឹកមុខស្លេកស្លាំងគ្មានឈាមមួយតំនក់ ព្រមទាំងបែកញើសជោកខ្លួន។ - មេលហ្វ៊យបានហៅនាងថា "ឈាមកខ្វក់" ណា៎ ហាហ្គ្រីដ...

រ៉ុនជ្រមុជក្បាលទៅក្នុងធុងទឹកម្តងទៀត ពេលដែលខ្យងស្រស់ៗប៉ុន្មានក្បាលចាប់ផ្តើមប្រាកដឡើង។ ហាហ្គ្រីដមើលទៅដូចជាខឹងឡាំប៉ា។

- វានិយាយអញ្ចឹងមែន?!!- គាត់ស្រែកគំហកដាក់ហឺម៉ាយអូនី។

- ហ្នឹងហើយ- នាងពោលតប។ - ប៉ុន្តែខ្ញុំមិនដឹងថា វាមានន័យយ៉ាងម៉េចនោះទេ។ ខ្ញុំអាចត្រឹមតែថា វាពិតជាអសុរោះតែប៉ុណ្ណឹង...

- វាគឺជាពាក្យប្រមាថមាក់ងាយដ៏អាក្រក់បំផុតហើយ ចេះតែវានឹកឃើញកើត- រ៉ុននិយាយទាំងហត់គឃូស ពេលងើបក្បាលឡើងមកវិញ។ - ម៉ាត់ប្លាត់ គឺពិតជាឈ្មោះដ៏គំរោះគំរើយមួយ ប្រើសម្រាប់និយាយដល់នរណាម្នាក់ដែលមានដើមកំណើតពីពួកលោកិយ...ឯងដឹងទេ គឺឪពុកម្តាយដែលឥតចេះវេទមន្ត។ មានវេទគូមួយចំនួន...ដូចជាគ្រួសាររបស់មេលហ្វ៊យ...ដែលគិតថាពួកគេប្រសើរជាងអ្នកឯទៀតៗ ដោយសារតែពួកគេត្រូវមនុស្សម្នាហៅថាអ្នកមានឈាមជ័រសុទ្ធ។- វាគ្រើកបន្តិច ហើយមានខ្យងមួយក្បាលធ្លាក់ទៅលើដៃរបស់វា ដែលលាតសន្ធឹងចាំចាប់។ វាចាប់គ្រវាត់ខ្យងនោះទៅក្នុងធុងទឹក រួចបន្ត៖

- ខ្ញុំចង់បានន័យថា ពួកយើងឯទៀតដឹងហើយថា វានឹងមិនផ្លាស់ប្តូរអ្វីទាល់តែសោះ។ ជាឧទាហរណ៍ មើលនេវីលឡុងបត់ថម មើល៍...វាជាអ្នកមានឈាមជ័រសុទ្ធមែន តែគ្រាន់តែចាប់ផ្កាប់ថ្លាងឲ្យត្រង់នោះ ក៏វាមិនចេះផង...

- ហើយពួកវាក៏មិនចេះច្នៃបង្កើតបាលីអ្វីដែលហឺម៉ាយអូនីរបស់យើងមិនចេះដែរ- ហាហ្គ្រីដឧទានឡើងដោយមោទនភាពដែលធ្វើឲ្យមុខហឺម៉ាយអូនីឡើងក្រហមព្រឿងៗ។

- វាពិតជាពាក្យមិនសមគួរនឹងនិយាយទៅកាន់នរណាម្នាក់នោះទេ- រ៉ុនស្រដី ដោយយកដៃញ័រទទ្រើករបស់វាជូតញើសចេញពីថ្ងាស។ - ឈាមកខ្វក់ យល់ទេ។ គឺឈាមធម្មតា។ វាពិតជាមិនសមហេតុផលទាល់តែសោះ។ ទុកជាយ៉ាងណា ក៏មានវេទគូ

ភាគច្រើនសព្វថ្ងៃនេះជាកូនកាត់ដែរតើ។ ប្រសិនបើពួកយើងមិនបានទៅរៀបការជាមួយនឹងពួកលោកិយខ្លះណាស់ ពួកយើងច្បាស់ជាដាច់ពូជតាំងពីយូរមកហើយ។

វារកកលចង់ក្អួត ហើយក៏អោនក្បាលផុតពីក្រសែភ្នែកម្តងទៀត។

- ខ្ញុំមិនប្រកាន់ឯងជេរប្រទេចផ្តាសាវានោះទេ រ៉ុន- ហាគ្រីដនិយាយខ្លាំងៗ សន្ធប់ពីលើសំឡេងខ្យងធ្លាក់ទៅប៉ះនឹងធុងទឹកដែលឮសូរក្លុកៗ។- ប៉ុន្តែប្រហែលវាក៏ជារឿងល្អមួយដែរ ដែលចង្កឹះរបស់ឯងបាញ់បញ្ច្រាសមកវិញនោះ។ ចាំតែមើលទៅលូសៀស មេលហ្វយច្បាស់ជាធ្វើដំណើរបោក់ទឹកបាក់ដីមកកាន់សាលានេះតែម្តង ប្រសិនបើឯងដាក់បាលីបណ្តាសាលើកូនរបស់គេនោះ។ ហោចណាស់ ក៏ឯងមិនបានបង្កឿងធំដុំដែរ។

ហេរីនឹកចង់បញ្ជាក់ប្រាប់ថា គ្មានបញ្ហាណាធ្ងន់ធ្ងរជាជាងមានសត្វខ្យងហូរចេញពីមាត់នោះទេ ប៉ុន្តែវានិយាយមិនចេញទេ។ ស្ករក្រាមរង្វបានធ្វើឲ្យថ្គាមរបស់វាស្អិតជាប់គ្នាដូចបាយម៉ានអញ្ចឹង។

- ហេរី- ហាគ្រីដស្រដីយ៉ាងរួសរាន់ ហាក់ដូចជានឹកឃើញអ្វីមួយភ្លាមៗ។- មានរឿងមួយចង់និយាយជាមួយឯង។ ខ្ញុំឮដំណឹងរហៀងៗមកថា ឯងបានចែកចាយរូបថតដែលមានហត្ថលេខារបស់ឯង។ ម៉េចក៏ខ្ញុំអត់ទទួលបានមួយនឹងគេសោះអញ្ចឹង?

ដោយខឹងខ្លាំងពេក ធ្វើឲ្យធ្មេញរបស់ហេរីចាប់បែកចេញពីគ្នាតែម្តង។

- ខ្ញុំមិនបានចែកចាយរូបថតមានហត្ថលេខាខ្ញុំឯណា- វានិយាយទាំងក្តៅក្រហាយ។ - ប្រសិនបើលោក ឡក់ហាត នៅតែផ្សព្វផ្សាយរឿងនោះទៀត...

ប៉ុន្តែបន្ទាប់មក វាឃើញថាហាគ្រីដកំពុងតែអស់សំណើច។

- ខ្ញុំគ្រាន់តែនិយាយលេងទេតើ- គាត់បន្លឺឡើង ដោយទះខ្នងហេរីយ៉ាងរួសរាយ ស្ទើរតែធ្វើឲ្យវាផ្កាប់មុខទៅនឹងតុ។- ខ្ញុំក៏ដឹងដែរថាឯងមិនធ្វើរឿងដូច្នោះទេ។ ខ្ញុំបានប្រាប់ ឡក់ហាត ថាឯងមិនត្រូវការនោះទេ។ ឯងល្បីល្បាញជាងគាត់ទៅទៀតទាំងមិនបាច់ប្រឹងអ្វីបន្តិចឡើយ។

- ខ្ញុំហ៊ានភ្នាល់ថា គាត់មិនចូលចិត្តបែបនោះទេ- ហេរីពោលតប ដោយតម្រង់ខ្លួនអង្គុយឡើងវិញ ព្រមទាំងអង្អែលចង្ការបស់វា។

- ខ្ញុំក៏គិតអ៊ីចឹងដែរ- ហាគ្រីដនិយាយ ភ្នែករបស់គាត់បញ្ចេញពន្លឺព្រិចៗ។ - ហើយក្រោយមក ខ្ញុំបានប្រាប់គាត់ថា ខ្ញុំនឹងមិនអានសៀវភៅរបស់គាត់សូម្បីតែមួយក្បាល រួចគាត់ក៏សម្រេចចិត្តចាកចេញទៅ។ ញ៉ាំស្ករក្រាមរង្វទេ រ៉ុន?- គាត់បន្ថែមសម្តី ពេលដែលឃើញរ៉ុនលេចខ្លួនមកម្តងទៀត។

- ទេ អរគុណច្រើន- រ៉ុនតបយ៉ាងខ្សោយកម្លាំង។ - យកល្អកុំប្រថុយអីល្អជាង។

- មកមើលនែ៎ ថាខ្ញុំកំពុងតែដាំអ្វី- ហាគ្រីដឧទានឡើង ខណៈដែលហេរី និងហឺម៉ាយអូនីផឹកបង្ហើយតែចុងក្រោយរបស់ពួកគេ។

នៅក្នុងដីដាំបន្លែមួយក្បាលតូចខាងក្រោយផ្ទះហាគ្រីដ មានដាំដើមល្ពៅធំៗបំផុតចំនួនដប់ពីរផ្លែ ដែលហេរីមិនធ្លាប់បានប្រទះពីមុនមកសោះ។ គ្រាន់តែមួយផ្លែៗមានទំហំប៉ុននឹងផ្ទាំងថ្មមួយផ្ទាំងធំទៅហើយ។

- លូតលាស់ល្អដែរតើ មិនថាអញ្ចឹងរឺ?- ហាគ្រីដនិយាយទាំងសោមនស្ស។ - គឺទុកសម្រាប់ពិធីជប់លៀងនៅថ្ងៃបុណ្យហាឡូវីន...ទំរាំតែដល់ពេលនោះ គួរតែធំល្មមដែរហើយ។

- តើលោកដាក់អ្វីបំប៉នពួកវា?- ហេរីសួរ។

ហាហ្គ្រីដសម្លឹងមើលពីលើស្មារបស់គាត់ដើម្បីត្រួតពិនិត្យបញ្ជាក់ថា ពួកគេមានតែបួននាក់។

- ខ្ញុំដាក់...ឯងដឹងទេ...គឺ...ប្រើជំនួយបន្ថែមបន្តិចបន្តួច...

ហេរីបានកត់សម្គាល់ទៅឆ័ត្រពណ៌ផ្កាឈូកដ៏ស្រស់ឆើតឆាយរបស់ហាហ្គ្រីដ ដែលកំពុងតែដាក់ផ្អែកទល់នឹងជញ្ជាំងខាងក្រោយផ្ទះរបស់គាត់។ ហេរីមានហេតុផលនឹងជឿកាលពីមុនឥឡូវថា ឆ័ត្ររបស់គាត់មិនមែនដូចជាសំបកខាងក្រៅរបស់វានោះទេ។ តាមពិតទៅ វាមានអារម្មណ៍សង្កត់ធ្ងន់ថា ចង្កឹះវេទមន្តរបស់ហាហ្គ្រីដកាលពីនៅរៀន គឺត្រូវបានលាក់ទុកនៅក្នុងឆ័ត្រនោះ។ ហាហ្គ្រីដត្រូវបានគេហាមប្រាមមិនឲ្យប្រើប្រាស់វេទមន្តនោះទេ។ គាត់ត្រូវបានបណ្តេញចេញពីសាលាហុកវ៉ាតនៅក្នុងឆ្នាំសិក្សាទីបីរបស់គាត់ ប៉ុន្តែហេរីមិនដែលដឹងអំពីមូលហេតុឡើយ...រាល់លើក ឲ្យតែមានការបង្ហើបបន្តិចបន្តួចអំពីបញ្ហានោះ ហាហ្គ្រីដច្បាស់ជាជំរះបំពង់កពួសូរខ្លាំងៗ រួចធ្វើជាគធ្វើជាថ្លង់យ៉ាងអាថ៌កំបាំងរហូតទាល់តែផ្លាស់ប្តូរប្រធានបទទៅរឿងផ្សេងវិញ។

- ខ្ញុំគិតថា ប្រហែលជាអាគមធ្វើឲ្យវាស៊ីច្រើនហើយមើលទៅ?- ហឺម៉ាយអូនីស្រដី ពាក់កណ្តាលបែបមិនឯកភាពតាម ឯពាក់កណ្តាលបែបលលេង។ - លោកពិតជាធ្វើបានល្អមែន។

- នោះហើយគឺជាអ្វីដែលប្អូនស្រីតូចរបស់ឯងនិយាយ- ហាហ្គ្រីដបន្លឺឡើង ព្រមទាំងងក់ក្បាលទៅរ៉ុន។ - បានជួបនាងកាលពីម្សិលមិញ។- ហាហ្គ្រីដមៀងមើលទៅកាន់ហេរី ពុកចង្ការរបស់គាត់ចាក់ឈឺខ្នោកៗ។ - បាននិយាយថា នាងគ្រាន់តែដើរមើលដីលេង ប៉ុន្តែខ្ញុំដឹងថា នាងសង្ឃឹមថានឹងបានជួបនរណាម្នាក់ដោយចៃដន្យនៅឯផ្ទះរបស់ខ្ញុំ។- គាត់ព្រិចភ្នែកដាក់ហេរី។ - ប្រសិនបើឯងសួរខ្ញុំវិញណ៎ា ខ្ញុំគិតថានាងមិនប្រកែកទេចំពោះរូប...

- អូ! ឈប់និយាយទៅ- ហេរីនិយាយ។ រ៉ុនផ្ទុះសំណើច ហើយក៏ព្រួសចេញខ្យងជាច្រើនទៅលើដី។

- ប្រយ័ត្ន!- ហាហ្គ្រីដស្រែកគ្រហឹម ព្រមទាំងទាញរ៉ុនចេញឆ្ងាយពីដើមល្ពៅដ៏មានតម្លៃរបស់គាត់។

ជិតដល់ពេលទទួលទានអាហារថ្ងៃត្រង់ទៅហើយ ហើយដោយ ហេរី ទើបតែបានឆី ស្ករក្រាមរង្វ មួយម៉ាត់គត់តាំងពីព្រលឹមមក វាដូចជាចង់ត្រលប់ទៅហូបអ្វីនៅសាលាវិញណាស់។ ពួកគេនិយាយពាក្យលាគ្នាទៅកាន់ហាហ្គ្រីដ រួចដើរឡើងត្រលប់ទៅកាន់ប្រាសាទវិញ ឯរ៉ុនត្អើកម្តងម្កាលៗ ប៉ុន្តែគ្រាន់តែក្អួតចេញខ្យងតូចៗពីរតែប៉ុណ្ណោះ។

ពួកគេមិនទាន់ទាំងបានឈានជើងលើច្រកចូលផ្លូវរបៀងដ៏ត្រជាក់ផង ស្រាប់តែសម្លេងមួយពោទឹឡើង៖

- ពួកឯងនៅទីនោះទេតើ ផោតធ័រ...វីស្លី- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលកំពុងតែដើរសំដៅមករកពួកគេ មើលទៅបែបម៉ឺងម៉ាត់។ - ពួកឯងទាំងពីរនាក់នឹងត្រូវទទួលការពិន័យនាល្ងាចនេះ។

- តើពួកយើងនឹងត្រូវធ្វើអ្វីទៅ អ្នកស្រីសាស្ត្រាចារ្យ?- រ៉ុនសួរ ដោយខំប្រឹងទប់កំអួតរបស់វាទាំងភិតភ័យ។

- ឯង នឹងត្រូវទៅជូតសំអាតប្រាក់នៅក្នុងបន្ទប់ជ័យភ័ណ្ឌជាមួយនឹងលោក ហ្វីលច្ឆ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលបន្លឺឡើង។ - ហើយមិនឲ្យប្រើវេទមន្តទេ វីស្លី...គឺត្រូវប្រើក្រណាត់ជ្រលក់ប្រេង។

រ៉ុនលេបទឹកមាត់ក្អឹកៗ។ អារហ្គួស ហ្វីលច្ឆ ដែលជាឆ្មាំយាម សុទ្ធតែត្រូវសិស្សគ្រប់គ្នានៅក្នុងសាលាមិនពេញចិត្តទាំងអស់ហ្នឹង។

- ហើយឯង ផោតធ័រ នឹងត្រូវទៅជួយសាស្ត្រាចារ្យ ឡក់ហាត ឆ្លើយតបនឹងសំបុត្រអ្នកគាំទ្ររបស់គាត់- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយ។

- អូ! ទេ...អ្នកស្រីសាស្ត្រាចារ្យ តើខ្ញុំអាចទៅធ្វើការនៅបន្ទប់ជ័យភ័ណ្ឌបានទេ?- ហេរីស្រដីទាំងអស់សង្ឃឹម។

- ប្រាកដជាមិនបានទេ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលតប ដោយជ្រួញចិញ្ចើម។ - លោកសាស្ត្រាចារ្យ ឡក់ហាត បានស្នើសុំឯងជាពិសេស។ នៅម៉ោងប្រាំបី ចាំឲ្យច្បាស់ណ៎ា ពួកឯងទាំងពីរនាក់។

ហេរី និងរ៉ុនដើរចូលទៅក្នុងមហាសាលដូចអត់ព្រលឹង ដោយស្ថិតក្នុងសភាពស្រងេះស្រងោចយ៉ាងជ្រាលជ្រៅបំផុត ហើម៉ាយអូនីនៅពីក្រោយពួកគេ ដោយបង្ហាញទឹកមុខដូចចង់និយាយថា "ហ្នឹងហើយមកពីពួកឯងមិនគោរពវិន័យសាលា"។ ហេរីមិនពេញចិត្តនឹងនំផៃស្ងួលសាច់គោទាល់តែសោះ តែកាលណាគិតដល់រឿងដែលវា និងរ៉ុននឹងត្រូវប្រឈមមុខ។

- ហ្វីលច្ច ច្បាស់ជាបង្ខាំងខ្ញុំទុកក្នុងនោះមួយយប់តែម្តង- រ៉ុននិយាយដោយសង្កត់ពាក្យធ្ងន់ៗ។ - មិនអោយប្រើវេទមន្ត! ច្បាស់ជាមានជាងមួយរយពែងហើយនៅក្នុងបន្ទប់នោះ។ ខ្ញុំមិនសូវប្រសប់អាខាងការសំអាតដូចពួកលោកិយផង។

- ប្រសិនបើដូរបាន ខ្ញុំដូរបាត់ទៅហើយ- ហេរីនិយាយទាំងគ្មានខ្លឹមសារ។ - ខ្ញុំមានការអនុវត្តជាច្រើនជាមួយនឹងគ្រួសារឌើស្លី។ ការឆ្លើយតបសំបុត្រអ្នកគាំទ្ររបស់ ឡក់ហាត...គាត់គឺពិតជាសុបិន្តអាក្រក់មួយមែន...

រសៀលថ្ងៃសៅរ៍ហាក់ដូចជារសាត់ចេញឆ្ងាយ ហើយហាក់ដូចជាគ្មានពេលម៉ោង ឥឡូវម៉ោងប្រាំបីខ្វះប្រាំនាទី ហើយហេរីកំពុងតែដើរអូសជើងទាំងរួញរាតាមផ្លូវរបៀងជាន់ទីពីរសំដៅទៅកាន់ការិយាល័យរបស់លោក ឡក់ហាត។ វាខាំធ្មេញសង្កត់ចិត្ត រួចក៏គោះទ្វារ។

ទ្វាររបើកឡើងភ្លាមមួយរំពេច។ លោក ឡក់ហាត កំពុងតែញញឹមពព្រាយដាក់វា។

- ហ្អា! ជនមិនស្មោះត្រង់នៅទីនេះទេតើ!- គាត់ឧទានឡើង។ - ចូលមកក្នុងមក៍ ហេរី ចូលមក...

ដែលចែងចាំយ៉ាងភ្លឺចិញ្ចែងចិញ្ចាចនៅលើជញ្ជាំងបំភ្លឺដោយទៀនជាច្រើន គឺសុទ្ធតែជារូបថតរបស់លោក ឡក់ហាត ដាក់ក្នុងស៊ុមរាប់មិនចេះអស់។ គាត់ថែមទាំងបានចុះហត្ថលេខាលើរូបថតខ្លះទៀតផង។ មានមួយគំនរធំផ្សេងទៀតស្ថិតនៅលើតុការិយាល័យរបស់គាត់។

- ឯងដាក់អាស័យដ្ឋានលើស្រោមសំបុត្រទៅ!- ឡក់ហាតពោលប្រាប់ហេរី ហាក់ដូចវាជាការងារដ៏សប្បាយមួយអញ្ចឹង។ - សំបុត្រទីមួយត្រូវផ្ញើទៅ គ្លេឌី ហ្គាត់ជិន ជួយជូនពរដល់នាងផង...គឺជាអ្នកគាំទ្រដ៏ខ្លាំងក្លាម្នាក់របស់ខ្ញុំ...

មួយនាទីៗកន្លងទៅដូចខ្យងវារ។ សំឡេងរបស់ ឡក់ហាត ចេះតែសន្ធប់ពីលើហេរីជានិច្ច ជួនកាលនិយាយថា "អើ" រឺ "ត្រូវហើយ" ហើយពេលខ្លះទៀតនិយាយថា "ហ្នឹងហើយ"។ ម្តងម្កាល វាស្តាប់ឮឃ្លាបន្លឺឡើងដូចជាថា "កិត្តិនាមគឺជាមិត្តមិនស្មោះត្រង់ម្នាក់ណ៎ា ហេរី" រឺក៏ "ភាពល្បីល្បាញគឺជាអ្វីដែលជនល្បីល្បាញធ្វើ ឯងគួរតែចងចាំពាក្យនេះទុកទៅ។"

ទានកាន់តែបំភ្លឺទាបទៅៗ ធ្វើឲ្យពន្លឺនៅរេរាំពីលើមុខរបស់លោកឡក់ហាតមានចលនា ដែលកំពុងតែតាមសម្លឹងមើលគាត់។ ហេរីទម្លាក់ដៃ ដែលត្រូវសរសេរឡើងចុករបស់វា ទៅលើគំនរដែលហាក់មានស្រោមសំបុត្ររាប់ពាន់ ថែមទាំងត្រូវសរសេរអាស័យដ្ឋានរបស់ វ៉េរ៉ូនីកា ស្មេតលី ទៀត។ វាច្បាស់ជាជិតដល់ម៉ោងចាកចេញហើយ ហេរីសញ្ជឹងគិតទាំងវេទនា សូមឲ្យជិតដល់ម៉ោងត្រូវចេញទៅចុះ...

ហើយបន្ទាប់មក ស្រាប់តែវាឮសំឡេងអ្វីម្យ៉ាង...មិនជាសូវប្រែសៗតិចៗបន្លឺចេញពីទៀនជិតរលត់ រឺក៏សម្តីឥតបានការរបស់លោក ឡក់ហាត និយាយអំពីអ្នកគាំទ្ររបស់គាត់នោះទេ។

វាគឺជាសំឡេងមួយ ជាសម្លេងដែលធ្វើឲ្យព្រឺឆ្អឹងខ្នង ជាសម្លេងនៃដំណកដង្ហើមរបស់សត្វមានពិសដែលត្រជាក់ដូចទឹកកក។

*- មក...មករកខ្ញុំមក៍...ឲ្យខ្ញុំចាប់ច្រៀកឯងជាចម្រៀកៗមក៍...ឲ្យខ្ញុំចាប់ហែកឯងស៊ីទៅ...ឲ្យខ្ញុំសម្លាប់ឯងចោលទៅ...*

ហេរីងើបឈរឡើងភ្លែត ហើយស្នាមប្រឡាក់ពណ៌ស្វាយព្រលែតមួយលេចធ្លោឡើងនៅលើ អាស័យដ្ឋានផ្ញើរទៅផ្ទះ វេរ៉ូនីកាស្មេតលី។

- ស្អីគេហ្នឹង?- វានិយាយខ្លាំងៗ។

- ខ្ញុំដឹងហើយ!- ឡក់ហាតពោលតប។ - បានជាប់ឈ្មោះលើគេបង្អស់ ក្នុងបញ្ជីឈ្មោះសៀវភៅលក់ដាច់បំផុត ដាច់ប្រាំមួយខែត្រឹម! ពិតជាបំបែកឯតទគ្គកម្មមែន!

- ទេ- ហេរីស្រដីយ៉ាងរហ័ស។ - គឺសម្លេងនោះ!

- ឯងចង់និយាយស្អីហ្នឹង?- ឡក់ហាតសួរ មើលទៅបែបស្រឡាំងកាំង។ - តើសម្លេងអ្វីទៅ?

- គឺសម្លេងនោះ...សម្លេងដែលបាននិយាយពាក្យប៉ុន្មានម៉ាត់នោះ...តើលោកស្តាប់មិនឮទេរឺអ្វី?

ឡក់ហាតសម្លឹងមើលមកហេរីដោយភ្ញាក់ផ្អើលយ៉ាងខ្លាំង។

- តើឯងកំពុងតែនិយាយពីអ្វីហ្នឹង ហេរី? ប្រហែលជាឯងងងុយដេកហើយ។ ព្រះម្ចាស់ថ្លៃ...មើលម៉ោងទៅមើល៍! ពួកយើងនៅទីនេះអស់ជិតបួនម៉ោងមកហើយ! ខ្ញុំស្ទើរតែមិនជឿទាល់តែសោះ...ពេលវេលាដូចជាទឹកហូរអញ្ចឹង មិនថាអ៊ីចឹងរឺ?

ហេរីមិនឆ្លើយតបវិញទេ។ វាកំពុងតែផ្ទៀងត្រចៀកស្តាប់សម្លេងនោះម្តងទៀត ប៉ុន្តែគ្មានសម្លេងណាបន្លឺឡើងក្រៅពីសម្តីដែលលោក ឡក់ហាត ប្រាប់វាថា វាមិនត្រូវគិតថាវានឹងត្រូវធ្វើការអញ្ចឹងៗរាល់ពេលដែលវាត្រូវពិន័យនោះទេ។ ដោយមានអារម្មណ៍ភ័ន្តភាំង ហេរីក៏ចាកចេញទៅ។

វាយប់ណាស់ទៅហើយ ឯសហសាលក្រុមហ្គ្រីហ្វីដ័រស្ទើរតែគ្មានមនុស្សម្នាក់។ ហេរីដើរត្រង់ៗសំដៅទៅសយនដ្ឋាន។ រ៉ុនមិនទាន់ត្រលប់មកវិញទេ។ ហេរីស្លៀកខោអាវដេកយប់របស់វា ដេកលើគ្រែ ហើយរង់ចាំ។ កន្លះម៉ោងក្រោយមក រ៉ុនក៏មកដល់ដោយទប់ដៃស្តាំរបស់វាថ្នមៗ ព្រមទាំងបំភាយក្លិនទឹកថ្នាំដុសលាងពេញបន្ទប់ងងឹតសូន្យសុងនោះ។

- សាច់ដុំរបស់ខ្ញុំខ្វិនអស់ទៅហើយ- វាត្អូញត្អែរប្រាប់ ដោយទម្លាក់ខ្លួនទៅលើគ្រែ។ - អស់ដប់បួនដង ដែលគាត់បង្ខំឲ្យខ្ញុំដុសខាត់ពានរង្វាន់ឃ្វីដឌីច្ចនោះ ទំរាំតែគាត់ពេញចិត្ត។ ហើយបន្ទាប់មក ខ្ញុំក៏ក្អួតចេញខ្យងធ្លាក់ស្រោចទៅលើរង្វាន់ចំពោះសេវាកម្មល្អសំរាប់សាលា។ ត្រូវចំនាយពេលជាយូរ ទំរាំតែធ្វើឲ្យបាត់ជាតិស្អិត...ចុះយ៉ាងម៉េចដែរ នៅជាមួយឡក់ហាតនោះ?

ដោយបន្ទាបសម្លេងរបស់វាកុំឲ្យដាស់ភ្ញាក់ នេវីល ឌីន និងស៊ីម្យុស ហេរីក៏ប្រាប់រ៉ុននូវអ្វីទាំងឡាយដែលវាបានស្តាប់ឮ។

- ហើយឡក់ហាតនិយាយថាគាត់ស្តាប់មិនឮរឺ?- រ៉ុននិយាយ។ ហេរីអាចឃើញចិញ្ចើមរបស់វាឡើងជ្រួញតាមពន្លឺព្រះចន្ទ។ - តើឯងគិតថាគាត់និយាយកុហកដែររឺទេ? ប៉ុន្តែខ្ញុំមិនយល់ឡើយ...ទោះបីជានរណាម្នាក់ចេះបំបាំងកាយ ក៏ត្រូវតែបើកទ្វារនោះដើម្បីចូលមកក្នុងបានដែរ។

- ខ្ញុំដឹងហើយ- ហេរីស្រដី ដោយផ្តេកខ្លួនទៅលើគ្រែបង្គោលបួន ហើយសម្លឹងមើលមិនដាក់ភ្នែកទៅកាន់បុស្បុកនៅពីលើវា។ - ខ្ញុំក៏មិនយល់អំពីវាដូចតែគ្នាហ្នឹង។

## វគ្គ VIII



# ពិធីជប់លៀងបុណ្យសព

ខែតុលាបានមកដល់ នាំយកមកនូវផ្សែងអ័ព្ទត្រជាក់ព្រឺសម្បុរទាំងនៅលើដី និងក្នុងប្រាសាទ។ អ្នកស្រីផុមហ្វ្រី ដែលត្រូវជាគិលានុបដ្ឋាយិកា កំពុងតែត្រូវជាប់រវល់ដោយសារតែមានការរីករាលដាលឡើងជាបន្ទាន់ នៃជម្ងឺផ្ដាសាយក្នុងចំនោមបុគ្គលិកធ្វើការ និងពួកកូនសិស្សផងដែរ។ ឱសថបំបាត់ផ្ដាសាយរបស់គាត់មានប្រសិទ្ធិភាពភ្លាមៗតែម្ដង ទោះជាអ្នកដែលផឹកវាត្រូវហុយផ្សែងចេញតាមត្រចៀកអស់ជាច្រើនម៉ោងយ៉ាងណាក្ដី។ ជីននី វីស្លី ដែលមើលទៅដូចជាស្លេកស្លាំង ក៏ត្រូវ ពើរស៊ី ចាប់បញ្ចុកខ្លះៗដែរ។ ចំហាយទឹកភាយចេញពីក្រោមសក់ដ៏ឆើតរបស់នាង មើលទៅមានអារម្មណ៍ដូចជា ក្បាលទាំងមូលរបស់នាងត្រូវភ្លើងឆេះអញ្ចឹង។

តំណក់ទឹកភ្លៀងប៉ុនគ្រាប់កាំភ្លើងចាប់ផ្ដើមបង្អុរធ្លាក់មកតាមបង្អួចប្រាសាទអស់ជាច្រើនថ្ងៃទំរាំតែឈប់ភ្លៀង។ ផ្កាកុលាបនៅមាត់បឹង ហើយនិងផើងផ្កាត្រូវប្រែក្លាយទៅជាខ្សែទឹកជោកជាំដោយភក់ជ្រាំ រីឯផ្លែល្ពៅរបស់ហាហ្គ្រីដរីកប៉ោងឡើងទំហំស្មើនឹងរោងសួនច្បារទៅហើយ។ ទុកជាយ៉ាងម៉េចក៏ដោយ សេចក្ដីត្រេកត្រអាលរបស់ ដំបង ចំពោះការហាត់សមជាទៀងទាត់ នៅតែមិនអាចបង្ក្រាបបាន ដែលជាមូលហេតុពន្យល់ថាតើ ហេតុអ្វីបានជាហេរីត្រូវគេឃើញត្រលប់មកអគារហ្គ្រីហ្វីនដ័រវិញ នៅល្ងាចថ្ងៃសៅរ៍ប៉ុន្មានថ្ងៃមុនបុណ្យហាឡូវីន ទាំងទទឹកជោក និងប្រឡាក់សុទ្ធតែភក់...

ទោះជាមិនមែនដោយសារតែភ្លៀង និងខ្យល់ ក៏វាមិនមែនជាការហ្វឹកហាត់ដ៏រីករាយមួយនោះដែរ។ ហ្វ្រេដ និងចច ដែលបានទៅលបមើលក្រុមស្លីធីរីន បានឃើញនឹងផ្ទាល់ភ្នែកពួកគេនូវល្បឿនដ៏អស្ចារ្យនៃអំបោស នីមប៊ូស ២០០១ ថ្មីៗទាំងនោះ។ ពួកគេបានរាយការណ៍ថា ពួកគេមើលក្រុមស្លីធីរីនមិនចង់ទាំងទាន់ផង ព្រោះឃើញតែរូបរាងពណ៌បៃតងស្រពិចស្រពិលទាំងប្រាំពីរនាក់ហោះវូទៅវូមក ដូចជាគ្រាប់រ៉ុកកែតអញ្ចឹង។

ខណៈពេល ដែលហេរីដើរស្ងាត់ៗតាមផ្លូវរបៀងដែលគ្មានមនុស្ស វាស្រាប់តែជួបមនុស្សម្នាក់ដោយចៃដន្យដែលមើលទៅខ្វល់ខ្វាយដូចជាវាអញ្ចឹង។ នីកស្ទើរគតក្បាល ដែលជាខ្មោចអគារហ្គ្រីហ្វីនដ័រ កំពុងតែសម្លឹងមើលយ៉ាងទុក្ខសោកចេញទៅក្រៅបង្អួច ថែមទាំងនិយាយរអ៊ូរទាំតិចៗតែម្នាក់ឯងថា៖

- ...កុំបំពេញតម្រូវការរបស់ពួកគេអី...ប្រសិនបើដូច្នោះមែន ច្បាស់ជាអស់មួយសង់ទីម៉ែតហើយ។

- សួស្ដី នីក- ហេរីស្រដី។

- សួស្តី សួស្តី- នីកស្ទើរតែគ្មានក្បាលតប ព្រមងាកករកមើលប្រភពសម្លេង។ គាត់ពាក់មួកពោមបក្សីដ៏សង្ហាមួយនៅពីលើសក់រួញវែងរបស់គាត់ ហើយនិងស្លៀកអាវផាយ ដោយមានទាំងរ៉ូបរឹង ដែលលាក់កំបាំងនូវការពិតដែលថា ករបស់គាត់ស្ទើរតែត្រូវគេកាត់ដាច់ទាំងស្រុងទៅហើយ។ គាត់មានទឹកមុខស្លេកស្លាំងដូចជាផ្សែង ហើយហេរីអាចមើលគាត់ធ្លុះទៅដល់ផ្ទៃមេឃដ៏ងងឹត និងភ្លៀងដែលធ្លាក់ជោកជាំនៅខាងក្រៅ។

- ឯងមើលទៅដូចជាមានបញ្ហា អ្នកកម្លោះជោគជ័យ- នីកបន្លឺឡើង ដោយចាប់រមូរសំបុត្រដែលអាចមើលឃើញធ្លុះ ខណៈពេលដែលគាត់និយាយ ព្រមទាំងញាត់វាចូលទៅក្នុងអាវសម័យបុរាណរបស់គាត់។

- លោកក៏អញ្ចឹងដែរ- ហេរីពោល។

- ហ្អា!- នីកស្ទើរតែគ្មានក្បាលគ្រវីដៃដ៏យ៉ាងសមសួន - គ្មានការអ្វីសំខាន់នោះទេ...វាមិនមែនថា ខ្ញុំពិតជាចង់ចូលរួមនោះទេ...គិតថាខ្ញុំនឹងដាក់ពាក្យស្នើសុំ ប៉ុន្តែច្បាស់ណាស់ ខ្ញុំគ្មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការឡើយ...

ផ្ទុយពីសំឡេងដ៏រស់រវើករបស់គាត់ ទឹកមុខរបស់គាត់បែរជាពោរពេញទៅដោយភាពជូរចត់។

- ប៉ុន្តែឯងច្បាស់ជាគិតអញ្ចឹងដែរហើយ មែនទេ- គាត់ផ្ទុះសម្តីឡើងភ្លាមៗ ដោយចាប់ទាញសំបុត្រចេញពីហោប៉ៅរបស់គាត់ឡើងវិញ - ច្បាស់ជាគិតថា ការត្រូវវាយដំនឹងពូថៅរឹលមុខយ៉ាងដំណំសែសិបប្រាំដងចំត្រង់ក្បាល នឹងធ្វើឲ្យឯងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងចូលរួមក្រុមប្រមាញ់ឥតក្បាលហើយ មែនរឺទេ?

- អូ...មែនហើយ- ហេរីឆ្លើយតប ដែលជាក់ស្តែងណាស់ គឺធ្វើពុតជាយល់ស្របតាម។

- ខ្ញុំចង់មានន័យថា គ្មាននរណាប្រាថ្នាច្រើនជាងខ្ញុំនោះទេ ថាចង់ឲ្យវាឆាប់ចប់ និងស្អាតផង ថែមទាំងឲ្យក្បាលរបស់ខ្ញុំកាត់ដាច់ចេញឲ្យស្រួលបួល។ អ្វីដែលខ្ញុំចង់និយាយនោះគឺថា វាច្បាស់ជាផ្តល់មកឲ្យខ្ញុំនូវសេចក្តីធូរស្រាលក្នុងចិត្តច្រើន អំពីការឈឺចាប់ និងភាពមិនសមហេតុសមផលទាំងនោះ។ ទុកជាយ៉ាងណាក្តី- នីកស្ទើរតែគ្មានក្បាលរលាស់សំបុត្ររបស់គាត់ ហើយអានទាំងខឹងក្រេវក្រោធៈ "ពួកយើងអាចត្រឹមតែទទួលយកអ្នកប្រមាញ់ណាដែលក្បាលរបស់គេត្រូវដាច់ចេញពីខ្លួនតែប៉ុណ្ណោះ។ បើមិនដូច្នោះទេ វាមិនអាចទៅរួចទេសម្រាប់សមាជិកក្នុងការចូលរួមសកម្មភាពដេញប្រមាញ់ ដូចជា ការរត់ប្រដេញតាមចាប់ក្បាលដោយជិះលើខ្នងសេះ និងល្បែងប៉ូឡូបោះក្បាលជាអាទិ៍។ ដោយហេតុនេះ ខ្ញុំពិតជាសោកស្តាយខ្លាំងណាស់ដែលត្រូវជម្រាបប្រាប់លោកអោយដឹងថា លោកគ្មានកាយសម្បទាគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ពួកយើងនោះទេ។ ដោយក្តីជូនពរ ពីលោក ផាទ្រីក ឌេឡានី-ផោដម័រ។

ដោយម៉ូម៉ៅក្តៅក្រហាយ នីកស្ទើរតែគ្មានក្បាលក៏ញាត់សំបុត្រអោយបាត់ពីមុខពីមាត់។

- ដាច់អស់ស្បែកកន្លះអ៊ីង ហើយនៅមានសរសៃភ្ជាប់ក្បាលខ្ញុំទៀតណ៎ា ហេរី! មនុស្សភាគច្រើនច្បាស់ជាគិតថា កាត់ក្បាលប៉ុណ្ណឹងគឺវាល្អណាស់ទៅហើយ ប៉ុន្តែពុទ្ធោអើយ! ទេ វានៅមិនទាន់គ្រប់គ្រាន់សម្រាប់លោក ផោដម័រឥតក្បាលទាំងស្រុង នោះទេ។

នីកស្ទើរតែគ្មានក្បាលដកដង្ហើមវែងៗ ហើយបន្ទាប់មកក៏និយាយ តែសំឡេងរាងស្ងប់ជាងមុនឆ្ងាយៈ

- និយាយអញ្ចឹង តើមានអ្វីរំខានឯង? តើមានអ្វីដែលខ្ញុំអាចធ្វើបានទេ?

- ទេ- ហេរីស្រដី។ - ជួយមិនបានទេ លុះត្រាតែលោកដឹងពីកន្លែងដែលពួកយើងអាចទៅយកអំបោស នីមប៊ូស ២០០១ ប្រាំពីរដោយមិនគិតថ្លៃ ដើម្បីទៅប្រកួតនឹងក្រុមស្លី...

ចុងប្រយោគរបស់ ហេរី ត្រូវកប់បាត់ដោយសារសំឡេងម៉េវៗយ៉ាងស្រួយស្រែសមួយ ពីកន្លែងណាមួយក្បែរកែងជើងរបស់វា។ វាសម្លឹងមើលចុះក្រោយ ហើយក៏ឃើញភ្នែកពណ៌លឿងដូចចង្កៀងភ្លើងមួយគូសម្លក់មករកវា។ វាគឺ អ្នកស្រី ណូរីស ឆ្មាពណ៌

ប្រផេះស្គមសល់តែឆ្អឹងដែល ឆ្មាំយាម អាហ្គូស ហ្វីលច្ច ប្រើប្រាស់ជាអាវុធនៅក្នុងការប្រយុទ្ធមិនចេះចប់មិនចេះហើយរវាងពួកកូនសិស្ស និងរូបគាត់។

- យល់ល្អ ឯងគួរតែចាកចេញពីទីនេះទៅ ហេរី- នីកនិយាយយ៉ាងរហ័ស។ - ហ្វីលច្ចមិនសូវមានអារម្មណ៍ល្អប៉ុន្មានទេ...គាត់ឆ្លងរោគផ្ដាសាយផង ណាមួយមានពួកកូនសិស្សឆ្នាំទីបីបូកប៉ាន់ច្រលំលាយខួរកង្កែបពាសពេញពិតាននៅក្នុងគុកងងឹតទីប្រាំផង។ គាត់ត្រូវសម្អាតចេញពេញមួយព្រឹក ហើយប្រសិនបើគាត់ឃើញឯងធ្វើឲ្យប្រឡាក់ភក់ពេញទីកន្លែងដូច្នេះនោះ...

- ត្រូវហើយ- ហេរីបន្លឺឡើង ថែមទាំងដើរថយក្រោយឲ្យចេញផុតពីក្រសែភ្នែកចោទប្រកាន់របស់អ្នកស្រីណូរីស ប៉ុន្តែនៅតែគេចមិនផុត។ មានថាមពលដ៏អាថ៌កំបាំងមួយដែលហាក់ដូចជា ភ្ជាប់ទំនាក់ទំនងងរវាងគាត់ និងឆ្មាដ៏អាក្រក់របស់គាត់អញ្ចឹង។ អាហ្គូស ហ្វីលច្ចដើរសម្រុកមកភ្លាមៗតាមកម្រាលឥដ្ឋនៅខាងស្ដាំដៃហេរី ដោយដកដង្ហើមតឹងៗ និងសម្លឹងរកមើលអ្នកធ្វើខុសវិន័យដូចចង់ស៊ីសាច់ហុតឈាម។ មានកន្សែងក្រឡាៗយ៉ាងក្រាស់មួយបង់ជុំវិញក្បាលរបស់គាត់ ហើយច្រមុះរបស់គាត់ឡើងពណ៌ស្វាយខុសពីធម្មតា។

- កខ្វក់ណាស់!- គាត់ស្រែកខ្លាំងៗ ធ្វើឲ្យថ្គាមក្រោមរបស់គាត់ឡើងញ័រ ឯភ្នែករបស់គាត់បាញ់សំដៅយ៉ាងតក់ស្លុតទៅកាន់គ្រលុកសុទ្ធតែភក់ដែលហូរហៀរចេញពីអាវរ៉ូបលេងឃ្វីដឌីច្ចរបស់ហេរី។ - ធ្វើឲ្យរញ៉េរញ៉ៃ និងធ្វើឲ្យស្មោកគ្រោកគ្រប់តែទីកន្លែង! ខ្ញុំសូមប្រាប់ឯងទៅចុះថា ល្មមៗបានហើយ! មកតាមខ្ញុំមក ផោតធ័រ!

ដូច្នេះ ហេរីក៏បក់ដៃលាគ្នាយ៉ាងស្រងេះស្រងោចទៅរកនីកស្ទើរគតក្បាល ហើយក៏ដើរតាមពីក្រោយហ្វីលច្ចចុះទៅជាន់ក្រោម ដោយបន្ថែមស្នាមជើងប្រឡាក់ភក់ពីរដងទៅលើកំរាល។

ហេរីមិនដែលបាននៅក្នុងការិយាល័យរបស់ហ្វីលច្ចពីមុនមកទេ។ វាជាកន្លែងមួយដែលកូនសិស្សភាគច្រើនជៀសគេចមិនចង់ចូល។ បន្ទប់នោះតូចគ្រិច ហើយគ្មានបង្អួចសូម្បីតែមួយ និងត្រូវបំភ្លឺឡើងដោយចង្កៀងប្រេងត្រឹមតែមួយគត់ដែលត្រូវចងព្យួរព្រយុងចុះក្រោមពីពិតានដ៏ទាប។ មានក្លិនឆ្អាបត្រីចៀនតិចៗឆ្អួលពេញកន្លែងនោះ។ ទូដាក់ឯកសារធ្វើអំពីឈើត្រូវបញ្ឈរនៅជុំវិញជញ្ជាំង។ ដោយមើលតាមផ្លាកឈ្មោះ ហេរីអាចមើលឃើញថា ក្នុងឯកសារទាំងនោះក៏មានផ្ទុកនូវសេចក្ដីលំអិតអំពីកូនសិស្សគ្រប់រូបដែលហ្វីលច្ចធ្លាប់ដាក់ទណ្ឌកម្ម។ ហ្វ្រេដ និង ចច វីស្លី មានកំណត់ហេតុស្ទើរតែពេញទូទៅហើយ។ មានច្រវ៉ាក់ និងខ្នោះដៃដែលត្រូវដុសខាត់យ៉ាងស្អាតផេងមួយចង្វាយ ព្យួរនៅលើជញ្ជាំងពីក្រោយតុការិយាល័យរបស់ហ្វីលច្ច។ វាជាការយល់ដឹងជាទូទៅមួយទៅហើយ ដែលថាហ្វីលច្ចតែងតែអង្វរករលោកដាំប័លដ័រ ដើម្បីអនុញ្ញាតឲ្យគាត់ចាប់ចងកជើងកូនសិស្សព្យួរឡើងពីពិតាន។ ហ្វីលច្ចរើសយកស្លាបប៉ាកាមួយពីភាជន៍នៅលើតុការិយាល័យរបស់គាត់ ព្រមទាំងចាប់ផ្ដើមរាវជុំវិញរកមើលក្រដាសស្បែកចៀម។

- សុទ្ធតែចង្រៃ!- គាត់រអ៊ូរទាំដោយម៉ូរម៉ៅ - ព្រលឹងខ្មោចនាគកាចៗ...ខួរកង្កែប...ពោះវៀនកណ្ដុរ...ល្មមហើយប៉ុណ្ណឹង...ទុកមេរៀនមួយឲ្យពួកឯងចុះ...ឯណាអីចេះ ក្រដាសបំពេញនោះ...នៅនេះទេតើ...

គាត់ដកហូតចេញមកនូវក្រដាសស្បែកចៀមមួយដុំធំពីថតតុរបស់គាត់ ហើយលាតនៅពីមុខគាត់ ព្រមទាំងជ្រលក់ស្លាបប៉ាកាពណ៌ខ្មៅដ៏វែងរបស់គាត់ទៅក្នុងដបទឹកខ្មៅ។

- ឈ្មោះ...ហេរី ផោតធ័រ។ ឧក្រិដ្ឋកម្ម...

- វាគ្រាន់តែជាភក់បន្តិចប៉ុណ្ណោះទេតើ!- ហេរីឧទានឡើង។

- អាច្រមក់ វាគ្រាន់តែជាភក់បន្តិចប៉ុណ្ណោះសម្រាប់ឯង តែចំពោះខ្ញុំវិញ វាត្រូវប្រើពេលមួយម៉ោងទៀតដើម្បីដុសជូតឲ្យស្អាតណា!- ហ្វីលច្ឆស្រែកគំហកដាក់វិញ ដោយមានតំនក់ទឹករញ្ជួយយ៉ាងមិនគួរឲ្យរីករាយឯចុងច្រមុះមូលឆ្កញរបស់គាត់។

ដោយជូតច្រមុះគាត់បន្តិច ហ្វីលច្ឆសម្លឹងមើលព្រឹមៗទៅកាន់ហេរីយ៉ាងមិនពេញចិត្ត ឯហេរីវិញកំពុងតែរង់ចាំឲ្យគាត់បន្លឺប្រយោគមួយទៀតស្មើរថប់ដង្ហើមស្លាប់។

ប៉ុន្តែខណៈដែលហ្វីលច្ឆបន្ទាបស្លាបប៉ាការបស់គាត់ចុះ ស្រាប់តែមានសូរផ្ទុះខ្លាំង នៅលើពិតានការិយាល័យនោះ ដែលធ្វើឲ្យចង្កៀងប្រេងរង្គោះរង្គើ។

- ភីវ!- ហ្វីលច្ឆស្រែកគ្រហឹម ព្រមទាំងគ្រវែងចោលស្លាបប៉ាការបស់គាត់ដោយក្រោធខឹងខ្លាំង។ - ខ្ញុំនឹងចាប់ឯងឲ្យបានលើកនេះ ខ្ញុំនឹងចាប់ឯងឲ្យបាន!

ហើយដោយគ្មានសម្លឹងមើលមកហេរីម្តងទៀត ហ្វីលច្ឆក៏រត់ទាំងជើងទទេពីការិយាល័យ ចំនែក អ្នកស្រីណូរីស រត់ប្រកិតជិតគាត់។

ភីវគឺជាខ្មោចលងប្រចាំសាលា ហើយជាអ្នកគំរាមកំហែងជើងអាកាសសើចស្ទេញជានិច្ចម្នាក់ ដែលរស់នៅដើម្បីតែបង្កឲ្យវិនាសហិនហោច និងធ្វើទុក្ខបុកម្នេញគេឯង។ ហេរីមិនសូវជាចូលចិត្តភីវប៉ុន្មាននោះទេ ប៉ុន្តែក៏មិនអាចនឹងមិនដឹងគុណចំពោះការបង្កហេតុទាន់ពេលរបស់គាត់ដែរ។ ដោយមានសង្ឃឹមជាងមុន ទោះជាភីវបានធ្វើរឿងអ្វីក៏ដោយ (ហើយស្តាប់មើលទៅ ហាក់ដូចជាគាត់បានធ្វើឲ្យបែកអ្វីមួយធំខ្លាំងណាស់លើកនេះ) ក៏វាអាចទាញការចាប់អារម្មណ៍របស់ហ្វីលច្ឆពីហេរីបានមួយគ្រាដែរ។

ដោយគិតថាវាគួរតែរង់ចាំឲ្យ ហ្វីលច្ឆ ត្រឡប់មកវិញ ហេរីក៏បន្ទាបខ្លួនចុះទៅលើកៅអីដែលត្រូវខ្មូតស៊ីមួយនៅជាប់នឹងតុការិយាល័យនោះ។ មានតែរបស់ម្យ៉ាងគត់ ដែលនៅដាច់ដោយឡែកពីក្រដាសបំពេញបែបបទដែលសរសេរហើយពាក់កណ្តាលរបស់គាត់៖ គឺស្រោមសំបុត្រពណ៌ស្វាយរលោងដ៏ធំមួយដែលមានសរសេរអក្សរពណ៌ប្រាក់នៅខ្នងខាងមុខ។ ដោយក្រឡេកមើលមួយឆ្វាច់ឯទ្វារដើម្បីបញ្ជាក់ថា ហ្វីលច្ឆមិនទាន់ត្រលប់មកវិញទេ ហេរីក៏រើសយកស្រោមសំបុត្រនោះ ហើយអានថា៖

*បាលីងាយរៀន*
*វគ្គសិក្សាតាមសំបុត្រ*
*សម្រាប់អ្នកសិក្សាវេទមន្តដំបូង*

ដោយហេតុតែចង់ដឹង ហេរីក៏ផ្ទាត់ស្រោមសំបុត្រឲ្យរបើកឡើង រួចទាញបំនត់ក្រដាសស្បែកចៀមចេញពីខាងក្នុង។ មានអក្សរពណ៌ប្រាក់ជាច្រើនទៀតសរសេរនៅទំព័រខាងមុខថា៖

*ទើបតែឈានជើងចូលទៅក្នុង ពិភពវេទមន្តទំនើប ដំបូងរឺ? មានហេតុផលផ្ទាល់ខ្លួន ដែលហាមប្រាមមិនឲ្យប្រើវេទមន្តសាមញ្ញៗរឺ? ធ្លាប់ត្រូវគេចំអកឡកឡឺយដោយសារតែការប្រើចង្កឹះវេទមន្តមិនល្អរបស់អ្នកដែររឺទេ?*
នេះហើយគឺជាចម្លើយចំពោះសំណួរទាំងប៉ុន្មានខាងលើនេះ!

*បាលីងាយរៀន គឺជាវគ្គសិក្សាដែលផ្តល់ភាពងាយស្រួល ទទួលបានលទ្ធផលឆាប់រហ័ស និងមានសុវត្ថិភាពមួយរយភាគរយ ថែមទាំងទើបច្នៃបង្កើតថ្មីៗទាំងអស់។ មានធ្មប់ និងវេទគូរាប់រយនាក់ ដែលទទួលបាននូវគុណសម្បត្តិអំពីវិធីបាលីងាយរៀននេះ!*

*អ្នកស្រី ហ្វ. នេតថល នៃត្រកូល ថប់ស្ដែម បានសរសេរថា៖*
*"ខ្ញុំគ្មានខួរក្បាលនឹងសូត្រឲ្យចាំនូវរបៀនអាគមគាថាទាល់តែសោះ   ចំនែកវិធីផ្សំឱសថរបស់ខ្ញុំត្រឹមតែអាចធ្វើឲ្យសមាជិកគ្រួសារខ្ញុំសើចចំអកដាក់តែប៉ុណ្ណឹង! ឥឡូវនេះ ក្រោយពីបានសិក្សាវគ្គបាលីងាយរៀនរួចមក ខ្ញុំក្លាយជាមជ្ឈដ្ឋានចោមរោមពីគ្រប់បក្សគ្រប់ក្រុម ចំនែកឯភ្ញៀនរបស់ខ្ញុំថែមទាំងបានមកតាមសុំអង្វរករខ្ញុំឲ្យបង្រៀនពួកគេនូវដំណោះស្រាយក្នុងការបង្កើតផ្កាភ្លើងរបស់ខ្ញុំទៀតផង!"*

*រីឯលោក វ៉ាំឡក់ ដ. ច. ព្រោត នៃត្រកូល ឌីដប៊ីរី វិញនិយាយថា៖*
*"ភរិយារបស់ខ្ញុំធ្លាប់តែនិយាយមើលងាយចំពោះវេទមន្តដ៏ខ្សត់ខ្សោយរបស់ខ្ញុំ ប៉ុន្តែគ្រាន់តែចាប់ផ្តើមសិក្សាវគ្គបាលីងាយរៀនភ្លាម ខ្ញុំក៏ទទួលបានជោគជ័យក្នុងការបំប្លែងរូបនាងទៅជាសត្វចាបរីបាត់ទៅហើយ! អរគុណហើយ បាលីងាយរៀន!*

ដោយមានការចាប់អារម្មណ៍ ហេរីក៏អានតចុះរហូតមកនូវខ្លឹមសារនៅក្នុងស្រោមសំបុត្រនោះ។ តើមានហេតុផលដែលអាចទៅរួចណាមួយទៅ ដែលជំរុញឲ្យហ្វីលច្ចមានចិត្តចង់រៀនវគ្គបាលីងាយរៀននោះ? តើនេះបានន័យថា គាត់មិនមែនជាវេទគូល្អគត់មត់ម្នាក់រឺ? ហេរីទើបតែបានអាន "មេរៀនទីមួយ៖ របៀបកាន់ចង្កឹះ (ដំបូន្មានល្អៗខ្លះៗ)" ស្រាប់តែសម្លេងដើរអូសជើងនៅខាងក្រៅបានផ្តល់សញ្ញាឲ្យវាថា ហ្វីលច្ចត្រលប់មកវិញហើយ។ ដោយញាត់ក្រដាសស្បែកចៀមចូលទៅក្នុងស្រោមសំបុត្រវិញ ហេរីក៏គ្រវែងវាទៅលើតុការិយាល័យវា ចំពេលដែលទ្វារបង្អើបឡើង។

ហ្វីលច្ចមើលទៅដូចជាទទួលបានជោគជ័យហើយ។

- ទូបំបាំងកាយនោះពិតជាមានតម្លៃខ្លាំងណាស់!- គាត់ឧទានឡើងដោយក្តីរីករាយទៅកាន់អ្នកស្រីណូរីស។ - ពួកយើងច្បាស់ជាបានបណ្តេញភីវចេញជាមិនខាន ឆ្មាសម្លាញ់...

ភ្នែករបស់គាត់បែរមករកហេរី ហើយក្រោយមក ក៏សំដៅទៅស្រោមសំបុត្របាលីងាយរៀន ដែល...ទំរាំតែហេរីដឹង វាហួសពេលទៅហើយ  គឺវាស្ថិតនៅចម្ងាយពីរហ្វីតពីកន្លែងដើមរបស់វាឯណោះ។ មុខដ៏ខែងរ៉ែងរបស់ហ្វីលច្ចប្រែក្លាយទៅជាពណ៌ក្រហមដូចដុំឥដ្ឋ។ ហេរី ប្រុងប្រៀបខ្លួនទប់ទល់នឹងរលករញ្ជួយព្រះធរណីនៃកំហឹងក្រេវក្រោធដែលនឹងកើតឡើងនាពេលបន្តិចទៀតនេះ។ ហ្វីលច្ចដើរខ្ចកៗទៅកាន់តុការិយាល័យរបស់គាត់ រួញទាញកញ្ចក់បើកស្រោមសំបុត្រ ហើយគ្រវែងវាទៅក្នុងថតមួយ។

- តើឯង...មានបានអានទេ?- គាត់និយាយឡើងញាប់ស្មេក។

- ទេ- ហេរីកុហកយ៉ាងរហ័ស។

ប្រអប់ដៃកំពកៗជាដុំរបស់ហ្វីលច្ចកំពុងមួលត្របាញ់បញ្ចូលគ្នា។

- ប្រសិនបើឯងគិតថា ឯងបានអានទ្រព្យជាកម្មសិទ្ធិឯកជនរបស់ខ្ញុំនោះ...មិនមែនថាវាជារបស់ខ្ញុំទេ...គឺជារបស់មិត្តម្នាក់...ចាត់ទុកថាអញ្ចឹងចុះ...ទោះជាយ៉ាងណាក៏ដោយ...

ហេរីកំពុងសម្លឹងមើលគាត់មិនដាក់ភ្នែក ដោយភិតភ័យ។ ហ្វីលច្ចមិនដែលខឹងដល់ម្លឹងៗនោះទេ។ ភ្នែករបស់គាត់កំពុងតែលៀនចេញមក ឯថ្គាល់ដូចជាថង់របស់គាត់កំពុងតែញញាក់ញញ័រ ហើយសូម្បីតែកន្សែងបង់ករាងក្រឡាៗនោះក៏ជួយមិនបានដែរពេលនេះ។

- ល្អណាស់អញ្ចឹង...ទៅ...ហើយកុំបង្ហើបអ្វីសូម្បីតែមួយម៉ាត់...កុំឲ្យសោះ...ទុកជាយ៉ាងណាក្តី ប្រសិនបើឯងពិតជាមិនបានអានអ្វីនោះទេ...ចេញឥឡូវភ្លាមទៅ ខ្ញុំត្រូវសរសេររបាយការណ៍របស់ភីវផង...ម៉េចក៏មិនទៅ...

ដោយសែនភ្ញាក់ផ្អើលនឹងសំណាងរបស់វា ហេរីត់ផាយក្រញាំចេញពីការិយាល័យនោះ ឡើងទៅផ្លូវរបៀង ហើយត្រលប់មកជាន់លើវិញ។ ការគេចផុតពីការិយាល័យរបស់ហ្វីលច្ចដោយគ្មានទទួលទណ្ឌកម្ម ប្រហែលជាការបំបែកឯតទគ្គកម្មមួយនៅក្នុងសាលាហើយ។

- ហេរី! ហេរី! តើវាមានប្រសិទ្ធិភាពដែរឺទេ?

នីកស្ទើរគតក្បាលហោះសំកាំងចេញពីថ្នាក់រៀនមួយ។ នៅពីក្រោយគាត់ ហេរីអាចមើលឃើញបំណែកបាក់បែកនៃទូពណ៌មាសក្រមៅ ដ៏ធំមួយ ដែលហាក់ដូចជាត្រូវបានទំលាក់ពីកំពស់ដ៏មហាសែនខ្ពស់មួយ។

- ខ្ញុំបានបញ្ចុះបញ្ចូលភីវឲ្យទម្លាក់វាចំពីលើការិយាល័យរបស់ហ្វីលច្ច- នីកនិយាយទាំងចង់ដឹងចង់ឃើញ។ - គិតថាវាប្រហែលជាអាចបំបែកអារម្មណ៍របស់គាត់បាន...

- តើលោកជាអ្នកធ្វើរឿងហ្នឹងរឺ?- ហេរីស្រដីដោយក្តីដឹងគុណ។ - មែនហើយ វាពិតជាមានប្រសិទ្ធិភាពមែន ខ្ញុំថែមទាំងមិនទទួលការពិន័យទៀតផង។ អរគុណច្រើនហើយ នីក!

ពួកគេដើរឡើងតាមផ្លូវរបៀងជាមួយគ្នា។ ហេរីកត់សម្គាល់ថា នីកស្ទើរគតក្បាលនៅតែកំពុងកាន់សំបុត្របដិសេធរបស់លោក ផាទ្រីក ដដែល...

- ខ្ញុំសង្ឃឹមថា ខ្ញុំអាចជួយអ្វីបានទៅចុះអំពីការប្រមាញ់ឥតក្បាលនោះ- ហេរីបន្លឺឡើង។

នីកស្ទើរគតក្បាលទុចដំនើរង៉ក់ ហើយហេរីក៏ដើរកាត់ខ្លួនគាត់។ វាបន់តែកុំឲ្យដើរឆ្លងកាត់ខ្លួនគាត់ទៅចុះ ព្រោះថា វាដូចជាបោះជំហានឆ្លងកាត់ទឹកផ្កាឈូកត្រជាក់ដូចទឹកកកអ៊ីចឹង។

- ប៉ុន្តែមានរឿងមួយដែលឯងអាចធ្វើឲ្យខ្ញុំបាន- នីកឧទានឡើងយ៉ាងរំជួលចិត្ត។ - ហេរី...បើខ្ញុំមិនស្នើសុំច្រើនពេកនោះទេ...ប៉ុន្តែ មិនចាំបាច់ទេ ឯងច្បាស់ជាមិនចង់...

- តើវាជាអ្វីទៅ?- ហេរីសួរ។

- អឺ...ពិធីបុណ្យហាឡូវីនឆ្នាំនេះគឺជាពិធីរំលឹកសពទីប្រាំរយរបស់ខ្ញុំ- នីកស្ទើរគតក្បាលនិយាយ ព្រមទាំងបង្អោះខ្លួនឡើងបន្តិច ហើយមើលទៅដូចជាមានកិត្តិយសណាស់។

- អូ!- ហេរីពោលតប ដោយមិនប្រាកដថា តើវាគួរតែធ្វើមុខសោកស្តាយ រឺក៏រីករាយអំពីដំណឹងនេះនោះទេ។ - មែនហើយ។

- ខ្ញុំនឹងប្រារព្ធពិធីជប់លៀងមួយនៅក្នុងគុកងងឹតដែលមានកន្លែងរាងធំបន្តិច។ មិត្តភក្តិនឹងមកចូលរួមពីទូទាំងប្រទេស។ វាពិតជាមានកិត្តិយសខ្លាំងណាស់ ដែលបានឯងទៅចូលរួម។ លោកវីស្លី និងកញ្ញាហ្គ្រេនជឺរក៏នឹងស្វាគមន៍ដែរ ជាការពិត

ណាស់...ប៉ុន្តែខ្ញុំខ្លាចថា ឯងចង់ទៅចូលរួមពិធីជប់លៀងជាមួយសិស្សសាលាគ្នាឯងជាង មែនរឺក៏ទេ?- គាត់សម្លឹងមើលមកហេរីទន្ទឹងស្ដាប់ចម្លើយតប។

- ទេ- ហេរីស្រដីយ៉ាងប្រញាប់ប្រញាល់ - ខ្ញុំនឹងទៅ...

- ក្មេងប្រុសសំណព្វចិត្តខ្ញុំអើយ! ហេរី ផោតធ័រ នៅឯពិធីជប់លៀងបុណ្យសពរបស់ខ្ញុំ! ហើយ- គាត់និយាយបែបស្ទាក់ស្ទើរដោយមើលទៅរាងរំភើបចិត្តជាខ្លាំង - តើឯងអាចបញ្ជាក់ប្រាប់លោក ផេទ្រីក ថាតើ ឯងយល់ថាខ្ញុំហ្នឹង គួរឲ្យខ្លាច និងគួរឲ្យសរសើរយ៉ាងណាបានដែររឺទេ?

- បាន...ពិតជាបាន- ហេរីតប។

នីកស្ទើរឥតក្បាលញញឹមយ៉ាងប្រិមប្រិយដាក់វា។

*

- ពិធីជប់លៀងបុណ្យសពរឺ?- ហឺម៉ាយអូនីឧទានឡើងយ៉ាងរហ័សរហួន នៅពេលដែលហេរីបានផ្លាស់ប្ដូរសម្លៀកបំពាក់ និងចូលរួមជាមួយនាង និងរ៉ុនក្នុងសហសាល។ - ខ្ញុំហ៊ានភ្នាល់ថា មិនមានមនុស្សនៅរស់ច្រើនទេ ដែលអាចនិយាយថា ពួកគេធ្លាប់ទៅចូលរួមពិធីនោះ...វាច្បាស់ជាគួរឲ្យចាប់អារម្មណ៍ណាស់ហើយ!

- តើហេតុអ្វីបានជាម្នាក់ៗចង់ប្រារព្ធពិធីនៅថ្ងៃដែលពួកគេស្លាប់ទៅវិញ?- រ៉ុនសួរ វាកំពុងតែធ្វើលំហាត់កិច្ចការផ្ទះផ្នែកឱសថ រាវរបស់វាបានពាក់កណ្ដាល ហើយក៏រាងម៉ូម៉ៅផងដែរ។ - ឥឡូវតែឮពាក្យថា សាកសព ខ្ញុំអារម្មណ៍មិនល្អតែម្ដង...

ភ្លៀងនៅតែហូរចុះសស្រាក់តាមបង្អួច ដែលឥឡូវឡើងពណ៌ទឹកខ្មៅ ប៉ុន្តែនៅខាងក្នុងសុទ្ធតែមានសភាពភ្លឺថ្លា និងរួសរាយ។ ពន្លឺភ្លើងចែងចាំងពន្លឺពីលើកៅអីភ្នាក់ដៃស្រួយៗជាច្រើនរាប់មិនអស់ ដែលមនុស្សម្នានៅអង្គុយអានសៀវភៅ ជជែកគ្នា ធ្វើលំហាត់កិច្ចការផ្ទះ រឺក៏...បើក្នុងករណីហ្វ្រេដ និងចច វីស្លីវិញ...គឺព្យាយាមរកនឹកមើលថាតើ នឹងមានអ្វីកើតឡើងប្រសិនបើគេឲ្យត្រកួតស៊ីកាំជ្រួចចោរសមុទ្រវិញនោះ។ ហ្វ្រេដបាន "ជួយសង្គ្រោះ" សត្វត្រកួតរស់នៅក្នុងភ្លើងពណ៌ទឹកក្រូចភ្លឺថ្លាមួយក្បាលកាលពីនៅរៀនមុខវិជ្ជា ថែរក្សាសត្វវេទមន្ត ហើយឥឡូវ សត្វត្រកួតនោះកំពុងតែឆេះធំៗនៅលើតុមួយ ដែលត្រូវបានឡោមព័ទ្ធជិតទៅដោយពួកអ្នកចង់ដឹងចង់ឃើញមួយក្រុម។

ហេរីនិយាយប្រាប់រ៉ុន និងហឺម៉ាយអូនីដល់ត្រង់កន្លែង ហ្វីលច្ឆ និង វគ្គសិក្សាបាលីងាយរៀន ស្រាប់តែពេលនោះ សត្វត្រកួតបន្លឺសូរស៊ីៗហោះទៅក្នុងអាកាស ដោយបញ្ចេញផ្កាភ្លើង និង សំឡេងផ្ទុះខ្លាំងៗ ខណៈពេលដែលវាបង្វិលខ្លួនយ៉ាងសាហាវឃោរឃៅជុំវិញបន្ទប់នោះ។ ការប្រាកដខ្លួនឡើងរបស់ ពៀរស៊ី ចេញមកស្រែកឡើងស្អកកដាក់ហ្វ្រេដ និងចច ការសំដែងដ៏ពិសេសមួយនូវផ្កាយលឿងខ្ចាតព្រាតៗចេញពីមាត់របស់សត្វត្រកួត ហើយនិងការរត់គេចរបស់វាដោយលោតចូលទៅក្នុងភ្លើង ដោយមានបន្លឺសំឡេងផ្ទុះផ្ទួងៗ បានធ្វើឲ្យគំនិតអំពី ហ្វីលច្ឆ និង ស្រោមសំបុត្របាលីងាយរៀន រលុបបាត់ចេញពីសតិរបស់ហេរី។ នៅជិតដល់ពេលបុណ្យហាឡូវីនមកដល់ ហេរីក៏ចាប់ផ្ដើមសោកស្ដាយចំពោះពាក្យសន្យាដ៏ប្រញាប់ប្រញាល់ ថាទៅចូលរួមពិធីជប់លៀងបុណ្យសព។ អ្នកផ្សេងទៀតក្នុងសាលានឹងទៅចូលរួមពិធីជប់លៀងថ្ងៃបុណ្យហាឡូវីនរបស់ពួកគេយ៉ាងសប្បាយរីករាយ។ មហាសាលត្រូវបានលំអទៅដោយប្រជៀវរស់ៗដូចសព្វដង ចំនែកផ្លែល្ពៅធំល្វឹងរបស់ហាហ្គ្រីដក៏ត្រូវបានគេឆ្លាក់ទៅជាគោមធំៗល្មមតែនឹងអាចដាក់មនុស្សបីនាក់អង្គុយបាន ហើយក៏មានពាក្យចចាមអារ៉ាមថា លោកដាំប័លដ័របានកក់នូវក្រុមរាំឆ្អឹងខ្មោចសម្រាប់ទុកជាការកែអផ្សុក។

## ពិធីជប់លៀងបុណ្យសព

- សន្យាគឺជាសន្យាណ៎ា- ហឺម៉ាយអូនីរំលឹកហេរីបែបបង្គាប់បញ្ជា។ - ឯងនិយាយហើយតើ ថាឯងនឹងទៅចូលរួមពិធីជប់លៀងបុណ្យសព។

ដូច្នេះ នៅម៉ោងប្រាំពីរ ហេរី រ៉ុន និងហឺម៉ាយអូនីធ្វើដំណើរតាមផ្លូវចូលទៅក្នុងមហាសាល ដែលពោរពេញដោយមនុស្សម្នា ថៃមទាំងត្រូវបំភ្លឺឡើងព្រោងព្រាតយ៉ាងស្វាគមន៍ ទៅដោយចានមាស ព្រមទាំងទានជាច្រើនដើម រួចក៏តំរង់ជំហានរបស់ពួកគេសំដៅទៅគុកងងឹត។

ផ្លូវរបៀងដែលនាំទៅកាន់ពិធីជប់លៀងរបស់ នីកស្ទើរតតក្បាល ត្រូវបានតំរៀបជាជួរទៅដោយទានផងដែរ ទោះបីជាប្រសិទ្ធិភាពដាច់ឆ្ងាយពីភាពរីករាយយ៉ាងណាក្តី៖ មានទានពណ៌ខ្មៅជាំវែងស្តើងៗ ដែលសុទ្ធតែបញ្ចេះពន្លឺពណ៌ខៀវខ្ចី បង្កើតបាននូវពន្លឺដូចខ្មោចស្រពិចស្រពិល សូម្បីតែនៅលើមុខដ៏រស់រវើករបស់ពួកគេក៏ដោយ។ សីតុណ្ហភាពកាន់តែធ្លាក់ចុះបន្តិចម្តងៗ ទន្ទឹមនឹងរាល់ជំហានដែលពួកគេឈានទៅមុខ។ ខណៈពេលដែលហេរីញ័រចំប្រប់ពេញប្រាណ ព្រមទាំងទាញបន្តឹងអាវរ៉ូបរបស់វា ស្រាប់តែវាឮសូរអ្វីមួយដែលស្តាប់មើលទៅដូចជា សូរក្រចកដៃរាប់ពាន់ទង្គិចនឹងបន្ទះក្តារខៀនដ៏ធំមហិមាមួយ។

- តើនោះវីជាតន្ត្រី?- រ៉ុនខ្សឹបសួរ។ ពួកគេបត់កាច់ជ្រុង ហើយក៏ឃើញ នីកស្ទើរតតក្បាល កំពុងតែឈរនៅមាត់ទ្វារចូលស្ថិតក្នុងឈុតរ៉ូបសំពត់កម្ម៉ី។

- មិត្តភក្តិសម្លាញ់របស់ខ្ញុំអើយ- គាត់បន្លឺឡើងទាំងទុក្ខព្រួយ។ - សូមស្វាគមន៍ សូមស្វាគមន៍...ពិតជារីករាយណាស់ដែលពួកឯងអាចឆ្លៀតមកបាន...

គាត់ដោះមួកពោមបក្សីរបស់គាត់ចេញ ហើយលំអោនកាយឲ្យអញ្ជើញពួកគេចូលក្នុង។

ពិតជាមិនគួរឲ្យជឿនឹងភ្នែកទាល់តែសោះ។ គុកងងឹតសុទ្ធតែពោរពេញទៅដោយមនុស្សពណ៌សដូចគុជខ្យងយ៉ាងថ្លាឈ្វង់ ភាគច្រើនរសាត់ទៅមកជុំវិញឆាករាំដ៏កកកុញ កំពុងតែរាំរបាំវ៉ាល់ស៍ ទៅតាមសំឡេងញ័រៗដ៏គួរអោយញញើត បន្លឺឡើងពីឧបករណ៍តន្ត្រីជាងសាមសិប ដែលប្រគំដោយក្រុមភ្លេងនៅច្រកផ្លូវមួយ។ ចង្កៀងចងព្យួរនៅពីលើក្បាលបញ្ចេះពន្លឺពណ៌ខៀវស្រងាត់នាពេលពាក់កណ្តាលអធ្រាត្រ បូកបន្ថែមនឹងពន្លឺទៀនពណ៌ខ្មៅៗមួយពាន់ទៀត។ ដំណកដង្ហើមរបស់ពួកគេបានក្លាយទៅជាផ្សែងអ័ព្ទនៅពីមុខខ្លួន វាហាក់បីដូចជាដើរចូលទៅក្នុងទូទឹកកកអញ្ចឹង។

- តើយើងគួរតែដើរមើលជុំវិញដែររឺទេ?- ហេរីផ្តល់មតិ ដោយហេតុតែចង់កំដៅជើងរបស់វា។

- ប្រយ័ត្នណ៎ា កុំដើរកាត់នរណាម្នាក់ឲ្យសោះ- រ៉ុននិយាយទាំងញញើតញញើម ហើយពួកគេក៏ដើរសសៀរៗតាមគែមឆាករាំ។ ពួកគេដើរកាត់មុខដូនជីស្រងេះស្រងោចមួយក្រុម បុរសដាច់រហែកខោអាវម្នាក់ដែលកំពុងពាក់ច្រវ៉ាក់ ព្រមទាំងបព្វជិតគន្ធាត់ម្នាក់ ត្រូវជាខ្មោចដ៏ស្រស់ស្រាយនៃក្រុមហាហ្វលផ័ហ្វ ដែលកំពុងនិយាយទៅកាន់អប្បប្ញទ្ធិម្នាក់មានព្រួញមួយដោតចេញពីថ្ងាស។ ហេរីមិនភ្ញាក់ផ្អើលទេដែលបានឃើញថា ប្លដឌី បារ៉ុន ខ្មោចក្រុមស្លីតឺរីនស្គមកំព្រឹងៗ ខ្លួនប្រឡាក់សុទ្ធតែស្នាមឈាមពណ៌ប្រាក់ កំពុងតែត្រូវខ្មោចឯទៀតៗព្យាយាមនៅឲ្យឆ្ងាយពីគាត់។

- អូ! ទេ- ហឺម៉ាយអូនីស្រដី ព្រមទាំងទុចដំណើរង៉ក់។ - ត្រលប់ក្រោយវិញ ទៅក្រោយវិញ ខ្ញុំមិនចង់និយាយជាមួយម៉ុននីង មីតថលនោះទេ...

- នរណាគេ?- ហេរីសួរ ខណៈពេលដែលពួកគេដើរមកក្រោយវិញយ៉ាងរហ័សដៃរហ័សជើង។

- នាងគឺជាខ្មោចបង្កន់ក្នុងបន្ទប់ទឹកសិស្សស្រីនៅជាន់ទីមួយ- ហឺម៉ាយអូនីពន្យល់។

- នាងនៅក្នុងបង្គន់?

- ហ្នឹងហើយ។ បង្គន់នោះខូចប្រើមិនកើតពេញមួយឆ្នាំ ដោយសារតែនាងចេះតែមានអារម្មណ៍ឆេវឆាវ ព្រមទាំងធ្វើឲ្យជន់លិចពេញទីកន្លែងទៀតផង។ ប្រសិនបើជៀសរួច ខ្ញុំមិនចូលទៅទីនេះទេ។ វាពិតជាពិបាកនឹងបត់ដៃបត់ជើងណាស់ ពេលដែលនាងយំរៀបរាប់ប្រាប់យើង...

- មើលនុះ! គឺអាហារទេតើ!- រ៉ុនឧទានឡើង។

នៅជ្រុងម្ខាងទៀតនៃបន្ទប់ងងឹត មានតុវែងមួយ ហើយក៏ត្រូវគ្របដណ្ដប់ដោយសំពត់កម្ទីពណ៌ខ្មៅដែរ។ ពួកគេខិតទៅជិតរកមើលអីញ៉ាំទាំងចង់ដឹងចង់ឃើញ ប៉ុន្តែមួយសន្ទុះក្រោយមក ក៏ឈប់ដំណើរភ្លាម ដោយតក់ស្លុតយ៉ាងខ្លាំង។ ក្លិនម្ហូបពិតជាគួរឲ្យខ្ពើមរអើមណាស់។ មានត្រីរលួយៗធំៗនៅលើចានទាបពណ៌ប្រាក់ដ៏ស្អាតសង្ហា។ នំ ធ្យូងខ្មៅៗដែលឆេះងំៗ ត្រូវចាប់ដាក់ទៅលើថាសដាក់ម្ហូបអាហារ។ មានបង្អែមដង្កូវដ៏ធំមួយ បន្ទះប្រូម៉ាសមួយចំនិតដែលដុះផ្សិតពណ៌បៃតងឡើងដូចរោមសត្វ ហើយនិង... ដែលមានសភាពល្អជាងគេក្នុងបន្ទប់នោះ...គឺនំពណ៌ប្រផេះដ៏ធំសម្បើមមានរូបរាងជាថ្មដាក់ក្បាលផ្នូរ ថែមទាំងឆ្លាក់ពីលើដោយពាក្យកករឹងដូចជ័រកៅស៊ូ គឺ៖

លោក នីកូឡាស ឌឺ មីមស៊ី ដបភីជ័តុន

ស្លាប់នៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៤៩២

ហេរីសម្លឹងមើល ដោយភ្ញាក់ផ្អើលទៅកាន់ខ្មោចគន្ធាត់មួយខិតមកជិតតុអាហារ អោនចុះយ៉ាងទាប ហើយក៏ដើរកាត់តុនោះព្រមទាំងប្រហមាត់ធំៗដើម្បីដាក់បញ្ចូលត្រីសូម៉ុងស្អុយមួយក្បាល។

- តើលោកអាចភ្លក្សរសជាតិបានដែរឬ ពេលដើរកាត់ត្រីនោះ?- ហេរីសួរគាត់។

- ស្ទើរតែអាចភ្លក្សបាន- ខ្មោចនោះតបវិញយ៉ាងសោកសង្រេង រួចគាត់ក៏ហោះរសាត់ទៅឆ្ងាយ។

- ខ្ញុំគិតថា ពួកគេច្បាស់ជាទុកឲ្យវាស្អុយរលួយអញ្ចឹងហើយ ដើម្បីឲ្យមានក្លិនខ្លាំង- ហឺម៉ាយអូនីស្រដីធ្វើជាអ្នកចេះដឹង ថែមទាំងយកដៃខ្ទប់ច្រមុះ ហើយអោនទៅមើលបង្អែមរលួយនោះឲ្យបានច្បាស់។

- តើយើងអាចទៅកន្លែងផ្សេងបានដែរឬទេ? ខ្ញុំដូចជាចង់ក្អួតដល់ហើយ- រ៉ុនផ្ដល់យោបល់។

ពួកគេមិនទាន់ទាំងបានបែរខ្លួនមកវិញផង ស្រាប់តែបុរសមាឌល្អិតម្នាក់ហោះឆាបភ្លាមៗពីខាងក្រោមតុ ហើយមកឈប់នៅពីមុខពួកគេតែម្ដង។

- សួស្ដី! ភីវ- ហេរីនិយាយយ៉ាងប្រយ័ត្នប្រយែង។

ខុសពីខ្មោចដទៃទៀតនៅជុំវិញពួកគេ ខ្មោចភីវ មានសភាពផុះដាច់ស្រឡះពីភាពស្លេកស្លាំង និងភាពអាចមើលធ្លុះ។ គាត់កំពុងតែពាក់មួយចូលរួមពិធីពណ៌ទឹកក្រូចខ្ចី ពាក់ក្រវ៉ាត់កដែលចេះបង្វិលចុះឡើង ព្រមទាំងផ្គិតស្នាមញញឹមស្ញេញស្ញាញនៅលើមុខដ៏ពិរុទ្ធយ៉ាងធំទូលាយរបស់គាត់។

- ញ៉ាំអីបន្តិចទេ?- គាត់និយាយយ៉ាងផ្អែមល្ហែម ដោយហុចទៅឲ្យពួកគេនូវចានគ្រាប់សណ្ដែកដុះផ្សិត។

- ទេ អរគុណច្រើន- ហឺម៉ាយអូនីបន្លឺឡើង។

- បានស្ដាប់ឮឯងនិយាយដើមពីមីតថលកំសត់- ភីវស្រដី ដោយភ្នែកចុះឡើង។ - ពិតជាមិនគួរសមទេដែលឯងធ្វើចំពោះមីតថលកំសត់បែបនេះនោះ។- គាត់ដកដង្ហើមមួយយ៉ាងវែង រួចក៏ស្រែកខ្លាំងៗថា៖

- អេ! មីតថល!

- អូ! ទេ ភីវ កុំប្រាប់នាងពីអ្វីដែលខ្ញុំបាននិយាយអី នាងច្បាស់ជានឹងកើតទុក្ខមិនខាន- ហ៊ីម៉ាយអូនីខ្សឹបប្រាប់យ៉ាងប្រញាប់ប្រញាល់។ - ខ្ញុំមិនមានន័យថាដូច្នោះទេ ខ្ញុំមិនប្រកាន់នឹងនាងឡើយ...អឺ សួស្តី មីតថល។

ខ្មោចក្មេងស្រីរាងកន្ទុលក្រអាញបានហោះសំកាំងមក។ នាងមានមុខកើតទុក្ខសោកបំផុត ដែលហេរីមិនដែលធ្លាប់បានឃើញពីមុនមកទេ។ មុខនាងត្រូវបានបិទបាំងពាក់កណ្ដាលពីក្រោយសក់វែងស្រឡូន និងវ៉ែនតាដូចគុជខ្យងដ៏ក្រាស់មួយ។

- ស្អីគេ?- នាងនិយាយទាំងមុខក្រញូវ។

- តើឯងសុខសប្បាយជាទេ មីតថល?- ហ៊ីម៉ាយអូនីសួរ ដោយសំឡេងក្លែងក្លាយដ៏ឆ្លាតវៃ។ - ពិតជារីករាយណាស់ដែលបានជួបឯងនៅក្រៅបង្គន់។

មីតថលដកដង្ហើមមួយខ្សឹត។

- កញ្ញាប្រេ្គនជឺរទើបតែនិយាយដើមអំពីឯងអំបាញ់មិញនេះ...- ភីវបន្លឺឡើងយ៉ាងប៊ិនប្រសប់ដាក់ត្រចៀករបស់មីតថល។

- គ្រាន់តែនិយាយ...និយាយថា...នាងមានរូបរាងស្អាតម្ល៉េះទេនៅយប់នេះ- ហ៊ីម៉ាយអូនីនិយាយ ព្រមទាំងដៀងភ្នែកសំដៅទៅភីវ។

មីតថលសម្លឹងមើលមកហ៊ីម៉ាយអូនីដោយមន្ទិលសង្ស័យ។

- ឯងកំពុងតែយកខ្ញុំមកកំប្លែងលេង- នាងនិយាយ ថែមទាំងមានទឹកភ្នែកពណ៌ប្រាក់រលីងរលោងនៅក្នុងភ្នែកដែលអាចមើលធ្លុះទាំងគូរបស់នាង។

- ទេ...និយាយតាមត្រង់ទៅ...តើខ្ញុំមានបាននិយាយថាតើមីតថលមើលទៅស្អាតប៉ុណ្ណាដែររឺទេ?- ហ៊ីម៉ាយអូនីស្រដី ដោយចាប់អង្រួនឆ្អឹងជំនីររ៉ុន និងហេរីយ៉ាងខ្លាំង។

- អូ! មែនហើយ...

- នាងពិតជា...

- កុំភូតខ្ញុំឲ្យសោះ- មីតថលឧទានឡើងទាំងដង្ហក់ ឯទឹកភ្នែកកំពុងតែជោរជន់លើមុខរបស់នាង ខណៈពេលដែលភីវសើចកក្អឹកយ៉ាងសប្បាយរីករាយពីលើស្មារបស់នាង។ - តើឯងគិតថា ខ្ញុំមិនដឹងពីអ្វីដែលពួកមនុស្សទាំងនោះហៅខ្ញុំពីក្រោយខ្នងរឺ? មីតថលគន្ធាត់! មីតថលគម្រក់! មីតថលវេទនា មីតថលស្រពោន និងចេះតែថ្ងូចថ្ងូរ!

- ឯងភ្លេចពាក្យ "សំបូរមុន" ហើយ- ភីវខ្សឹបដាក់ត្រចៀកនាង។

ម៉ុននីងមីតថលចាប់ផ្ដើមយំខ្សឹកខ្សួលយ៉ាងគួរឲ្យតានតឹងក្នុងចិត្ត ហើយក៏អៀសខ្លួនចេញពីគុកងងឹតនោះទៅ។ ភីវហោះតាមពីក្រោយនាង ព្រមទាំងគប់គ្រាប់សណ្ដែកដុះផ្សិតទៅកាន់នាង និងស្រែកខ្លាំងៗថា៖

- សុទ្ធតែមុន! សុទ្ធតែមុន!

ឥឡូវ នីកស្ទើរផុតក្បាលបានរសាត់កាត់ហ្វូងមនុស្សសំដៅមករកពួកគេ។

- សប្បាយដែររឺទេ?

- អូ! សប្បាយណាស់- ពួកគេកុហក។

- មិនអន់ដែរ- នីកស្ទើរតែគ្មានក្បាលនិយាយយ៉ាងមានមោទនៈ។ - ស្ត្រីមេម៉ាយចេះតែទ្រហោយំម្នាក់នោះមកពី ក្រុងឃិន ឯណោះ...ជិតដល់ពេលឡើងថ្លែងសុន្ទរកថារបស់ខ្ញុំហើយ យកល្អ ខ្ញុំគួរតែទៅដាស់តឿនក្រុមភ្លេងបន្តិចសិន...

ប៉ុន្តែ ស្រាប់តែក្រុមវង់ភ្លេងឈប់លេងនាក្សិណនោះតែម្តង។ ពួកគេ ហើយនិងអ្នករាល់គ្នាឯទៀតនៅក្នុងគុកងងឹតសុទ្ធតែស្ងាត់មាត់ជ្រប ព្រមទាំងសម្លឹងមើលជុំវិញដោយរំជើបរំជួលចិត្ត ខណៈពេលដែលសម្លេងត្រែផ្លុំបញ្ជាក់ពីការដេញប្រមាញ់មួយបន្លឺឡើង។

- អូ! តាំងទៀតហើយ- នីកស្ទើរតែគ្មានក្បាលស្រដីទាំងជូរចត់។

មានសេះខ្មោចដប់ពីរក្បាលផុសចេញពីជញ្ជាំងគុកងងឹត ដែលសេះមួយក្បាលៗសុទ្ធតែមានអ្នកជិះគ្មានក្បាលម្នាក់។ ក្រុមហ្វូងមនុស្សនាំគ្នាទះដៃយ៉ាងខ្លាំងៗ ចំណែកហេរីក៏ចាប់ផ្តើមទះដៃនឹងគេនឹងឯងដែរ ប៉ុន្តែក៏ដាក់ដៃចុះវិញភ្លាមពេលឃើញទឹកមុខរបស់នីក។

សេះទាំងនោះបំផាយខ្លួនចូលទៅចំកណ្តាលវង់រាំ រួចឈប់ព្រឹប ខ្លួនរេថយក្រោយបន្តិចទៅមុខបន្តិច។ នៅពីមុខគេ គឺជាខ្មោចមាឌធំម្នាក់ ដែលកំពុងតែកាន់ក្បាលសុទ្ធតែពុកចង្ការបស់គាត់នៅពីក្រោមដៃ ហើយក៏ជាកន្លែងសម្រាប់គាត់ផ្លុំត្រែដែរ។

ខ្មោចនោះលោតចុះមកក្រោម លើកក្បាលរបស់គាត់ឡើងខ្ពស់ ដើម្បីឲ្យគាត់អាចមើលឃើញហ្វូងមនុស្ស (អ្នករាល់គ្នាផ្ទុះសំណើចចំពោះរឿងនេះ) រួចក៏បោះជំហានវែងៗសំដៅទៅរកនីក ដោយបំពាក់ក្បាលទៅលើកគាត់វិញ។

- នីក!- គាត់គ្រហឹម។ - តើឯងសុខទុក្ខយ៉ាងម៉េចដែរ? ក្បាលនៅតែរណែងរណោងនៅឡើយទេរឺ?

- សូមស្វាគមន៍ ផាទ្រីក- នីកបន្លឺឡើងទាំងទើសទាល់។

- មានពួកមនុស្សមកទៀត!- លោក ផេទ្រីក ឧទានឡើង ពេលបានឃើញ ហេរី រ៉ុន និងហឺម៉ាយអូនី ហើយក៏ធ្វើជាលោតកញ្ឆេងដោយភាពភ្ញាក់ផ្អើល ដែលធ្វើឲ្យក្បាលរបស់គាត់ធ្លាក់ចុះម្តងទៀត (ហ្វូងមនុស្សចាប់ផ្តើមសើចគឹល)។

- ពិតជាពូកែកំប្លែងលេងមែន- នីកស្ទើរតែគ្មានក្បាលនិយាយបែបគំរាមកំហែង។

- កុំប្រកាន់អី នីក!- ក្បាលលោក ផេទ្រីក ស្រែកឡើងពីលើកម្រាល។ - នៅតែកើតទុក្ខមិនសុខចិត្តនឹងពួកយើងមិនឲ្យចូលរួមក្នុងក្រុមប្រមាញ់ទៀតរឺ! ប៉ុន្តែខ្ញុំចង់បានន័យថា...មើលគូកនយើងទៅមើល...

- ខ្ញុំគិតថា- ហេរីនិយាយយ៉ាងប្រញាប់ប្រញាល់ ពេលបានឃើញទឹកមុខបង្កប់ដោយអត្ថន័យរបស់នីកបាញ់ឆ្ពោះមករកវា។ - នីកពិតជា...ភិតភ័យ ហើយ...អឺ...

- ហា!- ក្បាលរបស់លោក ផេទ្រីក ស្រែក។ - ហ៊ានភ្នាល់ថា គាត់ច្បាស់ជាស្នើសុំឲ្យឯងនិយាយដូច្នោះហើយ!

- ប្រសិនបើអ្នករាល់គ្នាមិនយល់ទាស់អ្វីទេ ខ្ញុំគិតថាដល់ពេលដែលត្រូវថ្លែងសុន្ទរកថារបស់ខ្ញុំហើយ!- នីកស្ទើរតែគ្មានក្បាលឧទានឡើងខ្លាំងៗ រួចបោះជំហានវែងៗសំដៅទៅរកវេទិកា ហើយឡើងទៅលើឆាកបំភ្លឺដោយភ្លើងពណ៌ខៀវព្រោងព្រាត។

- អស់លោក លោកស្រី អ្នកនាងកញ្ញា ខ្ញុំពិតជាមានសេចក្តីសោកស្តាយយ៉ាងខ្លាំង....

ប៉ុន្តែគ្មាននរណាម្នាក់យកត្រចៀកស្តាប់ទៀតទេ។ លោក ផាទ្រីក ហើយនិងខ្មោចដទៃទៀតក្នុងក្រុមប្រមាញ់គ្មានក្បាលស្រាប់តែចាប់ផ្តើមលេងល្បែង ដេញចាប់ក្បាល ហើយហ្វូងខ្មោចនាំគ្នាម្នីម្នាមកមើលទាំងអស់។ នីកស្ទើរតែគ្មានក្បាលព្យាយាមទាំងឥតអំពើដើម្បីទាក់ទាញអារម្មណ៍ទស្សនិកជនរបស់គាត់ ប៉ុន្តែក៏សម្រេចចិត្តបោះបង់ចោល ខណៈដែលក្បាលរបស់លោក ផាទ្រីកហោះវែរកាត់ពីមុខគាត់ បណ្តាលឲ្យមានសម្រែកហូរកញ្ជ្រៀវយ៉ាងខ្លាំង។

ហេរីពិតជាត្រជាក់ណាស់នាពេលឥឡូវនេះ នេះមិនទាំងនិយាយអំពីគំលានផង។

- ខ្ញុំទ្រាំមិនបានទៀតទេ- រ៉ុនអ៊ូរទាំតិចៗដោយសង្កៀតធ្មេញ ខណៈពេលដែលក្រុមវង់ភ្លេងចាប់ផ្ដើមសំដែងឡើងវិញ រីឯពួកខ្មោចក៏នាំគ្នាត្រលប់មករាំលើឆាក។

- តោះទៅ- ហេរីយល់ស្របតាម។

ពួកគេនាំគ្នាដើរថយក្រោយសំដៅមករកទ្វារចេញ ព្រមទាំងងក់ក្បាល និងសើចញឹមៗដាក់នរណាក៏ដោយដែលសម្លឹងមើលមកពួកគេ ហើយមួយនាទីក្រោយមក ពួកគេក៏ប្រញាប់ប្រញាល់ឡើងមកផ្លូវរបៀង ដែលពោរពេញដោយទានពណ៌ខ្មៅវិញ។

- បង្អែមលាងមាត់ប្រហែលជាមិនទាន់ចប់នៅឡើយទេ- រ៉ុនបន្លឺឡើងដោយក្ដីសង្ឃឹម ដោយដឹកនាំផ្លូវឡើងកាំជណ្ដើរទៅកាន់ច្រកចូលសាល។

ហើយបន្ទាប់មក ហេរីបានឮសំឡេងនោះទៀត។

- *...ចិញ្ច្រាំ...ហែក...សម្លាប់...*

វាគឺជាសម្លេងចង់អាឃាតដ៏សោះកក្រោះ ដូចគ្នាទៅនឹងសំឡេងដែលវាបានឮនៅក្នុងការិយាល័យរបស់លោក ឡក់ហាត។

វាបញ្ឈប់ដំណើរភ្លាម រួចផ្អឹបខ្លួនទៅនឹងជញ្ជាំងថ្ម ហើយខំត្រងត្រាប់ស្ដាប់ ក្រោយមកក៏សម្លឹងមើលជុំវិញ ព្រមទាំងមៀងមើលចុះឡើងផ្លូវរបៀងដែលបំភ្លឺឡើងព្រាលៗ។

- ហេរី តើឯង...?

- ខ្ញុំឮសំឡេងនោះម្ដងទៀតហើយ...ឈប់និយាយមួយភ្លែតសិនទៅ...

- *...ស្រេកឃ្លានណាស់...អស់ពេលជាយូរមកហើយ...*

- ស្ដាប់ទៅមើល!- ហេរីឧទានឡើងជាបន្ទាន់ ហើយ រ៉ុន និង ហឺម៉ាយអូនីឈរស្ងៀមទ្រឹងតាមសម្លឹងមើលវា។

- *....សម្លាប់...ដល់ពេលត្រូវសម្លាប់ហើយ...*

សំឡេងនោះកាន់តែរសាត់ទៅឆ្ងាយ។ ហេរីប្រាកដក្នុងចិត្តណាស់ថា វាធ្វើដំណើរទៅឆ្ងាយហើយ...គឺធ្វើដំណើរឡើងទៅលើ។ ភាពច្របូកច្របល់រវាង សេចក្ដីភ័យខ្លាច និង ក្ដីរំភើប បានបុកផ្ទប់នឹងសតិរបស់វា ខណៈពេលដែលវាសម្លឹងមើលមិនដាក់ភ្នែកឯពិតានងងឹតស្លុងនោះ៖ តើវាធ្វើចលនាទៅលើយ៉ាងម៉េចនឹងកើតទៅ? តើវាជាខ្មោចរឺ បានជាពិតានថ្មមិនមែនជាឧបសគ្គចំពោះវា?

- តាមផ្លូវនេះ- វាស្រែក ហើយក៏ចាប់ផ្ដើមរត់ គឺរត់ឡើងតាមជណ្ដើរ សំដៅទៅកាន់ច្រកចូលសាល។ គ្មានប្រយោជន៍អ្វីនឹងសង្ឃឹមថាបានស្ដាប់ឮសម្លេងអ្វីទៀតនៅទីនេះនោះទេ ពីព្រោះតែការនិយាយប៉ប៉ាច់ប៉ប៉ោចក្នុងពិធីជប់លៀងបុណ្យហាឡូវីនកំពុងតែរំពងឡើងទ្រហឹងអឺងកងពេញមហាសាលទៅហើយនោះ។ ហេរីឈានជើងឡើងតាមជណ្ដើរធ្វើពីថ្មកែវទៅជាន់ទីមួយ ដោយមានរ៉ុន និងហឺម៉ាយអូនីរត់ត្រឹកៗពីក្រោយ។

- ហេរី តើពួកយើង...

- ស្ហូ!

ហេរីប្រុងចាំស្ដាប់។ វាស្ដាប់ឮសំឡេងនោះទៀត យ៉ាងសែនឆ្ងាយ បន្លឺចេញពីជាន់ខាងលើ ហើយកាន់តែខ្សោយទៅៗ៖

- *...ខ្ញុំធុំក្លិនឈាម...ខ្ញុំធុំក្លិនឈាម!*

ពោះរបស់វាដូចជាត្រូវទ្រេតទៅម្ខាង...

- វានឹងសម្លាប់នរណាម្នាក់ហើយ!- ហេរីស្រែក ហើយដោយមិនរវីរវល់នឹងទឹកមុខស្រឡាំងកាំងរបស់រ៉ុន និងហឺម៉ាយអូនី វាក៏រត់ត្រុយឡើងកាំជណ្ដើរទៅជាន់ខាងលើ ដោយរំលងម្ដងបីកាំ ព្រមទាំងព្យាយាមផ្ទៀងត្រចៀកស្ដាប់សម្លេងមួយផ្សេងពីស្នូរជើងតតូងតតាងរបស់វា...

ហេរីរត់យ៉ាងញាប់ជើងជុំវិញជាន់ទីពីរទាំងមូល ព្រមទាំងមានរ៉ុន និងហឺម៉ាយអូនីរត់ទាំងហត់គយូសតាមពីក្រោយវា ហើយមិនព្រមឈប់ឡើយ រហូតដល់ពួកគេកាច់ជ្រុងមួយទៅក្នុងច្រកដែលគ្មានមនុស្សចុងក្រោយបង្អស់។

- ហេរី តើរឿងទាំងអស់ហ្នឹងវាយ៉ាងម៉េចទៅ?- រ៉ុនបន្លឺឡើង ព្រមទាំងជូតញើសចេញពីមុខរបស់វា។ - ខ្ញុំស្ដាប់មិនឮអ្វីនោះទេ...

ប៉ុន្ដែហឺម៉ាយអូនីរកខ្យល់គក្លាមមួយរំពេច ដោយចង្អុលទៅច្រករបៀង។

មានអ្វីម្យ៉ាងកំពុងតែបញ្ចេញរស្មីនៅលើជញ្ជាំងខាងមុខ។ ពួកគេបានដើរខិតទៅជិតយ៉ាងយឺតៗ ដោយម៉ៀងមើលចុះឡើងស្មែអន្ធការ។ ពាក្យកំពស់ប៉ុន្មានហ្វីត ត្រូវបានគេប៉ាតជាអក្សរនៅលើជញ្ជាំង ចន្លោះបង្អួចពីរ ដែលចាំងព្រឹមៗក្រោមពន្លឺ បង្កឡើងពីចន្លុះឆេះភ្លើងសន្ធោសន្ធៅនៅទាំងសងខាង។

## បន្ទប់សម្ងាត់ត្រូវបានបើកហើយ។ ពួកដែលជាសត្រូវរបស់ជាយាទ ចូរប្រយ័ត្នខ្លួនទៅ។

- តើនោះជាអ្វី...ព្យួរបន្ដោកពីខាងក្រោមនុះ?- រ៉ុនសួរ ប្រកបដោយសម្លេងរាងញ័រៗបន្ដិច។

ខណៈពេលដែលពួកគេ រំកិលជើងទៅជិតជាងមុន ហេរី ស្ទើរតែរអិលជើងដួល...មានគ្រលុកទឹកដ៏ធំមួយនៅលើកំរាល។ រ៉ុន និង ហឺម៉ាយអូនី ចាប់ដៃវា ហើយពួកគេក៏បង្ខិតខ្លួនចូលទៅជិតសារនោះ ដោយផ្ដោតក្រសៃភ្នែកសម្លឹងជាប់ទៅនឹងស្រមោលងងឹតមួយពីខាងក្រោមវា។ ពួកគេទាំងបីនាក់ដឹងថាវាជាអ្វីភ្លាមមួយរំពេច ហើយក៏លោតមកក្រោយវិញ ធ្វើឲ្យសាចទឹកប្រាវ...អ្នកស្រីណូរីស ដែលត្រូវជាឆ្មារបស់ឆ្មាំយាម កំពុងតែចងព្យួរកន្ទុយរបស់វាពីកន្ត្រកដាក់ចន្លុះ។ វានៅរឹងឆ្អឹតដូចជាបន្ទះក្ដារ ចំណែកភ្នែករបស់វាបើកធំៗ និងសម្លឹងមើលមិនព្រិចទាល់តែសោះ។

អស់ប៉ុន្មានវិនាទីក្រោយមក ពួកគេមិនកំរើកខ្លួនសូម្បីតែបន្ដិច។ បន្ទាប់មក រ៉ុនក៏បន្លឺឡើងថា៖

- តោះ! ឆាប់ចេញពីទីនេះទៅ។

- ម៉េចក៏ពួកយើងមិនសាកជួយសិនទៅមើល៍- ហេរីផ្ដើមឡើងទាំងឆ្គាំឆ្គង។

- ជឿខ្ញុំចុះ- រ៉ុនពោល។ - ពួកយើងមិនចង់ឲ្យគេប្រទះឃើញនៅទីនេះទេ។

ប៉ុន្ដែវាហួសពេលទៅហើយ។ ដំណើរលាន់ឮសូរសន្ធឹក ប្រៀបបាននឹងផ្គរលាន់ពីចម្ងាយ បានប្រាប់ពួកគេថា ពិធីជប់លៀងទើបតែបានបញ្ចប់ទៅអំបាញ់មិញនេះឯង។ ពីចុងទាំងសងខាងនៃផ្លូវរបៀង ចំកន្លែងដែលពួកគេកំពុងឈរ មានឮសម្លេងជើងរាប់រយបន្លឺឡើង ពេលពួកកូនសិស្សប្រទាក់ប្រតោងគ្នាឡើងជណ្ដើរ ព្រមគ្នានឹងសំឡេងជជែកគ្នាយ៉ាងសប្បាយរីករាយរបស់មនុស្សដែលឆ្អែតប៉ោងពោះ។ ពេលមួយសន្ទុះក្រោយមក ពួកកូនសិស្សចាប់ផ្ដើមសំរុកគ្នាចូលទៅក្នុងច្រកផ្លូវនោះពីចុងទាំងសងខាង។

ការជជែកគ្នា ភាពពពាក់ពពូនគ្នា ហើយនិងសំឡេងអ៊ូអរត្រូវស្ងប់បាត់ភ្លាមៗ ពេលដែលជួរមនុស្សនៅខាងមុខគេ បានពើបប្រទះនឹងឆ្មាកំពុងតែត្រូវចងព្យួរបន្ដោកយ៉ាងដូច្នេះ។ ហេរី រ៉ុន និង ហឺម៉ាយអូនី ឈរនៅទីនោះតែបីនាក់គត់ គឺនៅចំកណ្ដាលច្រក

របៀង ខណៈដែលភាពស្ងប់ស្ងាត់បានសាយភាយទៅក្នុងចំនោមក្រុមហ្វូងមនុស្ស ដែលកំពុងតែប្រជ្រៀតគ្នាចុះឡើង ដើម្បីតែមកមើលទស្សនីយភាពដ៏គួរឲ្យខ្ពើមរអើមនេះ។

បន្ទាប់មក មាននរណាម្នាក់ស្រែកបំបែកភាពស្ងៀមស្ងាត់។

- ពួកដែលជាសត្រូវរបស់ទាយាទ ចូរប្រយ័ត្នខ្លួនទៅ! ពួកឯងនឹងជាអ្នកបន្ទាប់ហើយ អាពួកឈាមកខ្វក់!

នោះគឺ ដ្រាកូ មេលហ្វ័យ។ វាបានប្រជ្រៀតខ្លួនទៅខាងមុខហ្វូងមនុស្ស ភ្នែករបស់វាឡើងរស់រវើក រីឯមុខគ្មានឈាមជាធម្មតារបស់វាបែរជាឡើងពណ៌ ខណៈពេលដែលវាញញឹមស្ញេញដាក់រូបភាពនៃឆ្មាព្យួរបញ្ច្រាស់ដែលនៅនឹងថ្កល់។

វគ្គ IX



# សំណោះលើជញ្ជាំង

- តើមានបញ្ហាអីនៅទីនេះ? តើមានរឿងអ្វីកើតឡើង?

ដោយទទួលការចាប់អារម្មណ៍ពីសម្រែករបស់មេលហ្វ៊យទាំងឥតមន្ទិលសង្ស័យអ្វី អារហ្គូស ហ្វីលច្ចក៏យកស្មារែកផ្លូវឆ្លងកាត់ហ្វូងមនុស្ស។ បន្ទាប់មក គាត់ក៏ឃើញអ្នកស្រីណូរីស រួចក៏ថយក្រោយវិញ ថែមទាំងយកដៃខ្ទប់មុខយ៉ាងណែនដោយស្លុតអារម្មណ៍ ។

- ឆ្មាខ្ញុំ! ឆ្មារបស់ខ្ញុំ! តើមានអ្វីកើតឡើងចំពោះអ្នកស្រី ណូរីស?- គាត់ស្រែកសួរ។

ហើយភ្នែកដែលលៀនចេញមកក្រៅរបស់គាត់បង្វែរមកចំហេរី។

- គឺឯង!- គាត់ឧទានឡើង។ - គឺឯង! ឯងបានធ្វើឃាតឆ្មារបស់ខ្ញុំ! ឯងបានសម្លាប់វា! ខ្ញុំនឹងសម្លាប់ឯង! ខ្ញុំនឹង...

- អារហ្គូស!

លោក ដាំប័លដ័របានមកដល់កន្លែងកើតហេតុ ព្រមទាំងមានគ្រូដទៃទៀតមកតាមពីក្រោម។ ពេលមួយភ្លែតនោះ គាត់បានគ្រវាសភ្នែកមើលមកហេរី រ៉ុន និងហឺម៉ាយអូនី រួចស្រាយអ្នកស្រីណូរីសចេញពីកន្ត្រកដាក់ចន្លុះ។

- មកតាមខ្ញុំ អារហ្គូស! - គាត់និយាយទៅកាន់ ហ្វីលច្ច។ - ពួកឯងក៏អញ្ចឹងដែរ លោកផោតធ័រ លោកវីស្លី និងកញ្ញាហ្គ្រេនជឺរ។

ឡក់ហាតបោះជំហានមកមុខទាំងងឿងឆ្ងល់។

- ការិយាល័យរបស់ខ្ញុំនៅជិតជាងគេ លោកនាយក...គឺនៅជាន់លើនេះឯង...សូមអញ្ជើញចុះ...

- អរគុណលោកហើយ ហ្គីលដឺរ័យ- ដាំប័លដ័រតប។

ហ្វូងមនុស្សដ៏ស្ងៀមស្ងាត់ចាប់ផ្តើមបំបែកគ្នាដើម្បីឲ្យពួកគេឆ្លងកាត់។ ឡក់ហាត ដែលមើលទៅដូចជារំភើបចិត្ត និងធ្វើឬកក្អេងក្អាង ដើរយ៉ាងប្រញាប់ប្រញាល់តាមពីក្រោយលោក ដាំប័លដ័រ ចំនែក សាស្ត្រាចារ្យ ម៉ាកហ្គូណាហ្កាល និងស្នេពក៏ធ្វើដូច្នេះដែរ។

ខណៈពេលដែលពួកគេដើរចូលទៅក្នុងការិយាល័យងងឹតស្លុងរបស់ឡក់ហាត ស្រាប់តែមានចលនាបែបភ្ញាក់ភ្លាមៗកើតឡើងនៅតាមជញ្ជាំង។ ហេរី ឃើញរូបលោក ឡក់ហាត ជាច្រើននៅក្នុងស៊ុមរូបថតគេចចេញពីក្រសែភ្នែក ថែមទាំងមានប្រដាប់ម្ចូរ

សក់នៅពីលើក្បាលផង។ លោក ឡក់ហាត ពិតប្រាកដបានបញ្ឆោះទៀននៅលើតុការិយាល័យរបស់គាត់ ហើយឈរទៅក្រោយ។ លោក ដាំប័លដ័រ បានផ្ដេកអ្នកស្រីណូរីសនៅលើផ្ទៃតុដ៏រលោងស្រិល ហើយចាប់ផ្ដើមពិនិត្យពិច័យវា។ ហេរី រ៉ុន និងហឺម៉ាយអូនី សម្លឹងមើលគ្នាទៅវិញទៅមកដោយធ្វើទឹកមុខតឹងតែង ហើយក៏ទម្លាក់ខ្លួនទៅលើកៅអីនៅក្រៅរង្វង់នៃពន្លឺទៀន ដោយពន្លៃកតាមមើល។

ចុងច្រមុះសេកដ៏វែងរបស់ ដាំប័លដ័រ នៅមិនដល់មួយអ៊ីងពីរោមអ្នកស្រីណូរីសផង។ គាត់កំពុងតែសម្លឹងមើលវាយ៉ាងជិតដិតតាមរយៈវ៉ែនតារាងចំណិតខែរបស់គាត់ ព្រមទាំងម្រាមដៃវែងៗរបស់គាត់ចាក់ថ្នមៗ។ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គលបង្អោនខ្លួនស្ទើរតែទៅប៉ះ ដោយបង្រួញកែវភ្នែករបស់គាត់។ ស្នេពវិញ លេចឡើងស្ងងៗពីខាងក្រោយពួកគាត់ ឯខ្លួនគាត់ពាក់កណ្ដាលត្រូវបាំងដោយស្រមោលអន្ធការ ថែមទាំងមានទឹកមុខយ៉ាងចម្លែកបំផុតខុសពីប្រក្រតី៖ មើលទៅ ហាក់ដូចជាគាត់កំពុងតែព្យាយាមយ៉ាងខ្លាំងដើម្បីទប់ខ្លួនឯងមិនឲ្យញញឹម។ រីឯលោក ឡក់ហាត កំពុងតែដើរក្រវែលចុះឡើងនៅជុំវិញពួកគេទាំងអស់គ្នា ដោយផ្ដល់ជាយោបល់ប៉ប៉ាច់ប៉ប៉ោចឥតឈប់។

- វាច្បាស់ជាបណ្ដាសាមួយហើយ ដែលបានសម្លាប់វានោះ...ប្រហែលជាត្រូវអាគមបំផ្លាញព្រលឹង...ខ្ញុំធ្លាប់ឃើញអាគមហ្នឹងត្រូវបានគេប្រើប្រាស់ជាច្រើនដង ពិតជាស៊យមែនដែលខ្ញុំមិននៅទីនោះ ខ្ញុំដឹងបាលីប្រឆាំងដែលអាចនឹងជួយសង្គ្រោះជីវិតវាបាន...

ឃ្លាប្រយោគរបស់ ឡក់ហាត ត្រូវគួបផ្សំបន្ថែមទៅដោយការយំខ្សឹកខ្សួលយ៉ាងឈឺចាប់ ដែលគ្មានទឹកភ្នែកស្រក់របស់ហ្វីលច្ឆ។ គាត់អង្គុយចាក់ឫសលើកៅអីមួយក្បែរតុការិយាល័យ ដោយមិនហ៊ានសម្លឹងមើលមកអ្នកស្រី ណូរីស ព្រមទាំងយកដៃខ្ទប់មុខជិត។ ទុកជាវាស្អប់ខ្ពើមហ្វីលច្ឆខ្លាំងយ៉ាងណា ក៏ហេរីមិនអាចទប់ចិត្តមិនមានអារម្មណ៍សោកស្ដាយបន្តិចបន្តួចជំនួសគាត់បានដែរ ទោះជាសេចក្ដីសោកស្ដាយនេះមិនស្មើនឹងទុក្ខរបស់វាយ៉ាងណាក្ដី។ ប្រសិនបើលោក ដាំប័លដ័រជឿហ្វីលច្ឆមែននោះ វាមុខជានឹងត្រូវបណ្ដេញចេញពីសាលាជាក់ជាមិនខាន។

លោក ដាំប័លដ័រ ឥឡូវគាត់កំពុងតែនិយាយរង្វើវៗនូវពាក្យចម្លែកៗ ហើយគោះអ្នកស្រីណូរីសតិចៗនឹងចង្កឹះវេទមន្តរបស់គាត់ ប៉ុន្តែគ្មានអ្វីកើតឡើងនោះទេ៖ វានៅតែមើលទៅដូច ទើបតែត្រូវគេចាប់គ្រញេចងាប់អំបាញ់មិញដដែល។

- ...ខ្ញុំនៅចាំរឿងមួយស្រដៀងនឹងស្ថានភាពបែបនេះ ដែលកើតឡើងនៅ អូអាហ្កាដូហ្គូ - លោកឡក់ហាតបន្លឺឡើង - ជាការវាយប្រហារស៊េរីជាមួយគ្នាហ្នឹងឯង ហើយសុទ្ធតែមានចារនៅក្នុងសៀវភៅជីវប្រវត្តិរបស់ខ្ញុំទាំងអស់ ខ្ញុំ បានផ្ដល់ឲ្យអ្នកក្រុងនូវអាគមគាថាសម្រាប់ការពារជាច្រើនផ្សេងៗគ្នា ដែលសុទ្ធតែបានដោះស្រាយបញ្ហាទាំងអស់អោយជ្រះស្រឡះភ្លាមៗតែម្ដង...

រូបថតរបស់លោក ឡក់ហាត នៅលើជញ្ជាំងសុទ្ធតែងក់ក្បាលយល់ស្របតាម ខណៈពេលដែលគាត់និយាយ។ ម្នាក់ក្នុងចំណោមពួកគេភ្លេចដោះស្បោងគ្របសក់ចេញទៀតផង។

ចុងបញ្ចប់ លោក ដាំប័លដ័រ ក៏ងើបឈរឡើងត្រង់ខ្លួន។

- វាមិនទាន់ងាប់ទេ អារហ្គូស- គាត់និយាយយ៉ាងទន់ភ្លន់។

ឡក់ហាតទុចដំណើរង៉ក់ពេលកំពុងរាប់ម្រាមដៃគិតអំពីចំនួនឃាតកម្មដែលគាត់បានដោះស្រាយ។

- មិនទាន់ងាប់រឺ? - ហ្វីលច្ឆឧទានទាំងឈ្លក់ ព្រមទាំងសម្លឹងមើលទៅអ្នកស្រីណូរីសតាមចន្លោះម្រាមដៃរបស់គាត់។ - ចុះហេតុអ្វីបានជាវានៅរឹងឆ្អឹតដូចកកអ៊ីចឹង?

- វាត្រូវគេដាក់បាលីបង្អក- ដាំប័លដ័រពោល ( - អា! ខ្ញុំក៏គិតអញ្ចឹងដែរ - ឡក់ហាតនិយាយ)។ - ប៉ុន្តែដោយរបៀបណានោះ គឺខ្ញុំមិនអាចនិយាយបានទេ...

- សួរវាទៅ!- ហ្វីលច្ជស្រែកដាក់ ដោយបែរមុខជោកជាំដោយទឹកភ្នែក និងមានស្នាមជាំ សំដៅទៅកាន់ហេរី។

- គ្មានសិស្សឆ្នាំទីពីរណាអាចធ្វើរឿងនេះបានឡើយ - ដាំប័លដ័រប្រកាសក្តែងៗ។ - ច្បាស់ជាអ្នកចេះអាគមងងឹតដល់កំរិតកំពូលហើយទើបអាចធ្វើទៅកើត...

- វាជាអ្នកធ្វើ ! វាបានធ្វើវាច្បាស់ណាស់! - ហ្វីលច្ជនិយាយឡើងញាប់មាត់ដោយក្តៅក្រហាយ។ - លោកក៏បានឃើញពីអ្វីដែលវាបានសរសេរនៅលើជញ្ជាំងដែរ! វាបានរកឃើញ...នៅក្នុងការិយាល័យរបស់ខ្ញុំ...វាដឹងថាខ្ញុំគឺជា...ខ្ញុំជា... - មុខរបស់ហ្វីលច្ជស្តែងឡើងយ៉ាងគួរឲ្យខ្លាច។ - វាដឹងថាខ្ញុំជាជនអវេទ!- គាត់បញ្ចប់ប្រយោគ។

- ខ្ញុំមិនដែលបានប៉ះអ្នកស្រីណូរីសទេ! - ហេរីស្រដីយ៉ាងខ្លាំងៗ ដោយដឹងច្បាស់ថាអ្នករាល់គ្នាបែរក្រសែភ្នែកសម្លឹងមកវាយ៉ាងគួរឲ្យរំខាន រួមមានទាំងរូបរបស់លោក ឡក់ហាត ទាំងអស់នៅលើជញ្ជាំងថែមទៀត។ - ខ្ញុំមិនដឹងថាជនអវេទនោះយ៉ាងម៉េចផង។

- កុំនិយាយពាសវាលពាសកាលពេក!- ហ្វីលច្ជកគំហកដាក់។ - វាបានឃើញសំបុត្របាលីងាយរៀនរបស់ខ្ញុំ!

- បើតាមគំនិតរបស់ខ្ញុំ លោកនាយក - ស្នេពបន្លឺសម្លេងឡើងចេញពីស្បែអន្ធការ ហើយ ហេរីក៏ដឹងភ្លាមថារឿងអពមង្គលច្បាស់ជាកើតឡើងក្នុងពេលឆាប់ៗនេះហើយ។ វាច្បាស់ក្នុងចិត្តណាស់ថា គ្មានអ្វីដែលស្នេពនិយាយនឹងធ្វើឲ្យវាល្អនោះទេ។

- ផោតធ័រ និងមិត្តភក្តិរបស់វា ប្រហែលជាគ្រាន់តែមកស្ថិតក្នុងកន្លែងមិនត្រឹមត្រូវ និងនៅពេលវេលាមិនសមរម្យ ប៉ុណ្ណោះ- គាត់និយាយ ព្រមទាំងមានស្នាមញញឹមមើលងាយបន្តិចប្រាកដឡើងចេញពីមាត់របស់គាត់ ហាក់បីដូចជាគាត់សង្ស័យខ្លាចគេឃើញ។ - ប៉ុន្តែពួកយើងពិតជាមានចំនុចដែលគួរឲ្យសង្ស័យច្រើនណាស់នៅត្រង់កន្លែងនេះ។ តើហេតុអ្វីបានជាវាបែរជាត្រូវនៅផ្លូវរបៀងជាន់ខាងលើទៅវិញ? ហេតុអ្វីបានជាវាមិននៅចូលរួមក្នុងពិធីជប់លៀងបុណ្យហាឡូវីនទៅ?

ហេរី រ៉ុន និងហឺម៉ាយអូនីក៏ចាប់ផ្តើមមូលមតិគ្នាពន្យល់រៀបរាប់អំពីពិធីជប់លៀងបុណ្យសព។

-...មានខ្មោចរាប់សិបនាក់ ពួកគេទាំងអស់គ្នាសុទ្ធតែអាចធ្វើជាសាក្សីថាពួកយើងបានទៅទីនោះ...

- ប៉ុន្តែហេតុអីក៏មិនចូលរួមក្នុងពិធីជប់លៀងនាពេលក្រោយមកទៅ? - ស្នេពចោទសួរ រីឯភ្នែកពណ៌ខ្មៅរបស់គាត់ចាំងពន្លឺព្រិចៗដោយសារពន្លឺភ្លៀងទៀន។ - តើហេតុអ្វីបានជាឡើងទៅផ្លូវរបៀងនោះទៅវិញ?

រ៉ុន និងហឺម៉ាយអូនីសម្លឹងមកហេរី។

- ពីព្រោះ...ពីព្រោះថា... - ហេរីនិយាយ បេះដូងរបស់វាលោតកន្ត្រាក់យ៉ាងលឿន។ មានអ្វីម្យ៉ាងបានប្រាប់វាថា ស្តាប់មើលទៅហាក់ដូចជាវែងឆ្ងាយពេកហើយ ប្រសិនបើវាប្រាប់ពួកគេថា វាត្រូវបាននាំផ្លូវទៅកាន់ទីនោះ ដោយសារតែសម្លេងគ្មានរូបរាងដែលគ្មាននរណាម្នាក់ក្រៅអំពីវាអាចស្តាប់ឮ - គឺដោយសារតែពួកយើងអស់កម្លាំង ហើយចង់ទៅដេក- វាស្រដី។

- ទាំងមិនញុំាអាហារពេលយប់រឺ? - ស្នេពបន្លឺឡើង ព្រមទាំងមានស្នាមញញឹមជោគជ័យមួយលេចឡើងសន្សឹមៗពីលើមុខដ៏ស្គមកំព្រឹងរបស់គាត់។ - ខ្ញុំមិនគិតថា ពួកខ្មោចផ្តល់ម្ហូបអាហារសម្រាប់មនុស្សនៅរស់ឯពិធីជប់លៀងរបស់ពួកគេទេ។

- ពួកយើងមិនឃ្លានទេ- រ៉ុនឧទានឡើងយ៉ាងខ្លាំងៗ ស្រាប់តែពោះរបស់វាចាប់ផ្តើមកូរជាខ្លាំង។

ស្នាមញញឹមដ៏កាចរបស់ស្នេពកាន់តែពង្រីកធំឡើង។

- លោកនាយក ខ្ញុំសន្មតថា ផោតផ័រមិននិយាយការពិតទាំងស្រុងនោះទេ - គាត់ពោល។ - ប្រហែលជាគំនិតល្អមួយ ប្រសិនបើដកហូតអភ័យឯកសិទ្ធិសំខាន់ៗរបស់វា រហូត ទាល់តែវាប្រាប់យើងនូវរឿងរ៉ាវទាំងមូល។ បើតាមគំនិតផ្ទាល់ខ្លួន ខ្ញុំមានអារម្មណ៍ថា វាគួរតែត្រូវដកចេញពីក្រុមកីឡាឃ្វីដឌីច្ច រហូតដល់ពេលដែលវាព្រមនិយាយដោយស្មោះត្រង់។

- តាមពិតទៅ សេវេរូស - សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលបន្លឺឡើងយ៉ាងច្បាស់ៗ - ខ្ញុំនឹកមិនឃើញនូវមូលហេតុ ដែលត្រូវបញ្ឈប់ក្មេងប្រុសនេះមិនអោយចូលលេងកីឡាឃ្វីដឌីច្ចនោះទេ។ ឆ្មានេះមិនមែនត្រូវវាយចំក្បាលនឹងដងអំបោសឯណា។ គ្មានភ័ស្តុតាងណាដែលអាចបញ្ជាក់បានថា ផោតផ័រ បានធ្វើអ្វីខុសនោះទេ។

លោក ដាំប័លដ័រ បានសម្លឹងមើលសព្វខ្លួនហេរី។ ការសម្លឹងមើលនឹងកែវភ្នែកពណ៌ខៀវខ្ចីចាំងពន្លឺភ្លឺផ្លេករបស់គាត់ធ្វើឲ្យហេរីមានអារម្មណ៍ថា គាត់មើលវាធ្លុះទៅដល់ឆ្អឹងខ្នងឯណោះ។

- គ្មានទោសពៃអ្វីឡើយ រហូតដល់មានតឹកតាងបញ្ជាក់ថាមានទោសណា៎ សេវេរូស- គាត់ស្រដីយ៉ាងមាំទាំ។

ស្នេពមើលទាំងដូចជាខឹងសម្បា។ ឯហ្វីលច្ឆវិញក៏ដូចគ្នាដែរ។

- ឆ្មារបស់ខ្ញុំត្រូវគេដាក់បាលីបង្កកណា៎! - គាត់ស្រែកក្តែងៗ ភ្នែករបស់គាត់លៀនចេញមក។ - ខ្ញុំចង់ឃើញការដាក់ពិន័យខ្លះ!

- ពួកយើងគង់តែនឹងអាចព្យាបាលវាបានទេ អារហ្គូស- ដាំប័លដ័របន្លឺឡើងយ៉ាងអត់ធ្មត់។ - ថ្មីៗនេះ សាស្ត្រាចារ្យសប្រ៉ោតលៃលករកបានគ្រាប់ពូជ ម៉ានឌ្រែក ខ្លះហើយ។ តែកាលណាវាធំពេញវ័យ ខ្ញុំនឹងបេះផ្លែរបស់វាយកទៅធ្វើថ្នាំ ដែលនឹងធ្វើឲ្យអ្នកស្រីណូរីសដឹងខ្លួនឡើងវិញ។

- ទុកភារកិច្ចហ្នឹងឲ្យខ្ញុំចុះ- ឡក់ហាតលូកមាត់។ - ខ្ញុំប្រាកដជាបានធ្វើរឿងរបៀបៗនេះមួយរយដងរួចមកហើយ។ ខ្ញុំអាចកូរថ្នាំប្រស់បណ្តឹងខ្លួនម៉ានឌ្រែកទៅក្នុង...

- សូមអភ័យទោស- ស្នេពនិយាយយ៉ាងសោះកក្រោះ។ - ប៉ុន្តែខ្ញុំជឿជាក់ថា ខ្ញុំទេដែលជាគ្រូឱសថប្រចាំសាលានេះ។

មានការបង្អាក់ដ៏មិនសមរម្យមួយកើតឡើង។

- ពួកឯងអាចទៅបានហើយ- លោកដាំប័លដ័រស្រដីទៅកាន់ហេរី រ៉ុន និងហឺម៉ាយអូនី។

ពួកគេក៏ចាកចេញទៅ គឺចេញទៅឲ្យបានឆាប់តាមដែលពួកគេអាចធ្វើបានដោយធ្វើជាមិនរត់។ នៅពេលដែលពួកគេឡើងដល់ជាន់មួយនៅពីលើការិយាល័យរបស់លោកឡក់ហាត ពួកគេក៏បត់ចូលទៅក្នុងបន្ទប់រៀនទំនេរមួយ រួចបិទទ្វារ ភ្ជិតវិញយ៉ាងស្ងៀមស្ងាត់។ ហើយសំលឹងមើលដោយចុងភ្នែកទៅកាន់ទឹកមុខងងឹតសូន្យរបស់មិត្តភក្តិរបស់វា។

- តើពួកឯងគិតថា ខ្ញុំគួរតែប្រាប់ពួកគេអំពីសម្លេងដែលខ្ញុំបានស្តាប់ឮដែររឺទេ?

- ទេ- រ៉ុនតប ដោយគ្មានការស្ទាក់ស្ទើរ។ - ការស្តាប់ឮសំឡេងដែលគ្មាននរណាទៀតអាចស្តាប់ឮ គឺមិនមែនជាសញ្ញាមួយល្អនោះទេ សូម្បីតែនៅក្នុងពិភពវេទមន្តក៏ដោយ។

អ្វីម្យ៉ាងនៅក្នុងសំឡេងរបស់រ៉ុនធ្វើឲ្យហេរីសួរថាៈ

- ឯងជឿខ្ញុំដែររឺ?

- ច្បាស់ជាជឿហើយ- រ៉ុនបន្លឺឡើងយ៉ាងរួសរាន់។ - ប៉ុន្តែ...ឯងច្បាស់ជាគិតថាវាចម្លែកណាស់ហើយ...

- ខ្ញុំដឹងថាវាចម្លែកហើយ - ហេរីពោល។ - រឿងទាំងមូលពិតជាចម្លែកណាស់។ តើសំណេរនៅលើជញ្ជាំងនោះនិយាយអំពីអ្វី? បន្ទប់សម្ងាត់ត្រូវបានបើកហើយ...តើនោះចង់បានន័យថាម៉េចទៅ?

- ឯងដឹងទេ ខ្ញុំដូចជាចាំថាធ្លាប់ឮពាក្យនេះនៅកន្លែងណាម្តង- រ៉ុននិយាយមួយៗ។ - ខ្ញុំគិតថា មាននរណាម្នាក់បានប្រាប់ខ្ញុំអំពីរឿងបន្ទប់សម្ងាត់នៅឯសាលាហុកវ៉ាតម្តង...ប្រហែលជាប៊ីលហើយ...

- ហើយចុះអាពាក្យ "ជនអវេទ" នោះវិញ វាមានន័យអ្វីទៅ?- ហេរីសួរ។

ដោយនឹកហួសចិត្តពេក រ៉ុនសើចបិទមាត់ស្ទើរតែថប់ដង្ហើមស្លាប់។

- អឺ...តាមពិតទៅ វាមិនមែនជាពាក្យកំប្លែងលេងនោះទេ...ប៉ុន្តែបើជាហ្វីលច្ចវិញ... - វាស្រដី។ - ជនអវេទគឺជានរណាម្នាក់ដែលចាប់កំនើតនៅក្នុងត្រកូលគ្រួសារវេទគូ ប៉ុន្តែបែរជាគ្មានថាមពលវេទមន្ត។ វាជាប្រភេទពាក្យប្រើផ្ទុយពីវេទគូដែលមានដើមកំណើតពីឪពុកម្តាយជាពួកលោកិយ ប៉ុន្តែជនអវេទពិតជាមិនធម្មតាឡើយ។ ប្រសិនបើហ្វីលច្ចកំពុងតែព្យាយាមហាត់រៀនវេទមន្តពីវគ្គសិក្សាបាលីងាយរៀននោះ ខ្ញុំហ៊ានសន្មតថាគាត់ច្បាស់ជាជនអវេទហើយ។ វានឹងពន្យល់នូវរឿងហេតុច្រើនណាស់។ ដូចជាពីមូលហេតុដែលគាត់ស្អប់ពួកកូនសិស្សខ្លាំងម្ល៉េះ។- រ៉ុនសើចញញឹមបែបពេញចិត្តនឹងខ្លួនឯង។ - គាត់ពិតជាជូរចត់មែន។

សម្លេងនាឡិកាពាទិ៍បន្លឺឡើងនៅកន្លែងណាមួយ។

- ដល់ពេលពាក់កណ្តាលអធ្រាត្រហើយ- ហេរីនិយាយ។ -យល់ល្អ ពួកយើងគួរតែទៅដេក មុនពេលដែលស្នេពមកតាមរករឿងយើងទៀត។

*

អស់រយៈកាលជាពីរបីថ្ងៃ សាលាទាំងមូលមិនសូវជានិយាយអ្វីច្រើន ជាជាងការវាយប្រហារទៅលើអ្នកស្រីណូរីសឡើយ។ ហ្វីលច្ចរក្សាកន្លែងកើតហេតុឲ្យនៅដូចដើម ដោយចេះតែដើរយាមល្បាតចុះឡើងកន្លែងដែលវាត្រូវបានគេវាយប្រហារ ហាក់ដូចជាគាត់គិតថា អ្នកវាយប្រហារនោះនឹងប្រហែលជាត្រលប់មកម្តងទៀត។ ហេរីបានឃើញគាត់ដុសលុបសារនៅលើជញ្ជាំង ព្រមទាំងមានកាន់នៅក្នុងដៃនូវសៀវភៅ **វិធីលុបស្លាកស្នាមបន្ទុឡើងដោយវេទមន្តគ្រប់ជំពូក** និពន្ធដោយអ្នកស្រី ស្កូវើ ប៉ុន្តែនៅតែគ្មានបានផល។ ពាក្យទាំងនោះនៅតែចាំងពន្លឺយ៉ាងភ្លឺចិញ្ចែងចិញ្ចាចដូចដើមនៅលើផ្ទាំងថ្ម។ នៅពេលដែលហ្វីលច្ចមិននៅដើរល្បាតកន្លែងកើតហេតុទេ គឺគាត់កំពុងតែចាំលួចមើលឡើងក្រហមភ្នែកតាមផ្លូវរបៀងទាំងឡាយ ហើយនិងហាក់ភ្លែតមកពីមុខពួកកូនសិស្សដែលមិនគួរឲ្យសង្ស័យ ព្រមទាំងព្យាយាមដាក់ពិន័យពួកគេពីបទ "ដកដង្ហើមឮខ្លាំង" និង "ធ្វើទឹកមុខសប្បាយចិត្ត"។

ជីននី វីស្លី មើលទៅហាក់ដូចជាមិនស្រណុកក្នុងចិត្តទាល់តែសោះ ដោយសារតែជោគវាសនាអភ័ព្វរបស់អ្នកស្រីណូរីស។ ដោយយោងទៅតាមរ៉ុន នាងគឺជាអ្នកស្រឡាញ់សត្វឆ្មាដ៏ងប់ងុលម្នាក់។

- ប៉ុន្តែឯងមិនទាន់ស្គាល់អ្នកស្រីណូរីសច្បាស់នោះទេ - រ៉ុនប្រាប់នាងដោយគាំទ្រ។ - និយាយតាមត្រង់ទៅ ពួកយើងនៅសុខកាយជាងបើគ្មានវា។- បបូរមាត់របស់ជីននីឡើងញ័រ។ - រឿងដូច្នោះមិនចេះតែកើតឡើងនៅសាលាហុកវ៉ាតនោះទេ - រ៉ុនលួងលោមនាង។ - ពួកគេច្បាស់ជានឹងចាប់បានអាមនុស្សឆ្កួតដែលប្រព្រឹត្តរឿងនេះ និងបណ្តេញវាចេញមិនទុកដល់ស្អែកទេ។ ខ្ញុំគ្រាន់តែសង្ឃឹមថា វាមានពេលនឹងផ្តំបាលីបង្កកទៅលើហ្វីលច្ច មុនពេលដែលវាត្រូវគេបណ្តេញចេញទៅចុះ។ ខ្ញុំគ្រាន់តែនិយាយលេងទេតើ...- រ៉ុនបន្ថែមយ៉ាងប្រញាប់ប្រញាល់ ពេលដែលជីននីចាប់ផ្តើមស្លេកស្លាំង។

## សំណោះលើខញ្ជាំង

ការវាយប្រហារនេះក៏មានជះឥទ្ធិពលទៅលើហឺម៉ាយអូនីដែរ។ វាពិតជាធម្មតាទេសម្រាប់ហឺម៉ាយអូនីក្នុងការចំណាយពេលច្រើនអានសៀវភៅនោះ ប៉ុន្តែឥឡូវនាងស្ទើរតែគ្មានធ្វើអ្វីក្រៅពីអាននោះទេ។ ទាំងហេរី និងរ៉ុនសុទ្ធតែមិនអាចទទួលបាននូវចម្លើយតបច្រើនពីនាងឡើយ នៅពេលដែលពួកគេសាកសួរនាងថា តើនាងកើតអី រហូតទៅដល់ថ្ងៃពុធសប្តាហ៍ក្រោយ ទំរាំតែពួកគេដឹង។

ហេរីត្រូវបានបង្អង់យូរក្នុងមុខវិជ្ជាឱសថរាវ ដោយហេតុថា ស្នេពបានបង្ខំវា ឲ្យនៅក្រោយគេ ដើម្បីចាំបោសសម្អាតដង្កូវបំពង់ចេញពីលើតុ។ ក្រោយពីបរិភោគអាហារថ្ងៃត្រង់ទាំងប្រញាប់ប្រញាល់រួចមក វាក៏ឡើងទៅជាន់លើជួបនឹងរ៉ុនក្នុងបណ្ណាល័យ ហើយក៏ឃើញ ចាស្ទីន ហ្វិញ ហ្លីតឈី ដែលត្រូវជាក្មេងប្រុសក្រុមហាហ្វ័លផហ្វម្នាក់ ចេញពីសិក្សាមុខវិជ្ជាភូតគាមសាស្ត្រ កំពុងតែដើរសំដៅមករកវា។ ហេរីទើបតែបង្អើបមាត់រកនិយាយពាក្យសួស្តី ស្រាប់តែចាស្ទី នប្រទះឃើញវា រួចក៏បែរចេញយ៉ាងរហ័ស ហើយដើរយ៉ាងលឿនចេញទៅបាត់តាមទិសដៅផ្ទុយគ្នា។

ហេរីរកឃើញរ៉ុននៅផ្នែកខាងក្រោយនៃបណ្ណាល័យ កំពុងតែវាស់ស្ទង់កិច្ចការផ្ទះអំពីមុខវិជ្ជា ប្រវត្តិនៃវេទមន្ត របស់វា។ សាស្ត្រាចារ្យប៊ីនបានស្នើសុំនូវសំណេរប្រហែលបីហ្វិតស្តីអំពី "រដ្ឋសភាសម័យមជ្ឈិមសម័យនៃវេទគូជនជាតិអឺរ៉ុប"។

- ខ្ញុំស្ទើរតែមិនជឿឡើយ នៅខ្វះប្រាំបីអ៊ីងទៀតឯណោះ - រ៉ុនឧទានឡើងទាំងខឹងសំបា ព្រមទាំងគ្រវែងក្រដាសស្បែកចៀមរបស់វា ដែលបានរមូរមកជាក្រដាសដុំវិញ។ - ហើយហឺម៉ាយអូនីសរសេរបានបួនហ្វិតប្រាំពីរអ៊ីង ហើយនាងសរសេរអក្សរតូចៗទៀត។

- តើនាងទៅណាបាត់ហើយ?- ហេរីសួរ ព្រមទាំងចាប់យកប្រដាប់វាស់វែង និងរមូរលាកិច្ចការផ្ទះរបស់វា។

- នៅកន្លែងណាមួយទីនោះ - រ៉ុនតប ដោយចង្អុលដៃទៅតាមធ្នើរ។ - កំពុងតែរកមើលសៀវភៅមួយក្បាលផ្សេងទៀត។ ខ្ញុំគិតថា នាងកំពុងតែព្យាយាមអានសៀវភៅដែលមានក្នុងបណ្ណាល័យហ្នឹងឲ្យអស់មុនពេលបុណ្យណូអែលតែម្តង។

ហេរីបានប្រាប់រ៉ុនអំពី ចាស្ទីន ហ្វិញ ហ្លីតឈី រត់គេចចេញឆ្ងាយពីវា។

- កុំទៅខ្វល់អី។ ខ្ញុំគិតថាវាឡប់ៗម៉េចមិនដឹងទេ - រ៉ុននិយាយ ដោយចាប់ផ្តើមសរសេរខ្មៀកបណ្តើរ ព្រមទាំងខំពង្រីកអក្សរឲ្យបានធំៗតាមដែលអាចធ្វើទៅបាន។ - អារឿងគ្មានបានការ អំពីឡក់ហាតនោះពិតជាអស្ចារ្យណាស់ឥឡូវ...

ហឺម៉ាយអូនីបានប្រាកដខ្លួនឡើងពីចន្លោះធ្នើរដាក់សៀវភៅ។ នាងមើលទៅដូចជាម៉ួម៉ៅ ហើយ ទីបំផុត ហាក់ត្រៀមខ្លួនរួចរាល់នឹងនិយាយមកកាន់ពួកគេ។

- គ្រប់ច្បាប់ចម្លងអំពី ប្រវត្តិនៃសាលាហុកវ៉ាត ត្រូវបានគេយកចេញទៅអស់ហើយ - នាងស្រដី ដោយដាក់ខ្លួនអង្គុយចុះជិតហេរី និងរ៉ុន។ - ហើយនៅមានបញ្ជីឈ្មោះសៀវភៅ ដែលត្រូវរង់ចាំដល់ពីរសប្តាហ៍ឯណោះ ទំរាំតែមកដល់។ ខ្ញុំបន់ថាមិនបានទុកវាចោលឯផ្ទះចុះ ប៉ុន្តែខ្ញុំដាក់វាមិនចុះឡើយទៅក្នុងវ៉ាលិស ដោយសារមានសៀវភៅលោក ឡក់ហាត ច្រើនពេក។

- ហើយចុះ ឯងរកសៀវភៅហ្នឹងធ្វើអី?- ហេរីសួរ។

- គឺហេតុផលតែមួយដូចដែលអ្នកឯងទៀតចង់បានវាដែរ - ហឺម៉ាយអូនីពោល - គឺដើម្បីអានអំពីរឿងព្រេងទាក់ទងនឹងបន្ទប់សម្ងាត់។

- តើនោះជាអ្វីទៅ?- ហេរីបន្លឺឡើងយ៉ាងរហ័ស។

- មានតែប៉ុណ្ណឹង។ ខ្ញុំអត់បានចាំផង - ហឺម៉ាយអូនីតប ដោយខាំបបូរមាត់។ - ហើយខ្ញុំរកមិនឃើញរឿងនោះនៅកន្លែងណាផ្សេងទៀតទេ...

- ហឺម៉ាយអូនី ឲ្យខ្ញុំអានសំនេររបស់ឯងបន្តិចមក- រ៉ុនស្រដីយ៉ាងអស់សង្ឃឹម ព្រមទាំងមើលម៉ោងលើនាឡិការបស់វា។

- ទេ! ខ្ញុំមិនអោយមើលទេ- ហឺម៉ាយអូនីនិយាយយ៉ាងដាច់ម៉ាត់ភ្លាមៗតែម្តង។ - ឯងមានពេលដប់ថ្ងៃដើម្បីបញ្ចប់វា...

- ខ្ញុំត្រូវការតែប្រវែងពីរអ៊ីងទៀតប៉ុណ្ណោះ សូមអង្វរ...

សូរជួងបានបន្លឺឡើង។ រ៉ុន និងហឺម៉ាយអូនីនាំផ្លូវចូលទៅរៀនមុខវិជ្ជា ប្រវត្តិនៃវេទមន្ត ដើរបណ្តើរឈ្លោះគ្នាបណ្តើរ។

ប្រវត្តិនៃវេទមន្ត គឺជាមុខវិជ្ជាដ៏គួរឲ្យធុញទ្រាន់បំផុតនៅលើកាលវិភាគសិក្សារបស់ពួកគេ។ សាស្ត្រាចារ្យប៊ីន ដែលជាគ្រូបង្រៀនមុខវិជ្ជានោះ គឺជាគ្រូខ្មោចរបស់ពួកគេតែម្នាក់គត់ ហើយរឿងដ៏គួរឲ្យរំភើបបំផុតដែលមិនធ្លាប់កើតឡើងនោះ គឺថាគាត់ចូលទៅក្នុងថ្នាក់ដោយដើរកាត់ក្តារខៀន។ ដោយចាស់បុរាណ និងហួតហែងផង មនុស្សជាច្រើននិយាយថា គាត់មិនបានកត់សម្គាល់ថាខ្លួនគាត់បានស្លាប់បាត់ទៅហើយនោះទេ។ មានថ្ងៃមួយ គាត់ងើបឡើងមកបង្រៀនដូចធម្មតា ហើយទុករាងកាយរបស់គាត់ចោលនៅលើកៅអីភ្នាក់ដៃពីមុខចង្ក្រានកំដៅក្នុងបន្ទប់បុគ្គលិក ឯទម្លាប់របស់គាត់វិញ មិនដែលផ្លាស់ប្តូរសូម្បីតែបន្តិចចាប់តាំងពីពេលនោះមក។

ថ្ងៃនេះមានសភាពគួរឲ្យធុញទ្រាន់ដូចសព្វដងអញ្ចឹងដែរ។ សាស្ត្រាចារ្យប៊ីនចាប់បើកក្រដាសកត់ត្រារបស់គាត់ រួចអានដោយសំឡេងរហឹមៗរាបស្មើប្រៀបបាននឹងម៉ាស៊ីនបោសផ្ទះកញ្ចាស់មួយ រហូតធ្វើអោយស្ទើរតែសិស្សគ្រប់គ្នាក្នុងថ្នាក់នោះស្ថិតក្នុងសភាពស្ពឹកស្រពន់ពេញទី យូរៗម្តងឃើញលើកស្លាបប៉ាកាកត់ត្រានូវឈ្មោះ និងកាលបរិច្ឆេទ បន្ទាប់មកក៏ដេកលក់ទៀត។ គាត់និយាយអស់ពេលកន្លះម៉ោង ស្រាប់តែមានរឿងមួយបានកើតឡើងដែលមិនធ្លាប់កើតឡើងទាល់តែសោះពីមុនមក។ ហឺម៉ាយអូនីលើកដៃរបស់នាងឡើង។

សាស្ត្រាចារ្យប៊ីនមើលទៅមុខឡើងស្រឡាំងកាំង ខណៈដែលគាត់ងើយមុខឡើង ពេលកំពុងអានបាឋកថាស្តីអំពីអនុសញ្ញាវេទមន្តអន្តរជាតិក្នុងឆ្នាំ១២៨៩បានពាក់កណ្តាល។

- កញ្ញា...អឺ...?

- គឺហ្គ្រេនជឺរ លោកសាស្ត្រាចារ្យ។ ខ្ញុំកំពុងតែឆ្ងល់ថាតើលោកអាចប្រាប់ពួកយើងនូវរឿងមួយចំនួនដែលពាក់ព័ន្ធនឹងបន្ទប់សម្ងាត់បានដែរឬទេ- ហឺម៉ាយអូនីបន្លឺឡើងដោយសំលេងច្បាស់ៗ។

ឌីន ថូម៉ាស ដែលកំពុងតែអង្គុយច្រហាមាត់ក្រឡេកមើលទៅក្រៅបង្អួច ស្រាប់តែភ្ញាក់ព្រើតដាច់អស់ភាពអណ្តែតអណ្តូងរបស់វា ឯក្បាលឡាវេនឌ័រ ប្រោន ងើបឡើងចេញពីដៃច្រត់ចង្ការបស់នាង ហើយកែងដៃ នេវីល ឡុងបត់ថម រអិលធ្លាក់ផុតពីតុរបស់វា។

សាស្ត្រាចារ្យប៊ីនព្រិចភ្នែក។

- មុខវិជ្ជារបស់ខ្ញុំគឺ ប្រវត្តិនៃវេទមន្ត- គាត់ពោលដោយដង្ហើមតឹងៗ។ - ការបង្រៀនរបស់ខ្ញុំលើកឡើងនូវហេតុការណ៍ពិតៗណា៎ កញ្ញាហ្គ្រេនជឺរ មិនមែននិយាយអំពីរឿងព្រេង រឺទេវកថានោះទេ។- គាត់ជម្រះបំពង់កដោយបន្លឺសំឡេងតូចមួយដូចជាសំឡេងសរសេរដីស ហើយក៏បន្តទៀតថា៖

- នៅក្នុងខែកញ្ញាឆ្នាំនោះ អនុគណៈកម្មាធិការនៃវេទគូជនជាតិសាឌីណា...

គាត់និយាយត្រដិតៗហូតដល់ឈប់និយាយ។ ដៃរបស់ហឺម៉ាយអូនីកំពុងតែគ្រវីចុះឡើងម្តងទៀតហើយ។

- យ៉ាងម៉េច កញ្ញាហ្គ្រេន?

- សូមមេត្តា លោកគ្រូ ក្រែងថារឿងព្រេងតែងតែមានជាមូលដ្ឋាននៅក្នុងហេតុការណ៍ពិតវឺ?

សាស្រ្តាចារ្យប៊ីនកំពុងតែសម្លឹងមើលមកនាងដោយងឿងឆ្ងល់មែនទែន។ ហេរីប្រាកដក្នុងចិត្តណាស់ថា មិនដែលមានកូនសិស្សណាធ្លាប់កាត់ប្រសាសន៍គាត់ពីមុនមកនោះទេ ទោះជាគាត់នៅរស់ រឺស្លាប់ទៅហើយក្តី។

- អឺ- សាស្ត្រាចារ្យប៊ីននិយាយយ៉ាងយឺតៗ។ - មែនហើយ គេអាចប្រកែកថាដូច្នោះបាន ខ្ញុំគិតថាអ៊ីចឹងឯង។- គាត់ខំសម្លឹងមើលហឺម៉ាយអូនី ហាក់បីដូចជាគាត់មិនដែលធ្លាប់សម្លឹងសិស្សណាឲ្យបានម៉ត់ចត់ពីមុនមកឡើយ។ - ទោះជាយ៉ាងណាក៏ដោយ រឿងព្រេងដែលឯងនិយាយនោះគឺពិតជារឿងមួយដ៏គួរឲ្យអស្ចារ្យ ថែមទាំងគួរឲ្យអស់សំណើចផងដែរ...

ប៉ុន្តែឥឡូវនេះ សិស្សក្នុងថ្នាក់ទាំងអស់កំពុងតែត្រងត្រាប់ស្តាប់គ្រប់ម៉ាត់ដែលលោកសាស្រ្តាចារ្យ ប៊ីន ស្រដី។ គាត់សម្លឹងមើលទៅពួកគេទាំងអស់គ្នាយ៉ាងស្រពិចស្រពិល រីឯមុខសិស្សគ្រប់គ្នាបែរមករកគាត់។ ហេរីអាចប្រាប់បានថា គាត់ពិតជាភ្ញាក់ផ្អើលទាំងស្រុងដោយសិស្សគ្រប់គ្នាបែរជាយកចិត្តទុកដាក់ចាប់អារម្មណ៍ខុសពីប្រក្រតី។

- អូ! អញ្ចឹងក៏បាន- គាត់បន្លឺឡើងមួយ។ - ឲ្យខ្ញុំគិតមើលសិន...បន្ទប់សម្ងាត់...

- ជាការពិតណាស់ អ្នកទាំងអស់សុទ្ធតែបានជ្រាបច្បាស់ថា សាលាហុកវ៉ាតត្រូវបានគេរកឃើញជាងមួយពាន់ឆ្នាំកន្លងទៅហើយ...ឯកាលបរិច្ឆេទជាក់លាក់វិញមិនច្បាស់លាស់នោះទេ...គឺត្រូវបានរកឃើញដោយ មេធ្មប់ និង វេទគូ ដ៏អស្ចារ្យបំផុតនាសម័យកាលនោះ។ អគារសាលាទាំងបួន ត្រូវបានដាក់ឈ្មោះតាមពួកគេៈ មាន ហ្គូឌ្រីក ហ្រ្គីហ្វីនដ័រ, ហេលហ្គា ហាហ្វលផ័ហ្វ, រ៉ូវេណា រ៉ាវីនក្លាហ្វ ហើយនិង សាឡាហ្សា ស្លីតឺរីន។ ពួកគេបានកសាងប្រាសាទនេះជាមួយគ្នា គឺស្ថិតនៅឆ្ងាយពីក្រសែភ្នែករបស់ពួកលោកិយ ពីព្រោះវាគឺជាសម័យកាលមួយ នៅពេលដែលវេទមន្តត្រូវបានមនុស្សជាទូទៅភ័យខ្លាច ហើយធ្មប់ និងវេទគូត្រូវទទួលរងនូវការធ្វើបាបជាច្រើន។

គាត់បង្អាក់សម្តីបន្តិច ដោយក្រឡេកមើលជុំវិញថ្នាក់ឡើងស្រវាំងភ្នែក រួចក៏បន្តទៅទៀត។

- អស់រយៈកាលពីរបីឆ្នាំ អ្នកស្វែងរកឃើញទាំងបួននោះធ្វើការដោយសុខដុមរមនាទាំងអស់គ្នា ព្រមទាំងត្រាច់ចររកមើលពួកក្មេងៗដែលបង្ហាញនូវសញ្ញាណនៃវេទមន្ត និងនាំពួកគេមកកាន់ប្រាសាទដើម្បីអប់រំ។ ប៉ុន្តែបន្ទាប់មក ភាពមិនឯកច្ឆន្ទគ្នាបានផ្ទុះឡើងរវាងពួកគេ។ ស្នាមប្រេះឆាចាប់ផ្តើមរីកធំឡើងរវាង ស្លីតឺរីន និងអ្នកផ្សេងៗទៀត។ ស្លីតឺរីនបានប្រាថ្នាឲ្យមានការជ្រើសរើសសិស្សចូលក្រុមខ្លួនឲ្យបានច្រើនជាងគេនៅសាលាហុកវ៉ាត។ គាត់ជឿជាក់ថា ការបង្រៀនវេទមន្តគួរតែផ្តល់ឲ្យតែគ្រួសារត្រកូលវេទគូតែប៉ុណ្ណោះ។ គាត់មិនចូលចិត្តក្នុងការទទួលយកសិស្សដែលមានពួកលោកិយជាឪពុកម្តាយ ដោយជឿថាពួកគេមិនអាចជឿទុកចិត្តបាន។ អស់ពេលមួយរយៈ មានការឈ្លោះប្រកែកគ្នាដ៏ធ្ងន់ធ្ងរមួយទៅលើមុខវិជ្ជាបង្រៀនរវាង ស្លីតឺរីន និងហ្រ្គីហ្វីដ័រ ហើយស្លីតឺរីនក៏បានចាកចេញពីសាលាទៅ។

សាស្រ្តាចារ្យប៊ីនបង្អាក់ម្តងទៀត ដោយខាំមាត់របស់គាត់ មើលទៅដូចជាអណ្តើកកញ្ចាស់រួញខ្លួនចូលស្នូក។

- ប្រភពប្រវត្តិសាស្រ្តដែលអាចជឿទុកចិត្តបានផ្តល់ឲ្យពួកយើងច្រើនប៉ុណ្ណឹងឯង- គាត់ពោល។ - ប៉ុន្តែហេតុការណ៍ពិតប្រាកដទាំងនេះត្រូវបានធ្វើឲ្យមិនជាក់ច្បាស់ ដោយសារតែរឿងព្រេងអំពីបន្ទប់សម្ងាត់នេះដែលទាក់ទាញអារម្មណ៍អ្នករាល់គ្នា។ រឿងនោះនិទានថា កាលដើមឡើយ លោកស្លីតឺរីនបានកសាងនូវបន្ទប់សម្ងាត់មួយនៅក្នុងប្រាសាទ ដោយមិនអោយអ្នកស្វែងរកឃើញដទៃទៀតដឹងឡើយ។

- ស្លីតឺរីន ដោយយោងទៅតាមរឿងព្រេង គឺបានបិទបន្ទប់សម្ងាត់នោះធ្វើយ៉ាងណាកុំអោយមាននរណាបើកវាបានឲ្យសោះ រហូតទាល់តែទាយាទពិតប្រាកដរបស់គាត់មកដល់សាលានេះ។ មានតែទាយាទម្នាក់គត់ដែលអាចមានសមត្ថភាពនឹងបើកបន្ទប់សម្ងាត់នោះបាន ព្រមទាំងព្រលែងនូវខ្មោចព្រាយបិសាចនៅខាងក្នុង ហើយនិងប្រើប្រាស់វាដើម្បីសំអាតចេញនូវអ្នកទាំងអស់នោះដែលមិនគួរឲ្យទុកចិត្តនឹងសិក្សាវេទមន្តបាន។

មានភាពស្ងៀមស្ងាត់មួយសន្ទុះ ខណៈពេលដែលគាត់តំនាលរឿងចប់ ប៉ុន្តែវាមិនមែនជាភាពស្ងៀមស្ងាត់បែបងងុយគេងដូចធម្មតានៅក្នុងថ្នាក់រៀនរបស់លោកសាស្ត្រាចារ្យប៊ីននោះទេ។ មានភាពគ្មានផាសុកមួយ ពេលដែលអ្នកគ្រប់គ្នាបន្តសម្លឹងមើលមកគាត់ សង្ឃឹមថាគាត់នឹងនិយាយបន្តទៀត។ លោកសាស្ត្រាចារ្យប៊ីនមើលទៅដូចជាក្តៅក្រហាយបន្តិចដែរ។

- ជាការពិតណាស់ រឿងទាំងអស់ហ្នឹងគឺពិតជាគ្មានបានការអ្វីទេ- គាត់ស្រដី។ - និយាយឲ្យអស់ទៅ សាលានេះត្រូវបានគេរុករកមើលភ័ស្តុតាងស្តីអំពីបន្ទប់នោះអស់រយៈពេលជាច្រើនលើកច្រើនសារមកហើយ ហើយអ្នករុករកទាំងនោះសុទ្ធតែជាធ្មប់ និងវេទគូដែលបានសិក្សាជ្រៅជ្រះទៀតផង។ វាមិនមាននោះទេ។ រឿងតំណាលនេះគ្រាន់តែទុកសម្រាប់បន្លាចពួកអ្នកត្រចៀកស្រាលតែប៉ុណ្ណោះ។

ដៃរបស់ហឺម៉ាយអូនីលើកឡើងម្តងទៀត។

- លោកគ្រូ...តើលោកគ្រូចង់បានន័យថាម៉េចឲ្យពិតប្រាកដអំពី "ខ្មោចព្រាយបិសាចនៅក្នុង" បន្ទប់សម្ងាត់នោះ?

- នោះត្រូវគេជឿថា ជាប្រភេទបិសាចម្យ៉ាង ដែលមានតែទាយាទ ស្លីតឺរីន ម្នាក់គត់ ដែលអាចបញ្ជាគ្រប់គ្រងបាន- សាស្ត្រាចារ្យប៊ីនបន្លឺឡើងដោយសំឡេងស្ងួតគ្រែងៗ។

ថ្នាក់ទាំងមូលចាប់ផ្តើមសំឡឹងមើលមុខគ្នាដោយព្រួយបារម្ភ។

- ខ្ញុំប្រាប់ពួកឯងហើយ រឿងនោះគ្មានជាការពិតនោះទេ- សាស្ត្រាចារ្យប៊ីននិយាយ ព្រមទាំងបើកក្រដាសកត់ត្រារបស់គាត់បណ្តើរៗ។ - គ្មានបន្ទប់សម្ងាត់ ហើយក៏គ្មានបិសាចអ្វីដែរ។

- ប៉ុន្តែ លោកគ្រូ- ស៊ីម្យុស ហ្វីនីហ្គេនស្រដី - ប្រសិនបើបន្ទប់នោះអាចតែបើកបានដោយទាយាទពិតប្រាកដរបស់ស្លីតឺរីននោះ ច្បាស់ជាគ្មាននរណាផ្សេងមានសមត្ថភាពនឹងរកវាឃើញហើយ មែនទេ?

- កុំនិយាយតែផ្តាស អូហ្វ្លាហឺទី- លោកសាស្ត្រាចារ្យប៊ីនតបវិញដោយខ្នាញ់។ - ប្រសិនបើនាយក និងនាយិកាដែលទទួលបានជោគជ័យយូរអង្វែងមកមិនបានរកឃើញអ្វីសោះនោះ...

- ប៉ុន្តែ លោកសាស្ត្រាចារ្យ- ផាវ៉ាទី ប៉ាធីលបន្លឺឡើង។- គេប្រហែលជាត្រូវប្រើអាគមងងឹតហើយ ដើម្បីបើកវាបាន...

- គ្រាន់តែដោយសារវេទគូម្នាក់មិនប្រើប្រាស់អាគមងងឹត ក៏មិនមែនមានន័យថាគេមិនអាចប្រើបាននោះដែរ កញ្ញា ភេននី- ហ្វីដ័រ- សាស្ត្រាចារ្យប៊ីននិយាយយ៉ាងដាច់ម៉ាត់។ - ខ្ញុំសូមនិយាយឡើងវិញម្តងទៀត ប្រសិនបើមនុស្សដូចជាលោក ដាំប័លដ័រទៅហើយ...

- ប៉ុន្តែប្រហែលជាគេត្រូវតែជាប់សាច់ឈាមជាមួយនឹងស្លីតឺរីន ដូច្នេះលោក ដាំប័លដ័រ មិនអាច...- ឌីន ថូម៉ាស់ ផ្តើមនិយាយឡើង ប៉ុន្តែលោកសាស្ត្រាចារ្យប៊ីនទ្រាំលែងបានតទៅទៀតហើយ។

- ប៉ុណ្ណឹងបានហើយ- គាត់ពោលកាត់ភ្លាម។ - វាគ្រាន់តែជាទេវកថាទេ! វាគ្មានជាការពិតទេ! វាគ្មានភ័ស្តុតាងអ្វីសូម្បីតែបន្តិចដែលថា ស្លីតឺរីនធ្លាប់បានកសាងកន្លែងមួយដូចជាបន្ទប់ដាក់អំបោសសម្ងាត់ស្អីគេនោះឡើយ! ខ្ញុំពិតជាសោកស្តាយណាស់

ដែលបានប្រាប់ពួកឯងនូវរឿងដ៏មិនសមហេតុផលនេះ! ឥឡូវប្រសិនបើពួកឯងមិនយល់ទាស់អ្វីទេ សូមត្រលប់មករកប្រវត្តិសាស្ត្រវិញ គឺត្រលប់មករកហេតុការណ៍ពិតៗដែលត្រឹមត្រូវមួយរយភាគមួយរយមិនអាចប្រកែកបានវិញ!

ហើយក្នុងរយៈពេលប្រាំនាទី ថ្នាក់នោះក៏ចាប់ផ្តើមធ្លាក់ទៅក្នុងសភាពស្ពឹកស្រពន់ដូចធម្មតាវិញ។

*

- ខ្ញុំតែងតែបានដឹងថា សាឡាហ្សា ស្លីតឺរីនគឺជាតាឆ្កួតដ៏ក្រឡិចក្រឡុចម្នាក់- រ៉ុនប្រាប់ហេរី និងហឺម៉ាយអូនី ខណៈពេលដែលពួកគេប្រជ្រៀតគ្នាឆ្លងកាត់ផ្លូវរបៀងដ៏ណែនណាន់តាន់តាប់នៅឯចុងម៉ោងរៀន ដើម្បីយកកាតាបរបស់ពួកគេទៅទុក មុននឹងស្រស់ស្រូបអាហារពេលល្ងាច។ - ប៉ុន្តែខ្ញុំមិនដែលដឹងថា គាត់ជាអ្នកចាប់ផ្តើមអារឿងទាក់ទងនឹងអ្នកមានឈាមជ័រសុទ្ធទាល់តែសោះ។ ទោះជាឯងឲ្យលុយខ្ញុំប៉ុន្មានក៏ដោយ ក៏ខ្ញុំមិនទៅចូលក្នុងក្រុមនោះដែរ។ និយាយតាមត្រង់ទៅ ប្រសិនបើមួកសិល្ប៍ហ៊ានតែសាកដាក់ខ្ញុំក្នុងក្រុមស្លីតឺរីនមើល៍ ខ្ញុំច្បាស់ជានឹងវេចបង្វេចឡើងរថភ្លើងទៅផ្ទះវិញភ្លាម...

ហឺម៉ាយអូនីងក់ក្បាលយល់ស្របតាមយ៉ាងលឿន ប៉ុន្តែហេរីមិនស្តីអ្វីនោះទេ។ ពោះរបស់វាទើបតែធ្លាក់ចុះដល់ដីយ៉ាងទោមនស្សចិត្ត។

ហេរីមិនដែលបានប្រាប់រ៉ុន និងហឺម៉ាយអូនីថា មួកសិល្ប៍ពិតជាបានពិចារណារកដាក់វាទៅក្នុងក្រុមស្លីតឺរីនមែននោះទេ។ វានៅតែអាចចាំបាន ប្រៀបដូចជាទើបតែម្សិលមិញអញ្ចឹង គឺចាំបាននូវសំឡេងដែលនិយាយដាក់ត្រចៀករបស់វា នៅពេលដែលវាពាក់មួកនោះលើក្បាលកាលពីឆ្នាំទៅ៖ ឯងអាចនឹងអស្ចារ្យបាន ឯងដឹងទេ វាសុទ្ធតែឋិតលើឯងជាអ្នកសម្រេចទាំងអស់ ហើយស្លីតឺរីនអាចជួយវែកផ្លូវឲ្យឯងឆ្ពោះទៅរកភាពមហស្ចារ្យបាន ទាំងគ្មានមន្ទិលសង្ស័យអ្វីឡើយ...

ប៉ុន្តែហេរី ដែលបានស្តាប់ឮអំពីកិត្តិនាមរបស់ក្រុមស្លីតឺរីនក្នុងការបង្វែរវេទគូឲ្យទៅជាចិត្តអាក្រក់រួចហើយនោះ ក៏បានគិតក្នុងចិត្តទាំងអស់សង្ឃឹម៖ មិនមែនក្រុមស្លីតឺរីនទេ! ហើយមួកនោះតបវិញថា៖ អូ! អើ! ប្រសិនបើឯងច្បាស់ក្នុងចិត្តទៅហើយនោះ...យល់ល្អ គួរតែនៅក្រុមហ្គ្រីហ្វីនដ័រចុះ...

ខណៈពេលដែលពួកគេដើរទៅតាមហ្វូងមនុស្ស ខូលីន គ្រីវី ក៏ដើរកាត់មុខពួកគេ។

- អីយ៉ា! ហេរី!

- សួស្តី ខូលីន- ហេរីឧទានឡើងដោយស្វ័យប្រវត្តិ។

- ហេរី...ហេរី...ក្មេងប្រុសម្នាក់នៅក្នុងថ្នាក់រៀនខ្ញុំតែងនិយាយរហូតថាឯង...

ប៉ុន្តែខូលីនមានមាឌល្អិតពេក មិនអាចទប់ឈ្នះនឹងក្រុមមនុស្សដែលរុញវាសំរុកចូលទៅក្នុងមហាសាលបានឡើយ។ ពួកគេឮតែវាស្រែកថា៖

- ជួបគ្នាពេលក្រោយណ៎ា ហេរី!

ហើយវាក៏បាត់ខ្លួនទៅ។

- តើក្មេងប្រុសនៅក្នុងថ្នាក់រៀនវានិយាយអ្វីអំពីឯងទៅ?- ហឺម៉ាយអូនីងឿងឆ្ងល់។

- ថាខ្ញុំជាទាយាទស្លីតឺរីនទេដឹង?- ហេរីស្រដី ឯពោះរបស់វាហាក់ធ្លាក់ប្រហែលមួយអ៊ីងទៀត ពេលដែលវាស្រាប់តែនឹកឃើញដល់ ចាស់ស្ទីន ហ្វីញ ហ្វ្លីតឈី ដែលបានរត់ជៀសឆ្ងាយពីវានៅម៉ោងបរិភោគអាហារថ្ងៃត្រង់។

- មនុស្សនៅទីនេះស្អីក៏ជឿដែរ- រ៉ុននិយាយបែបខ្ពើមរអើម។

ពួកហ្វូងមនុស្សកាន់តែថយចំនួនបន្តិចម្តងៗ ហើយពួកគេក៏មានលទ្ធភាពនឹងឡើងជណ្តើរបន្ទាប់ដោយគ្មានការលំបាកឡើយ។

- តើឯងពិតជាគិតថាមានបន្ទប់សម្ងាត់មែនដែរឬអត់?- រ៉ុនសួរហឺម៉ាយអូនី។

- ខ្ញុំមិនដឹងទេ- នាងពោលតប ដោយជ្រួញចិញ្ចើម។ - លោកដាំប៊័លដ័រមិនអាចព្យាបាលអ្នកស្រីណូរីសបានទេ ហើយរឿងនោះធ្វើឲ្យខ្ញុំគិតថា អ្វីក៏ដោយដែលបានវាយប្រហារមកលើវានោះ ប្រហែលជាមិនមែន...អឺ...ជាមនុស្សទេ។

ខណៈដែលនាងនិយាយ ពួកគេបានបត់នៅកន្លែងកាច់ជ្រុងមួយ ហើយក៏ឃើញថាពួកគេស្ថិតនៅខាងចុងផ្លូវរបៀងចំកន្លែងដែលការវាយប្រហារបានកើតឡើងតែម្តង។ ពួកគេបញ្ឈប់ដំណើរ ហើយសម្លឹងមើល។ កន្លែងកើតហេតុគឺដូចដែលកាលពីយប់មុនអញ្ចឹង គ្រាន់តែថា គ្មានឆ្មារឹងត្អឹងព្យួរបន្តោកពីកន្តុរកដាក់ចន្លុះតែប៉ុណ្ណឹង ហើយនិងមានកៅអីទំនេរមួយដាក់បញ្ឈរផ្អែកនឹងជញ្ជាំងដែលបំផុសសារថា "បន្ទប់សម្ងាត់ត្រូវបានបើកហើយ"។

- នោះហើយជាកន្លែងដែលហ្វីលច្ចតែងតែយាមល្បាត- រ៉ុននិយាយតិចៗ។

ពួកគេសម្លឹងមើលមុខគ្នាទៅវិញទៅមក។ ផ្លូវរបៀងនោះគ្មានមនុស្សទេ។

- មិនអីទេមើលទៅ បើគ្រាន់តែរកមើលបន្តិចនោះ- ហេរីបន្លឺឡើង ព្រមទាំងទម្លាក់កាតាបរបស់វា រួចលុតជង្គង់ចុះ ហើយវារតាមម្ខាងនៃផ្លូវរបៀង ដើម្បីតែរកមើលស្លាកស្នាមអ្វីមួយ។

- ស្នាមខ្លោច!- វាឧទានឡើង។ - មើលនេះ...នៅទីនេះ...

- មកមើលកន្លែងនេះ!- ហឺម៉ាយអូនីនិយាយ។ - នេះពិតជាគួរឲ្យអស់សំណើចមែន...

ហេរីងើបឈរឡើង ហើយដើរសំដៅទៅកាន់បង្អួចនៅជិតសារលើជញ្ជាំង។ ហឺម៉ាយអូនីកំពុងតែចង្អុលទៅកាន់កញ្ចក់បង្អួចដែលនៅលើគេបង្អស់ ជាទីដែលប្រហែលជាមានពីងពាងម្ភៃក្បាលកំពុងតែរត់គ្របាញ់ជើងគ្នា ជាក់ស្តែងណាស់ វត្ថុបំណងគឺដើម្បីតែឆ្លងកាត់តាមស្នាមប្រេះតូចមួយ។ សំណាញ់ពីងពាងពណ៌ប្រាក់ដ៏វែងមួយ កំពុងតែសំយុងចុះមកដូចជាខ្សែព្យួរមួយអញ្ចឹង ហាក់ដូចជាពួកវាទាំងអស់គ្នាសុទ្ធតែឡើងតាមសំណាញ់ទាំងប្រញាប់ប្រញាល់ដើម្បីចេញទៅខាងក្រៅ។

- តើឯងធ្លាប់ដែលឃើញពីងពាងធ្វើសកម្មភាពដូច្នោះដែរឬទេ?- ហឺម៉ាយអូនីសួរទាំងងឿងឆ្ងល់។

- ទេ- ហេរីតប។ - ចុះឯងវិញ រ៉ុន? រ៉ុន?

វាសម្លឹងមើលពីលើស្មារបស់វា។ រ៉ុនកំពុងតែឈរនៅខាងក្រៅយ៉ាងសមសួន ហើយដូចជាប្រឆាំងនឹងសន្ទុះចិត្តកុំរត់។

- តើមានរឿងអ្វី?- ហេរីស្រដី។

- ខ្ញុំ...មិន...ចូល...ចិត្ត...ពីងពាង...ទេ- រ៉ុននិយាយទាំងតឹងទ្រូង។

- ខ្ញុំមិនដែលដឹងរឿងនោះឡើយ- ហឺម៉ាយអូនីបន្លឺឡើង ព្រមទាំងសម្លឹងមើលមករ៉ុនដោយភ្ញាក់ផ្អើល។ - ឯងធ្លាប់ប្រើប្រាស់ពីងពាងនៅក្នុងមុខវិជ្ជាឱសថរាវរាប់សិបដងមកហើយ...

- ខ្ញុំមិនអីទេពេលពួកវាងាប់បាត់នោះ- រ៉ុនពោល ដែលគ្មានសម្លឹងមើលកន្លែងណាទៀតឡើយក្រៅពីបង្អួច។ - ខ្ញុំមិនចូលចិត្តការធ្វើចលនារបស់ពួកវាតែម្តង...

ហឺម៉ាយអូនីសើចក្អឹកៗ។

- វាមិនគួរឲ្យអស់សំណើចឯណា- រ៉ុនឧទានឡើងដោយម៉ឺងម៉ាត់។ - ប្រសិនបើឯងត្រូវតែដឹងនោះ គឺនៅពេលដែលខ្ញុំអាយុបានបីឆ្នាំ ហ្វ្រេដបាននិម្មិត...និម្មិតខ្លាឃ្មុំតុក្កតារបស់ខ្ញុំទៅជាពីងពាងកខ្វក់ដ៏ធំមហិមាមួយក្បាល ដោយសារតែខ្ញុំបានធ្វើបាក់អំបោសក្មេងលេងរបស់គាត់...ឯងក៏មិនចូលចិត្តពួកវាដែរ ប្រសិនបើឯងកំពុងតែកាន់តុក្កតារបស់ឯង ហើយវាស្រាប់តែដុះចេញជើងច្រើនមកនោះ ហើយ...

វាឈប់និយាយ ព្រមទាំងធ្វើជាញ័រខ្លួនទទ្រើក។ ហឺម៉ាយអូនីពិតជាព្យាយាមខ្លាំងណាស់ ក្នុងការទប់ខ្លួនកុំអោយផ្ទុះសំណើច។ ដោយទទួលអារម្មណ៍ថា យកល្អពួកគេគួរតែផ្លាស់ប្តូរប្រធានបទ ហេរីក៏និយាយឡើងថា៖

- មាននាំថាំទឹកដែលនៅលើកម្រាលដែររឺទេ? តើទឹកនោះចេញមកពីណាទៅ? រឺក៏មាននរណាម្នាក់ជុសជូតលាងកន្លែងនេះ។

- វាប្រហែលជានៅម្តុំនេះឯង- រ៉ុនស្រដី ដោយប្រមូលស្មារតីរបស់ខ្លួន រួចដើរប៉ុន្មានជំហានរំលងកៅអីរបស់ហ្វីលច្ព ព្រមទាំងចង្អុល។ - ដូចជាមកដល់ត្រឹមទ្វារនេះឯង។

វាឈោងចាប់ ដៃទ្វារ ធ្វើអំពីទង់ដែងនោះ ប៉ុន្តែស្រាប់តែដកដៃចេញវាភ្លាម ហាក់ដូចជាដៃរបស់វាត្រូវរលាក។

- មានបញ្ហាអី?- ហេរីសួរ។

- ចូលមិនបានទេ- រ៉ុនតបវិញយ៉ាងគ្រោតគ្រាត។ - នោះគឺជាបន្ទប់ទឹកសិស្សស្រីទេតើ។

- អូ! រ៉ុន គ្មាននរណាម្នាក់នៅក្នុងនោះទេ- ហឺម៉ាយអូនីបន្លឺឡើង ព្រមទាំងក្រោកឈរ រួចដើរសំដៅមក។ - នោះគឺជាកន្លែងរបស់ម៉ុននីង មីតថល។ ឆាប់ឡើង ចូលមកមើលបន្តិចទៅ។

ហើយដោយមិនខ្វល់អំពីផ្លាកសញ្ញា "ហាមប្រើ" ប៉ុនណាណី នាងក៏បើកទ្វារចូលទៅ។

វាគឺជាបន្ទប់ទឹកដ៏អាក្រក់ និងងងឹតសូន្យសុងជាទីបំផុតដែលហេរីមិនដែលធ្លាប់ឈានជើងចូល។ នៅពីក្រោមកញ្ចក់ឆ្លុះមុខដែលប្រេះបែកដ៏ធំមួយ មានកំទេចស្នូកទឹកមួយជួរ។ កំរាលនោះមានជ្រាំកខ្វក់ ហើយមានជះនូវពន្លឺដ៏គួរឲ្យធុញទ្រាន់មួយចេញពីដង្កត់ទានពីរបីដើមឆេះស្ទើរជិតអស់។ ទ្វារឈើសម្រាប់បើកចេញទៅបន្ទប់ផ្សេងៗត្រូវរបក ហើយនិងមានស្នាមឈ្នូតៗ ចំនែកទ្វារមួយត្រូវព្យួររណែងរណោងដាច់ចេញពីត្រចៀកម្ខាង។

ហឺម៉ាយអូនីយកដៃខ្ទប់មាត់របស់នាង ហើយដើរសំដៅទៅបន្ទប់ខាងចុងគេ។ នៅពេលដែលនាងទៅដល់ នាងក៏បន្លឺឡើងថា៖

- សួស្តី មីតថល តើឯងសុខសប្បាយជាទេ?

ហេរី និងរ៉ុនដើរទៅមើល។ ម៉ុននីង មីតថលកំពុងតែអណ្តែតពីលើធុងបង្គន់ ព្រមទាំងយកម្រាមដៃទ្រចង្ការបស់នាង។

- នេះគឺជាបន្ទប់ទឹកសិស្សស្រី- នាងនិយាយ សម្លឹងមើលរ៉ុន និងហេរីដោយសង្ស័យ។ - ពួកគេមិនមែនជាស្រីឯណា។

- ទេ- ហឺម៉ាយអូនីយល់ស្របតាម។ - ខ្ញុំគ្រាន់តែចង់បង្ហាញប្រាប់ពួកគេថាតើ...អឺ...កន្លែងនេះស្អាតប៉ុណ្ណាដែរ។

នាងបក់ដៃយ៉ាងស្រពិចស្រពិលទៅកាន់កញ្ចក់គគ្រិចដ៏ចាស់មួយ ហើយនិងទៅកម្រាលសុទ្ធតែភក់ជ្រាំ។

- សួរនាងទៅមើល ថាមានបានឃើញអ្វីដែរអត់- ហេរីធ្វើមាត់អេចអូចដាក់ហឺម៉ាយអូនី។

- ហេតុអ្វីបានជាឯងខ្សឹបខ្សៀវគ្នាអញ្ចឹង?- មីតថលស្រដី ដោយសម្លឹងមើលវាមិនដាក់ភ្នែក។

- គ្មានអីទេ- ហេរីនិយាយយ៉ាងរួសរាន់។ - ពួកយើងចង់សួរថា...

- ខ្ញុំបន់ឲ្យតែឈប់មានមនុស្សនិយាយពីក្រោយខ្នងខ្ញុំទេ!- មីតចលឧទានឡើង ដោយសំឡេងឈ្លក់ៗទាំងទឹកភ្នែកទឹកសំបោរ។ - ខ្ញុំមានអារម្មណ៍ ឯងដឹងទេ ទោះបីជាខ្ញុំស្លាប់ទៅហើយក្តី...

- មីតចល គ្មាននរណាម្នាក់ចង់ធ្វើ ទុក្ខបុកម្នេញឯងនោះទេ- ហឺម៉ាយអូនីនិយាយ។ - ហេរីគ្រាន់តែ...

- គ្មាននរណាម្នាក់ចង់ធ្វើទុក្ខបុកម្នេញខ្ញុំ! នៅឌីដងខ្ញុំទៀត!- មីតចលយំយ៉ាងគ្រលួច។ - ជីវិតរបស់ខ្ញុំគ្មានអ្វីក្រៅពីទុក្ខវេទនា នៅកន្លែងនេះនោះទេ ហើយឥឡូវមានមនុស្សមករុកគួននំខានខ្មោចខ្ញុំទៀត!

- ពួកយើងចង់សួរឯងថា តើឯងមានបានឃើញអ្វីម្យ៉ាងគួរឲ្យអស់សំណើចដែរឬទេ នាពេលថ្មីៗនេះ- ហឺម៉ាយអូនីបន្លឺឡើងយ៉ាងរហ័ស។ - ពីព្រោះថា មានឆ្មាមួយក្បាលត្រូវបានគេវាយប្រហារនៅចំពីក្រៅទ្វារខាងមុខបន្ទប់ទឹករបស់ឯងតែម្តង នៅយប់បុណ្យហាឡូវីន។

- តើឯងមានបានឃើញនរណាម្នាក់នៅជិតៗនេះដែរឬទេក្នុងយប់នោះ?- ហេរីចោទសួរ។

- ខ្ញុំមិនបានចាប់អារម្មណ៍ផង- មីតចលតបយ៉ាងរំភើប។ - ភីវបានធ្វើឲ្យខ្ញុំកើតទុក្ខជាខ្លាំង ឯខ្ញុំក៏មកទីនេះ ហើយព្យាយាមសម្លាប់ខ្លួនឯង។ បន្ទាប់មក ជាការពិតណាស់ ខ្ញុំក៏នឹកឃើញថាខ្ញុំ...ថាខ្ញុំ...

- ស្លាប់រួចទៅហើយ- រ៉ុនជួយនិយាយបន្ថែម។

មីតចលយប់យ៉ាងខ្សឹកខ្សួលបែបសោកសង្រេង ហើយក៏ហោះឡើងទៅលើវេហាស៍ បត់មកវិញ រួចដាំដូងក្បាលចុះក្រោមសំដៅទៅក្នុងបង្គន់ ធ្វើឲ្យខ្ទាយទឹកប្រឡាក់ពេញខ្លួនពួកគេ និងរលាយខ្លួនបាត់ទៅ។ ប៉ុន្តែតាមរយៈទិសនៃសម្លេងយំខ្សឹកខ្សួលតិចៗរបស់នាង នាងបានមកស្នាក់កន្លែងណាមួយក្នុងបន្ទប់ទឹក។

ហេរី និងរ៉ុនក្រោកឈរឡើងដោយច្រហមាត់ធ្លុង ប៉ុន្តែហឺម៉ាយអូនីគ្រាន់តែញាក់ស្មាបែបនឿយណាយ ហើយនិយាយថា៖

- និយាយតាមត្រង់ទៅ ចំពោះមីតចលប៉ុណ្ណឹងគួរឲ្យរីករាយណាស់ទៅហើយ...តោះទៅយើង។

ហេរីទើបតែបិទទ្វារកន្លែងដែលមីតចលយំខ្សឹកខ្សួល ស្រាប់តែមានសំលេងដ៏ខ្លាំងមួយបានបន្លឺឡើង ធ្វើឲ្យពួកគេទាំងបីនាក់លោតកញ្ឆេងតែម្តង។

- រ៉ុន!

ពឿរស៊ី វីស្លី ឈរឆ្ងឹងទៅក្បាលជណ្តើរ ផ្លាកប្រធានសិស្សបញ្ចេញពន្លឺភ្លឺផ្លេក ព្រមទាំងមានទឹកមុខតក់ស្លុតទាំងស្រុង។

- នោះគឺជាបន្ទប់ទឹកសិស្សស្រីណា៎!- គាត់និយាយទាំងដង្ហក់។ - តើឯងកំពុង..?

- គ្រាន់តែដើរមើលជុំវិញហ្នឹងទេតើ- រ៉ុនញាក់ស្មា។ - គឺរកមើលភ័ស្តុតាង បងដឹងទេ...

ពឿរស៊ីឡើងមុខក្រហមក្នុងឫកពាមួយ ដែលធ្វើឲ្យហេរីនឹកឃើញដល់អ្នកស្រីវីស្លី។

- ចេញ...ពី...ទី...នេះ...ភ្លាម- ពឿរស៊ីឧទានឡើង ព្រមទាំងបោះជំហានវែងៗសំដៅមករកពួកគេ ហើយចាប់ផ្តើមកៀរពួកគេទៅតាម ដោយទះពួកគេភ្លឹបៗនឹងដៃរបស់គាត់។ - តើឯងមិនខ្វល់ថាគេមើលមកយ៉ាងម៉េចទេវី? បែរជាមកទីនេះ ខណៈពេលដែលអ្នករាល់គ្នានៅញ៉ាំអាហារពេលល្ងាច...

- ហេតុអ្វីបានជាពួកយើងមិនគួរមកទីនេះ?- រ៉ុនបន្លឺឡើងទាំងក្តៅក្រហាយ ព្រមទាំងឈប់ដើរ ហើយសម្លក់មកពឿរស៊ី។ - ស្តាប់ណា៎ ពួកយើងមិនដែលប៉ះឆ្មានោះទេ!

- នោះហើយគឺជាអ្វីដែលខ្ញុំបានប្រាប់ជីននី- ពៀរស៊ីតបវិញយ៉ាងម៉ឺងម៉ាត់។ - ប៉ុន្តែនាងហាក់ដូចជានៅតែគិតថា ឯងនឹងត្រូវគេបណ្តេញចេញពីសាលា ខ្ញុំមិនដែលឃើញនាងកើតទុក្ខយ៉ាងដូច្នេះទេ ឃើញតែយំរហូត ឯងគួរតែគិតដល់នាងខ្លះផង រាល់សិស្សឆ្នាំទីមួយទាំងអស់សុទ្ធតែរំជើបរំជួលចិត្តហួសហេតុដោយសារតែរឿងនេះ...

- បងទេដែលមិនខ្វល់ពីជីននីនោះ- រ៉ុនពោល ដែលត្រចៀករបស់វាឡើងក្រហមឆ្អៅ។ - បងគ្រាន់តែព្រួយបារម្ភខ្លាចខ្ញុំធ្វើឲ្យបងលែងបានធ្វើជាប្រធានសិស្សតែប៉ុណ្ណោះ...

- ដកប្រាំពិន្ទុពីក្រុមហ្គ្រីហ្វីនដ័រ!- ពៀរស៊ីឧទានឡើងយ៉ាងកំបុតកំបុយ ដោយយកដៃទប់ផ្លាកប្រធានសិស្សរបស់គាត់។ - ហើយខ្ញុំសង្ឃឹមថា ឯងនឹងទទួលបានមេរៀនមួយ! មិនត្រូវធ្វើអារឿងស៊ើបអង្កេតស្អីគេនោះទៀតទេ បើមិនអញ្ចឹងបងនឹងសរសេរសំបុត្រប្រាប់ម៉ាក់ហើយ!

ហើយគាត់ក៏បោះជំហានវែងៗចេញទៅ រីឯផ្នែកខាងក្រោយករបស់គាត់ក៏ឡើងក្រហមដូចជាត្រចៀករ៉ុនដែរ។

*

ហេរី រ៉ុន និង ហឺម៉ាយអូនី ជ្រើសរើសអង្គុយកៅអីណា ដែលនៅឆ្ងាយតាមដែលអាចធ្វើទៅបានពីពៀរស៊ីនៅក្នុងសហសាលនាយប់នោះ។ រ៉ុននៅតែមានអារម្មណ៍មិនល្អ ហើយចេះតែធ្វើឲ្យប្រឡាក់លើក្រដាសកិច្ចការផ្ទះមុខវិជ្ជាវេទមន្តរបស់វារហូត។ នៅពេលដែលវាឈោងយកចង្កឹះទាំងមិនដឹងខ្លួនដើម្បីជំរះស្នាមប្រឡាក់ចេញ វាបែរជាបញ្ឆេះក្រដាសស្បែកចៀមនោះទៅវិញ។ ដោយហុយផ្សែងដូចជាក្រដាសកិច្ចការផ្ទះរបស់វាដែរ រ៉ុនក៏ទាញ សៀវភៅស្តីអំពីមន្តអាគមសម្រាប់ថ្នាក់ដំបូងកំរិតពីរ បិទលាន់សូរផាំង។ ដែលធ្វើឲ្យហេរីភ្ញាក់ផ្អើលនោះគឺថា ហឺម៉ាយអូនីនៅតែបន្តស្រាវជ្រាវរឿងក្តីនោះដដែល។

- តើអាចជានរណាម្នាក់ទៅ?- នាងបន្លឺឡើងដោយស្ងាត់ៗ ហាក់ដូចជាកំពុងតែបន្តនូវការសន្ទនាដែលពួកគេទើបតែបានបង្កឡើងអំបាញ់មិញអញ្ចឹង។ - តើនរណាទៅដែលចង់បន្លាច ជនអវេទ និង ជនដែលមានដើមកំណើតពីពួកលោកិយទាំងអស់ឲ្យចេញពីសាលាហុកវ៉ាតនោះ?

- សាកគិតទៅមើល- រ៉ុនពោលធ្វើពុតជាមិនដឹង។ - តើយើងស្គាល់នរណាគេដែលគិតថា ជនដែលមានដើមកំណើតពីពួកលោកិយ គឺជាមនុស្សថោកទាបនោះ?

វាសម្លឹងមើលហឺម៉ាយអូនី។ ហឺម៉ាយអូនីសម្លឹងមើលមកវាវិញ បែបមិនឯកភាពតាម។

- ប្រសិនបើឯងកំពុងតែនិយាយអំពីមេលហ្វយនោះ...

- ជាការពិតហើយ!- រ៉ុនឧទានឡើង។ - ឯងក៏ស្តាប់ឮវានិយាយដែរ... "ពួកឯងនឹងជាអ្នកបន្ទាប់ហើយ អាពួកឈាមកខ្វក់!"...យ៉ាងម៉េច ឯងគ្រាន់តែសម្លឹងមើលមុខដូចកណ្តុរដ៏គម្រក់របស់វាទៅ ក៏ដឹងថាគឺជាវាដែរ...

- មេលហ្វយ ជាទាយាទស្លីធើរីនរឺ?- ហឺម៉ាយអូនីនិយាយទាំងសង្ស័យ។

- មើលទៅគ្រួសាររបស់វាមើល៍- ហេរីស្រដី ព្រមទាំងបិទសៀវភៅរបស់វាដែរ។ - ម្ដុំគ្នាគេហ្នឹងសុទ្ធតែនៅក្នុងក្រុមស្លីធើរីនទាំងអស់។ វាតែងតែអួតអាងជានិច្ចអំពីរឿងនេះ។ ហេងស៊យ ពួកគេអាចជាកូនចៅជំនាន់ក្រោយរបស់ស្លីធើរីនមែនហ្នឹង។ គ្រាន់តែឪពុករបស់វាក៏អាក្រក់ល្មមគ្រប់គ្រាន់នឹងអាចបញ្ជាក់បានទៅហើយ។

- ពួកគេអាចនឹងមានកូនសោចាក់ចូលទៅក្នុងបន្ទប់សម្ងាត់ជាច្រើនសតវត្សមកហើយ!- រ៉ុនបន្លឺឡើង។ - ប្រគល់តៗគ្នាមកពីឪពុកទៅកូន...

- អឺ- ហឺម៉ាយអូនីស្រដីយ៉ាងប្រុងប្រយ័ត្ន។ - ខ្ញុំគិតថា វាអាចទៅរួចដែរ...

- ប៉ុន្តែយើងមានភ័ស្តុតាងអ្វីបញ្ជាក់ទៅ?- ហេរីសួរទាំងងងឹតងងុល។

- ប្រហែលជាមានវិធីមួយ- ហឺម៉ាយអូនីតបយ៉ាងយឺតៗ ដោយទម្លាក់សម្លេងរបស់នាងឲ្យនៅខ្សោយដដែល ព្រមទាំងសម្លឹងមើលមួយឆ្វាច់ជុំវិញបន្ទប់នោះ ក្រែងលោប្រទះឃើញពៀរស៊ីមកជិត។ - ជាការពិតណាស់ វាគឺជាការលំបាកមួយ។ ហើយមានគ្រោះថ្នាក់ទៀតផង ពិតជាមានគ្រោះថ្នាក់ខ្លាំងណាស់។ បើតាមខ្ញុំរំពឹងទុក ពួកយើងប្រហែលជាត្រូវធ្វើបំពានវិន័យសាលាប្រហែលជាហាសិបឯណោះ...

- ប្រហែលជាមួយខែក្រោយ កាលណាឯងមានអារម្មណ៍ចង់ពន្យល់ ចាំប្រាប់ពួកយើងឲ្យបានដឹង មែនទេ?- រ៉ុននិយាយយ៉ាងម៉ូម៉ៅ។

- មិនអីទេ- ហឺម៉ាយអូនីពោលយ៉ាងសោះកក្រោះ។ - អ្វីដែលពួកយើងត្រូវធ្វើគឺត្រូវចូលទៅខាងក្នុងសហសាលក្រុមស្លីតឺរីនឲ្យបាន ហើយសាកសួរមេលហ្វ៊យនូវសំណួរពីរបី តែធ្វើយ៉ាងម៉េចកុំឲ្យវាដឹងថាជាពួកយើង។

- ប៉ុន្តែរឿងនោះមិនអាចទៅរួចទេ- ហេរីបន្លឺឡើង ខណៈពេលដែលរ៉ុនអស់សំណើច។

- ទេ វាមិនមែនថាមិនបាននោះទេ- ហឺម៉ាយអូនីតប។ - អ្វីទាំងអស់ដែលពួកយើងត្រូវការគឺទឹកថ្នាំបំលែងកាយខ្លះៗ តែប៉ុណ្ណឹងគ្រប់គ្រាន់ហើយ។

- ស៊្មីគេ?- រ៉ុន និងហេរីបន្លឺឡើងព្រមៗគ្នា។

- ស្នេពបានបញ្ជាក់អំពីវាក្នុងថ្នាក់រៀនកាលពីពីរបីសប្តាហ៍មុន...

- តើឯងគិតថាពួកយើងមិនអាចធ្វើឱសថដែលល្អប្រសើរជាជាងស្តាប់តាមស្នេពទេរឺ?- រ៉ុនរអ៊ូរទាំតិចៗ។

- ឱសថនោះអាចបំលែងខ្លួនពួកឯងទៅជាអ្នកផ្សេងទៀត។ សាកគិតទៅមើល! ពួកយើងអាចបំប្លែងខ្លួនទៅជាសិស្សស្លីតឺរីនបីនាក់។ គ្មាននរណានឹងដឹងថាជាពួកយើងនោះទេ។ មេលហ្វ៊យប្រហែលជានឹងប្រាប់យើងនូវរឿងខ្លះៗហើយ។ ឥឡូវនេះប្រហែលជាវាកំពុងតែអួតអំពីរឿងនេះហើយ ប្រសិនបើពួកយើងអាចបានស្តាប់ឮវានិយាយនោះ ជាប្រយោជន៍ល្អមួយ។

- អារបស់បំលែងកាយស៊្មីគេនេះស្តាប់មើលទៅដូចជាមិនស្រួលត្រចៀកសោះ- រ៉ុនស្រដីដោយចងចិញ្ចើម។ - យ៉ាងម៉េចទៅប្រសិនបើពួកយើងត្រូវក្លាយទៅជាសិស្សក្រុមស្លីតឺរីនបីនាក់ហូតនោះ?

- វានឹងអស់ប្រសិទ្ធិភាពហើយ បន្ទាប់ពីមួយរយៈពេល- ហឺម៉ាយអូនីនិយាយ ព្រមទាំងបក់ដៃរបស់នាងអោយរ៉ុនឈប់រអ៊ូទាំងអត់ទ្រាំមិនបាន។ - ប៉ុន្តែការទៅយកថ្នាំប្រភេទនេះពិតជាពិបាកខ្លាំងណាស់។ ស្នេពនិយាយថា វាមាននៅក្នុងសៀវភៅចំណងជើងថា ឱសថមានសក្តានុភាពបំផុត ហើយវាត្រូវគេទុកនៅក្នុងផ្នែកហាមឃាត់នៃបណ្ណាល័យ។

មានតែវិធីមួយគត់ដើម្បីអាចយកសៀវភៅចេញពីផ្នែកហាមឃាត់បាន៖ អ្នកត្រូវតែមានសំបុត្រអនុញ្ញាតចុះហត្ថលេខាដោយគ្រូម្នាក់ទើបបាន។

- ដូចជារកនឹកមិនឃើញពីមូលហេតុដែលតំរូវឲ្យចង់បានសៀវភៅនោះទាល់តែសោះ- រ៉ុនស្រដី - ប្រសិនបើពួកយើងមិនត្រូវទៅសាកល្បងបង្កើតឱសថអ្វីផង។

- ខ្ញុំគិតថា- ហឺម៉ាយអូនីបន្លឺឡើង - ប្រសិនបើពួកយើងនិយាយធ្វើដូចជាពួកយើងចាប់អារម្មណ៍ចំពោះទ្រឹស្តីបទនេះទៅប្រហែលជាពួកយើងនឹងមានឱកាស...

- អូ! ពុទ្ធោហ្អើយ! គ្មានគ្រូណានឹងចាក់បោកល្បិចកំប៉ិកកំប៉ុកហ្នឹងទេ- រ៉ុននិយាយ។ - សៀវភៅទាំងនោះច្បាស់ជាក្រាស់ណាស់ហើយ...

## វគ្គ X



# ចាល់ឆ្លាត់ជីរកំណាច

តាំងពីមានរឿងហេតុដ៏គួរឲ្យភ័យខ្លាចនៃពួកមេ្រញគង្វាលមក សាស្ត្រាចារ្យ ឡក់ហាត មិនបានយកសត្វដែលមានជីវិតមកក្នុងថ្នាក់រៀនទៀតទេ។ ជំនួសមកវិញ គាត់បានអានអត្ថបទចេញពីសៀវភៅរបស់គាត់ទៅកាន់ពួកគេ ហើយពេលខ្លះបានបញ្ចេញសកម្មភាពដែលបានកើតឡើងនោះម្តងទៀតផង។ ជាធម្មតា គាត់តែងតែពឹងឲ្យហេរីជួយគាត់ក្នុងរៀបចំឡើងវិញទាំងនេះ។ រហូតមកដល់ឥឡូវនេះ ហេរីត្រូវបានបង្ខំឲ្យដើរតួជាអ្នកភូមិ ត្រង់ស៊ីវ៉ាន្យៀ ដ៏សាមញ្ញម្នាក់ដែលឡក់ហាតបានជួយសង្គ្រោះពីបណ្តាសាប៉ាច់ប៉ោច ជួនដើរតួជាបិសាចទឹកកកក្បាលត្រជាក់ ជួនជាព្រាយជញ្ជក់ឈាម ដែលមិនអាចស៊ីអ្វីបានទាំងអស់ លើកលែងតែបន្លែ តាំងពីឡក់ហាតបានប្រដៅរួចមក។

ហេរីត្រូវបានទាញទៅខាងមុខមិត្តរួមថ្នាក់ភ្លាម ក្នុងពេលរៀនមេរៀនមុខវិជ្ជា ការពារនឹងមន្តអាគមងងឹត បន្ទាប់។ ពេលនេះវាត្រូវសម្តែងធ្វើជាមនុស្សចចក។ នេះមកពីវាគ្មានហេតុផលល្អណាមួយដើម្បីធ្វើឲ្យ ឡក់ហាត សប្បាយចិត្ត កុំអីវាក៏មិនមកធ្វើអញ្ចឹងដែរ។

- សម្លេងលូដ៏ឮហើយច្បាស់ណ៎ា ហេរី...ហ្នឹងហើយ... ហើយបន្ទាប់មក ខ្ញុំក៏សង្គ្រប់... អញ្ចេះ...រួចផ្តួលវាទៅលើកម្រាលឥដ្ឋ...ចុងក្រោយ... ខ្ញុំចាប់វាជាប់ដោយប្រើដៃម្ខាង... ហើយខ្ញុំភ្ជង់ចង្កឹះវេទមន្តចំករបស់វាដោយដៃម្ខាងទៀត... បន្ទាប់មក ខ្ញុំក៏ប្រមូលកម្លាំងរបស់ខ្ញុំដែលនៅសល់ទាំងប៉ុន្មាន ហើយសូត្របាលី ហូម៉ូហ្វុស ដ៏អស្ចារ្យ បំលែងចចកជារូបរាង មនុស្សវិញ ... វាបានបញ្ចេញនូវសម្លេងថ្ងូរគួរឲ្យអាណិតអាសូរមួយ... បន្តទៀត ហេរី... ខ្ពស់ជាងនោះទៀត... ល្អ... រោមសត្វរលាយបាត់ហើយ... ចង្កូមរួញខ្លីហើយ... ហើយវាក៏បានក្លាយជាបុរសម្នាក់ពេញលេញ។ ជារឿងតូចតាច ប៉ុន្តែមានផលល្អ... ហើយអ្នកភូមិផ្សេងទៀតនឹងចងចាំខ្ញុំ ជាវីរបុរសដែលបានជួយដោះលែងពួកគេចេញពីភាពភ័យខ្លាចជារៀងរាល់ខែ ដោយសារការវាយប្រហាររបស់មនុស្សចចក។

កណ្តឹងបានរោទិ៍ឡើង ហើយឡក់ហាតក្រោកឈរឡើង។

- កិច្ចការផ្ទះ៖ តែងកំណាព្យមួយអំពីជ័យជំនះរបស់ខ្ញុំទៅលើមនុស្សចចក វ៉ាហ្គា វ៉ាហ្គា! ច្បាប់ចម្លងនៃសៀវភៅ*វេទមន្តខ្ញុំ* ដែលមានចុះហត្ថលេខា នឹងប្រគល់ជូនដល់អ្នកតែងបានល្អជាងគេ!

## ចាល់ធ្លាត់ជីវកំណាច

សិស្សនៅក្នុងថ្នាក់ចាប់ផ្ដើមចាកចេញ។ ហេរីបានត្រឡប់ទៅខាងក្រោយបន្ទប់ ដែលរ៉ុន និងហឺម៉ាយអូនីកំពុងរង់ចាំនៅទីនោះ។

- តើហើយឬនៅ?- ហេរីស្ដីតិចៗ។

- ចាំអ្នកទាំងអស់គ្នាទៅអស់សិន។- ហឺម៉ាយអូនីស្រដីដោយម៉ឺងម៉ាត់។ - តោះទៅ...
នាងបានចូលទៅជិតតុរបស់ឡក់ហាត ក្រដាសមួយសន្លឹកក្ដាប់យ៉ាងណែននៅក្នុងដៃរបស់នាង ហេរី និងរ៉ុននៅស្គាំដៃខាងក្រោយនាង។

- អឺ... សាស្ត្រាចារ្យឡក់ហាត?- ហឺម៉ាយអូនីនិយាយជាប់ៗ។ - ខ្ញុំចង់... យកសៀវភៅនេះចេញពីបណ្ណាល័យ។ គ្រាន់តែអានពីសាវតារប៉ុណ្ណោះ។- នាងបានយកសន្លឹកក្រដាសចេញមក ដៃរបស់នាងញ័រតិចៗ។ - ប៉ុន្តែរបស់នេះគឺ វានៅក្នុងផ្នែកហាមឃាត់របស់បណ្ណាល័យ ដូច្នេះ ខ្ញុំត្រូវការសាស្ត្រាចារ្យម្នាក់ចុះហត្ថលេខាដើម្បីយកវាបាន... ខ្ញុំប្រាកដថា វានឹងអាចជួយខ្ញុំឲ្យយល់ពីអ្វីដែលលោកនិយាយនៅក្នុងសៀវភៅ *ការធ្វើដំណើរជាមួយប៉ែត* អំពីពិសដែលមានឥទ្ធិពលយឺតៗ...

- អ៎ា! *ការធ្វើដំណើរជាមួយប៉ែត*- ឡក់ហាតនិយាយ ព្រមទាំងយកក្រដាសពីដៃនាង ហើយញញឹមយ៉ាងពព្រាយដាក់នាង។ ប្រហែលជាសៀវភៅដែលខ្ញុំពេញចិត្តជាងគេហើយ។ ឯងចូលចិត្តវាមែនទេ?

-អូ! មែនហើយ- ហឺម៉ាយអូនីនិយាយទាំងត្រេកត្រអាល។ - វិធីដែលលោកគ្រូដាក់អន្ទាក់អាមួយចុងក្រោយ នឹងប្រដាប់តម្រងតែនោះ...

- មែនហើយ ខ្ញុំជឿថាគ្មាននរណាម្នាក់នឹងប្រកាន់ខ្ញុំ ដែលគ្រាន់តែជួយសិស្សដ៏ឆ្នើមប្រចាំឆ្នាំរបស់ខ្ញុំបន្តិចបន្តួចនោះទេ- ឡក់ហាតស្រដីយ៉ាងកក់ក្ដៅ រួចគាត់បានទាញចេញនូវប៉ាកកាស្លាបក្ងោកដ៏ធំមួយ។ - មែនហើយ ពិតជាស្អាតណាស់ មិនថាអញ្ចឹង?- គាត់និយាយ ដោយយល់ច្រឡំពីទឹកមុខក្រហមឆេះរបស់រ៉ុន។ - ជាធម្មតាខ្ញុំទុកស្លាបប៉ាកកានេះសម្រាប់តែចុះហត្ថលេខាលើសៀវភៅប៉ុណ្ណោះ។

គាត់បានគូសវាសនូវហត្ថលេខាដ៏ធំរាងមូលៗ នៅលើក្រដាស ហើយហុចវាទៅឲ្យហឺម៉ាយអូនីវិញ។

- និយាយអញ្ចឹង ហេរី- ឡក់ហាតបន្លឺឡើង ពេលដែលហឺម៉ាយអូនីបត់ក្រដាសទាំងឆ្គង រួចដាក់ទៅក្នុងកាតាបរបស់នាង។ - ស្អែកជាការប្រកួតកីឡាហ្វីដឌីច្ចរដូវកាលថ្មីហើយ ខ្ញុំនិយាយត្រូវទេ? ហ្គ្រីហ្វីនដ័រប្រកួតជាមួយស្លីតឺរីន មែនទេ? ខ្ញុំឮថា ឯងគឺជាសមាជិកក្រុមដ៏សំខាន់ម្នាក់។ ខ្ញុំធ្លាប់ជាកីឡាករដេញចាប់បាល់ម្នាក់ដែរ។ ខ្ញុំត្រូវបានគេអញ្ជើញអោយទៅហ្វឹកហ្វឺនសម្រាប់ក្រុមជម្រើសជាតិ ប៉ុន្តែខ្ញុំចង់បូជាជីវិតរបស់ខ្ញុំទៅដល់ការកំចាត់អាគមងងឹតជាង។ ប៉ុន្តែ ប្រសិនបើឯងមានអារម្មណ៍ត្រូវការការហ្វឹកហាត់ឯកជនបន្តិចបន្តួចនោះ មិនបាច់ខ្លាចចិត្តថ្លើមខ្ញុំទេ។ ខ្ញុំរីករាយជានិច្ចក្នុងការផ្ទេរជំនាញរបស់ខ្ញុំទៅឲ្យកីឡាករខ្វះសមត្ថភាព...

ហេរីបន្លឺសម្លេងស្អកស្អាមួយនៅក្នុងបំពង់ក ហើយក៏ប្រញាប់ចេញទៅបន្ទាប់ពីរ៉ុន និងហឺម៉ាយអូនី។

- ខ្ញុំសឹងតែមិនជឿឡើយ- វានិយាយ ពេលដែលពួកគេទាំងបីនាក់ពិនិត្យមើលហត្ថលេខានៅលើក្រដាស។ - សូម្បីតែសៀវភៅដែលយើងស្នើសុំចង់បាននោះ ក៏គាត់មិនខ្វីក្រឡេកភ្នែកមើលផង។

- នោះក៏ព្រោះតែគាត់គឺជាមនុស្សដែលគ្មានខួរក្បាល- រ៉ុនបញ្ជាក់។ - ប៉ុន្តែនរណាទៅខ្វល់ទៅ យើងបានអ្វីដែលយើងចង់បានហើយតើ។

- គាត់មិនមែនជាមនុស្សគ្មានខួរក្បាលទេ- ហឺម៉ាយអូនីប្រកែកដោយសម្លេងខ្លាំងៗ ពេលដែលពួកគេរត់បានពាក់កណ្ដាលផ្លូវទៅកាន់បណ្ណាល័យ។

- ឯងនិយាយការពារគាត់ មកពីគាត់បានសរសើរឯងថាជាសិស្សឆ្នើមប្រចាំឆ្នាំហ្នឹងអី្ហ...

ពួកគេបានបន្ថយសម្លេងនិយាយ ពេលដែលពួកគេចូលមកដល់បណ្ណាល័យដ៏ស្ងាត់ឈឹង។

អ្នកស្រីភីន ជាបណ្ណារក្ស មានរូបរាងស្គម ជាស្ត្រីម្នាក់ដែលឆាប់ខឹង រាងគាត់មើលទៅដូចជាសត្វត្មាតខ្វះចំណីស៊ីមួយក្បាលអ៊ីចឹង។

- សៀវភៅ*ឱសថមានអានុភាពខ្លាំងក្លាបំផុត*?- គាត់បាននិយាយជាប់ៗមាត់ដោយមន្ទិលសង្ស័យ និងកំពុងព្យាយាមទាញក្រដាសចេញពីដៃហឺម៉ាយអូនី ប៉ុន្តែហឺម៉ាយអូនីពុំព្រមលែងឡើយ។

- ខ្ញុំសុំរក្សាក្រដាសនេះទុក បានទេ- នាងនិយាយទាំងដកដង្ហើមមិនស្មើគ្នា។

- ពុទ្ធោ! អោយគាត់ទៅ!- រ៉ុនឧទានឡើង ព្រមទាំងទាញដៃនាងចេញ រួចហុចក្រដាសទៅអោយអ្នកស្រីភីន។ - ចាំពួកយើងសុំហត្ថលេខារបស់គាត់មួយទៀតឲ្យឯង។ ឯងចង់បានប៉ុន្មាន ក៏គាត់ព្រមចុះឲ្យដែរ។

អ្នកស្រីភីន លើកក្រដាសនោះឡើងដាក់ចំពន្លឺថ្ងៃ ខ្លាចក្រែងមានការក្លែងបន្លំ ប៉ុន្តែវាមិនអីទេ។ គាត់បានដើរចេញទៅក្នុងចំនោមធ្នើរខ្ពស់ៗ ហើយពីរបីនាទីក្រោយមក គាត់ក៏បានត្រឡប់មកវិញ ជាមួយនឹងសៀវភៅដ៏ធំមួយក្បាលនៅនឹងដៃដែលមើលទៅដូចជាដុះផ្សិតផង។ ហឺម៉ាយអូនី បានដាក់សៀវភៅនោះដោយប្រុងប្រយ័ត្នទៅក្នុងកាតាបរបស់នាង ហើយពួកគេក៏ចាកចេញទៅដោយព្យាយាមមិនដើរលឿនពេក ក្រែងលោគេសង្ស័យ។

ប្រាំនាទីក្រោយមក ពួកគេបានចូលមកដល់បន្ទប់ទឹកខូចប្រើមិនកើត របស់ ម៉ុននីង មីតថល ម្តងទៀត។ ហឺម៉ាយអូនីបានប្រឆាំងនឹងការជំទាស់របស់រ៉ុន ដោយចង្អុលបង្ហាញថា វាគឺជាកន្លែងចុងក្រោយហើយ ដែលពួកអ្នកជានឹងទៅប្រសិនបើត្រូវការទីសម្ងាត់ ដូចនេះពួកគេមានភាពឯកជនពេញលេញ។ ម៉ុននីង មីតថល កំពុងយំឮៗនៅក្នុងបន្ទប់តូចរបស់នាង ប៉ុន្តែពួកគេមិនរវល់ឡើយ។

ហឺម៉ាយអូនីបានបើកសៀវភៅ *ឱសថមានអានុភាពខ្លាំងក្លាបំផុត* ដោយប្រុងប្រយ័ត្ន ហើយពួកគេទាំងបីនាក់បានបន្ទាបខ្លួនចុះមើលលើទំព័រដែលមានស្នាមអុជដ៏កខ្វក់។ គ្រាន់តែក្រឡេកមើលក៏ដឹងថា ហេតុអ្វីបានជាគេដាក់សៀវភៅនេះក្នុងផ្នែកហាមឃាត់ដែរ។ ទឹកថ្នាំវេទមន្តខ្លះមានឥទ្ធិពលគួរឲ្យខ្ពើមរអើម ដែលនឹកស្មានមិនដល់ ហើយមានរូបភាពដ៏គួរឲ្យព្រឺសម្បុរមួយចំនួន ព្រមទាំងបន្ថែមនូវរូបបុរសម្នាក់ ដែលមើលទៅដូចជារូបរាងត្រូវបានផ្លាស់ប្តូរ គ្រឿងក្នុងចេញមកក្រៅ ក្រៅចូលទៅក្នុង មានទាំងរូបមេធ្មប់ម្នាក់កំពុងដុះដៃជាច្រើនគូបន្ថែមទៀតចេញពីក្បាលរបស់គាត់។

- គឺនេះហើយ- ហឺម៉ាយអូនីបន្លឺឡើងដោយក្តីរំភើប ពេលនាងរកឃើញទំព័រដែលមានចំណងជើងថា *ទឹកថ្នាំបំលែងកាយ*។ ទំព័រនោះត្រូវបានរចនាដោយរូបគំនូរមនុស្សជាច្រើន ដែលកំពុងប្រែរូបទៅជាមនុស្សផ្សេងទៀតបានពាក់កណ្តាល។ ហេីសង្ឃឹមយ៉ាងស្មោះត្រង់ថា វិចិត្រករគ្រាន់តែស្រមើស្រមៃគូរទឹកមុខឈឺចាប់ដ៏លំបាកលំបិនរបស់ពួកគេតែប៉ុណ្ណោះ។

- នេះជាទឹកថ្នាំវេទមន្តដ៏ស្មុគស្មាញជាងគេបំផុត ដែលខ្ញុំបានជួបប្រទះ- ហឺម៉ាយអូនីនិយាយ ពេលពួកគេត្រួតពិនិត្យមើលគ្រឿងផ្សំ។ - រុយស្លាបជរ ឈ្លើង ស្មៅប្រែរូប និង ស្មៅពក- នាងនិយាយខ្សឹបៗ ដោយកំពុងអូសម្រាមដៃរបស់នាងចុះបញ្ជីតាមឈ្មោះគ្រឿងផ្សំ។ - ល្អ គ្រឿងផ្សំទាំងនេះងាយស្រួលរកទេ សុទ្ធតែមាននៅក្នុងទូដាក់អីវ៉ាន់របស់សិស្ស យើងអាចរកបាន។ អូ! មើល

នេះ ស្នេងកិនជាម្សៅរបស់សេះស្នែងពីរ... មិនដឹងជាត្រូវទៅរកកន្លែងណានោះទេ... បំណែកស្បែកតូចៗនៃ សត្វប៊ូមស្លែង... អាហ្នឹងក៏មិនងាយរកដែរ... ហើយនិងបំនែកបន្តិចបន្តួចនៃមនុស្សដែលយើងចង់ប្រែរូបទៅជា។

- ខ្ញុំស្តាប់មិនច្រឡំទេរឺ?- រ៉ុនសួរយ៉ាងម៉ឹងម៉ាត់។ -តើឯងចង់មានន័យថាម៉េច បំនែកបន្តិចបន្តួចរបស់មនុស្សដែលយើងចង់ប្រែរូបទៅជា? សាកតែដាក់ក្រចកជើងក្រេបចូលមើល៍ ខ្ញុំធានាថាទោះជាស្លាប់ក៏ខ្ញុំមិនព្រមផឹកដែរ...-
ហឺម៉ាយអូនីនិយាយបន្ត ហាក់ដូចជានាងមិនបានឮវា។

- យើងមិនទាន់ត្រូវបារម្ភពីរឿងនោះនៅឡើយទេ ពីព្រោះយើងបន្ថែមគ្រឿងទាំងនោះពេលក្រោយ...

រ៉ុនបែរទៅរកហេរីដោយកប់យោបល់។ ហេរីវិញកំពុងតែមានកង្វល់។

- តើឯងមានដឹងថា តើយើងត្រូវលួចយកមកច្រើនប៉ុណ្ណាទេ? បំណែកតូចៗនៃស្បែករបស់សត្វ ប៊ូមស្លែង ច្បាស់ជាមិននៅក្នុងទូសំភារៈរបស់សិស្សឡើយ។ តើយើងធ្វើម៉េចទៅ រឺក៏ត្រូវលួចចូលទៅក្នុងបន្ទប់រក្សាឱសថផ្ទាល់ខ្លួនរបស់ស្នេប? ខ្ញុំមិនដឹងថា នេះជាគំនិតល្អរឺក៏អត់នោះទេ...

ហឺម៉ាយអូនី បិទសៀវភៅឮសូរគ្រឹប។

- ល្អ ប្រសិនបើពួកឯងទាំងពីរកំសាកនោះ ក៏គ្មានបញ្ហាដែរ- នាងនិយាយ។ មានស្នាមភ្លឹពណ៌ផ្កាឈូកនៅលើថ្ពាល់របស់នាង ហើយភ្នែករបស់នាងមានពន្លឺភ្លឺជាងធម្មតា។ - ឯងដឹងទេ ខ្ញុំក៏មិនចង់ប្រព្រឹត្តខុសវិន័យប៉ុន្មានដែរ។ ខ្ញុំគិតថា ការគំរាមកំហែងដល់ពួកមានដើមកំណើតពីពួកលោកិយ គឺអាក្រក់ជាងធ្វើទឹកថ្នាំវេទមន្តដ៏វេទនានេះឆ្ងាយណាស់។ ប៉ុន្តែប្រសិនបើឯងមិនចង់រកឃើញថាជនដៃដល់នោះគឺជាមេលហ្វ៊យរឺក៏អត់ទេ ខ្ញុំនឹងត្រលប់ទៅរកអ្នកស្រីភីនឥឡូវនេះ ហើយប្រគល់សៀវភៅជូនគាត់វិញភ្លាម...

- ខ្ញុំមិនដែលគិតថានឹងបានឃើញថ្ងៃដែលឯងបញ្ចុះបញ្ចូលពួកយើងឲ្យធ្វើខុសវិន័យឡើយ- រ៉ុននិយាយ។ - ល្អ! យើងនឹងធ្វើវា។ ប៉ុន្តែសូមកុំដាក់ក្រចកជើងអី បានទេ?

- និយាយទៅនិយាយមក តើវាត្រូវចំណាយពេលប៉ុន្មាន?- ហេរីសួរដោយងឿងឆ្ងល់ ពេលដែលហឺម៉ាយអូនីមើលទៅដូចជារីករាយជាងមុន ហើយបើកសៀវភៅម្តងទៀត។

- ស្មៅប្រែរូប ត្រូវបេះអោយចំថ្ងៃពេញបូណ៌មី ហើយស្លាបជរត្រូវចម្អិនរយៈពេលម្ភៃមួយថ្ងៃ... ខ្ញុំអាចនិយាយថា វានឹងរួចរាល់ប្រហែលជាក្នុងរយៈពេលមួយខែ ប្រសិនបើយើងអាចរកគ្រឿងផ្សំទាំងអស់បាន។

- មួយខែ?- រ៉ុនសួរបញ្ជាក់។ - ទំរាំដល់ពេលនោះ មេលហ្វ៊យ វាយប្រហារសិស្សកើតពីត្រកូលពួកលោកិយអស់ពាក់កណ្តាលសាលាបាត់ទៅហើយ!- ប៉ុន្តែភ្នែករបស់ហឺម៉ាយអូនីបានបង្រួមតូចយ៉ាងគួរឲ្យភ័យខ្លាចម្តងទៀត ហើយរ៉ុនក៏បានពោលបន្ថែមយ៉ាងលឿនទៀតថា៖

- ប៉ុន្តែវាជាគម្រោងដ៏ល្អបំផុតសម្រាប់ពួកយើង ដូច្នេះត្រូវតែព្យាយាមឡើង នេះបើតាមយោបល់របស់ខ្ញុំ។ ទោះជាយ៉ាងនេះក្តី ពេលដែលហឺម៉ាយអូនីកំពុងតែឆែកមើលថាផ្លូវស្ងាត់គ្មានមនុស្សហើយ ល្មមនឹងអាចឲ្យពួកគេចាកចេញពីបន្ទប់ទឹក រ៉ុនបែរមកខ្សឹបប្រាប់ហេរីថា៖

- ប្រាកដជានឹងគ្មានរឿងរ៉ាវធំដុំឡើយ ប្រសិនបើឯងអាចផ្តួល មេលហ្វ៊យ ឲ្យធ្លាក់ពីលើអំបោសរបស់វាបាននៅថ្ងៃស្អែក។

*

**ចាល់ឆ្នាត់ជីវកំណាច**

នៅព្រឹកថ្ងៃសៅរ៍ ហេរីបានភ្ញាក់តាំងពីព្រលឹម ហើយសម្រាកមួយសន្ទុះសញ្ជឹងគិតពីកីឡា ឃ្វីដឌីច្ច ដែលនឹងប្រព្រឹត្តទៅនៅពេលដ៏ខ្លីខាងមុខនេះ។ វាជ្រួលច្របល់ក្នុងចិត្ត ចេះតែខ្វល់មិនដឹងជាត្រូវ ដំបង ស្ដីបន្ទោសឲ្យយ៉ាងណាទេ ប្រសិនបើក្រុមហ្គ្រីហ្វីនដ័រចាញ់ ណាមួយខ្វល់ថាត្រូវប្រឈមមុខនឹងក្រុមជិះអំបោសហោះលឿនបំផុតទាំងនោះយ៉ាងណា។ វាមិនដែលចង់ជួលក្រុមស្លីតឺរីនអាក្រក់យ៉ាងនេះនោះទេ។ កន្លះម៉ោងក្រោយពីការសម្រាកនៅទីនោះទាំងពោះរបស់វាកំពុងតែក្ងរគ្រូកៗ វាក៏ក្រោកឡើងស្លៀកពាក់ ហើយធ្វើដំណើរទៅស្រស់ស្រូបអាហារពេលព្រឹកមុនជាងសព្វដង។ ទៅដល់កន្លែងនោះ វាបានឃើញក្រុមហ្គ្រីហ្វីនដ័រប្រមូលផ្ដុំគ្នាអង្គុយនៅតុទំនេរវែងមួយ។ ទាំងអស់គ្នាមើលទៅដូចជាតឹងតែង ហើយមិនសូវមាត់កឡើយ។

នៅពេលជិតដល់ម៉ោងដប់មួយ សិស្សទាំងអស់ចាប់ផ្ដើមចុះព្រួទៅកាន់ទីលានប្រកួតកីឡាឃ្វីដឌីច្ច។ ថ្ងៃនេះរាងមានសំណើមតិចៗ ព្រមទាំងមានផ្គរលាន់ក្នុងក្ដាំងផង។ រ៉ុន និង ហឺម៉ាយអូនី បានមកយ៉ាងប្រញាប់ប្រញាល់ដើម្បីជូនពរដល់ ហេរី ឲ្យមានសំណាងល្អ ពេលដែលវាហៀបនឹងចូលបន្ទប់ផ្លាស់ប្ដូរសម្លៀកបំពាក់។ សមាជិកទាំងអស់បានយកសម្លៀកបំពាក់ពណ៌ក្រហមឆ្អៅប្រចាំក្រុមហ្គ្រីហ្វីនដ័រចេញមក ហើយក៏អង្គុយចាំស្ដាប់ការលើកទឹកចិត្តរបស់ដំបងមុនការប្រកួតមកដល់។

- ស្លីតឺរីន មានអំបោសល្អជាងពួកយើង។- វាបានផ្ដើម។ - នេះជារឿងពិតប្រកែកមិនបានឡើយ។ ប៉ុន្តែពួកយើងមានកីឡាករឆ្នើមជាងពួកគេ។ ពួកយើងបានហ្វឹកហាត់ស្វិតស្វាញជាងពួកគេ ពួកយើងតស៊ូមិនថាអាកាសធាតុអាក្រក់យ៉ាងណានោះទេ...។ (- ត្រូវហ្នឹង វាហួសពីត្រូវទៅទៀត!- ចច វីស្លីនិយាយរអ៊ូ ។ - ខ្លួនខ្ញុំមិនដែលថាបានស្ងួតស្រួលបួលម្ដងណាឡើយ តាំងពីខែសីហាមកម្ល៉េះ។) -...ហើយ ពួកយើងនឹងធ្វើឲ្យពួកគេស្ដាយក្រោយ ដែលបានអនុញ្ញាតឲ្យអាសំអុយមេលហ្វ៊យនោះយកលុយវែកផ្លូវចូលក្រុមប្រកួត។

ចិត្តកំពុងតែពុះពារ ដំបងក៏បែរទៅរកហេរី។

- វាស្រេចទៅលើឯងហើយ ហេរី។ ឯងត្រូវបង្ហាញពួកគេឲ្យបានភ្លឺភ្នែកថា កីឡាករដេញចាប់បាល់ ត្រូវតែមានទេពកោសល្យមិនមែនមានឪពុកជាអ្នកមាននោះទេ។ ហេរី ឯងត្រូវតែចាប់ស្នីតមាសនោះឲ្យបានមុន មេលហ្វ៊យ បើមិនអញ្ចឹងទេប្រាកដជាអសារបង់ហើយ ពីព្រោះថាថ្ងៃនេះពួកយើងត្រូវតែឈ្នះ ពួកយើងត្រូវតែធ្វើឲ្យបាន។

- មិនចាំបាច់តឹងតែងពេកទេណា៎ ហេរី!- ហ្វ្រីដនិយាយ ដោយមិចភ្នែកដាក់វា។

ពេលដែលពួកគេដើរចេញក្រៅសំដៅទីលានប្រកួត មានសម្លេងហ៊ោកញ្ជ្រៀវអបអរសាទរពួកគេ ភាគច្រើនជាសម្លេងអបអរសាទរ ពីព្រោះសិស្សក្រុមរ៉ាវីនក្លាហ្វ និងហាហ្វ៊លផហ្វ អន្ទះសាចង់ឃើញក្រុមស្លីតឺរីនចាញ់ ប៉ុន្តែពួកក្រុមស្លីតឺរីនក៏ខំប្រឹងស្រែកចំអកអោយមិនចាញ់ក្រុមផ្សេងទៀតប៉ុន្មានដែរ។ អ្នកស្រីហ៊ុច្ច គ្រូបង្ហាត់កីឡាឃ្វីដឌីច្ច បានសុំឲ្យហ្វ្លីនត៍ និងដំបងចាប់ដៃគ្នា ហើយពួកគេក៏ធ្វើតាម ដោយឆ្លៀតសម្លក់គ្នាចង់ស៊ីសាច់ហុតឈាម និងច្របាច់ដៃគ្នាយ៉ាងខ្លាំងខុសពីធម្មតា។

- ចាំស្ដាប់តាមកញ្ចែរបស់ខ្ញុំ!- អ្នកស្រីហ៊ុច្ចឧទានឡើង។ - បី... ពីរ... មួយ...។

អមជាមួយនឹងសំឡេងហ៊ោកញ្ជ្រៀវពីហ្វូងមនុស្សដើម្បីជួយលើកកម្លាំងចិត្ត កីឡាករទាំងដប់បួននាក់ហោះស្ទុយឆ្ពោះទៅផ្ទៃមេឃពណ៌ប្រផេះ។ ហេរីហោះខ្ពស់ជាងអ្នកឯទៀតៗ ភ្នែកមៀងមើលក្រែងឃើញស្នីតមាស។

- នៅទីនោះទេអេ៎ អាស្នាមក្បាល!- មេលហ្វ៊យស្រែកទៅហេរី ព្រមទាំងហោះវូទៅវូមកពីក្រោមហេរី ហាក់ដូចជាចង់បង្អួតពីល្បឿនអំបោសហោះរបស់វា។

**បាល់ប្លាត់ជីរកំណាច**

ហេរីគ្មានពេលនឹងឆ្លើយតបទៅវិញទេ។ នៅក្នុងខណៈពេលដ៏ខ្លីនោះ បាល់ ប្លាត់ជីរ ពណ៌ខ្មៅដ៏ធំមួយបានហោះយ៉ាងលឿនសំដៅទៅបុកវា។ វាគេចចេញពីបាល់នោះសឹងតែមិនទាន់។ សំណាងល្អដែរ បាល់នោះហោះប៉ះត្រឹមតែជើងសក់វាប៉ុណ្ណោះ។

- វិះនឹងត្រូវឯងហើយ ហេរី!- ចចបន្លឺឡើង ពេលហោះកាត់មុខវា ដោយមានដំបងមួយនៅនឹងដៃ ត្រៀមនឹងវាយបាល់ប្លាត់ជីរនោះសំដៅទៅរកក្រុមស្លីតឺរីនវិញ។ ហេរីបានឃើញចច វាយបាល់នោះមួយទំហឹងដៃឲ្យទៅចំ អាជ្រៀន ភូស៊ី ប៉ុន្តែដល់ពាក់កណ្ដាលផ្លូវ ស្រាប់តែបាល់នោះផ្លាស់ប្ដូរទិសដៅ រួចសំរុកមករកហេរីម្ដងទៀត។

ហេរីបានបន្ទាបខ្លួនយ៉ាងរហ័ស ដើម្បីគេចចេញពីវា ហើយចចបានវាយបាល់យ៉ាងខ្លាំងឲ្យសំដៅទៅរក មេលហ្វ័យ។ បាល់ប្លាត់ជីរបានបកក្រោយយ៉ាងរហ័សដូចជាគ្រាប់កាំភ្លើង ហើយតម្រង់ទៅរកហេរីម្ដងទៀត។

ហេរីបានបន្ថែមសន្ទុះល្បឿន ហើយបោះពួយទៅចំហៀងទីលានប្រកួត។ វាឮសំឡេងរបស់បាល់ប្លាត់ជីរដែលតាមពីក្រោយវា។ តើកើតអីហ្នឹង ? បាល់ប្លាត់ជីរមិនដែលសំដៅរកកីឡាករតែម្នាក់ដូចនេះទេ។ វាជាភារកិច្ចរបស់ពួកវាក្នុងការព្យាយាមទម្លាក់កីឡាករពីលើអំបោសតាមតែអាចធ្វើបាន...

ហ្វ្រេដ វីស្លី កំពុងចាំវាយបាល់ប្លាត់ជីរនោះនៅចុងម្ខាងទៀត។ ហេរីបានអោន ពេលដែលហ្វ្រេដគ្រវែងដំបងដាក់បាល់ប្លាត់ជីរនោះមួយទំហឹង ធ្វើឲ្យបាល់នោះប៉ើងទៅម្ខាង។

- ប៉ុណ្ណឹងរួចរាល់ហើយ!- ហ្វ្រេដស្រែកហ៊ោដោយមោទនៈ ប៉ុន្តែមិនដូចវាគិតទេ បាល់ប្លាត់ជីរនោះស្រាប់តែបោះពួយលឿនស្លេវមករកហេរី ហាក់ដូច ហេរីហ្នឹងជាមេដែកទាញវាមកអញ្ចឹង បណ្ដាលឲ្យហេរីត្រូវហោះចេញយ៉ាងលឿនបំផុត។

មេឃចាប់ផ្ដើមភ្លៀងហើយ។ តំនក់ទឹកភ្លៀងធ្ងន់ៗធ្លាក់មកលើមុខរបស់ហេរី រួចខ្ទាយពីលើវ៉ែនតារបស់វា។ វាមិនដឹងជាកីឡាករក្រុមរបស់វាឯទៀតប្រកួតយ៉ាងណាៗហើយនោះទេ ទាល់តែបានឮលី ចចដាន់ប្រកាសថាៈ

- ពិន្ទុបានលើក្រុមស្លីតឺរីន ហុកសិបពិន្ទុ ទល់នឹង សូន្យ។

អំបោសពិសេសរបស់ក្រុមស្លីតឺរីនពិតជាមានប្រយោជន៍មែន ហើយស្របពេលជាមួយគ្នានោះដែរ បាល់ប្លាត់ជីរចំកួតនោះកំពុងតែធ្វើយ៉ាងណាឲ្យហេរីធ្លាក់ពីលើអំបោសមិនលែងសោះ។ ឥឡូវ ហ្វ្រេដ និងចចកំពុងតែហោះអមហេរី ធ្វើឲ្យហេរីមើលមិនឃើញអ្វីឡើយក្រៅពីដៃគ្រវែងចុះឡើងរបស់ពួកគេ ហើយឱកាសក្នុងការរកស្នីតមាសហ្នឹងក៏គ្មានទៀត កុំថាឡើយនិយាយដល់រកចាប់នោះ។

- មានគេលួចដាក់អាគមលើបាល់ប្លាត់ជីរនោះហើយ- ហ្វ្រេដនិយាយទាំងគ្រឹតធ្មេញ ដោយគ្រវែងដំបងរបស់វាមួយទំហឹងទប់បាល់ប្លាត់ជីរនោះ ពេលដែលវាមកវាយប្រហារហេរីម្ដងទៀត។

- យើងត្រូវការពេលសម្រាកមួយភ្លែត- ចចបន្លឺឡើង ដោយព្យាយាមឲ្យសញ្ញាទៅកាន់*ដំបង* ព្រមទាំងកំចាយបាល់ប្លាត់ជីរនោះម្ដងទៀត។

ដំបងបានទទួលសញ្ញាហើយ។ សំឡេងកញ្ចែរបស់អ្នកស្រី ហុច្ឆ បានបន្លឺឡើង ហើយហេរី ហ្វ្រេដ និងចចបោះពួយសំដៅទៅរកដី ដោយនៅតែព្យាយាមគេចពីបាល់ប្លាត់ជីរឆ្កួតៗនោះ។

- តើមានរឿងអីហ្នឹង?- ដំបងសួរ ខណៈពេលដែលក្រុមហ្គ្រីហ្វីដ័រជួបជុំគ្នា។ ក្រុមស្លីតឺរីននៅឯខាងនោះកំពុងតែសើចចំអកឲ្យ។ - យើងកំពុងតែចាញ់ប្រៀបគេហើយ។ ហ្វ្រេដ ចច តើពួកឯងទាំងពីរនៅឯណានៅពេលដែល បាល់ប្លាត់ជីរឃាំងមិនឲ្យអេនជីលីណា ស៊ុតបញ្ចូលទីនោះ?

- ពួកយើងនៅខាងលើប្រហែលប្រាំមួយម៉ែត កំពុងតែរវល់បញ្ឈប់បាល់ប្លាត់ជីរមួយផ្សេងទៀតដែលរកកលចង់ធ្វើឃាតហេរីណ៎ា អូលីវើ- ចចនិយាយទាំងច្រឡោត។ - មានគេកែប្រែបាល់នោះហើយ។ វាមិនព្រមលែងហេរីសោះ ហើយវាក៏មិនដែលសំដៅទៅរកកីឡាករណាផ្សេងទៀតដែរ។ ក្រុមស្លីតឺរីនច្បាស់ជាខូច លួចដាក់អ្វីម្យ៉ាងហើយ។

- ប៉ុន្តែបាល់ ប្លាត់ជីរ ទាំងអស់សុទ្ធតែបានចាក់សោទុកក្នុងការិយាល័យរបស់អ្នកស្រីហ៊ុច្ឆតាំងពីការហាត់សមចុងក្រោយរបស់ពួកយើងម្ល៉េះ ហើយពេលនោះក៏គ្មានអ្វីប្លែកជាមួយនឹងពួកវាដែរ...- ដំបងស្រដី ទាំងអន្ទះសា។

អ្នកស្រីហ៊ុច្ឆកំពុងតែដើរសំដៅមករកពួកគេ។ ពីក្រោយស្មារបស់គាត់ ហេរីអាចមើលឃើញក្រុមស្លីតឺរីនកំពុងតែសើចស្ទេញស្ទាញ ថែមទាំងចង្អុលមករកវាទៀត។

- ចាំស្តាប់ខ្ញុំ- ហេរីនិយាយ ខណៈពេលដែលគាត់កាន់តែខិតជិតទៅៗ - ប្រសិនបើអ្នកទាំងពីរនៅកៀកជាប់ខ្ញុំរហូតនោះ ចង់ឲ្យខ្ញុំចាប់ស្និតមាសបាន លុះត្រាតែវាហោះចូលដៃអាវខ្ញុំ។ សូមត្រលប់ទៅកាន់ក្រុមរបស់ពួកឯងវិញចុះ ទុកឲ្យខ្ញុំចាត់ការនឹងបាល់ប្លាត់ជីរនោះទៅបានហើយ។

- កុំចចេសពេក- ហ្វ្រេដស្រដី។ - ប្រយ័ត្នតែវាបុកដាច់ក្បាលទៅ។

ដំបងសម្លឹងមើលពីហេរី ទៅកាន់ត្រកូលវីស្លី។

- ដំបង នេះឆ្កួតទេតើ!- អាលីស្យា ស្ពីនណេត បន្លឺឡើងទាំងខឹងសម្បា។ - ឯងមិនអាចទុកហេរីចោលជាមួយនឹងបាល់ឆ្កួតៗនោះទេ។ យើងគួរតែសុំឲ្យមានការស៊ើបអង្កេត...

- ប្រសិនបើយើងបញ្ឈប់ការប្រកួតត្រឹមនេះ យើងនឹងត្រូវដកខ្លួនចេញពីការប្រកួតហើយ!- ហេរីឧទានឡើង។ - ហើយយើងមិនត្រូវចាញ់ក្រុមស្លីតឺរីនដោយសារតែបាល់ប្លាត់ជីរចំកួតមួយនោះទេ! ឆាប់ឡើង អូលីវើ ប្រាប់ពួកគេកុំឲ្យរវល់នឹងខ្ញុំអី!

អ្នកស្រីហ៊ុច្ឆបានមកដល់ពួកគេហើយ។

- រួចហើយរឺនៅ?- គាត់បានសួរដំបង។

ដំបងសម្លឹងមើលអាការដ៏ម៉ឺងម៉ាត់នៅលើទឹកមុខរបស់ហេរី។

- បានហើយ- វានិយាយ - ហ្វ្រេដ ចច ពួកឯងឮហេរីថាហើយ...ទុកឲ្យគេចាត់ការនឹងបាល់ប្លាត់ជីរនោះតែម្នាក់ឯងចុះ។

ឥឡូវនេះភ្លៀងធ្លាក់កាន់តែខ្លាំងមែនហើយ។ ក្រោយពេលកញ្ចែអ្នកស្រី ហ៊ុច្ឆ បន្លឺឡើងភ្លាម ហេរីក៏ហោះស្ទុះទៅលើមេឃហើយក៏ឮសម្លេងតាមចងពៀររបស់បាល់ប្លាត់ជីរមកប្រកិតពីក្រោយវាដែរ។ ហេរីហោះកាន់តែខ្ពស់ទៅៗ។ វាហោះឆ្វៃលចុះឡើង ម្តងទៅនេះម្តងទៅនោះ បត់បែនទៅលិចទៅកើត។ ទោះបីជារាងវិលមុខបន្តិចមែន តែហេរីនៅខំប្រឹងបើកភ្នែកធំៗ។ គ្រាប់ភ្លៀងធ្លាក់តក់ៗមកលើវ៉ែនតារបស់វា ហើយហូរចូលរន្ធច្រមុះរបស់វា ពេលដែលវាក្រឡាប់ខ្លួនគេចពីការវាយប្រហារដ៏រន្ធត់ពីបាល់ប្លាត់ជីរនោះម្តងទៀត។ វាអាចឮសំឡេងសើចក្អាកក្អាយពីហ្វូងមនុស្ស។ វាដឹងថាអាការរបស់វាពេលនេះពិតជាគួរឲ្យអស់សំណើចណាស់ ប៉ុន្តែបាល់ប្លាត់ជីរកំណាចនោះមានទម្ងន់ធ្ងន់ ហើយមិនអាចផ្លាស់ប្តូរទិសដៅឲ្យបានលឿនទាន់នឹងវាទេ។ វាចាប់ផ្តើមបង្ហោះខ្លួនធ្វើដូចជាជិះ

រទេះគោ ក្រវែលជុំវិញគែមកីឡាដ្ឋាន ផ្លៀតពេលមៀងមើលទៅកាន់បង្គោលទីរបស់ក្រុមហ្វ្រីហ្វិនដរ ឃើញ អាឌ្រីយ៉ាន ពីស៊ី កំពុងតែគេចពីដំបង...

សម្លេងង៉ាំងមួយឆ្លងកាត់ត្រចៀកហេរី បញ្ជាក់ថាបាល់ប្លាត់ជីរបានបុកខុសវាទៀតហើយ។ វាក៏ចាប់បត់ស្តាំ ហើយស្ទុះតាមទិសដៅផ្ទុយគ្នា។

- អូ្ហ! ហេរី ឯងកំពុងហាត់សមរបាំបាទេរឺ?- មេលហ្វ៊យស្រែកដាក់ ពេលដែលហេរីបង្វិលខ្លួនមួយជុំនៅកណ្តាលវេហាស៍ដើម្បីគេចពីបាល់ប្លាត់ជីរ។ ហេរីក៏គៀសខ្លួនចេញ ឯបាល់ប្លាត់ជីរតាមប្រជិតប្រជើយតែប៉ុន្មានសង់ទីម៉ែតពីខ្លួនវាប៉ុណ្ណោះ។ ស្រាប់តែពេលនោះ ពេលកំពុងងៀកមើលមកមេលហ្វ៊យដោយក្តីស្អប់ខ្ពើម ហេរីក៏បានឃើញរបស់ម្យ៉ាងនៅត្រចៀកខាងឆ្វេងរបស់មេលហ្វ៊យ៖ គឺស្នីតមាស។ មេលហ្វ៊យដោយហេតុតែកំពុងជាប់សើចចំអកឲ្យហេរី មិនបានចាប់អារម្មណ៍អ្វីឡើយ។

ដោយធ្វើអ្វីមិនកើត ហេរីក៏ឈប់សំកាំងនៅកណ្តាលអាកាស ព្រោះមិនហ៊ានស្ទុះទៅមុខខ្លាចក្រែងមេលហ្វ៊យឃើញស្នីតមាសដែរ។

វ៉ូ!

វានៅស្ងៀមយូរពេកហើយ។ បាល់ប្លាត់ជីរនោះបានបុកចំត្រង់កែងដៃវា។ ហេរីមានអារម្មណ៍ថា ដៃរបស់វាបាក់បាត់ទៅហើយ។ អារម្មណ៍ធីងធោង គួបផ្សំនឹងក្តីពើតផ្សានៅនឹងកែងដៃរបស់វា វាក៏រអិលធ្លាក់ចុះពីអំបោសទាំងខ្លួនទទឹកជោកដោយទឹកភ្លៀង សំណាងល្អ វាដាក់ជើងម្ខាងគាបអំបោសជាប់ត្រឹមជង្គង់។ ប៉ុន្តែដៃស្តាំរបស់វាយោលទៅយោលមកគ្មានប្រើការបានទៀតទេ។ បាល់ ប្លាត់ជីរ នោះក៏សំដៅមកធ្វើការវាយប្រហារជាលើកទីពីរ ម្តងនេះតម្រង់ចំមុខវាតែម្តង។ ហេរីក៏ប្តូរទិសដៅភ្លាម ជាមួយនឹងគំនិតតែមួយគត់ដែលនៅជាប់នឹងខួរក្បាលដ៏ស្ពឹកស្រពន់របស់វា៖ *ទៅរកមេលហ្វ៊យ*។

ដោយហោះកាត់ភ្លៀង ពោរពេញដោយក្តីឈឺចាប់ឥតឧបមា ហេរីបោះពួយទៅរកទឹកមុខមើលងាយដែលនៅពីក្រោមវាហើយឃើញមេលហ្វ៊យបើកភ្នែកធំៗដោយក្តីភ័យខ្លាច៖ មេលហ្វ៊យគិតថាហេរីកំពុងតែវាយប្រហារវាហើយ។

- ស្អីគេ...- វានិយាយទាំងដង្ហក់ ព្រមទាំងគ្រវាសខ្លួនចេញពីផ្លូវហេរី។

ហេរីដកដៃចេញពីអំបោស ហើយក៏កញ្ឆក់របស់អ្វីម្យ៉ាងទាំងមមើមមាយ។ វាមានអារម្មណ៍ថាម្រាមដៃរបស់វាបានប៉ះនឹងស្នីតមាស តែឥឡូវវានៅជាប់នឹងអំបោសដោយសារតែជើងរបស់វាប៉ុណ្ណោះ ហើយមានសំឡេងស្រែកហ៊ោកញ្ជ្រៀវពីហ្វូងទស្សនិកជននៅខាងក្រោម ខណៈពេលដែលវាធ្លាក់ចុះទៅក្រោម ដោយព្យាយាមតាំងស្មារតីកុំឲ្យសន្លប់។

ខ្លួនវាធ្លាក់ចូលទៅក្នុងវាលភក់ព្សូរក្អក ហើយក៏រមៀលចេញពីអំបោស។ ដៃស្តាំរបស់វាបត់ខុសពីធម្មតា។ ដោយកំពុងតែមីងមុាំងដោយការឈឺចាប់ វាឮសម្លេងហួច និងសម្លេងស្រែក ហាក់ដូចជាមកពីចម្ងាយ។ វាផ្តោតខ្សែភ្នែកទៅលើស្នីតមាសដែលវាក្តាប់បាននៅនឹងដៃរបស់វា។

- ជយោ- វានិយាយទាំងវង្វេងវង្វាន់ - យើងឈ្នះហើយ។

ហើយវាក៏សន្លប់បាត់ទៅ។

ពេលវាដឹងខ្លួនឡើងវិញ ភ្លៀងកំពុងតែធ្លាក់លើមុខវានៅឡើយ ហើយខ្លួនវានៅក្នុងទីលានប្រកួតដដែល តែមាននរណាម្នាក់កំពុងតែអោនមកមើលវា។ វាឃើញធ្មេញមួយក្រាសសចិញ្ចាច។

- អូ! ទេ មិនមែនលោកទេ- វានិយាយទាំងមិនចង់រួច។

- វាចាប់ផ្ដើមនិយាយផ្ដេសផ្ដាសហើយ- ឡាក់ហាតស្រដីឡើងញាប់ៗ ទៅកាន់ហ្វូងក្រុមប្រ៊ីហ្វីនដ័រដែលកំពុងតែចោមរោមមើលទាំងអន្ទះសា។ - មិនចាំបាច់ព្រួយបារម្ភទេ ហេរី។ ខ្ញុំព្យាបាលតែមួយភ្លែត ដៃរបស់ឯងនឹងជាភ្លាមជាមិនខាន។

- ទេ!- ហេរីតប។ - ខ្ញុំសុខចិត្តនៅអញ្ចឹងល្អជាង អរគុណហើយ...

វាព្យាយាមក្រោកអង្គុយ ប៉ុន្តែឈឺបួសវាធ្ងន់ធ្ងរខ្លាំងណាស់។ វាឮសម្លេងចុចក្រិកៗនៅជិតនោះ។

- ខ្ញុំមិនចង់ឲ្យឯងថតរូបខ្ញុំក្នុងសភាពបែបនេះនោះទេ ខូលីន- វានិយាយខ្លាំងៗ។

- ដេកសិនទៅ ហេរី- ឡាក់ហាតនិយាយលួងលោម។ - អាគមហ្នឹងធម្មតាទេ ខ្ញុំប្រើឡើងសឹកទៅហើយ។

- ហេតុអ្វីក៏មិននាំខ្ញុំទៅគិលានដ្ឋាន?- ហេរីពោលទាំងសង្កៀតធ្មេញ។

- លោកសាស្ត្រាចារ្យ គេគួរតែទៅដេកពេទ្យល្អជាង- ដំបងបន្លឺឡើង ខ្លួនសុទ្ធតែភក់ ប៉ុន្តែនៅតែមិនអាចទប់ចិត្តញញឹមស្ញេញបាន ទុកជាកីឡាករដេញចាប់បាល់ខ្លួនរបួសយ៉ាងនេះក៏ដោយ។ - ពិតជាចាប់បានល្អណាស់ ហេរី គ្មាននរណាប្រដូចទេ។ ខ្ញុំថានេះមិនទាន់ជាស្នៀតកំពូលរបស់ឯងទេ មែនទេ?

មើលទៅឆ្ងាយទៅ ហេរីឃើញហ្វ្រេដ និងចចវីស្លីកំពុងតែបង្ខំញាត់បាល់ប្លាត់ជីរកំណាចនោះចូលទៅក្នុងប្រអប់វា។ បាល់នោះ ដល់ពេលនេះហើយ ក៏នៅតែមិនទាន់អស់អានុភាពដដែល។

- សូមថយក្រោយបន្តិច- ឡាក់ហាតពោល ដោយកំពុងតែមូរដៃអាវពណ៌បៃតងឡើង។

- ទេ...កុំ...- ហេរីអង្វរទាំងទន់ខ្សោយ ប៉ុន្តែឡាក់ហាតកំពុងតែគ្រវីចង្កឹះវេទមន្តរបស់គាត់ទៅហើយ ហើយប៉ុន្មានវិនាទីក្រោយមកគាត់ក៏តម្រង់វាមករកដៃរបស់ហេរី។

អារម្មណ៍មិនស្រួលដ៏ចម្លែកមួយបានរត់តាមស្មារបស់ហេរី ហើយសាយភាយរហូតដល់ចុងម្រាមដៃរបស់ហេរី។ វាមានអារម្មណ៍ហាក់ដូចជាមានគេកំពុងបន្ទូរដៃរបស់វាអញ្ចឹង។ វាមិនហ៊ានសម្លឹងមើលអ្វីដែលកំពុងកើតឡើងនោះទេ។ វាក៏បិទភ្នែកឡើងជិត មុខវាងាកចេញពីដៃ ប៉ុន្តែសេចក្ដីភ័យខ្លាចដ៏អាក្រក់បំផុតរបស់វាកើតឡើងនៅពេលដែលមនុស្សម្នានៅជុំវិញខ្លួនវាដង្ហក់គ្រប់ៗគ្នា ចំនែកឯ ខូលីន គ្រីវី កំពុងតែចុចថតរូបយ៉ាងញាប់ដូចព្យុះ។ ដៃរបស់វាលែងឈឺទៀតហើយ...ប៉ុន្តែវាក៏លែងមានអារម្មណ៍ថាជាដៃទៀតដែរ។

- ហ្អា!- ឡាក់ហាតឧទាន។ - មែនហើយ។ អឺ...ជួនកាលវាអញ្ចឹងឯង។ ប៉ុន្តែ និយាយជារួម ឆ្អឹងលែងបាក់ទៀតហើយ។ ចាំតែប៉ុណ្ណឹងទៅបានហើយ។ អញ្ចឹង ហេរី ឯងគ្រាន់តែដើរទៅឲ្យគេពិនិត្យនៅគិលានដ្ឋានបន្តិចទៅបានហើយ...នុះ! លោកវីស្លី និងកញ្ញាហ្គ្រេនជឺរ...សូមអ្នកទាំងពីរជួយគ្រាហ៍គេទៅបន្តិចបានទេ?...ហើយអ្នកស្រីផុមហ្វ្រីនិងអាច...អឺ...រៀបចំឲ្យឯងបានធូរស្រួលបួល។

ខណៈដែលហេរីក្រោកឈរឡើង វាមានអារម្មណ៍ដូចជាផ្អៀងទៅម្ខាង។ វាសម្លឹងមើលខ្លួនប្រាណវាផ្នែកខាងស្ដាំ រួចដកដង្ហើមធំ។ អ្វីដែលវាមើលឃើញស្ទើរតែធ្វើឲ្យវាសន្លប់ម្ដងទៀតទៅហើយ។

ដៃដែលលៀនចេញពីចុងរ៉ូបរបស់ហេរី មើលទៅដូចជាស្រោមដៃធ្វើពីសាច់កៅស៊ូដ៏ក្រាស់មួយ។ វាសាកកម្រើកម្រាមដៃរបស់វា។ គ្មានចលនាបន្តិចសោះ។

**បាល់ប្លាត់ជីរកំណាច**

ឡុក់ហាតមិនបានព្យាបាលឆ្អឹងរបស់ហេរីសោះឡើយ។ គឺគាត់ដកឆ្អឹងរបស់វាចេញតែម្តង។

*

អ្នកស្រីផុមហ្វ្រីមិនរីករាយទាល់តែសោះចំពោះរឿងនេះ។

- ឯងគួរតែមករកខ្ញុំភ្លាមពេលនោះ!- គាត់ផ្ទុះកំហឹង ដោយកំពុងកាន់ដៃគ្មានវិញ្ញាណដែលកាលពីកន្លះម៉ោងមុននៅប្រើការបានសោះ។ - ខ្ញុំអាចព្យាបាលឆ្អឹងបានដោយប្រើពេលតែមួយភ្លែតប៉ុណ្ណោះ...ប៉ុន្តែការបណ្តុះឆ្អឹងមកវិញនោះ...

- កុំប្រាប់ខ្ញុំថាអ្នកស្រីមិនអាចធ្វើបានណា៎- ហេរីនិយាយបែបអស់សង្ឃឹម។

- ខ្ញុំពិតជាអាចធ្វើបាន ប៉ុន្តែវានឹងឈឺចាប់ណាស់- អ្នកស្រីផុមហ្វ្រីបន្លឺឡើងដោយក្រៀមក្រំ ព្រមទាំងគ្រវែងអាវដេកយប់មួយសម្រាប់ឲ្យហេរី។ - ឯងនឹងត្រូវដេកមួយយប់នៅទីនេះហើយ...

ហឺម៉ាយអូនីចាំនៅខាងម្ខាងវាំងននដែលទាញបិទជុំវិញគ្រែរបស់ហេរី ខណៈពេលដែលរ៉ុនកំពុងជួយស្លៀកពាក់អាវដេកយប់ឲ្យហេរី។ ទំរាំតែដាក់ដៃគ្មានឆ្អឹង ទន់ដូចជ័រនោះចូលក្នុងដៃអាវបាន ក៏ត្រូវចំណាយពេលច្រើនដែរ។

- តឡូវឯងចង់ការពារឡុក់ហាតយ៉ាងម៉េចទៀត ប៉ា ហឺម៉ាយអូនី?- រ៉ុនស្រែកសួរតាមវាំងនន ពេលដែលវាកំពុងទាញម្រាមដៃគ្មានវិញ្ញាណតាមកដៃអាវ។ - ប្រសិនបើហេរីចង់ឲ្យគេដកឆ្អឹងចេញនោះ វាច្បាស់ជាសុំគេហើយ។

- នរណាក៏មានកំហុសដែរ- ហឺម៉ាយអូនីស្រដី - ហើយវាក៏មិនឈឺទៀតដែរ មែនទេ ហេរី?

- លែងឈឺមែន- ហេរីតប - តែក៏គ្មានធ្វើអ្វីកើតទៀតដែរ។

ខណៈពេលដែលវាគ្រវែងខ្លួនទៅលើគ្រែ ដៃរបស់វាយោលយោកចុះឡើងគ្មានទិសដៅ។

ហឺម៉ាយអូនី និងអ្នកស្រីផុមហ្វ្រីក្រវែលវាំងននចូលមកជិតគ្រែរបស់ហេរី។ អ្នកស្រីផុមហ្វ្រីកំពុងតែកាន់ដបដ៏ធំមួយដែលមានឈ្មោះថា "ថ្នាំបណ្តុះឆ្អឹង" ។

- យប់នេះឯងយ៉ាប់បន្តិចហើយ- គាត់ពោល ដោយចាក់ថ្នាំមួយស្លាបព្រាបាយ ហើយហុចឲ្យវា។ - ការបណ្តុះឆ្អឹងឡើងវិញមិនមែនជាការងាយស្រួលឡើយ។

ឯការផឹកថ្នាំបណ្តុះឆ្អឹងនោះទៀតសោតក៏មិនងាយស្រួលប៉ុន្មានដែរ។ ថ្នាំនោះធ្វើឲ្យរលាកមាត់ និងករបស់ហេរី ធ្វើឲ្យវាក្អកផងរកក្អួតផង។ មាត់កំពុងតែស្តីឲ្យពីរឿងកីឡាគ្រោះថ្នាក់ និងគ្រូគ្មានជំនាញ អ្នកស្រីផុមហ្វ្រីក៏ថយចេញទៅ ទុកឲ្យរ៉ុន និងហឺម៉ាយអូនីជួយបញ្ច្រកទឹកហេរី។

- ទុកជាយ៉ាងណាក្តី យើងទទួលបានជ័យជំនះហើយ- រ៉ុននិយាយ ដោយញញឹមស្ញេញស្ញាញ។ - ឯងពិតជាចាប់បានល្អមែន។ មុខមេលហ្វ័យវិញ...មើលទៅហាក់ដូចជាវាត្រៀមខ្លួនសម្លាប់នរណាម្នាក់អញ្ចឹង!

- ខ្ញុំពិតជាចង់ដឹងថា វាអាចដាក់អាគមលើបាល់ប្លាត់ជីរនោះបានយ៉ាងម៉េចណាស់- ហឺម៉ាយអូនីបន្លឺឡើងយ៉ាងអាថ៌កំបាំង។

- ចាំដាក់សំណួរនេះចូលក្នុងបញ្ជីសំណួរ ដែលពួកយើងនឹងសួរវានៅពេលដែលពួកយើងផឹកថ្នាំបំលែងកាយនោះទៅ- ហេរីពោល ដោយផ្អែកខ្លួនដេកបណ្តើរ។ - ខ្ញុំសង្ឃឹមថាវារសជាតិល្អជាងថ្នាំនេះ...

- ដាក់បំណែកនៃក្រុមស្លីធើរីនហ្នឹង? កុំនិយាយលេងសើចអី- រ៉ុនស្រដី។

ទ្វារបន្ទប់គិលានដ្ឋានក៏របើកឡើងនាពេលនោះ។ ក្រុមគ្រូប្រើហ្វ៊ីនដ័រទាំងអស់បាននាំគ្នាមកមើលហេរី ទាំងទទឹកនិងប្រឡាក់ប្រឡូស។

- ពិតជាហោះឡូយមែន ហេរី- ចចបន្លឺឡើង។ - ខ្ញុំទើបតែឃើញ ម៉ាកកើស ហ្វ្លីនត៍ ស្រែកគំហកឲ្យមេលហ្វ៊យអំបាញ់មិញ។ ដូចជាស្ពីឲ្យពីរឿង ដែលស្នីតមាសនៅពីលើក្បាលហើយ នៅមើលមិនឃើញទៀត។ មេលហ្វ៊យដូចជាមិនអរប៉ុន្មានទេ។

ពួកគេបាននាំមកនូវនំចំនី ស្ករគ្រាប់ ព្រមទាំងដបទឹកល្ពៅ។ ពួកគេទាំងអស់គ្នាបានប្រជុំគ្នាជុំវិញគ្រែរបស់ហេរី ហើយទើបតែត្រៀមចាប់ផ្តើមពិធីជប់លៀងអបអរ ស្រាប់តែអ្នកស្រីផុមហ្វ្រីបោលដូចព្យុះចូលមកស្រែកឡូងៗះ

- ក្មេងប្រុសនេះត្រូវការសម្រាក! វាត្រូវបណ្តុះឆ្អឹងសាមសិបបីណា! ចេញទៅ! ចេញឲ្យអស់!

ហើយហេរីក៏ត្រូវនៅម្នាក់ឯង ដោយគ្មានអ្វីអាចបន្លប់វាពីការឈឺចាប់ដូចគេចាក់ នៅក្នុងដៃគ្មានវិញ្ញាណរបស់វា។

*

ជាច្រើនម៉ោងក្រោយមក ហេរីស្រាប់តែភ្ញាក់ឡើងព្រើតទាំងយប់ងងឹតស្លុង ហើយស្រែកមួយរ៉ាសះ ឥឡូវដៃរបស់វាពោរពេញទៅដោយបំណែកតូចៗ។ ពេលនោះ វាគិតថាប្រហែលជាវាភ្ញាក់ដោយសារតែរឿងហ្នឹងហើយ។ ប៉ុន្តែបន្ទាប់មក វាស្រាប់តែស្លុតដោយឃើញថាមាននរណាម្នាក់កំពុងតែយកអេប៉ុងជូតថ្ងាសរបស់វា។

- ចេញទៅ!- វានិយាយខ្លាំងៗ ហើយក្រោយមក - *ដុបប៊ី!*

ភ្នែកធំៗប៉ុនគ្រាប់បាល់តិន្នីសរបស់ម្រេញគង្វាលកំពុងតែលួចសម្លឹងមើលហេរីក្នុងស្បៃអន្ធការ។ ទឹកភ្នែកមួយតំណក់កំពុងតែហូរចុះពីច្រមុះដ៏ស្រួចហើយវែងរបស់វា។

- ហេរី ផោតធ័របានត្រលប់មកសាលាវិញ- វានិយាយខ្សឹបៗទាំងទុក្ខវេទនា។ - ដុបប៊ីផ្តាំហេរី ផោតធ័រម្តងហើយម្តងទៀត។ ទានប្រោសអើយ ហេតុអ្វីបានជាលោកមិនស្តាប់តាមដុបប៊ី? ហេតុអ្វីបានជាហេរី ផោតធ័រមិនត្រលប់ទៅផ្ទះវិញនៅពេលដែលលោកខកជើងរថភ្លើងហើយនោះ?

ហេរីងើបខ្លួនអង្គុយផ្អែកនឹងខ្នើយ ហើយរុញអេប៉ុងរបស់ដុបប៊ីចេញ។

- តើឯងធ្វើអ្វីនៅទីនេះ?- វាបន្លឺសួរ។ -ហើយម៉េចក៏ឯងដឹងថាខ្ញុំខករថភ្លើង?

បបូរមាត់របស់ដុបប៊ីញញីញញ័រ ហើយហេរីក៏ចាប់ផ្តើមសង្ស័យភ្លាម។

- គឺឯង!- វានិយាយយឺតៗ។ - ឯងបានឃាំងរបាំងមិនអោយពួកយើងឆ្លងកាត់បាន!

- ពិតប្រាកដណាស់ ទាន- ដុបប៊ីតប ព្រមទាំងងក់ក្បាលយ៉ាងម៉ឺងម៉ាត់ ត្រចៀកវាទះព្ធផ្លាប់ៗ។ - ដុបប៊ីបានលាក់ខ្លួនរង់ចាំមើលហេរី ផោតធ័រ ហើយក៏បិទច្រកផ្លូវ ប៉ុន្តែដុបប៊ីត្រូវអ៊ុតដៃខ្លួនឯងពេលក្រោយមក...- វាបានបង្ហាញម្រាមដៃរុំបង់ទាំងដប់ឲ្យហេរីមើល - ប៉ុន្តែដុបប៊ីមិនខ្វល់ទេ ទាន ព្រោះថាហេរី ផោតធ័រមានសុវត្ថិភាពហើយ ហើយដុបប៊ីមិននឹកស្មានថា ហេរី ផោតធ័រ នៅតែទៅសាលាតាមមធ្យោបាយផ្សេងសោះ!

វាយោលខ្លួនទៅមុខទៅក្រោយ ដោយគ្រវីក្បាលដ៏គគ្រិចរបស់វា។

- ដុបប៊ីពិតជាតក់ស្លុតណាស់នៅពេលដែលឮថា ហេរី ផោតធ័រ បានត្រលប់មកហុកវ៉ាតវិញ រហូតទាល់តែដាំខ្លោចម្ហូបរបស់ចៅហ្វាយទៀតផង! ដុបប៊ីពិតជារងទណ្ឌកម្មធ្ងន់ណាស់ចំពោះកំហុសនេះណា ទាន...

ហេរីផ្ដេកខ្លួនទៅលើខ្នើយវិញ។

- ឯងស្ទើរតែធ្វើឲ្យខ្ញុំ និងរ៉ុនត្រូវគេបណ្ដេញចេញទៅហើយ- វានិយាយយ៉ាងឃោរឃៅ។ - ទាន់ពេលនេះឆ្អឹងខ្ញុំមិនទាន់ដុះមកវិញស្រួលបួល យល់ល្អឯងគួរតែចេញឲ្យបាត់ពីមុខខ្ញុំទៅ បើមិនអញ្ចឹងទេ ខ្ញុំនឹងចាប់ឯងព្យួរកហើយ។

ដុបប៊ីបញ្ចេញស្នាមញញឹមយ៉ាងខ្សត់ខ្សោយ។

- ដុបប៊ីស៊ាំនឹងសម្ដីគំរាមកំហែងរកសម្លាប់អស់នេះហើយ ទាន។ នៅឯផ្ទះនោះ ដុបប៊ីតែងទទួលការគំរាមកំហែងរបៀបនេះយ៉ាងហោចណាស់ក៏ប្រាំដងដែរក្នុងមួយថ្ងៃ។

ដុបប៊ីហឺតសំបោរនឹងជាយស្រោមខ្នើយដ៏កខ្វក់ដែលវាពាក់ មើលទៅគួរឲ្យអាណិតអាសូរណាស់ ដែលធ្វើឲ្យកំហឹងរបស់ហេរីសាយអស់ទោះជាមិនចង់ក្ដី។

- ហេតុអ្វីបានជាឯងពាក់របស់នោះ ដុបប៊ី?- វាសួរដោយចង់ដឹង។

- អានេះរឺ ទាន?- ដុបប៊ីសួរបញ្ជាក់ ដោយកន្ត្រាក់ស្រោមខ្នើយបង្ហាញ។ - នេះគឺជាសញ្ញាបង្ហាញអំពីទាសភាពរបស់ម្រេញគង្វាលប្រចាំផ្ទះណ៎ា ទាន។ ដុបប៊ីអាចមានសេរីភាពបានលុះត្រាតែចៅហ្វាយអោយក្រណាត់អ្វីមួយមកខ្ញុំ។ គ្រួសារនោះពិតជាប្រយ័ត្នណាស់ មិនធ្លោយឲ្យសូម្បីតែស្រោមជើងមួយចំហៀងដល់ដុបប៊ីផង ព្រោះថាបើពុំនោះទេ ដុបប៊ីនឹងមានសេរីភាពអាចចាកចេញពីផ្ទះនោះបានភ្លាម។

ដុបប៊ីជូតភ្នែកដូចក្ដាមរបស់វា ហើយបន្លឺឡើងភ្លាមៈ

- ហេរី ផោតធ័រត្រូវតែត្រលប់ទៅផ្ទះវិញ! ដុបប៊ីគិតថាបាល់ប្លាត់ជីររបស់ខ្ញុំនោះល្មមតែអាច...

- ប្លាត់ជីររបស់ឯង?- ហេរីឧទានឡើង ក្នុងខ្លួនពុះពោរដោយកំហឹងម្ដងទៀត។ - តើឯងចង់មានន័យថាម៉េច ប្លាត់ជីររបស់ឯងនោះ? ឯងដាក់អាគមធ្វើឲ្យបាល់ប្លាត់ជីរនោះព្យាយាមសម្លាប់ខ្ញុំ មែនទេ?

- មិនមែនសម្លាប់លោកទេ ទាន មិនមែនទេ!- ដុបប៊ីប្រកែក ដោយតក់ស្លុត។ - ដុបប៊ីគ្រាន់តែចង់ជួយសង្គ្រោះជីវិតរបស់ហេរី ផោតធ័រប៉ុណ្ណោះ! ទុកជាត្រូវបញ្ជូនទៅផ្ទះ ដោយរងរបួសធ្ងន់ធ្ងរយ៉ាងណា ក៏ល្អជាងនៅទីនេះដែរណ៎ា ទាន! ដុបប៊ីគ្រាន់តែចង់ឲ្យហេរី ផោតធ័រត្រូវរបួសធ្ងន់ល្មមតែត្រូវបញ្ជូនទៅផ្ទះវិញប៉ុននោះ!

- អូ! តែប៉ុណ្ណឹងទេហ្អី?- ហេរីនិយាយទាំងខឹងសម្បា។ - ឯងមិនមែនចង់មានន័យថា ត្រូវកំទេចយើងជាកង់ៗ ហើយចាំបញ្ជូនយើងទៅផ្ទះវិញទេរឺ?

- អ្ហា! ហេរី ផោតធ័រមិនទាន់ដឹងទេ!- ដុបប៊ីនិយាយថ្ងូចថ្ងូរ ទឹកភ្នែកស្រក់តក់ៗមកលើស្រោមខ្នើយដាច់រយ៉ែរបស់វា។ - លោកមិនទាន់ដឹងថា ពួកទាសករវណ្ណៈទាបបំផុតដូចជាពួកយើងរងទុក្ខវេទនាប៉ុណ្ណានោះទេនៅក្នុងពិភពវេទមន្ត! ដុបប៊ីនៅចាំពីទិដ្ឋភាពទាំងអស់នោះ ពេលដែលអំណាចរបស់ អ្នកដែលមិនត្រូវហៅចំឈ្មោះ ឡើងដល់កំរិតកំពូល ទាន! ម្រេញគង្វាលប្រចាំផ្ទះពួកយើង ត្រូវបានគេមើលងាយដូចជាសត្វល្អិតចង្រៃអញ្ចឹង! ជាការពិតណាស់ ឥឡូវដុបប៊ីក៏នៅតែរងការប្រមាថមើលងាយដូចតែគ្នាហ្នឹង- វាសារភាព ដោយយកមុខជូតនឹងស្រោមខ្នើយ។ - ប៉ុន្តែប្រការដែលសំខាន់នោះគឺថា ជីវភាពរស់នៅរបស់ពួកខ្ញុំបានរីកចំរើនគ្រាន់បើច្រើន តាំងតែពីពេលដែលលោកបានយកឈ្នះលើ អ្នកដែលមិនត្រូវហៅចំឈ្មោះ។ ហេរី ផោតធ័របានរស់រានមានជីវិត ហើយថាមពលរបស់បិសាចមន្តអាគមងងឹតក៏ត្រូវរលាយសាបសូន្យ។ នោះហើយគឺជាព្រះអាទិត្យថ្មី ហើយហេរី ផោតធ័រនេះឯង

ដែលរះភ្លឺចិញ្ចែញចិញ្ចាចប្រៀបបាននឹងពន្លឺនៃសេចក្ដីសង្ឃឹមសម្រាប់ពួកយើងទាំងអស់គ្នា ដែលរមែងគិតថាស្បែអន្ធការនឹងមិនចប់រលត់ឡើយ...ហើយនាពេលនេះ នៅសាលាហុកវ៉ាត រឿងអាក្រក់ៗនឹងកើតឡើង រឺក៏ប្រហែលជាកំពុងកើតឡើងរួចទៅហើយ ហើយដុបប៊ីមិនអាចអោបដៃឈរមើលបានទេ ដោយហេតុថាប្រវត្តិសាស្ត្រជិតនឹងកើតឡើងម្ដងទៀតហើយ គឺពេលនេះហើយដែលបន្ទប់សម្ងាត់នឹងត្រូវបើកឡើងម្ដងទៀត...

ដុបប៊ីស្រាប់តែឈប់ ដោយក្ដីរន្ធត់ បន្ទាប់មកក៏កញ្ចក់យកកាទឹកពីតុជិតគ្រែរបស់ហេរី ហើយសំពោងក្បាលរបស់វា រហូតទាល់តែដួលខ្លួនឯង។ បន្តិចក្រោយមក វាក៏វារឡើងមកលើគ្រែវិញ ភ្នែករាងស្រឡេវទេវ ឆ្លៀតនិយាយមមើមមាយជាប់ថា៖

- ដុបប៊ីអាក្រក់ ដុបប៊ីចង្រៃ...

- អញ្ចឹងមានបន្ទប់សម្ងាត់ពាក់ព័ន្ធទៀត?- ហេរីខ្សឹបសួរ។ - ហើយ...តើឯងមានបាននិយាយថាវាត្រូវបានបើកឡើងកាលពីមុនទេ? *ប្រាប់ខ្ញុំមក* ដុបប៊ី!

ហេរីចាប់ដៃសុទ្ធតែឆ្អឹងរបស់ដុបប៊ីទាន់មុនពេលដែលដុបប៊ីហៀបនឹងឈោងយកកាទឹកម្ដងទៀត។ - ប៉ុន្តែខ្ញុំមិនមែនជាអ្នកកើតពីឪពុកម្ដាយលោកិយ ... តើខ្ញុំអាចមានគ្រោះថ្នាក់ដោយសារបន្ទប់សម្ងាត់នោះបានដោយរបៀបណាទៅ?

- អ្ហា! ឈប់សួរទៀតទៅ! ឈប់សួរដុបប៊ីកំសត់ទៀតទៅ!- ម្រេញគង្វាលពោលឡើងទាំងត្រដិតៗ ភ្នែករបស់វាលៀនប៉ុនៗពងមាន់នៅក្នុងទីងងឹត។ - មានគេរៀបចំប្រព្រឹត្តអំពើខ្មៅងងឹតនៅក្នុងកន្លែងនេះ ប៉ុន្តែហេរី ផោតធ័រ មិនត្រូវនៅទីនេះទេនៅពេលដែលហេតុការណ៍អស់នោះកើតឡើង។ ទៅផ្ទះទៅ ហេរី ផោតធ័រ។ ទៅផ្ទះវិញ។ ហេរី ផោតធ័រមិនត្រូវប្រឡូកខ្លួននៅក្នុងកិច្ចការនេះទេ ទាន។ វាមានគ្រោះថ្នាក់ពេកហើយ ...

- តើគេនោះជានរណាទៅ ដុបប៊ី?- ហេរីសួរ ដោយនៅតែកាន់ដៃរបស់ដុបប៊ីជាប់ក្រែងលោវាចង់យកកាទឹកមកវាយខ្លួនឯងសាជាថ្មី។ - តើនរណាបានបើកវា? តើនរណាបានបើកវាកាលពីលើកមុន?

- ដុបប៊ីមិនអាចនិយាយបានទេ ទាន ដុបប៊ីមិនអាចប្រាប់បានទេ ដុបប៊ីមិនត្រូវប្រាប់ទេ!- ម្រេញគង្វាលអង្វរករ។ - ទៅផ្ទះទៅ ហេរី ផោតធ័រ សូមទៅផ្ទះចុះ!

- ខ្ញុំមិនទៅទីណាទាំងអស់!- ហេរីឧទានឡើងទាំងរឹងប៉ឹង។ - មិត្តភក្តិជិតស្និទ្ធិខ្ញុំម្នាក់មានឪពុកម្ដាយជាពួកលោកិយ។ នាងច្បាស់ជាមានគ្រោះថ្នាក់ប្រសិនបើបន្ទប់នោះពិតជាត្រូវបានបើកឡើងវិញមែន...

- ហេរី ផោតធ័រហ៊ានប្រថុយជីវិតខ្លួនឯងដើម្បីតែមិត្តភក្តិ!- ដុបប៊ីស្រែកថ្ងូចថ្ងូរ ហាក់ដូចជាអណ្ដែតអណ្ដូងក្នុងទុក្ខវេទនា។ - ពិតជាថ្លៃថ្នូរណាស់! ពិតជាក្លាហានមែន! ប៉ុន្តែលោកត្រូវតែជួយខ្លួនឯងសិន ហេរី ផោតធ័រមិនត្រូវ...

ដុបប៊ីស្រាប់តែគាំងភ្លាមមួយរំពេច ត្រចៀកស្លាបប្រចៀវរបស់វាកំពុងញ័រទទ្រើក។ ហេរីក៏ស្ដាប់ឮដែរ។ មានស្នូរជើងកំពុងតែដើរសំដៅចុះមកនៅខាងក្រៅ។

- ដុបប៊ីសូមលាសិនហើយ!- ម្រេញគង្វាលនិយាយខ្សឹបប្រាប់ ដោយភ័យខ្លាច។ មានសំឡេងគ្រិកមួយបន្លឺឡើង ហើយកណ្ដាប់ដៃរបស់ហេរីចាប់តែខ្យល់ប៉ុណ្ណោះ។ វាផ្ដួលខ្លួនទៅលើគ្រែវិញ ភ្នែកសម្លឹងជាប់នឹងមាត់ទ្វារបន្ទប់គិលានដ្ឋាន ខណៈពេលដែលស្នូរជើងកាន់តែខិតជិតទៅ។

## ចាល់ឆ្លាត់ជីវកំណាច

មួយសន្ទុះក្រោយមក ដាំប័លដ័រកំពុងតែដើរថយក្រោយចូលមកក្នុងសយនដ្ឋាន ដោយស្លៀកប៉ូបរោមសត្វដ៏វែងមួយ និងពាក់មួកដេកយប់។ គាត់កំពុងតែសែងអ្វីម្យ៉ាងដូចជារូបចម្លាក់។ មួយសន្ទុះក្រោយឃើញសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលសែងនៅចុងម្ខាងទៀត។ ពួកគេលើកវាដាក់ទៅលើគ្រែ។

- ទៅហៅអ្នកស្រី ផុមហ្វ្រី មក- លោកដាំប័លដ័រខ្សឹបតិចៗ ហើយអ្នកស្រីម៉ាកហ្គូណាហ្គាលក៏ប្រញាប់ប្រញាល់ដើរកាត់ចុងគ្រែហេរីចេញទៅបាត់។ ហេរីសណ្ដូកខ្លួននៅលើគ្រែយ៉ាងស្ងៀម ធ្វើពុតជាដេកលក់។ វាឮសំឡេងអាសន្ន រួចឃើញអ្នកស្រីម៉ាកហ្គូណាហ្គាលត្រលប់មកវិញ ដោយមានអ្នកស្រីផុមហ្វ្រីដើរប្រកិតតាមពីក្រោយ ដៃកំពុងតែទាញតម្រង់កអាវដេកយប់របស់គាត់។ វាស្ដាប់ឮសំឡេងដកដង្ហើមគយូស។

- តើមានរឿងអីកើតឡើង?- អ្នកស្រីផុមហ្វ្រីខ្សឹបសួរលោកដាំប័លដ័រ ព្រមទាំងឱនមើលរូបចម្លាក់នៅលើគ្រែ។

- គឺជាការវាយប្រហារមួយទៀត- លោកដាំប័លដ័រតប។ - មីណែរវ៉ា រកវាឃើញនៅជណ្ដើរ។

- មានទំពាំងបាយជូរមួយចង្វាយនៅជិតខ្លួនវា- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលស្រដី។ - ពួកយើងគិតថា វាប្រហែលជាចង់លបឡើងមកលេង ផោតធ័រ នៅទីនេះ។

ពោះរបស់ហេរីក្ដួយ៉ាងខ្លាំង។ វាបង្ហើបខ្លួនយឺតៗ យ៉ាងប្រុងប្រយ័ត្នដើម្បីមើលរូបចម្លាក់នៅលើគ្រែនោះឲ្យបានច្បាស់។ ពន្លឺព្រះចន្ទមួយចំនិតជះលើមុខស្មឹងស្មាធ៏នៃរូបចម្លាក់នោះ។

វាគឺខូលីន គ្រីវី។ ភ្នែករបស់វាបើកធំៗ ហើយដៃលយទៅមុខកាន់ម៉ាស៊ីនឡើងជាប់។

- ត្រូវសិល្ប៍បង្កក់រឺ?- អ្នកស្រីផុមហ្វ្រីខ្សឹបសួរទៀត។

- មែនហើយ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលតប។ - ប៉ុន្តែខ្លាចក្រែងថា...ប្រសិនបើអាល់ប៊ូសមិនចុះជណ្ដើររកញ៉ាំសូកូឡាក្ដៅទេ មិនដឹងជានឹងមានរឿងអ្វីកើតឡើងនោះទេ...

ពួកគេទាំងបីនាក់សម្លឹងមើលមកខូលីន។ បន្ទាប់មក លោកដាំប័លដ័រឱនទៅទាញម៉ាស៊ីនថតចេញពីដៃរឹងឆ្អឹងរបស់ខូលីន។

- លោកគិតថា វាប្រហែលជាថតបានរូបអ្នកដែលវាយប្រហារវារឺ?- អ្នកស្រីម៉ាកហ្គូណាហ្គាលសួរចង់ដឹង។

លោកដាំប័លដ័រមិនឆ្លើយទេ។ គាត់បើកមើលផ្នែកខាងក្រោយនៃម៉ាស៊ីនថតនោះ។

- ព្រះអើយ!- អ្នកស្រីផុមហ្វ្រីឧទានឡើង។

ផ្សែងហុយទ្រលោមចេញពីម៉ាស៊ីនថតនោះ។ ទោះជា ហេរី នៅចម្ងាយបីគ្រែពីគ្នា ក៏ធុំក្លិនឆ្អួលនៃប្លាស្ទិចឆេះដែរ។

- រលាយ- អ្នកស្រីផុមហ្វ្រីនិយាយបែបមមើមមាយ - រលាយអស់តែម្ដង...

- តើនេះមានន័យយ៉ាងម៉េចទៅ អាល់ប៊ូស?- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលជជីកសួរជាបន្ទាន់។

- វាមានន័យថា- លោកដាំប័លដ័រនិយាយ - បន្ទប់សម្ងាត់ពិតជាមានគេបើកឡើងវិញម្ដងទៀតមែនហើយ។

អ្នកស្រីផុមហ្វ្រីយកដៃខ្ទប់មាត់។ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលសម្លឹងមើលលោក ដាំប័លដ័រ មិនដាក់ភ្នែក។

- ប៉ុន្តែ អាល់ប៊ូស...ប្រាកដណាស់...តើនរណាគេទៅ?

- មិនគួរសួរថា "នរណាគេ" ទេ...- ដាំប័លដ័រស្រដី ភ្នែកសម្លឹងមើលទៅខូលីន។ - គួរតែសួរថា "យ៉ាងដូចម្ដេច" ទើបត្រូវ...

បើតាមទឹកមុខស្រងូតស្រងាត់របស់អ្នកស្រីម៉ាកហ្គូណាហ្គាល គាត់ក៏ប្រហែលជាមិនយល់អ្វីជាជាងវានោះដែរ។

## វគ្គ XI



# ក្រុមប្រយុទ្ធតតាំង

ពេលហេរីភ្ញាក់ឡើងនៅព្រឹកថ្ងៃអាទិត្យ វាឃើញសយនដ្ឋានចែងចាំងទៅដោយពន្លឺសូរ្យសែងនាសិសិររដូវ ចំនែកដៃរបស់វាឥឡូវដុះឆ្អឹងវិញហើយ តែនៅរឹងសរសៃនៅឡើយ។ វាក្រោកអង្គុយយ៉ាងរហ័ស ហើយក្រឡេកទៅគ្រែរបស់ខូលីន ប៉ុន្តែត្រូវវាំងនននដែលវាប្រើផ្លាស់សម្លៀកបំពាក់ម្សិលមិញ បាំងជិតរកមើលអ្វីមិនឃើញសោះ។ ឃើញថាវាភ្ញាក់ហើយ អ្នកស្រីផុមហ្វ្រីក៏ប្រញាប់ប្រញាល់លើកយកថាសអាហារពេលព្រឹកមក ហើយបន្ទាប់មក ចាប់ផ្តើមតម្រែតម្រង់ដៃ និងម្រាមដៃរបស់វា។

- រៀបរយអស់ហើយ- គាត់បន្លឺឡើង ខណៈពេលដែលវាកំពុងញ៉ាំបបរនឹងដៃឆ្វេងទាំងទើសទាល់។ - ពេលស្រស់ស្រូបអាហាររួច ឯងអាចចេញទៅបានហើយ។

ហេរីខំស្លៀកពាក់យ៉ាងលឿនតាមដែលអាចធ្វើបាន រួចប្រញាប់ទៅអគារក្រុមហ្គ្រីហ្វីនដ័រ នឹងអាលប្រាប់រ៉ុន និងហឺម៉ាយអូនីអំពីខូលីន និង ដុបប៊ី ប៉ុន្តែពួកគេមិននៅទីនោះទេ។ ហេរី ចាកចេញពីទីនោះដើម្បីរកមើលពួកគេ ក្នុងចិត្តងឿងឆ្ងល់ថាពួកគេទៅធ្វើអ្វីនៅឯណា ព្រមទាំងឈឺចិត្តបន្តិចដែរ ដោយព្រោះតែពួកគេមិនចាប់អារម្មណ៍ថា វាបានដុះឆ្អឹងជាសះស្បើយរួចហើយរឺនៅ។

ពេលដែលហេរីដើរកាត់បណ្ណាល័យ ក៏ឃើញពឿរស៊ី វីស្លីដើរចេញមកយ៉ាងហំហាន ទឹកមុខដូចជាស្រស់បស់ជាងកាលពីជួបគ្នាលើកមុន។

- អូ! សួស្តី ហេរី- វាស្រដី។ - ពិតជាហោះបានល្អណាស់កាលពីម្សិលមិញ ពិតជាល្អមែន។ ឥឡូវហ្គ្រីហ្វីនដ័រនាំមុខគេក្នុងការដណ្តើមកយកពានប្រចាំសាលាហើយ...ឯងរកពិន្ទុបានដល់ហាសិបឯនោះណា!

- ឯងមានឃើញរ៉ុន និងហឺម៉ាយអូនីទេ?- ហេរីសួរ។

- ទេ អត់បានឃើញទេ- ពឿរស៊ីតប ស្នាមញញឹមរសាយបន្តិចម្តងៗ។ - ខ្ញុំសង្ឃឹមថារ៉ុននឹងមិនទៅ *បន្ទប់ទឹកស្រី* ទៀតទេ...

ហេរីសើចទាំងបង្ខំ ចាំដល់ពឿរស៊ីដើរទៅផុត រួចក៏តំរង់ទិសសំដៅបន្ទប់ទឹករបស់ ម៉ុននីង មីតថល ភ្លាម។ វាមើលមិនឃើញពីមូលហេតុដែល រ៉ុន និង ហឺម៉ាយអូនីត្រូវទៅទីនោះម្តងទៀតទេ ប៉ុន្តែបន្ទាប់ពីពិនិត្យមើលឃើញថាហ្វីលច្ច និងប្រធានសិស្សឯទៀតមិននៅទេ វាក៏បើកទ្វារ ហើយឮសំឡេងរបស់ពួកគេចេញពីបន្ទប់ចាក់សោមួយ។

- គឺខ្ញុំទេ- វានិយាយ ព្រមទាំងបិទទ្វារ។ ឮសំឡេងក្អុកៗ សំឡេងទឹកខ្វាយ និងសំឡេងដង្ហក់ចេញពីក្នុងបន្ទប់នោះ ហើយវាឃើញភ្នែករបស់ហឺម៉ាយអូនីអើតមើលតាមប្រហោងសោ។

- ហេរី!- នាងឧទានឡើង។ - ឯងធ្វើឲ្យពួកយើងភ័យស្ទើរតែលោះព្រលឹងទៅហើយ។ ចូលមកក្នុងមក៍...ហើយចុះដៃឯងយ៉ាងម៉េចហើយ?

- មិនអីទេ- ហេរីឆ្លើយ រួចខំបញ្ច្រៀតខ្លួនឲ្យចូលទៅក្នុងបន្ទប់តូចនោះ។ មានថ្លាងកញ្ចាស់មួយនៅលើបង្គន់ ហើយសំឡេងប្រែសៗនៅគែមៗថ្លាងនោះ នាំឲ្យហេរីដឹងថាពួកគេកំពុងតែបង្កាត់ភ្លើង។ ការបង្កាត់ភ្លើងចល័ត និងមិនជ្រាបទឹកគឺជាជំនាញរបស់ហឺម៉ាយអូនីទៅហើយ។

- យើងនឹកថាចង់ទៅលេងឯងដែរ ប៉ុន្តែពួកយើងសម្រេចចិត្តថាគួរតែចាប់ផ្តើមលើការដាំទឹកថ្នាំបំលែងកាយវិញល្អជាង- រ៉ុនពន្យល់ ខណៈពេលដែលហេរីចាក់សោបន្ទប់តូចនោះ ទាំងទើសទាល់ម្តងទៀត។ - ពួកយើងគិតថានេះគឺជាកន្លែងមានសុវត្ថិភាពបំផុតដើម្បីលាក់ការណ៍។

ហេរីហៀបនឹងនិយាយប្រាប់ពួកគេអំពីខូលីនទៅហើយ ស្រាប់តែហឺម៉ាយអូនីមកកាត់សម្តី។ - ពួកយើងដឹងអស់ហើយ។ ពួកយើងឮសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល ប្រាប់សាស្ត្រាចារ្យ ហ្លីតវីក កាលពីព្រឹកនេះ។ ដូច្នេះហើយបានជាយើងគួរតែចាប់ផ្តើម...

- យើងឲ្យមេលហ្វ័យសារភាពបានកាន់តែឆាប់ កាន់តែល្អ- រ៉ុនគ្រហឹម។ - តើឯងដឹងថាខ្ញុំគិតយ៉ាងម៉េចទេ? ខ្ញុំគិតថាក្រោយពីចាញ់កីឡាឃ្វីដឌីច្ចហើយ វាច្បាស់ជាម៉ូម៉ៅយ៉ាងខ្លាំង ដែលជាហេតុធ្វើឲ្យវាបញ្ចេញកំហឹងទៅលើ ខូលីន តែម្តងទៅ។

- មានរឿងមួយទៀត- ហេរីនិយាយបណ្តើរ មើលហឺម៉ាយអូនីហែកស្មៅពកជាកំណាត់ៗរួចបោះចូលទៅក្នុងទឹកថ្នាំបណ្តើរ។ - ដុបប៊ីបានមកជួបខ្ញុំកាលពីពាក់កណ្តាលអធ្រាត្រយប់មិញ។

រ៉ុន និងហឺម៉ាយអូនីងើយមើលទាំងភ្ញាក់ផ្អើល។ ហេរីបានប្រាប់ពួកគេពីអ្វីៗគ្រប់យ៉ាងដែលដុបប៊ីបានប្រាប់វា...រឺក៏មិនបានប្រាប់វា។ រ៉ុន និងហឺម៉ាយអូនីស្តាប់ឡើងច្រហមាត់។

- បន្ទប់សម្ងាត់ត្រូវបានបើកឡើងកាលពីលើកមុនរឺ?- ហឺម៉ាយអូនីសួរ។

- អញ្ចឹងត្រូវហើយ- រ៉ុននិយាយយ៉ាងក្លាហាន។ - លូស៊ីស មេលហ្វ័យប្រាកដជាបានបើកបន្ទប់នោះ នៅពេលដែលគេរៀននៅទីនេះ ហើយឥឡូវគេបានប្រាប់ ដ្រាកូ សំណព្វចិត្តរបស់គេ ពីរបៀបបើកទៀត។ វាជាក់ស្តែងណាស់។ បើដុបប៊ីប្រាប់ថាមានបិសាចអ្វីនៅក្នុងបន្ទប់នោះគឺល្អហើយ។ ខ្ញុំចង់ដឹងណាស់ថា តើហេតុអ្វីបានជាគ្មាននរណាដឹងថាវាលួចចូលមកក្នុងសាលាសោះអញ្ចឹង។

- ប្រហែលជាវាអាចបំបាំងកាយបានហើយ- ហឺម៉ាយអូនីនិយាយបណ្តើរ ចាក់ឈ្លើងទៅក្នុងថ្លាងបណ្តើរ។ - រឺក៏ប្រហែលជាវាអាចក្លែងបន្លំខ្លួនបាន...អាចក្លែងធ្វើជារូបចម្លាក់ រឺក៏អ្វីម្យ៉ាង។ ខ្ញុំធ្លាប់បានអានប៉ះអំពីប្រែត ឆាមេលេអុង...

- ឯងអានសៀវភៅច្រើនពេកហើយ ហឺម៉ាយអូនី- រ៉ុនរអ៊ូ រួចចាក់ស្លាបជរងាប់ពីលើឈ្លើង។ វាខ្ទុកខ្ទីចង់ទទេសម្រាប់ដាក់ស្លាបជរ ហើយបែរមកមើលហេរី។

- អញ្ចឹង គឺដុបប៊ីជាអ្នកឃាត់ពួកយើងមិនឲ្យឡើងរថភ្លើង ហើយធ្វើឲ្យដៃឯងបាក់...- វាគ្រវីក្បាល។ - ឯងដឹងទេ ហេរី ប្រសិនបើវាមិនឈប់ចង់ជួយជីវិតរបស់ឯងនោះទេ វាច្បាស់ជានឹងធ្វើឲ្យឯងស្លាប់ជាមិនខានឡើយ។

*

ដំណឹងដែលថា ខូលីន គ្រីវីត្រូវគេវាយប្រហារ ហើយឥឡូវកំពុងដេកដូចស្លាប់នៅក្នុងគិលានដ្ឋាន ត្រូវបានផ្សព្វផ្សាយទូទាំងសាលានៅព្រឹកថ្ងៃច័ន្ទ។ បរិយាកាសនាពេលនោះអាប់អួទៅដោយពាក្យចចាមអារ៉ាម និងការមន្ទិលសង្ស័យ។ ឥឡូវ សិស្សឆ្នាំទីមួយដើរទៅណាមកណាសុទ្ធតែមានគ្នាជាក្រុមៗ ហាក់ដូចជាពួកគេខ្លាចថា ប្រាកដជានឹងត្រូវរងការវាយប្រហារដែរ ប្រសិនបើដើរតែម្នាក់ឯង។

ជីននី វីស្លី ដែលអង្គុយជិតខូលីន គ្រីវីក្នុងម៉ោងរៀនវេទមន្ត កំពុងតែកើតទុក្ខបុកម្នេញ ប៉ុន្តែហេរីមានអារម្មណ៍ថា ហ្វ្រេដ និងចចប្រើមធ្យោបាយលួងចិត្តនាងមិនត្រឹមត្រូវសោះ។ ពួកគេកំពុងតែផ្លាស់វេនគ្នាធ្វើឲ្យដុះរោម រឺចេញពងបែកពេញខ្លួន រួចចាំលោត

ពញ្ញាក់នាងពីខាងក្រោយរូបចម្លាក់។ ដោយអត់ទ្រាំមិនបាន ពៀវស៊ីប្រាប់ពួកគេថា វានឹងសរសេរសំបុត្រទៅកាន់អ្នកស្រីវីស្លី ប្រាប់ថាជីននីយល់សប្តិអាក្រក់ ទើបបានពួកគេឈប់ធ្វើតទៅទៀត។

ក្នុងពេលជាមួយគ្នានោះដែរ នៅពីក្រោយខ្នងសាស្ត្រាចារ្យទាំងឡាយ មានចរាចរណ៍ទីផ្សារជួញដូរយ័ន្ត ខ្សែកថា និងគ្រឿងការពារខ្លួនដទៃទៀតជាច្រើន កើតឡើងពាសពេញសាលា។ នេវីល ឡង់បត់ថម បានទិញខ្ទឹមបារាំងដ៏ធំមួយពណ៌បៃតង មានក្លិនឡើងអសោច និងគ្រីស្តាល់ស្រួចពណ៌ផ្កាឈូក ថែមទាំង កន្ទុយបង្គួយរលួយ រហូតដល់ពួកប្រុសៗខាងក្រុមហ្គ្រីហ្វីនដ័រដាច់ចិត្តប្រាប់វាថា វាគ្មានគ្រោះថ្នាក់ទេះ វាជាអ្នកមានឈាមជ័រសុទ្ធ ហើយដូច្នេះគួរតែមិនត្រូវរងការវាយប្រហារនោះឡើយ។

- ដំបូងពួកគេសំដៅទៅហ្វិលច្ឆ- នេវីលនិយាយ មុខមូលរបស់វាឡើងតក់ស្លុត - ហើយនរណាៗក៏ដឹងថាខ្ញុំស្ទើរតែជាជនអផេទទៅហើយ។

*

នៅសប្តាហ៍ទីពីរក្នុងខែធ្នូ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល បានមកដើរប្រមូលឈ្មោះសិស្សដែលនឹងស្នាក់នៅសាលាក្នុងថ្ងៃបុណ្យណូអែល ដូចសព្វដង។ ហេរី រ៉ុន និង ហឺម៉ាយអូនី ក៏បានចុះឈ្មោះដែរ។ ពួកគេឮថាមេលហ្វ័យក៏នៅសាលាថ្ងៃបុណ្យណូអែលដែរ ដែលជាហេតុធ្វើឲ្យពួកគេសង្ស័យកាន់តែខ្លាំងឡើង។ ថ្ងៃឈប់សម្រាកគឺជាពេលវេលាដ៏ល្អបំផុតក្នុងការប្រើទឹកថ្នាំបំលែងកាយដើម្បីឲ្យវាសារភាព។

ជាអកុសល ទឹកថ្នាំធ្វើហើយបានតែពាក់កណ្តាលប៉ុណ្ណោះ។ ពួកគេត្រូវការស្នែងសេះស្នែងពីរ និងស្បែកសត្វប៊ូមស្លែងទៀត ហើយបើចង់បាន លុះត្រាតែទៅលួចពីក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់ស្នេព។ បើតាមគំនិតហេរី វាយល់ថា សុខចិត្តប្រឈមមុខជាមួយនឹងបិសាចក្នុងរឿងព្រេងរបស់ក្រុមស្លីតឺរីន ជាជាងឲ្យស្នេពចាប់វាបានពេលកំពុងលួចរបស់ក្នុងការិយាល័យគាត់។

- អ្វីដែលយើងធ្វើនោះ- ហឺម៉ាយអូនីនិយាយយ៉ាងរហ័សរហួន ដោយហេតុតែម៉ោងរៀនឱសថពីរម៉ោងពេលរសៀលថ្ងៃព្រហស្បតិ៍កាន់តែកៀកជិតទៅហើយ - គឺការបង្វែងដាន។ ទាល់តែធ្វើអញ្ចឹង ទើបម្នាក់ក្នុងចំណោមពួកយើងអាចលបចូលទៅក្នុងការិយាល័យរបស់ស្នេព ហើយយកអ្វីដែលយើងត្រូវការបាន។

ហេរី និងរ៉ុនសម្លឹងមើលមកនាងទាំងរអា។

- ខ្ញុំគិតថា ខ្ញុំគួរតែទៅលួច- ហឺម៉ាយអូនីនិយាយបន្ត ដោយធ្វើសំឡេងយ៉ាងជាក់លាក់។ - ឯងទាំងពីរនាក់នឹងត្រូវបណ្តេញចេញជាមិនខាន ប្រសិនបើបង្ករឿងទៀត ចំនែកខ្ញុំវិញគ្មានបញ្ហាអ្វីទេ។ អញ្ចឹង ពួកឯងគ្រាន់តែបង្កចលាចលបន្តិចបន្តួចល្មមតែនឹងឲ្យស្នេពជាប់ដៃប្រហែលជាប្រាំនាទីទៅបានហើយ។

ហេរីញញឹមបែបមិនចង់។ ការបង្ករឿងរ៉ាវដោយចេតនានៅក្នុងថ្នាក់រៀនឱសថរបស់ស្នេព គឺដូចជាយកឈើទៅរុកភ្នែកនាគកំពុងតែដេកអញ្ចឹង។

មុខវិជ្ជាឱសថត្រូវរៀននៅក្នុងបន្ទប់ងងឹតដ៏ធំមួយ។ មេរៀននារសៀលថ្ងៃព្រហស្បតិ៍ដំណើរការទៅជាធម្មតា។ ថ្លាងម្ភៃហុយផ្សែងទ្រលោម ត្រូវដាក់បញ្ឈរនៅចន្លោះតុឈើ ប្រដាប់ដោយជញ្ជីងថ្លឹង និងក្រឡគ្រឿងផ្សំ។ ស្នេពដើរក្រវែលជុំវិញបន្ទប់នោះបណ្តើរស្តីជេរថាឲ្យក្រុមហ្គ្រីហ្វីនដ័របណ្តើរ រីឯក្រុមស្លីតឺរីនឯនោះវិញ កំពុងតែសើចកក្អឹកលើគំនរទុក្ខអ្នកដទៃ។ ដ្រាកូ មេលហ្វ័យ ដែលជាសិស្សសំណព្វរបស់ស្នេព ចេះតែញាក់ភ្នែកឌឺរ៉ុន និងហេរី តែឲ្យធ្វើយ៉ាងម៉េច ព្រោះថាតែល្ងីកណា ពួកគេហ៊ានតបតវិញ ច្បាស់ជាត្រូវទទួលពិន័យមុននឹងមានពេលនិយាយថា "អយុត្តិធម៌" ទៅទៀត។

សូលុយស្យុងបំប៉ោង របស់ហេរីហូរហៀរពេកហើយ ប៉ុន្តែចិត្តវាបែរជាផ្តោតទៅលើរឿងសំខាន់ៗឯទៀតទៅវិញ។ វាកំពុងតែរង់ចាំសញ្ញារបស់ហឺម៉ាយអូនី ហើយវាសឹងតែមិនស្តាប់ផង ពេលដែលស្នេពឈប់ ហើយនិយាយមើលងាយឱសថហៀរហូររបស់វា។ នៅពេលដែលស្នេពបែរ ហើយដើរទៅស្ដីឲ្យនេវីលម្ដង ហឺម៉ាយអូនីងាកទៅហេរី ហើយងក់ក្បាល។

ហេរីឱនយ៉ាងលឿនចុះទៅក្រោម ពីក្រោយថ្លុងរបស់វា រួចទាញកាំជ្រួច ហ្វីលីបាសទ័រ មួយរបស់ហ្វ្រេដចេញមក ហើយគោះកាំជ្រួចនោះយ៉ាងរហ័សនឹងចង្កឹះរបស់វា។ កាំជ្រួចនោះចាប់ផ្ដើមបន្លឺសំឡេងស៊ីៗ ហើយក៏ខ្ទាតបែកផ្កាភ្លើង។ ដឹងថាវាមានពេលតែប៉ុន្មានវិនាទីប៉ុណ្ណោះ ហេរីក៏ក្រោកភ្លែត តម្រង់ឲ្យចំ ហើយគប់វាទៅក្នុងអាកាស។ កាំជ្រួចធ្លាក់ចំគោលដៅ គឺថ្លាងរបស់ហ្គូយល៍។

ទឹកថ្នាំរបស់ហ្គូយល៍ចាប់ផ្ដើមផ្ទុះ ធ្វើឲ្យខ្ទាតពាសពេញថ្នាក់រៀន។ ពួកសិស្សនាំគ្នាស្រែក ពេលដែល សូលុយស្យុងបំប៉ោង ប៉ះនឹងពួកគេ។ មេលហ្វ័យប្រឡាក់ត្រូវពេញមុខតែម្ដង ហើយច្រមុះរបស់វាឡើងប៉ោងដូចបាល់បាឡុងអញ្ចឹង។ រីឯហ្គូយល៍ដើរមិនដឹងទៅណាទៅណី ដៃគ្របភ្នែករបស់វាទាំងពីរ ដែលឡើងប៉ោងប៉ុនចានញ៉ាំបាយ ចំនែកស្នេពកំពុងតែរក្សារបៀបរៀបរយ និងរកដើមចមនៃរឿងនេះ។ នៅក្នុងពេលច្របូកច្របល់ទាំងនេះ ហេរីឃើញហឺម៉ាយអូនីលបចេញយ៉ាងស្ងាត់ៗតាមទ្វារទៅក្រៅ។

- ស្ងាត់! ស្ងាត់!- ស្នេពស្រែកអស់មួយទំហឹង។ - អ្នកដែលត្រូវទឹកថ្នាំខ្ទាតលើ មកយកឱសថពង្រាបនៅទីនេះ។ តែកាលណាខ្ញុំរកឃើញថា ជនដៃដល់ជានរណាគេនោះ...

ហេរីទប់ខ្លួនមិនអោយសើច ពេលដែលវាឃើញមេលហ្វ័យប្រញាប់ដើរទៅខាងមុខ ក្បាលរបស់វាធ្លាក់ចុះដោយសារតែទំងន់ច្រមុះ ដែលមានរាងដូចក្រូចឆ្មារ។ សិស្សឡើងកន្លះថ្នាក់តម្រង់ជួរគ្នានៅតុរបស់ស្នេព អ្នកខ្លះដៃឡើងធំដូចដំបង ខ្លះទៀតនិយាយមិនរួចព្រោះតែបបូរមាត់រីកហើមស្ប៉ុល។ ហេរីឃើញហឺម៉ាយអូនីលបចូលមកក្នុងថ្នាក់វិញ ផ្នែកខាងមុខនៃរ៉ូបរបស់នាងឡើងប៉ោងទល់។

នៅពេលដែលអ្នករាល់គ្នាផឹកថ្នាំបន្សាបហើយ និងបានព្យាបាលការហើមប៉ោងផ្សេងៗរួចរាល់អស់ ស្នេពដើរយ៉ាងរហ័សរហួនសំដៅថ្លាងរបស់ហ្គូយល៍ ហើយទាញចេញមកនូវកំទេចកាំជ្រួច ពណ៌ឡើងខ្មៅ។ ស្រាប់តែមានភាពស្ងៀមស្ងាត់មួយរំពេច។

- ប្រសិនបើខ្ញុំដឹងថានរណាជាអ្នកធ្វើនោះ- ស្នេពខ្សឹប - ខ្ញុំនឹងឲ្យវាត្រូវបណ្ដេញចេញពីសាលានេះជាមិនខាន។

ហេរីរៀបចំទឹកមុខធ្វើដូចជាមិនដឹងអី។ ស្នេពសំឡឹងមើលមកវាចំៗតែម្ដង រហូតទាល់តែដល់ឮសូរកណ្ដឹងដប់នាទីក្រោយមក ទើបបានធូរខ្យាកក្នុងទ្រូង។

- គាត់ដឹងថាជាខ្ញុំ- ហេរីប្រាប់រ៉ុន និងហឺម៉ាយអូនី ខណៈពេលដែលពួកគេប្រញាប់ប្រញាល់ទៅកាន់បន្ទប់ទឹករបស់ម៉ុននីងមីតថល។ - ខ្ញុំអាចដឹងបាន។

ហឺម៉ាយអូនីបោះគ្រឿងផ្សំថ្មីចូលទៅក្នុងថ្លាង ហើយចាប់ផ្ដើមកូរយ៉ាងតក់ក្រហល់។

- ពីរសប្ដាហ៍ទៀតរួចរាល់ហើយ- នាងបន្លឺឡើងយ៉ាងរីករាយ។

- ស្នេពគ្មានភ័ស្ដុតាងចាប់កំហុសឯងនោះទេ- រ៉ុននិយាយលួងចិត្តហេរី។ - តើគាត់ធ្វើអ្វីបានទៅ?

- ការស្គាល់ស្នេព គឺជាកំហុសដ៏ធំមួយ- ហេរីតប ខណៈពេលដែលទឹកថ្នាំបែកពពុះគ្រូកៗ។

*

មួយសប្ដាហ៍ក្រោយមក ហេរី រ៉ុន និងហឺម៉ាយអូនី កំពុងតែដើរឆ្លងកាត់តាមទ្វារចូលសាល ស្រាប់តែឃើញមនុស្សមួយក្រុមកំពុងតែប្រមូលផ្ដុំគ្នាជុំវិញក្ដារប្រកាសព័ត៌មាន។ ពួកគេកំពុងអានសេចក្ដីប្រកាសមួយមួយដែលទើបនឹងបិតផ្សាយ។ ស៊ីម្យុស ហ្វីននីហ្គេន និង ឌីន ថូម៉ាស ជាអ្នកអាន មើលទៅដូចជារំភើបខ្លាំងណាស់។

# ក្រុមប្រយុទ្ធតតាំង

- ពួកគេចាបផ្ដើមបើក ក្រុមប្រយុទ្ធតតាំងហើយ!- ស៊ីម្យុសស្រែក។ - ការប្រជុំលើកទីមួយគឺយប់នេះ! ខ្ញុំមិនប្រកាន់នឹងមេរៀនប្រយុទ្ធនោះទេ ព្រោះថាអាចផ្ដល់ផលប្រយោជន៍ដល់ថ្ងៃក្រោយ...

- ថាម៉េច! ឯងគិតថាបិសាចក្រុមស្លីធើរីនអាចប្រយុទ្ធបានដែររឺ?- រ៉ុនស្រដី ប៉ុន្តែវាក៏អានសេចក្ដីប្រកាសនោះដោយចាប់អារម្មណ៍ណាស់ដែរ។

- អាចមានប្រយោជន៍- វានិយាយទៅកាន់ ហេរី និង ហឺម៉ាយអូនី ពេលដែលពួកគេទៅទទួលទានអាហារពេលល្ងាច។ - តើពួកយើងគួរទៅទេ?

ហេរី និងហឺម៉ាយអូនីយល់ស្របទាំងស្រុងចំពោះរឿងនេះ ដូច្នេះនៅម៉ោងប្រាំបីល្ងាចនោះ ពួកគេប្រញាប់ត្រលប់ទៅកាន់សាលធំវិញ។ តុទទួលទានអាហារត្រូវរលាយបាត់ ហើយឆាកពណ៌មាសមួយបានលេចឡើងនៅតាមជញ្ជាំង បំភ្លឺទៅដោយពន្លឺទៀនរាប់រយរាប់ពាន់នៅពីលើ។ ពិតានមានពណ៌ខ្មៅរលោងម្ដងទៀត ហើយសាលាសឹងតែទាំងមូលសុទ្ធតែនៅក្រោមពិតាននេះ ម្នាក់ៗកាន់ចង្កឹះជាប់នឹងដៃ ទឹកមុខរំភើបរំជើបរំជួល។

- តើនរណាជាអ្នកបង្រៀនយើងទៅហ្ន៎?- ហឺម៉ាយអូនីបន្លឺឡើង ខណៈពេលដែលពួកគេប្រជ្រៀតចូលទៅក្នុងហ្វូងមនុស្សអ៊ូអរ។ - មានគេប្រាប់ខ្ញុំថាសាស្ត្រាចារ្យ ហ្វ្លីតវីក ធ្លាប់ជាជើងឯកខាងការប្រយុទ្ធ កាលពីគាត់នៅក្មេង។ ប្រហែលជាគាត់ហើយ។

- នរណាក៏បានដែរ កុំឲ្យតែ...- ហេរីហៀបនឹងនិយាយ ប៉ុន្តែក៏ឈប់ទៅវិញដោយបន្លឺសំឡេងគ្រហឹមបែបមិនពេញចិត្តះ ហ្គីលដឺរ័យ ឡក់ហាត កំពុងតែដើរឡើងមកលើឆាក ខ្លួនលំអទៅដោយរ៉ូបពណ៌ផ្លែព្រូនចាស់ ហើយអ្នកហែហមគាត់នោះ គឺគ្មាននរណាក្រៅពីស្នេពឡើយ ដែលស្លៀកពាក់ឈុតខ្មៅ ដូចរាល់ដង។

ឡក់បក់ដៃឲ្យស្ងាត់ ហើយប្រកាសះ

- មកឲ្យជុំគ្នា មកឲ្យជុំគ្នាមក់! តើអ្នកទាំងអស់គ្នាមើលខ្ញុំឃើញទេ? តើអ្នកទាំងអស់គ្នាស្ដាប់ខ្ញុំឮទេ? ល្អណាស់!

- ឥឡូវ លោកសាស្ត្រាចារ្យដាំប៊ល់ដ័រ បានផ្ដល់សិទ្ធិអនុញ្ញាតឲ្យខ្ញុំចាប់ផ្ដើមដំណើរការ ក្រុមប្រយុទ្ធតតាំង ដ៏តូចតាចមួយនេះ គឺក្នុងគោលបំណងហ្វឹកហ្វឺនអ្នកទាំងអស់គ្នា ត្រៀមប្រើក្នុងករណីដែលអ្នកទាំងអស់គ្នាចាំបាច់ការពារខ្លួនឯង ដូចដែលខ្ញុំធ្លាប់បានធ្វើជាច្រើនលើកច្រើនសារួចមកហើយ ... បើចង់ជ្រាបច្បាស់ សូមអានសៀវភៅដែលខ្ញុំបានចេញផ្សាយចុះ។

- អនុញ្ញាតឲ្យខ្ញុំណែនាំជំនួយការរបស់ខ្ញុំគឺ សាស្ត្រាចារ្យស្នេព- ឡក់ហាតបន្លឺឡើង ជាមួយនឹងស្នាមញញឹមដ៏ធំមួយ។ - គាត់ប្រាប់ខ្ញុំថា គាត់ចេះដឹងបន្តិចបន្តួចដែរអំពីការប្រយុទ្ធ ហើយក៏ស្ម័គ្រចិត្តជួយខ្ញុំក្នុងការសម្ដែងខ្លីមួយមុននឹងពួកយើងចាប់ផ្ដើម។ ឥឡូវ ខ្ញុំមិនចង់ឲ្យពួកក្មេងៗទាំងអស់គ្នាព្រួយបារម្ភនោះទេ ... ខ្ញុំគ្រាន់តែឲ្យគាត់ជួយប៉ុណ្ណោះ មិនមែនថាសម្លាប់គាត់ឯណា...ដូច្នេះកុំព្រួយបារម្ភថ្វី!

- តើមិនល្អជាងទេរឺ ប្រសិនបើពួកគេប្រយុទ្ធគ្នាឲ្យណាណីតែម្ដងនោះ?- រ៉ុនត្អូញត្អែរដាក់ត្រចៀកហេរី។

បបូរមាត់ខាងលើរបស់ស្នេពចាប់ផ្ដើមរួញ។ ហេរីឆ្ងល់ថាហេតុអ្វីក៏ឡក់ហាតនៅតែញញឹមទៅរួចទៀត...ប្រសិនបើស្នេពសម្លឹងមើលវាតែរបៀបហ្នឹង វាច្បាស់ជាដាក់មេប្រូចរត់គេចចេញឆ្ងាយពីគាត់ហើយ មិននៅយូរទេ។

ឡក់ហាត និងស្នេពបែរមកទល់មុខគ្នា ហើយអោនគោរពគ្នាជាគំនាប់។ យ៉ាងហោចណាស់ក៏ ឡក់ហាតធ្វើគួរសមដែរ ដោយគ្រវាសគ្រវាត់ដៃសមរម្យ ឯស្នេពវិញគ្រាន់តែអោនក្បាលបន្តិច សឹងតែនឹងអត់។ បន្ទាប់មក ពួកគេលើកចង្កឹះវេទមន្តរបស់ពួកគេដាក់ពីមុខ ប្រៀបបានដូចជាដាវ។

- ដូចដែលពួកឯងឃើញស្រាប់ហើយ ពួកយើងកំពុងតែកាន់ចង្កឹះវេទមន្តដោយឈរក្នុងលក្ខណៈត្រៀមប្រយុទ្ធ- ឡក់ហាត ពោលទៅកាន់ហ្វូងមនុស្សដែលស្ងាត់ឈឹង។ - ពេលរាប់ដល់បី ពួកយើងនឹងសូត្របញ្ចេញសិល្ប៍ទីមួយរបស់ពួកយើង។ ជាការពិត ណាស់ យើងគ្មានគោលបំណងសម្លាប់គ្នានោះទេ។

- ខ្ញុំដូចជាមិនសូវជឿទេ- ហេរីនិយាយតិចៗ ដោយសម្លឹងមើលស្នេពកំពុងតែបញ្ចេញចង្កូម។

- មួយ...ពីរ...បី!

ពួកគេទាំងពីរនាក់លាស់ចង្កឹះរបស់ពួកគេឡើង ដាក់ត្រឹមស្មា។ ស្នេពស្រែកថា៖ *"អិចស្ពេលីអាមុស!"* មានពន្លឺភ្លើងពណ៌ក្រហមភ្លឺបភ្លែតដ៏អស្ចារ្យមួយបាញ់ចេញមក ហើយ ឡក់ហាត ស្រាប់តែប៉ើងខ្ទាតផុតពីដី៖ គាត់ប៉ើងទៅក្រោយហួសឆាក រួចបុកទៅនឹងជញ្ជាំង ហើយរអិលចុះក្រោម មកពោបនឹងកម្រាលឥដ្ឋ។

មេលហ្វ័យ និងសិស្សក្រុមស្លីធីរីនមួយចំនួនទៀតហ៊ោអបអរ។ ហឺម៉ាយអូនីខំប្រឹងជំទើតម្រាមជើងអើតមើល។

- តើឯងគិតថាគាត់មិនអីទេវី?- នាងស្រែកសួរ។

- នរណាទៅខ្វល់ទៅ?- រ៉ុន និងហេរីនិយាយព្រមៗគ្នា។

ឡក់ហាតកំពុងតែក្រោកឈរឡើងទាំងមមីងមមាំង។ មួករបស់គាត់ជ្រុះមកដី ហើយសក់រាងទឹករលករបស់គាត់ឡើងបះច្រូង។

- ល្អ...គឺវាអញ្ចឹងឯង!- គាត់ឧទានឡើង ពេលកំពុងដើរទ្រេតទ្រោតឡើងលើឆាកវិញ។ - នោះហើយគឺជា សិល្ប៍បណ្ដោះ ... ដូចដែលពួកឯងឃើញស្រាប់ ខ្ញុំបានជ្រុះបាត់ចង្កឹះវេទមន្តខ្ញុំហើយ...អូ្ន! អរគុណ កញ្ញាប្រោន។ មែន! ពិតជាគំនិតល្អមែនក្នុងការបង្ហាញពួកគេឲ្យដឹងពីយុទ្ធសិល្ប៍នេះ លោកសាស្ត្រាចារ្យស្នេព ប៉ុន្តែប្រសិនបើលោកមិនប្រកាន់នឹងសម្ដីខ្ញុំទេ ខ្ញុំគិតថាវាដូចជាជាក់ស្ដែងពេកហើយចំពោះអ្វីដែលលោករៀបនឹងធ្វើអំបាញ់មិញនេះ។ ប្រសិនបើខ្ញុំចង់បញ្ឈប់លោកនោះ គឺងាយស្រួលដូចបកចេញអញ្ចឹង។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំយល់ថាវាក៏មានផលល្អដែរ ព្រោះអាចបង្ហាត់ឲ្យពួកគេចេះបាន...

ស្នេពមើលទៅដូចជាចង់សម្លាប់នរណាម្នាក់អញ្ចឹង។ ប្រហែលជា ឡក់ហាត ក៏បានចាប់អារម្មណ៍ពីរឿងនេះដែរ បានជាគាត់ប្រកាសថា៖

- សម្ដែងប៉ុណ្ណឹងគ្រប់គ្រាន់ហើយ! ខ្ញុំនឹងដើរទៅចែកពួកឯងទាំងអស់គ្នាជាគូៗ។ លោកសាស្ត្រាចារ្យស្នេព ប្រសិនបើលោកមិនយល់ទាស់ទេ...

ពួកគេទាំងពីរដើរចូលទៅក្នុងហ្វូងសិស្ស រួចចាប់ផ្ដើមរកដៃគូឲ្យសិស្សម្នាក់ៗ។ ឡក់ហាតចាប់គូ នេវីលជាមួយ ហ្វីន-ហ្វ្លិតឈ្លី ប៉ុន្តែស្នេពដើរសំដៅមករក ហេរី និងរ៉ុន ដំបូងគេតែម្ដង។

- ខ្ញុំគិតថាដល់ពេលបំបែកក្រុមសុបិនរបស់ពួកឯងហើយ- គាត់ញញឹមបែបចំអក។ - វីស្លី ឯងចាប់គូជាមួយនឹងហ្វីននីហ្គេន។ ឯផោតធ័រវិញ...

ហេរីរឹកិលខ្លួនសំដៅទៅហឺម៉ាយអូនីដោយស្វ័យប្រវត្តិ។

- ខ្ញុំមិនគិតដូច្នោះទេ- ស្នេពស្រដី ដោយញញឹមយ៉ាងសោះកក្រោះ។ - លោកមេលហ្វ័យ មកទីនេះ។ ចាំមើល តើឯងនឹងធ្វើឲ្យ ផោតធ័រ ដ៏ល្បីល្បាញម្នាក់នេះទៅជាយ៉ាងណា។ ហើយឯងវិញ កញ្ញាហ្គ្រេនជឺរ...ឯងអាចចាប់គូជាមួយកញ្ញា បាល់ស្ត្រូដ ចុះ។

មេលហ្វ័យដើរពើងទ្រូងមក មុខញញឹមជាប់។ មានក្មេងស្រីស្លីតឺរីនម្នាក់ដើរត្រុកៗតាមក្រោយវា ធ្វើឲ្យហេរីនឹកឃើញដល់រូបភាពមួយ ដែលវាឃើញនៅក្នុងសៀវភៅ *វិស្សមកាលជាមួយស្ត្រីមេធ្មប់*។ នាងមានមាឌធំ ដូចធុងសាំង ហើយថ្គាមដ៏ធូន់របស់នាងទង្គិចនឹងគ្នាយ៉ាងសាហាវ។ ហឺម៉ាយអូនីញញឹមបន្តិចដាក់នាង តែនាងមិនស្វាគមន៍តបមកវិញសោះឡើយ។

- បែរមុខមករកដៃគូ!- ឡក់ហាតប្រកាសនៅលើឆាក - ហើយឱនគោរពគ្នា!

ហេរី និងមេលហ្វ័យបន្ទាបក្បាលរបស់ពួកគេសឹងតែនឹងអត់ ឯភ្នែកសម្លឹងមើលគ្នាមិនដាក់ឡើយ។

- ត្រៀមចង្កឹះ!- ឡក់ហាតស្រែក។ - ពេលខ្ញុំរាប់ដល់បី ត្រូវបាញ់សិល្ប៍របស់ពួកឯងដើម្បីបណ្ដេញអាវុធចេញពីគូប្រកួត...បានត្រឹមតែបណ្ដេញអាវុធប៉ុណ្ណោះ...ពួកយើងមិនចង់ឲ្យមានគ្រោះថ្នាក់អ្វីនោះទេ។ មួយ...ពីរ...បី...

ហេរីគ្រវីចង្កឹះរបស់វាដាក់ត្រឹមស្មា ប៉ុន្តែមេលហ្វ័យចាប់ផ្ដើមតាំងពីរាប់បានត្រឹម "ពីរ" ម្ល៉េះ៖ សិល្ប៍របស់វាបានបុកហេរីយ៉ាងខ្លាំង ធ្វើឲ្យវាមានអារម្មណ៍ដូចជាមានគេយកខ្ទះមកសំពោងក្បាលវាអញ្ចឹង។ វាជំពប់ជើងដួល ប៉ុន្តែអ្វីៗគ្រប់យ៉ាងដូចជាធម្មតាទេ ហើយដើម្បីកុំឲ្យខ្ទះខ្ជាយពេលវេលា ហេរីក៏ចង្អុលចង្កឹះរបស់វាចំមេលហ្វ័យ ហើយស្រែក៖ "*រីកធូសេមប្រា!*"

ពន្លឺភ្លើងពណ៌ប្រាក់មួយបុកមេលហ្វ័យចំពោះ ហើយវាក៏ដួលទៅមុខ ខ្លួនពិបាកដកដង្ហើម។

- ខ្ញុំប្រាប់ហើយថាគ្រាន់តែបណ្ដេញអាវុធប៉ុណ្ណោះ!- ឡក់ហាតស្រែកខ្លាំងៗពីលើសំឡេងហ្វូងសិស្សកំពុងតែប្រយុទ្ធគ្នាខណៈពេលដែលមេលហ្វ័យកំពុងលុតជង្គង់ចុះ។ ហេរីបានវាយប្រហារវានឹង សិល្ប៍សើប ដូច្នេះវាសើចឡើងកម្រើកខ្លួនលែងចង់បានទៅហើយ។ ហេរីថយក្រោយវិញ ដោយគិតថាមិនគួរដាក់អាគមលើវាទៀតទេ ពេលដែលវាដួលទៅហើយ ប៉ុន្តែវាគិតខុសហើយ។ ទាំងដង្ហក់រកដង្ហើមដកមិនចង់បានផង មេលហ្វ័យនៅតែលើកចង្កឹះវេទមន្តរបស់វាដាក់ចំជង្គង់របស់ហេរី ហើយស្រែក "*ថារ៉េនថាឡាហ្គ្រា!*" ហើយមួយវិនាទីក្រោយមក ជើងរបស់ហេរីក៏ស្រាប់តែកន្ត្រាក់រាំ មិនអាចគ្រប់គ្រងបានឡើយ។

- ឈប់! ឈប់!- ឡក់ហាតស្រែក ប៉ុន្តែស្នេពចាត់ការមុនបាត់ទៅហើយ។

- *ហ្វីនីត អ៊ីនខានថាថេម!*- គាត់ស្រែក។ ជើងរបស់ហេរីឈប់រាំ ឯមេលហ្វ័យក៏ឈប់សើច ហើយពួកគេក៏អាចងើយមើលទៅលើបានវិញ។

ផ្សែងពណ៌បៃតងរសាត់ជុំវិញទស្សនីយភាពនោះ។ នេវីល និងចាស់ស្ទីន ទាំងពីរនាក់កំពុងតែដេកលើកំរាលឥដ្ឋទាំងហត់គឃុស។ រ៉ុនកំពុងតែជួយគ្រាហ៍ស៊ីម្មុសដែលមុខឡើងខ្មៅដូចផេះបណ្ដើរ សុំទោសចំពោះចង្កឹះបាក់របស់វាបណ្ដើរ។ ហឺម៉ាយអូនី និង មីលីសិន បាល់ស្ត្រូដនៅប្រយុទ្ធនៅឡើយ។ មីលីសិនចាប់ឃ្លេក្បាលរបស់ហឺម៉ាយអូនីជាប់ ហើយហឺម៉ាយអូនីកំពុងតែថ្ងូរដោយឈឺ។ ដោយទុកចង្កឹះចោលនៅលើកំរាលឥដ្ឋ ហេរីហក់ភ្លែតទៅទាញ មីលីសិន ចេញ។ មិនងាយស្រួលប៉ុន្មានទេ ព្រោះថានាងធំជាងវាឆ្ងាយណាស់។

- ពុទ្ធោៗ!- ឡក់ហាតនិយាយ ព្រមទាំងដើរកាត់តាមហ្វូងមនុស្ស ពិនិត្យមើលលទ្ធផលនៃការប្រកួតទាំងនោះ។ - ក្រោកឡើង មេកស៍មីលេន...ប្រយ័ត្នបន្តិច កញ្ញា ហ្វ័រសិត...សង្កត់ឲ្យខ្លាំង តែបន្តិចទៀតឈប់ហូរឈាមហើយ ប៊ូត...

- ខ្ញុំគិតថា ខ្ញុំគួរតែបង្រៀនពួកឯងពីវិធីទប់ទល់នឹងយុទ្ធសិល្ប៍អាក្រក់ៗហើយ- ឡក់ហាតស្រដី ដោយឈរទាំងច្របូកច្របល់នៅកណ្ដាលសាលនោះ។ គាត់ក្រឡេកមើលទៅស្នេព ឃើញភ្នែកពណ៌ខ្មៅរបស់គាត់បញ្ចេញពន្លឺឆ្វាច ហើយក៏ងាកភ្នែកចេញយ៉ាងរហ័ស។ - សូមឲ្យគូស្ម័គ្រចិត្តម្នាក់ឡើងមក ... ឡុងបត់ថម និង ហ្វីន-ហ្លិតឈ្លី ពីរនាក់ឯងគិតយ៉ាងម៉េចដែ?

- មិនសូវល្អទេ លោកសាស្ត្រាចារ្យឡក់ហាត- ស្នេពនិយាយ ព្រមទាំងដើរសសៀរមកដូចជាបិសាចប្រជៀវដ៏ធំមួយក្បាល។ - គ្រាន់តែសិល្ប៍ធម្មតាៗបំផុត ក៏ឡុងបត់ថមធ្វើឲ្យកើតជាមហន្តរាយដែរ។ ប្រសិនជាឲ្យពួកគេប្រយុទ្ធគ្នា ច្បាស់ជានឹងត្រូវដាក់

បំណែករាងកាយរបស់ហ្វីន-ហ្វ្លិតឈ្លីដែលនៅសល់ក្នុងប្រអប់ឈើគូស រួចបញ្ជូន ទៅកាន់គិលានដ្ឋានហើយ។- មុខមូលពណ៌ផ្កាឈូករបស់នេវីលកាន់តែឡើងពណ៌ផ្កាឈូក។ - យ៉ាងម៉េចដែរ ចំពោះគូ មេលហ្វ័យ និងផោតធ័រ វិញ?- ស្នេពស្រដីជាមួយនឹងស្នាមញញឹមបែបពុតត្បុត។

- គំនិតប្រសើរណាស់!- ឡក់ហាតតប ព្រមទាំងធ្វើសញ្ញាឲ្យ ហេរី និងមេលហ្វ័យចូលមកកណ្ដាលសាល ខណៈពេលដែលហ្វូងសិស្សទាំងឡាយនាំគ្នាថយក្រោយ ដើម្បីទុកចន្លោះឲ្យពួកគេទាំងពីរនាក់។

- ឥឡូវ ហេរី- ឡក់ហាតពោល - នៅពេលដែលជ្រាកូចង្អុលចង្កឹះចំឯង ឯងត្រូវធ្វើយ៉ាងនេះ។

គាត់លើកចង្កឹះរបស់គាត់ រួចធ្វើកាយវិការគ្រវីគ្រវាត់មិនដឹងក្បាលកន្ទុយ ហើយស្រាប់តែជ្រុះចង្កឹះចេញពីដៃ។ ស្នេពញញឹមឡកឡឺយដាក់ឡក់ហាត ពេលដែលគាត់លើកចង្កឹះឡើងវិញយ៉ាងរហ័សរហួន ថែមទាំងនិយាយថា៖

- អូ្ហ...ចង្កឹះរបស់ខ្ញុំប្រហែលជារំជើបរំជួលពេកហើយ។

ស្នេពដើរទៅជិតមេលហ្វ័យ អោនចុះហើយខ្សឹបរឿងអ្វីម្យ៉ាងដាក់ត្រចៀកវា។ មេលហ្វ័យក៏ញញឹមដែរ។ ហេរីងើយមើលយ៉ាងអន្ទះសាទៅឡក់ហាត ហើយនិយាយ៖

- លោកសាស្ត្រាចារ្យ តើលោកអាចបង្ហាញខ្ញុំពីរបៀបទប់ទល់ស្ពឺគេនោះម្ដងទៀតបានទេ?

- ខ្លាចហើយ?- មេលហ្វ័យសួរតិចៗ ដើម្បីកុំឲ្យឡក់ហាតស្ដាប់ឮ។

- ដេកយល់សប្ដិទៅ- ហេរីបង្អើបមាត់និយាយតិចៗ។

ឡក់ហាតកៀកស្មាហេរីយ៉ាងរីករាយ។ - ធ្វើតាមតែខ្ញុំធ្វើអំបាញ់មិញទៅបានហើយ ហេរី!

- ធ្វើអីគេ ធ្វើជ្រុះចង្កឹះហ្នឹងអ្វី?

ប៉ុន្តែឡក់ហាតមិនស្ដាប់ឡើយ។

- បី...ពីរ...មួយ...ចាប់ផ្ដើម!- គាត់ស្រែក។

មេលហ្វ័យលើកចង្កឹះរបស់វាយ៉ាងរហ័ស ហើយស្រែក៖ "*សើផិនស័តធីយ៉ា!*"

ចុងចង្កឹះរបស់វាផ្ទុះឡើង។ ហេរីសម្លឹងមើលទាំងស្រឡាំងកាំង ខណៈដែលពស់ពណ៌ខ្មៅដ៏វែងមួយក្បាលបាញ់ចេញពីចង្កឹះនោះ រួចធ្លាក់លើសួរក្នុកទៅលើកំរាលឥដ្ឋ នៅចន្លោះពួកគេទាំងពីរនាក់ ហើយក៏ងើបក្បាលរបស់វាឡើង ត្រៀមខ្លួនដើម្បីចឹកវាយប្រហារ។ ឮសូរសម្រែកពេលដែលហ្វូងសិស្សម្នីម្នាថយក្រោយយ៉ាងលឿន ធ្វើឲ្យមានចន្លោះកាន់តែធំឡើង។

- កុំកម្រើកអី ផោតធ័រ- ស្នេពស្រដីហាក់ដូចជាមិនចង់ ក្នុងចិត្តកំពុងតែសប្បាយនឹងមើលហេរីឈរដោយគ្មានវិញ្ញាណ ពេលប្រឈមមុខគ្នាជាមួយនឹងពស់កំណាចនោះ។ - ចាំខ្ញុំចាត់ការវាអោយ...

- ទុកឲ្យខ្ញុំវិញ!- ឡក់ហាតលូកមាត់។ គាត់គ្រវីចង្កឹះវេទមន្តរបស់គាត់ដាក់ពស់នោះ ក៏ស្រាប់តែឮសូរផ្ទុះផ្ទូង! ពស់នោះ មិនត្រឹមតែមិនរលាយបាត់ទៅវិញទេ បែរជាប៉ើងចម្ងាយប្រមាណបីម៉ែតទៅក្នុងលំហ ហើយធ្លាក់ចុះមកលើកម្រាលឥដ្ឋវិញឮសូរក្នុក។ លើកនេះ វាកាន់តែខឹងខ្លាំងឡើង ហើយក៏វារសំដៅទៅរក ចាស់ស្ទីន ហ្វីន-ហ្វ្លិតឈ្លី រួចដកកឲ្យខ្ពស់ ដកពពារ ក្នុងកាយវិការត្រៀមនឹងចឹក។

ហេរីមិនប្រាកដថាហេតុអ្វីបានជានាំឲ្យវាធ្វើអញ្ចឹងនោះទេ ហើយវាក៏មិនដឹងថាវាសម្រេចចិត្តធ្វើតាំងពីពេលណាដែរ។ វាគ្រាន់តែដឹងថា ពេលនោះជើងទាំងទ្វេរបស់វាដើរសំដៅទៅមុខ ហាក់ដូចជាវាកំពុងជិះរទេះរុញ ហើយវាស្រាប់តែស្រែកដាក់ពស់នោះយ៉ាងល្ងីល្ងើថា៖ "ចេញពីគេភ្លាម!" ក្រោយមក ហាក់ដូចជាមានអព្ភូតហេតុកើតឡើង ដោយជៀសមិនផុត ពស់នោះក៏ទម្លាក់ខ្លួនទៅ

លើកម្រាលឥដ្ឋវិញ យ៉ាងស្លូតបូតដូចជាបំពង់ទុយោទឹកពណ៌ខ្មៅដ៏ក្រាស់នៅក្នុងសួនច្បារដូច្នោះដែរ រីឯភ្នែកវាសម្លឹងមើលមកហេរី។ ហេរីមានអារម្មណ៍ថាសេចក្ដីភ័យខ្លាចឥឡូវបាត់បង់ពីខ្លួនវាអស់ហើយ។ វាដូចជាដឹងថាពស់នោះនឹងលែងវាយប្រហារនរណាម្នាក់ទៀតហើយ តែវាក៏មិនអាចពន្យល់បានថាហេតុអ្វីបានជាដូច្នោះឡើយ។

វាងើយមើលទៅចាស់ស្ទីន ដោយញញឹមស្ញេញ ស្មានតែឃើញចាស់ស្ទីនធូរទ្រូង រឺភ័ន្តភាំង រឺក៏ដឹងគុណចំពោះវា ស្រាប់តែឃើញវាបែរជាខឹង និងតក់ស្លុតទៅវិញ។

- ឯងគិតថាឯងកំពុងតែលេងល្បែងអ្វីហ្នឹង?- វាស្រែក ឯហេរីមិនទាន់ទាំងបាននិយាយអ្វីផង ចាស់ស្ទីនបង្វែរខ្លួនដើរចេញពីសាលនោះបាត់ទៅហើយ។

ស្នេពឈានចេញមកមុខ រួចរលាស់ចង្កឹះរបស់គាត់ ហើយពស់នោះក៏រលាយបាត់ទៅបន្សល់នូវផ្សែងពណ៌ខ្មៅមួយដុំ។ ស្នេពក៏សម្លឹងមើលមកហេរីយ៉ាងចម្លែកដែរៈ ទឹកមុខគាត់ហាក់ដូចជាសញ្ជឹងគិតពីរឿងអ្វីមួយ ហើយហេរីមិនចូលចិត្តទឹកមុខនោះឡើយ។ វាក៏ចាប់អារម្មណ៍ពីការនិយាយខ្សឹបខ្សៀវគ្នា ដ៏ទ្រហឹងអឺងកងគួរឲ្យខ្លាចនៅក្នុងសាលនោះដែរ។ បន្ទាប់មក វាក៏មានអារម្មណ៍ថាមាននរណាម្នាក់កំពុងរុញពីក្រោយរ៉ូបរបស់វា។

- ឆាប់ឡើង- សំឡេងរ៉ុនបន្លឺឡើងក្នុងត្រចៀករបស់វា។ - ឆាប់មកឲ្យលឿនឡើង...

រ៉ុនរុញវាចេញពីសាលនោះ ឯហឺម៉ាយអូនីដើរតាមពួកគេទាំងពីរ។ ពេលដែលពួកគេដើរឆ្លងកាត់ទ្វារមួយៗ មនុស្សម្នានាំគ្នាជៀសចេញហាក់ដូចជាខ្លាចចាប់បានអ្វីមួយអញ្ចឹង។ ហេរីគ្មានដឹងខ្យល់ថាមានរឿងអ្វីកំពុងតែកើតឡើងនោះទេ ចំនែកឯរ៉ុន និងហឺម៉ាយអូនីក៏មិននិយាយអ្វីទាំងអស់រហូតទាល់តែពួកគេអូសវាឡើងទៅដល់សាលរួមនៃអគារក្រុមហ្គ្រីហ្វីនដ័រ។ បន្ទាប់មក រ៉ុនរុញហេរីឲ្យអង្គុយលើកៅអីភ្នាក់ដៃមួយ ហើយនិយាយថាៈ

- ឯងចេះនិយាយភាសាពស់។ ហេតុអ្វីបានជាឯងមិនប្រាប់ពួកយើង?

- ខ្ញុំចេះស្អី?- ហេរីស៊ី្ត។

- គឺចេះនិយាយភាសាពស់ហ្នឹងណ៎ា!- រ៉ុនឆ្លើយ។ - ឯងអាចនិយាយជាមួយពស់បាន!

- ខ្ញុំដឹងហើយ- ហេរីពោល។ - ខ្ញុំចង់និយាយថា នេះគឺជាលើកទីពីរហើយដែលខ្ញុំបានធ្វើរឿងដូច្នេះ។ មានម្ដងនោះខ្ញុំបានធ្វើឲ្យ បងជីដូនមួយរបស់ខ្ញុំ ដាត់លី ជាប់ក្នុងទ្រុងពស់នៅសួនសត្វដោយអចេតនា ... បើនិយាយទៅវែងឆ្ងាយណាស់...ប៉ុន្តែពស់នោះប្រាប់ខ្ញុំថា វាមិនដែលទៅលេងប្រេស៊ីលឡើយ ហើយខ្ញុំក៏លែងវាឲ្យចេញតែម្ដងទៅដោយគ្មាននឹកគិតអ្វីទេ។ នោះគឺមុនពេលដែលខ្ញុំដឹងថាខ្លួនជាវេទគូ...

- ពស់មួយក្បាលប្រាប់ឯងថាវាមិនដែលទៅលេងប្រេស៊ីលរឺ?- រ៉ុនថាតាមខ្សោយៗ។

- ហើយចុះយ៉ាងម៉េច?- ហេរីស្រដី។ - ខ្ញុំជឿថាមានមនុស្សជាច្រើនដែលអាចធ្វើបាន។

- អូ! ទេ ពួកគេធ្វើមិនកើតទេ- រ៉ុននិយាយ។ - វាមិនមែនជានិស្ស័យដែលមនុស្សគ្រប់គ្នាចេះតែមាននោះទេ។ ហេរី រឿងនេះមិនល្អឡើយ។

- រឿងអីមិនល្អ?- ហេរីសួរ ហាក់ដូចជារាងក្ដៅក្រហាយ។ - តើអ្នកទាំងអស់គ្នាកើតអី? ស្ដាំណ៎ា! ប្រសិនបើខ្ញុំមិនប្រាប់ពស់នោះកុំឲ្យចឹកចាស់ស្ទីន...

- អូ! ឯងនិយាយប្រាប់វាអញ្ចឹងរឺ?

- តើឯងនិយាយពីអ្វីហ្នឹង? ក្រែងឯងក៏នៅទីនោះដែរ...ច្បាស់ជាបានស្ដាប់ឮខ្ញុំនិយាយហើយ។

- ខ្ញុំឮតែឯងនិយាយភាសាពស់ប៉ុណ្ណោះ- រ៉ុនប្រាប់ - គឺភាសាពស់តែប៉ុណ្ណឹងឯង។ នរណាទៅដឹងថាឯងនិយាយអ្វីខ្លះនោះ។ មិនចម្លែកទេដែលចាស់ស្ទីនស្លន់ស្លោរដល់ថ្នាក់ហ្នឹងនោះ។ សំឡេងឯងនិយាយស្ដាប់ទៅដូចជាកំពុងជំរុញឲ្យពស់នោះចឹកវាអញ្ចឹង។ ឯងដឹងទេ វាពិតជាគួរឲ្យខ្លាចណាស់។

ហេរីសម្លឹងមើលរ៉ុនទាំងប្រហមាត់ធ្លុង។

- ខ្ញុំនិយាយភាសាផ្សេងរឺ? ប៉ុន្តែ...ខ្ញុំមិនបានដឹងថា...ហេតុអ្វីបានជាខ្ញុំចេះនិយាយភាសាផ្សេងទាំងមិនដឹងខ្លួនសោះអញ្ចឹង?

រ៉ុនគ្រវីក្បាល។ វា និងហឺម៉ាយអូនីកំពុងតែសម្លឹងហាក់ដូចជាមាននរណាម្នាក់ស្លាប់អញ្ចឹង។ ហេរីគិតមិនយល់ថាមានអ្វីគួរឲ្យខ្លាចយ៉ាងនេះនោះទេ។

- តើពួកឯងអាចប្រាប់ខ្ញុំបានទេថា តើវាមានអ្វីខុសឆ្គងទៅ ក្នុងការជួយកុំឲ្យពស់កំណាចមួយក្បាលខាំដាច់ក្បាលរបស់ចាស់ស្ទីននោះ?- វានិយាយ។ - តើវាមានបញ្ហាអ្វីទេ ដែលថាចាស់ស្ទីនមិនត្រូវបង្ខំចិត្តចូលរួមក្រុមអ្នកប្រមាញ់ឥតក្បាលនោះ?

- វាមានបញ្ហា- ហឺម៉ាយអូនីតបដោយសម្លេងស្ងាត់ៗ - ពីព្រោះថាការចេះនិយាយជាមួយពស់គឺជាសមត្ថភាពដ៏មហស្ចារ្យមួយដែលធ្វើឲ្យ សាឡាហ្សា ស្លីតឺរីន ល្បីឈ្មោះ។ ហេតុនេះហើយបានជាមានរូបសត្វពស់នៅលើផ្លាកនិមិត្តសញ្ញារបស់ក្រុមស្លីតឺរីន។

មាត់ហេរីប្រហធ្លុង។

- ពិតប្រាកដហើយ- រ៉ុនឯកភាព។ - ហើយឥឡូវសាលាទាំងមូលច្បាស់ជាគិតថា ឯងគឺជាចៅទួតជាលួតជាលា រឺក៏ជាប់សាច់ជាប់ឈាមអ្វីម្យ៉ាងជាមួយគាត់ជាមិនខាន...

- ប៉ុន្តែខ្ញុំមិនមែនទេ- ហេរីស្រដី ទាំងក្នុងសភាពស្លន់ស្លោរ ដែលសូម្បីតែវាក៏រកពាក្យនិយាយមិនត្រូវដែរ។

- ឯងពិបាកនឹងបញ្ជាក់រឿងនេះណាស់- ហឺម៉ាយអូនីពោល។ - គាត់រស់តាំងពីមួយពាន់ឆ្នាំមុនម៉្លេះ។ បើតាមភ័ស្តុតាងដែលយើងមាននៅពេលនេះ ឯងអាចជាប់សាច់ឈាមជាមួយគាត់មែន។

*

ហេរីដេកមិនលក់ជាច្រើនម៉ោងនៅយប់នោះ។ វាសម្លឹងមើលព្រឹល តាមចន្លោះខ្សែព្យួរជុំវិញបង្គោលគ្រែទាំងបួនរបស់វា ដែលចាប់ផ្ដើមរសាត់តាមបង្អួចអគារ...ហើយសញ្ជឹងគិត។

តើវាអាចជាកូនចៅរបស់ សាឡាហ្សា ស្លីតឺរីន ទេ? បើនិយាយឲ្យអស់ទៅ វាក៏មិនដឹងរឿងអ្វីអំពីគ្រួសាររបស់ប៉ាវាដែរ។ គ្រួសារឌើស្លីតែងតែហាមឃាត់សំនួរទាក់ទងនឹងសាច់ញាតិវេទគួររបស់វាជានិច្ច។

ហេរីលួចសាកនិយាយភាសាពស់ម្ដងទៀត។ គ្មានពាក្យចេញពីមាត់របស់វាទេ។ មើលទៅប្រហែលជាវាត្រូវជួបជាមួយនឹងពស់ដោយផ្ទាល់ហើយ ទើបអាចនិយាយបាន។

- ប៉ុន្តែខ្ញុំនៅក្នុងក្រុមហ្គ្រីហ្វីនដ័រទេតើ- ហេរីគិត។ - មួកសិល្ប៍ច្បាស់ជាមិនដាក់ខ្ញុំក្នុងក្រុមនេះទេ ប្រសិនបើខ្ញុំមានឈាមជ័រស្លីតឺរីននោះ...

- អ្ហ- សំឡេងរបិលរប៉ូចតូចឆ្មារមួយបន្លឺឡើងក្នុងខួរក្បាលរបស់វា - ប៉ុន្តែមួកសិល្ប៍ក៏ចង់ដាក់ឯងក្នុងក្រុមស្លីតឺរីនដែរ នៅចាំទេ?

ហេរីប្រែខ្នង។ វានឹងជួបចាស់ស្ទីននៅថ្ងៃបន្ទាប់ក្នុងម៉ោងមុខវិជ្ជាភូតគាមសាស្ត្រ ដល់ពេលនោះចាំវាបកស្រាយថាវាបានហៅពស់នោះឲ្យឈប់តែប៉ុណ្ណោះ មិនមែនជំរុញថែមនោះទេ។ សូម្បីតែមនុស្សល្ងង់ផុតលេខក៏គួរតែដឹងពីរឿងនេះដែរ..ហេរីគិតទាំងខឹងក្នុងចិត្ត ព្រមទាំងវាយខ្នើយរបស់វា។

*

ក៏ប៉ុន្តែ នៅព្រឹកបន្ទាប់ ព្រឹលដែលចាប់ផ្តើមធ្លាក់កាលពីយប់មិញបានប្រែក្លាយទៅជាព្យុះព្រឹលយ៉ាងក្រាស់ ដែលជាហេតុធ្វើឲ្យមានការរំសាយចោលមេរៀនភូតគាមសាស្ត្រចុងក្រោយ៖ សាស្ត្រាចារ្យ សប្រ៉ោត ចង់ដាក់ស្រោមជើង និងកន្សែងបង់កទៅលើដើមម៉ានដ្រេក។ វាជាការងារដ៏លំបាកមួយ ដូច្នេះគាត់មិនទុកចិត្តឲ្យនរណាផ្សេងធ្វើជំនួសឡើយ ព្រោះថាតឡូវគឺជាពេលដ៏សំខាន់ក្នុងការធ្វើឲ្យដើមម៉ានដ្រេកឆាប់លូតលាស់ ដើម្បីជួយសង្គ្រោះអ្នកស្រីណូរីស និងខូលីន គ្រីវី។

ហេរីពាលត្អូញត្អែរពីរឿងនេះនៅជិតភ្នក់ភ្លើងក្នុងសាលរួមនៃអគារហ្គ្រីហ្វិនដរ ពេលដែលរ៉ុន និងហឺម៉ាយអូនីយកម៉ោងទំនេរលេងអុកវេទមន្ត។

- ពុទ្ធោអើយ! ហេរី- ហឺម៉ាយអូនីស្រដីទាំងម៉ូម៉ៅ ខណៈពេលដែលគ្រាប់អុករបស់រ៉ុនបោកចំបាប់ជាមួយនឹងសេនាសេះរបស់នាងរហូតដល់ធ្លាក់ពីលើខ្នងសេះ ហើយអូសវាចេញពីក្តារចត្រង្គ។ - ទៅរកចាស់ស្ទីនតែម្តងទៅប្រសិនបើសំខាន់យ៉ាងនេះ។

ដូច្នេះហេរីក៏ក្រោកឡើង រួចចេញតាមចន្លោះប្រហោងរូបភាព ក្នុងចិត្តមន្ទិលមិនដឹងជាចាស់ស្ទីននៅឯណា។

ពេលថ្ងៃសោះប្រាសាទនេះឡើងងងឹតដូចយប់ទៅហើយ នេះក៏ដោយសារតែព្រឹលធ្លាក់ជុំជិតគ្រប់បង្អួចទាំងអស់។ ហេរីដើរកាត់ថ្នាក់មានសិស្សកំពុងរៀន ទាំងញ័រទទ្រើក ដោយលួចអើតមើលថាគេកំពុងតែធ្វើអីនៅតាមថ្នាក់នីមួយៗ។ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល កំពុងតែស្រែកស្តីឲ្យសិស្សម្នាក់។ ស្តាប់មើលទៅ ប្រហែលជាសិស្សម្នាក់នោះបានធ្វើឲ្យមិត្តរបស់គេក្លាយទៅជាស្កាហើយ។ ដោយសង្កត់ចិត្តទប់អារម្មណ៍កុំទៅលួចមើល ហេរីបន្តដំណើរតទៅទៀត ដោយគិតថាចាស់ស្ទីនប្រហែលជាយកម៉ោងទំនេររបស់វាទៅធ្វើការអ្វីផ្សេង ហើយក៏សម្រេចចិត្តទៅពិនិត្យមើលបណ្ណាល័យមុនគេ។

សិស្ស ហាហ្វ៍លផហ្វ មួយក្រុមដែលត្រូវរៀនមុខវិជ្ជាភូតគាមសាស្ត្រ ពិតជានាំគ្នាមកអង្គុយនៅខាងក្រោយបណ្ណាល័យមែន ប៉ុន្តែមើលទៅពួកគេហាក់ដូចជាមិនធ្វើកិច្ចការអ្វីទេ។ តាមចន្លោះជួរសៀវភៅវែងៗនៅលើធ្នើរខ្ពស់ៗ ហេរីអាចមើលឃើញក្បាលពួកគេកំពុងតែផ្តុំជិតគ្នា ហើយពួកគេហាក់ដូចជាកំពុងតែសន្ទនាគ្នាយ៉ាងជក់ចិត្តណាស់។ វាមើលមិនដឹងថាចាស់ស្ទីននៅក្នុងចំនោមពួកគេនោះរឺក៏អត់ទេ។ ពេលវាដើរសំដៅទៅរកពួកគេ ស្រាប់តែសម្តីដែលពួកគេនិយាយគ្នាឮមកដល់វា ហើយវាក៏ឈប់ដើម្បីស្តាប់ដោយលាក់ខ្លួននៅក្នុងផ្នែកបំបាំងកាយ។

- និយាយជារួមមក- ក្មេងប្រុសដ៏រឹងប៉ឹងម្នាក់និយាយ - ខ្ញុំបានប្រាប់ចាស់ស្ទីនឲ្យលាក់ខ្លួននៅឯសយនដ្ឋានរបស់ពួកយើង។ ខ្ញុំចង់បានន័យថា ប្រសិនបើផោតផ័រពិតជាកំណត់ថា វាជាជនរងគ្រោះបន្ទាប់មែន មួយរយៈនេះវាគួរតែកុំចេញមុខចេញមាត់ពេកទើបល្អ។ ជាការពិតណាស់ ចាស់ស្ទីនគិតទុករួចទៅហើយថា មុននិងក្រោយ រឿងនេះច្បាស់ជានឹងកើតឡើង តាំងតែពីពេលដែលវាធ្លោយមាត់ប្រាប់ហេរីថា វាកើតពីពួកលោកិយមកម្ល៉េះ។ ចាស់ស្ទីនពិតជាបានប្រាប់វាថា វាជាកូនចៅជំនាន់ក្រោយរបស់អេតុន មែន។ បើដឹងថាទាយាទស្លីតឺរីនកំពុងតែនៅទីនេះ យើងមិនគួរព្រោកប្រាជ្ញពីរឿងបែបនេះនោះទេ មិនថាអញ្ចឹង?

- ឯងពិតជាគិតថាគឺផោតផ័រមែនរឺ អើនី?- ក្មេងស្រីម្នាក់ចង់សក់ទីទុយពណ៌ទង់ដែងស្រដីទាំងខ្លាច។

- ហាណា- ក្មេងប្រុសរឹងប៉ឹងម្នាក់នោះឆ្លើយយ៉ាងម៉ឺងម៉ាត់ - គេចេះនិយាយភាសាពស់ណ៎ា។ នរណាៗក៏ដឹងដែរថា វាគឺជាសញ្ញាសំគាល់វេទគូអាក្រក់។ តើឯងមានដែលឮវេទគូល្អណាចេះនិយាយជាមួយពស់ដែរឬទេ? ពួកគេដាក់ឈ្មោះឲ្យស្លិតឺរីនថាជាតាអណ្ដាតពស់ ទៀតផង។

សំឡេងជជែកគ្នាឮកាន់តែខ្លាំងឡើងៗ ហើយអើនីក៏បន្តទៀតៈ

- មាននៅចាំអក្សរសរសេរលើជញ្ជាំងនោះទេ។ ពួកដែលជាសត្រូវរបស់ទាយាទ ចូរប្រយ័ត្នខ្លួនទៅ។ ហេរីធ្លាប់មានទំនាស់ជាមួយនឹងហ្វីលច្ច។ ក្រោយមក ឆ្មារបស់ហ្វីលច្ចក៏ត្រូវបានគេវាយប្រហារ។ ឯសិស្សឆ្នាំទីមួយឈ្មោះ គ្រីវី នោះទៀតសោត តែងទៅរំខានហេរីនៅឯការប្រកួតកីឡាឃ្វីដឌីច្ច ដោយចេះតែថតរូបវាពេលវាធ្លាក់ចូលភក់។ ក្រោយមក គ្រីវីក៏ត្រូវគេវាយប្រហារទៀត។

- តែគេដូចជារួសរាយណាស់- ហាណាស្រដីទាំងមិនប្រាកដប្រជា។ - ហើយ...អឺ...គេក៏ជាអ្នកដែលធ្វើឲ្យអ្នកដែលឯងស្គាល់ រលាយបាត់ខ្លួនដែរ។ គេមិនអាក្រក់ទាំងអស់នោះទេ មែនទេ?

អើនីបន្ទាបសំឡេងរបស់វាយ៉ាងអាថ៌កំបាំង ធ្វើឲ្យពួកហាហ្វ៊លផហ្វបង្អោនខ្លួនឲ្យកាន់តែជិតដែរ ហើយហេរីក៏ត្រូវខិតទៅជិតដែរដើម្បីអាចស្ដាប់ឮសម្ដីរបស់អើនី។

- គ្មាននរណាម្នាក់ដឹងថា តើវាអាចរស់រានមានជីវិតពីការវាយប្រហាររបស់អ្នកដែលឯងស្គាល់យ៉ាងណានោះទេ។ ខ្ញុំចង់មានន័យថា វាគ្រាន់តែជាកូនង៉ែតប៉ុណ្ណោះពេលដែលរឿងនោះកើតឡើង។ វាគួរតែត្រូវផ្ទុះបែកខ្ទេចខ្ទីសាកសពជាបំនែកៗ។ មានតែវេទគូបិសាចដ៏ខ្លាំងក្លាប៉ុណ្ណោះ ទើបអាចទប់ទល់នឹងបណ្ដាសានោះបាន។- វាបន្ទាបសំឡេងឲ្យកាន់តែតិចទៅៗ រហូតទាល់តែស្ដាប់ស្ទើរមិនចង់បាន រួចនិយាយបន្ត - នោះប្រហែលជាមូលហេតុដែល អ្នកដែលឯងស្គាល់ ចង់សំលាប់វាចោលហើយ។ គឺមិនចង់ឲ្យមានវេទគូបិសាចម្នាក់ទៀតដែលអាចប្រកួតប្រជែងនឹងគាត់បាន។ ខ្ញុំឆ្ងល់ណាស់ តើហេរីនៅលាក់ថាមពលអ្វីផ្សេងទៀតទៅ?

ហេរីទ្រាំនឹងរឿងនេះមិនបានទៀតទេ។ វាជម្រះបំពង់កយ៉ាងឮ រួចឈានជើងចេញពីក្រោយធ្នើរសៀវភៅ។ ប្រសិនបើវាមិនមានអារម្មណ៍ខឹងខ្លាំងនោះទេ វាច្បាស់ជាបានទទួលការស្វាគមន៍ដ៏រាក់ទាក់ហើយៈ ម្នាក់ៗក្នុងក្រុមហាហ្វ៊លផហ្វមានទឹកមុខហាក់ដូចជាត្រូវបង្កកដោយគ្រាន់តែឃើញហេរីអញ្ចឹង ចំនែកឯមុខរបស់អើនីចាប់ផ្ដើមស្លេកឡើងអស់ពណ៌។

- សួស្ដី- ហេរីនិយាយ។ - ខ្ញុំកំពុងរកមើល ចាស់ស្ទីន ហ្វីន-ហ្លិតឈ្លី។

សេចក្ដីភ័យខ្លាចបំផុតរបស់ក្រុម ហាហ្វ៊លផហ្វ ត្រូវបានបញ្ជាក់ហើយ។ ពួកគេទាំងអស់គ្នាសម្លឹងមើលអើនីទាំងភិតភ័យ។

- តើឯងចង់បានអ្វីពីគេ?- អើនីសួរទាំងញ័រទទ្រាក់។

- ខ្ញុំចង់ប្រាប់គេពីរឿងរ៉ាវពិតប្រាកដដែលបានកើតឡើងជាមួយនឹងពស់នោះ នៅក្នុងកម្មវិធីប្រកួតគ្នា។- ហេរីឆ្លើយ។

អើនីខាំបបូរមាត់ពណ៌សស្លាំងរបស់វា រួចដកដង្ហើមវែងៗ ហើយនិយាយៈ

- ពួកយើងសុទ្ធតែនៅទីនោះ។ ពួកយើងបានឃើញរឿងដែលកើតឡើងហើយ។

- អញ្ចឹងឯងមានបានកត់សម្គាល់ថា ក្រោយពីខ្ញុំបាននិយាយទៅកាន់វារួច ពស់នោះដកខ្លួនថយដែរឬទេ?- ហេរីស្រដី។

- អ្វីដែលខ្ញុំបានឃើញ- អើនីបន្លឺឡើងទាំងរឹងរូស ទោះជាវានិយាយទាំងញញើញញ័រក៏ដោយ - គឺឯងនិយាយភាសាពស់ ហើយបណ្ដេញពស់នោះឲ្យទៅរកចាស់ស្ទីន។

- ខ្ញុំមិនបានបណ្ដេញវាឲ្យទៅរកគេទេ!- ហេរីឧទានឡើងទាំងញ័រដោយកំហឹង។ - វាមិនទាំងបានប៉ះពាល់គេនោះទេ!

- វារិះតែនឹងត្រូវទៅហើយ- អើនីនិយាយ។ - ហើយប្រសិនបើឯងចង់មានបំណងអ្វីនោះ- វាបន្ថែមយ៉ាងហ័សរហួន - ខ្ញុំសូមប្រាប់ឯងចុះថា ទោះជាឯងតាមដានគ្រួសាររបស់ខ្ញុំដល់ទៅប្រាំបួនជំនាន់មុន នៃត្រកូលវេទមន្ត ក៏ឈាមរបស់ខ្ញុំនៅតែសុទ្ធដូចអ្នកឯងទៀតដែរ ដូច្នេះ...

- ខ្ញុំមិនខ្វល់ថាឯងមានឈាមប្រភេទណានោះទេ!- ហេរីបន្លឺឡើងយ៉ាងសាហាវ។ - ហេតុអ្វីបានជាខ្ញុំត្រូវវាយប្រហារអ្នកដែលកើតពីពួកលោកិយ?

- ខ្ញុំឮថា ឯងស្អប់ពួកលោកិយដែលឯងនៅជាមួយនោះណាស់។- អើនីវាយបកវិញយ៉ាងប្រញាប់។

- វាមិនអាចទៅរួចទេក្នុងការរស់នៅជាមួយគ្រួសារឌើស្លី ហើយមិនស្អប់ពួកគេនោះ- ហេរីស៊កសម្តី។ - បើឯងមិនជឿ សាកខ្លួនឯងទៅដឹងហើយ។

ហេរីបង្វែរកែងជើងរបស់វា ហើយដើរខ្លាំងៗចេញពីបណ្ណាល័យភ្លាម ធ្វើឲ្យអ្នកស្រីភីន ដែលកំពុងជូតសំអាតក្របសៀវភៅមន្តអាគមដ៏ធំដែលកំពុងហោះសំកាំង តាមសំឡក់មើលវាបែបចង់ស្តីបន្ទោស។

ហេរីឈ្ពុលឡើងតាមទ្វាររបៀង ដោយមិនចាប់ភ្លឹកថាកំពុងតែទៅណានោះទេ ហេតុតែវាកំពុងតែខឹងយ៉ាងខ្លាំង។ លទ្ធផលនោះគឺ វាបានដើរបុកនឹងអ្វីម្យ៉ាងដ៏ធំហើយរឹងមាំ ដែលធ្វើឲ្យខ្លួនវាត្រូវដួលមកក្រោយលើកំរាលឥដ្ឋវិញ។

- អូ! សួស្តី ហាហ្គ្រីដ- ហេរីស្រដី ព្រមទាំងងើយមើលលើ។

មុខរបស់ហាហ្គ្រីដត្រូវបិទបាំងទាំងស្រុងដោយម្មុកទឹកកកធ្វើពីរោមសត្វ ដែលប្រឡាក់សុទ្ធតែព្រឹល ប៉ុន្តែគ្មាននរណាក្រៅពីគាត់ហ្នឹងទេ ព្រោះថាខ្លួនគាត់ទាំងមូលបំពាក់ដោយអាវក្រៅធ្វើពីស្បែកសត្វកំពីងដូង ស្ទើរតែពេញផ្លូវរបៀងនោះទៅហើយ។ មាន់ឈ្មោលងាប់មួយក្បាលកំពុងតែស្រយុងចុះពីដៃពាក់ស្រោមដ៏ធំរបស់គាត់។

- មិនអីទេរី ហេរី?- គាត់សួរ ព្រមទាំងលើកម្មុកទឹកកករបស់គាត់ឡើង ទើបអាចនិយាយបាន។ - ហេតុអ្វីក៏ឯងមិននៅក្នុងថ្នាក់?

- ត្រូវរំសាយចោលហើយ- ហេរីស្រដី រួចងើបឡើង។ - តើលោកធ្វើអ្វីនៅទីនេះ?

ហាហ្គ្រីដលើកមាន់ឈ្មោលនោះបង្ហាញ។

- មួយឆមាសនេះស្លាប់អស់ពីរក្បាលហើយ- គាត់ពន្យល់។ - បើមិនកញ្ជ្រោង ច្បាស់ជាម្រេញគង្វាលជញ្ជក់ឈាមហើយ ហើយខ្ញុំត្រូវការការអនុញ្ញាតពីលោកនាយកសាលាដើម្បីដាក់អាគមជុំវិញទ្រុងមាន់។

គាត់សម្លឹងមើលហេរីឲ្យកាន់តែជិត ពីក្រោមចិញ្ចើមប្រឡាក់ព្រឹលដ៏ក្រាស់របស់គាត់។

- ឯងប្រាកដហើយរឺថាមិនអី? ឯងមើលទៅដូចជាក្តៅក្រហាយមកពីណា។

ហេរី មិនអាចជម្រុញខ្លួនឯងឲ្យរៀបរាប់ឡើងវិញនូវអ្វីដែល អើនី និងសិស្សក្រុម ហាហ្វ៊លផហ្វ ដទៃទៀតនិយាយពីវាបានទាល់តែសោះ។

- គ្មានអីទេ- វានិយាយ។ - ខ្ញុំគួរតែដល់ពេលទៅហើយ ហាហ្គ្រីដ។ ម៉ោងក្រោយរៀន និម្មិតកម្ម ដូច្នេះខ្ញុំត្រូវទៅយកសៀវភៅរបស់ខ្ញុំ។

វាក៏ដើរចេញទៅ តែក្នុងចិត្តវិលវល់ទៅដោយសម្តីដែលអើនីនិយាយចំពោះវា។

*- ចាស់ស្ទីនគិតទុករួចទៅហើយថា មុននិងក្រោយ រឿងនេះច្បាស់ជានឹងកើតឡើង តាំងតែពីពេលដែលវាធ្លោយមាត់ប្រាប់ហេរីថាវាកើតពីពួកលោកិយមកម្ល៉េះ...*

ហេរីទន្រ្ទាំជើងឡើងជណ្តើរ ហើយបត់តាមផ្លូវរបៀងមួយទៀត ដែលងងឹតស្លុង។ ភ្លើងចន្លុះត្រូវពន្លត់ដោយកម្លាំងខ្យល់បក់ត្រជាក់ដូចទឹកកក តាមកញ្ចក់បង្អួចរបើកមួយ។ វាដើរបានពាក់កណ្តាលផ្លូវហើយ ស្រាប់តែដួលជំពប់ជើងបុកក្បាលនឹងអ្វីម្យ៉ាងនៅលើកម្រាលឥដ្ឋ។

វាបែរទៅមើលថាវាដួលលើអ្វី ហើយក៏មានអារម្មណ៍ថាពោះរបស់វាត្រូវរលាយបាត់តែម្តង។

ចាស់ស្ទីន ហ្វីន-ហ្វិតឈ្លី កំពុងតែដេកនៅលើកម្រាលឥដ្ឋ ខ្លួនប្រាណរឹងស្តូក ហើយត្រជាក់ស្រេង ចំនែកឯទឹកមុខវាហាក់ដូចជាស្រឡាំងកាំង ភ្នែករបស់វាសម្លឹងមើលទៅពិតាន។ ហើយនៅមានទៀត។ នៅជិតវាមានមនុស្សម្នាក់ទៀត គឺជាទិដ្ឋភាពដ៏ចម្លែកបំផុត ដែលវាធ្លាប់បានជួបប្រទះ។

មនុស្សនោះគឺ នីកស្ទើរឥតក្បាល ដែលលែងមានពណ៌សដូចគុជខ្យង និងអាចមើលធ្លុះទៀតហើយ បែរជាមានពណ៌ខ្មៅហុយផ្សែង កំពុងតែអណ្តែតនៅស្ងៀមតាមខ្សែរដេក កំពស់ប្រមាណដប់ប្រាំសង់ទីម៉ែតពីកម្រាលឥដ្ឋ។ ក្បាលរបស់គាត់ដាច់ពាក់កណ្តាល ហើយទឹកមុខរបស់គាត់មានសភាពស្រឡាំងកាំងស្រដៀងនឹងចាស់ស្ទីនដែរ។

ហេរីក្រោកឈរឡើង ដង្ហើមរបស់វាដកមិនស្មើគ្នាម្តងវែងម្តងខ្លី ឯបេះដូងរបស់វាលោតតាមចង្វាក់ដូចគេទូងស្គរភឹបៗទង្គិចនឹងឆ្អឹងជំនីររបស់វា។ វាក្រឡេកមើលទាំងស្លន់ស្លោរពីមុខពីក្រោយផ្លូវរបៀងនោះ រួចឃើញពីងពាងមួយចង្វាយកំពុងតែរត់យ៉ាងលឿនចេញឆ្ងាយពីខ្លួនប្រាណទាំងពីរនាក់នេះ។ ឮតែសំឡេងគ្រូៗក្នុងថ្នាក់រៀននៅសង្ខាងផ្លូវរបៀងតែប៉ុណ្ណោះ។

វាអាចរត់ទៅឲ្យផុត នោះនឹងគ្មាននរណាម្នាក់ដឹងថាវានៅកន្លែងកើតហេតុទេ។ ប៉ុន្តែវាមិនអាចទុកពួកគេចោលយ៉ាងនេះនោះទេ...វាត្រូវតែទៅរកជំនួយ។ តើមានគេជឿថារឿងនេះគ្មានអ្វីពាក់ព័ន្ធនឹងវាដែរឬទេ?

ខណៈពេលដែលវាឈរស្លន់ស្លោរនៅទីនោះ ទ្វារមួយនៅជិតខ្លួនវាស្រាប់តែរបើកឡើងឮសូរផ្ទុង។ ខ្មោចរបិលរប៉ូចភីវក៏ស្ទុះហោះចេញមក។

- អីយ៉ា! គឺផោតធីផោតធ័រទេតើ!- ភីវស្រែកខ្លាំងៗ ធ្វើឲ្យវ៉ែនតារបស់ហេរីផ្អៀងទៅម្ខាង ខណៈដែលគាត់ហោះបុកកាត់ខ្លួនវា។ - ផោតធ័រមកធ្វើអីនៅទីនេះ? ម៉េចក៏លឹបលល...

ភីវ ឈប់និយាយពាក់កណ្តាលទី។ ទាំងខ្លួនក្រឡាប់ចុះក្រោម គាត់ឃើញចាស់ស្ទីន និងនីកស្ទើរឥតក្បាល។ គាត់ក្រឡាប់ខ្លួនឲ្យត្រង់វិញ រួចដកដង្ហើមវែងៗចូលក្នុងសួត ហើយស្រែកអស់មួយទំហឹង សូម្បីតែហេរីចង់ទប់ក៏ទប់មិនឈ្នះដែរៈ

- ការវាយប្រហារ! ការវាយប្រហារ! ការវាយប្រហារទៀតហើយ! ទាំងមនុស្សធម្មតា ទាំងខ្មោចសុទ្ធតែគ្មានសុវត្ថិភាពទេ! រត់ប្រាសអាយុទៅ! ការវាយប្រហារៗៗៗ!

ផាំង! ផាំង! ផាំង! ទ្វារបន្ទប់នីមួយៗតាមដងផ្លូវរបៀងនោះរបើកឡើង ហើយមនុស្សម្នាហូរហៀរចេញជាបន្តបន្ទាប់។ មួយសន្ទុះធំនោះ ស្ថានការណ៍ច្របូកច្របល់យ៉ាងខ្លាំង ធ្វើឲ្យចាស់ស្ទីនប៊ិះតែនឹងត្រូវគេជាន់កំប៉ែតជាច្រើនដង ហើយគេចេះតែច្រលំជាន់លើនីកស្ទើរឥតក្បាលរហូត។ ហេរីត្រូវគេច្រានចុះឡើងរហូតទាល់តែត្រូវផ្ទប់នឹងជញ្ជាំង ខណៈពេលដែលគ្រូៗស្រែកឲ្យមានភាពស្ងៀមស្ងាត់។ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលរត់មកកន្លែងកើតហេតុ ដោយមានសិស្សថ្នាក់គាត់ទាំងមូលមកតាមពីក្រោយដែរ ដែលម្នាក់ក្នុងចំនោមពួកគេនៅមានសក់សលាយខ្មៅនៅឡើយ។ គាត់ប្រើចង្កឹះរបស់គាត់ ធ្វើឲ្យឮសំលេងផ្ទុះដ៏ខ្លាំងមួយ ទើបមានភាពស្ងប់ស្ងាត់ឡើងវិញ រួចក៏បញ្ជាអ្នកគ្រប់គ្នាឲ្យត្រឡប់ទៅថ្នាក់រៀនរៀងៗខ្លួន។ កន្លែងកើតហេតុមិនទាន់ទាំងស្ងាត់មនុស្សបានប៉ុន្មានផង ស្រាប់តែសិស្សក្រុមហាហ្វ៍លផហ្វ អើនី មកដល់ទាំងហត់គឃុស។

- ចាប់បាននៅនឹងកន្លែងហើយ!- អើនីស្រែក មុខរបស់វាឡើងសស្លុស ឯដៃរបស់វាចង្អុលយ៉ាងជាប់ទៅហេរី។

- ប៉ុណ្ណឹងបានហើយ មេកស៍មីលេន!- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលបន្លឺឡើងទាំងដាច់អហង្ការ។

ភីវកំពុងតែហោះទៅវិញទៅមកនៅលើក្បាល ឥឡូវកំពុងតែសើចស្វេញយ៉ាងពុតត្បុត តាមដានរឿងហេតុនៅកន្លែងនោះ។ ភីវចូលចិត្តណាស់នូវភាពភាពរឹករវ។ ខណៈពេលដែលគ្រូៗអានពិនិត្យមើលចាស់ស្ទីន និងនីកស្ទើរឥតក្បាល ភីវក៏ច្រៀងលេងៈ

*- ឱ! ផោតធ័រអើយ! ឯងពិតជាខូចមែន! ឱ! ឥឡូវឯងបង្ករឿងអ្វីទៀតហើយ?*

*ឯងសំលាប់កូនសិស្ស ឯងគិតថាវាសប្បាយ...*

- បានហើយ ភីវ!- សាស្ត្រចារ្យម៉ាកហ្គូណាហ្គាលស្តីឲ្យ ហើយភីវក៏ហោះចេញទៅបាត់ ព្រមទាំងផ្លៀតលានអណ្តាតដាក់ហេរីទៀត។

ចាស់ស្ទីនត្រូវបានសែងទៅគិលានដ្ឋានដោយសាស្ត្រាចារ្យ ហ្លីតវីក និងសាស្ត្រាចារ្យ ស៊ីនីស្ត្រា ដែលបង្រៀននៅថ្នាក់តារាវិទ្យា ប៉ុន្តែគ្មាននរណាម្នាក់ដឹងថាត្រូវធ្វើយ៉ាងម៉េចចំពោះនីកស្ទើរឥតក្បាលឡើយ។ ចុងបញ្ចប់ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលសូត្រអាគម បង្កើតកង្ហារដ៏ធំមួយចេញពីខ្យល់ រួចណែនាំអើនីឲ្យបក់នីកស្ទើរឥតក្បាលឡើងកាំជណ្តើរទៅជាន់លើ។ អើនីក៏ធ្វើតាមដោយប្រើកង្ហារផ្លុំនីកទៅតាមខ្យល់ដូចជាអាកាសយានពណ៌ខ្មៅដ៏ស្ងៀមស្ងាត់។

- មកតាមនេះ ផោតធ័រ- គាត់និយាយ។

- សាស្ត្រាចារ្យ- ហេរីប្រកែកភ្លាមមួយរំពេច - ខ្ញុំសូមស្បថថាខ្ញុំមិន...

- រឿងនេះខ្ញុំចាត់ការលែងបានទៀតហើយ ផោតធ័រ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយកាត់។

- បង្អែមក្រូចឆ្មារ!- គាត់បន្លឺឡើង។ នេះច្បាស់ជាពាក្យសម្ងាត់ហើយ ព្រោះថារូបចម្លាក់ស្រាប់តែមានជីវិត ហើយលោតទៅម្ខាងខណៈពេលដែលជញ្ជាំងខាងក្រោយប្រេះបែកជាពីរ។ ទោះបីជាអារម្មណ៍មិនល្អចំពោះរឿងដែលបានកើតឡើងក្តី ក៏ហេរីនៅតែបង្ហាញនូវការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ នៅពីក្រោយជញ្ជាំងនោះ មានជណ្តើរវិលមួយដែលកំពុងតែរំកិលឡើងទៅលើយ៉ាងរលូន ដូចជាជណ្តើរយន្តអញ្ចឹង។ ខណៈដែលវា និងសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលឈានជើងលើជណ្តើរនោះ ហេរីឮសូរសំឡេងជញ្ជាំងបិទទៅវិញនៅពីក្រោយពួកគេ។ ពួកគេឡើងទៅលើជារង្វង់ កាន់តែខ្ពស់ទៅៗ ឡើងចង់វិលមុខបន្តិចដែរ រហូតដល់ហេរីឃើញទ្វារធ្វើពីដើមសែនភ្លឺរលោងនៅខាងមុខ ប្រដាប់ដោយដែកគោះជារូបសត្វតោស្លាបឥន្ទ្រី។

វាដឹងថាគេនាំវាមកកន្លែងណាហើយ។ នេះច្បាស់ជាកន្លែងដែលលោក ដាំប៊័លដ័រ រស់នៅជាក់ជាមិនខាន។

# វគ្គ XII



## ទឹកថ្នាំបំលែងកាយ

ពួកគេចុះពីជណ្តើរថ្ម ហើយសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលដើរទៅគោះទ្វារ។ ទ្វារនោះរបើកឡើងតិចៗ ហើយពួកគេក៏ចូលទៅក្នុង។ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលប្រាប់ហេរីឲ្យចាំបន្តិច រួចក៏ទុកវាចោលនៅទីនោះតែម្នាក់ឯង។

ហេរីក្រឡេកមើលជុំវិញ។ ក្នុងចិត្តវាមានតែរឿងមួយគត់ដែលច្បាស់លាស់៖ ក្នុងចំណោមការិយាល័យគ្រូបង្រៀនទាំងអស់ដែលវាធ្លាប់បានចូលទៅលេងនៅក្នុងឆ្នាំនេះ មានតែការិយាល័យរបស់លោកដាំប៊័លដ័រប៉ុណ្ណោះដែលគួរឲ្យចាប់អារម្មណ៍ជាងគេ។ ប្រសិនបើវាមិនភ័យថា ខ្លួនជិតនឹងត្រូវគេទាត់ចេញពីសាលាទេ វាច្បាស់ជាឆ្លៀតឱកាសដើរមើលជុំវិញជាមិនខានឡើយ។

បន្ទប់នោះមានរាងមូល ធំ និងស្រស់ស្អាត ពោរពេញទៅដោយសំឡេងឆ្មារៗគួរឲ្យចង់សើចជាច្រើន។ នៅលើតុជើងកោងមួយ មានដាក់បញ្ឈរឧបករណ៍ភ្លេងពណ៌ប្រាក់គួរឲ្យចាប់អារម្មណ៍មួយចំនួន ដែលកំពុងបន្លឺសូរង្ហូងៗ ព្រមទាំងបាញ់ចេញកំសួលផ្សែងទៀតផង។ នៅតាមជញ្ជាំងពោរពេញទៅដោយរូបថតរបស់នាយក និងនាយិកាសាលាជំនាន់មុនៗ។ ពួកគេទាំងអស់គ្នាកំពុងតែស្រមុកខុរៗ នៅក្នុងស៊ុមរូបថតនីមួយៗរៀងៗខ្លួន។ នៅមានតុជើងដូចក្រញាំសត្វដ៏ធំមួយ ដែលនៅផ្ទើរខាងក្រោយតុនោះ មានដាក់មួកវេទមន្តដាច់ថ្មេរ ដ៏កន្រ្ទុករួកមួយ...គឺមួកសិល្ប៍។

ហេរីមានអារម្មណ៍ស្ទាក់ស្ទើរនៅឡើយ។ វាចោលភ្នែកសំឡឹងមើលវេទគូ ដែលកំពុងតែដេកលក់នៅលើជញ្ជាំងជុំវិញ។ គ្រាន់តែយកមួកនោះមកសាកពាក់លេងម្តងទៀត ច្បាស់ជាគ្មានបញ្ហាអ្វីធ្ងន់ធ្ងរទេ មិនថាអញ្ចឹង? គ្រាន់តែចង់ដឹង...គ្រាន់តែចង់ធ្វើឲ្យប្រាកដក្នុងចិត្តថា មួកនោះបានដាក់វានៅក្នុងក្រុមគ្រីមគ្រូវីក៏អត់តែប៉ុណ្ណោះ។

វាដើរស្ងាត់ៗក្រវែលតុ រួចលើកមួកនោះចុះពីលើផ្ទើរ បន្ទាប់មកបន្ទាបមួកនោះយឺតៗដាក់ពីលើក្បាលរបស់វា។ មួកនោះធំពេកហើយ រហូតដល់របូតធ្លាក់បាំងភ្នែករបស់វាឡើងជិតឈឹង ដូចដែលកាលពីវាធ្លាប់បានពាក់មួកនោះពីលើកមុនអញ្ចឹង។ ហេរីសំឡឹងស្មៀមរង់ចាំនៅក្នុងស្បែអន្ធការនៃមួកសិល្ប៍។ បន្ទាប់មក សំឡេងតូចមួយបន្លឺឡើងនៅក្នុងត្រចៀករបស់វា៖

- ឯងគឺហេរី ផោតធ័រី?

- អឺ...មែនហើយ- ហេរីនិយាយតិចៗ។ - អឺ...សុំទោសដែលមករំខាន...ខ្ញុំគ្រាន់តែចង់សួរថា...

- ឯងកំពុងតែឆ្ងល់ថាតើ ខ្ញុំបានដាក់ឯងនៅក្នុងក្រុមត្រឹមត្រូវរឺក៏អត់ មែនទេ?- មួកនោះស្រដីយ៉ាងឈ្លាសវៃ។ - មែនហើយ...ឯងពិតជាពិបាកនឹងជ្រើសរើសក្រុមឲ្យមែន។ ប៉ុន្តែខ្ញុំនៅតែប្រកាន់ខ្ជាប់នូវអ្វីដែលខ្ញុំបាននិយាយកាលពីលើកមុនដដែល...-បេះដូងរបស់ហេរីស្ទើរតែលោតចេញមកក្រៅ - ឯងនឹងទទួលបានលទ្ធផលល្អប្រសិនបើនៅក្នុងក្រុមស្លីតឺរីន។

ពោះរបស់ហេរីហាក់ដូចជាជ្រុះបាត់។ វាចាប់ចុងមួក ហើយទាញមួកនោះចេញ។ មួកនោះយោលតែលតោកក្នុងដៃរបស់វាក្នុងសភាពកខ្វក់ ថែមទាំងគ្មានជីវិត។ ហេរីរុញមួកនោះទៅលើធ្នើរវិញ ដោយមានអារម្មណ៍កាន់តែអាក្រក់ជាងមុនទៅទៀត។

- ឯងនិយាយខុសហើយ- វានិយាយខ្លាំងៗទៅកាន់មួកស្ងៀមស្ងាត់នោះ។ វាមិនកម្រើកអ្វីឡើយ។ ហេរីដើរថយក្រោយមកវិញ ភ្នែកសំឡឹងមើលមួកនោះនៅឡើយ។ បន្ទាប់មក សំឡេងឈ្លក់ដ៏ចំឡែកមួយនៅពីក្រោយវាធ្វើឲ្យវាបែរខ្នងមកក្រោយ។

តាមពិត វាមិននៅតែឯងទេ។ មានបក្សីរាងចំនាស់មួយក្បាល កំពុងតែទំលើបង្គងពណ៌មាសនៅខាងក្រោយទ្វារ មើលទៅស្រដៀងនឹងមាន់តួគីដែលត្រូវគេបោចរោមអស់ពាក់កណ្តាល។ ហេរីសម្លឹងមើលវា ហើយបក្សីនោះក៏ចោលក្រសែភ្នែកយ៉ាងវេទនាមកវិញ ដោយបន្លឺសំឡេងឈ្លក់ម្តងទៀត។ ហេរីគិតថាបក្សីនោះដូចជាឈឺខ្លាំងណាស់។ ភ្នែកវាទាំងពីរឡើងស្រអាប់ ហើយសូម្បីតែពេលដែលហេរីកំពុងតែមើល នៅមានរោមពីរបីបន្តជ្រុះពីកន្ទុយវាឥតដាច់។

ហេរីកំពុងតែគិតថា ប្រសិនបើបក្សីចិញ្ចឹមនោះមកស្លាប់ចំពេល ដែលវាកំពុងតែនៅក្នុងការិយាល័យលោក ដាំប័លដ័រច្បាស់ជាវីវរហើយ ស្រាប់តែភ្លើងឆេះខ្លួនបក្សីនោះតែមួយប៉ប្រិចភ្នែក។

ហេរីស្រែកដោយរន្ធត់ ហើយដើរថយក្រោយមករកតុ។ វាសម្លឹងមើលទាំងអន្ទះសាក្រែងលោឃើញមានកែវទឹកនៅកន្លែងណា ប៉ុន្តែរកមិនឃើញសោះ។ ក្នុងពេលជាមួយគ្នានោះដែរ បក្សីនោះបានប្រែក្លាយទៅជាដុំភ្លើង។ វាបន្លឺសម្រែកយ៉ាងខ្លាំងមួយ ហើយតែមួយវិនាទីក្រោយមកក៏រលាយសូន្យសុងគ្មានអ្វីនៅសល់ក្រៅពីផេះមួយកញ្ចុំនៅលើកម្រាលឥដ្ឋតែប៉ុណ្ណោះ។

ទ្វារការិយាល័យបានបើកឡើង។ លោកដាំប័លដ័រចូលមកក្នុង ទឹកមុខរបស់គាត់ដូចជាស្រងូតស្រងាត់ណាស់។

- លោកសាស្ត្រាចារ្យ- ហេរីស្រដីទាំងដង្ហក់ - បក្សីរបស់លោក ... ខ្ញុំអត់បានធ្វើអីទេ ... វាស្រាប់តែភ្លើងឆេះ...

ហេរីស្រាប់តែភ្ញាក់ផ្អើល ដោយឃើញលោកដាំប័លដ័រញញឹម។

- ល្មមតែដល់ពេលហើយដែរ- គាត់និយាយ។ - វាមានទឹកមុខមិនស្រស់បស់ជាច្រើនថ្ងៃមកហើយ។ ខ្ញុំក៏បានរំលឹកវាច្រើនដងដែរថា កុំនៅរង់ចាំធ្វើអ្វីទៀត គួរតែត្រូវទៅហើយ។

គាត់សើចកក្អឹកដោយឃើញទឹកមុខស្រឡាំងកាំងរបស់ហេរី។

- ហ្វំរំយែស គឺជាហង្សភ្លើងណ៎ា ហេរី។ ហង្សភ្លើងរមែងឆេះក្លាយជាដុំភ្លើង នៅពេលដែលវាត្រូវស្លាប់ រួចក៏កើតឡើងវិញពីផេះ។ ចាំមើលណ៎ា...

ហេរី អោនមើលទៅឃើញបក្សីទើបនឹងកើតតូចក្រញង់មួយក្បាលលេចក្បាលចេញពីផេះ។ វាក៏មានរូបរាងអាក្រក់ដូចបក្សីអំបាញ់មិញនេះដែរ។

- ពិតជាស៊យណាស់ដែលឯងមកជួបវាចំថ្ងៃអគ្គី- ដាំប័លដ័រពោល ដោយដាក់ខ្លួនអង្គុយពីក្រោយតុ។ - ពេលភាគច្រើន វាពិតជាស្រស់សង្ហាណាស់៖ ស្លាបពណ៌មាសលាយក្រហមដ៏អស្ចារ្យ។ ហង្សភ្លើងពិតជាពពួកបក្សីគួរឲ្យចាប់អារម្មណ៍មែនទែន។ ពួកវាអាចយួររបស់ធ្ងន់ៗប៉ុណ្ណាក៏រួចដែរ ចំនែកទឹកភ្នែករបស់ពួកវាមានថាមពលព្យាបាល មិនតែប៉ុណ្ណោះពួកវាជាសត្វចិញ្ចឹមស្មោះស្ម័គ្រនឹងម្ចាស់វាណាស់។

ដោយសារតែរឿង ហ្វ៉រយែស ត្រូវភ្លើងឆេះ ធ្វើឲ្យហេរីសឹងតែភ្លេចថាវាមកទីនេះដើម្បីអ្វីទៅហើយ ប៉ុន្តែវានឹកឃើញឡើងវិញទាំងអស់ពេលដែល ដាំប័លដ័រ អង្គុយនៅលើកៅអីខ្នងខ្ពស់មួយ រួចសំឡឹងមើលហេរីតាមរយៈកែវភ្នែកពណ៌ខៀវស្រស់របស់គាត់ឡើងមុត។

ដាំប័លដ័រមិនទាន់នឹងបានហាស្តីមួយម៉ាត់ផង ស្រាប់តែទ្វារការិយាល័យប៉ើងរបើកឡើងឮសូរខ្លាំង ហើយហាគ្រ្គីដសម្រុកចូលមក ភ្នែកគាត់ឡើងព្រៃផ្សៃ រីឯមួកទឹកកករបស់គាត់នៅទីមទាមលើក្បាលពណ៌ខ្មៅដ៏ស្រមេមស្រមាមរបស់គាត់ ព្រមទាំងមានមាន់ងាប់យោលទៅយោលមកនៅនឹងដៃគាត់នៅឡើយ។

- មិនមែនជាហេរីទេ សាស្ត្រាចារ្យដាំប័លដ័រ!- ហាគ្រ្គីដឧទានឡើងជាបន្ទាន់។ - ខ្ញុំទើបនឹងនិយាយជាមួយវាប៉ុន្មាននិនាទីមុនពេលដែលក្មេងនោះត្រូវបានគេរកឃើញ វាច្បាស់ជាគ្មានពេលធ្វើទាន់ទេ លោក...

ដាំប័លដ័រហៀបនឹងនិយាយហើយ ប៉ុន្តែហាគ្រ្គីដនៅតែបន្តនិយាយប៉ប៉ាច់ប៉ប៉ោចមិនឈប់ ព្រមទាំងគ្រវីគ្រវាត់មាន់ងាប់នោះទៅវិញទៅមក បណ្តាលឲ្យជ្រុះស្លាបគ្រប់ទីកន្លែង។

- ...មិនអាចជាវាទេ ទោះជាឲ្យខ្ញុំស្បថចំពោះមុខក្រសួងវេទមន្តក៏ខ្ញុំហ៊ានដែរ...

- ហាគ្រ្គីដ ខ្ញុំ...

- ...លោកចាប់មនុស្សខុសហើយ។ ខ្ញុំដឹងថាហេរីមិនដែល...

- *ហាគ្រ្គីដ!*- ដាំប័លដ័រស្រែកខ្លាំងៗ។ - ខ្ញុំក៏មិនគិតថា ហេរីបានវាយប្រហារមនុស្សទាំងនោះដែរ។

- អូ!- ហាគ្រ្គីដស្រដី មាន់នោះធ្លាក់ខ្ទោកមកខាងខ្លួនគាត់វិញ។ - អញ្ចឹងទេអ្ហ។ ខ្ញុំចាំនៅក្រៅចុះ លោកនាយក។

រួចគាត់ក៏ដើរតន្ត្រំជើងចេញទៅក្រៅវិញទាំងអៀនខ្មាស។

- លោកមិនគិតថាជាខ្ញុំមែនរឺ លោកសាស្ត្រាចារ្យ?- ហេរីសួរបញ្ជាក់ទាំងមានសង្ឃឹម ខណៈពេលដែលដាំប័លដ័របបោសរោមមាន់ចេញពីតុរបស់គាត់។

- ទេ ហេរី ខ្ញុំមិនគិតថាជាឯងទេ- ដាំប័លដ័រឆ្លើយ តែមុខរបស់គាត់ប្រែជាស្រងូតស្រងាត់ម្តងទៀត។ - ប៉ុន្តែខ្ញុំនៅតែត្រូវការនិយាយជាមួយឯងដដែល។

ហេរីរង់ចាំយ៉ាងអន្ទះសា ខណៈពេលដែលដាំប័លដ័រកំពុងតែពិចារណាពីវា ម្រាមដៃវែងៗរបស់គាត់ដាក់ផ្គុំចូលគ្នា។

- ហេរី ខ្ញុំត្រូវសួរឯងថា តើឯងមានអ្វីចង់ប្រាប់ខ្ញុំទេ?- គាត់និយាយថ្នមៗ។ - អ្វីក៏បានដែរ។

ហេរីមិនដឹងជាត្រូវនិយាយយ៉ាងម៉េចនោះទេ។ វាគិតដល់មេលហ្វ៉យស្រែកថា "ឯងនឹងជាអ្នកបន្ទាប់ហើយ អាពួកឈាមកខ្វក់!" ហើយនិងទឹកថ្នាំបំលែងកាយ ដែលកំពុងតែចំអិនដោយលួចលាក់នៅក្នុងបន្ទប់ទឹករបស់ម៉ុននីង មីតថល។ បន្ទាប់មក វាគិតដល់សំឡេងចំឡែកដែលវាបានឮពីរដង ហើយចាំនូវអ្វីដែលរ៉ុននិយាយថា៖ "*ការឮសំឡេងដែលគ្មាននរណាទៀតឮបានមិនមែនជាប្រផ្នូលល្អទេ សូម្បីតែនៅក្នុងពិភពវេទមន្តក៏ដោយ។*" វាក៏បានគិតផងដែរចំពោះអ្វីដែលអ្នកគ្រប់គ្នាកំពុងតែនិយាយអំពីវា និងសេចក្តីភ័យខ្លាចដែលកាន់តែរាលដាលខ្លាំងឡើងៗថា វាអាចមានជាប់ទំនាក់ទំនងជាមួយសាឡាហ្សា ស្លីតឺរីន...

- ទេ- ហេរីតប - គ្មានអ្វីទេ លោកសាស្ត្រាចារ្យ។

*

ការវាយប្រហារស្ទួនៗគ្នាទៅលើចាស់ស្ទីន និងនីកស្ទើរតតក្បាលបានប្រែក្លាយភាពភ័យខ្លាចក្នុងពេលបច្ចុប្បន្នឲ្យទៅជាភាពស្លន់ស្លោរ។ អ្វីដែលពួកគេចង់ដឹងបំផុតនោះគឺថា តើវាសនារបស់នីកស្ទើរតតក្បាលនឹងក្លាយទៅជាយ៉ាងណា។ មនុស្សម្នាសួរគ្នាទៅវិញ

ទៅមកថា តើអ្វីទៅដែលអាចមានលទ្ធភាពនឹងធ្វើរឿងដូច្នោះដាក់ខ្មោចបាន។ តើថាមពលបិសាចអ្វីទៅដែលអាចព្យាបាទរហូតដល់មនុស្សដែលស្លាប់ទៅហើយទៀត? ពួកកូនសិស្សដណ្ដើមគ្នាកក់សំបុត្ររថភ្លើងសាលាហុកវ៉ាត ដើម្បីបានទៅផ្ទះនៅថ្ងៃបុណ្យណូអែល។

- ដល់ដំណាក់កាលនេះហើយ ប្រហែលជាសល់តែពួកយើងទេ- រ៉ុនប្រាប់ ហេរី និងហឺម៉ាយអូនី។ - គឺពួកយើង មេលហ្វ័យ ក្រេប និងហ្គយល៍។ ថ្ងៃឈប់សម្រាកនេះមិនដឹងជាសប្បាយយ៉ាងណាទេ។

ក្រេប និងហ្គយល៍ ដែលតែងតែដើរតាមមេលហ្វ័យ ក៏បានចុះឈ្មោះស្នាក់នៅសាលានាថ្ងៃឈប់សម្រាកដែរ។ ប៉ុន្តែហេរីបែរជាត្រេកអរទៅវិញ ដែលមនុស្សជាច្រើនចាកចេញ។ វានឿយហត់នឹងឃើញមនុស្សដើរគេចវា ខ្លាចក្រែងតែវាប្រុងនឹងបញ្ចេញចង្កូមព្រោះពិសអញ្ចឹង។ នឿយហត់នឹងសំឡេងខ្សឹបខ្សៀវ និងការចង្អុលមករកខ្លួន រាល់ពេលដែលវាទៅកន្លែងណាក៏ដោយ។

ទោះបីជាយ៉ាងនេះក៏ដោយ ហ្វ្រេដ និងចចបែរជាយល់ថារឿងនេះគួរឲ្យអស់សំណើចទៅវិញ។ ពួកគេទាំងពីរនាក់បបួលគ្នាដើរហែហមមុខហេរីតាមផ្លូវរបៀង ដោយស្រែកខ្លាំងៗថាៈ

- ជៀសចេញ ទាយាទស្លីតឺរីនមកដល់ហើយ មែនណា! វេទគូកំណាចកំពុងយាងដល់ហើយ...

ពើរស៊ីមិនឯកភាពចំពោះអាកប្បកិរិយាបែបនេះឡើយ។

- នេះ*មិន*មែនជារឿងគួរឲ្យលេងសើចទេ- វាស្រដីទាំងសោះកក្រោះ។

- អូ! កុំនៅទើសផ្លូវ ពើរស៊ី- ហ្វ្រេដស័កសម្ដី។ - ហេរីកំពុងតែប្រញាប់។

- មែនហើយ វាកំពុងតែឆ្លៀតពេលទៅបន្ទប់សម្ងាត់ផឹកតែជាមួយអ្នកបម្រើដុះចង្កូមរបស់វា- ចចថែមសម្ដី ព្រមទាំងសើចកក្អឹក។

ជីននីក៏មិនយល់ថា នេះគឺជារឿងលេងសើចដែរ។

- អូ! *ឈប់ទៅ*- នាងទ្រហោយំរាល់ពេលដែលហ្វ្រេដសួរហេរីថា តើនឹងចាត់ការនរណាទៀត រឺក៏ពេលដែលចចធ្វើពុតជាបណ្ដេញហេរីចេញដោយប្រើកម្រងខ្ទឹមសមួយបាច់ធំពេលដែលពួកគេជួបគ្នា។

ហេរីមិនប្រកាន់នឹងរឿងនេះទេ។ ផ្ទុយទៅវិញ វាបែរជាធ្វើឲ្យហេរីមានអារម្មណ៍ល្អឡើងវិញ ដោយដឹងថាយ៉ាងហោចណាស់ក៏មានហ្វ្រេដ និងចច គិតថាទស្សនៈដែលថា វាជាទាយាទស្លីតឺរីនគឺជារឿងគួរឲ្យអស់សំណើចណាស់។ ប៉ុន្តែអំពើក្រមិចក្រមើមរបស់ពួកគេបែរជាជាធ្វើឲ្យ ដ្រាកូ មេលហ្វ័យ កាន់តែក្ដៅក្រហាយ។ ល្គឹកណាដែលវាឃើញពួកគេកំពុងតែលេងសើចដូច្នេះ វាតែងតែធ្វើមុខជូរហួញ។

- គឺព្រោះតែវាចង់ប្រាប់គេឯងថា គឺវាឯនេះទេដែលជាទាយាទស្លីតឺរីនពិតៗ- រ៉ុននិយាយធ្វើដូចជាអ្នកចេះដឹង។ - ឯងដឹងស្រាប់ហើយថា វាស្អប់អ្នកដែលយកឈ្នះវាណាស់ ហើយឯងបែរជាអ្នកទទួលផលពីអំពើកខ្វក់របស់វាទៅវិញ។

- មិនយូរទេ- ហឺម៉ាយអូនីស្រដីទាំងពេញចិត្តពេញថ្លើម។ ទឹកថ្នាំបំលែងកាយជិតរួចរាល់ហើយ។ មិនដល់ប៉ុន្មានថ្ងៃទៀតទេ ពួកយើងនឹងឲ្យវានិយាយការពិតចេញមកជាមិនខាន។

*

នៅទីបំផុត ឆមាសក៏ត្រូវបានបញ្ចប់ ហើយភាពស្ងប់ស្ងាត់ក៏បានជ្រាបចូលមកដល់ ខណៈពេលដែលព្រឹលកំពុងធ្លាក់មកលើតួប្រាសាទ។ ហេរីមានអារម្មណ៍សុខស្រួលជាជាងសោកសៅ ព្រមទាំងរីករាយផង ដោយសារមានតែវា ហឺម៉ាយអូនី និងបងប្អូនត្រកូលវីស្លីប៉ុណ្ណោះ ដែលនៅគ្រប់គ្រងអគារក្រុមហ្គ្រីហ្វីនដ័រ។ នេះមានន័យថា ពួកគេអាចលែងល្បែង ផ្ទាត់បំផ្ទុះ បានយ៉ាងឡូឡា

ដោយមិនចាំបាច់ត្រូវរំខាននរណាឡើយ ម្យ៉ាងទៀតពួកគេអាចហ្វឹកហាត់ការប្រកួតវេទមន្តគ្នាដោយផ្ទាល់ទៀតផង។ ហ្វ្រេដ ចច និង ជីននីបានជ្រើសរើសនៅសាលាជាជាងទៅសួរសុខទុក្ខប៊ីលនៅអេស៊ីប ជាមួយលោក និងអ្នកស្រីវីស្លី។ ពឿរស៊ី ដែលមិនយល់ស្រប តាមអ្វីដែលវាហៅថាអាកប្បកិរិយាកូនក្មេងរបស់ពួកគេ មិនដែលចំនាយពេលទំនេរច្រើននៅក្នុងសាលរួមហ្គ្រីហ្វីនដ័រទេ។ វាបាន ប្រាប់ពួកគេយ៉ាងក្អេងក្អាងរួចមកហើយថា វាស្នាក់នៅសាលានាថ្ងៃបុណ្យណូអែល ក៏ព្រោះតែនេះជាកាតព្វកិច្ចរបស់វា ក្នុងឋានៈជា ប្រធានសិស្ស ដើម្បីជួយជ្រោមជ្រែងលោកគ្រូអ្នកគ្រូក្នុងគ្រាលំបាកតែប៉ុណ្ណោះ។

ព្រឹកថ្ងៃបុណ្យណូអែលរះឡើង នាំមកនូវភាពរងាត្រជាក់ និងពណ៌សស្វាច។ ហេរី និងរ៉ុន ដែលនៅតែពីរនាក់គត់ក្នុង សយនដ្ឋានរបស់ពួកគេ ត្រូវបានដាស់ឲ្យភ្ញាក់ឡើងទាំងព្រឹកព្រលឹមដោយហឺម៉ាយអូនី ដែលសម្រុកចូលមក ខ្លួនប្រាណស្លៀកពាក់ រួចរាល់ ព្រមទាំងកាន់អំណោយសម្រាប់ពួកគេមកជាមួយ។

- ភ្ញាក់ឡើង- នាងនិយាយខ្លាំងៗ ហើយទៅទាញវាំងននចេញពីបង្អួច។

- ហឺម៉ាយអូនី...នាងមិនគួរនៅទីនេះទេ- រ៉ុនស្រដី ដោយយកដៃបាំងភ្នែករបស់វានឹងពន្លឺថ្ងៃ។

- រីករាយថ្ងៃបុណ្យណូអែល- ហឺម៉ាយអូនីនិយាយ ព្រមទាំងបោះអំណោយទៅឲ្យវា។ - ខ្ញុំក្រោកឡើងជិតមួយម៉ោងទៅ ហើយ ឆ្លៀតពេលទៅបន្ថែមស្លាបជរក្នុងទឹកថ្នាំទៀត។ ឥឡូវរួចរាល់ហើយ។

ហេរីក្រោកឡើងភ្លែត ស្វាងទាំងស្រុងតែម្តង។

- ឯងប្រាកដទេ?

- ច្បាស់ណាស់- ហឺម៉ាយអូនីឆ្លើយ ដោយលើកកណ្តុរ ស្កេបប៊ឺរ ចេញ ដើម្បីឲ្យនាងអង្គុយចុះលើគែមគ្រែបង្គោលបួនរបស់ វា។ - ប្រសិនបើពួកយើងសម្រេចថានឹងធ្វើវា គួរតែចាប់ផ្តើមយប់នេះ។

នៅពេលនោះ ហ៊ីដវីកស្រាប់តែហោះចូលមកក្នុងបន្ទប់ ក្នុងចំពុះវាមានពាំកូនកញ្ចប់តូចមួយ។

- សួស្តី- ហេរីស្រដីយ៉ាងរីករាយ ខណៈពេលដែលវាចុះមកទំលើគ្រែរបស់វា - តើឯងមកនិយាយជាមួយខ្ញុំទៀតហើយមែន ទេ?

ហ៊ីដវីកចឹកត្រចៀករបស់វាយ៉ាងថ្នមៗគួរឲ្យស្រឡាញ់ ដែលជាអំណោយដ៏ល្អប្រសើរជាជាងអំណោយដែលវាយកមកឲ្យ ហេរីទៅទៀត។ អំណោយនោះផ្ញើមកពីគ្រួសារឌឺស្លី។ ពួកគេបានផ្ញើឈើចាក់ធ្មេញមួយឲ្យហេរី ភ្ជាប់ជាមួយសំបុត្រមួយច្បាប់សាក សួរថា តើវាអាចស្នាក់នៅសាលាហុកវ៉ាតនាពេលវិស្សមកាលរដូវក្តៅផងបានដែរឺទេ។

អំណោយថ្ងៃបុណ្យណូអែលផ្សេងៗទៀតរបស់ហេរីល្អប្រសើរជាងនេះឆ្ងាយណាស់។ ហាគ្រ្គីដបានផ្ញើឲ្យហេរីនូវ គ្រាប់ សណ្តែកមនោសញ្ចេតនាមួយកំប៉ុងធំ ដែលហេរីសម្រេចចិត្តថា នឹងយកទៅកំដៅភ្លើងមុននឹងញ៉ាំបាន។ រ៉ុនបានឲ្យសៀវភៅមួយ ក្បាលមានចំណងជើងថា *ហោះហើរជាមួយនឹងក្រុមកាណុង* ទៅវា ចំនែកឯហឺម៉ាយអូនីបានទិញស្លាបប៉ាកកាពាមឥន្ទ្រីដ៏ប្រណិត មួយឲ្យវា។ ហេរីបើកអំណោយចុងក្រោយឃើញអាវរងាទើបនឹងចាក់ដោយផ្ទាល់ដៃថ្មីមួយផ្ញើមកពីអ្នកស្រីវីស្លី ហើយនិងនំផ្លែព្រូន។ វាអានកាតជូនពររបស់គាត់ ដោយនឹកខ្មាសខ្លួនឯងចំពោះកំហុសខ្លួន ពេលគិតដល់ឡានរបស់លោកវីស្លី ដែលបាត់មុខរហូតតាំងពី បុកនឹងដើមវ៉ុមភីងវីឡូរួចមក ហើយឥឡូវកំពុងរៀបចំគម្រោងធ្វើបំពានច្បាប់សាលាទៀត។

*

គ្មាននរណាអាចទប់ចិត្តមិនត្រេកត្រអាលនឹងពិធីជប់លៀងពេលល្ងាចនាថ្ងៃបុណ្យណូអែលនៅសាលាហុកវ៉ាតបានឡើយ ទោះជា ដឹងថាខ្លួនជិតនឹងត្រូវបង្ខំចិត្តផឹកទឹកថ្នាំបំលែងកាយក៏ដោយ។

សាលធំមើលទៅពិតជាអស្ចារ្យណាស់។ មិនត្រឹមតែមានដើមណូអែលគ្របដណ្តប់ដោកជាំដោយទឹកកកជាងដប់ពីរដើម ព្រមទាំងខ្សែលំអនៃផ្លែហូលីក្រាស់ៗ គួបផ្សំនឹងដើមបញ្ញើក្អែកខ្វាត់ខ្វែងពេញពិតានប៉ុណ្ណោះទេ ថែមទាំងមានព្រឹលផទមន្តធ្លាក់ចុះពីលើពិតាន ផ្តល់នូវភាពកក់ក្តៅ និងស្ងួតទៀតផង។ ដាំប័លដ័រឲ្យពួកគេស្តាប់ចម្រៀងបុណ្យណូអែលជាទីពេញចិត្តរបស់គាត់ប៉ុន្មានបទ ឯហាគ្រ្គីដច្រៀងតាមកាន់តែខ្លាំងឡើងៗរាល់ពេលដែលគាត់ផឹកស្រាលាយពងមាន់មួយកែវហើយ ថែមមួយកែវទៀត។ ពើរស៊ីដែលមិនបានដឹងថាហ្វ្រេដបានជប់ផ្លាកប្រធានសិស្សរបស់វា កែឈ្មោះទៅជា "មនុស្សឆ្កួត" ចេះតែតាមសួរពួកគេថាតើកំពុងតែសើចអ្វី។ ហេរីមិនទាំងខ្វល់ពី ដ្រាកូ មេលហ្វ៊យ ដែលកំពុងតែនិយាយបន្តុះបង្អាប់ឮៗពីអាវរងាថ្មីរបស់វានៅឯតុក្រុម ស្លីធើរីន នោះផង។ ឲ្យតែឱកាសហុចដល់ មេលហ្វ៊យច្បាស់ជាទទួលកម្មពៀរសមនឹងអំពើរបស់វា នៅក្នុងពេលតែពីរបីម៉ោងទៀតតែប៉ុណ្ណោះ។

ហេរី និងរ៉ុនញ៉ាំបង្អើយបង្អែមណូអែលចានទីបីមិនទាន់ទាំងរួចរាល់ផង ត្រូវហឺម៉ាយអូនីអូសចេញទៅក្រៅសាល ដើម្បីពិគ្រោះបញ្ចប់ផែនការរបស់ពួកគេនាល្ងាចនេះ។

- ពួកយើងនូវត្រូវការចំណែករបស់មនុស្សដែលពួកយើងត្រូវបំលែងខ្លួនទៀត- ហឺម៉ាយអូនីស្រដីដោយមិនចាំបាច់បត់បែនយូរ ហាក់ដូចជានាងកំពុងបញ្ជាពួកគេឲ្យទៅទិញម្សៅដុសលាងនៅផ្សារទំនើបអញ្ចឹង។ - ហើយជាក់ស្តែងណាស់ ប្រសិនបើពួកឯងអាចយកចំនែកអ្វីមួយពីក្រេប និងហ្គូយល៍រឹតតែប្រសើរ។ ពួកគេទាំងពីរជាមិត្តភក្តិជិតស្និទ្ធិនឹងមេលហ្វ៊យ ដូច្នេះវាពិតជាប្រាប់ពួកគេគ្រប់យ៉ាង។ ហើយពួកយើងក៏ត្រូវធ្វើយ៉ាងណាកុំឲ្យក្រេប និងហ្គូយល៍ពិតប្រាកដចូលមកក្នុងឃើញពួកយើង ពេលដែលពួកយើងកំពុងតែសួរចម្លើយមេលហ្វ៊យផងដែរ។

- ខ្ញុំបានរៀបចំរួចរាល់អស់ហើយ- នាងបន្តបរិយាយយ៉ាងរលូនឥតអាក់ ដោយគ្មានខ្វល់ពីទឹកមុខស្រឡាំងកាំងរបស់ហេរី និងរ៉ុនបន្តិចសោះ។ នាងលើកនំសូកូឡាពីរដុំធំៗឡើងមក។ - ខ្ញុំបានដាក់ថ្នាំសណ្តំឲ្យដេកលក់កម្រិតធម្មតានៅក្នុងនំទាំងនេះ។ ពួកឯងទាំងពីរគ្រាន់តែធ្វើយ៉ាងណាឲ្យក្រេប និងហ្គូយល៍រកឃើញនំនេះតែប៉ុណ្ណឹងទៅ បានហើយ។ ពួកឯងដឹងស្រាប់ហើយថាពួកគេទាំងពីរនាក់នោះល្មោភស៊ីប៉ុណ្ណា។ ពួកគេច្បាស់ជាញ៉ាំនំទាំងនេះជាមិនខាន។ ពេលដែលពួកគេដេកលក់ហើយ ទាញសក់ពួកគេប៉ុន្មានសរសៃ ហើយលាក់ខ្លួនពួកគេនៅក្នុងទូដាក់ចានឆ្នាំងចុះ។

ហេរី និងរ៉ុនសម្លឹងមើលមុខគ្នាទាំងភ័ន្តភាំង។

- ហឺម៉ាយអូនី ខ្ញុំមិនគិតថា...

- ប្រសិនបើមានបញ្ហាអ្វីធ្ងន់ធ្ងរនោះ...

ប៉ុន្តែភ្នែករបស់ ហឺម៉ាយអូនី បញ្ចេញពន្លឺភ្លឺបភ្លែតយ៉ាងមាំទាំ មិនខុសគ្នាពីភ្នែករបស់អ្នកស្រីម៉ាកហ្គូណាហ្គាលប៉ុន្មាននោះទេ។

- ទឹកថ្នាំបំលែងកាយនឹងគ្មានបានការអ្វីឡើយប្រសិនជាគ្មានសក់របស់ក្រេប និងហ្គូយល៍- នាងស្រដីយ៉ាងម៉ឺងម៉ាត់។ - តើពួកឯងទាំងពីរ*ចង់*ស៊ើបអង្កេតមេលហ្វ៊យដែររឺអត់?

- អូ! មិនអីទេ មិនអីទេ- ហេរីតប។ - ប៉ុន្តែចុះចំណែកនាងវិញ? តើនាងចង់ទៅបោចសក់នរណាគេ?

- ខ្ញុំយកបានសក់រួចហើយ!- ហឺម៉ាយអូនីឧទានឡើងយ៉ាងរីករាយ ព្រមទាំងទាញកូនដបតូចមួយចេញពីក្នុងហោប៉ៅរបស់នាង ហើយបង្ហាញពួកគេនូវសក់មួយសរសៃនៅខាងក្នុងដបនោះ។ - មាននៅចាំ មីលីសិន បាល់ស្ត្រូដ ដែលបានប្រកួតជាមួយខ្ញុំនៅក្រុមប្រយុទ្ធតតាំងដែររឺទេ? នាងបានធ្វើឲ្យជ្រុះសក់មួយសរសៃនេះនៅលើរ៉ូបរបស់ខ្ញុំ ពេលដែលនាងព្យាយាមក្រៀកករបស់ខ្ញុំ!

ហើយឥឡូវនាងទៅផ្ទះនៅថ្ងៃបុណ្យណូអែលបាត់ហើយ...ដូច្នេះខ្ញុំគ្រាន់តែប្រាប់ពួកគេថាខ្ញុំសម្រេចចិត្តត្រលប់មកវិញតែប៉ុណ្ណឹង គឺចប់រឿងទៅហើយ។

នៅពេលដែលហឺម៉ាយអូនីដើរត្រុយទៅពិនិត្យមើលទឹកថ្នាំបំលែងកាយម្តងទៀត រ៉ុនបែរមុខមករកហេរី ដោយបង្ហាញទឹកមុខអាប់អួ។

- តើឯងមានដែលធ្លាប់ឮផែនការណាដែលអាចនឹងថ្លោះធ្លោយស្ទើរតែគ្រប់ចំនុចយ៉ាងនេះរឺទេ?

*

ប៉ុន្តែហេរី និងរ៉ុនបែរជាភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលជំហានទីមួយដំណើរការបានយ៉ាងរលូន ដូចហឺម៉ាយអូនីបានប្រាប់មែន។ ពួកគេលបពួននៅច្រកចេញសាលក្រោយពីផឹកតែណូអែលហើយ រង់ចាំក្រេប និងហ្គួយល៍ ដែលកំពុងអង្គុយតែពីរនាក់នៅតុស្លីធីរីនញាត់ម្ហូបអាហារទាំងបួនដុំចូលមាត់ព្រមៗគ្នា។ នៅពេលដែលពួកគេឃើញ ក្រេប និងហ្គួយល៍ដើរចេញពីសាលធំ ពួកគេរត់ទៅពួនយ៉ាងលឿនពីក្រោយរូបអាវក្រោះនៅជិតមាត់ទ្វារ។

- ចាំមើលតើឯងធាត់ប៉ុណ្ណាទើបឈប់?- រ៉ុនខ្សឹបយ៉ាងអណ្តែតអណ្តូង ខណៈពេលដែលក្រេប និងហ្គួយល៍ចង្អុលប្រាប់ហ្គួយល៍យ៉ាងសោមនស្ស រួចទៅលើកនំទាំងនោះឡើង។ ពួកគេញាត់នំទាំងមូលចូលក្នុងមាត់ទាំងញញឹមស្ញេញស្ញាញយ៉ាងល្ងង់ខ្លៅ។ ពួកគេទាំងពីរនាក់ទំពាយ៉ាងរីករាយមួយសន្ទុះ ទឹកមុខពួកគេដូចជាទទួលបានជ័យជំនះអ្វីមួយអញ្ចឹង។ បន្ទាប់មក ពួកគេទាំងពីរក៏ផ្ងារក្រោយទៅលើលើកម្រាលឥដ្ឋ ដោយគ្មានប្រែប្រួលទឹកមុខបន្តិចសោះ។

អ្វីដែលយ៉ាប់ជាងគេនោះគឺ ការយកខ្លួនពួកគេទៅលាក់ក្នុងទូដាក់ចានឆ្នាំងនៅទល់មុខសាល។ ពេលដែលដាក់ខ្លួនប្រាណគេទាំងពីរនាក់ឲ្យស្រួលបួលក្នុងចំណោមធុងទឹក និងក្រណាត់ជូតហើយនោះ ហេរីបោចសក់ពីរបីសរសៃដែលលយចេញលើថ្ងាសរបស់ហ្គួយល៍ ចំនែករ៉ុនទាញយកសក់ក្រេបជាច្រើនសរសៃ។ ពួកគេក៏បានលួចយកស្បែកជើងរបស់ក្រេប និងហ្គួយល៍ដែរ ពីព្រោះថាស្បែកជើងរបស់ពួកគេមិនត្រូវនឹងទំហំជើងរបស់ក្រេប និងហ្គួយល៍ឡើយ។ ក្រោយមក គេទាំងពីរនាក់ ក៏ប្រញាប់រត់ឡើងសំដៅបន្ទប់ទឹករបស់ ម៉ុននីង មីតថល ទាំងមិនទាន់បាត់ភ្ញាក់ផ្អើលចំពោះទង្វើរបស់ពួកគេនៅឡើយ។

ពួកគេមើលស្ទើរតែមិនឃើញ ដោយសារតែផ្សែងខ្មៅហុយចេញពីបន្ទប់ ដែលហឺម៉ាយអូនីកំពុងតែកូរថ្លាង។ ហេរី និងរ៉ុនទាញរ៉ូបរបស់ពួកគេគ្របមុខ រួចគោះទ្វារតិចៗ។

- ហឺម៉ាយអូនី?

ពួកគេឮសំឡេងចាក់សោ រួចឃើញហឺម៉ាយអូនីចេញមក ទឹកមុខពោរពេញដោយភាពស្រស់ថ្លា និងភាពអន្ទះសា។ ពួកគេឮសំឡេងគ្រូកៗនៃទឹកថ្នាំខាប់ ដែលកំពុងបែកពពុះ។ កែវតូចៗបីត្រូវបានដាក់រួចជាស្រេចនៅលើកៅអីបង្គន់។

- តើពួកឯងយកបានទេ?- ហឺម៉ាយអូនីសួរទាំងមិនចង់ដកដង្ហើម។

ហេរីបង្ហាញសក់ហ្គួយល៍ទៅនាង។

- ល្អ។ ហើយខ្ញុំក៏បានលួចយករ៉ូបទំនេរប៉ុន្មានសំរាប់ចេញពីកន្លែងបោកគក់ផងដែរ- ហឺម៉ាយអូនីស្រដី ព្រមទាំងលើកបង្ហាញបង្វេចតូចមួយ។ - ពួកឯងនឹងត្រូវការរ៉ូបធំជាងហ្នឹងពេលដែលប្រែរូបជាក្រេប និងហ្គួយល៍។

ពួកគេទាំងបីនាក់សំឡឹងមើលទៅថ្លាង។ ដល់ពេលមើលឲ្យជិតទៅ ទឹកថ្នាំនោះហាក់ដូចជាភក់ខ្មៅដ៏ខាប់មួយ ដែលកំពុងចេញពពុះយឺតៗ។

- ខ្ញុំប្រាកដក្នុងចិត្តណាស់ថាបានធ្វើអ្វីៗត្រឹមត្រូវអស់ហើយ- ហឺម៉ាយអូនីនិយាយ តែនៅឆ្លៀតអានទំព័រកំណត់ចំណាំនៃសៀវភៅ *ឱសថមានអានុភាពខ្លាំងក្លាបំផុត* ឡើងវិញម្ដងទៀត ហាក់មិនទុកចិត្ត។ - បើតាមសៀវភៅនិយាយគួរតែ ... ពេលដែលយើងផឹកវាហើយ យើងនឹងមានពេលមួយម៉ោងពេញមុននឹងប្រែមករូបដើមវិញ។

- តទ្បូវប្រុងធ្វើយ៉ាងម៉េច?- រ៉ុនខ្សឹបសួរ។

- ពួកយើងនឹងចាក់ទឹកថ្នាំបីកែវ ហើយដាក់សក់ចូល។

ហឺម៉ាយអូនីដួសទឹកថ្នាំដាក់ទៅក្នុងកែវនីមួយៗ។ បន្ទាប់មក នាងរលាក់ឲ្យសក់របស់មីលីសិន បាល់ស្ត្រូដធ្លាក់ចេញពីដបចូលទៅក្នុងកែវទីមួយ ទាំងដៃញ័រទទ្រើក។

ទឹកថ្នាំនោះបន្លឺសូរស៊ីៗយ៉ាងខ្លាំងប្រៀបបាននឹងកំសៀវកំពុងពុះ រួចក៏បែកពពុះជាច្រើន។ មួយវិនាទីក្រោយមក វាក៏ប្រែទៅជារាងពណ៌លឿង គួរឲ្យចង់ក្អួត។

- អិក...ជាតិមីលីសិន បាល់ស្ត្រូដ។ រ៉ុននិយាយ ដោយសំឡឹងមើលវាបែបស្អប់ខ្ពើម។ - ហ៊ានភ្នាល់ថាច្បាស់ជាមានរសជាតិគួរឲ្យឆ្អើមណាស់។

- ដាក់របស់ឯងទៅ អញ្ចឹង- ហឺម៉ាយអូនីពោល។

ហេរីទំលាក់សក់របស់ហ្គូយល៍ទៅក្នុងកែវកណ្ដាល ឯរ៉ុនដាក់សក់របស់ក្រេបទៅក្នុងកែវចុងក្រោយ។ កែវទាំងពីរបន្លឺសូរស៊ីៗហើយក៏បែកពពុះ៖ កែវដាក់សក់ហ្គូយល៍ប្រែទៅជាពណ៌កាគីស្រទ្បែត ចំណែកឯកែវដាក់សក់ក្រេបវិញពណ៌ខ្មៅ លាយត្នោតចាស់។

- ឈប់សិន- ហេរីបន្លឺឡើង ពេលដែលរ៉ុន និងហឺម៉ាយអូនីឈោងយកកែវរបស់ពួកគេ។ - យល់ល្អ ពួកយើងមិនគួរផឹកនៅទីនេះទាំងអស់គ្នាទេ៖ ពេលដែលពួកយើងប្រែរូបទៅជាក្រេប និងហ្គូយល៍ សំលៀកបំពាក់ពួកយើងនឹងមិនល្មមខ្លួនទៀតទេ។ម្យ៉ាងទៀត ខ្លួនរបស់មីលីសិន បាល់ស្ត្រូដក៏មិនជាតូចប៉ុន្មានដែរ។

- គំនិតល្អ- រ៉ុនឯកភាព ព្រមទាំងចាក់បើកសោ។ - ពួកយើងនឹងទៅបន្ទប់ដោយឡែកៗពីគ្នា។

ហេរីចូលទៅក្នុងបន្ទប់កណ្ដាល ដោយប្រយ័ត្នប្រយែងមិនឲ្យធ្លាក់ទឹកថ្នាំនោះសូម្បីតែមួយតំនក់។

- រួចហើយរឺនៅ?- វាស្រែកសួរ។

- រួចហើយ- សំទ្បេងរ៉ុន និងហឺម៉ាយអូនីបន្លឺឡើងព្រមៗគ្នា។

- មួយ...ពីរ...បី...

ហេរីច្របាច់ច្រមុះខ្លួន រួចបញ្ច្រកទឹកថ្នាំចូលទៅក្នុងមាត់អស់តែក្នុងពីរក្អឹក។ វាមានរសជាតិដូចស្ពៃខ្លោចអញ្ចឹង។

ក្បិណនោះ សរីរាង្គខាងក្នុងខ្លួនវាចាប់ផ្ដើមរមួលហាក់ដូចជាវាទើបនឹងលេបពស់ចូលទាំងរស់ដូច្នោះដែរ។ វាអោនទៅមុខចង់ក្អួតបន្តិចអត់បន្តិច បន្ទាប់មកអារម្មណ៍ដូចភ្លើងឆេះមួយបានរាលដាលយ៉ាងរហ័សពីក្នុងពោះរបស់វារហូតដល់ចុងម្រាមដៃម្រាមជើង។ បន្ទាប់មក វាក៏ដួលជើងបួនលើកម្រាលឥដ្ឋ ហើយក៏មានអារម្មណ៍ដូចកំពុងតែរលាយ ពោលគឺហាក់ដូចជាស្បែកពេញទាំងខ្លួនប្រាណរបស់វាបែកពពុះដូចជាក្រមួនត្រូវក្ដៅ រីឯដៃទាំងគូរបស់វាចាប់ផ្ដើមលូតវែង ម្រាមដៃកាន់តែប៉ោងឡើងៗ ក្រចកកាន់តែវែងទៅៗ ថែមទាំងក្រញូវដៃចាប់ផ្ដើមប៉ោងធំដូចប៊ូទ្បុង។ ស្មារបស់វាលាតសន្ធឹងយ៉ាងចុកផ្សា ចំនែកឯការឈឺស្ញៀបៗនៅលើថ្ងាសរបស់វានាំឲ្យវាដឹងថា សក់កំពុងតែលូតចុះមកត្រឹមចិញ្ចើមរបស់វា។ អាវរ៉ូបរបស់វាត្រូវរហែក ខណៈពេលដែលទ្រូងរបស់វារីកធំឡើង

ដូចធុងឈើផ្ទុះវណ្ណ។ ជើងរបស់វាកំពុងតែឈឺចាប់ដោយសារស្បែកជើងតូចពេក។ ជើងវាប្រហែលជាធំជាងស្បែកជើងបួនដងឯនោះ...

អ្វីៗគ្រប់យ៉ាងត្រូវបានបញ្ចប់យ៉ាងឆាប់រហ័ស ដូចកាលដែលវាកើតឡើងអញ្ចឹងដែរ។ ហេរីផ្ទប់មុខចុះលើកម្រាលថ្មត្រជាក់ស្រេប ស្តាប់សូរយំអំរួយមិនចេះឈប់របស់មីតចលនៅបង្គន់បន្ទប់ចុងក្រោយគេ។ វាធាក់ស្បែកជើងរបស់វាចេញទាំងទើសទែងហើយក្រោកឈរឡើង។ អញ្ចឹង នេះហើយគឺជាអារម្មណ៍ដែលបានធ្វើជា ហ្គយល៍។ វាទាញរ៉ូបចាស់របស់វាចេញ ដែលខើចប្រមាណជាងសាមសិបសង់ទីម៉ែតពីកែងជើងរបស់វា ទាំងដៃញញើញញ័រនៅឡើយ រួចស្លៀករ៉ូបបម្រុង ហើយពាក់ស្បែកជើងរាងដូចទូករបស់ហ្គយល៍។ វាឈោងទៅបបោសសក់ចេញពីភ្នែករបស់វា តែប៉ះសក់រឹងដូចដែកលួស ធ្លាក់ត្រឹមថ្ងាសរបស់វា។ បន្ទាប់មក វាចាប់អារម្មណ៍ថាវ៉ែនតារបស់វាកំពុងតែធ្វើឲ្យភ្នែករបស់វាស្រអាប់ ពីព្រោះថាជាក់ស្តែងណាស់ ហ្គយល៍មិនពាក់វ៉ែនតាទេ។ វាក៏ដោះវ៉ែនតាចេញ ហើយស្រែកសួរ៖

- ឯងទាំងពីរមិនអីទេរឺ?- សំឡេងស្អកៗរបស់ហ្គយល៍បន្លឺចេញពីមាត់របស់វា។

- មិនអីទេ- សំឡេងគ្រហឹមរបស់ក្រេបបន្លឺឡើងពីបន្ទប់ខាងស្តាំ។

ហេរីបើកសោទ្វារ ហើយដើរទៅឈរពីមុខកញ្ចក់ដែលប្រេះ។ ហ្គយល៍សំឡឹងមើលមកវាវិញតាមរយៈកែវភ្នែករូងខូងទៅក្នុងដ៏អួអាប់។ ហេរីអេះត្រចៀករបស់វា។ ហ្គយល៍ក៏ធ្វើតាមដែរ។

ទ្វារបន្ទប់រ៉ុនបើកឡើង។ ពួកគេសម្លឹងមើលគ្នាទៅវិញទៅមក។ ក្រៅពីទឹកមុខស្លេកស្លាំង និងស្រឡាំងកាំងរបស់វា រ៉ុនមើលទៅគ្មានខុសអ្វីពីក្រេបបន្តិចឡើយ តាំងពីសក់កាត់ដូចធុងពូឌិញ រហូតដល់ដៃដូចស្វាឌី។

- នេះពិតជាមិនគួរឲ្យជឿទេ- រ៉ុនស្រដី ដោយខិតទៅជិតកញ្ចក់ ហើយយកដៃចាក់ច្រមុះកំពិតរបស់ក្រេប។ - *ពិតជាមិនគួរឲ្យជឿទេ*។

- គួរតែដល់ពេលត្រូវទៅហើយ- ហេរីនិយាយ ព្រមទាំងដោះនាឡិកាដែលកំពុងតែរឹតតឹងលើកដៃដ៏ក្រាស់របស់ហ្គយល៍។ - ពួកយើងត្រូវរកមើលថាតើសាលរួមរបស់ក្រុមស្លីធើរីននៅទីណាទៀត ខ្ញុំសង្ឃឹមថានឹងមានមនុស្សឲ្យដើរតាមចុះ...

រ៉ុន ដែលកំពុងតែសំឡឹងមើលហេរី បន្លឺឡើងថា៖

- ឯងដឹងទេថា វាចម្លែកណាស់ដែលឃើញហ្គយល៍*ចេះគិត*ដូច្នេះ។- វាដំផូងៗទៅលើទ្វាររបស់ហឺម៉ាយអូនី។ - ឆាប់ឡើង ពួកយើងត្រូវទៅហើយ...

សំឡេងដ៏ស្រួយមួយឆ្លើយមកវិញ៖ - ខ្ញុំ...ខ្ញុំគិតថាខ្ញុំមិនចង់ទៅទេ។ ពួកយើងទៅចុះ មិនបាច់ចាំខ្ញុំទេ។

- ហឺម៉ាយអូនី ពួកយើងដឹងថា មីលីសិន បាល់ស្ត្រូដ មានរូបរាងអាក្រក់ហើយ តែគ្មាននរណានឹងដឹងថាជាឯងនោះទេ។

- ទេ...ខ្ញុំនិយាយមែនណា៎...ខ្ញុំមិនទៅទេ។ ពួកឯងពីរនាក់ប្រញាប់ឡើង កុំនៅខ្ជះខ្ជាយពេលវេលាទៀត។

ហេរីសម្លឹងមើលមករ៉ុន ទាំងមិនយល់។

- *ធ្វើមុខ*អញ្ចឹងទៅរាងដូចហ្គយល៍បន្តិច- រ៉ុនពោល។ - វាតែងតែធ្វើមុខអញ្ចឹងឯង ឲ្យតែពេលណាគ្រូសួរសំណួរវា។

- ហឺម៉ាយអូនី ឯងមិនអីទេរឺ?- ហេរីស្រែកសួរ។

- មិនអីទេ...ខ្ញុំមិនអីទេ...ទៅចុះ...

ហេរី មើលនាឡិការបស់វា។ ប្រាំនាទីក្នុងហុកសិបនាទីដ៏មានតម្លៃរបស់ពួកគេបានកន្លងផុតបាត់ទៅហើយ។

- ពួកយើងនឹងជួបឯងនៅទីនេះវិញ បានទេ?- វាស្រដី។

ហេរី និងរ៉ុនបើកទ្វារបន្ទប់ទឹកយ៉ាងប្រុងប្រយ័ត្ន រួចពិនិត្យមើលថាមាននរណានៅជុំវិញរឺទេ ហើយក៏ចេញដំណើរ។

- កុំយោលដៃឯងអ៊ីចឹង- ហេរីខ្សឹបប្រាប់រ៉ុន។

- យ៉ាងម៉េច?

- ក្រេបកាន់ដៃរាងរឹងត្អឹងណ៎ា...

- ធ្វើអញ្ចេះយ៉ាងម៉េចដែរ?

- បាន ប៉ុណ្ណឹងគ្រាន់បើ។

ពួកគេដើរចុះជណ្តើរថ្មើមថ្ម។ អ្វីដែលពួកគេត្រូវធ្វើពេលនេះគឺរកសិស្សស្លីតឺរីនម្នាក់ ដើម្បីអាចឲ្យពួកគេដើរតាមទៅកាន់សាលរួមក្រុមស្លីតឺរីន ប៉ុន្តែដូចជាគ្មានឃើញនរណាម្នាក់នៅជុំវិញសោះ។

- មានយោបល់អ្វីទេ?- ហេរីសួរតិចៗ។

- សិស្សស្លីតឺរីនតែងតែឡើងមកញ៉ាំអាហារពេលព្រឹកពីទីនោះ- រ៉ុនតប ដោយងក់ក្បាលទៅកាន់ច្រកចូលបន្ទប់ងងឹត។ វានិយាយមិនទាន់ផុតពីមាត់ផង ស្រាប់តែមានក្មេងស្រីម្នាក់សក់ក្រញាញ់វែង ដើរចេញពីច្រកចូលនោះ។

- អត់ទោស- រ៉ុននិយាយ ព្រមទាំងដើររួសរាន់ទៅរកនាង - ពួកយើងវង្វេងផ្លូវទៅសាលរួមរបស់ពួកយើងបាត់ទៅហើយ។

- ឯងនិយាយថាម៉េច?- ក្មេងស្រីនោះនិយាយទាំងមិនទទន់ភ្លន់។ - សាលរួមរបស់*ពួកយើង*? ខ្ញុំជាសិស្សរ៉ាវិនក្លាហ្វទេតើ។

នាងក៏ដើរចេញទៅ ទាំងសំឡឹងមើលមកពួកគេបែបសង្ស័យ។

ហេរី និងរ៉ុនប្រញាប់ប្រញាល់រត់ចុះជណ្តើរថ្មទៅក្នុងស្បៃអន្ធការ។ ស្នូរជើងរបស់ពួកគេលាន់ឡើងខ្លាំងៗខុសពីធម្មតា ពេលដែលជើងក្រេប និងហ្គយល៍ជាន់លើកម្រាលឥដ្ឋម្តងៗ។ បេសកកម្មនេះមិនងាយស្រួលដូចដែលពួកគេគិតនោះទេ។

ច្រកផ្លូវខ្វាត់ខ្វែងគ្មានមនុស្សដើរទេ។ ពួកគេដើរកាន់តែជ្រៅទៅៗនៅក្រោមសាលា ភ្នែកចេះតែពិនិត្យមើលនាឡិកាពួកគេជារឿយៗ ដើម្បីឲ្យដឹងថាពួកគេនៅសល់ពេលប៉ុន្មានទៀត។ ដប់ប្រាំនាទីក្រោយមក ពេលដែលពួកគេកំពុងតែអស់សង្ឃឹម ស្រាប់តែឮសំឡេងអ្វីមួយធ្វើដំណើរមកនៅខាងមុខ។

- ហា!- រ៉ុនឧទានឡើងយ៉ាងរំភើប។ - ឃើញម្នាក់ហើយ!

ម្នាក់នោះកំពុងតែចេញពីបន្ទប់មួយនៅម្ខាង។ ប៉ុន្តែ នៅពេលដែលពួកគេខិតទៅជិត ស្រាប់តែធ្លាក់ថ្លើមក្តុកតែម្តង។ គេមិនមែនជាសិស្សស្លីតឺរីនទេ គឺពឿរស៊ី។

- តើឯងមកធ្វើអ្វីនៅទីនេះ?- រ៉ុនសួរបែបភ្ញាក់ផ្អើល។

ពឿរស៊ីស្រាប់តែក្តៅឆេវតែម្តង។

- វា- វាបន្លឺឡើងយ៉ាងដាច់ម៉ាត់។ - មិនមែនជារឿងរបស់ឯងនោះទេ។ ឯងឈ្មោះក្រេប មែនទេ?

- អឺ...អូ! គឺយើងហ្នឹងហើយ- រ៉ុនតប។

- ម៉េចក៏មិនទៅសយនដ្ឋាន- ពឿរស៊ីស្រដីយ៉ាងម៉ឺងម៉ាត់។ - គ្មានសុវត្ថិភាពទេ ដែលដើរជុំវិញផ្លូវរបៀងងងឹតៗនៅពេលអាសន្នបែបនេះ។

- ចុះឯងម៉េចមិនថាផង- រ៉ុនស៊កសម្តី។

- ខ្ញុំ- ពឿរស៊ីតប ថែមទាំងតម្រង់ខ្លួនឲ្យត្រង់ - គឺជាប្រធានសិស្ស។ គ្មានអ្វីអាចវាយប្រហារខ្ញុំបានទេ។

សំឡេងមួយទៀតស្រាប់តែបន្លឺឡើងពីក្រោយហេរី និងរ៉ុន។ ដ្រាកូ មេលហ្វ័យកំពុងតែដើរសំដៅមករកពួកគេ។ នេះជាលើកដំបូងហើយក្នុងជីវិតវា ដែលហេរីសប្បាយចិត្តនឹងបានជួបមេលហ្វ័យ។

- ពួកឯងនៅទីនេះសោះ- វានិយាយយឺតៗបែបខ្ជិល ព្រមទាំងចោលក្រសែភ្នែកមកពួកគេ។ - តើពួកឯងទាំងពីរនាក់កំពុងតែល្មោភស៊ីនៅក្នុងសាលធំពេញមួយយប់នេះទេរឺ? ខ្ញុំខំតែតាមរកពួកឯង។ ខ្ញុំចង់បង្ហាញឯងនូវអ្វីមួយគួរឲ្យអស់សំណើចខ្លាំងណាស់។

មេលហ្វ័យក្រឡេកមើលពឿរស៊ីមិនដាក់ភ្នែក។

- ហើយចុះឯងកំពុងតែធ្វើអ្វីនៅខាងក្រោមនេះ វីស្លី?- វាញញឹមបែបចំអក។

ពឿរស៊ីចាប់ផ្តើមក្តៅក្រហាយ។

- ឯងត្រូវតែចេះគោរពឋានៈប្រធានសិស្សបន្តិចផង!- វាបន្លឺឡើង។ - ខ្ញុំមិនចូលចិត្តឥរិយាបថរបស់ឯងឡើយ!

មេលហ្វ័យសើចចំអក ហើយធ្វើសញ្ញាឲ្យហេរី និងរ៉ុនទៅតាមវា។ ហេរីស្ទើរតែភ្លាត់មាត់និយាយពាក្យសុំទោសដាក់ពឿរស៊ីបាត់ទៅហើយ កុំតែទប់ខ្លួនទាន់។ វា និងរ៉ុនប្រញាប់ដើរតាមពីក្រោយមេលហ្វ័យជាប់។ ពេលដែលពួកគេបត់ចូលច្រកផ្លូវមួយទៀត មេលហ្វ័យនិយាយថា៖

- អា ភីតធើ វីស្លី ស៊្មីគេនោះ...

- គឺពឿរស៊ីទេ- រ៉ុននិយាយកែតម្រូវវាដោយស្វ័យប្រវត្តិ។

- ស៊្មីក៏ស៊្មីទៅ- មេលហ្វ័យតប។ - ខ្ញុំកត់សម្គាល់ឃើញថា វាកំពុងតែធ្វើអ្វីលបៗច្រើនដងណាស់ថ្មីៗនេះ។ ហើយខ្ញុំហ៊ានភ្នាល់ថាវាកំពុងតែចង់ធ្វើអ្វី។ វាច្បាស់ជាគិតថា នឹងចាប់ទាយាទស្លីធើរីនដោយខ្លួនឯងហើយ មើលទៅ។

វាសើចបែបមើលងាយបន្តិច។ ទឹកមុខហេរី និងរ៉ុនចាប់ផ្តើមរំភើបឡើង។

មេលហ្វ័យបង្អាក់ដំណើរនៅជិតជញ្ជាំងថ្មសើមទទេដ៏ទូលាយមួយ។

- តើពាក្យសម្ងាត់ថ្មីនោះស៊្មីគេអញ្ចេះ?- វាសួរទៅហេរី។

- អឺ...- ហេរីស្រដី។

- អូ! ត្រូវហើយ...ឈាមសុទ្ធ!- មេលហ្វ័យឧទានឡើង ដោយមិនស្តាប់ឡើយ ហើយទ្វារថ្មមួយដែលកប់ក្នុងជញ្ជាំងក៏របើកឡើង។ មេលហ្វ័យដើរចូលទៅក្នុង ដោយមានហេរី និងរ៉ុនតាមប្រកិតពីក្រោយ។

សាលរួមស្លីធើរីនគឺជាបន្ទប់ក្រោមដីទាបដ៏វែងមួយ ដែលមានជញ្ជាំងថ្ម និងពិតានគ្រើមៗ គួបផ្សំនឹងចង្កៀងពណ៌បៃតងដាក់ព្យួរលើច្រវាក់។ ភ្លើងកំពុងតែខ្ទាតផ្កាភ្លើងប្រេស នៅពីក្រោមធ្នើរចង្ក្រានកំដៅពីមុខពួកគេដែលមានឆ្លាក់ក្បាច់យ៉ាងល្អប្រណីត ហើយមានសិស្ស ស្លីធើរីន ជាច្រើននាក់កំពុងតែអង្គុយជុំវិញភ្នក់ភ្លើងនោះលើកៅអីឆ្លាក់ ចោលស្រមោលមកលើកម្រាលឥដ្ឋ។

- ចាំនៅទីនេះហើយ- មេលហ្វ័យនិយាយប្រាប់ហេរី និងរ៉ុន ព្រមទាំងឲ្យសញ្ញាឲ្យពួកគេអង្គុយលើកៅអីមួយគូដាក់នៅឆ្ងាយពីភ្នក់ភ្លើង។ - ចាំខ្ញុំទៅយកវា...ប៉ារបស់ខ្ញុំទើបតែផ្ញើមក...

ដោយឆ្ងល់មិនដឹងជា មេលហ្វ័យ នឹងបង្ហាញអ្វីប្រាប់ពួកគេ ហេរី និងរ៉ុនក៏អង្គុយចុះ និងធ្វើចិត្តឲ្យដូចជានៅផ្ទះខ្លួនឯង។

មួយនាទីក្រោយមក មេលហ្វ័យត្រឡប់មកវិញ ដោយមានកាន់ក្នុងដៃនូវអ្វីម្យ៉ាងដូចជាក្រដាសកាត់ចេញពីកាសែត។ វារុញក្រដាសនោះទៅដាក់ពីក្រោយច្រមុះរបស់រ៉ុន។

- ឯងមើលហើយច្បាស់ជាសើចចុកពោះមិនខាន- វានិយាយ។

ហេរីឃើញភ្នែករបស់រ៉ុនបើកធំៗបែបភ័ន្តភាំង។ វាអានក្រដាសនោះយ៉ាងរហ័សរហួន រួចសើចទាំងបង្ខំចិត្ត ហើយហុចទៅឲ្យហេរី។

ក្រដាសនោះត្រូវបានកាត់ចេញពី សារព័ត៌មានវេទគូ ហើយក្នុងនោះសរសេរថា៖

*ការស៊ើបអង្កេតនៅក្រសួងវេទមន្ត*

*អស់សឺ វីស្លី ដែលជានាយកផ្នែកការិយាល័យ ការប្រើប្រាស់របស់របរពួកលោកិយមិនត្រឹមត្រូវ ថ្ងៃនេះត្រូវបានគេដាក់ពិន័យចំនួនហាសិបហ្គាលឡុនពីបទដាក់មន្តអាគមទៅលើឡានពួកលោកិយ។*

*លោក លូស៊ីស មេលហ្វ៊យ ដែលជាអ្នកគ្រប់គ្រងសាលាវេទមន្ត ហុកវ៉ាត ដែលជាទីកន្លែងដែលឡានវេទមន្តនោះបានក្រឡាប់ថ្មីៗនេះ ថ្ងៃនេះបានស្នើឲ្យលោកវីស្លីចុះចេញពីតំណែង។*

*"វីស្លីពិតជាធ្វើឲ្យក្រសួងអាប់អោនមុខមាត់ណាស់" លោកមេលហ្វ៊យប្រាប់អ្នកយកការណ៍។ "គេពិតជាមិនសក្តិសមក្នុងការពង្រឹងច្បាប់របស់យើងនោះទេ ហើយយុទ្ធនាការការពារពួកលោកិយដ៏គ្មានបានការរបស់គេគួរតែបញ្ឈប់ភ្លាមទៅ។*

*លោកវីស្លីមិនអាចទាក់ទងផ្តល់យោបល់បាននោះទេ ប៉ុន្តែប្រពន្ធរបស់គាត់បានប្រាប់អ្នករាយការណ៍ថាឲ្យចេញទៅឲ្យឆ្ងាយ បើមិនអញ្ចឹងទេគាត់នឹងព្រលែងប្រែតប្រចាំគ្រួសារដេញខាំពួកគេមិនខាន។*

- យ៉ាងម៉េច?- មេលហ្វ៊យសួរទាំងមិនអត់ធ្មត់ ខណៈពេលដែលហេរីហុចក្រដាសនោះមកឲ្យវាវិញ។ - ឯងមិនយល់ថាគួរឲ្យចង់សើចទេវី?

- ហា ហា- ហេរីស្រដីយ៉ាងស្រងូតស្រងាត់។

- ប្រសិនបើ អស់សឺ វីស្លី ស្រឡាញ់ពួកលោកិយខ្លាំងយ៉ាងនេះ គេគួរតែកាច់ចង្កឹះឲ្យបាក់ជាពីរ ហើយរត់ទៅរស់នៅជាមួយពួកអស់ទាំងនោះតែម្តងទៅ- មេលហ្វ៊យនិយាយចំអក។ - បើមើលពីអាកប្បកិរិយារបស់ពួកគេ ច្បាស់ជាមិនដឹងថាត្រកូលវីស្លីនោះជាអ្នកមានឈាមជ័រសុទ្ធឡើយ។

មុខរបស់រ៉ុន...រីក៏ក្រេប កំពុងតែពុះពោរដោយកំហឹង។

- ឯងកើតស្អីហ្នឹង ក្រេប?- មេលហ្វ៊យនិយាយម៉ាត់ៗ។

- ឈឺពោះ- រ៉ុនឆ្លើយរាងគ្រលួៗ។

- បើអញ្ចឹង ឆាប់ទៅគិលានដ្ឋានចុះ ហើយផ្ញើពីរបីជើងសម្រាប់អាពួកឈាមកខ្វក់ទាំងអស់នោះផង- មេលហ្វ៊យស្រដីទាំងសើចចំអកឡុកឡឺយ។ - ឯងដឹងទេ ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ដែល សារព័ត៌មានវេទគូ មិនទាន់ចុះផ្សាយពីការវាយប្រហារអស់នេះនៅឡើយ- វានិយាយបន្តមួយៗ។ - ខ្ញុំគិតថាតាដាំប័លដ័រកំពុងតែព្យាយាមលាក់ការណ៍ហើយ។ បើរឿងនេះមិនឈប់ក្នុងពេលឆាប់ៗនេះទេ គាត់ច្បាស់ជាត្រូវវេចបង្វេចជាមិនខាន។ ប៉ាតែងតែនិយាយថា ដាំប័លដ័រគឺជារឿងដ៏អាក្រក់បំផុតដែលធ្លាប់កើតមានឡើង

នៅទីកន្លែងនេះ។ គាត់ស្រឡាញ់ពួកកើតពីពួកលោកិយ។ នាយកដែលមានសុភវិនិច្ឆ័យម្នាក់ច្បាស់ជាមិនឲ្យអាសំគម គ្រីវ ចូលមករៀនឡើយ។

មេលហ្វ័យលើកដៃឡើងធ្វើជាថតរូប ហើយនិយាយគ្រាប់តាមខូលីនបេះបិទ តែឃោរឃៅជាងហ្នឹងទៅទៀត៖

- ផោតធ័រ ខ្ញុំថតរូបឯងបានទេ ផោតធ័រ? ខ្ញុំសុំហត្ថលេខាឯងបានទេ? ឲ្យខ្ញុំសូមលិទ្ធស្បែកជើងឯងបានទេ ផោតធ័រ?

វាទម្លាក់ដៃចុះវិញ ហើយសម្លឹងមើលហេរី និងរ៉ុន។

- ហើយចុះពីរនាក់ឯងយ៉ាងម៉េចហ្នឹងថ្ងៃនេះ?

ស្ថានការណ៍កំពុងតែរឹករវ ហេរី និងរ៉ុនក៏បង្ខំខ្លួនឯងឲ្យសើចចេញមក ប៉ុន្តែមេលហ្វ័យហាក់ដូចជាសប្បាយចិត្តឡើងវិញ។ ប្រហែលជាមកពីក្រេប និងហ្គូយល៍រមែងយល់ដឹងរឿងរ៉ាវយឺតយ៉ាវហើយ។

- ទេវៈផោតធ័រ មិត្តសម្លាញ់របស់ពួកឈាមកខ្វក់- មេលហ្វ័យស្រដីយឺតៗ។ - វានោះហើយជាមនុស្សម្នាក់ទៀត ដែលគ្មានអារម្មណ៍ដូចវេទគូអ្វីបន្តិចសោះ បើមិនអញ្ចឹងវាច្បាស់ជាមិនដើរហើរជាមួយនាងឈាមកខ្វក់ហ្គ្រេនជឺរ ដែលប៉ិនវាយឫកនោះទេ។ ហើយមនុស្សទាំងឡាយនាំគ្នាគិតថា វាជាទាយាទស្លីធីរីនទៀត!

ហេរី និងរ៉ុនរត់ចាំដល់ថ្នាក់មិនដកដង្ហើម៖ សល់តែប៉ុន្មានវិនាទីទៀត មេលហ្វ័យនឹងប្រាប់ពួកគេថាទាយាទគឺជាវាហើយ។ ប៉ុន្តែបន្ទាប់មក...

- បើខ្ញុំដឹងថាគេជានរណា ច្បាស់ជាល្អហើយ- មេលហ្វ័យនិយាយទាំងម៉ូម៉ៅ។ - ខ្ញុំអាចជួយពួកគេបាន។

ថ្គាមរបស់រ៉ុនធ្លាក់ចុះមក ធ្វើឲ្យមុខរបស់ក្រេបកាន់តែមើលទៅល្ងីល្ងើជាងសព្វដង។ សំណាងល្អដែលមេលហ្វ័យមិនបានចាប់ភ្លឹក ចំនែកឯហេរី មានគំនិតរហ័សរហួន ក៏បន្ថែមសំដី៖

- តែឯងច្បាស់ជាមានគំរុយខ្លះហើយថា នរណានៅពីក្រោយរឿងទាំងអស់នេះ...

- ឯងដឹងថាខ្ញុំគ្មានហើយ ហ្គូយល៍ តើឲ្យខ្ញុំត្រូវប្រាប់ឯងប៉ុន្មានដងទៀត?- មេលហ្វ័យស្ដីឲ្យ។ - ឯប៉ាខ្ញុំវិញមិនព្រមប្រាប់ខ្ញុំថាមានអ្វីកើតឡើងកាលពីបន្ទប់នោះត្រូវបានបើកឡើងពីលើកមុនទេ បន្តិចក៏អត់ដែរ។ ជាការពិតណាស់ កាលនោះហាសិបឆ្នាំមុនឯនោះ ដូច្នេះវាកើតឡើងមុនពេលគាត់ចូលរៀនទៅទៀត ប៉ុន្តែគាត់ដឹងរឿងនោះទាំងអស់ ហើយគាត់និយាយថារឿងនោះសុទ្ធតែត្រូវបានរក្សាទុកជាអាថ៌កំបាំង ហើយថាប្រសិនបើខ្ញុំដឹងច្រើនពេក នឹងធ្វើឲ្យមនុស្សម្នាមានការសង្ស័យ។ ប៉ុន្តែខ្ញុំដឹងរឿងមួយ៖ លើកមុនពេលដែលបន្ទប់សម្ងាត់បានបើកឡើង សិស្សឈាមកខ្វក់ម្នាក់បាន*ស្លាប់*។ ដូច្នេះខ្ញុំហ៊ានភ្នាល់ថា មិនយូរមិនឆាប់ច្បាស់ជាមានពួកឈាមកខ្វក់ម្នាក់ស្លាប់ជាមិនខាន...ខ្ញុំសង្ឃឹមថាជាហ្គ្រេនជឺរទៅចុះ- វាស្រដីយ៉ាងរីករាយ។

រ៉ុនកំពុងតែក្ដាប់ដៃយក្សរបស់ក្រេបយ៉ាងណែន។ ដោយខ្លាចថារ៉ុនហាក់ទៅដាល់មេលហ្វ័យ ហេរីក៏បាញ់ក្រសែភ្នែកព្រមានមករករ៉ុន ហើយបន្លឺឡើងថា៖

- ឯងមានដឹងទេថា អ្នកដែលបើកបន្ទប់សម្ងាត់កាលពីលើកមុន ត្រូវគេចាប់បានរឺក៏អត់?

- អូ! មែនហើយ...អ្នកដែលបើកនោះត្រូវបានបណ្ដេញចេញពីសាលាហើយ- មេលហ្វ័យឆ្លើយ។ - ពួកគេប្រហែលជានៅអាសកាបាន នៅឡើយទេ។

- អាសកាបាន?- ហេរីសួរដោយឆ្ងល់។

- អាសកាបាន...គឺគុកវេទគូណ៌ា ហ្គូយល៍- មេលហ្វ័យពោល ដោយសម្លឹងមើលវាហាក់មិនចង់ជឿនឹងភ្នែកខ្លួនឯង។ - និយាយតាមត្រង់ ឲ្យតែឯងចាប់អត្ថន័យបានយឺតយ៉ាងនេះ ច្បាស់ជាធាក់ថយហើយ។

វាបំរះខ្លួនលើកៅអីរបស់វាហាក់មិនស្រណុក ហើយនិយាយបន្ត៖

- ប៉ាថាកុំឲ្យខ្ញុំចេញមុខ ទុកឲ្យតែទាយាទស្លីតឺរីនចាត់ការទៅបានហើយ។ គាត់និយាយថាសាលានេះត្រូវការកំចាត់ចោលពួកសំរាមឈាមកខ្វក់ឲ្យអស់ ប៉ុន្តែក៏មិនចាំបាច់ត្រូវជាប់ពាក់ព័ន្ធនាំតែប្រឡាក់ដៃដែរ។ ជាការពិតណាស់ ពេលនេះគាត់មានបញ្ហាច្រើនណាស់។ ឯងមានដឹងថា ក្រសួងវេទមន្ត បានចូលឆែកឆេរភូមិគ្រឹះរបស់ពួកយើងកាលពីសប្តាហ៍មុនទេ?

ហេរីព្យាយាមធ្វើមុខស្លេកស្លាំងរបស់ហ្គូយល៍ឲ្យបង្ហាញភាពព្រួយបារម្ភ។

- ត្រូវហើយ...- មេលហ្វ័យស្រដី។ - សំណាងល្អ ពួកគេរកឃើញមិនច្រើនទេ។ ប៉ាមានរបស់របរមន្តអាគមងងឹតសុទ្ធតែមានតម្លៃមិនតិចទេ។ ប៉ុន្តែសំណាងណាស់ ដែលពួកយើងក៏មានបន្ទប់សម្ងាត់ផ្ទាល់ខ្លួននៅក្រោមក្តារបន្ទប់ទទួលភ្ញៀវដែរ...

- ហូ!- រ៉ុនឧទានឡើង។

មេលហ្វ័យងាកមកមើលវា។ ហេរីក៏ធ្វើតាមដែរ។ មុខរ៉ុនឡើងក្រហម។ សូម្បីតែសក់របស់វាក៏ឡើងក្រហមដែរ។ ច្រមុះរបស់វាកំពុងតែលូតវែងបន្តិចម្តងៗ...ពួកគេអស់ម៉ោងហើយ។ រ៉ុនកំពុងតែប្រែទៅជារូបដើមវិញហើយ ហើយបើមើលតាមទឹកមុខតក់ស្លុតរបស់វាដែលសម្លឹងមើលមកហេរី វាក៏ច្បាស់ជាប្រែរូបវិញដែរ។

ពួកគេទាំងពីរក្រោកឈរឡើងភ្លែត។

- ដល់ពេលផឹកថ្នាំឈឺពោះហើយ- រ៉ុនស្រដីបែបគ្រលរៗ ហើយដោយមិនរង់ចាំយូរ ពួកគេដើរទៅយ៉ាងលឿនចេញពីសាលរួមស្លីតឺរីន រួចលោតចេញពីជញ្ជាំងថ្ម ហើយរត់ប្រុយឡើងតាមច្រកផ្លូវទៅលើវិញ ក្នុងចិត្តសង្ឃឹមថាមេលហ្វ័យមិនបានចាប់អារម្មណ៍អ្វីទៅចុះ។ ហេរីមានអារម្មណ៍ថាស្បែកជើងធំៗរបស់ហ្គូយល៍កំពុងតែរលុង ហើយវាត្រូវលើករ៉ូបឡើងពេលដើរ ព្រោះខ្លួនវាកំពុងតែរួញតូចវិញ។ ពួកគេតន្ត្រំរត់ឡើងកាំជណ្តើរទៅក្នុងច្រកចូលសាលដែលងងឹតសូន្យសុង ឮតែសំឡេងដំផ្លុងៗចេញពីទូដាក់ចានឆ្នាំងដែលពួកគេចាក់សោឃុំក្រេប និងហ្គូយល៍។ ក្រោយពីចោលស្បែកជើងនៅក្រៅទ្វារទូ សល់តែស្រោមជើង ពួកគេរត់យ៉ាងលឿនឡើងជណ្តើរថ្មើមថ្មសំដៅបន្ទប់ទឹករបស់ម៉ុននីង មីតថល។

- យ៉ាងណាមិញ វាក៏មិនអត់ប្រយោជន៍ដែរ- រ៉ុននិយាយទាំងដង្ហក់ ព្រមទាំងបិទទ្វារបន្ទប់ទឹកនៅពីក្រោយពួកគេ។ - ខ្ញុំដឹងថា ពួកយើងនៅមិនទាន់រកឃើញថានរណាជាអ្នកធ្វើការវាយប្រហារអស់ទាំងនោះទេ ប៉ុន្តែខ្ញុំនឹងសរសេរសំបុត្រ ផ្ញើទៅប៉ានៅថ្ងៃស្អែក ប្រាប់គាត់ឲ្យឆែកក្រោម បន្ទប់ទទួលភ្ញៀវ របស់គ្រួសារមេលហ្វ័យជាក់ជាមិនខាន។

ហេរីពិនិត្យមើលមុខរបស់វានៅក្នុងកញ្ចក់ដែលប្រេះបែក។ វាប្រែរូបជាធម្មតាវិញហើយ។ វាពាក់វ៉ែនតាឡើងវិញ ខណៈពេលដែលរ៉ុនដំផាំងៗលើទ្វារបន្ទប់របស់ហឺម៉ាយអូនី។

- ហឺម៉ាយអូនី ចេញមក ពួកយើងមានរឿងជាច្រើនត្រូវប្រាប់ឯង...

- ចេញឲ្យឆ្ងាយទៅ!- ហឺម៉ាយអូនីស្រែក។

ហេរី និងរ៉ុនសម្លឹងមើលគ្នាទៅវិញទៅមក។

- តើមានរឿងអ្វី?- រ៉ុនសួរ។ - ថ្មើរនេះ ឯងច្បាស់ជាត្រលប់មករូបដើមវិញហើយ ពួកយើង...

ប៉ុន្តែម៉ុននីង មីតថលស្រាប់តែរំអិលខ្លួនកាត់ទ្វារបន្ទប់នោះចេញមក។ ហេរីមិនដែលឃើញនាងមានទឹកមុខសប្បាយយ៉ាងនេះនោះទេ។

- អ៊ូៗៗៗ ចាំតែមើលទៅ- នាងនិយាយ។ - ពិតជា*អាក្រក់*មើលណាស់!

ពួកគេឮសូរសោទ្វារបើកឡើង ហើយហឺម៉ាយអូនីបង្ហាញខ្លួនចេញមក ដោយយំខ្សឹកខ្សួល ឯរ៉ូបរបស់នាងទាញគ្របពីលើក្បាល។

- កើតអី?- រ៉ុនសួរទាំងមិនប្រាកដប្រជា។ - ឯងនៅមានច្រមុះរបស់មីលីសិនទៀត រឺមួយក៏យ៉ាងម៉េច?

ហឺម៉ាយអូនីទាញរ៉ូបនាងឲ្យធ្លាក់ចុះមក ហើយរ៉ុនស្រាប់តែថយក្រោយសំដៅទៅស្ទូកទឹក។

មុខរបស់នាងពេញសុទ្ធតែរោមពណ៌ខ្មៅ។ ភ្នែករបស់នាងទាំងពីរប្រែជាពណ៌លឿង ហើយមានត្រចៀកស្រួចៗពីរលៀនចេញពីសក់របស់នាង។

- វាជាសក់ឆ្ម...ឆ្មា!- នាងស្រែកទ្រហោយំ។ - ម...មីលីសិន បាល់ស្ត្រូដច្បាស់ជាមានឆ្មាហើយ! ហើយទ...ទឹកថ្នាំនោះមិនមែនប្រើសម្រាប់បំលែងទៅជាសត្វនោះទេ!

- ពុទ្ធោអើយ- រ៉ុនស្រដី។

- ឯងច្បាស់ជាត្រូវគេហៅឈ្មោះ*អាក្រក់ៗ*ជាមិនខាន- មីតថលនិយាយយ៉ាងសោមនស្ស។

- មិនអីទេ ហឺម៉ាយអូនី- ហេរីបន្លឺឡើងយ៉ាងរួសរាន់។ - ពួកយើងនឹងនាំឯងទៅគិលានដ្ឋាន។ អ្នកស្រីផុមហ្វ្រីមិនដែលសួរច្រើនទេ...

ត្រូវចំណាយពេលយ៉ាងយូរ ទំរាំតែបញ្ចុះបញ្ចូលហឺម៉ាយអូនីឲ្យចាកចេញពីបន្ទប់ទឹកបាន។ មុននឹង មីតថលហោះតាមពួកគេដោយសើចកក្អឹកជាប់រហូត។

- ចាំមើលតែគេដឹងថាឯងដុះ*កន្ទុយ*ទៅ!

**វគ្គ XIII**



# សៀវភៅកំណត់ហេតុដ៏សំខាន់

ហឺម៉ាយអូនី នៅតែបន្តស្នាក់នៅគិលានដ្ឋានអស់រយៈពេលបី ទៅបួនសប្តាហ៍។ មានការរំភើបជ្រួលជ្រើមដែលកើតមានភ្លាមៗចំពោះពាក្យចចាមអារ៉ាមអំពីការបាត់ខ្លួនរបស់នាង នៅពេលដែលពួកកូនសិស្សត្រលប់មកសាលាវិញក្រោយពីថ្ងៃឈប់សំរាកបុណ្យណូអែលមក។ ជាការពិតណាស់ មនុស្សរាល់គ្នាបានគិតថានាងត្រូវបានវាយប្រហារ។ ដូច្នេះ សិស្សរាល់គ្នាបានមកពពាក់ពពូនគ្នានៅទីនោះ ដើម្បីតែព្យាយាមក្រឡេកមើលនាង ដែលធ្វើឲ្យអ្នកស្រី ផុមហ្វ្រី យកវាំងននរបស់គាត់ចេញម្តងទៀត ហើយបាំងនៅជុំវិញគ្រែរបស់នាង ដើម្បីជួយលាក់បាំងភាពអាម៉ាស់របស់នាងមិនឲ្យគេឃើញនាងដោយសារតែមុខនាងមានដុះរោមសត្វ។

ហេរី និងរ៉ុន បានទៅសួរសុខទុក្ខនាងរាល់ពេលរសៀលមកដល់។ នៅពេលដែលឆមាសថ្មីចាប់ផ្តើម ពួកគេបាននាំយកកិច្ចការសាលាប្រចាំថ្ងៃអោយនាង។

- ប្រសិនបើខ្ញុំអាចបណ្តុះពុកមាត់បាន ខ្ញុំនឹងមានពេលសំរាកពីកិច្ចការទាំងនេះបានហើយ- រ៉ុននិយាយ ព្រមទាំងទំលាក់ផ្នឹមសៀវភៅជាច្រើនទៅលើតុជិតគ្រែហឺម៉ាយអូនីនៅល្ងាចមួយ។

- កុំធ្វើដូចជាកូនក្មេងណ៎ា រ៉ុន ខ្ញុំត្រូវរៀនឲ្យទាន់កម្មវិធីសិក្សា - ហឺម៉ាយអូនីតបយ៉ាងរហ័ស។ ស្មារតីរបស់នាងកាន់តែល្អប្រសើរឡើង ដោយហេតុថារោមទាំងអស់នៅលើមុខរបស់នាងបានបាត់អស់ ហើយភ្នែករបស់នាងបានប្រែមកជាពណ៌ត្នោតវិញបន្តិចម្តងៗ។

- ខ្ញុំមិនគិតថាឯងទទួលបានព័ត៌មានថ្មីៗអីទេ មែនរឺទេ?- នាងនិយាយបន្ថែមដោយខ្សឹបៗ ដើម្បីកុំឲ្យអ្នកស្រី ផុមហ្វ្រី លឺនាងនិយាយ។

- គ្មានអ្វីទេ។- ហេរីបានឆ្លើយតបទាំងទឹកមុខក្រៀមក្រំ។

- ខ្ញុំប្រាកដក្នុងចិត្តណាស់ ច្បាស់ជាមេលហ្វ័យហើយ- រ៉ុនពោល ប្រហែលជាលើកទីមួយរយហើយ។

- តើនោះជាអ្វី?- ហេរីបានសួរ ដោយចង្អុលទៅវត្ថុម្យ៉ាងពណ៌មាស លៀនចេញមកក្រៅខាងក្រោមខ្នើយរបស់ហឺម៉ាយអូនី។

- ជាកាតជូនពរឲ្យឆាប់ជាសះស្បើយហ្នឹងណ៎ា - ហឺម៉ាយអូនីនិយាយយ៉ាងលឿង ដោយព្យាយាមលាក់វាឲ្យផុតពីក្រសែភ្នែកអ្នកដទៃ។ ប៉ុន្តែរ៉ុនលឿនជាងនាងទៅទៀត វាបានកញ្ឆក់យក ហើយបើកវា រួចអានខ្លាំងៗ។

*- ពីហ្គីលដឺរ័យ ឡក់ហាត សង្ឃឹមថាឯងនឹងឆាប់ជាសះស្បើយ ពីគ្រូដែលខ្វល់ខ្វាយពីឯង សាស្ត្រាចារ្យ ហ្គីលដឺរ័យ ឡក់ហាត ខ្សែស្រឡាយខាង មើលីន ថ្នាក់ទីបី ជាសមាជិកកិត្តិយសក្នុងក្រុមសម្ព័ន្ធការពារប្រឆាំងមន្តអាគមងងឹត និងជាអ្នកឈ្នះប្រាំលើកនូវពានរង្វាន់វេទតួប្រចាំសប្តាហ៍ដែលស្នាមញញឹមមានមន្តស្នេហ៍ជាងគេ។*

រ៉ុន ក្រឡេកមើលមក ហឺម៉ាយអូនី ដោយឆ្ងើម។

- តើឯងដេកដោយដាក់កាតនេះនៅក្រោមខ្នើយរឺ?

ប៉ុន្តែហឺម៉ាយអូនីមិនទាន់ទាំងឆ្លើយតបវិញផង ស្រាប់តែអ្នកស្រី ផុមហ្ប្រី ដើរផាត់ផាយមកជាមួយនឹងថ្នាំសំរាប់ផឹកពេលល្ងាចរបស់នាង។

- តើ ឡក់ហាត ពិតជាមនុស្សពូកែវោហាបំផុតដែលឯងធ្លាប់ជួបមែន រឺក៏យ៉ាងណា?- រ៉ុន និយាយទៅកាន់ហេរី ពេលដែលពួកគេបានចាកចេញពីបន្ទប់ ហើយឡើងកាំជណ្តើរឆ្ពោះទៅអគារហ្គ្រីហ្វីនដ័រ។ ស្នេពបានដាក់កិច្ចការផ្ទះឲ្យពួកគេធ្វើច្រើនណាស់។ ហេរីគិតថា វាទំនងជាត្រូវរៀនដល់ឆ្នាំទីប្រាំមួយហើយទើបធ្វើអស់។ រ៉ុនទើបតែនិយាយថា វាបន់ថាវាបានសួរហឺម៉ាយអូនីថាតើយើងត្រូវដាក់កន្ទុយកណ្តុរប៉ុន្មានបន្ថែមទៅក្នុងទឹកថ្នាំបណ្តុះសក់ ស្រាប់តែមានកំហឹងផ្ទុះមកពីជាន់លើ ឮមកដល់ត្រចៀកពួកគេ។

- នោះច្បាស់ជាហ្វីលច្ចហើយ- ហេរីនិយាយតិចៗ ខណៈពេលដែលពួកគេប្រញាប់រត់ទៅជណ្តើរ ហើយផ្អាកដំណើររកកន្លែងពួនកុំឲ្យគេឃើញ រួចចាំផ្ទៀងត្រចៀកស្តាប់យ៉ាងម៉ត់ចត់។

- តើឯងមិនគិតថាមាននរណាម្នាក់ទៀតត្រូវបានវាយប្រហារទេរឺ?- រ៉ុនសួរទាំងសំលេងតឹង។

ពួកគេងើបឈរយ៉ាងស្ងៀមស្ងាត់ ក្បាលរបស់ពួកគេទេរទៅជិតប្រភពសំលេងរបស់ហ្វីលច្ច ដែលស្តាប់មើលទៅដូចជារំជួលចិត្តខ្លាំងណាស់។

*- មានបន្ថែមការងារជាច្រើនមកឲ្យខ្ញុំទៀត! ត្រូវជូតសំអាតទាំងយប់ ដូចជាខ្ញុំធ្វើការងារមិនទាន់គ្រប់គ្រាន់ហើយអញ្ចឹង! ទេទ្រាំតែម្តងនេះទៀតទេ តែលើកក្រោយមានទៀត ខ្ញុំច្បាស់ជានឹងទៅជួបលោកដាំប៊័លដ័រហើយ...*

ស្នូរជើងរបស់គាត់រសាត់ស្ងាត់ទៅតាមបណ្តោយផ្លូវរបៀងដាច់កន្ទុយភ្នែក ហើយពួកគេឮសម្លេងទ្វារបិទគ្រាំងពីចម្ងាយ។

ពួកគេឈរអេះក្បាលនៅកាច់ជ្រុងនោះ។ ជាក់ស្តែងណាស់ ហ្វីលច្ច កំពុងតែយាមកាមនៅកន្លែងកើតហេតុដូចសព្វដង៖ ពួកគេកំពុងតែស្ថិតនៅកន្លែងដែល អ្នកស្រី ណូរីស ទទួលរងការវាយប្រហារ។ ពួកគេបានឃើញនូវចំនុច ដែលហ្វីលច្ចកំពុងតែស្រែកឡូឡាដាក់ហើយ។ មានទឹកជាច្រើនជន់លិចអស់ពាក់កណ្តាលផ្លូវរបៀង ហើយមើលទៅទឹកនោះហាក់ដូចជានៅតែជ្រាបចេញពីក្រោមទ្វារបន្ទប់ទឹករបស់ ម៉ុននីង មីតថល ដដែលទេ។ ឥលូវ ហ្វីលច្ច ឈប់ស្រែក ពួកគេអាចស្តាប់ឮសម្លេងទ្រហោយំរបស់មីតថលនៅឯម្ខាងជញ្ជាំងបន្ទប់ទឹក។

- ឥលូវតើនាងមានរឿងអី?- រ៉ុននិយាយទៅកាន់ហេរី។

- តោះ! ទៅមើល!- ហេរីនិយាយ ហើយក៏លើកអាវរ៉ូបរបស់ពួកគេអោយផុតពីកជើង បន្ទាប់មកពួកគេបានលុយទឹកសំដៅទៅទ្វារដែលដាក់ផ្លាក "មិនអាចប្រើការបាន" ប៉ុន្តែពួកគេមិនរវីរវល់ឡើយ រួចក៏ចូលទៅមើល។

ម៉ុននីង មីតថលកំពុងតែព្យាយាមយំឲ្យកាន់តែខ្លាំងឡើងៗជាងមុនទៅទៀត។ នាងហាក់ដូចជាកំពុងពួននៅខាងក្រោមបង្គន់របស់នាងជាធម្មតា។ មានសភាពងងឹតនៅក្នុងបន្ទប់នោះ ពីព្រោះមានទៀនជាច្រើនបានរលត់ដោយសារទឹកហូរយ៉ាងខ្លាំង ដែលធ្វើឲ្យជញ្ជាំងទាំងពីរ និងកំរាលឥដ្ឋសើមជោក។

- តើមានរឿងអ្វី មីតថល?- ហេរីសួរដោយងឿងឆ្ងល់។

- តើអ្នកណាហ្នឹង?- មីតថលនិយាយទាំងអួលណែនដើមក។ - មកគប់របស់ដាក់ខ្ញុំទៀតហើយ មែនទេ?

ហេរីលុយទឹកឆ្ពោះទៅរកបន្ទប់របស់នាង ហើយនិយាយៈ

- តើហេតុអ្វីបានជាខ្ញុំត្រូវគប់របស់ដាក់នាង?

- កុំសួរខ្ញុំ- មីតថលស្រែក ព្រមទាំងងើបឡើងមក ធ្វើឲ្យសាចទឹកជាច្រើនទៅលើកំរាលឥដ្ឋ ដែលទទឹកស្រាប់ទៅហើយនោះ។ - ខ្ញុំនៅតែទីនេះសោះ មិនដែលទៅលូកដៃក្នុងរឿងនរណាឡើយ តែបែរជាមានគេគិតថា វាជារឿងសប្បាយក្នុងការគប់សៀវភៅដាក់ខ្ញុំ...

- ប៉ុន្តែវាមិនអាចធ្វើអោយនាងឈឺចាប់ឡើយ ប្រសិនបើនរណាម្នាក់គប់របស់ដាក់នាងនោះ- ហេរីនិយាយ ដោយសមហេតុផល។ - ខ្ញុំចង់មានន័យថា វានឹងច្បាស់ជាហោះធ្លុះខ្លួនរបស់នាង មិនថាអ៊ីចឹងរឺ?

វានិយាយខុសហើយ។ មីតថលស្ទុះហោះឡើងមក ហើយស្រែកដូចចង្រិតៈ

- តោះ! ទាំងអស់គ្នា ទៅគប់សៀវភៅដាក់មីតថល ព្រោះនាងគ្មានអារម្មណ៍ឈឺទេ។ ដប់ពិន្ទុប្រសិនបើអាចគប់ចំពោះរបស់នាង! ហាសិបពិន្ទុប្រសិនបើគប់ត្រូវក្បាលរបស់នាង! ហា ហា ហា! ល្បែងអ្វីក៏សប្បាយម្ល៉េះទេ ខ្ញុំមិនគិតអញ្ចឹងទេ!

- និយាយអញ្ចឹង តើនរណាគប់នាងទៅ?- ហេរីបានសួរ។

- ខ្ញុំមិនដឹងទេ......ខ្ញុំអង្គុយលើបង្គន់ កំពុងគិតពីរឿងមរណភាព ហើយវាក៏ធ្លាក់ចុះពីលើក្បាលរបស់ខ្ញុំមកដល់ក្រោមតែម្តង- មីតថលឆ្លើយប្រាប់ ដោយសម្លឹងសម្លក់ពួកគេ។ - វានៅទីនោះ វាទទឹកអស់ហើយ...

ហេរី និងរ៉ុនក្រឡេកមើលក្រោមស្នូកទឹក ដែលមីតថលចង្អុល។ មានសៀវភៅតូចស្តើងមួយក្បាលនៅទីនោះ។ វាមានគំរបពណ៌ខ្មៅរយាក និងទទឹកជោកទៀតផង។

- ស្អីគេហ្នឹង?- ហេរីសួរ។

- ឯងឆ្កួតទេរឺ? វាអាចមានគ្រោះថ្នាក់ណា- រ៉ុនស្តីអោយហេរី។

- គ្រោះថ្នាក់រឺ? ហេរីសើច។ - ឈប់គិតអញ្ចឹងទៅ តើវាមានគ្រោះថ្នាក់យ៉ាងណាបាន?

- ឯងច្បាស់ជានឹងភ្ញាក់ផ្អើលជាមិនខាន- រ៉ុននិយាយ ព្រមទាំងសម្លឹងមើលទៅសៀវភៅនោះ។ - សៀវភៅមួយចំនួនដែលក្រសួងបានរឹបអូសតាមដែលប៉ាខ្ញុំប្រាប់...មានសៀវភៅមួយក្បាលនោះធ្វើឲ្យភ្នែករបស់ឯងឆេះខ្លោចទៀតផង។ ហើយអ្នកណាក៏ដោយឲ្យតែបានអានសៀវភៅ *កវីនិពន្ធដប់បួនបាទនៃវេទគូ* និយាយបានតែភាសាកំនាព្យប្រាំជួរដែលគ្មានទំនុកសូត្រអស់មួយជីវិត។ ហើយមេធ្មប់ចំនាស់ម្នាក់នៅស្រុក បាស មានសៀវភៅមួយក្បាលដែលឯងមិនអាចឈប់អានបានឡើយ! ទោះជាដើរទៅណាមកណា ត្រូវតែមើលសៀវភៅនោះជាប់ជានិច្ច ហើយបើធ្វើការវិញប្រើបានតែដៃម្ខាងទេ។ ហើយ...

- មិនអីទេ ខ្ញុំយល់ហើយ- ហេរីនិយាយ។

សៀវភៅនោះត្រូវទុកចោលនៅលើកំរាលឥដ្ឋ មានសភាពរញ៉េរញ៉ៃ និងទទឹកល្បៀច។

- បើយើងមិនទាន់បានមើលផង ម៉េចនឹងដឹងទៅ- ហេរីឆ្លើយ រួចទៅរើសសៀវភៅនោះ។

ហេរីមើលដឹងភ្លាមថាវាគឺជាសៀវភៅកំណត់ហេតុមួយ ហើយឆ្នាំរលុបៗនៅឯក្របសៀវភៅនោះប្រាប់វាថាសៀវភៅនោះមានអាយុកាលហាសិបឆ្នាំមកហើយ។ វាបើកសៀវភៅនោះមើលដោយចង់ដឹង។ នៅទំព័រទីមួយ វាអានដាច់តែពាក្យថា "ថ. ម. រីតដល" សរសេរជាទឹកខ្មៅប្រលាក់ប្រឡូស។

- ឈប់សិន- រ៉ុនស្រដី។ វាដើរខិតមកជិតយ៉ាងប្រយ័ត្នប្រយែង ហើយអើតមើលពីលើស្មារបស់ហេរី។ - ខ្ញុំស្គាល់ឈ្មោះនេះ...ថ. ម. រីតដល ទទួលបានពានរង្វាន់សំរាប់ សេវាកម្មពិសេសចំពោះសាលា កាលពីហាសិបឆ្នាំមុន។

- ម៉េចក៏ឯងដឹងពីរឿងនេះ?- ហេរីសួរដោយងឿងឆ្ងល់។

- ពីព្រោះហ្វីលច្ចបានបានដាក់ពិន័យឲ្យខ្ញុំជូតសំអាតរបាំងការពាររបស់គាត់ប្រហែលជាហាសិបដងមកហើយ។- រ៉ុនប្រាប់ហេរីទាំងមិនសប្បាយចិត្ត - ពានរង្វាន់នោះហើយដែលខ្ញុំក្អួតលើធ្វើឲ្យប្រលាក់ខ្ទង់ឥតស្នូកពាសពេញ។ ប្រសិនបើឯងត្រូវជូតសំអាតឈ្មោះនោះអស់រយៈពេលមួយម៉ោង ឯងក៏ប្រាកដជាចងចាំឈ្មោះនោះដែរ។

ហេរីបើកសៀវភៅនោះមើល តែទទេស្អាត ព្រោះសន្លឹកនីមួយៗគ្មានអក្សរទាល់តែសោះ គ្មានសូម្បីតែ "ខួបកំណើតរបស់អ្នកមីងម៉ាបេល" រឺក៏ "ពេទ្យធ្មេញ ម៉ោងបីកន្លះ" ក៏គ្មាន។

- គាត់មិនដែលបានសរសេរទេ- ហេរីនិយាយទាំងអស់សង្ឃឹម។

- ខ្ញុំមិនយល់សោះថា ហេតុអ្វីបានជាមានមនុស្សចង់បំផ្លាញវាចោល?- រ៉ុនសួរដោយមន្ទិល។

ហេរីត្រលប់សៀវភៅនោះមកក្របខាងក្រោយ ហើយក៏ឃើញឈ្មោះបោះពុម្ពរបស់ហាងលក់សម្ភារៈសព្វសារពើនៅតាមផ្លូវវ៉ូចស៍ហល ក្រុងឡុង។

- គាត់ច្បាស់ជាកើតចេញពីពួកលោកិយហើយ- ហេរីនិយាយយ៉ាងយកចិត្តទុកដាក់។ - បានជាអាចទិញសៀវភៅកំណត់ហេតុពីតូបលើផ្លូវ វ៉ូចស៍ហល បាន...

- ចំពោះឯងវាគ្មានប្រយោជន៍អ្វីទេ- រ៉ុននិយាយ។ វាទម្លាក់សម្លេង។ - ហាសិបពិន្ទុប្រសិនបើគប់ត្រូវច្រមុះរបស់មីតថល។

ប៉ុន្តែហេរីបានដាក់វាចូលក្នុងហោប៉ៅទៅហើយ។

*

ហឺម៉ាយអូនី ចាកចេញពីគិលានដ្ឋាននៅដើមខែកុម្ភៈ ដោយមិនមានពុកមាត់ មិនមានកន្ទុយ និងគ្មានរោមទៀតទេ។ ហេរី បានឲ្យនាងមើលសៀវភៅកំណត់ហេតុរបស់ រីតដល ហើយបានប្រាប់នាងអំពីដំណើររឿងនៃការរើសបានសៀវភៅនោះ។

- ហ៊ឺ ... វាប្រាកដជាមានលាក់បំពួននូវមន្តអាគមអាថ៌កំបាំងអ្វីមួយជាមិនខាន- ហឺម៉ាយអូនីយកវាមកមើលយ៉ាងល្អិតល្អន់។

- ប្រសិនបើមានមែន ច្បាស់ជាលាក់យ៉ាងល្អិតល្អន់បំផុតហើយ- រ៉ុនបន្ទរ។ - ប្រហែលជាវាអៀនហើយ។ ហេរី ខ្ញុំមិនយល់ទាល់តែសោះ ហេតុអ្វីបានជាឯងមិនបោះវាចោល?

- ប្រសិនបើខ្ញុំដឹងថា ហេតុអ្វីបានជាមានមនុស្សបោះវាចោល គឺល្អហើយ- ហេរីពោល - ហើយខ្ញុំក៏ចង់ដឹងដែរថាតើ រីតដលបានធ្វើអ្វីខ្លះជាពិសេសទើបទទួលបានរង្វាន់ពីសាលាហុកវ៉ាត។

- អាចបណ្តាលមកពីរឿងច្រើនយ៉ាងណាស់- រ៉ុននិយាយ។ - ប្រហែលជាគេទទួលបានពិន្ទុប្រឡង ក.ប.វ.ក.ស. សាមសិបពេញ រឺក៏គេបានជួយសង្គ្រោះគ្រូបង្រៀនណាម្នាក់ចេញពីមាត់ត្រីមឹកដ៏ធំសំបើម រឺក៏ប្រហែលជាគេបានសំលាប់មីតថល។ ទាំងនេះសុទ្ធតែជារឿងដែលជួយយកអាសាអ្នកទាំងអស់គ្នាហើយ...

ប៉ុន្តែហេរីអាចមើលដឹងតាមរយៈទឹកមុខដ៏ប្រុងប្រយ័ត្នរបស់ហឺម៉ាយអូនីថា វា និងនាងកំពុងតែគិតដូចគ្នា។

- ស្អីគេ?- រ៉ុនក្រឡេកមើលមុខម្នាក់ម្តងៗ។

- គឺថា មានគេបានបើកបន្ទប់សំងាត់កាលពីហាសិបឆ្នាំមុន មែនទេ?- វានិយាយ។ - មេលហ្វ័យនិយាយដូច្នេះ។

- មែន...- រ៉ុននិយាយយឺតៗ។

- ហើយសៀវភៅកំណត់ហេតុនេះក៏មានអាយុកាលហាសិបឆ្នាំដែរ- ហឺម៉ាយអូនីស្រដី ព្រមទាំងគោះសៀវភៅនោះយ៉ាងរំភើបចិត្ត។

- ហើយវាយ៉ាងម៉េច?

- អូ! រ៉ុន ភ្ញាក់ឡើង។- ហឺម៉ាយអូនីនិយាយម៉ាត់ៗ។ - ពួកយើងដឹងថា អ្នកដែលបានបើកបន្ទប់សម្ងាត់នោះ ត្រូវបានគេបណ្តេញចេញពីសាលាកាលពីហាសិបឆ្នាំមុន។ ហើយពួកយើងក៏បានដឹងដែរថា រីតដល បានធ្វើរឿងពិសេសមួយដ៏មានប្រយោជន៍ដើម្បីសាលា ហើយក៏បានទទួលរង្វាន់ពីសាលាកាលពីហាសិបឆ្នាំមុន។ - អញ្ចឹង ចុះបើ រីតដល ទទួលបានពានរង្វាន់ពិសេស ដោយសារតែចាប់បានទាយាទស្លីតឺរីននោះ? សៀវភៅកំណត់ហេតុរបស់គាត់ប្រហែលជាប្រាប់ពួកយើងបាននូវរឿងគ្រប់យ៉ាង ... ថាតើ បន្ទប់សំងាត់នៅឯណា តើយើងអាចបើកវាយ៉ាងដូចម្តេច ហើយថាតើ សត្វចម្លែកប្រភេទណារស់នៅក្នុងបន្ទប់នោះ ... ជនដែលស្ថិតនៅពីក្រោយការវាយប្រហារទាំងនេះ នាពេលនេះពិតជាមិនចង់ឲ្យមានបន្សល់ទុកភ័ស្តុតាងឡើយ មិនថាអញ្ចឹងរឺ?

- ហឺម៉ាយអូនី នេះគឺជាទ្រឹស្តីដ៏អស្ចារ្យមួយ- រ៉ុននិយាយ - ទាស់តែត្រង់ថា *ក្នុងសៀវភៅនោះគ្មានសរសេរអក្សរមួយតួសោះ។*

ប៉ុន្តែ ហឺម៉ាយអូនី យកចង្កឹះវេទមន្តរបស់នាងចេញពីក្នុងកាតាបស្រេច។

- វាប្រហែលជាទឹកថ្នាំបំបាំងកាយ!- នាងនិយាយខ្សឹបៗ។

នាងគោះសៀវភៅនោះបីដង ហើយនិយាយៈ

- *អាផារីស៊ីអ៊ុម!*

គ្មានអ្វីកើតឡើងទាល់តែសោះ។ ដោយមិនរួញរា ហឺម៉ាយអូនីបានលូកដៃចូលទៅក្នុង កាតាបយកវត្ថុមួយដែលមានរូបរាងជាជ័រលុបមានពណ៌ក្រហម។

- នេះជាឧបករណ៍លាតត្រដាង ខ្ញុំទិញវានៅផ្លូវកាត់ទទឹង- នាងបាននិយាយ។

នាងបានប្រើកំលាំងយកវាលុបត្រង់អក្សរថ្ងៃទីមួយខែមករា ប៉ុន្តែគ្មានអ្វីកើតឡើងទាល់តែសោះ។

- ខ្ញុំប្រាប់ឯងហើយ គ្មានសរសេរអក្សរអ្វីក្នុងសៀវភៅនេះទេ- រ៉ុននិយាយ។ - រីតដលគ្រាន់តែទទួលបានអំណោយជាសៀវភៅកំណត់ហេតុទទេស្អាតមួយក្នុងឱកាសបុណ្យណូអែលតែប៉ុននោះ ហើយមិនមានបំនងសរសេរអ្វីក្នុងនោះទេ។

ហេរីក៏មិនដឹងដែរ ថាហេតុអ្វីបានជា ខ្លួនមិនព្រមបោះសៀវភៅកំណត់ហេតុរបស់រីតដលចោល។ តាមការពិតទោះបីជាហេរីដឹងថា វាជាសៀវភៅកំណត់ហេតុទទេមួយក៏ដោយ ក៏ហេរីនៅតែទ្រាំមិនបានយកវាមកបើកមើល ហាក់ដូចជាសៀវភៅនោះមានសរសេររឿងនិទានដែលវាចង់អានឲ្យចប់អ៊ីចឹង។ ទោះជាហេរីប្រាកដថា វាមិនដែលឮឈ្មោះរីតដលនេះពីមុនមកក៏ដោយ ប៉ុន្តែឈ្មោះនេះហាក់ដូចជាមានអត្ថន័យម្យ៉ាងចំពោះវាយ៉ាងម៉េចទេ ប្រៀបដូចជារីតដលគឺជាមិត្តរបស់វាកាលពីតូច ដែលវាភ្លេចរកនឹកមិនឃើញ។ ប៉ុន្តែវាមិនសមហេតុផលសោះ ព្រោះពេលចូលហុកវ៉ាតដំបូង ហេរីមិនមានមិត្តទាល់សោះ។ ដាត់លីអាចបញ្ជាក់រឿងនេះបាន។

មិនថាយ៉ាងមេចទេ ហេរីប្តេជ្ញាចិត្តថា នឹងស្វែងយល់ពីរីតដលអោយបានច្រើនបន្តិច ដូច្នេះពេលព្រឹកថ្ងៃបន្ទាប់ ហេរីជាមួយនឹងហឺម៉ាយអូនីដែលមានការចាប់អារម្មណ៍ និងរ៉ុនដែលមិនព្រមជឿទាំងស្រុង ទៅបន្ទប់ជ័យភណ្ឌដើម្បីត្រួតពិនិត្យមើល រង្វាន់

របស់រីតដល។ តាមផ្លូវ រ៉ុនរអ៊ូប្រាប់ពួកគេថា វាមើលបន្ទប់ជ័យភណ្ឌនោះឆ្អែតឆ្អន់ហើយ មិនបាច់មកទៀតក្នុងមួយជាតិនេះក៏មិនទាស់ខុសអីដែរ។

ខែលធ្វើពីមាសភ្លឺរលោងរបស់ រីតដល ត្រូវគេយកទៅដាក់នៅក្នុងទូងជ្រុងម្ខាងនៃបន្ទប់។ ខែលនោះមិនបានសរសេរអ្វីជាលំអិតអំពីមូលហេតុដែលរីតដលទទួលបានរង្វាន់នេះទេ (- ក៏ជារឿងល្អម្យ៉ាងដែរ បើមិនអញ្ចឹងទេ សាកតែធំជាហ្នឹងមើល ខ្ញុំប្រហែលជានៅតែជូតសំអាតវានៅឡើយនោះទេ- រ៉ុនពោល។ ទោះបីជាយ៉ាងណាក៏ដោយ ទីបំផុតពួកគេអាចរកឈ្មោះរបស់រីតដលឃើញនៅលើបញ្ជីឈ្មោះអ្នកទទួលបានពានរង្វាន់គុណូបការៈវេទមន្តចាស់ៗ ហើយនិងនៅលើបញ្ជីឈ្មោះប្រធានក្រុមសិស្សចាស់ៗ។

- ស្តាប់មើលទៅ គាត់ដូចតែពឿរស៊ីដែរ- រ៉ុនស្អប់ខ្ពើមឡើងជ្រួញច្រមុះ។ - អនុរក្សក្រុមសិស្សច្បង ប្រធានក្រុមសិស្ស...ជាប់លេខមួយគ្រប់មុខវិជ្ជា...

- ឯងនិយាយចេញមកដូចវាជារឿងអាក្រក់ខ្លាំងណាស់អញ្ចឹង- ហឺម៉ាយអូនីឆ្លើយតបទាំងឈឺចុកចាប់។

*

ឥឡូវ ព្រះអាទិត្យចាប់ផ្តើមចែងចាំងរស្មីយ៉ាងខ្សោយពីលើសាលាហុកវ៉ាតទៀតហើយ។ នៅក្នុងប្រាសាទ ចាប់ផ្តើមមានក្តីសង្ឃឹមជាងមុន។ ចាប់ពី ចាស់ស្ទីន និង នីកស្ទើរឥតក្បាលមក លែងមានការវាយប្រហារតទៅទៀតហើយ។ អ្នកស្រីផុមហ្រ្វីសប្បាយរីករាយនឹងរាយការណ៍ថា ដើមម៉ាន់ឌ្រេក បានប្រែទៅជាឆេវឆាវ និងចេះលាក់ការសម្ងាត់ នេះបញ្ជាក់ថាពួកគេលូតលាស់ធំធាត់ហើយ។

- នៅពេលដែលមុនរបស់ពួកវាបាត់អស់ហើយ នឹងអាចយកពួកវាទៅដាក់ដាំផើងផ្សេងបានហើយ- ហេរីឮគាត់ប្រាប់ហ្វីលច្ឆយ៉ាងចិត្តល្អនៅថ្ងៃមួយពេលរសៀល។

- បន្ទាប់មក វានឹងមិនចំនាយពេលយូរនោះទេ ទំរាំដល់ពេលយើងកាត់ដើមវាយកមកស្ល។ អ្នកស្រី ណូរីស នឹងឆាប់ជាសះស្បើយមិនយូរនោះទេ។

ហេរីគិតថា ប្រហែលជាទាយាទ ស្លីគីរីន លះបង់គំនិតរបស់គេហើយ។ សាលាទាំងមូល កំពុងតែមានស្មារតីប្រុងប្រយ័ត្នខ្ពស់ និងពោរពេញដោយភាពសង្ស័យ ជាហេតុធ្វើឲ្យការបើកបន្ទប់សំងាត់កាន់តែមានគ្រោះថ្នាក់ឡើងៗ។ ប្រហែលជាបិសាចនោះ មិនថាវាជាអ្វីក៏ដោយ ឥលូវកំពុងតែភៀសទៅលាក់ខ្លួនពួនសំងំរង់ចាំរយៈពេលហាសិបឆ្នាំទៀតហើយ...

អើនី មេកស៍មីលេន ក្នុងក្រុម ហាហ្វ៉លផហ្វ នៅតែមិនគិតថានេះជារឿងគួរឲ្យត្រេកអរឡើយ។ វានៅតែយល់ថាហេរីជាអ្នកមានកំហុស ជឿថាវាបាន "ទម្លាយអាថ៌កំបាំងរបស់ខ្លួននៅឯក្រុមប្រយុទ្ធតតាំង។ ភីវកាន់តែធ្វើបញ្ហាឲ្យកាន់តែស្មុគស្មាញថែមទៀត។ គាត់នៅតែបន្តបង្ហាញខ្លួននៅក្នុងផ្លូវរបៀងមានមនុស្សកកកុញ ហើយច្រៀងថា៖

- ឱ! ផោតផ័រ អាមនុស្សកំហូច...- ហើយឥលូវនៅមានប្រើកាយវិការទៀត។

ហ្គីលដឺរ័យ ឡក់ហាត ហាក់ដូចជាយល់ថា ខ្លួនគាត់ជាអ្នកបញ្ឈប់ការវាយប្រហារនេះអញ្ចឹង។ ហេរីស្តាប់ឮគាត់និយាយប្រាប់សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលដោយចៃដន្យថាដូច្នោះ ខណៈពេលដែលសិស្សក្រុមហ្គ្រីហ្វីនដ័រកំពុងតំរង់ជួរចូលរៀនមុខវិជ្ជានិម្មិតកម្ម។

- ខ្ញុំគិតថាគ្មានអ្វីគួរខ្វាយខ្វល់ទៀតទេ មីណែរវ៉ា- គាត់អង្អែលច្រមុះស្រាលៗ ហើយមិចភ្នែក។ - ខ្ញុំគិតថាបន្ទប់សំងាត់នឹងត្រូវបិទទ្វារជារៀងរហូត។ ឃាតករប្រហែលជាដឹងខ្លួនថា មិនយូរនោះទេ ខ្ញុំប្រាកដជានឹងចាប់ពួកគេបាន។ ចេះឆ្លាតដែរមកបញ្ឈប់សកម្មភាពក្នុងពេលនេះ ខ្លាចខ្ញុំលែងធម៌ក្ដៅដាក់។

- លោកដឹងទេ ឥលូវក្នុងសាលា ត្រូវការជនគំរូម្នាក់ដើម្បីលើកកំពស់សីលធម៌។ សូមបំភ្លេចចោលនូវរឿងរ៉ាវកាលពីឆមាសមុនទៅ! ខ្ញុំនឹងមិននិយាយអ្វីទៀតទេពេលនេះ ប៉ុន្តែខ្ញុំដឹងថាត្រូវតែធ្វើដូច្នេះ...

គាត់បានអង្អែលច្រមុះម្ដងទៀត ហើយដើរចេញ។

គំនិតរបស់ឡក់ហាតក្នុងការធ្វើជាជនគំរូក្នុងការលើកកំពស់សីលធម៌ ត្រូវបានដឹងច្បាស់លាស់អស់ហើយនៅពេលស្រស់ស្រូបអាហារពេលព្រឹកថ្ងៃទីដប់បួនខែកុម្ភៈ។ ហេរីដេកមិនបានឆ្អែតទេ ដោយសារតែការហាត់សមកីឡា ឃ្វីដឌីច្ចរហូតដល់យប់ជ្រៅពេក ហើយវាត្រូវប្រញាប់ប្រញាល់ទៅកាន់មហាសាល រាងយឺតបន្តិច។ ស្រាប់តែដល់ពេលនោះ វាគិតថាវាបានដើរចូលច្រឡំទ្វារ។

គ្រប់ជញ្ជាំងទាំងអស់ត្រូវបានផ្កាពណ៌ផ្កាឈូកគ្របដណ្ដប់ជុំជិត។ រឺរទៅទៀតនោះ គឺមានផ្កាក្រដាសរាងបេះដូងកំពុងតែធ្លាក់ពីពិតានពណ៌ខៀវស្រទ្បែត។ ហេរីដើរដល់តុក្រុម ហ្គ្រីនហ្វីនដ័រ ឃើញរ៉ុនកំពុងតែអង្គុយមិនសប្បាយចិត្ត ចំនែកហឺម៉ាយអូនីកំពុងតែប្រឹងទប់សំណើច។

- តើមានរឿងអ្វីកើតឡើង?- ហេរីសួរពួកគេ ព្រមទាំងអង្គុយចុះ ហើយបបោសផ្កាក្រដាសចេញពីលើខ្លាញ់ជុំប្រឡាក់របស់វា។

រ៉ុនចង្អុលដៃទៅតុរបស់គ្រូៗ ជាក់ស្ដែងគឺថាខ្ពើមរអើមរហូតដល់និយាយលែងចេញ។ ឡក់ហាត ដែលពាក់អាវផាយពណ៌ផ្កាឈូកឲ្យស៊ីគ្នាទៅនឹងការតុបតែងទាំងនោះ កំពុងតែគ្រវីដៃសូមភាពស្ងាត់ស្ងៀម។ គ្រូពីរនាក់នៅសង្ខាងគាត់មើលទៅមុខរឹងដូចថ្ម។ ពីកន្លែងដែលវាអង្គុយ ហេរីអាចឃើញសាច់ដុំថ្ពាល់របស់សាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល កំពុងលោតផ្លោតៗ។ ស្នេពមើលទៅហាក់ដូចជាមានមនុស្សទើបតែបញ្ចុកថ្នាំបណ្ដុះឆ្អឹងគាត់មួយស្លាបព្រាធំអ៊ីចឹង។

- រីករាយថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់!- ឡក់ហាតស្រែក។ - ហើយខ្ញុំសូមអរគុណទៅដល់មនុស្សសែសិបប្រាំមួយនាក់ដែលបានផ្ញើកាតជូនពរមកឲ្យខ្ញុំ! មែនហើយ ខ្ញុំទទួលបានសិទ្ធិអនុញ្ញាតក្នុងការរៀបចំការភ្ញាក់ផ្អើលបន្តិចបន្តួចនេះសំរាប់អ្នកទាំងអស់គ្នា...ហើយវាមិនមែនមានតែប៉ុណ្ណឹងនោះទេ!

ឡក់ហាតទះដៃ ហើយមានមនុស្សកន្លើរាងមួម៉ៅដប់ពីរនាក់ដើរចូលមកតាមច្រកចូលសាល។ ពួកគេមិនមែនគ្រាន់តែជាពួកមនុស្សកន្លើប៉ុណ្ណោះទេ។ ឡក់ហាតបានអោយពួកគេពាក់ស្លាបមាស ព្រមទាំងកាន់ពិណម្នាក់មួយផង។

- មិត្តជួយកាន់កាតជូនពរដ៏រាក់ទាក់របស់ខ្ញុំទាំងឡាយ!- ឡក់ហាតបានញញឹម។ - ពួកគេថ្ងៃនេះនឹងមកសាលាជួយចែកចាយកាតជូនពរថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់! បរិយាកាសរីករាយថ្ងៃនេះមិនមែនចប់តែត្រឹមហ្នឹងនោះទេ! ខ្ញុំសង្ឃឹមថា សហការីរបស់ខ្ញុំទាំងឡាយនឹងចូលរួមជួយធ្វើឲ្យកម្មវិធីនេះកាន់តែមានភាពអធិកអធមថែមមួយកម្រិតទៀត។ ហេតុអ្វីក៏មិនសុំសាស្ត្រាចារ្យស្នេពឲ្យគាត់បង្ហាត់បង្ហាញពីវិធីស្លថ្នាំស្នេហាតែម្ដងទៅ! ហើយក្នុងឱកាសនេះផងដែរ លោកសាស្ត្រាចារ្យ ហ្វ្លីតវីក យល់ដឹងច្រើនអំពីការដាក់មន្តស្នេហ៍ជាជាងវេទគុណាៗទាំងអស់ ដែលខ្ញុំធ្លាប់ជួបប្រទះ ពិតជាតាកញ្ចាស់របិលរប៉ូចម្នាក់មែន!

លោកសាស្ត្រាចារ្យ ហ្វ្លីតវីក យកដៃខ្ទប់មុខ។ ស្នេពមើលទៅហាក់ដូចជាថា ឲ្យតែហ៊ានមាននរណាម្នាក់ទៅសុំថ្នាំស្នេហារបស់គាត់ នឹងត្រូវចាប់បញ្ចុកដោយថ្នាំពុលតែម្ដង។

- ហើម៉ាយអូនី សូមប្រាប់ខ្ញុំមកថាឯងមិនមែននៅក្នុងចំនោមអ្នកសរសេរកាតជូនពរទាំងសែសិបប្រាំមួយនាក់នោះទេ- រ៉ុនបាននិយាយនៅពេលដែលពួកគេចាកចេញពីមហាសាលទៅរៀនម៉ោងទីមួយ។ ហើម៉ាយអូនី ស្រាប់តែធ្វើពុតជារវល់រកមើលកាលវិភាគក្នុងកាតាបរបស់នាង ហើយមិនឆ្លើយតបវិញទេ។

ពេញមួយថ្ងៃ មនុស្សកន្លឿចូលទៅចែកកាតជូនពរដល់ក្នុងថ្នាក់រៀនមិនឈប់ឈរ ពេលនោះគ្រូទាំងអស់ពិតជាមួម៉ៅណាស់ ហើយរសៀលថ្ងៃនោះ ខណៈពេលដែលក្រុមគ្រីហ្វីនដ័រកំពុងឆ្ពោះទៅរៀនមុខវិជ្ជា មន្តអាគម ម្នាក់ក្នុងចំនោមពួកមនុស្សកន្លឿទាំងនោះបានរត់មករកហេរី។

- ហ្អេ! ហេរី ផោតធ័រ!- មនុស្សកន្លឿទឹកមុខក្តៅក្រហាយម្នាក់ស្រែក ព្រមទាំងវែកផ្លូវចូលមករកហេរី។

ដោយមិនចង់ឲ្យសិស្សឆ្នាំទីមួយឃើញខ្លួនទទួលបានកាតជូនពរថ្ងៃបុណ្យនៃសេចក្តីស្រឡាញ់ ដែលក្នុងនោះរួមមានទាំងជីននី វីស្លីផងដែរ វាក៏ព្យាយាមរត់គេច។ យ៉ាងណាមិញ មនុស្សកន្លឿម្នាក់នោះទាត់ស្មងជើងគេឯង ធ្វើយ៉ាងណាឲ្យតែបានដល់ហេរី។ ហេរីមិនទាន់រត់បានពីរជំហានផងក៏ត្រូវរាំងផ្លូវជាប់។

- ខ្ញុំមានសារតន្រ្តីមួយដែលត្រូវជូនចំពោះហេរី ផោតធ័រដោយផ្ទាល់- វាបាននិយាយ រួចបន្លឺសំឡេងពិណរបស់វាយ៉ាងគ្រលួច ធ្វើឲ្យព្រឺរោម ។

- *កុំលេងនៅទីនេះ*- ហេរីនិយាយតិចៗ ហើយព្យាយាមរត់ចេញ។

- នៅឲ្យ*ស្ងៀម*!- មនុស្សកន្លឿស្រែកដាក់ ព្រមទាំងចាប់កាតាបហេរីជាប់ ហើយទាញវាត្រលប់មកវិញ។

- លែងខ្ញុំទៅ!- ហេរីស្រែក ដោយខំប្រឹងរើបំរះ។

សំឡេងយ៉ាងខ្លាំងស្ទើរបែកក្រដាសត្រចៀកមួយបានបន្លឺឡើង ធ្វើឲ្យកាតាបរបស់វារហែកខ្វាកជាពីរ។ សៀវភៅ ចង្កឹះផេទមន្ត ក្រដាសស្បែកចៀម និងស្លាបប៉ាកការបស់វាត្រូវជ្រុះធ្លាក់ទៅលើកំរាលឥដ្ឋ ហើយដបទឹកខ្មៅរបស់វាបែកខ្ចាយប្រលាក់ពេញលើអ្វីៗគ្រប់យ៉ាង។

ហេរីក៏ឆាប់អោនរើសរបស់របរទាំងអស់ មុនពេលដែលមនុស្សកន្លឿនោះចាប់ផ្តើមច្រៀង ដែលនឹងអាចធ្វើឲ្យស្ទះកកកុញនៅក្នុងផ្លូវរបៀងនោះ។

- តើទីនេះមានរឿងអ្វីកើតឡើង?- សំឡេងបង្អូសយ៉ាងសោះកក្រោះរបស់ដ្រាកូ មេលហ្វ័យបានបន្លឺឡើង។ ហេរីចាប់ផ្តើមញាត់របស់ទាំងអស់ដាក់ក្នុងកាតាបរហែករបស់វា ចិត្តអន្ទះសាចង់ចេញទៅឲ្យឆ្ងាយមុនពេលដែលមេលហ្វ័យអាចស្តាប់ឮចម្រៀងថ្ងៃបុណ្យនៃសេចក្តីស្រឡាញ់របស់វា។

- ទីនេះហេតុអ្វីបានជារញ៉េរញ៉ៃម្ល៉េះ?- សំលេងធ្លាប់ស្គាល់មួយទៀតបន្លឺឡើង ពេលដែលពើរស៊ី វីស្លីបានមកដល់។ ហេរីចង់លួចរត់គេចពីទីនោះ ប៉ុន្តែមនុស្សកន្លឿចាប់ជង្គង់របស់វាជាប់ ធ្វើឲ្យវាដួលព្រូសទៅលើដី។

- បានហើយ- វានិយាយ ដោយអង្គុយលើកជើងរបស់ហេរី។ - នេះគឺជាចម្រៀងថ្ងៃបុណ្យនៃសេចក្តីស្រឡាញ់របស់ឯង៖

ភ្នែករបស់វាមានពណ៌បៃតងប្រៀបបាននឹងសត្វគីង្គក់
សក់របស់វាខ្មៅក្រិបដូចជាក្តារខៀន
ខ្ញុំសង្ឃឹមថាជាខ្ញុំ វាពិតជាគួរអោយស្រលាញ់
វីរជនដែលឈ្នះលើផេទគួបិសាច។

ហេរីសុខចិត្តលះបង់នូវមាសពេជ្រទាំងអស់នៅក្នុងធនាគារ ហ្គ្រីង្គហុត ធ្វើយ៉ាងណាឲ្យតែវាអាចរលាយបាត់ខ្លួនភ្លាមៗនៅពេលនោះ។ ហេរីក្រោកឈរឡើង ដោយធ្វើពុតជាសើចទាំងបង្ខំជាមួយអ្នកទាំងអស់គ្នា មានអារម្មណ៍ថាជើងស្ពឹកដោយសារតែទម្ងន់ខ្លួនរបស់មនុស្សកន្លើនោះ។ ពឿរស៊ី វីស្លីព្យាយាមអស់ពីកម្លាំងកាយចិត្តក្នុងការបំបែកហ្វូងមនុស្សនោះ ដែលមានអ្នកខ្លះអស់សំណើចរហូតដល់ស្រក់ទឹកភ្នែក។

- ចេញទៅ! ចេញទៅ! ជួងចូលរៀនបានបន្លឺឡើងប្រាំនាទីកន្លងទៅហើយ ចូលទៅថ្នាក់ទៅ នៅអល់អែកដល់ណាទៀត- វានិយាយ ព្រមទាំងបណ្តេញសិស្សក្មេងៗមួយចំនួនឲ្យចេញឆ្ងាយ។ - នៅមានឯងទៀត មេលហ្វ័យ។

ហេរីក្រឡេកមើលទៅ ឃើញថា មេលហ្វ័យ ឱនកញ្ចក់យកអ្វីម្យ៉ាង។ វាហុចរបស់នោះឲ្យក្រេប និង ហ្គូយល៍ មើលដោយញញឹមបែបចំអក ហើយហេរីក៏ដឹងភ្លាមថានោះជាសៀវភៅកំណត់ហេតុរបស់រីតដល។

- សងមកខ្ញុំវិញ- ហេរីនិយាយតិចៗ។

- ចង់ដឹងថា ផោតធ័រ សរសេរអ្វីដល់ហើយ?- មេលហ្វ័យនិយាយ។ ជាក់ស្តែងណាស់ មេលហ្វ័យមិនបានចាប់អារម្មណ៍ដល់ថ្ងៃខែនៅលើក្របសៀវភៅ ហើយក៏គិតថានេះជាសៀវភៅកំណត់ហេតុរបស់ហេរី។ ភាពស្ងប់ស្ងាត់មួយទ្រោបនៅទីនោះ។ ជីននីសម្លឹងមើលសៀវភៅកំណត់ហេតុនោះ រួចសម្លឹងហេរី ដោយទឹកមុខខ្លាចរអា។

- ឲ្យគេវិញទៅ មេលហ្វ័យ- ពឿរស៊ីនិយាយយ៉ាងម៉ឺងម៉ាត់។

- អោយខ្ញុំមើលមួយភ្លែតសិន- មេលហ្វ័យពោល ព្រមទាំងគ្រវីសៀវភៅកំណត់ហេតុនោះបែបចំអកឡកឡឺយដាក់ហេរី។

ពឿរស៊ីបន្លឺឡើង៖

- ក្នុងនាមជាអនុរក្សក្រុមសិស្សច្បង...

ប៉ុន្តែហេរីទប់កំហឹងរបស់វាលែងបានហើយ។ វាទាញចង្កឹះវេទមន្តរបស់វាចេញមក ហើយស្រែកថា៖

- *អ៊ិចស្ពេលីអាមុស!*

ដូចដែលស្នេពបានបណ្តោះអារុធពីឡក់ហាតអញ្ចឹង មេលហ្វ័យឃើញថា សៀវភៅកំណត់ហេតុនោះហោះឡើងផុតពីដៃរបស់វា។ រ៉ុនចាប់បានសៀវភៅនោះដោយស្នាមញញឹមស្ញេញស្ញាញ។

-ហេរី!- ពឿរស៊ីនិយាយខ្លាំងៗ។ - មិនត្រូវប្រើវេទមន្តក្នុងផ្លូវរបៀងជាដាច់ខាត។ ខ្ញុំនឹងរាយការណ៍រឿងនេះហើយ ឯងដឹងទេ!

ប៉ុន្តែហេរីមិនខ្វល់ឡើយ វាមានប្រៀបលើមេលហ្វ័យមួយសូន្យហើយ ហើយនោះក៏សមនឹងតម្លៃប្រាំពិន្ទុដែលត្រូវបានដកពីក្រុមហ្គ្រីហ្វិនដ័រមិនថាថ្ងៃណាជាថ្ងៃណានោះដែរ។ មេលហ្វ័យខឹងខ្លាំងណាស់ ហើយនៅពេលដែលជីននីដើរកាត់មុខវាត្រលប់ទៅកាន់បន្ទប់រៀនរបស់នាងវិញ វាក៏ស្រែកពីក្រោយនាងទាំងក្តៅក្រហាយ៖

- ខ្ញុំមិនគិតថា ផោតធ័រ ចូលចិត្តកាតជូនពររបស់នាងខ្លាំងណាស់ណានោះទេ!

ជីននី យកដៃខ្ទប់មុខ ហើយក៏រត់ចូលទៅក្នុងថ្នាក់។ ដោយគ្រហឹមខឹង រ៉ុនបានទាញចង្កឹះវេទមន្តរបស់វាចេញមក ប៉ុន្តែហេរីទាញវាចេញទៅឆ្ងាយ។ រ៉ុនមិនចាំបាច់ចំណាយពេលម៉ោងមុខវិជ្ជា មន្តអាគម ទាំងមូលទៅក្អួតចេញខ្យងឥតស្នូកនោះទេ។

ទំរាំតែពួកគេទៅដល់ថ្នាក់របស់សាស្ត្រាចារ្យ ហ្វ្លីតវីក ទើបហេរីកត់សំគាល់អ្វីម្យ៉ាងរាងចម្លែកអំពីសៀវភៅកំណត់ហេតុរបស់រីតដល។ គ្រប់សៀវភៅទាំងអស់ត្រូវប្រលាក់ដោយទឹកថ្នាំពណ៌ក្រហម ។ ទុកជាយ៉ាងណាក្តី សៀវភៅកំណត់ហេតុនេះនៅតែល្អស្អាតដដែល ដូចកាលពីមុនពេលកំពប់ដបទឹកខ្មៅលើអញ្ចឹង។ វាចង់ប្រាប់រ៉ុនពីបញ្ហានេះដែរ ប៉ុន្តែរ៉ុនកំពុងតែមានបញ្ហាជាមួយ

ចង្កឹះវេទមន្តរបស់វាម្តងទៀតហើយ។ មានពពុះពណ៌ស្វាយធំៗ កំពុងតែរីកចេញមកពីចុងចង្កឹះរបស់វា ហើយវាគ្មានពេលទៅចាប់អារម្មណ៍រឿងផ្សេងឡើយ។

នៅយប់នោះ ហេរីចូលដេកមុនអ្នកឯទៀតនៅក្នុងសយនដ្ឋាន។ ហេតុផលមួយផ្នែកនោះគឺថា វាមិនអាចទ្រាំនឹងហ្វ្រេដ និងចចច្រៀងចំរៀង៖ "ភ្នែករបស់វាមានពណ៌បៃតងប្រៀបបាននឹងសត្វគីង្គក់" សាជាថ្មីទៀតទេ ហើយមូលហេតុមួយផ្សេងទៀតនោះគឺវាចង់ពិនិត្យមើលសៀវភៅកំណត់ហេតុរបស់រីតដលម្តងទៀត ទោះបីជាវាដឹងថារ៉ុនកំពុងគិតថាវាខ្ជះខ្ជាយពេលវេលាក៏ដោយ។

ហេរីអង្គុយលើគ្រែបង្គោលបួនរបស់វា រួចបើកសៀវភៅកំណត់ហេតុនោះ។ គ្មានទំព័រណាដែលប្រលាក់ទឹកថ្នាំពណ៌ក្រហមទេ។ បន្ទាប់មក វាទាញយកដបទឹកថ្នាំថ្មីមួយចេញពីទូជិតគ្រែដេករបស់វា រួចយកស្លាបប៉ាកកាជ្រលក់ទឹកថ្នាំបន្តិច ហើយយកទៅបន្តក់នៅទំព័រទីមួយ។

ទឹកខ្មៅនោះបញ្ចេញពន្លឺយ៉ាងភ្លឺត្រចះនៅលើក្រដាសមួយភ្លែត ហើយក៏រលាយបាត់ទៅ ដូចជាត្រូវក្រដាសនោះស្រូបចូលអញ្ចឹង។ ដោយរំភើបចិត្ត ហេរីក៏ជ្រលក់ស្លាបប៉ាកការបស់វាជាលើកទីពីរ ហើយចាប់ផ្តើមសរសេរ៖

- ខ្ញុំឈ្មោះហេរី ផោតធ័រ។

ពាក្យទាំងនេះបានបញ្ចេញពន្លឺឡើងលើទំព័រសៀវភៅនោះមួយភ្លែត រួចលិចចូលទៅក្នុងដោយគ្មានដានអ្វីបន្តិច។ បន្ទាប់មកស្រាប់តែមានអ្វីម្យ៉ាងកើតឡើង។

ពាក្យសម្តី ដែលហេរីមិនដែលបានសរសេរសោះ ស្រាប់តែផុសឡើងពីខ្នងក្រដាស ជាទឹកខ្មៅរបស់វាតែម្តង។

*- សួស្តី! ហេរី ផោតធ័រ ខ្ញុំឈ្មោះរីតដល។ ហេតុអ្វីអ្នកយកបានសៀវភៅរបស់ខ្ញុំ?*

ពាក្យទាំងនេះត្រូវរលាយបាត់អស់ នៅពេលដែលហេរីចាប់ផ្តើមសរសេរពាក្យនៅពីក្រោម។

- មានមនុស្សព្យាយាមគប់វាចូលទៅក្នុងបង្គន់។

វារងចាំដោយចង់ដឹងចង់ឃើញនូវការឆ្លើយតបរបស់រីតដល។

*- សំណាងល្អណាស់ ដែលខ្ញុំបានកត់ត្រានូវការចងចាំរបស់ខ្ញុំតាមវិធីដែលអាចនៅគង់វង្សជាងទឹកខ្មៅ។ ប៉ុន្តែខ្ញុំដឹងតាំងពីយូរហើយថា ប្រាកដជាមានមនុស្សមិនចង់ឲ្យគេអានសៀវភៅកំណត់ហេតុនេះទេ។*

- តើលោកចង់មានន័យថាម៉េច?- ហេរីសរសេរដោយខ្ចីខ្ចា ធ្វើឲ្យដាមក្រដាស ដោយសារការរំជើបរំជួលចិត្តពេក។

*- ខ្ញុំចង់និយាយថា សៀវភៅនេះកត់ត្រានូវរឿងដ៏គួរអោយខ្លាច។ រឿងដែលគេត្រូវបានបិទបាំង ពោលគឺរឿងដែលកើតឡើងនៅសាលាវេទមន្តហុកវ៉ាត។*

- នោះហើយជាកន្លែងដែលខ្ញុំកំពុងស្នាក់នៅនាពេលនេះ- ហេរីសរសេរយ៉ាងលឿង។ - ខ្ញុំនៅសាលាហុកវ៉ាត ហើយមានរឿងអាក្រក់ៗជាច្រើនកំពុងតែកើតឡើង។ តើលោកមានដឹងរឿងអ្វីទាក់ទងនឹងបន្ទប់សម្ងាត់ដែររឺទេ?

បេះដូចរបស់វាលោតយ៉ាងញាប់។ រីតដលឆ្លើយតបយ៉ាងលឿង ការសរសេររឹតតែខ្ចីខ្ចា ហាក់ដូចជាគាត់កំពុងតែប្រញាប់និយាយអ្វីទាំងអស់ដែលគាត់បានដឹងប្រាប់វា។

*- ខ្ញុំប្រាកដជាដឹងពីបន្ទប់សម្ងាត់នោះហើយ។ កាលខ្ញុំនៅរៀន ពួកគេតែងប្រាប់ពួកយើងថា វាគ្រាន់តែជារឿងព្រេងតែប៉ុណ្ណោះ ថាបន្ទប់នោះមិនមានពិតប្រាកដឡើយ។ ប៉ុន្តែនោះគឺជាការកុហក។ ក្នុងឆ្នាំទីប្រាំរបស់ខ្ញុំ បន្ទប់នោះត្រូវបានបើក ហើយសត្វចំលែកបានចេញមកវាយប្រហារសិស្សជាច្រើន ហើយក្នុងនោះមានសិស្សម្នាក់ស្លាប់។ ខ្ញុំចាប់បានអ្នកបើកបន្ទប់សំងាត់ ហើយគេក៏ត្រូវបណ្តេញចេញ។ ប៉ុន្តែលោកនាយកសាលា សាស្ត្រាចារ្យ ឌីផេត យល់ថាវាគឺជាការអាម៉ាស់មួយ ដែលមានរឿងដូច្នេះ*

*កើតឡើងនៅសាលាហុកវ៉ាត អញ្ចឹងហើយទើបគាត់ហាមឃាត់ខ្ញុំមិនឲ្យនិយាយការពិត។ ពួកគេបានប្រឌិតរឿងកុហកមួយថា ក្មេងស្រីម្នាក់នោះបានស្លាប់ក្នុងឧប្បត្តិហេតុដ៏ចម្លែកមួយ ។ ពួកគេបានអោយរង្វាន់ដ៏ភ្លឺចិញ្ចែងចិញ្ចាចមួយដល់ខ្ញុំ ដើម្បីតែបំបិទមាត់ខ្ញុំមិនអោយនិយាយរឿងនេះតទៅទៀត។ ប៉ុន្តែខ្ញុំដឹងថារឿងនេះនឹងអាចកើតឡើងម្តងទៀត ព្រោះសត្វចំលែកនៅរស់នៅឡើយ។ អ្នកដែលមានសមត្ថភាពអាចដោះលែងវាមិនទាន់ត្រូវឃុំឃាំងនៅឡើយទេ។*

ហេរីស្ទើរតែជ្រុលដៃធ្វើឲ្យកំពប់ដបទឹកខ្មៅទៅហើយ ដោយសារតែការប្រញាប់ប្រញាល់របស់វាក្នុងការសរសេរតបទៅវិញ។

- វាកំពុងតែកើតឡើងម្តងទៀតហើយ។ មានការវាយប្រហារជាច្រើន ហើយគ្មាននរណាម្នាក់អាចរកមុខមាត់ពិតនៃអ្នកដែលនៅពីក្រោយរឿងនេះបានឡើយ។ តើពិរុទ្ធជននោះជានរណាកាលពីលើកមុន?

- *ខ្ញុំអាចបង្ហាញឲ្យឯងឃើញបាន ប្រសិនបើឯងចង់-* រីតដលឆ្លើយតបមកវិញ។ - *ឯងមិនចាំបាច់ឲ្យខ្ញុំសរសេរឲ្យឯងមើលនោះទេ។ ខ្ញុំអាចនាំឯងចូលទៅក្នុងការចងចាំរបស់ខ្ញុំនៅយប់ដែលខ្ញុំចាប់គេម្នាក់នោះបាន។*

ហេរីហាក់មានការស្ទាក់ស្ទើរ ស្លាបប៉ាកការបស់វានៅពេរពីលើសៀវភៅកំណត់ហេតុនោះ។ តើរីតដលចង់មានន័យថាម៉េច? តើគាត់នាំវាចូលទៅក្នុងការចងចាំរបស់គាត់ដោយរបៀបណា? វាក្រឡេកមើលទាំងញញើតញញើមឯទ្វារសយនដ្ឋាន ដែលកាន់តែងងឹតទៅៗ។ នៅពេលវាមើលសៀវភៅម្តងទៀត វាឃើញមានអក្សរថ្មីមួយជួរ។

*- ឲ្យខ្ញុំបង្ហាញឯងទៅ។*

ហេរីឈប់បន្តិច រួចសរសេរពាក្យពីរម៉ាត់។

- យល់ព្រម។

ទំព័រសៀវភៅចាប់ផ្តើមបើង ហាក់ដូចជាត្រូវខ្យល់ខ្លាំង ហើយឈប់នៅទំព័រពាក់កណ្តាលខែមិថុនា។ ដោយចំហមាត់ផ្លូង ហេរីឃើញថា នៅគែមតូចមួយដែលមានចារថ្ងៃទីដប់បីខែមិថុនាហាក់ដូចជាប្រែទៅជាអេក្រង់ទូរទស្សន៍ដ៏តូចមួយ។ វាក៏លើកសៀវភៅនោះ ទាំងដៃញ័រទទ្រើក ហើយសង្កត់ភ្នែកទល់នឹងផ្ទាំងតូចមួយនោះ ទំរាំតែវាដឹងខ្លួន វាត្រូវស្រូបចូលបាត់ទៅហើយ។ ផ្ទាំងនោះកាន់តែរីកធំឡើងៗ វាយល់ថាខ្លួនវាកំពុងតែហោះចេញពីគ្រែ ហើយត្រូវដាំដូងក្បាលទៅមុនចូលក្នុងផ្ទាំងក្រដាសនោះ ឆ្ពោះទៅក្នុងគំនួចនៃពណ៌ និងស្រមោល។

វាមានអារម្មណ៍ថាជើងរបស់វាប៉ះនឹងដីរឹង ហើយវានៅឈរទាំងញ័រខ្លួន ពេលដែលរូបភាពស្រវាំងៗទាំងឡាយនៅជុំវិញខ្លួនវាចាប់ផ្តើមច្បាស់ឡើង។

វាដឹងភ្លាមថា វានៅទីណាហើយ។ នេះគឺជាការិយាល័យរបស់លោក ដាំប័លដ័រ ដែលជាបន្ទប់រាងមូលមានរូបគំនូរកំពុងតែដេកលក់...ប៉ុន្តែអ្នកដែលអង្គុយលើកៅអីការិយាល័យនោះមិនមែនដាំប័លដ័រទេ។ វេទគូម្នាក់ដែលមានរូបរាងស្គមកំព្រឹង ទន់ខ្សោយ ក្បាលទំពែកសល់តែសក់សប៉ុន្មានចង្វាយ កំពុងតែអានសំបុត្រក្រោមពន្លឺភ្លើងទៀន។ ហេរីមិនដែលជួបបុរសម្នាក់នេះពីមុនមកទេ។

- ខ្ញុំសូមទោស- ហេរីនិយាយទាំងញ័រ - ខ្ញុំមិនមានចេតនាបំពានចូលមកទេ...។

ប៉ុន្តែវេទគូនោះមិនងើយមើលមកលើឡើយ។ គាត់បន្តមើលសំបុត្រ ព្រមទាំងជ្រួញចិញ្ចើមតិចៗ។ ហេរីទៅជិតហើយនិយាយជាប់ៗថា៖

- អឺ...ខ្ញុំនឹងចេញទៅភ្លាម បានទេ?

វេទគូម្នាក់នោះនៅតែមិនរើរវល់នឹងហេរី។ គាត់ហាក់ដូចជាមិនបានលឺហេរីនិយាយទាល់តែសោះ។ វាគិតថាវេទគូនោះប្រហែលជាត្រចៀកធ្ងន់ ក៏ខំដំឡើងសំលេង។

- សូមទោសដែលខ្ញុំរំខានលោក។ ឥលូវខ្ញុំទៅហើយ- ហេរីនិយាយស្ទើរតែស្រែក។

វេទគូនោះដកដង្ហើមធំ រួចក៏មូរសំបុត្រ ក្រោកឈរឡើង ហើយដើរកាត់មុខហេរីទៅបិទវាំងននបង្អួចរបស់គាត់ ដោយគ្មានក្រឡេកមើលហេរីបន្តិចសោះ។

នៅខាងក្រៅបង្អួច មេឃមានពណ៌ក្រហមដូចពេជ្រ ប្រហែលជាពេលព្រះអាទិត្យអស្តង្គត។ វេទគូនោះ ដើរមកតុគាត់វិញ ហើយអង្គុយចុះ។ គាត់ពត់មេដៃរបស់គាត់ ហើយមើលទៅមាត់ទ្វារ។

ហេរីសម្លឹងមើលជុំវិញការិយាល័យនោះ មិនឃើញមានហង្សភ្លើង ហ្វ៉ូវយែស ក៏គ្មានគ្រឿងម៉ាស៊ីនពណ៌ប្រាក់បន្លឺសម្លេងង្ហុងៗដែរ។ នេះគឺជាសាលាហុកវ៉ាតកាលដែលរីតដលនៅរៀន បាននន័យថា វេទគូដែលហេរីមិនធ្លាប់ស្គាល់ម្នាក់នេះជានាយកសាលា មិនមែនលោកដាំប័លដ័រទេ ចំនែកហេរី និងខ្មោចខុសគ្នាតែបន្តិចប៉ុណ្ណោះ ក្នុងកែវភ្នែករបស់មនុស្សកាលពីហាសិបឆ្នាំមុន គឺពិតជាមើលមិនឃើញវាទេ។

មានមនុស្សគោះទ្វារបន្ទប់ការិយាល័យនោះ។

- ចូលមក។- វេទគូចំណាស់នោះនិយាយដោយសំលេងខ្សោយ។

ក្មេងប្រុសម្នាក់អាយុប្រហែលដប់ប្រាំមួយឆ្នាំដើរចូលមក រួចដោះមួកកំពូលស្រួចរបស់គេចេញ។ ទ្រូងរបស់គេមានបំពាក់សញ្ញា អនុរក្សក្រុមសិស្សច្បង។ គេខ្ពស់ជាងហេរីច្រើន ប៉ុន្តែគេក៏មានសក់ខ្មៅភ្លឺរលោងដូចវាដែរ។

- អូ! រីតដល- លោកនាយកនិយាយ។

- លោកសាស្ត្រាចារ្យ ឌីផេត លោកចង់ជួបខ្ញុំរឺ?- រីតដលពោល។ គេមើលទៅដូចជាខ្លាចរអា។

- អង្គុយចុះមក- ឌីផេតស្រដី។ - ខ្ញុំទើបតែអានសំបុត្រដែលឯងផ្ញើមកឲ្យខ្ញុំ។

- អូ- រីតដលនិយាយ។ គេអង្គុយចុះ ដោយក្តាប់ដៃយ៉ាងណែន។

- សិស្សសម្លាញ់!- លោកសាស្ត្រាចារ្យ ឌីផេត និយាយយ៉ាងទន់ភ្លន់ - ខ្ញុំមិនអាចឲ្យឯងស្នាក់នៅសាលានារដូវក្តៅនេះបានទេ។ ឯងច្បាស់ជាចង់ទៅផ្ទះនៅថ្ងៃវិស្សមកាលហើយ មែនទេ?

- អត់ទេ- រីតដលនិយាយមួយរំពេច -ខ្ញុំសុខចិត្តនៅហុកវ៉ាតនេះក៏មិនត្រលប់ទៅកាន់កន្លែង...កន្លែង...

- តើឯងស្នាក់នៅមជ្ឈមណ្ឌលក្មេងកំព្រាពួកលោកិយនៅពេលវិស្សមកាលរឺ?- សាស្ត្រាចារ្យ ឌីផេត សួរដោយឆ្ងល់។

- បាទ លោកគ្រូ- រីតដលឆ្លើយតប មុខឡើងក្រហមតិចៗ។

- ឯងកើតពីពួកលោកិយរឺ?

- បាទលោក គឺមានឈាមជ័រពាក់កណ្តាល- រីតដលឆ្លើយនិយាយ - ឪពុកខ្ញុំគឺជាពួកលោកិយ ឯម្តាយខ្ញុំគឺជាវេទគូ។

- ហើយអញ្ចឹង តើឪពុកម្តាយឯងទាំងពីរនាក់...?

- លោកគ្រូ ម្តាយរបស់ខ្ញុំបានចែកឋានទៅក្រោយពីកើតខ្ញុំមក។ ពួកគេប្រាប់ខ្ញុំនៅមជ្ឈមណ្ឌលក្មេងកំព្រាថាគាត់នៅទាន់ដង្ហើមនឹងដាក់ឈ្មោះឲ្យខ្ញុំ...ថម ដាក់ឈ្មោះតាមឪពុករបស់ខ្ញុំ រឺង ម៉ាវ៉ូឡូ ដាក់ឈ្មោះតាមជីតារបស់ខ្ញុំ។

លោកសាស្ត្រាចារ្យ ឌីផេត បន្លឺសូរចិៗសម្តែងក្តីអានិតអាសូរ។

- ថម រឿងដែលខ្ញុំចង់និយាយនោះ- គាត់បានដកដង្ហើមធំ - គឺថាគេប្រហែលជាអាចរៀបចំជាពិសេសសំរាប់រូបឯង ប៉ុន្តែបើតាមកាលៈទេសៈបច្ចុប្បន្ននេះ...

- លោកចង់និយាយពីការវាយប្រហារទាំងនេះ មែនទេ លោកគ្រូ?- រីតដលសួរ ហើយបេះដូងរបស់ហេរីក៏លោតញាប់ស្មេ។ វាខិតចូលទៅជិត ខ្លាចថាស្តាប់មិនទាន់ត្រង់ចំនុចណាមួយ។

- គឺចំណុចហ្នឹងហើយ- លោកនាយកនិយាយ។ - សិស្សសម្លាញ់ ឯងប្រាកដជាដឹងហើយថា វាមិនសមគួរទេប្រសិនជាខ្ញុំអនុញ្ញាតឲ្យឯងបន្តស្នាក់នៅសាលា ពេលវគ្គសិក្សាត្រូវបញ្ចប់នោះ។ ជាពិសេសចំពេលដែលកំពុងមានសោកនាដ្យកម្មថ្មីៗនេះ ...ការស្លាប់របស់ក្មេងស្រីដ៏គួរអោយអានិតម្នាក់... ឯងនឹងមានសុវត្ថិភាពជាង នៅឯមជ្ឈមណ្ឌលកុមារកំព្រា។ តាមការពិតទៅ ក្រសួងវេទមន្ត ឥលូវថែមទាំងកំពុងពិភាក្សាអំពីការបិទសាលានេះចោលទៀតផង។ ពួកយើងដូចជាមិនអាចកំណត់ប្រភពឲ្យជាក់លាក់នៃអំពើអពមង្គលទាំងនេះសោះឡើយ...

ភ្នែករបស់រីតដលបើកធំឡើង។

- លោកគ្រូ...ប្រសិនបើមាននរណាម្នាក់ត្រូវចាប់បាន...ប្រសិនជារឿងទាំងអស់ត្រូវបានបញ្ចប់នោះ...

- ឯងនិយាយពីអ្វីហ្នឹង?- សាស្ត្រាចារ្យ ឌីផេត បន្លឺឡើងដោយសម្លេងស្រួយ ព្រមទាំងងើបឡើងពីតុ។ - រីតដល តើឯងចង់មានន័យថា ឯងដឹងរឿងអ្វីម្យ៉ាងទាក់ទងនឹងការវាយប្រហារទាំងនេះរឺ?

- ទេ លោកគ្រូ- រីតដលឆ្លើយតបយ៉ាងលឿន។

ប៉ុន្តែហេរីប្រាកដក្នុងចិត្តណាស់ថា សំឡេងឆ្លើយថា "ទេ" នេះគឺដូចគ្នានឹងចម្លើយ ដែលខ្លួនវាបាននិយាយទៅកាន់ដាំប័លដ័រដែរ។

លោកសាស្ត្រាចារ្យ ឌីផេត អង្គុយចុះមកវិញ ហាក់ស្រងាកចិត្ត។

- ឯងអាចទៅបានហើយ ថម...

រីតដលរំអិលខ្លួនចុះពីលើកៅអី ហើយដើរមួយៗចេញពីបន្ទប់នោះ។ ហេរីដើរតាមគេ។

ពួកគេដើរចុះជណ្តើរវិល ចេញទៅជិតនឹងរូបចម្លាក់នៅក្នុងផ្លូវរបៀងងងឹត។ រីតដលឈប់ ហើយក៏ឈប់ដែរ ដោយតាមឃ្លាំមើលគេ។ ហេរីអាចប្រាប់បានថា រីតដលកំពុងតែត្រិះរិះពិចារណានូវបញ្ហាស្មុគស្មាញមួយ។ គេកំពុងតែខាំបបូរមាត់ ថ្ងាសឡើងជ្រួញ។

បន្ទាប់មក គេហាក់ដូចជាធ្វើការសម្រេចចិត្តរួចរាល់ ហើយក៏ដើរចេញទៅយ៉ាងលឿន។ ហេរីដើរតាមពីក្រោយគេដោយគ្មានបន្លឺសំឡេងអ្វីបន្តិចឡើយ។ ពួកគេមិនឃើញអ្នកផ្សេងឡើយ រហូតដល់ពួកគេទៅដល់ច្រកចូលសាល ស្រាប់តែមាន វេទគូម្នាក់សក់ពណ៌ក្រហម រាងខ្ពស់ ឈរនៅលើជណ្តើរធ្វើពីថ្មើមថ្ម ហៅរីតដល។

- ថម តើឯងដើរទៅណាមកណាទាំងយប់ព្រលប់ហ្នឹង?

ហេរីងាកមើលវេទគូម្នាក់នោះ។ គាត់គឺគ្មាននរណាក្រៅពី ដាំប័លដ័រ ដែលនៅក្មេងជាងបច្ចុប្បន្នហាសិបឆ្នាំនោះទេ។

- ខ្ញុំត្រូវទៅជួបលោកនាយក លោកគ្រូ- រីតដលបានឆ្លើយ។

- បានហើយ ទៅដេកចុះ- ដាំប័លដ័រនិយាយ ដោយសំដែងទឹកមុខសម្លក់យ៉ាងមុតទៅកាន់រីតដល ដែលហេរីចំណាំយ៉ាងច្បាស់មិនច្រលំឡើយ។ - ល្អបំផុត គួរតែកុំដើរចរច្រប់នៅតាមផ្លូវរបៀងនាសព្វថ្ងៃនេះ។ តាំងពីមាន...

គាត់ដកដង្ហើមធំ រួចនិយាយរាត្រីសួស្តីទៅកាន់រីតដល ហើយក៏ដើរទៅបាត់។ រីតដល ពេលឃើញគាត់ដើរទៅបាត់ ក៏ប្រញាប់ប្រញាល់ទៅជាន់ក្រោមសំដៅគុកងងឹត។ ហេរីតាមគេយ៉ាងប្រកៀក។

ប៉ុន្តែធ្វើអោយហេរីអស់សង្ឃឹម រីតដលមិនមែននាំវាទៅច្រកបន្ទប់សំងាត់ទេ បែរជាទៅបន្ទប់ដែលហេរី រៀនមុខវិជ្ជាឱសថជាមួយស្នេពទៅវិញ។ ចន្លុះមិនទាន់បំភ្លឺនៅឡើយ ហើយនៅពេលដែលរីតដលរុញទ្វារស្ទើរតែបិទជិតទៅហើយ ហេរីគ្រាន់តែអាចសម្លឹងមើលឃើញរីតដលឈរស្ងៀមនៅមាត់ទ្វារ មើលទៅច្រកផ្លូវខាងក្រៅប៉ុណ្ណោះ។

ហេរីមានអារម្មណ៍ថាពួកគេនៅទីនោះអស់យ៉ាងហោចណាស់ក៏មួយម៉ោងដែរ។ វាអាចត្រឹមតែ មើលឃើញស្រមោលរបស់រីតដល ដែលកំពុងសម្លឹងមើលមិនដាក់ភ្នែកទៅក្នុងស្នាមប្រេះមួយ នៅទន្ទឹងរង់ចាំដូចជារូបចម្លាក់។ ហើយចំពេលដែលហេរីលែងមានអារម្មណ៍ចង់នៅចាំតទៅទៀត ព្រមទាំងប្រាថ្នាចង់ត្រលប់ទៅបច្ចុប្បន្នកាលវិញ ស្រាប់តែវាស្តាប់ឮអ្វីម្យ៉ាងកំរើកនៅឯម្ខាងទ្វារឯណោះ។

មានមនុស្សកំពុងតែវារតាមច្រកផ្លូវនោះ។ វាស្តាប់ឮនរណាម្នាក់ដើរកាត់បន្ទប់ងងឹតនៅកន្លែងដែលវា និងរីតដលកំពុងពួន។ រីតដល ដែលស្ងាត់មាត់ឈឹងដូចស្រមោល រំកិលខ្លួនចូលចន្លោះទ្វារនោះ ហើយដើរតាម ចំនែកហេរីដើរលបៗពីក្រោយខ្នង ដោយភ្លេចខ្លួនថាគេស្តាប់វាមិនឮនោះទេ។

ពួកគេដើរតាមស្នូរជើងនោះប្រហែលជាប្រាំនាទី រហូតដល់រីតដលស្រាប់តែឈប់ ក្បាលរបស់គេបែរទៅតាមទិសនៃសំឡេងថ្មីនោះ។ ហេរីឮសូរទ្វាររបើកឡើង ហើយបន្ទាប់មកឮមនុស្សម្នាក់និយាយជាសម្លេងខ្សឹបស្អកៗ។

- ឆាប់ឡើង...ត្រូវតែយកឯងចេញពីទេនេះ...ចាឲ្យឆាប់ឡើង...ចូលក្នុងប្រអប់នេះទៅ...

សំលេងនោះដូចធ្លាប់ស្គាល់។

រីតដលលោតចេញពីជ្រុងនោះ ហេរីក៏ឈានជើងចេញមកតាមក្រោយគេដែរ។ ហេរីមើលឃើញរូបរាងខ្មៅងងឹតនៃយុវជនមាឌធំខ្ពស់ស្រឡះម្នាក់ កំពុងបង្អោនខ្លួននៅពីមុខទ្វារមួយ នៅជិតនោះមានប្រអប់ធំមួយ។

- សាយណ្ណសួស្តី រូប៊ុស- រីតដលនិយាយយ៉ាងវាងវៃ។

ក្មេងប្រុសនោះបិទទ្វារយ៉ាងខ្លាំង រួចក្រោកឈរឡើង។

- ថម តើឯងកំពុងធ្វើអ្វីនៅខាងក្រោមនេះ?

រីតដលឈានជើងខិតទៅជិត។

- ឈប់ត្រឹមហ្នឹងបានហើយ- រីតដលបាននិយាយ។ - ខ្ញុំនឹងរាយការណ៍ប្រាប់គេហើយ រូប៊ុស។ ពួកគេនឹងពិភាក្សាអំពីការបិទសាលាហុកវ៉ាតចោល ប្រសិនបើការវាយប្រហារមិនបញ្ឈប់ទេ។

- ឯងចង់និយាយពីស្អីហ្នឹង?

- ខ្ញុំមិនគិតថា ឯងមានចេតនាសំលាប់មនុស្សទេ។ ប៉ុន្តែបិសាចមិនអាចយកមកធ្វើជាសត្វចិញ្ចឹមបានឡើយ។ ខ្ញុំគិតថាឯងគ្រាន់តែចង់ដោះលែងវាអោយមកកំសាន្តតែប៉ុននោះ ហើយ...

- វាមិនដែលសម្លាប់នរណាម្នាក់ទេ!- ក្មេងមាឌធំម្នាក់នោះឧទានឡើង ព្រមទាំងថយក្រោយមកផ្អែកនឹងទ្វារដែលបិទនោះ។ នៅពីក្រោយគាត់ ហេរីឮសូរសំឡេងក្រឹកៗ។

- ឲ្យឆាប់ឡើង រ៉ូប៊ុស។- រីតដលនិយាយ ព្រមទាំងខិតទៅជិតបន្តិចម្តងៗ។ - ឪពុកម្តាយក្មេងស្រីម្នាក់នោះស្ទែកនឹងមកដល់ហើយ។ រឿងស្តួចស្តើងបំផុត ដែលសាលាហុកវ៉ាតអាចធ្វើបាននោះគឺត្រូវឲ្យប្រាកដថាភាវៈដែលសម្លាប់កូនស្រីរបស់ពួកគេនឹងត្រូវស្លាប់សងវិញ...

- មិនមែនជាវាទេ!- ក្មេងនោះស្រែកគំហក សំឡេងរបស់វាលាន់រំពងឡើងនៅក្នុងច្រកផ្លូវងងឹតនោះ។ - វាមិនអាចទេ! វាមិនដែលមានទេ!

- ឈរទៅម្ខាងទៅ។- រីតដលដកចង្កឹះវេទមន្តចេញមក។

វេទមន្តរបស់គេ បំភ្លឺផ្លូវរបៀងនោះដោយពន្លឺអណ្តាតភ្លើងមួយឆាវ។ ទ្វារដែលក្មេងប្រុសនោះផ្អែកលើត្រូវប៉ើងរបើកឡើងដោយកម្លាំងអរូបីមួយរហូតដល់ធ្វើឲ្យក្មេងប្រុសនោះ ខ្ទាតទៅនឹងជញ្ជាំងទល់មុខ។ ហើយអ្វីម្យ៉ាងដែលចេញមកពីក្នុងនោះធ្វើឲ្យហេរីស្រែកយ៉ាងខ្លាំងតែគ្មាននរណាម្នាក់ស្តាប់ឮ។

មាឌធំ ការធ្វើដំនើរយឺតៗ ខ្លួនពោរពេញដោយរោម និងជើងទាំងបួនមានពណ៌ខ្មៅ។ ភ្នែកជាច្រើនបើកចេញជាពន្លឺ និងមានតង្កៀបមុតស្រួចៗមួយគូ។ រីតដលលើកចង្កឹះវេទមន្តឡើង ប៉ុន្តែយឺតពេលហើយ។ របស់នោះរត់កាត់ផ្លូវរបៀង ហើយក៏ផុតដាច់កន្ទុយភ្នែកទៅ។ រីតដលរត់ញាប់ជើងតាមពីក្រោយវា។ គាត់លើកចង្កឹះវេទមន្តម្តងទៀត ប៉ុន្តែក្មេងប្រុសនោះមាឌធំម្នាក់នោះហក់សង្គ្រប់លើគេ រួចដណ្តើមចង្កឹះវេទមន្តរបស់គេ ហើយផ្តួលគេផ្ងារក្រោយវិញ។ សំឡេងមួយ ស្រែកសន្ធាប់ឡើង៖

- ទេៗៗៗ...។

កន្លែងកើតហេតុនោះចាបផ្តើមគួចគ្របាញ់បញ្ចូលគ្នា ឯភាពងងឹតចាប់ផ្តើមគ្របដណ្តប់ទាំងស្រុង។ ហេរីមានអារម្មណ៍ថាខ្លួនវាកំពុងតែធ្លាក់ ហើយវាក៏មកដល់លើគ្រែបង្គោលបួន ខ្លួនលាតសន្ធឹង ដូចជាសត្វឥន្ទ្រីយ៍ នៅក្នុងសយនដ្ឋានក្រុមហ្គ្រីហ្វីនដ័រ សៀវភៅកំណត់ហេតុរបស់រីតដលស្ថិតនៅលើពោះរបស់វា។

មិនទាន់ទាំងបានដកដង្ហើមឲ្យស្មើគ្នាផង ទ្វារសយនដ្ឋានបើកឡើង ហើយរ៉ុនក៏ចូលមកក្នុង។

- ឯងនៅទីនេះសោះ- វានិយាយ។

ហេរីអង្គុយចុះ ខ្លួនរបស់វាភ័យហូរញើសមិនឈប់។

- មានរឿងអី?- រ៉ុនសួរ ព្រមទាំងសម្លឹងមើលមកវាដោយក្តីព្រួយបារម្ភ។

- រ៉ុន គឺហាគ្រ្កីដ ហាគ្រ្កីដកាលពីហាសិបឆ្នាំមុនបានបើកបន្ទប់សំងាត់។

## វគ្គ XIV



# ខននីលុស ហ្វូដហ្យ៍

ហេរី រ៉ុន និង ហឺម៉ាយអូនី ដឹងយូរមកហើយថា ហាហ្គ្រីដ មានទំនោរចិត្តស្រឡាញ់យ៉ាងខ្លាំងទៅលើសត្វចម្លែកធំៗ។ ក្នុងកំលុងពេលឆ្នាំដំបូងនៅសាលាហុកវ៉ាត គាត់បានព្យាយាមចិញ្ចឹមសត្វនាគមួយក្បាលនៅក្នុងកូនផ្ទះឈើរបស់គាត់ ហើយត្រូវចំនាយពេលយ៉ាងយូរទំរាំតែគាត់ដាច់ចិត្តបំភ្លេចសត្វឆ្កែយក្សក្បាលបី ដែលគាត់បានដាក់ឈ្មោះថា ផ្លាហ្វី។ ហើយប្រសិនជា ហាហ្គ្រីដ កាលពីនៅក្មេងវិញ ឲ្យតែឮថាមានសត្វចម្លែកមួយក្បាលពួនសំងំនៅកន្លែងណាមួយក្នុងប្រាសាទ ហេរីច្បាស់ក្នុងចិត្តណាស់ថា គាត់ប្រាកដជាតាមមើលសត្វនោះឲ្យខាងតែបាន មិនថានៅឆ្ងាយប៉ុណ្ណាឡើយ។ គាត់ប្រហែលជាគិតថា វាគឺជារឿងបោរមុខមួយដែលសត្វចម្លែកនោះត្រូវឃុំឃាំងអស់រយៈពេលយូរយ៉ាងនេះ ហើយគិតទៀតថា វាសមនឹងទទួលបាននូវឱកាសដើម្បីពត់ពែនជើងជាច្រើនរបស់វា។ ហេរីត្រឹមតែអាចស្រមើស្រមៃដល់ហាហ្គ្រីដកាលនៅអាយុដប់បីឆ្នាំ កំពុងព្យាយាមស៊កបញ្ចូលខ្សែចង និងប្រឡៅកទៅលើឆ្កែក្បាលបីនោះ។ ប៉ុន្តែវាក៏ដឹងច្បាស់ដែរថា ហាហ្គ្រីដមិនដែលមានចេតនាសម្លាប់នរណាម្នាក់ឡើយ។

ហេរីបានបន់ស្រន់ហាសិបភាគរយថា វាមិនបានដឹងអំពីរបៀបប្រើប្រាស់សៀវភៅកំណត់ហេតុរបស់ រីតដល ទេ។ ម្តងហើយម្តងទៀតដែល រ៉ុន និង ហឺម៉ាយអូនី បង្ខំវាឲ្យនិយាយសាឡើងវិញនូវអ្វីដែលវាបានឃើញ រហូតទាល់តែវាធុញទ្រាន់លែងចង់ប្រាប់ពួកគេ និងធុញទ្រាន់នឹងការបរិយាយសាចុះសាឡើងនូវសន្ទនាដែលកើតមានឡើងបន្តបន្ទាប់មក។

- រីតដលប្រហែលជាចាប់មនុស្សខុសហើយ- ហឺម៉ាយអូនីនិយាយ។ - ប្រហែលជាបិសាចផ្សេងទេដែលបានវាយប្រហារមនុស្សទាំងអស់នោះ...

- តើឯងគិតថាកន្លែងនេះផ្ទុកបិសាចបានប៉ុន្មានក្បាលទៅ?- រ៉ុនសួរទាំងធុញទ្រាន់។

- ពួកយើងបានដឹងរួចមកហើយថា ហាហ្គ្រីដ ត្រូវគេបណ្តេញចេញ- ហេរីនិយាយយ៉ាងកំសត់។ - ហើយការវាយប្រហារប្រាកដជាត្រូវបានបញ្ឈប់ បន្ទាប់ពីហាហ្គ្រីដត្រូវគេដេញចេញពីសាលា។ បើមិនដូច្នោះទេ រីតដលក៏មិនទទួលបានរង្វាន់ដែរ។

រ៉ុនព្យាយាមរកនឹកមើលហេតុផលផ្សេងពីនោះ។

- ស្តាប់មើលទៅ រីតដល *ពិត*ជាដូចពៀរស៊ីមែនទែន...និយាយអញ្ចឹង តើនរណាសុំឲ្យគេបកអាក្រាតពីហាហ្គ្រីដទៅហ្នំ?

- ប៉ុន្តែបិសាចនោះបានសំលាប់មនុស្សម្នាក់ណា៎ រ៉ុន- ហឺម៉ាយអូនីស្រដី។

- ហើយ រីតដល នឹងត្រូវត្រលប់ទៅមជ្ឈមណ្ឌលកុមារកំព្រាពួកលោកិយវិញប្រសិនបើពួកគេបិទសាលាហុកវ៉ាតចោល- ហេរីពោល។ - ខ្ញុំមិនបន្ទោសគាត់ដែលចង់នៅទីនេះទេ...

រ៉ុនខាំមាត់បន្តិច រួចនិយាយទាំងស្ទាក់ស្ទើរ៖

- តើឯងនៅ ផ្លូវរាត្រី បានជួបហាក្រ៊ីដមែនទេ ហេរី?

- គាត់ពេលនោះកំពុងតែទិញថ្នាំបណ្ដេញខ្យងស៊ីសាច់- ហេរីនិយាយយ៉ាងលឿន។

ពួកគេទាំងបីនាក់ស្ងាត់មាត់ជ្រៀប។ មួយសន្ទុះក្រោយមក ហឺម៉ាយអូនីបានបន្លឺឡើងនូវសំណួរដែលចាក់ស្រេះបំផុតដោយសំឡេងស្ទាក់ស្ទើរះ

- តើឯងគិតថាពួកយើងគួរតែទៅ*សាកសួរ*ហាក្រ៊ីដពីរឿងទាំងអស់នេះទេ?

- ផ្ញើទៅច្បាស់ជាសមណាស់ហើយ- រ៉ុននិយាយ។ - សួស្ដី! ហាក្រ៊ីដ ប្រាប់ពួកយើងមកមើល ថាតើថ្មីៗនេះលោកមានបានលែងអ្វីមួយឡប់ៗដុះរោមពេញចូលក្នុងសាលាទេ?

ដល់ចុងក្រោយ ពួកគេក៏សម្រេចចិត្តថានឹងមិននិយាយអ្វីទៅកាន់ហាក្រ៊ីដទេ លុះត្រាណាតែមានការវាយប្រហារមួយទៀតកើតឡើង ហើយខណៈពេលដែលពេលវេលាចេះតែកន្លងទៅច្រើនថ្ងៃ ដោយលែងឮសំឡេងខ្សឹបខ្សៀវគ្មានរូបគ្មានរាងនោះ ពួកគេក៏ចាប់ផ្ដើមមានសង្ឃឹមថា ពួកគេមិនចាំបាច់ត្រូវនិយាយពីមូលហេតុដែលគាត់ត្រូវគេបណ្ដេញចេញពីសាលានោះឡើយ។ ជិតបួនខែទៅហើយ ដែលចាស់ស្ទីន និងនីកស្ទើរគតក្បាលត្រូវរងអាគមបង្កក ហើយសឹងតែអ្នករាល់គ្នាហាក់ដូចជាគិតថា អ្នកវាយប្រហារនោះ ទោះជានរណាក៏ដោយ ប្រហែលជាចូលនិវត្តន៍ឈប់ធ្វើសកម្មភាពហើយ។ ក្រោយៗមកទៀត ភីវក៏ធុញទ្រាន់នឹងច្រៀងចម្រៀង "ឱ! ផោតធ័រ អាកំហូច"។ នៅថ្ងៃមួយ អើនី មេកស៍មីលេន បានសុំហេរីយ៉ាងគួរសម ឲ្យជួយហុចធុងដាក់ផ្សិតពុលលោតផ្លោតៗក្នុងម៉ោងរៀនមុខវិជ្ជាភូតគាមសាស្ត្រ ហើយនៅខែមីនាដើម ម៉ានដ្រេក ជាច្រើនប្រារព្ធពិធីជប់លៀងដ៏ថ្លង់សឹងបែកក្រដាសត្រចៀកក្នុងផ្ទះកញ្ចក់ទីបី។ រឿងនេះធ្វើឲ្យសាស្ត្រាចារ្យ សប្រ៉ោត សប្បាយចិត្តយ៉ាងខ្លាំង។

- ពេលដែលពួកវាចាប់ផ្ដើមព្យាយាមដើរចូលផើងគ្នាវាទៅវិញទៅមក ពេលនោះយើងនឹងដឹងថាពួកវាពេញវ័យហើយ- គាត់ប្រាប់ហេរី។ - បន្ទាប់មក ពួកយើងនឹងអាចព្យាបាលពួកមនុស្សគួរឲ្យកំសត់ទាំងនោះនៅគិលានដ្ឋានបានហើយ។

*

សិស្សឆ្នាំទីពីរមានរឿងថ្មីដែលត្រូវគិតក្នុងកំឡុងពេលថ្ងៃឈប់សម្រាកបុណ្យប៉ាក។ ដល់ពេលត្រូវជ្រើសរើសមុខវិជ្ជាសម្រាប់ឆ្នាំទីបីហើយ គឺជាបញ្ហាដែលយ៉ាងហោចណាស់ ហឺម៉ាយអូនី យកចិត្តទុកដាក់យ៉ាងម៉ឺងម៉ាត់បំផុត។

- វាអាចកំណត់អនាគតយើងទាំងមូលបាន- នាងប្រាប់ហេរី និងរ៉ុន ខណៈពេលដែលពួកគេពិនិត្យមើលបញ្ជីមុខវិជ្ជាថ្មីៗព្រមទាំងគូសចំណាំក្បែរមុខវិជ្ជាដែលគេជ្រើសរើស។

- ខ្ញុំចង់តែបោះបង់មុខវិជ្ជាឱសថចោលទេ- ហេរីស្រដី។

- ពួកយើងធ្វើមិនបានទេ- រ៉ុនបដិសេធយ៉ាងស្រងេះស្រងោច។ - ពួកយើងត្រូវតែរៀនមុខវិជ្ជាចាស់ៗទាំងអស់ បើមិនអញ្ចឹងទេ ខ្ញុំទាត់មុខវិជ្ជា ការការពារប្រឆាំងនឹងមន្តអាគមងងឹត ចោលតាំងពីយូរបាត់ទៅហើយ។

- ប៉ុន្តែមុខវិជ្ជានេះសំខាន់ណាស់ណា!- ហឺម៉ាយអូនីបន្លឺឡើង ទាំងផ្ទាក់ផ្អើល។

- បើឲ្យឡក់ហាតបង្រៀន មិនបាច់ក៏បានដែរ- រ៉ុនពោល។ - ខ្ញុំគ្មានរៀនបានអ្វី ក្រៅពីចេះលែងសត្វម្រេញគង្វាលនោះទេ។

នេវីល ឡុងបត់ថម ទទួលបានសំបុត្រជាច្រើនពីគ្រប់វេទគូទាំងអស់នៅក្នុងគ្រួសាររបស់វា។ ពួកគេសុទ្ធតែផ្ដល់យោបល់អញ្ចេះអញ្ចុះទៅលើមុខវិជ្ជាដែលវាគួរជ្រើសរើស។ ដោយច្របូកច្របល់ និងព្រួយបារម្ភ វាក៏អង្គុយអានមុខវិជ្ជាក្នុងបញ្ជីនោះម្ដងមួយៗ ដោយលានអណ្ដាតចេញក្រៅ រួចសួរសិស្សឯទៀតថា តើពួកគេគិតថាមុខវិជ្ជានព្វន្តស្ដាប់មើលទៅពិបាកជាងមុខវិជ្ជាសិក្សាអក្សរបុរាណរីក៏យ៉ាងណា។ ឌីន ថូម៉ាស ដែលកើតពីពួកលោកិយដូចហេរីដែរ ទាល់តម្រិះមិនដឹងជាធ្វើយ៉ាងណាក៏បិទភ្នែក រួចចាក់ចង្អឹះ

វេទមន្តទៅលើក្រដាសបញ្ជី បើចាក់ត្រូវមុខវិជ្ជាណា ជ្រើសរើសមុខវិជ្ជាហ្នឹង។ ហើម៉ាយអូនីវិញគ្មានស្តាប់យោបល់នរណាគេទេ ក៏ជ្រើសរើស ទាំងអស់តែម្តង។

ហេរីញញឹមទាំងក្រៀមក្រំដាក់ខ្លួនឯង កាលណាគិតដល់អ្វីដែលលោកមាវើរណុន និងអ្នកមីងពីទូនៀនឹងនិយាយប្រសិនបើវាសាកពិគ្រោះអាជីពដែលវាចង់ជ្រើសរើសក្នុង ពិភពវេទមន្ត ជាមួយនឹងពួកគេនោះ។ មិនមែនថាវាមិនទទួលបានការណែនាំពីនរណាម្នាក់នោះទេះ ពឿរស៊ី វីស្លី បើកដៃចំហាជានិច្ចក្នុងការចែករំលែកបទពិសោធផ្ទាល់ខ្លួនរបស់វា។

- វាស្រេចទៅលើថាតើឯងចង់*ទៅ*ណា ហេរី- វាបរិយាយប្រាប់។ - ប៉ុណ្ណឹងមិនចាត់ទុកថាឆាប់ពេកទេក្នុងការគិតគូរពីអនាគត ដូច្នេះហើយខ្ញុំសូមផ្តល់យោបល់ឯងឲ្យជ្រើសរើសមុខវិជ្ជា ទស្សន៍ទាយ ចុះ។ អ្នកផងគេតែងតែថាមុខវិជ្ជា ការសិក្សាពីពួកលោកិយ គឺជាជម្រើសទន់ខ្សោយ ប៉ុន្តែបើតាមទស្សនៈខ្ញុំផ្ទាល់ ខ្ញុំបែរជាគិតថា វេទគួគួរតែមានការយល់ដឹងស៊ីជម្រៅអំពីសហគមគ្មានវេទមន្ត ជាពិសេសប្រសិនបើគិតចង់ធ្វើការដោយមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងពួកគេ...មើលប៉ារបស់ខ្ញុំទៅ គាត់ត្រូវទាក់ទងជាមួយនឹងពួកលោកិយតែរហូតហ្នឹង។ បងប្រុសខ្ញុំ ឆាលី ជាប្រភេទមនុស្សរស់នៅក្រៅផ្ទះ ដូច្នេះគាត់ក៏ជ្រើសយកមុខវិជ្ជា តំហែរក្សាសត្វវេទមន្ត តែម្តង។ រើសតាមទេពកោសល្យឯងណ៎ា ហេរី។

ប៉ុន្តែរឿងតែម្យ៉ាងគត់ដែលហេរីមានអារម្មណ៍ថាពូកែគឺការលេង ឃ្វីដឌីច្ច។ ចុងបញ្ចប់ វាក៏ជ្រើសរើសមុខវិជ្ជាថ្មីៗតាមរ៉ុនទាំងអស់ ដោយគិតថាទោះជាវាខួរក្បាលបង្កងចំពោះមុខវិជ្ជាទាំងនេះក៏ដោយ យ៉ាងហោចណាស់ក៏វាមានមិត្តភក្តិរួសរាយម្នាក់ជួយឃឹតជួយយោងដែរ។

*

ការប្រកួតកីឡា ឃ្វីដឌីច្ច បន្ទាប់របស់ក្រុមហ្គ្រីហ្វីនដ័រគឺត្រូវប្រកួតនឹងក្រុម ហាហ្វ៊ុលផហ្វ។ ដំបងកំពុងតែទទូចស្នើឲ្យមានការហាត់សមជាក្រុមរៀងរាល់យប់ក្រោយពីញ៉ាំអាហារពេលល្ងាចហើយ អញ្ចឹងហេរីគ្មានពេលគិតអ្វីផ្សេងទៀតក្រៅពីឃ្វីដឌីច្ច និងកិច្ចការផ្ទះនោះឡើយ។ ទោះជាយ៉ាងណា ការហ្វឹកហាត់លើកនេះរាងគ្រាន់បើជាមុន ហោចណាស់ក៏មិនសូវប្រឡាក់ប្រឡូសភក់ជ្រាំដែរ ហើយនៅល្ងាចមុនពេលការប្រកួតថ្ងៃសៅរ៍ វាយកអំបោសឡើងទៅទុកនៅសយនដ្ឋានរបស់វា ក្នុងចិត្តមានអារម្មណ៍ថាឱកាសដណ្តើមបានពានរង្វាន់ឃ្វីដឌីច្ចមិនដែលបានល្អប្រពៃដូចពេលនេះទេ។

ប៉ុន្តែអារម្មណ៍រីករាយរបស់វានៅមិនបានយូរទេ។ នៅចុងជណ្តើរទៅកាន់សយនដ្ឋាន វាបានជួប នេវីល ឡង់បត់ថម ដែលកំពុងតែមានទឹកមុខភ័យស្លន់ស្លោរ។

- ហេរី...ខ្ញុំមិនដឹងថានរណាជាអ្នកធ្វើទេ។ ខ្ញុំទើបតែរកឃើញ...

នេវីលរុញទ្វារបើកឡើង ភ្នែកសម្លឹងមើលហេរីទាំងភិតភ័យ។

អីវ៉ែអីវ៉ាន់នៅក្នុងវ៉ាលិសរបស់ ហេរី ស្ថិតនៅរាយប៉ាយគ្រប់ទីកន្លែង។ អាវខ្លករបស់វាដាច់រហែកនៅលើកម្រាលឥដ្ឋ។ កម្រាលពូកត្រូវបានទាញចេញពីគ្រែបង្គោលបួនរបស់វា ហើយថតទូត្រូវបានទាញចេញពីទូជិតគ្រែរបស់វា ចំនែកឯរបស់របរក្នុងថតនោះពង្រាយរញ៉េរញ៉ៃពេញលើពូក។

ហេរីដើរទៅជិតគ្រែ ទាំងច្របាមាត់ឆ្លុង ជើងជាន់លើទំព័រពីរបីសន្លឹកដែលដាច់ចេញពីសៀវភៅ *ការធ្វើដំណើរជាមួយប៊្រែត*។

ខណៈពេលដែលវា និងនេវីលនាំគ្នាទាញភួយដាក់លើគ្រែវិញ រ៉ុន ឌីន និងស៊ីម្មុសក៏ចូលមកដល់។ ឌីនស្រែកជេរខ្លាំងៗតែម្តង។

- តើមានអ្វីកើតឡើង ហេរី?

- មិនដឹងដែរ- ហេរីតប។ ប៉ុន្តែរ៉ុនកំពុងតែពិនិត្យមើលអាវរ៉ូបរបស់ហេរីឯនោះទេ។ ហោប៉ៅទាំងអស់សុទ្ធតែលៀនចេញមកក្រៅ។

- មានគេកំពុងតែរកមើលអ្វីម្យ៉ាងហើយ- រ៉ុននិយាយ។ - តើមានបាត់អ្វីទេ?

ហេរីចាប់ផ្តើមលើករបស់របរវា គ្រវែងចូលទៅក្នុងវ៉ាលិសវិញ។ ទាល់តែដល់ពេលដែលវាបោះសៀវភៅឡុកហាតចុងក្រោយចូលទៅក្នុងវ៉ាលិស ទើបនឹកឃើញថាបាត់អ្វី។

- សៀវភៅកំណត់ហេតុរបស់រីតដលបាត់ហើយ- វានិយាយខ្សាវៗប្រាប់រ៉ុន។

- *ថាម៉េច?*

ហេរីញោចក្បាលជាសញ្ញាសំដៅទៅទ្វារសយនដ្ឋាន ហើយរ៉ុនក៏តាមវាចេញក្រៅ។ ពួកគេប្រញាប់ប្រញាល់ចុះទៅសាលរួមហ្គ្រីហ្វិនដ័រ ដែលនៅសល់តែសិស្សប្រហែលពាក់កណ្តាល រួចក៏ទៅអង្គុយជិតហឺម៉ាយអូនី ដែលកំពុងតែអង្គុយម្នាក់ឯងអានសៀវភៅមានចំណងជើងថា *រៀនអក្សរបុរាណងាយៗ*។

ហឺម៉ាយអូនីភ្ញាក់ផ្អើលជាខ្លាំងពេលបានឮដំណឹងនេះ។

- ប៉ុន្តែ...មានតែសិស្សហ្គ្រីហ្វិនដ័រទេដែលអាចចូលទៅលួចបាន...អ្នកក្រៅគេមិនដឹងពាក្យសម្ងាត់របស់ពួកយើងទេ...

- ប្រាកដហើយ- ហេរីយល់ស្រប។

*

ពួកគេភ្ញាក់ឡើងថ្ងៃស្អែក ផ្ទៃមេឃភ្លឺស្រឡះ ខ្យល់រំភើយៗបក់ផាត់ស្រស់ស្រាយកាយា។

- អាកាសធាតុថ្ងៃនេះល្អបំផុតក្នុងការប្រកួតកីឡាឃ្វីដឌីច្ឆ!- ដំបងឧទានឡើងយ៉ាងរំភើបនៅតុហ្គ្រីហ្វិនដ័រ ព្រមទាំងដាក់ពងទាបែកច្របល់ចូលគ្នាលើចានសមាជិកក្រុមម្នាក់ៗ។ - ហេរី ធ្វើចិត្តឲ្យរីករាយឡើង ឯងត្រូវទទួលទានអាហារពេលព្រឹកពិសេសៗ!

ហេរីរវល់តែសម្លឹងមើលតុហ្គ្រីហ្វិនដ័រដែលអង្គុយពេញដោយសិស្ស ក្នុងចិត្តសង្ស័យថា ម្ចាស់ថ្មីរបស់កំណត់ហេតុរីតដលមិនដឹងជានៅចំពីមុខវារឺក៏អត់។ ហឺម៉ាយអូនីចេះតែជម្រុញវាឲ្យរាយការណ៍ពីអំពើចោរកម្មនេះ ប៉ុន្តែហេរីមិនចូលចិត្តគំនិតនេះទេ។ ប្រសិនបើវាទៅរាយការណ៍មែន ច្បាស់ជាត្រូវរៀបរាប់ប្រាប់សាស្ត្រាចារ្យទាំងអស់អំពីកំណត់ហេតុនោះ ហើយតើនឹងមានមនុស្សប៉ុន្មាននាក់ទៅ ដែលដឹងពីមូលហេតុ ដែលហាហ្គ្រីដត្រូវបានបណ្តេញចេញពីសាលា? វាមិនចង់ក្លាយជាអ្នកដែលត្រូវសើរើរឿងទាំងអស់នេះឡើងវិញម្តងទៀតទេ។

ខណៈពេលដែលវាចាកចេញពីសាលធំជាមួយរ៉ុន និងហឺម៉ាយអូនី ដើម្បីទៅប្រមែប្រមូលរបស់របរឃ្វីដឌីច្ឆរបស់វា សេចក្តីព្រួយបារម្ភមួយទៀតបានចូលមកក្នុងបញ្ជីព្រួយបារម្ភ ដែលចេះតែកើនឡើងរបស់វា។ វាទើបតែឈានជើងជាន់លើជណ្តើរថ្មើមថ្មស្រាប់តែវាឮសំឡេងនោះម្តងទៀតៈ

- *សម្លាប់លើកនេះ...ឲ្យខ្ញុំចិញ្ច្រាំ...ហែក...*

វាស្រែកយ៉ាងខ្លាំង ធ្វើឲ្យរ៉ុន និងហឺម៉ាយអូនីភ្ញាក់លោតចេញពីវា។

- សំឡេងនោះទៀតហើយ!- ហេរីបន្លឺឡើង ព្រមទាំងងាកមើលទៅក្រោយ។ - ខ្ញុំទើបតែឮសំឡេងនោះអំបាញ់មិញនេះឯង...ពួកឯងឮទេ?

រ៉ុនគ្រវីក្បាល ភ្នែកបើកធំៗបិនពងមាន់។ ប៉ុន្តែហឺម៉ាយអូនីបែរជាយកក្បាលទះថ្ងាស។

- ហេរី...ខ្ញុំគិតថាខ្ញុំយល់ហើយ! ខ្ញុំត្រូវទៅបណ្ណាល័យសិន!

ថារួចនាងក៏រត់ប្រុយឡើងតាមជណ្ដើរទៅបាត់។

- តើនាងយល់*អ្វី*?- ហេរីស្រដីទាំងច្របូកច្របល់ក្នុងចិត្ត ភ្នែកនៅតែសម្លឹងមើលជុំវិញ ក្រែងដឹងថាតើប្រភពសំឡេងនោះចេញមកពីណា។

- ដឹងច្រើនជាងខ្ញុំទៀត- រ៉ុននិយាយ ព្រមទាំងគ្រវីក្បាល។

- ប៉ុន្តែហេតុអ្វីបានជានាងត្រូវទៅបណ្ណាល័យ?

- ពីព្រោះថាហឺម៉ាយអូនីតែងតែធ្វើអញ្ចឹងឯង- រ៉ុនតប ដោយញាក់ស្មា។ - ពេលឆ្ងល់ ទៅបណ្ណាល័យ។

ហេរីឈរទាំងស្ទាក់ស្ទើរ ត្រចៀកចាំស្ដាប់សំឡេងនោះម្ដងទៀត ប៉ុន្តែឥឡូវមនុស្សម្នាចាប់ផ្ដើមចេញពីសាលធំនៅខាងក្រោយវា ជជែកគ្នាខ្លាំងៗ និងធ្វើដំណើរចេញតាមទ្វារមុខទៅវាលប្រកួតកីឡាឃ្វីដឌីច្ច។

- ល្មមដល់ពេលទៅហើយ- រ៉ុននិយាយ។ - ជិតដល់ម៉ោងដប់មួយហើយ...ការប្រកួតជិតចាប់ផ្ដើមហើយ។

ហេរីរត់ឡើងទៅអគារហ្គ្រីហ្វីនដ័រ រួចយកអំបោស នីមប៊ូស ២០០០ របស់វា ហើយចូលរួមក្នុងហ្វូងមនុស្សដែលកំពុងតែពពាក់ពពូននៅលើទីលាន ប៉ុន្តែអារម្មណ៍របស់វាគឺនៅក្នុងប្រាសាទឯនោះទេ ក្នុងចិត្តខ្វាយខ្វល់ពីសំឡេងគ្មានរាងរៅមួយនោះ ហើយពេលដែលវាពាក់រ៉ូបពណ៌ក្រហមឆ្អៅក្នុងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់រួច វាក៏បានធូរស្រាលឡើងវិញ ព្រោះថាមនុស្សទាំងអស់នៅក្រៅទស្សនាការប្រកួតទាំងអស់គ្នា។

ក្រុមកីឡាករនីមួយៗដើរចេញទៅទីលានប្រកួត ដោយទទួលបាននូវសំឡេងទះដៃហ៊ោកញ្ជ្រៀវអបអរ។ អូលីវើ វូដ (ដំបង) ឡើងជិះអំបោសហោះកំដៅសាច់ជុំប៉ុន្មានជុំ ក្រឡឹងបង្គោលទី ចំនែកឯអ្នកស្រី ហ៊ុច្ច ចាប់ផ្ដើមព្រលែងបាល់។ ក្រុមហាហ្វ័លផហ្វដែលលេងក្នុងឯកសណ្ឋានពណ៌លឿងខ្ចី កំពុងតែឈរប្រជុំពិភាក្សាគ្នាពីយុទ្ធសាស្ត្រចុងក្រោយ។

ហេរីទើបតែឡើងជិះអំបោសរបស់វា ស្រាប់តែសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលដើរបណ្ដើរ រត់បណ្ដើរមកលើទីលាន ក្នុងដៃមានកាន់ឧគ្ឃោសនសព្ទពណ៌ស្វាយដ៏ធំសម្បើមមួយ។

ហេរីធ្លាក់បេះដូងក្តុកដូចជាថ្មមួយដុំអញ្ចឹង។

- ការប្រកួតនេះត្រូវបានរំសាយហើយ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលប្រកាសតាមឧគ្ឃោសនសព្ទទៅកាន់ទស្សនិកជនក្នុងពហុកីឡាដ្ឋានទាំងមូល។ សំឡេងស្រែកអ៊ូអរបានបន្លឺឡើង។ អូលីវើ វូដ ចុះមកលើដី ហើយរត់សំដៅមករកសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលទាំងទឹកមុខជ្រួលច្របល់ ដល់ថ្នាក់ភ្លេចចុះពីលើអំបោស។

- ប៉ុន្តែសាស្ត្រាចារ្យ!- វាស្រែក។ - យើងត្រូវតែប្រកួត...ពានរង្វាន់...*ហ្គ្រីហ្វីនដ័រ*...

សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលមិនរវល់នឹងវាឡើយ។ គាត់បែរមកបន្តស្រែកតាមឧគ្ឃោសនសព្ទៈ

- សិស្សានុសិស្សទាំងឡាយត្រូវត្រលប់ទៅកាន់សាលរួមក្រុមនីមួយៗ រង់ចាំស្ដាប់ដំណឹងបន្តទៀតពីមេក្រុមខ្លួន។ សូមចាកចេញជាប្រញាប់!

បន្ទាប់មកគាត់ដាក់ឧគ្ឃោសនសព្ទចុះ ហើយហៅហេរីឲ្យមកជួបគាត់។

- ផោតធ័រ ខ្ញុំចង់ឲ្យឯងមកជាមួយខ្ញុំ...

ហេរីឆ្ងល់ក្នុងចិត្តជាខ្លាំងថា តើគាត់អាចសង្ស័យវាបានយ៉ាងម៉េចទៀតលើកនេះ។ វាឃើញរ៉ុនផ្ដាច់ខ្លួនចេញពីហ្វូងមនុស្សដែលកំពុងតែអ៊ូទាំ រួចរត់មករកពួកគេ ខណៈពេលដែលពួកគេដើរសំដៅចេញទៅប្រាសាទ។ ដោយក្ដីភ្ញាក់ផ្អើលរបស់ហេរី សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលឥតជំទាស់ឡើយ។

- មែនហើយ ឯងក៏ប្រហែលជាគួរតែមកដែរ វីស្លី។

សិស្សមួយចំនួនដែលដើរជុំវិញពួកគេ ខ្លះកំពុងតែត្អូញត្អែរដោយសារតែការប្រកួតត្រូវបញ្ឈប់ ខ្លះទៀតបង្ហាញទឹកមុខព្រួយបារម្ភ។ ហេរី និងរ៉ុនដើរតាមសាស្ត្រាចារ្យម៉ាកហ្កូណាហ្កាលត្រលប់ចូលសាលា ឡើងជណ្តើរថ្មើមថ្ម។ ប៉ុន្តែលើកនេះពួកគេមិនទៅការិយាល័យគ្រូណាម្នាក់ទេ។

- នេះប្រហែលជាភ្ញាក់ផ្អើលបន្តិចហើយ- សាស្ត្រាចារ្យម៉ាកហ្កូណាហ្កាលបន្លឺឡើងដោយសំឡេងថ្នមៗគួរឲ្យភ្ញាក់ផ្អើល ខណៈពេលដែលពួកគេដើរទៅជិតគិលានដ្ឋាន។ - មានការវាយប្រហារម្តងទៀតហើយ ... គឺការវាយប្រហារ*ទ្វេរដង*ម្តងទៀត។

គ្រឿងក្នុងហេរីហាក់ដូចជាត្រូវរមួលចូលគ្នា។ សាស្ត្រាចារ្យម៉ាកហ្កូណាហ្កាលរុញទ្វារបើកឡើង ហើយវា និងរ៉ុនក៏ចូលទៅក្នុង។

អ្នកស្រីផុមហ្វ្រីកំពុងតែអោនមើលក្មេងស្រីឆ្នាំទីប្រាំម្នាក់ ដែលមានសក់វែងអង្កាញ់។ ហេរីចំនាំបានថា នាងជាសិស្សក្រុមរ៉ាវិនក្លាហ្វ ដែលពួកគេច្រឡំសួររកទិសដៅទៅសាលរួមរបស់ក្រុមស្លីធើរីន។ ហើយនៅគ្រែជាប់នាងគឺ...

- *ហឺម៉ាយអូនី!*- រ៉ុនបន្លឺឡើងគ្រលរតិចៗ។

ហឺម៉ាយអូនីសណ្តូកខ្លួននៅទីនោះឡើងរឹងឆ្អឹត រីឯភ្នែកទាំងពីររបស់នាក់បើកក្រឡក់គ្មានវិញ្ញាណអ្វីទាល់តែសោះ។

- ពួកគេត្រូវបានរកឃើញនៅជិតបណ្ណាល័យ- សាស្ត្រាចារ្យម៉ាកហ្កូណាហ្កាលពន្យល់។ - ខ្ញុំមិនគិតថាពួកឯងទាំងពីរនាក់អាចពន្យល់ថាមានរឿងអ្វីកើតឡើងទេ មែនទេ? របស់នេះស្ថិតនៅលើកម្រាលឥដ្ឋជិតពួកគេ...

គាត់កំពុងតែកាន់បង្ហាញកញ្ចក់រាងមូលតូចមួយ។

- ខ្ញុំនឹងនាំពួកឯងត្រលប់ទៅអគារហ្គ្រីហ្វីនដ័រវិញ- សាស្ត្រាចារ្យម៉ាកហ្កូណាហ្កាលស្រដីដោយសំឡេងធ្ងន់ៗ។ - ខ្ញុំក៏ត្រូវការទៅទីនោះដើម្បីប្រកាសប្រាប់ពួកសិស្សផងដែរ។

*

- សិស្សទាំងអស់នឹងត្រលប់ទៅសាលរួមតាមក្រុមខ្លួននីមួយៗនៅម៉ោងប្រាំមួយល្ងាច។ គ្មានសិស្សណាម្នាក់អាចចាកចេញពីសយនដ្ឋានក្រោយពីម៉ោងនោះឡើយ។ គ្មានសិស្សណាម្នាក់អាចប្រើប្រាស់បន្ទប់ទឹកដោយគ្មានគ្រូទៅជាមួយទេ។ រាល់ការហ្វឹកហាត់ និងការប្រកួតកីឡាឃ្វីដឌីច្ឆទាំងអស់នឹងត្រូវផ្អាកមួយរយៈ។ ហើយក៏នឹងគ្មានសកម្មភាពពេលល្ងាចទៀតដែរ។

សិស្ស ហ្គ្រីហ្វីនដ័រ ទាំងអស់ ដែលអង្គុយកកកុញក្នុងសាលរួម ស្តាប់សាស្ត្រាចារ្យ ម៉ាកហ្កូណាហ្កាលដោយស្ងាត់មាត់ជ្រាប។ គាត់មូរក្រដាសស្បែកចៀម ដែលគាត់ទើបនឹងអានទុក ហើយបន្លឺឡើងដោយសំឡេងហាក់ចង់ឈ្លក់បន្តិចអត់បន្តិចៈ

- មិនបាច់និយាយក៏ដឹងថា ខ្ញុំកម្រនឹងទទួលសំពាធធ្ងន់ធ្ងរដូចលើកនេះណាស់។ បើប្រមើលមើលទៅ សាលានេះនឹងត្រូវបិទជាមិនខាន លុះត្រាតែជនដៃដល់នៅពីក្រោយការវាយប្រហារទាំងអស់នេះត្រូវចាប់ខ្លួនបាន។ ខ្ញុំសូមជំរុញឲ្យអ្នក ដែលដឹងព័ត៌មានអ្វីអំពីឧក្រិដ្ឋជនទាំងនេះ សូមមេត្តាចេញមក។

គាត់ឡើងទាំងទើសទែងចេញពីចន្លោះប្រហោងរូបភាព ហើយក្រុមហ្គ្រីហ្វីនដ័រចាប់ផ្តើមជជែកគ្នាភ្លាម។

- ឥឡូវអ្នកដែលត្រូវរងការវាយប្រហារមានសិស្សហ្គ្រីហ្វីនដ័រពីរនាក់ បើមិនគិតខ្មោចហ្គ្រីហ្វីនដ័រថែមមួយទៀត ហើយសិស្សរ៉ាវិនក្លាហ្វម្នាក់ ព្រមទាំងសិស្សហាហ្វ៍លផហ្វម្នាក់ទៀត។- មិត្តភក្តិបងប្អូនភ្លោះវីស្លីឈ្មោះ លី ចចដាន់ បូរបាច់ប្រាប់ ដោយរាប់ម្រាមដៃ។ - តើពួកគ្រូៗមានកត់សំគាល់ឃើញទេថា សិស្សស្លីធើរីនទាំងអស់សុទ្ធតែមានសុវត្ថិភាព? *ទាយាទ*ស្លីធើរីន ... *បិសាច*ស្លីធើរីន ...

ហេតុអ្វីបានជាពួកគេមិនដេញពួកស្លីតឺរីនចេញឲ្យអស់ទៅ?- វាស្រែកគ្រហឹម ព្រមទាំងទទួលបាននូវការងក់ក្បាល និងទះដៃយល់ស្របពីមនុស្សមួយចំនួន។

ពៀរស៊ី វីស្លីកំពុងតែអង្គុយលើកៅអីពីក្រោយ លី ប៉ុន្តែនេះជាលើកទីមួយហើយ ដែលវាមិនខ្វល់ខ្វាយនឹងចង់ប្រកាសប្រាប់ពីទស្សនៈរបស់វាឲ្យអ្នកដទៃបានដឹងបានឮ។ វាមានទឹកមុខស្លេកស្លាំង ធ្វើក្បាលងឺងើ។

- ពៀរស៊ីស្រឡាំងកាំងហើយ- ចចប្រាប់ហេរីស្ងាត់ៗ។ - សិស្សស្រីរ៉ាវិនក្លាហ្វម្នាក់នោះ ... គឺម្នាក់ឈ្មោះ ពេនេឡុប ក្លៀវ៉ថធើរ...នាងគឺជាប្រធានសិស្ស។ វាប្រហែលជាមិនគិតថា បិសាចនោះហ៊ានដល់ថ្នាក់វាយប្រហារ*ប្រធានសិស្ស*នោះឡើយ។

ប៉ុន្តែហេរីស្ដាប់បានតែពាក់កណ្ដាលទេ។ វាហាក់ដូចជាមិនអាចឈប់គិតពីរូបភាពហឺម៉ាយអូនី ដែលដេកស្តូកស្ដឹងលើគ្រែគិលានដ្ឋានដូចចម្លាក់ថ្ម បានទាល់តែសោះ។ ហើយប្រសិនបើគេចាប់មិនបានឧក្រិដ្ឋជនក្នុងពេលឆាប់ៗនេះទេ វាច្បាស់ជាត្រលប់ទៅរស់នៅជីវភាពចាស់ ជាមួយនឹងគ្រួសារឌើស្លីទៀតហើយ។ ថម រីតដល បានបកអាក្រាតពីហាគ្រ្គីដ ក៏ដោយសារតែគេត្រូវប្រឈមមុខនឹងការត្រឡប់ទៅ មជ្ឈមណ្ឌលកុមារកំព្រាពួកលោកិយវិញ ប្រសិនបើសាលាត្រូវបិទ។ ឥឡូវ ហេរីដឹងហើយថាពេលនោះគេមានអារម្មណ៍យ៉ាងណា។

- តើពួកយើងគួរធ្វើយ៉ាងម៉េចទៅ?- រ៉ុនសួរខ្សាវៗដាក់ត្រចៀកហេរី។ - តើឯងគិតថាពួកគេសង្ស័យហាគ្រ្គីដទេ?

- ពួកយើងត្រូវតែទៅនិយាយជាមួយគាត់- ហេរីពោល លើកនេះសម្រេចចិត្តដាច់ស្រេចហើយ។ - ខ្ញុំមិនជឿថាជាគាត់ទេលើកនេះ ប៉ុន្តែប្រសិនបើគាត់ធ្លាប់ព្រលែងបិសាចនោះកាលពីលើកមុន គាត់ច្បាស់ជាដឹងពីរបៀបចូលទៅក្នុងបន្ទប់សម្ងាត់ហើយ។ យើងគួរតែចាប់ផ្ដើមពីត្រឹមនេះទៅ។

- ប៉ុន្តែអ្នកស្រី ម៉ាកហ្គូណាហ្គាល និយាយថាពួកយើងត្រូវតែនៅក្នុងអគាររបស់ពួកយើង លើកលែងតែនៅក្នុងថ្នាក់រៀន...

- ខ្ញុំគិតថា- ហេរីនិយាយខ្សឹបៗ - ដល់ពេលដែលត្រូវយកអាវខ្លុកចាស់របស់ប៉ាខ្ញុំចេញមកប្រើការទៀតហើយ។

*

ហេរីទទួលបានកេរមត៌កតែមួយគត់ពីឪពុករបស់វា៖ គឺអាវខ្លុកបំបាំងកាយពណ៌ប្រាក់ដ៏វែងមួយ។ វាគឺជាឱកាសរបស់ពួកគេតែមួយគត់ ដើម្បីលួចចេញពីសាលាទៅជួបហាគ្រ្គីដ ដោយមិនឲ្យនរណាគេដឹង។ ពួកគេចូលគេងនៅម៉ោងធម្មតាដូចសព្វដង ហើយរង់ចាំរហូតទាល់តែនេវីល ឌីន និងស៊ីម្មុសឈប់ពិភាក្សាវែកញែកពីរឿងបន្ទប់សម្ងាត់ ហើយដេកលក់អស់ ទើបក្រោកឡើង ស្លៀកពាក់សាថ្មី ព្រមទាំងយកអាវខ្លុកបំបាំងកាយគ្របពីលើខ្លួនពួកគេ។

ការធ្វើដំណើរតាមផ្លូវរបៀងក្នុងប្រាសាទងងឹត និងគ្មានមនុស្សម្នាក់សោះ មិនមែនជារឿងសប្បាយនោះទេ។ ហេរី ដែលធ្លាប់តែដើរលេងជុំវិញប្រាសាទនាពេលយប់កាលពីមុនជាច្រើនដងមកហើយ មិនដែលប្រទះឃើញថា មានមនុស្សកកកុញច្រើនយ៉ាងនេះទេ។ សាស្ត្រាចារ្យ ប្រធានសិស្ស និងខ្មោចដើរល្បាតទៅមកតាមផ្លូវរបៀងជាគូៗ ពិនិត្យមើលក្រែងមានសកម្មភាពមិនធម្មតាកើតឡើង។ អាវខ្លុកបំបាំងកាយរបស់ពួកគេមិនចេះបិទបាំងសំឡេងរបស់ពួកគេទេ ហើយស្ថានការណ៍រិះតែនឹងរឹកររពេលដែលរ៉ុនជំពប់ជើង នៅចម្ងាយតែប៉ុន្មានម៉ែតពីកន្លែងដែលស្នេពឈរយាមកាមតែប៉ុណ្ណោះ។ សំណាងល្អ ស្នេពស្រាប់តែកណ្ដាស់សឹងតែចំពេលដែលរ៉ុនស្រែកឈឺដែរ។ ពួកគេធូរទ្រូងខ្សាកពេលដែលដើរទៅដល់ទ្វារមុខ ធ្វើពីដើមសែន ហើយក៏រុញទ្វារបើកឡើងតិចៗ។

រាត្រីនោះមានផ្ទៃមេឃភ្លឺស្រឡះ ពោរពេញដោយដួងតារា។ ពួកគេប្រញាប់ប្រញាល់ដើរសំដៅទៅកាន់បង្អួចមានពន្លឺនៃផ្ទះរបស់ហាគ្រ្គីដ ហើយទាល់តែពួកគេទៅដល់ចំពីមុខទ្វារមុខផ្ទះគាត់តែម្ដង ទើបទាញអាវខ្លុកចេញ។

ពួកគេគោះទ្វាររួចមិនបានប៉ុន្មានវិនាទីផង ហាហ្គ្រីដក៏ទាញទ្វារបើកខ្ទាំង។ ពួកគេទាំងបីឈរទល់មុខគ្នា ចំនែកឯហាហ្គ្រីដកំពុងតែតម្រង់ស្នាដាក់ពួកគេ ព្រមទាំងមានឆ្កែប្រមាញ់ ឈ្មោះអាចង្កូម កំពុងតែព្រុសព្ទៗនៅពីក្រោយគាត់។

- អូ!- គាត់បន្លឺឡើង ព្រមទាំងទម្លាក់អាវុធគាត់ចុះ ហើយសម្លក់ពួកគេ។ - ហើយចុះពួកឯងទាំងពីរនាក់ធ្វើអ្វីនៅទីនេះ?

- ហើយយកអានោះមកធ្វើអ្វី?- ហេរីសួរ ដោយចង្អុលដៃទៅកាន់ស្នានោះ ខណៈពេលដែលពួកគេឈានជើងចូលទៅក្នុង។

- អត់អី...គ្មានអីទេ- ហាហ្គ្រីដនិយាយហើមៗ។ - ខ្ញុំស្មានតែជា...គ្មានបញ្ហាទេ...អង្គុយចុះមក...ចាំខ្ញុំទៅឆុងតែឲ្យ...

គាត់ហាក់ដូចជាមិនដឹងថាខ្លួនកំពុងតែធ្វើអ្វីនោះទេ។ គាត់ធ្វើឲ្យកំពប់ទឹកចេញពីកំសៀវ សឹងតែធ្វើឲ្យភ្លើងរលត់ ហើយបន្ទាប់មកទៀតធ្វើឲ្យបែកប៉ាន់តែ ដោយសារតែគាត់កាន់ណែនពេក។

- លោកមិនអីទេឬ ហាហ្គ្រីដ?- ហេរីស្រដី។ - តើលោកមានបានឮដំណឹងពីហឺម៉ាយអូនីទេ?

- អូ! ខ្ញុំឮតើ- ហាហ្គ្រីដតប រាងបែកសំឡេង។

គាត់ចេះតែមើលតាមបង្អួចរហូត។ គាត់ចាក់ទឹកក្តៅឲ្យពួកវាពីរកែវធំៗ (គាត់ភ្លេចដាក់តែចូល) ហើយរៀបនឹងដាក់នំតំណាប់ផ្លែឈើមួយបន្ទះលើចាន ស្រាប់តែមានសំឡេងគោះទ្វារខ្លាំងៗបន្លឺឡើង។

ហាហ្គ្រីដធ្វើជ្រុះនំតំណាប់ផ្លែឈើក្លុក។ ហេរី និងរ៉ុនមើលមុខគ្នាទៅវិញទៅមកទាំងស្លន់ស្លោ បន្ទាប់មកក៏យកអាវខ្លកបំបាំងកាយមកគ្របពីលើខ្លួនពួកគេ ហើយដកថយទៅកន្លៀតជញ្ជាំង។ ហាហ្គ្រីដពិនិត្យមើលចាំឲ្យពួកគេលាក់ខ្លួនរួចរាល់ហើយសិន រួចក៏កញ្ឆក់យកស្នារបស់គាត់ ព្រមទាំងបើកទ្វារគ្រាំងសាជាថ្មីម្តងទៀត។

- សាយណ្ហសួស្តី ហាហ្គ្រីដ។

គឺលោកដាំប័លដ័រ។ គាត់ដើរចូលមកក្នុង ទាំងទឹកមុខនឹងធឹង ហើយមានបុរសម្នាក់ទៀតរូបរាងចម្លែកខ្លាំងខុសពីធម្មតាដើរចូលតាមពីក្រោយ។

ជនចម្លែកនោះជាបុរសកន្ទាត់ កន្ទើម្នាក់ដែលមានសក់ស្កូវរួញ ទឹកមុខពោរពេញដោយភាពអន្ទះសា។ គាត់ស្លៀកសម្លៀកបំពាក់លាយលំគ្នាះ មានតាំងពីអាវកាក់ខ្នាស់ម្មុលឆ្នូតៗ ក្រវាត់កពណ៌ក្រហមឆ្អៅ និងស្បែកជើងកវែងពណ៌ស្វាយមានចុងស្រួចៗ។ ក្រោមដៃរបស់គាត់មានកាន់មួកមូលពណ៌បៃតងដូចក្រូចឆ្មារ។

- នោះគឺជាថៅកែប៉ាទេតើ!- រ៉ុនស្រែកតិចៗ។ - ខននីលូស ហ្វូដហ្ស៍ រដ្ឋមន្ត្រីក្រសួងវេទមន្ត!

ហេរីដាក់រ៉ុនមួយកែងដៃអស់មួយទំហឹងទំរាំតែឲ្យវាបិទមាត់បាន។

ហាហ្គ្រីដប្រែជាមានទឹកមុខស្លេកស្លាំង និងបែកញើសជោក។ គាត់ទម្លាក់ខ្លួនអង្គុយចុះលើកៅអី ម្តងសម្លឹងមើលទៅដាំប័លដ័រ ម្តងសម្លឹងមើលទៅខននីលូស ហ្វូដហ្ស៍។

- រឿងរ៉ាវមិនល្អទេ ហាហ្គ្រីដ- ហ្វូដហ្ស៍និយាយកំបុតៗ។ - រឿងរ៉ាវពិតជាដុនដាបមែនទែនហើយ។ ត្រូវតែមក។ មានការវាយប្រហារបួនដងមកហើយទៅលើអ្នកដែលកើតពីពួកលោកិយ។ បញ្ហាធ្ងន់ធ្ងរណាស់ហើយ។ ក្រសួងត្រូវតែចេញមុខដោះស្រាយ។

- ខ្ញុំមិនដែលទេ- ហាហ្គ្រីដប្រកែក ដោយបង្ហាញទឹកមុខអង្វរករដាក់ ដាំប័លដ័រ - លោកដឹងហើយថាខ្ញុំមិនដែលទេ លោកសាស្ត្រាចារ្យដាំប័លដ័រ លោក...

- ខ្ញុំចង់ឲ្យលោកជ្រាបណ៎ា ខននីលូស ថាខ្ញុំមានទំនុកចិត្តទាំងស្រុងចំពោះហាហ្គ្រីដ- ដាំប័លដ័របន្លឺឡើង ដោយជ្រួញចិញ្ចើមដាក់ហ្វូដហ្ស៍។

- ស្ដាប់ណា៎ អាលប៊ូស- ហ្វូដ្ស៍និយាយទាំងមិនស្រួល។ - ភ័ស្តុតាងទាំងឡាយសុទ្ធតែសំដៅមកហាហ្វ្រីដទាំងអស់។ ក្រសួងត្រូវតែធ្វើអ្វីម្យ៉ាង...អភិបាលសាលាបានមកទាក់ទងហើយ។

- ក៏ប៉ុន្តែ ខននីលូស ខ្ញុំសូមប្រាប់លោកចុះថា ទោះជានាំហាហ្វ្រីដទៅបាត់ ក៏មិនអាចជួយអ្វីបានសូម្បីតែបន្តិច - ដាំប័លដ័រ ស្រដី។ ភ្នែកពណ៌ខៀវរបស់គាត់ពោរពេញទៅដោយភ្លើងកំហឹង ដែលហោរីមិនដែលឃើញពីមុនមកទេ។

- សម្លឹងមើលបញ្ហានេះពីទស្សនវិស័យខ្ញុំវិញ - ហ្វូដ្ស៍ប្រកែក ព្រមទាំងតំរែតំរង់មួករបស់គាត់ហាក់មិនត្រូវចិត្ត។ - ខ្ញុំទទួលសំពាធច្រើនណាស់ហើយ។ ត្រូវតែឲ្យគេឃើញថាបានធ្វើអ្វីខ្លះ។ ប្រសិនបើមិនមែនជាហាហ្វ្រីដមែននោះ គាត់នឹងត្រឡប់មកវិញ ហើយមិនជាប់ពាក់ព័ន្ធអ្វីទៀតទេ។ ប៉ុន្តែខ្ញុំត្រូវតែចាប់គាត់ទៅ។ នេះជាបញ្ហា។ ប្រសិនបើមិនបំពេញកាតព្វកិច្ចខ្ញុំទេ...

- ចាប់ខ្ញុំ?- ហាហ្វ្រីដបន្លឺឡើង ខ្លួនកំពុងតែញញ័រញញ័រ។ - ចាប់ខ្ញុំទៅណា៎?

- តែមួយរយៈពេលខ្លីប៉ុណ្ណោះ- ហ្វូដ្ស៍និយាយ ដោយមិនហ៊ានមើលឲ្យចំភ្នែកហាហ្វ្រីដឡើយ។ - មិនមែនជាការដាក់ទណ្ឌកម្មទេ ហាហ្វ្រីដ គ្រាន់តែជាការការពារទុកជាមុនប៉ុណ្ណោះ។ ប្រសិនបើចាប់បានអ្នកផ្សេងវិញ លោកនឹងទទួលការអនុញ្ញាតឲ្យចេញមកវិញ ហើយនិងទទួលបាននូវការសុំអភ័យទោសដ៏ពេញលេញ...

- កុំថា អាសកាបាន ឲ្យសោះណា៎?- ហាហ្វ្រីដនិយាយគ្រលរៗ។

ហ្វូដ្ស៍មិនទាន់បានទាំងឆ្លើយតបវិញផង ស្រាប់តែឮសូរសំឡេងគោះទ្វារម៉ាំងៗ។

ដាំប័លដ័រជាអ្នកទៅបើកទ្វារ។ លើកនេះហោរីត្រូវមួយកែងដៃវិញចាំឆ្អឹងជំនីរះ វាភ្លេចខ្លួន ដង្ហក់ប៉ិះឮដល់គេ។

លោក លូស៊ីស មេលហ្វ៊យ បោះជំហានវែងៗចូលមកក្នុងខ្ទមរបស់ហាហ្វ្រីដ ក្នុងសម្លៀកបំពាក់អាវខ្លកធ្វើដំណើរពណ៌ខ្មៅដ៏វែងមួយ រីឯទឹកមុខប្រកបដោយស្នាមញញឹមសោមនស្សដ៏សោះកក្រោះមួយ។ អាចង្កូមចាប់ផ្ដើមគ្រហឹម។

- មកដល់ទីនេះហើយរឺ ហ្វូដ្ស៍- គាត់បន្លឺឡើងដោយយល់ស្រប។ - ល្អ ល្អ...

- តើលោកមកធ្វើអ្វីទីនេះ?- ហាហ្វ្រីដគំហកដាក់ទាំងខឹងសម្បា។ - ចេញពីផ្ទះខ្ញុំភ្លាមទៅ!

- សម្លាញ់អើយ! សូមជឿខ្ញុំចុះ ខ្ញុំគ្មានចិត្តបន្តិចណា៎ចង់មកជាន់ ... អឺ ... ឯងហៅកន្លែងនេះថាជាផ្ទះដែរ?- លូស៊ីស មេលហ្វ៊យ ស្រដី ព្រមទាំងបង្ហាញទឹកមុខមើលងាយមើលថោក ខណៈពេលដែលគាត់ក្រឡេកមើលជុំវិញផ្ទះតូចនោះ។ - ខ្ញុំគ្រាន់តែទាក់ទងមកសាលា ហើយគេប្រាប់ខ្ញុំថានាយកសាលានៅទីនេះតែប៉ុណ្ណឹងទេ។

- ហើយចុះ តើលោកមានការអ្វីជាមួយខ្ញុំទៅ លូស៊ីស?- ដាំប័លដ័រសួរ។ គាត់និយាយយ៉ាងមានសុជីវធម៌ តែភ្លើងកំហឹងនៅតែឆោលរាលក្នុងកែវភ្នែកពណ៌ខៀវរបស់គាត់ដដែល។

- គឺដំណឹង *អាក្រក់* ដាំប័លដ័រ- លោកមេលហ្វ៊យឆ្លើយទាំងខ្ជិល ព្រមទាំងយកក្រដាសស្បែកចៀមមួយដុំវែងចេញមក - ប៉ុន្តែអភិបាលយល់ថា ល្មមដល់ពេលដែលលោកត្រូវជៀសទៅម្ខាងហើយ។ នេះគឺជា បញ្ជាព្យួរឈ្មោះ ... លោកនឹងឃើញហត្ថលេខាទាំងដប់ពីរលើក្រដាសនេះ។ ខ្ញុំក្រែងតែពួកយើងយល់ថា លោកកំពុងតែថមថយហើយ។ តើមានការវាយប្រហារប៉ុន្មានដងហើយមកទល់ពេលនេះ? ពីរលើកទៀតហើយនារសៀលនេះ មែនទេ? បើរឿងរ៉ាវនៅតែអញ្ចឹងតទៅទៀត ច្បាស់ជាគ្មានសល់មនុស្សកើតពីពួកលោកិយម្នាក់នៅសាលាហុកវ៉ាតនេះទេ ហើយយើងទាំងអស់គ្នាសុទ្ធតែដឹងហើយថា វានឹងធ្វើឲ្យខាតបង់ធ្ងន់ធ្ងរដល់សាលាប៉ុណ្ណា។

- អូ! ឥឡូវ ស្ដាប់ខ្ញុំសិន លូស៊ីស- ហ្វូដ្ស៍ប្រកែក ហាក់ដូចជាភ័ន្តភាំង - ដាំប័លដ័រត្រូវព្យួរឈ្មោះ...ទេ ទេ...ដល់ដំណាក់កាលនេះ យើងមិនចង់ឲ្យ...

- ការតែងតាំង...រឺក៏ការព្យួរឈ្មោះ...នាយកសាលា គឺជាកិច្ចការរបស់អភិបាលនោះទេ ហ្វូដ្ស៍- លោកមេលហ្វ៍យនិយាយកាត់យ៉ាងរលូន។ - ហើយដោយហេតុតែ ដាំប័លដ័រ គ្មានលទ្ធភាពអាចបញ្ឈប់ការវាយប្រហារទាំងអស់នេះបាន...

- ឥឡូវចាំមើលនៃ លូស៊ីស ប្រសិនបើសូម្បីតែ *ដាំប័លដ័រ* ក៏មិនអាចបញ្ឈប់ការវាយប្រហារទាំងនោះបានផង...- ហ្វូដ្ស៍ស្រដី ឥឡូវបបូរមាត់ខាងលើរបស់គាត់បែកញើសជោក - ខ្ញុំចង់បាននិយថា តើនរណាធ្វើ*កើត*ទៅ?

- ចាំមើលទៅគង់តែដឹងទេ- លោកមេលហ្វ៍យនិយាយ ដោយបញ្ចេញស្នាមញញឹមបង្កប់ដោយពិសពុល។ - ប៉ុន្តែដូចដែលពួកយើងទាំងដប់ពីរនាក់បានបោះឆ្នោតរួចហើយ...

ហាហ្គ្រីដក្រោកឈរឡើងភ្លាម ក្បាលពណ៌ខ្មៅដ៏ស្រមេមស្រមាមរបស់គាត់ឆិតប៉ះនឹងពិតាន។

- ហើយតើមានមនុស្សប៉ុន្មាននាក់ទៅ ដែលលោកត្រូវគំរាមកំហែង និងបង្ខូចកេរ្តិ៍ឈ្មោះ ដើម្បីបង្ខំពួកគេឲ្យយល់ព្រម ប៉ា! មេលហ្វ៍យ?- គាត់ស្រែកមួយទំហឹង។

- ពុទ្ធោ! ពុទ្ធោ! លោកដឹងទេ ថ្ងៃណាមួយកំហឹងរបស់លោកច្បាស់ជាក្លាយជាមោហ៍បាំងមុខលោកឲ្យមានបញ្ហាជាមិនខានទេ ហាហ្គ្រីដ- លោកមេលហ្វ៍យស៊កសម្តីតបវិញ។ - ខ្ញុំសូមទូន្មានលោកទៅចុះ ថាគួរតែកុំស្រែកដាក់អ្នកយាមនៅអាសកាបានបែបនេះអី។ ពួកគេច្បាស់ជាមិនចូលចិត្តអាកប្បកិរិយាដូច្នេះឡើយ។

- លោកមិនអាចយកដាំប័លដ័រចេញបានទេ!- ហាហ្គ្រីដស្រែក ធ្វើឲ្យអាចង្កូមឆ្កែប្រមាញ់ញ័រខ្លួន យំញ៉េកៗលូនចូលទៅក្នុងកន្ត្រករបស់វា។ - បើដកគាត់ចេញ អ្នកដែលកើតពីពួកលោកិយទាំងនោះច្បាស់ជាគ្មានឱកាសរស់ទេ! ច្បាស់ជាមានការសម្លាប់រង្គាលជាមិនខាន!

- កុំឆេវឆាវពេក ហាហ្គ្រីដ- ដាំប័លដ័រស្រដីយ៉ាងឈ្លាសវៃ។ គាត់បែរមកមើល លូស៊ីស មេលហ្វ៍យ។

- ប្រសិនបើអភិបាលចង់ដកខ្ញុំចេញនោះ លូស៊ីស ខ្ញុំស្ម័គ្រចិត្តនឹងជៀសទៅម្ខាង។

- ប៉ុន្តែ...- ហ្វូដ្ស៍និយាយតតិបតតុប។

- *ទេ!*- ហាហ្គ្រីដគ្រហឹម។

ដាំប័លដ័រមិនដកក្រសែភ្នែកពណ៌ខៀវភ្លឺថ្លារបស់គាត់ ចេញពីភ្នែកពណ៌ប្រផេះគ្មានវិញ្ញាណរបស់លូស៊ីស មេលហ្វ៍យឡើយ។

- ទោះបីជាយ៉ាងណាក៏ដោយ- ដាំប័លដ័រពោល ដោយរៀបចំពាក្យសម្តីមួយៗច្បាស់ៗ ដើម្បីកុំឲ្យពួកគេស្តាប់ភ្លេចពាក្យណាមួយ - លោកគួរដឹងថា ខ្ញុំនឹងចាកចេញពីសាលានេះដោយ*សុទ្ធចិត្ត* លុះត្រាតែកាលណា នៅទីនេះគ្មាននរណាម្នាក់ស្មោះត្រង់នឹងខ្ញុំទៀតតែប៉ុណ្ណោះ។ លោកក៏គួរដឹងដែរថា ជំនួយនឹងតែងតែផ្តល់ឲ្យជានិច្ចនៅសាលាហុកវ៉ាត បានដល់អ្នកដែលដង្ហោយរកវា។

ពេលមួយភ្លែតនោះ ហេរីសឹងតែប្រាកដក្នុងចិត្តហើយថា ភ្នែករបស់ដាំប័លដ័របានក្រឡេកមួយឆ្វាច់សំដៅមកកន្លៀតជញ្ជាំង ដែលវា និងរ៉ុនកំពុងតែពួន។

- ពិតជាមានមនោសញ្ចេតនាជ្រៅមែន សូមសរសើរ- មេលហ្វ៍យនិយាយ ព្រមទាំងបង្អោនខ្លួនចុះ។ - ពួកយើងទាំងអស់គ្នានឹងចាំមិនភ្លេចទេដល់ ... អឺ ... មធ្យោបាយគ្រប់គ្រងពិសេសមានតែមួយរបស់លោក ហើយសង្ឃឹមថាអ្នកជំនួសរូបលោកនឹងមានសមត្ថភាពអាចទប់ស្កាត់...អ៊ំ...*ការសម្លាប់រង្គាល*នេះ។

---

[1] ត្រង់នេះ លូស៊ីស មេលហ្វ៍យ ចង់ធ្វើត្រាប់តាមសំឡេងរបស់ហាហ្គ្រីដ។

គាត់ដើរទៅបើកទ្វារផ្ទះ ហើយលំឱនកាយរង់ចាំឲ្យដាំប័លដ័រចេញ។ ហ្វូដ្យ៍ ដៃនៅមិនស្ងៀមជាមួយនឹងមួករបស់គាត់ រង់ចាំឲ្យហាហ្វ្រីដទៅមុនគាត់ ប៉ុន្តែហាហ្វ្រីដនៅឈរទ្រឹង ដកដង្ហើមវែងៗ ហើយនិយាយយ៉ាងប្រុងប្រយ័ត្នថាៈ

- ប្រសិនបើមាននរណាចង់រក *របស់* អ្វីម្យ៉ាង ពួកគេគ្រាន់តែទៅតាម *ពីងពាង* ទៅ បានហើយ។ ពួកវានឹងនាំផ្លូវអ្នកនោះ! ខ្ញុំនិយាយតែប៉ុណ្ណឹងទេ។

ហ្វូដ្យ៍សម្លក់មើលគាត់ទាំងស្រឡាំងកាំង។

- បានហើយ ខ្ញុំទៅហើយ- ហាហ្វ្រីដស្រដី ព្រមទាំងយកអាវធំធ្វើពីស្បែកសត្វកំពឹងដូងមកពាក់។ ប៉ុន្តែពេលដែលគាត់ហៀបនឹងដើរចេញទៅតាមហ្វូដ្យ៍ ស្រាប់តែគាត់បង្អង់ដំណើរម្តងទៀត ហើយស្តីខ្លាំងៗៈ

- ហើយនរណាម្នាក់ត្រូវឲ្យចំណី អាចង្គូម ផងពេលខ្ញុំទៅបាត់។

ទ្វារបិទឮសូរគ្រាំង ហើយរ៉ុនក៏ទាញអាវខ្លួកបំបាំងកាយចេញ។

- ឥឡូវពួកយើងអាសន្នធំហើយ- វានិយាយទាំងស្អកស្អា។ - គ្មានដាំប័លដ័រទៀតទេ។ ពួកគេប្រហែលជាបិទសាលាទៀតផងនាយប់នេះ។ ច្បាស់ជាមានការវាយប្រហារមួយថ្ងៃម្តងហើយ ពេលអត់គាត់នៅ។

អាចង្គូមចាប់ផ្តើមស្រែកលូ ព្រមទាំងខ្វេះខ្វាចលើទ្វារបិទជិតនោះ។

## វគ្គ XV



# អារ៉ាហ្គក

រដូវក្ដៅ កំពុងតែខិតជិតចូលសន្សឹមៗនៅជុំវិញប្រាសាទទាំងមូល។ ផ្ទៃមេឃ ក៏ដូចជាបឹងបួនានាប្រែពណ៌ខៀវត្រួយខ្ចី ចំនែកឯដើមផ្កាធំៗប៉ុនស្ពៃក្ដោបរីកយ៉ាងត្រសុំត្រសាយនៅក្នុងផ្ទះកញ្ចក់ទាំងឡាយ។ ប៉ុន្តែដោយបាត់មុខ ហាគ្រ្គីដ លែងឃើញបណ្ដើរអាចង្កូមនៅលើដី ធ្វើឲ្យហេរីមានអារម្មណ៍ដូចជាខ្វះអ្វីម្យ៉ាង។ និយាយឲ្យអស់ទៅ សូម្បីតែនៅក្នុងប្រាសាទក៏មិនជាល្អជាងគ្នាប៉ុន្មានដែរ ដោយហេតុថារឿងរ៉ាវកាន់តែយ៉ាប់យ៉ឺនទៅៗជាលំដាប់។

ហេរី និងរ៉ុនសាកទៅសួរសុខទុក្ខហឺម៉ាយអូនី ប៉ុន្តែគេហាម អ្នកមកសួរសុខទុក្ខអ្នកជម្ងឺ មិនអោយចូលគិលានដ្ឋានទៀតទេ។

- ពួកយើងមិនប្រថុយទៀតទេ- អ្នកស្រីផុមហ្វ្រីប្រាប់ពួកគេយ៉ាងដាច់ម៉ាត់តាមចន្លោះទ្វារគិលានដ្ឋាន។ - ទេ ខ្ញុំសុំទោស អ្នកវាយប្រហារនោះអាចត្រលប់មកចាត់ការមនុស្សទាំងនេះបានគ្រប់ពេល...

ពេលអត់ដាំប៊័លដ័រទៅ សេចក្ដីភ័យខ្លាចបានរាលដាលលើសពីមុនទៅទៀត ធ្វើឲ្យព្រះអាទិត្យដែលកំដៅជញ្ជាំងប្រាសាទហាក់ដូចជាឈប់ទើរនៅត្រឹមបង្អួច លែងយាត្រាទៅណាទៀតហើយ។ សឹងតែគ្មានទឹកមុខណាមួយនៅក្នុងសាលា ដែលមិនបង្ហាញភាពព្រួយបារម្ភ និងភាពតានតឹងនោះឡើយ ហើយសំណើចណាដែលលាន់ឮកងរំពងពេញផ្លូវរបៀងបែរជាស្ដាប់ទៅគួរឲ្យព្រឺសំបុរ ខុសពីធម្មតា ហើយត្រូវបញ្ឈប់វិញភ្លាម។

ហេរីចេះតែទន្ទេញពាក្យផ្ដែផ្ដាំចុងក្រោយរបស់ ដាំប៊័លដ័រ ជាប់រហូត។ - *ខ្ញុំនឹងចាកចេញពីសាលានេះដោយសុទ្ធចិត្ត លុះត្រាតែកាលណា នៅទីនេះគ្មាននរណាម្នាក់ស្មោះត្រង់នឹងខ្ញុំទៀតតែប៉ុណ្ណោះ... ជំនួយនឹងតែងតែផ្ដល់ឲ្យជានិច្ចនៅសាលាហុកវ៉ាតបានដល់អ្នកដែលដង្ហោយរកវា។-* ប៉ុន្តែតើសម្ដីទាំងនេះមានប្រយោជន៍អ្វីទៅ? តើឲ្យពួកវាត្រូវទៅសុំជំនួយពីនរណាម្នាក់ឲ្យប្រាកដទៅ បើសិនជាអ្នករាល់គ្នាសុទ្ធតែច្របូកច្របល់ និងភ័យខ្លាចដូចជាពួកវាដែរហ្នឹង?

តំរុយដែលហាគ្រ្គីដបន្សល់ឲ្យអំពីពីងពាងនោះគឺហួសពីងាយយល់ទៅទៀត ... តែបញ្ហានៅត្រង់ថា គ្មានឃើញស្រមោលពីងពាងមួយក្បាលនៅក្នុងប្រាសាទដែលត្រូវទៅតាមសោះ។ ហេរីរកសព្វទីកន្លែងដែលវាធ្លាប់ទៅរួចអស់ហើយ ថែមទាំងមានរ៉ុនជួយផង (ជួយទាំងស្ទាក់ស្ទើរ)។ ជាការពិតណាស់ ពួកគេត្រូវខកខានដំណើរ ពីព្រោះថា ពួកគេមិនត្រូវបានអនុញ្ញាតឲ្យដើរទៅណាមកណាតែឯងទេ ពោលគឺត្រូវធ្វើដំណើរក្នុងប្រាសាទជាក្រុមៗជាមួយនឹងសិស្សហ្គ្រីហ្វិនដ័រដទៃទៀត។ មិត្តរួមថ្នាក់ពួកគេភាគច្រើនហាក់ដូចជាត្រេកអរដោយមានគ្រូនាំពីថ្នាក់មួយទៅថ្នាក់មួយ ប៉ុន្តែហេរីយល់ថាគួរឲ្យរំខានណាស់។

ទោះជាយ៉ាងណាក្តី មានមនុស្សម្នាក់ ហាក់ដូចជាពេញចិត្តនឹងឃើញបរិយាកាសចលាចល ពោរពេញដោយការសង្ស័យគ្នាទៅវិញទៅមក នេះណាស់។ ដ្រាកូ មេលហ្វ័យកំពុងតែដើរពើងទ្រូងជុំវិញសាលាហាក់ដូចជាវាទើបនឹងត្រូវគេតែងតាំងជា អនុរក្សក្រុមសិស្សច្បង អញ្ចឹង។ ហេរីមិនបានដឹងថា វាសប្បាយចិត្តខ្លាំងយ៉ាងនេះដោយសារតែរឿងអ្វីទេ រហូតទាល់តែដល់ថ្ងៃមួយក្នុងម៉ោងរៀនឱសថ ប្រហែលជាពីរសប្តាហ៍ក្រោយដាំប័លដ័រ និងហាហ្រ៊ីដចាកចេញ ពេលវាកំពុងអង្គុយក្រោយមេលហ្វ័យ ស្រាប់តែស្តាប់ឮមេលហ្វ័យនិយាយអួតអាងប្រាប់ក្រេប និងហ្គយល័។

- ខ្ញុំគិតទុកតាំងពីយូរមកហើយថាប៉ាប្រហែលជាអ្នកដែលអាចកំចាត់ដាំប័លដ័រចេញបាន- វានិយាយ ដោយគ្មានខ្លាចក្រែងបន្ទាបសំឡេងរបស់វាបន្តិចទេ។ - ខ្ញុំប្រាប់ពួកឯងទៅចុះ គាត់គិតថាតាដាំប័លដ័រហ្នឹងគឺជានាយកសាលាដ៏អន់បំផុតហើយប្រចាំប្រវត្តិសាស្ត្រ។ ឥឡូវ ប្រហែលជាពួកយើងនឹងបាននាយកសាលាត្រឹមត្រូវម្នាក់ហើយ។ គឺអ្នកណាដែលមិន*ចង់*ឲ្យបន្ទប់សម្ងាត់ត្រូវបិទទៅវិញ។ ម៉ាកហ្គូណាហ្គាលក៏នៅមិនបានយូរដែរ គាត់គ្រាន់តែជំនួសប៉ុណ្ណោះ...

ស្នេពដើរហួសហេរី ដោយគ្មាននិយាយអ្វីបន្តិចឡើយអំពីកន្លែងអង្គុយ និងថ្លាងទំនេរដែលហឺម៉ាយអូនីធ្លាប់ប្រើ។

- លោកគ្រូ- មេលហ្វ័យបន្លឺឡើងខ្លាំងៗ។ - លោកគ្រូ ម៉េចក៏*លោក*មិនដាក់ពាក្យសុំធ្វើនាយកសាលាតែម្តងទៅ?

- កុំនិយាយលេងសើចអី មេលហ្វ័យ- ស្នេពតប តែគាត់មិនអាចលាក់បាំងស្នាមញញឹមបន្តិចរបស់គាត់បាននោះទេ។ - សាស្ត្រាចារ្យ ដាំប័លដ័រ គ្រាន់តែត្រូវអភិបាលព្យួរឈ្មោះប៉ុណ្ណោះ។ ខ្ញុំថាមិនយូរប៉ុន្មានគាត់ជួបពួកយើងវិញហើយ។

- មែនអ្ហេ!- មេលហ្វ័យនិយាយ ដោយញញឹមចំអក។ - ខ្ញុំពឹងថា ប៉ាខ្ញុំច្បាស់ជាបោះឆ្នោតឲ្យលោកគ្រូជាមិនខាន ប្រសិនបើលោកគ្រូចង់ដាក់ពាក្យសុំតំណែងនេះ។ ចាំខ្ញុំប្រាប់ប៉ាថា លោកគ្រូគឺជាគ្រូល្អបំផុតនៅទីនេះ...

ស្នេពញញឹម រួចដើរក្រវែលជុំវិញថ្នាក់ សំណាងល្អគាត់អត់ប្រទះភ្នែកចំ ស៊ីម្មុស ហ្វីននីហ្គេន ដែលកំពុងតែធ្វើជាក្អួតដាក់ថ្លាងរបស់វា។

- ខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ដែល ពួកឈាមកខ្វក់ អស់ទាំងនេះមិនទាន់វេចបង្វេចនៅឡើយទៀត- មេលហ្វ័យពោលបន្ត។ - ហ៊ានភ្នាល់ប្រាំហ្កាលឡុនថាអ្នករងគ្រោះបន្ទាប់ច្បាស់ជាស្លាប់មិនខាន។ ស័យមែនដែលហ្រ្គេនជឺរមិនស្លាប់...

សំណាងល្អកណ្តឹងរោទិ៍ឡើងចំពេលនោះ។ ពេលមេលហ្វ័យនិយាយចប់ភ្លាម រ៉ុនហាក់ភ្លែតចុះពីលើកៅអី តែដោយសារសិស្សផ្សេងៗកំពុងតែរវល់ប្រមែប្រមូលកាតាប និងសៀវភៅ គ្មាននរណាម្នាក់ចាប់អារម្មណ៍ពីរឿងនេះទេ។

- ឲ្យខ្ញុំចាត់ការវាទៅ- រ៉ុនគ្រហឹម ខណៈពេលដែលហេរី និងឌីនកំពុងតែក្រៀកដៃវាជាប់។ - ខ្ញុំមិនខ្វល់ទេ។ ខ្ញុំមិនត្រូវការចង្កឹះទេ។ ខ្ញុំនឹងសម្លាប់វាដោយផ្ទាល់ដៃតែម្តង...

- ញាប់ដៃញាប់ជើងឡើង! ខ្ញុំត្រូវនាំពួកឯងទាំងអស់គ្នាទៅថ្នាក់ភូតគាមសាស្ត្រទៀត- ស្នេពស្រែកប្រកាស។ ហើយពួកគេក៏ចេញទៅទាំងទទឹងទិស ដោយមានហេរី រ៉ុន និងឌីននៅពីក្រោយ។ រ៉ុននៅតែព្យាយាមយករួចខ្លួននៅឡើយ។ ពេលដែលស្នេពឃើញពួកគេចេញក្រៅប្រាសាទបាត់ ទើបលែងរ៉ុនបាន ហើយពួកគេក៏ធ្វើដំណើរកាត់ចំការបន្លែសំដៅទៅផ្ទះកញ្ចក់។

ថ្នាក់ភូតគាមសាស្ត្រកាន់តែមានសិស្សតិចទៅៗ។ ឥឡូវបាត់សិស្សអស់ពីរនាក់ទៀតហើយ នោះគឺចាស់ស្ទីន និងហឺម៉ាយអូនី។

សាស្ត្រាចារ្យសប្រ៉ោតឲ្យពួកគេរៀនកាត់ដើម អាប៊ីស៊ីនាន ស្រ៊ីវ៉ិលហ្វីក។ ហេរីដើរទៅចាក់មែកស្វិតៗមួយក្តាប់ដៃចូលទៅក្នុងគំនរកុមបុស ហើយស្រាប់តែមកប្រឈមមុខគ្នាជាមួយនឹង អើនី មេកស៍មីលេន។ អើនីដកដង្ហើមវែងៗ ហើយនិយាយយ៉ាងសមគួរថាៈ

- ហេរី ខ្ញុំគ្រាន់តែចង់និយាយថា ខ្ញុំសោកស្តាយណាស់ដែលសង្ស័យលើឯង។ ខ្ញុំដឹងថាឯងនឹងមិនដែលវាយប្រហារហឺម៉ាយអូនី ហ្គ្រេនជឺរទេ ហើយឲ្យខ្ញុំសូមអភ័យទោសចំពោះពាក្យសម្តីទាំងអំបាលម៉ានដែលខ្ញុំបាននិយាយកន្លងមក។ ពួកយើងទាំងអស់គ្នាសុទ្ធតែជិះទូកតែមួយហើយ អញ្ចឹង...អឺ...

វាហុចដៃធាត់កណ្តៀនចេញមក ហើយហេរីក៏ចាប់ដៃជាមួយវា។

អើនី និងមិត្តរបស់វាឈ្មោះ ហាណា បបួលគ្នាមកធ្វើការលើដើម ស្រ៊ីវ៉ិលហ្វីក ដូចហេរី និងរ៉ុនដែរ។

- អាម្នាក់ ដ្រាកូ មេលហ្វ៍យ ស្អីគេនោះ- អើនីស្រដីពេលកំពុងកាច់មែកឈើងាប់ - វាហាក់ដូចជាសប្បាយចិត្តនឹងរឿងអស់ទាំងនេះណាស់ មិនថាអញ្ចឹង? ឯងដឹងទេ ខ្ញុំគិតថា*វា*ប្រហែលជាទាយាទស្លីធើរីនហើយ។

- ឯងធ្វើដូចជាចេះណាស់អញ្ចឹង- រ៉ុនស្រដី។ វាហាក់ដូចជាមិនអត់អោនឲ្យ អើនី ដោយសុទ្ធចិត្តដូច ហេរី ទេ។

- តើ*ឯង*គិតថាជាមេលហ្វ៍យដែររឺទេ ហេរី?- អើនីសួរ។

- ទេ- ហេរីឆ្លើយយ៉ាងមុះមាត់ ធ្វើឲ្យអើនី និងហាណាសម្លក់វាមិនដាក់ភ្នែក។

មួយវិនាទីក្រោយមក ហេរីស្រាប់តែពើបប្រទះនឹងអ្វីម្យ៉ាង ដែលធ្វើឲ្យវាដាក់រ៉ុនមួយដៃ ពេលកំពុងតែកាន់កន្ត្រៃស្រាប់។

- *អូយ!* តើឯង...

ហេរីកំពុងតែចង្អុលទៅដីចម្ងាយប្រហែលមួយម៉ែតពីវា។ ពីងពាងធំៗជាច្រើនកំពុងតែរត់យ៉ាងលឿនលើដី។

- អូ! មែនហើយ- រ៉ុននិយាយ ដោយព្យាយាមធ្វើជារីករាយ។ - ប៉ុន្តែពួកយើងមិនអាចទៅតាមពួកវាបានទេពេលនេះ...

អើនី និងហាណាកំពុងតែផ្ទៀងត្រចៀកស្តាប់ដោយចង់ដឹង។

ហេរីសម្លឹងមើលពីងពាងទាំងនោះរត់ចេញទៅឆ្ងាយ។

- មើលទៅពួកវាហាក់ដូចជាសំដៅទៅព្រៃហាមឃាត់ហើយ...

និយាយដល់ព្រៃហាមឃាត់ រ៉ុនកាន់តែមានទឹកមុខមិនសប្បាយចិត្តថែមទៀត។

ពេលចប់មេរៀន សាស្ត្រាចារ្យស្នេពដឹកនាំពួកសិស្សទៅរៀនមុខវិជ្ជា ការការពារប្រឆាំងនឹងមន្តអាគមងងឹត ជាបន្ត។ ហេរី និងរ៉ុនដើរយឺតៗពីក្រោយអ្នកឯទៀត ដើម្បីឆ្លៀតឱកាសនិយាយគ្នាកុំឲ្យគេឮ។

- ពួកយើងត្រូវប្រើអាវខ្លុកបំបាំងកាយទៀតហើយ- ហេរីប្រាប់រ៉ុន។ - ពួកយើងអាចយកអាចង្កូមទៅជាមួយ។ វាធ្លាប់ចូលព្រៃជាមួយហាហ្គ្រីដដែរ វាប្រហែលជាអាចជួយបាន។

- ត្រូវហើយ- រ៉ុនយល់ស្រប តែវាកំពុងតែបង្វិលចង្កឹះរបស់វាទាំងភ័យខ្លាច។ - អឺ...តើមាន...តើមានមនុស្សចចកនៅក្នុងព្រៃដែររឺទេ?- វាសួរបន្ថែម ពេលដែលពួកគេអង្គុយចុះតាមកន្លែងអង្គុយធម្មតារបស់ពួកគេនៅខាងក្រោយថ្នាក់របស់ឡក់ហាត។

ដោយព្យាយាមបង្វៀងមិនឆ្លើយសំនួរនោះ ហេរីបែរមកនិយាយលួងលោមថា៖

- ក៏មានរបស់ល្អៗជាច្រើននៅទីនោះដែរ។ ពួក នរអស្សេតរ មិនអីនោះទេ ហើយនៅមានសេះស្នែងជាច្រើនទៀត។

រ៉ុនមិនដែលទៅព្រៃហាមឃាត់ពីមុនមកទេ។ ហេរីធ្លាប់ចូលទីនោះតែម្តងគត់ ក៏រាងចាលលែងចង់ចូលទៀតហើយ។

ឡក់ហាតដើរយ៉ាងស្វាហាប់ចូលមកក្នុងថ្នាក់ ហើយសិស្សទាំងអស់សម្លឹងមើលមកគាត់មិនដាក់ភ្នែក។ គ្រូផ្សេងៗទៀតនៅសាលាសុទ្ធតែមានទឹកមុខស្រពាប់ស្រពោនជាងធម្មតា ប៉ុន្តែឡក់ហាតហាក់ដូចជាគ្មានបាត់បង់ចរិតភ្លៀវភ្លារបស់គាត់បន្តិចទេ។

- រួសរាយឡើង- គាត់ស្រែក ព្រមទាំងញញឹមពព្រាយដាក់ពួកគេទាំងអស់គ្នា - ម៉េចក៏ធ្វើមុខអញ្ចឹង?

សិស្សទាំងឡាយផ្លាស់ប្តូរទឹកមុខម៉ូម៉ៅទៅវិញទៅមក ប៉ុន្តែគ្មាននរណាម្នាក់ឆ្លើយតបទេ។

- តើពួកឯងមិនបានដឹងទេរឺ- ឡក់ហាតនិយាយមួយៗ ហាក់ដូចជាពួកគេទាំងអស់គ្នាស្ដាប់មិនទាន់ - ថាគ្រោះថ្នាក់បានកន្លងផុតទៅហើយ! ឧក្រិដ្ឋជនត្រូវគេចាប់បានយកទៅបាត់ហើយ។

- ថានរណាគេ?- ឌីន ថូម៉ាសស្រដីខ្លាំងៗ។

- អ្នកកម្លោះ! រដ្ឋមន្ត្រីក្រសួងវេទមន្តច្បាស់ជាមិនចាប់ហាហ្គ្រីដទេប្រសិនបើ គាត់មិនប្រាកដមួយរយភាគរយថាហាហ្គ្រីដមានទោសនោះ- ឡក់ហាយបរិយាយប្រាប់ ដោយធ្វើសំឡេងដូចពន្យល់ប្រាប់កូនសិស្សថាមួយបូកមួយស្មើពីរដូច្នោះដែរ។

- អូ! នរណាក៏គាត់ចាប់ដែរ - រ៉ុនប្រកែកឮជាងឌីនទៅទៀត។

- មិនចង់អួតទេ ប៉ុន្តែខ្ញុំឯណេះទើបជាអ្នកដឹងរឿងរ៉ាវច្បាស់ពីការឃុំខ្លួនហាហ្គ្រីដជាងឯង លោកវីស្លី- ឡក់ហាតតបវិញហាក់មោទនៈនឹងខ្លួនឯង។

រ៉ុន ចាប់ផ្ដើមនិយាយថា វាមិនគិតអញ្ចឹងទេ តែបែរជាត្រូវឈប់ពាក់កណ្ដាលទី ពេលហេរីធាក់វាមួយជើងក្រោមតុ។

- កុំភ្លេចថាពួកយើងមិនបាននៅទីនោះទេ!- ហេរីរអ៊ូតិចៗ។

ប៉ុន្តែមោទនភាពដ៏គួរឲ្យខ្ពើមរបស់គាត់ ចេះតែអង្គុយលើចង្អេរលើកខ្លួនឯង ថាគាត់ដឹងយូរមកហើយថា ហាហ្គ្រីដមិនស្រួល ហើយនៅមានទំនុកចិត្តរបស់គាត់ថារឿងហេតុទាំងឡាយឥឡូវចប់សព្វគ្រប់ហើយ ពិតជាធ្វើឲ្យហេរីម៉ួម៉ៅខ្លាំងណាស់ ចង់តែគប់សៀវភៅ *ការធ្វើដំណើរជាមួយវ៉េមភ* ឲ្យចំកណ្ដាលមុខល្ងីល្ងើរបស់ឡក់ហាតនោះទេ។ ផ្ទុយទៅវិញ វាបែរជាលើកទឹកចិត្តខ្លួនឯងវិញដោយសរសេរសារឲ្យរ៉ុនមើល៖ "*ចាប់ផ្ដើមធ្វើការយប់នេះ*"។

រ៉ុនមើលសារនោះហើយ លេបទឹកមាត់ក្អឹក ហើយមៀងមើលទៅកន្លែងអង្គុយនៅខាងខ្លួនវា ដែលហឺម៉ាយអូនីធ្លាប់តែអង្គុយ។ ពេលនឹកឃើញដល់ហឺម៉ាយអូនី ហាក់ដូចជាពង្រឹងការតាំងចិត្តរបស់វាឡើងវិញ ហើយវាក៏ងក់ក្បាល។

*

ប៉ុន្មានថ្ងៃនេះសាលរួមហ្គ្រីហ្វិនដ័រតែងតែមានមនុស្សពេញៗរហូត ពីព្រោះថាចាប់ពីម៉ោងប្រាំមួយទៅ សិស្សហ្គ្រីហ្វិនដ័រទាំងឡាយគ្មានកន្លែងណាត្រូវទៅទៀតទេ។ ពួកគេក៏មានរឿងជាច្រើនត្រូវពិភាក្សាគ្នាដែរ ដូច្នេះសាលរួមទំរាំតែទំនេរមនុស្សគឺហួសពេលពាក់កណ្ដាលអធ្រាត្រទៅហើយ។

ហេរីទៅយកអាវខ្លុកបំបាំងកាយរបស់វាចេញពីវ៉ាលិសភ្លាមក្រោយពីទទួលទានអាហារពេលល្ងាចហើយ រួចមកចំនាយពេលពេញមួយល្ងាចអង្គុយលើអាវនោះ រង់ចាំឲ្យបន្ទប់អស់មនុស្សសិន។ ហ្វ្រេដ និងចច ប្រកួតជាមួយហេរី និងរ៉ុន លេងល្បែងផ្ទាត់បំផ្ទុះ ហើយជីននីអង្គុយមើលពួកគេលើកៅអី ដែលហឺម៉ាយអូនីធ្លាប់អង្គុយសព្វដង។ ហេរី និងរ៉ុនចេះតែធ្វើជាចាញ់ ដើម្បីឲ្យលេងឆាប់ចប់ ប៉ុន្តែទោះជាធ្វើយ៉ាងនេះក៏ដោយ ទំរាំតែហ្វ្រេដ ចច និងជីននីចូលទៅដេក គឺហួសពាក់កណ្ដាលអធ្រាត្រទៅហើយ។

ហេរី និងរ៉ុនរង់ចាំឲ្យទ្វារសយនដ្ឋានបិទអស់ រួចបានទៅយកអាវខ្លុក មកគ្របពីលើខ្លួនពួកគេ ហើយឡើងតាមចន្លោះប្រហោងរូបភាព។

ដល់ពេលធ្វើដំណើរលំបាកលំបិនតាមប្រាសាទទៀតហើយ ពោលគឺត្រូវដើរគេចពីគ្រូយាមល្បាតទាំងឡាយ។ ទីបញ្ចប់ពួកគេបានមកដល់ ទ្វារចូលសាល រួចចាក់សោទ្វារមុខធ្វើពីដើមសែន ដោយព្យាយាមមិនឲ្យឮសូរសំឡេងក្រេតក្រត ហើយចេញទៅខាងក្រៅក្រោមពន្លឺព្រះចន្ទ។

- ជាការពិតណាស់- រ៉ុនស្រាប់តែបន្លឺឡើងភ្លាម ពេលដែលពួកគេកំពុងបោះជំហានវែងៗកាត់វាលស្មៅពណ៌ខ្មៅ។ - ប្រហែលជាពួកយើងចូលទៅក្នុងព្រៃនោះ ហើយឃើញថាគ្មានអ្វីត្រូវទៅតាមទេ។ ពីងពាងទាំងនោះក៏មិនប្រហែលជាទៅក្នុងព្រៃនោះដែរ។ ខ្ញុំដឹងហើយថា បើមើលទៅ ពួកវាហាក់ដូចជាធ្វើដំណើរសំដៅទៅទីនោះមែន ប៉ុន្តែ...

សំឡេងរបស់វាខ្សោយទៅៗរហូតដល់លែងឮ ដោយហាក់ដូចជាមានសង្ឃឹមជាងមុន។

ពួកគេដើរទៅដល់ផ្ទះរបស់ហាហ្គ្រីដ ដែលហាក់ដូចជាឯកោកំសត់ មានតែបង្អួចទទេស្អាត។ នៅពេលដែលហេរីរុញទ្វារបើកឡើង អាចង្គូមអរកខិបកខុបពេលបានឃើញពួកគេ។ ដោយព្រួយបារម្ភខ្លាចវាព្រុសខ្លាំងៗធ្វើឲ្យភ្ញាក់អ្នកគ្រប់គ្នាក្នុងប្រាសាទ ពួកគេក៏ប្រញាប់ទៅយកនំស្ករក្រាមវង្ស ដែលដាក់ក្នុងកំប៉ុងលើធ្នើចង្ក្រានកំដៅឲ្យវាស៊ីភ្លាម ដោយហេតុថានំនោះធ្វើឲ្យធ្មេញរបស់វាស្អិតជាប់គ្នា។

ហេរីទុកអាវខ្លុកបំបាំងកាយនៅលើតុរបស់ហាហ្គ្រីដ។ មិនចាំបាច់ត្រូវការវាទេនៅក្នុងព្រៃងងឹតសូន្យសុងនោះ។

- ឲ្យឆាប់ឡើង អាចង្គូម ពួកយើងទៅដើរលេង- ហេរីនិយាយ ព្រមទាំងអង្អែលជើងរបស់វា ហើយអាចង្គូមលោតហាក់ចេញពីផ្ទះយ៉ាងរីករាយនៅពីក្រោយពួកគេ រួចបោលទៅជាយព្រៃ ព្រមទាំងលើកជើងវាដាក់ផ្អែកនឹងដើមស៊ីកាម័រដ៏ធំមួយ។

ហេរីយកចង្កឹះវេទមន្តវាចេញមក ហើយនិយាយតិចៗថា៖

- *លូម៉ុស!*

មានបន្លឺតូចមួយលេចឡើងនៅចុងចង្កឹះនោះ ល្មមនឹងឲ្យពួកគេមើលផ្លូវឃើញ ដើម្បីរកពីងពាង។

- គំនិតល្អមែន- រ៉ុនសរសើរ។ - ខ្ញុំក៏ចង់បំភ្លឺមួយដែរ ប៉ុន្តែដូចឯងដឹងស្រាប់ហើយ...តិចលោតែវាផ្ទុះ រឺក៏អីទៅ...

ហេរីគោះស្មារ៉ុន រួចចង្អុលទៅវាលស្មៅ។ ពីងពាងពីរកំពុងតែវារយ៉ាងរហ័សដែរហ័សជើងចេញពីពន្លឺចង្កឹះ ចូលទៅពួនក្នុងម្លប់ឈើ។

- យល់ព្រម- រ៉ុនដកដង្ហើមធំ ហាក់ដូចជាប្រុងប្រៀបខ្លួនបំពេញបេសកកម្មស្លាប់រស់មួយ។ - ខ្ញុំត្រៀមរួចហើយ។ តោះទៅ។

ដូច្នេះ ពួកគេក៏ចូលទៅក្នុងព្រៃហាមឃាត់ ដោយមានអាចង្គូមរត់ត្របាញ់ជើងជុំវិញពួកគេ ហិតមើលតាមឫស និងស្លឹកឈើនានា។ ពួកគេដើរតាមដានពីងពាងមួយខ្សែនោះជាប់ ដោយបានពន្លឺពីចង្កឹះហេរី។ ពួកគេដើរអស់ប្រហែលជាម្ភៃនាទី ដោយគ្មាននិយាយស្ដីមួយម៉ាត់ ព្រោះកំពុងតែរវល់ត្រងត្រាប់ស្ដាប់ ខ្លាចក្រែងឮសំឡេងអ្វីផ្សេងក្រៅពីមែកឈើបាក់ និងសំឡេងខ្យល់បក់ស្លឹកឈើ។ បន្ទាប់មក នៅពេលដែលព្រៃកាន់តែក្រាស់ទៅៗ រហូតដល់មើលលែងឃើញផ្កាយនៅលើក្បាល សល់តែពន្លឺចង្កឹះហេរីបំភ្លឺនៅក្នុងសមុទ្រអន្ធការនោះ ពួកគេស្រាប់តែឃើញ ពីងពាងមគ្គុទ្ទេសក៍ របស់ពួកគេវារចេញពីផ្លូវលំ។

ហេរីបង្អង់ដំណើរ ដោយព្យាយាមតាមមើលថាតើពីងពាងទាំងនោះទៅណា ប៉ុន្តែអ្វីៗគ្រប់យ៉ាងដែលនៅក្រៅពីរង្វង់ពន្លឺរបស់វាសុទ្ធតែងងឹតស្លុបមើលអ្វីមិនយល់ឡើយ។ វាមិនដែលធ្លាប់ចូលព្រៃជ្រៅយ៉ាងនេះទេ។ វានៅចាំយ៉ាងច្បាស់ថា ហាហ្គ្រីដបានទូន្មានវាកុំឲ្យចាកចេញពីផ្លូវលំក្នុងព្រៃឲ្យសោះ កាលពីវាមកទីនេះលើកមុន។ ប៉ុន្តែឥឡូវហាហ្គ្រីដនៅចម្ងាយរាប់រយគីឡូម៉ែតឯណោះពីទីនេះ ហើយឥឡូវប្រហែលជាកំពុងអង្គុយសំកុកក្នុងគុកនៅអាសកាបានទៀតផងក៏មិនដឹង ម្យ៉ាងទៀតគាត់ក៏ប្រាប់ដែរថាត្រូវទៅតាមពីងពាង។

អ្វីម្យ៉ាងសើមៗប៉ះដៃហេរី ធ្វើឲ្យវាលោតផ្លោតទៅក្រោយវិញ ជាន់ត្រូវជើងរបស់រ៉ុន ប៉ុន្តែតាមពិតគ្រាន់តែជាច្រមុះរបស់អាចង្គូមសោះ។

- តើឯងគិតយ៉ាងម៉េច?- ហេរីនិយាយទៅរ៉ុន។ វាមើលឃើញតែភ្នែករ៉ុនប៉ុណ្ណោះ ដែលចាំងនឹងពន្លឺចង្កឹះរបស់វា។

- ពួកយើងតស៊ូរហូតបានត្រឹមនេះហើយ- រ៉ុនស្រដី។

អញ្ចឹងពួកគេក៏ទៅតាមស្រមោលប្រិចៗរបស់ពីងពាងចូលទៅក្នុងព្រៃ។ ឥឡូវ ពួកគេដើរមិនបានរហ័សទេ ដោយសារតែមានឫសឈើ និងដង្គត់ឈើរាំងផ្លូវពួកគេ ដែលសឹងតែមើលមិនឃើញដោយសារតែងងឹតពេក។ ហេរីអាចទទួលអារម្មណ៍ដឹងពីដង្ហើមក្តៅៗរបស់អាចង្កូមភាយមកលើដៃវា។ ពួកគេត្រូវឈប់ជាច្រើនដង ដើម្បីឲ្យហេរីអង្គុញចុះ ហើយរកមើលពីងពាងដោយប្រើពន្លឺចង្កឹះ។

ពួកគេដើរអស់យ៉ាងហោចណាស់ក៏ជាងកន្លះម៉ោងដែរ រីឯ អាវរ៉ូប របស់ពួកគេត្រូវទាក់ជាប់រហែកនឹងមែកឈើទាបៗ និងបន្លា។ មួយសន្ទុះក្រោយមក ពួកគេកត់សម្គាល់ឃើញថា ដីហាក់ដូចជាទេរចុះទៅក្រោម ប៉ុន្តែព្រៃនៅតែក្រាស់ដូចមុនដដែល។

បន្ទាប់មក ស្រាប់តែអាចង្កូមព្រុសយ៉ាងខ្លាំង ឮសូរកងរំពងពេញព្រៃ ធ្វើឲ្យ ហេរី និងរ៉ុនព្រឺសម្បុរខ្លាក។

- អីគេ?- រ៉ុនបន្លឺឡើងខ្លាំងៗ ព្រមទាំងសំឡឹងមើលជុំវិញក្នុងស្បៃអន្ធការ ហើយចាប់កែងដៃហេរីយ៉ាងណែន។

- មានអ្វីម្យ៉ាងកំពុងតែមានចលនានៅទីនោះ- ហេរីខ្សឹបប្រាប់។ - ចាំស្តាប់...ស្តាប់មើលទៅដូចជាអ្វីម្យ៉ាងធំណាស់។

ពួកគេផ្ទៀងស្តាប់។ នៅចម្ងាយតែប៉ុន្មានម៉ែតខាងស្តាំដៃពួកគេ អ្វីម្យ៉ាងធំនោះកំពុងតែធ្វើដំណើរសម្រុកកាត់ព្រៃ ធ្វើឲ្យបាក់មែកឈើប្រោកៗ។

- អូ! ទេ- រ៉ុននិយាយ។ - អូ! ទេ! អូ! ទេ! អូ...

- បិទមាត់ទៅ- ហេរីស្រដីយ៉ាងរហ័សរហួន។ - ប្រយ័ត្នវាស្តាប់ឮ។

- ស្តាប់ឮ*ខ្ញុំ*?- រ៉ុនពោលដោយសំឡេងយ៉ាងខ្ពស់ខុសពីធម្មតា។ - វាស្តាប់ឮអាចង្កូមមុនបាត់ទៅហើយ!

ភាពងងឹតនោះហាក់ដូចជាកំពុងតែគាបសង្កត់ខ្លួនប្រាណពួកគេទាំងមូល ខណៈពេលដែលពួកគេកំពុងតែឈររង់ចាំទាំងតក់ស្លុត។ មានលាន់សូរសន្ទឹកដ៏ចម្លែកមួយ ហើយក៏ស្រាប់តែស្ងាត់ទៅវិញ។

- តើឯងគិតថាវាកំពុងតែធ្វើអ្វី?- ហេរីសួរ។

- ប្រហែលជាកំពុងត្រៀមខ្លួនចាំហក់សង្គ្រប់ហើយ- រ៉ុនឆ្លើយ។

ពួកគេឈរចាំនៅទីនោះ ទាំងញ័រខ្លួនចំប្រប់ សឹងតែមិនហ៊ានកំរើកសោះ។

- តើឯងគិតថាវាទៅបាត់ហើយរឺនៅ?- ហេរីខ្សឹប។

- អត់ដឹងទេ...

បន្ទាប់មក នៅខាងស្តាំដៃពួកគេ ស្រាប់តែមានពន្លឺភ្លឺចិញ្ចាចមួយចាំងមកយ៉ាងខ្លាំង ធ្វើឲ្យពួកគេត្រូវគ្រវាសដៃបាំងភ្នែក។ អាចង្កូមព្រុស ហើយព្យាយាមរត់យករួចខ្លួន ប៉ុន្តែបែរជាត្រូវជាប់ក្នុងគុម្ពបន្លា ហើយក៏ព្រុសកាន់តែខ្លាំងឡើង។

- ហេរី!- រ៉ុនស្រែក សំឡេងរបស់វាហាក់ដូចជាធូរស្រាលឡើងវិញ។ - ហេរី វាជាឡានរបស់ពួកយើង!

- ថាម៉េច?

- មកមើលនែ៎!

ហេរីដើរស្រវេស្រវាតាមពីក្រោយរ៉ុនសំដៅទៅប្រភពពន្លឺនោះ ជួនជំពប់ជើងរកដោលទៅមុខម្តងៗ ហើយមួយសន្ទុះក្រោយមក ពួកគេបានមកដល់កន្លែងព្រៃរបោះមួយ។

ឡានរបស់លោក វីស្លី កំពុងតែឈរ ដោយគ្មានមនុស្សជិះខាងក្នុង នៅក្នុងកណ្តាលរង្វង់ព័ទ្ធដោយដើមឈើធំៗ ក្រោមដំបូលមែកឈើយ៉ាងក្រាស់ក្រួន រីឯអំពូលមុខរបស់ឡាននោះបញ្ចេញពន្លឺចែងចាំង។ ខណៈពេលដែលរ៉ុនដើរសំដៅទៅរកឡាន

នោះទាំងប្រហមាត់ផ្លុង ឡាននោះក៏រំកិលយឺតៗសំដៅមករកវាដែរ គឺដូចគ្នាបេះបិទនឹងឆ្កែធំពណ៌ខៀវមួយក្បាលរត់មកទទួលម្ចាស់វា។

- វានៅទីនេះរហូតហ្នឹង!- រ៉ុនឧទានឡើងយ៉ាងត្រេកអរ ព្រមទាំងដើរជុំវិញឡាន។ - មើលវាចុះ។ នៅក្នុងព្រៃយូរធ្វើឲ្យវារញ៉េរញ៉ៃអស់ហើយ...

នៅខាងៗឡានត្រូវដាច់ឆ្កូត និងប្រឡាក់ប្រឡូកសុទ្ធតែភក់។ មិនបាច់សួរក៏ដឹងថា ឡាននោះបើកទៅវិញទៅមកជុំវិញព្រៃនេះដោយខ្លួនឯងដែរ។ អាចង្កូមហាក់មិនចូលចិត្តឡាននោះសោះ។ វាចេះតែនៅក្បែរហេរីជាប់រហូត ហើយញ័រមិនឈប់។ ក្រោយមក ដង្ហើមរបស់វាចាប់ផ្ដើមថយចុះមកធម្មតាវិញ។ ហេរីញាត់ចង្កឹះរបស់វាចូលទៅក្នុងអាវរ៉ូបវាវិញ។

- ខំតែភ័យ ស្មានតែមានអ្វីចង់វាយប្រហារយើង!- រ៉ុនស្រដី ដោយផ្អែកខ្លួនទៅលើឡាននោះ ព្រមទាំងអង្អែលវាថ្នមៗ។ - ខ្ញុំចេះតែឆ្ងល់មិនដឹងជាវាបាត់ទៅណា!

ហេរីមៀងមើលជុំវិញនៅលើដី ក្រែងឃើញមានដានពីងពាង ប៉ុន្តែពួកវារត់ចេញអស់ហើយដោយសារតែពន្លឺភ្លើងឡាន។

- ពួកយើងបាត់ដានហើយ- វានិយាយ។ - ឆាប់ឡើង! តោះទៅរកពួកវាទៀត។

រ៉ុនមិននិយាយអ្វីទេ។ វាមិនកម្រើកខ្លួនឡើយ។ ភ្នែករបស់វាកំពុងសម្លឹងជាប់ទៅលើចំនុចមួយប្រមាណបីម៉ែតពីដី គឺនៅចំពីក្រោយខ្នងហេរី។ មុខរបស់វាពោរពេញទៅដោយភាពតក់ស្លុត។

ហេរីគ្មានទាំងពេលបែរខ្លួនឡើយ។ មានសំឡេងក្រិកៗដ៏ខ្លាំងមួយបានបន្លឺឡើង ហើយក្សិណនោះ វាមានអារម្មណ៍ថា មានអ្វីម្យ៉ាងវែងសុទ្ធតែរោមចាប់វាត្រង់ចង្កេះ ហើយលើកវាផុតពីលើដី ធ្វើឲ្យវាត្រូវព្យួរជើងឡើងលើ ក្បាលចុះក្រោម។ ពេលកំពុងប្រតាយប្រតប់ផង ភ័យស្លុតផង វាស្រាប់តែឮសំឡេងក្រិកៗថែមទៀត ហើយឃើញជើងរបស់រ៉ុនឡើងផុតពីដីដែរ ក្រោយមកឮអាចង្កូមស្រែកថ្ងូរ ហើយលូ...មួយភ្លែតក្រោយមក វាក៏ត្រូវបានចាប់អូសចូលទៅក្នុងព្រៃងងឹត។

ក្បាលនៅសំយុងចុះក្រោមនៅឡើយ ហេរីឃើញថា អ្វីដែលចាប់វានោះ កំពុងតែដើរដោយជើងសុទ្ធតែរោមវែងៗប្រាំមួយ ជើងពីរខាងមុខកំពុងតែក្ដាប់វាយ៉ាងណែននឹងតង្កៀបពណ៌ខ្មៅភ្លឺរលោងមួយគូ។ នៅពីក្រោយវា វាឮសំឡេងសត្វនោះមួយក្បាលទៀត ដែលច្បាស់ជាកំពុងតែកាន់រ៉ុនមិនខាន។ ពួកគេកំពុងតែធ្វើដំណើរជ្រៅទៅៗចូលទៅកណ្ដាលព្រៃហើយ។ ហេរីឮសំឡេង អាចង្កូមកំពុងតែប្រវាយប្រតប់ដើម្បីរំដោះខ្លួនចេញពីបិសាចទីបី ព្រមទាំងស្រែកព្រុសខ្លាំងៗ ប៉ុន្តែទោះជាហេរីចង់ស្រែកយ៉ាងណា ក៏ស្រែកមិនរួចដែរ។ វាហាក់ដូចជាបានទុកសំឡេងរបស់វានៅនឹងឡានក្នុងព្រៃរបោះនោះអញ្ចឹង។

វាមិនដឹងថា ត្រូវនៅក្នុងកណ្ដាប់ដៃសត្វនោះយូរប៉ុណ្ណាទេ។ វាគ្រាន់តែដឹងថា ដល់ពេលមួយនោះ ភាពងងឹតស្រាប់តែរសាយបន្តិចម្ដងៗល្មមនឹងឲ្យវាមើលឃើញដីរាយប៉ាយដោយស្លឹកឈើ ឥឡូវមានសុទ្ធតែពីងពាងទាំងអស់។ វាផ្ងៀងកមើលដឹងថា ពេលនេះពួកគេបានមកដល់មាត់រន្ធដ៏ជ្រៅមួយ ពោលគឺជារូងដែលគ្មានដើមឈើដុះព័ទ្ធជុំវិញអ្វីទេ បណ្ដាលឲ្យពន្លឺផ្កាយចាំងយ៉ាងភ្លឺចិញ្ចែងទៅលើទិដ្ឋភាពដ៏អាក្រក់បំផុត ដែលវាធ្លាប់បានពេបប្រទះ។

ពីងពាង។ មិនមែនជាពីងពាងតូចៗដូចពពួកពីងពាងវារលើស្លឹកឈើនោះទេ។ គឺពីងពាងដែលមានទំហំប៉ុនរទេះសេះ ភ្នែកប្រាំបី ជើងប្រាំបី ពណ៌ខ្មៅ សុទ្ធតែរោម និងមានមាឌធំដូចយក្ស។ ពីងពាងដ៏សម្បើមដែលកំពុងតែកាន់ហេរីនេះបានធ្វើដំណើរចុះតាមជម្រាលទេរមួយ សំដៅសំណាញ់រាងមូលយ៉ាងស្រអាប់ ដែលស្ថិតនៅចំកណ្ដាលរូង ខណៈពេលដែលគ្នាគ្នីរបស់វាខិតចូលមកព័ទ្ធជុំវិញ ព្រមទាំងគោះតង្កៀបរបស់ពួកវាយ៉ាងរំភើប ដោយឃើញចំណីឆ្ងាញ់។

ហេរីធ្លាក់ពោបទៅលើដី ពេលដែលពីងពាងនោះលែងវា។ រ៉ុន និងអាចង្កូមធ្លាក់ក្តុកៗនៅជិតវា។ អាចង្កូមលែងស្រែកលូទៀតហើយ បែរជាសម្ងំខ្លួនស្ងៀមនឹងនៅកន្លែង។ រ៉ុនមានទឹកមុខដូចគ្នាបេះបិទនឹងអារម្មណ៍ហេរីនាពេលនោះ។ មាត់របស់វាលាតវែងហាក់ដូចជាចង់ស្រែកតែស្រែកមិនចេញ ចំនែកឯភ្នែករបស់វាឡើងសដូចភ្នែកត្រីស្ងោរ។

ភ្លាមនោះ ហេរីចាប់អារម្មណ៍ថាពីងពាងដែលបានទម្លាក់វាចុះនោះ កំពុងតែនិយាយអ្វីម្យ៉ាង។ ពិបាកនឹងស្តាប់ណាស់ ពីព្រោះថាវាចេះតែគោះតង្កៀបពេលនិយាយបានមួយម៉ាត់ៗ។

- អារ៉ាហ្គក!- វាស្រែកហៅ។ - អារ៉ាហ្គក!

ពីងពាងមួយក្បាល ទំហំប៉ុនកូនដំរី ចេញមកពីក្នុងសំណាញ់វាញមូលស្រអាប់នោះ យឺតៗ។ មានពណ៌ប្រផេះតិចៗលាយនឹងពណ៌ខ្មៅលើខ្លួន និងជើងរបស់វា ហើយភ្នែកនីមួយៗលើក្បាលសុទ្ធតែតង្កៀបដ៏អាក្រក់របស់វា មានពណ៌សដូចទឹកដោះគោ។ តាមពិត វាខ្វាក់ភ្នែក។

- មានការអី?- វាបន្លឺឡើង ព្រមទាំងគោះតង្កៀបរបស់វាយ៉ាងញាប់។

- មនុស្ស- ពីងពាងដែលបានចាប់ហេរីឆ្លើយ។

- តើជាហាគ្រីដឬ?- អារ៉ាហ្គកសួរ ព្រមទាំងខិតទៅជិត ភ្នែកដូចទឹកដោះគោទាំងប្រាំបីរបស់វាផទៅផមកមិនដឹងទិសតំបន់។

- មនុស្សចម្លែក- ពីងពាងដែលបានចាប់រ៉ុនតប។

- សម្លាប់ពួកវាទៅ- អារ៉ាហ្គកនិយាយទាំងម៉ូម៉ៅ។ - កំពុងតែដេកផង...

- ពួកយើងជាមិត្តរបស់ហាគ្រីដ- ហេរីស្រែក។ វាហាក់ដូចជាបាត់ព្រលឹងព្រលះចេញពីខ្លួនអស់ហើយ។

តង្កៀបទាំងអស់បន្លឺឡើងក្រិកៗព្រមៗគ្នាទ្រហឹងអឹងកងជុំវិញរូងនោះ។

អារ៉ាហ្គកបង្អាក់ដំណើរ។

- ហាគ្រីដមិនដែលបញ្ជូនមនុស្សមករូងយើងពីមុនទេ- វានិយាយមួយៗ។

- ហាគ្រីដមានរឿងហើយ- ហេរីនិយាយ ដោយដកដង្ហើមយ៉ាងលឿន។ - ដូច្នេះហើយបានជាពួកយើងមក។

- មានរឿង?- ពីងពាងចំណាស់នោះពោលបែបឆ្ងល់ ហើយហេរីគិតថា សំឡេងនោះហាក់បង្កប់នូវក្តីព្រួយបារម្ភ។ - ប៉ុន្តែហេតុអ្វីបានជាគាត់បញ្ជូនពួកឯងមក?

ហេរីគិតថាប្រុងនឹងក្រោកឈរ តែបែរជាដូរចិត្តវិញ។ វាគិតថាទោះជាវាឈរក៏ឈរមិននឹងដែរ។ អញ្ចឹងវាក៏និយាយដោយអង្គុយផ្ទាល់ដី និងធ្វើចិត្តឲ្យនឹងនបំផុតតាមដែលអាចធ្វើបាន។

- នៅឯសាលា ពួកគេគិតថាហាគ្រីដបាន...បាន...បានធ្វើអ្វីម្យ៉ាងចំពោះកូនសិស្ស។ ពួកគេនាំគាត់ទៅអាសកាបាន បាត់ហើយ។

អារ៉ាហ្គក គោះតង្កៀបរបស់វាយ៉ាងខឹងសម្បា ធ្វើឲ្យបន្លឺសូរកងរំពង អមដោយសំឡេងបន្ទរពីហ្វូងពីងពាងនៅជុំវិញរូងនោះ។ វាដូចជាការទះដៃអបអរសាទរដែរ ខុសតែត្រង់ថា ជាធម្មតា ការទះដៃអបអរសាទរមិនដែលធ្វើឲ្យហេរីមានអារម្មណ៍ភ័យផងឈឺផងដូចពេលនេះទេ។

- ប៉ុន្តែរឿងនោះចប់សព្វគ្រប់តាំងពីច្រើនឆ្នាំមុនម្ល៉េះ- អារ៉ាហ្គកស្រដីទាំងក្តៅក្រហាយ។ - យូរៗឆ្នាំមកហើយ។ យើងនៅចាំច្បាស់ណាស់។ នោះហើយគឺជាមូលហេតុដែលពួកគេបង្ខំឲ្យគាត់ចាកចេញពីសាលា។ ពួកគេជឿថា យើងគឺជាបិសាចដែលរស់នៅក្នុងកន្លែងឈ្មោះថា "បន្ទប់សម្ងាត់" ។ ពួកគេគិតថាហាគ្រីដបានបើកបន្ទប់នោះ រួចដោះលែងយើង។

- ហើយលោក...លោកមិនមែនមកពីក្នុងបន្ទប់សម្ងាត់ទេវី?- ហេរីសួរ ថ្វាសរបស់វាបែកញើសជោក។

- យើង!- អារ៉ាហ្គកឧទានឡើង ព្រមទាំងគោះតង្កៀបវាយ៉ាងក្រេវក្រោធ។ - យើងមិនបានកើតក្នុងប្រាសាទនោះទេ។ យើងជាអ្នកមកពីទឹកដីឆ្ងាយ។ អ្នកធ្វើដំណើរម្នាក់បានឲ្យយើងទៅហាគ្រ្គីដពេលដែលយើងនៅជាស៊ុតនៅឡើយ។ ហាគ្រ្គីដពេលនោះគ្រាន់តែជាក្មេងប្រុសម្នាក់ប៉ុណ្ណោះ ប៉ុន្តែគាត់ចេះថែរក្សាយើង ជួយលាក់យើងនៅក្នុងទូដាក់ចានឆ្នាំងក្នុងប្រាសាទ ជួយរកចំណីសល់ពីលើតុមកឲ្យយើងឆី។ ហាគ្រ្គីដគឺជាមិត្តសម្លាញ់របស់យើង ហើយក៏ជាមនុស្សល្អម្នាក់ដែរ។ នៅពេលដែលយើងត្រូវបានគេរកឃើញ និងត្រូវគេចោទពីបទសម្លាប់ក្មេងស្រីម្នាក់ គាត់ចេញមុខការពារយើង។ យើងក៏មករស់នៅក្នុងព្រៃនេះតាំងតែពីពេលនោះរហូតមក ហើយហាគ្រ្គីដក៏ឧស្សាហ៍មកលេងយើងដែរ។ គាត់ថែមទាំងបានរកប្រពន្ធឲ្យយើងម្នាក់ទៀតផង។ នាងឈ្មោះ ម៉ូហ្សាក់។ ឯងឃើញហើយថាតើគ្រួសារយើងបែកមែកសាខាបានប៉ុណ្ណា ទាំងអស់នេះសុទ្ធតែបានមកពីគុណស្រ័យហាគ្រ្គីដទាំងអស់...

ហេរីប្រមែប្រមូលសេចក្តីក្លាហានរបស់វាដែលនៅសេសសល់ទាំងប៉ុន្មាន។

- អញ្ចឹងលោកមិនដែល...មិនដែលវាយប្រហារនរណាម្នាក់ទេវី?

- មិនដែលទេ- ពីងពាងចំណាស់នោះនិយាយគ្រលរៗ។ - បើមានមែននោះគឺមកពីសភាវគតិរបស់យើងតែប៉ុណ្ណោះ។ ប៉ុន្តែដើម្បីជាការគោរពដល់ហាគ្រ្គីដ យើងមិនដែលធ្វើបាបមនុស្សឡើយ។ សាកសពក្មេងស្រីដែលត្រូវបានសម្លាប់នោះត្រូវបានគេរកឃើញនៅក្នុងបន្ទប់ទឹក។ យើងមិនដែលបានទៅអើតមើលកន្លែងណាផ្សេងក្នុងប្រាសាទឡើយក្រៅពីទូដាក់ចានឆ្នាំង ដែលយើងរស់នៅ។ ពួកយើងជាប្រភេទសត្វដែលចូលចិត្តទីងងឹត និងភាពស្ងប់ស្ងាត់...

- ប៉ុន្តែអញ្ចឹង...តើលោកមានដឹងថាអ្វីសម្លាប់ក្មេងស្រីនោះទេ?- ហេរីសួរ។ - ពីព្រោះថារបស់នេះ វាត្រលប់មកវាយប្រហារមនុស្សទៀតហើយ...

សំឡេងរបស់វាត្រូវលុបបាត់ដោយសារតែការផ្ទុះឡើងនូវសំឡេងគោះតង្កៀប និងសំឡេងតន្រ្តំជើងខ្លាំងៗ ហាក់ដូចជាខឹងសម្បា។ រូបរាងពណ៌ខ្មៅធំៗកំពុងតែរំកិលជុំវិញខ្លួនវា។

- ភាវៈដែលរស់នៅក្នុងប្រាសាទនោះ- អារ៉ាហ្គកស្រដី។ - គឺជាសត្វបុរាណមួយក្បាលដែលពួកពីងពាងខ្លាចជាទីបំផុត។ យើងនៅចាំច្បាស់ណាស់ថា យើងបានលន់តួអង្វរករហាគ្រ្គីដឲ្យលែងយើងចេញទៅយ៉ាងដូចម្តេចខ្លះ ពេលដែលយើងមានអារម្មណ៍ថាបិសាចនោះកំពុងតែរាតត្បាតក្នុងសាលា។

- តើវាជាអ្វីទៅ?- ហេរីបន្លឺឡើងទាំងប្រញាប់។

សំឡេងគោះតង្កៀប និងសំឡេងតន្រ្តំជើងបានបន្លឺឡើងម្តងទៀត។ ពីងពាងទាំងនោះហាក់ដូចជាកាន់តែខិតមកជិតហើយ។

- ពួកយើងមិននិយាយពីវាទេ!- អារ៉ាហ្គកស្រែកយ៉ាងសាហាវ។ - ពួកយើងមិនហៅឈ្មោះវាទេ! សូម្បីតែហាគ្រ្គីដក៏យើងមិនដែលប្រាប់គាត់ដែរ ទោះជាគាត់សួរប៉ុន្មានរយដងក៏ដោយ។

ហេរីមិនចង់ជជីកសួរទៀតទេ ព្រោះថាពួកពីងពាងកាន់តែចូលកៀកហើយ។ អារ៉ាហ្គកហាក់ដូចជានឿយហត់លែងចង់និយាយស្តីទៀតហើយ។ វាកំពុងតែថយក្រោយយឺតៗចូលទៅក្នុងសំណាញ់រាងមូលរបស់វាវិញ ប៉ុន្តែគ្នីគ្នាពីងពាងរបស់វានៅតែបន្តចូលមកបន្តិចម្តងៗសំដៅរកហេរី និងរ៉ុន។

- អញ្ចឹង ពួកយើងទៅសិនហើយ- ហេរីស្រែកហៅអារ៉ាហ្គកទាំងអស់សង្ឃឹម ដោយឮស្នូរស្លឹកឈើបក់ទៅមកពីក្រោយវា។

- ទៅ?- អារ៉ាហ្គកតប។ - យើងមិនគិតអញ្ចឹងទេ...

- ប៉ុន្តែ...ប៉ុន្តែ...

- កូនប្រុសស្រីរបស់យើងស្តាប់បញ្ជាយើងមិនធ្វើបាបហាហ្វ្រីដទេ។ ប៉ុន្តែយើងមិនអាចធានាបានទេចំពោះសាច់ស្រស់ៗដែលដើរចូលមកក្នុងមាត់សីហៈដោយឯកឯងនោះ។ លាហើយ មិត្តភក្តិហាហ្វ្រីដ។

ហេរីបង្វិលខ្លួនមកមើល ឃើញពីងពាងជាច្រើនផ្តុំគ្នាយ៉ាងក្រាស់ឃ្មឹក លេចឡើងខ្ពស់ផុតក្បាល នៅតែប៉ុន្មានម៉ែតពីវាប៉ុណ្ណោះ។ ពួកវាកំពុងតែគោះតង្កៀបរន្ថើនៗ ឯភ្នែកជាច្រើនរបស់ពួកវាចាំងពន្លឺភ្លឺបភ្លែតក្នុងក្បាលពណ៌ខ្មៅដ៏គគ្រិចរបស់ពួកវា...

សូម្បីតែពេលដែលវាឈោងរើសចង្កឹះរបស់វា ហេរីដឹងរួចទៅហើយថាគ្មានបានប្រយោជន៍ទេ ពួកវាមានគ្នាច្រើនណាស់ ប៉ុន្តែខណៈពេលដែលវាព្យាយាមក្រោកឈរ ត្រៀមខ្លួនប្រយុទ្ធស្លាប់រស់ ស្រាប់តែសំឡេងដ៏ខ្លាំងមួយបានបន្លឺឡើង ហើយក៏មានពន្លឺមួយបាញ់ជះចូលមកក្នុងរូងនោះ។

ឡានរបស់លោកវីស្លី កំពុងតែបើកកក្រើកមេឃកក្រើកដីចុះតាមជម្រាលនោះ ភ្លើងខាងមុខបើកអស់ៗមួយទំហឹង ឯស៊ីផ្លេស្រែកច្រេចៗជាប់រហូត ព្រមទាំងបុកពួកពីងពាងខ្ទាតប៉ើងទៅម្ខាងៗ។ ពីងពាងជាច្រើនត្រូវដួលផ្ងារជើងខ្វៃៗឡើងលើ។ ឡាននោះឈប់ង៉ក់ពីមុខហេរី និងរ៉ុន បន្ទាប់មកទ្វារក៏របើកឡើងខ្ទាក។

- ទៅយកអាចង្កូមមក!- ហេរីស្រែក ព្រមទាំងហក់ចូលទៅកៅអីខាងមុខ។ រ៉ុនចាប់ឆ្កែប្រមាញ់ត្រឹមពាក់កណ្តាលខ្លួន រួចគ្រវែងវាចូលទៅខាងក្រោយឡាន។ ទ្វារក៏បិទវិញគ្រាំង។ រ៉ុនមិនបានប៉ះឧបករណ៍បង្កើនល្បឿនទេ ព្រោះថាឡាននោះលែងត្រូវការវាទៀតហើយ។ ម៉ាស៊ីនចាប់ឆេះឡើង លាន់សូរកងរំពង ហើយពួកគេក៏ចេញដំណើរទៅ ថែមទាំងបុកពីងពាងជាច្រើនទៀត។ ពួកគេបង្កើនល្បឿនឡើងទួល ចេញពីរូងនោះ ហើយមិនយូរប៉ុន្មានក៏បើកដូចព្យុះកាត់ព្រៃបុកនេះបុកនោះ ចំនែកឯមែកឈើវាត់ខ្វាប់ៗលើកញ្ចក់ ខណៈពេលដែលឡាននោះបើកកាច់កុងចុះឡើងយ៉ាងឈ្លាសវៃរកមើលចន្លោះទូលាយៗ។ មើលទៅវាហាក់ដូចជាចំនាំផ្លូវក្នុងព្រៃនេះច្បាស់ណាស់។

ហេរីមៀងមើលរ៉ុន។ មាត់របស់វានៅតែចំហចង់ស្រែកតែស្រែកមិនចេញ ប៉ុន្តែភ្នែករបស់វាលែងដូចត្រីស្ងោរទៀតហើយ។

- ឯងមិនអីទេរឺ?

រ៉ុនសម្លឹងមើលទៅមុខជាប់ និយាយស្តីមិនចេញឡើយ។

ពួកគេបើករកផ្លូវចេញកាត់តាមព្រៃព្រឹក្សាលតាវល្លិ រីឯអាចង្កូមស្រែកលូខ្លាំងៗនៅកៅអីខាងក្រោយ ហើយហេរីឃើញកញ្ចក់ចំហៀងដាច់ធ្លាក់ប៉ិតពេលដែលពួកគេបើកប៉ះដើមសែនដ៏ធំមួយ។ ដប់នាទីក្រោយពីការរលាក់ក្នុងក្នាំងដូចជិះរទេះគោមក ព្រៃឈើជុំវិញចាប់ផ្តើមស្តើងទៅៗ ហើយហេរីមើលឃើញផ្ទៃមេឃបានខ្លះហើយ។

ឡាននោះឈប់យ៉ាងប្រថុចញ៉ុច សឹងតែធ្វើឲ្យពួកគេត្រូវផ្កាប់មុខនឹងកញ្ចក់ខាងមុខទៅហើយ។ ពួកគេបានមកដល់ជាយព្រៃហើយ។ អាចង្កូមលោតបុកនឹងបង្អួច អន្ទះសាចង់តែចេញទៅក្រៅ ហើយពេលដែលហេរីបើកទ្វារឲ្យវា វាស្រាប់តែបោលប្រុយកាត់ដើមឈើទៅផ្ទះរបស់ហាហ្វ្រីដ ឯកន្ទុយវាធ្លាក់ស្តូកនៅចន្លោះជើង។ ហេរីក៏ចេញក្រៅដែរ ហើយប្រហែលជាមួយនាទីក្រោយមកអវៈយវៈរបស់រ៉ុនហាក់ដូចជាមានវិញ្ញាណឡើងវិញ រួចវាក៏ចេញក្រៅតាម ប៉ុន្តែខ្លួនប្រាណនៅតែរឹងឆ្អឹង ឯភ្នែកសម្លឹងជាប់មិនប្រិចសោះ។ ហេរីគោះឡាននោះថ្នមៗដោយក្តីដឹងគុណ ពេលដែលវាថយចូលទៅក្នុងព្រៃ រហូតដល់ផុតកន្ទុយភ្នែក។

ហេរីត្រលប់ទៅក្នុងផ្ទះរបស់ហាហ្វ្រីដវិញដើម្បីយកអាវខ្លូកបំបាំងកាយ។ អាចង្កូមកំពុងតែដណ្តប់ភួយញ័រទទ្រើកក្នុងកន្ត្រករបស់វា។ នៅពេលដែលហេរីចេញមកក្រៅវិញ វាឃើញរ៉ុនកំពុងតែក្អួតយ៉ាងខ្លាំងនៅចំការល្ពៅ។

- ទៅតាមពីងពាង- រ៉ុននិយាយខ្សោយៗ ព្រមទាំងជូតមាត់នឹងដៃអាវវា។ - ខ្ញុំនឹងមិនលើកលែងឲ្យហាហ្គ្រីដជាដាច់ខាត។ សំណាងហើយដែលពួកយើងនៅរស់។

- ខ្ញុំយល់ថា គាត់ប្រហែលជាគិតថា អារ៉ាហ្គុក នឹងមិនធ្វើបាបមិត្តភក្តិគាត់ទេ មើលទៅ- ហេរីស្រដី។

- ហ្នឹងហើយគឺជាបញ្ហារបស់ហាហ្គ្រីដ!- រ៉ុនឧទានឡើង ព្រមទាំងយកដៃដំជញ្ជាំងផ្ទះផូងៗ។ - គាត់តែងតែគិតថា បិសាចមិនកាចសាហាវដូចឈ្មោះទេ ហើយមើលចុះ ថាគាត់ទទួលបានលទ្ធផលអ្វី! បានតែគុកមួយក្នុងអាសកាបានតែប៉ុណ្ណឹង!- ឥឡូវវាកំពុងតែញ័រខ្លួនយ៉ាងខ្លាំងហាក់ដូចជាមិនអាចទប់អារម្មណ៍បាន។ - តើមានបានប្រយោជន៍អ្វីទៅក្នុងការបញ្ជូនពួកយើងទៅក្នុងនោះ? ខ្ញុំចង់ដឹងណាស់ ថាតើពួកយើងបានដឹងអ្វីខ្លះ?

រ៉ុនបញ្ចេញខ្យល់តាមច្រមុះយ៉ាងឮ។ ជាក់ស្ដែងណាស់ ការយក អារ៉ាហ្គុក ទៅលួចចិញ្ចឹមក្នុងទូដាក់ចានឆ្នាំង រឿងនេះគាត់ក៏មានទោសដែរ។

ពេលដើរជិតដល់ប្រាសាទ ហេរីទាញអាវខ្លុកមកបំបាំងកាយភ្លាមដើម្បីកុំឲ្យគេមើលឃើញជើង បន្ទាប់មកពួកគេរុញទ្វារមុខដែលឮសូរក្រេតក្រតៗឲ្យចំហបន្តិច។ ពួកគេដើរត្រលប់មកវិញយ៉ាងប្រុងប្រយ័ត្នកាត់ទ្វារចូលសាល ឡើងតាមជណ្ដើរថ្មើមថ្មដល់ថ្នាក់មិនហ៊ានដកដង្ហើមល្ពឹកណាដើរប៉ះផ្លូវរបៀងដែលមានអ្នកយាមកាមដើរត្រួតពិនិត្យមើលយ៉ាងម៉ត់ចត់។ ចុងបញ្ចប់ ពួកគេក៏មានសុវត្ថិភាពបានមកដល់សាលរួម ហ្គ្រីហ្វីនដ័រ។ ថ្មើរនោះភ្លើងក្នុងចង្ក្រានកំដៅឆេះអស់សល់តែផេះពណ៌ក្រហមទុំភ្លឺៗតែប៉ុណ្ណោះ។ ពួកគេដោះអាវខ្លុកចេញ ហើយឡើងតាមជណ្ដើរវិលទៅកាន់សយនដ្ឋានរបស់ពួកគេ។

រ៉ុនផ្ដួលខ្លួនលើគ្រែដោយគ្មានខ្វល់ពីរឿងដោះខោអាវអ្វីនោះទេ។ ប៉ុន្តែ ហេរីមិនជាងងុយដេកប៉ុន្មានទេ។ វាអង្គុយនៅគែមគ្រែបង្គោលបួនរបស់វា សញ្ជឹងគិតអំពីអ្វីៗគ្រប់យ៉ាងដែល អារ៉ាហ្គុក បាននិយាយ។

វាគិតថា សត្វដែលពួននៅកន្លែងណាមួយក្នុងប្រាសាទ ស្ដាប់មើលទៅដូចជាបិសាចប្រភេទដូចវ៉ុលដឺម៉ដែរ ... សូម្បីតែបិសាចឯទៀតក៏មិនហ៊ានហៅឈ្មោះវាដែរ។ ប៉ុន្តែវា និងរ៉ុនគ្មានបានតម្រុយនឹងរកឃើញថា សត្វនោះជាអ្វីទាល់តែសោះ កុំថាឡើយដឹងពីរបៀបដែលវាបានបង្កកជនរងគ្រោះទាំងនោះ។ សូម្បីតែហាហ្គ្រីដក៏មិនដែលដឹងថាមានអ្វីនៅក្នុងបន្ទប់សម្ងាត់នោះដែរ។

ហេរីលើកជើងដាក់លើគ្រែ ហើយផ្អែកខ្លួនទល់នឹងខ្នើយ ភ្នែកគយគន់ព្រះចន្ទចាំងពន្លឺព្រិចៗមកលើវា តាមបង្អួចអគារ។

វាមិនដឹងថាពួកគេអាចធ្វើអ្វីបានទៀតទេ។ ពួកគេទាល់ច្រកហើយ។ រីតដលបានចាប់មនុស្សខុស ធ្វើឲ្យទាយាទស្លីតឺរីនត្រូវរួចខ្លួន ហើយគ្មាននរណាគេដឹងថា អ្នកដែលបើកបន្ទប់សម្ងាត់លើកនេះជាមនុស្សតែមួយ រឺផ្សេងគ្នាឡើយ។ គ្មាននរណាទៀតត្រូវសួរយោបល់នោះទេ។ ហេរីផ្ដេកខ្លួន ជញ្ជឹងគិតពីអ្វីដែលអារ៉ាហ្គុកបាននិយាយ។

វាកាន់តែងងុយដេកទៅៗ ស្រាប់តែពន្លឺនៃសេចក្ដីសង្ឃឹមចុងក្រោយរបស់ពួកគេលេចឡើងចំពោះវា ធ្វើឲ្យវាក្រោកអង្គុយឡើងត្រង់ខ្លួនភ្លឹង។

- រ៉ុន- វានិយាយតិចៗក្នុងទីងងឹត។ - រ៉ុន!

រ៉ុនក្រោកឡើងដោយស្រែកស្រដៀងនឹងអាចង្គុម ភ្នែកវាសំលឹងក្រឡិបក្រឡាប់ជុំវិញ ហើយក៏ឃើញហេរី។

- រ៉ុន...ក្មេងស្រីដែលស្លាប់នោះ។ អារ៉ាហ្គុកនិយាយថានាងត្រូវបានរកឃើញនៅក្នុងបន្ទប់ទឹក- ហេរីស្រដី ដោយមិនរវីរវល់នឹងសំឡេងស្រមុកខុរៗរបស់ នេវីល នៅឯជ្រុងបន្ទប់ឡើយ។ - ចុះបើនាងមិនដែលចាកចេញពីបន្ទប់ទឹកនោះទេ? ចុះបើនាងនៅទីនោះនៅឡើយ?

រ៉ុនញីភ្នែករបស់វា ព្រមទាំងជ្រួញចិញ្ចើមក្រោមពន្លឺដួងខែ។ ហើយបន្ទាប់មកវាក៏យល់...

- ឯងចង់និយាយថា...កុំថា *ម៉ុននីង មីតថល* ឲ្យសោះណា?

**វគ្គ XVI**



## បន្ទប់សម្ងាត់

- ពេលដែលពួកយើងនៅក្នុងបន្ទប់ទឹក នាងនៅឆ្ងាយពីយើងចម្ងាយបីបន្ទប់ប៉ុណ្ណោះ- រ៉ុននិយាយទាំងល្វីងជូរចត់នាពេលស្រស់ស្រូបអាហារពេលព្រឹកក្នុងថ្ងៃបន្ទាប់ - យើងគួរតែបានសួរនាង ហើយឥលូវ....។

វាមានការពិបាកខ្លាំងណាស់ក្នុងការព្យាយាមស្វែងរកសត្វពីងពាងនោះ។ ការបង្វែងដានគ្រូៗ ឲ្យបានឆ្ងាយគ្រប់គ្រាន់ដើម្បីលួចចូលទៅក្នុងបន្ទប់ទឹកស្រី ដែលជាពិសេស បន្ទាប់ពីមានការវាយប្រហារលើកទីមួយមក មានការពិបាកខ្លាំងណាស់។

ប៉ុន្តែរឿងមួយបានកើតឡើងនៅក្នុងមេរៀនដំបូងរបស់ពួកគេ គឺមុខវិជ្ជានិម្មិតកម្មដែលអាចធ្វើឲ្យពួកគេបំភ្លេចរឿងបន្ទប់សម្ងាត់នោះបានជាលើកដំបូងក្នុងរយៈពេលជាច្រើនសប្តាហ៍មកហើយ។ ដប់នាទីក្រោយពីការចូលរៀន សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល បានប្រាប់ពួកគេថាការប្រឡងរបស់ពួកគេនឹងចាប់ផ្តើមនៅថ្ងៃទីមួយខែមិថុនា គឺនៅសល់ពេលមួយសប្តាហ៍ទៀតបើរាប់ចាប់ពីថ្ងៃនេះទៅ។

- ប្រឡងឬ?- ស៊ីម្យុស ហ្វីននីហ្គេន បានស្រែកឡើង - យើងនៅតែមានការប្រឡងទៀតឬ?

មានសម្លេងទង្គិចខ្លាំងមួយបានបន្លឺឡើងពីក្រោយខ្នង ហេរី គឺដោយសារតែចង្កឹះវេទមន្តរបស់ នេវីល ឡង់បត់ថម បានជ្រុះហើយធ្វើឲ្យជើងតុរបស់វាមួយបាត់ទៅ។ សាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល បានធ្វើអ្វីៗត្រលប់មករកសភាពដើមវិញដោយគ្រាន់តែរលាស់ដៃបន្តិចជាមួយនឹងចង្កឹះវេទមន្តរបស់គាត់។ បន្ទាប់មកគាត់បានបែរខ្នង ហើយមើលទៅ ស៊ីម្យុស ទាំងចងចិញ្ចើម។

- លក្ខខណ្ឌដែលនាំឲ្យសាលានេះនៅតែបើកទ្វាររហូតដល់សព្វថ្ងៃ គឺដើម្បីអោយអ្នកទាំងអស់គ្នាបានទទួលនូវការអប់រំ-គាត់និយាយខ្លាំងៗ - ហេតុនេះហើយ ការប្រលងនឹងប្រព្រឹត្តទៅធម្មតា ហើយខ្ញុំជឿថាអ្នកទាំងអស់គ្នានឹងព្យាយាមរំលឹកមេរៀនឡើងវិញ។

ព្យាយាមរំលឹកមេរៀន! វាមិនដែលកើតឡើងទាល់តែសោះ ដែលថានឹងមានការប្រលងនៅក្នុងសាលាទាំងស្ថានភាពបែបនេះ។ មានការលួចរអ៊ូរទាំនៅក្នុងថ្នាក់ដែលជាហេតុធ្វើឲ្យសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល ត្រូវចងចិញ្ចើមជានិច្ច។

- ការខិតខំរបស់លោកសាស្ត្រាចារ្យ ដាំប៊័លដ័រ គឺធ្វើយ៉ាងណាឲ្យសាលានេះនៅតែដំណើរការទៅមុខតាមដែលអាចធ្វើបាន-គាត់និយាយ - ខ្ញុំចង់រំលឹកអ្នកទាំងអស់គ្នា គួរតែកំណត់ឲ្យបានពីអ្វីដែលពួកឯងបានរៀននៅក្នុងឆ្នាំនេះ។

ហេរីមើលចុះក្រោមទៅកាន់ទន្សាយសមួយគូ ដែលគាំរូវឲ្យវាដប់ទៅជាស្បែកជើងផ្ទាត់។ តើវាបានរៀនអ្វីខ្លះនៅក្នុងឆ្នាំនេះ? មើលទៅ វាហាក់ដូចជាមិនអាចនឹងគិតឃើញនូវអ្វីដែលមានប្រយោជន៍ចំពោះការប្រឡងរបស់វានោះទេ។

ទឹកមុខរបស់រ៉ុនប្រែពណ៌យ៉ាងលឿន ហាក់ដូចជាគេទើបនឹងប្រាប់ថាវាត្រូវទៅរស់នៅក្នុងព្រៃហាមឃាត់អញ្ចឹង។

- តើឯងគិតថាខ្ញុំអាចប្រឡងបានក្នុងស្ថានភាពបែបនេះរឺ?- វាសួរហើរី ព្រមទាំងលើកចង្កឹះផេទមន្តរបស់វាឡើងដែលចាប់ផ្ដើមបញ្ចេញសម្លេងយ៉ាងខ្លាំង។

★

បីថ្ងៃមុនការប្រឡងរបស់ពួកគេ សាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល បានធ្វើការប្រកាសមួយទៀតនៅពេលញ៉ាំអាហារពេលព្រឹក។

- ខ្ញុំមានដំណឹងល្អសម្រាប់អ្នកទាំងអស់គ្នា- គាត់បាននិយាយ។ សម្លេងស្រែកខ្ញៀវខ្ញារបានផ្ទុះឡើងនៅក្នុងសាលធំ ជំនួសឲ្យភាពស្ងៀមស្ងាត់។ - លោកសាស្ត្រាចារ្យ ដាំប័លដ័រ នឹងត្រលប់មកវិញ- សិស្សមួយចំនួនបានស្រែកឡើងប្រកបដោយភាពត្រេកអរ។

- អ្នកគ្រូចាប់បានទាយាទស្លីធីរីន!- សម្រែករបស់ក្មេងស្រីម្នាក់បានបន្លឺឡើងនៅតុរបស់ក្រុមរ៉ាវិនក្លាហ្វ។

- ការប្រកួតកីឡាឃ្វីដឌីច្ចនឹងត្រូវត្រលប់មកវិញសាជាថ្មីម្ដងទៀត!- ដំបងបានស្រែកយ៉ាងខ្លាំងដោយភាពរីករាយ។

ពេលដែលសម្រែកនៃភាពរីករាយបានស្ងប់ទៅវិញ សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយបន្តថា៖

- សាស្ត្រាចារ្យ សប្រ៉ោត បានប្រាប់ខ្ញុំថា យើងអាចប្រមូលផលពីដើម ម៉ានឌ្រេក បានហើយ។ យប់នេះយើងអាចធ្វើឲ្យអ្នកដែលត្រូវបង្កកដឹងខ្លួនឡើងវិញ ហើយខ្ញុំក៏សូមរំលឹកអ្នកទាំងអស់គ្នាផងដែរថា ម្នាក់ក្នុងចំនោមអ្នកទាំងនោះនឹងអាចប្រាប់ពួកយើងថា អ្នកណារឺអ្វីដែលបានវាយប្រហារទៅលើពួកគេ។ ខ្ញុំសង្ឃឹមថាឆ្នាំសិក្សាដ៏គួរឲ្យភ័យខ្លាចនេះនឹងបញ្ចប់ទៅដោយការស្វែងរកចាប់ឃាតករនោះបាន។

បន្ទាប់ពីអ្នកស្រីសាស្ត្រាចារ្យបានបញ្ចប់ការនិយាយរបស់គាត់ សំរែកនៃការអបអរសាទរបានផ្ទុះឡើង។ ហេរីបានក្រឡេកមើលទៅតុក្រុមស្លីធីរីន។ វាមិនសូវជាមានការភ្ញាក់ផ្អើលទេដែល ដ្រាកូ មេលហ្វ័យ មិនបានចូលរួមក្នុងការអបអរនេះ។ ប៉ុន្តែទោះជាយ៉ាងណា ក៏រ៉ុនមើលទៅ ដូចជាសប្បាយរីករាយជាងប៉ុន្មានថ្ងៃមុននេះដែរ។

- វាគ្មានបញ្ហាទេដែលយើងមិនបានសួរមីតចលនោះ- រ៉ុននិយាយទៅហេរី - ហឺម៉ាយអូនីនឹងមាននូវរាល់ចម្លើយនៅពេលដែលគេធ្វើឲ្យនាងដឹងខ្លួនឡើងវិញ! មិនថាអញ្ចឹងហ្អី? នាងប្រហែលជានឹងឈឺក្បាលនៅពេលដែលនាងដឹងថាយើងនឹងមានការប្រលងនៅរយៈពេលបីថ្ងៃទៀតនេះ។ នាងមិនទាន់បានរំលឹកមេរៀនឡើងវិញទេ។ វាប្រហែលជាល្អប្រសិនបើគេទុកឲ្យនាងនៅដដែលរហូតដល់ការប្រលងត្រូវបញ្ចប់ទៅ។

បន្តិចក្រោយមក ជីននី វីស្លី បានចូលមកដល់ ហើយបានអង្គុយនៅក្បែរ រ៉ុន។ នាងមើលទៅដូចជាតានតឹងហើយភ័យខ្លាចទៀតផង។ ហេរីសំគាល់ឃើញថា ម្រាមដៃរបស់នាងកំពុងតែប្រទាក់ចូលគ្នានៅលើភ្លៅរបស់នាង។

- តើឯងកើតអីហ្នឹង?- រ៉ុនសួរទាំងកំពុងញ៉ាំបបរ។

ជីននី មិនបាននិយាយអ្វីទាំងអស់ គ្រាន់តែមើលចុះមើលឡើងទៅកាន់តុរបស់ក្រុមហ្គ្រីហ្វីនដ័រ ដោយទឹកមុខប្រកបដោយភាពភ័យខ្លាច ដែលធ្វើឲ្យហេរីមើលទៅស្រដៀងនឹងនរណាម្នាក់ ប៉ុន្តែវារកនឹងមិនឃើញថាជានរណាឡើយ។

- និយាយមក!- រ៉ុននិយាយព្រមទាំងមើលទៅនាង។

ភ្លាមនោះ ហេរីនឹកឃើញថា ជីននី មើលទៅស្រដៀងអ្នកណាហើយ។ នាងបានបែរមុខចេញដោយនៅតែអង្គុយលើកៅអីរបស់នាងដដែល។ ពិតណាស់ នាងមើលទៅដូចដុបប៊ីបេះបិត នៅពេលវាកំពុងតែចង់និយាយនូវព័ត៌មានហាមឃាត់ទាំងទើសទាល់។

- ខ្ញុំមានអ្វីម្យ៉ាងចង់ប្រាប់ដល់អ្នកទាំងពីរ- ជីននីនិយាយតិចៗយ៉ាងប្រុងប្រយ័ត្នទាំងមិនមើលមុខហេរី។

- តើវាជាអ្វីទៅ?- ហេរីសួរ។

ជីននីមើលទៅហាក់ដូចជាពិបាកក្នុងការរកពាក្យឲ្យត្រូវសម្រាប់និយាយអំពីរឿងនោះណាស់។

- និយាយមក!- រ៉ុនស្រដី។

ជីននីបង្ហើបមាត់របស់នាង ប៉ុន្តែគ្មានសម្លេងអ្វីចេញមកទេ។ ហេរីផ្អៀងខ្លួនបន្តិចទៅជិតជីននី ហើយនិយាយតិចៗដែលល្មមអាចឲ្យជីននី និងរ៉ុនស្តាប់បានតែប៉ុណ្ណោះ។

- តើវាជារឿងដែលពាក់ព័ន្ធនឹងបន្ទប់សម្ងាត់រឺ? តើឯងបានឃើញអ្វីមួយ រឺក៏អ្នកណាម្នាក់ប្លែករឺ?

ជីននីដកដង្ហើមធំ។ ក្នុងពេលជាមួយគ្នានេះដែរ ពើស៊ី វីស្លី បានលេចមុខឡើង ដែលមើលទៅអស់កម្លាំង និងស្លេកស្លាំង។

- បើឯងញ៉ាំហើយ តើខ្ញុំអាចសុំកន្លែងអង្គុយនេះបានទេ ជីននី? ខ្ញុំឃ្លានខ្លាំងណាស់។ ខ្ញុំទើបតែបញ្ចប់ការដើរល្បាត។

ជីននីបានស្ទុះក្រោកឡើង ហាក់បីដូចជាកៅអីរបស់នាងបានភ្ជាប់ចរន្តអគ្គិសនីអញ្ចឹង។ នាងបានឲ្យកន្លែងអង្គុយរបស់នាងទៅ ពើស៊ី ហើយចេញទៅជាមួយនឹងទឹកមុខភ័យខ្លាចរបស់នាង។ ពើស៊ី អង្គុយចុះ ហើយចាប់យកពែងមានដៃមួយពីកណ្តាលតុ។

- ពើស៊ី!- រ៉ុននិយាយទាំងខឹងសម្បា។ - នាងហៀបតែនឹងនិយាយប្រាប់យើងពីរឿងមួយដ៏សំខាន់ទៅហើយ តែឯង...!

ពើស៊ីបានឈ្លក់ទឹកដែលវាទើបតែផឹកបានពាក់កណ្តាលប៉ុណ្ណោះ។

- តើវាជារឿងអ្វីទៅ?- វាបានសួរព្រមទាំងក្អកផង។

- ខ្ញុំទើបតែសួរនាងថា តើនាងបានឃើញអ្វីចម្លែកដែររឺទេ? នាងបំរុងតែនិយាយទៅហើយ តែ...។

- អូ! វាគ្មានអ្វីកើតឡើងដែលទាក់ទងនឹងរឿងបន្ទប់សម្ងាត់ទេ- ពើស៊ីឆ្លើយតបភ្លាមៗ។

- ហេតុអ្វីបានជាឯងដឹង?- រ៉ុនសួរទាំងដំឡើងចិញ្ចើមរបស់វាបែបឆ្ងល់។

- អឺ...ប្រសិនបើឯងចង់ដឹង អ្ហឺ...គឺជីននី អ្ហឺ...បានដើរទៅចំពេលដែល...អ្ហឺ...កុំភ័យអី! អ្វីដែលសំខាន់នោះគឺនាងបានឃើញខ្ញុំកំពុងធ្វើអ្វីមួយ ហើយខ្ញុំបានសុំនាងកុំឲ្យនិយាយប្រាប់នរណាម្នាក់ឲ្យសោះ។ ខ្ញុំគិតថានាងប្រាកដជាគោរពពាក្យសន្យារបស់នាង។ វាគ្មានអ្វីទេ! ពិតមែនណា! ខ្ញុំគ្រាន់តែចង់...

ហេរីមិនដែលឃើញពើស៊ីមើលទៅដូចជាមានកង្វល់ដូចនេះទេ។

- ពេលនោះឯងកំពុងធ្វើអ្វី ពើស៊ី?- រ៉ុនសួរទាំងសើច - ប្រាប់ពួកយើងមក យើងនឹងមិនសើចទេ។

ប៉ុន្តែពើស៊ីមិនបានឆ្លើយតបទៅវិញទេ។

- ហេរី! តើឯងអាចជួយហុចនំប៉័ងខ្លះឲ្យខ្ញុំបានទេ? ខ្ញុំឃ្លានណាស់។

ហេរីគិតថារឿងអាថ៌កំបាំងនឹងត្រូវបានដោះស្រាយនៅពេលឆាប់ៗនេះ ដោយមិនបាច់មានជំនួយពីពួកគេឡើយ។ ប៉ុន្តែ វាក៏នឹងឆ្លៀតនិយាយជាមួយមីតចលដែរ ប្រសិនបើមានឱកាស...ហើយដោយក្តីសប្បាយចិត្ត ឱកាសនោះពិតជាបានមកដល់មែន គឺនាពាក់កណ្តាលពេលព្រឹក ចំពេលដែលពួកគេកំពុងត្រូវបានលោកហ្គីលដីរ៉យ ឡក់ហាត នាំចូលទៅរៀនមុខវិជ្ជា "ប្រវត្តិនៃវេទមន្ត"។

★

សាស្ត្រាចារ្យ ឡុក់ហាត ដែលតែងតែធានាអះអាងថា គ្រោះថ្នាក់ទាំងអស់បានកន្លងផុតទៅហើយ ហើយត្រូវគេបញ្ជាក់ថាមិនត្រឹមត្រូវ ឥលូវបែរក្រឡាស់សំដីយ៉ាងពេញចិត្តពេញថ្លើមវិញថា វាពិបាកនឹងមានបញ្ហាអីណាស់ កាលបើបានឃើញពួកកូនសិស្សធ្វើដំណើរតាមផ្លូវរបៀងដោយសុវត្ថិភាពយ៉ាងនេះ។ សក់របស់គាត់មិនរលោងដូចធម្មតាទេ ហាក់បីដូចជាអត់ងងុយស្ទើរពេញមួយយប់ ដោយចំណាយពេលក្នុងការដើរល្បាតនៅជាន់ទីបួនអញ្ចឹង។

- ចាំសម្ដីរបស់ខ្ញុំទុកទៅ- គាត់និយាយ ដោយនាំពួកគេទៅជ្រុងម្ខាងនៃច្រករបៀង - សម្ដីដំបូងបង្អស់ដែលនឹងចេញពីមាត់របស់អ្នកដែលត្រូវបង្កកគឺៈ អ្នកដែលបានធ្វើរឿងនេះគឺហាហ្គ្រីដ...និយាយតាមត្រង់ទៅ ខ្ញុំមានការភ្ញាក់ផ្អើលណាស់នៅពេលដែលសាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល គិតថា ការការពារសុវត្ថិភាពគឺជារឿងចាំបាច់បំផុតនោះ។

- ខ្ញុំយល់ស្រប!- ហេរីនិយាយ ធ្វើឲ្យរ៉ុនជ្រុះសៀវភៅទៅដីក្នុងស្ថានភាពភ្ញាក់ផ្អើល។

- អរគុណហើយ ហេរី- សាស្ត្រាចារ្យឡុក់ហាតបាននិយាយយ៉ាងសុភាពរាបសា ខណៈដែលពួកគេឈររង់ចាំជួរសិស្សរបស់ក្រុមហាហ្វ៊ុលផហ្វផ្លងកាត់ទៅ។ - ខ្ញុំគិតថា គ្រូទាំងអស់គ្នាមានទំនាក់ទំនងល្អជាមួយសិស្សគ្រប់គ្រាន់ហើយ ហេតុអ្វីចាំបាច់ពួកគាត់ត្រូវជូនពួកគេទៅថ្នាក់រៀន និងត្រូវយាមល្បាតអស់ពេញមួយយប់ទៀតនោះ?

- វាត្រឹមត្រូវណាស់- រ៉ុននិយាយព្រមទាំងខំដើរតាមឲ្យទាន់ - ហេតុអ្វីលោកមិនទុកឲ្យពួកខ្ញុំត្រលប់ទៅវិញដោយខ្លួនឯង? នៅសល់តែច្រករបៀងមួយទៀតប៉ុណ្ណោះ ពួកយើងនឹងទៅដល់ហើយ។

- ខ្ញុំនឹងទៅ វីស្លី- សាស្ត្រាចារ្យឡុក់ហាតនិយាយ - ខ្ញុំពិតជាត្រូវទៅហើយ ដើម្បីរៀបចំកិច្ចតែងការបង្រៀនរបស់ខ្ញុំនៅថ្នាក់ក្រោយ។

គាត់បានត្រលប់ទៅវិញ។

- ទៅរៀបចំកិច្ចតែងការបង្រៀន!- រ៉ុនញញឹមមើលងាយគាត់ - វីក៏ទៅធ្វើឲ្យសក់របស់គាត់អង្កាញ់ជាងមុន?

ពួកគេបានទុកឲ្យសិស្សដទៃនៃក្រុមហ្គ្រីហ្វីនដ័រដើរទៅមុន ហើយពួកគេដើរយ៉ាងរហ័សទៅកាន់ផ្លូវមួយ ហើយប្រញាប់ប្រញាល់ធ្វើដំណើរទៅកាន់បន្ទប់ទឹករបស់ ម៉ុននីង មីតថល។ ប៉ុន្តែនៅពេលដែលពួកគេម្នាក់ៗកំពុងតែរីករាយនឹងគំរោងការដ៏ល្អរបស់ពួកគេ...

- ផោតធ័រ! វីស្លី! តើពួកឯងកំពុងធ្វើអ្វីនៅទីនេះ?

គឺសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល។ បបូរមាត់របស់គាត់ប្រៀបបាននឹងបន្ទាត់ដ៏ស្តើងបំផុតមួយ។

- ពួកយើង...ពួកយើង...- រ៉ុននិយាយជាប់ៗ - ពួកយើងកំពុងតែ...ទៅមើល...គឺទៅមើល...

- ហឺម៉ាយអូនី!- ហេរីនិយាយ ធ្វើឲ្យរ៉ុន និងសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលសម្លឹងទៅកាន់វា។

- ពួកយើងមិនបានជួបនាងអស់រយៈពេលជាយូរមកហើយ អ្នកគ្រូ- ហេរីដោះសាយ៉ាងលឿនព្រមទាំងជាន់ជើងរ៉ុន - ហើយពួកយើងគិតថាគួរតែលួចចូលទៅក្នុងបន្ទប់ពេទ្យ ហើយប្រាប់នាងថាដើម ម៉ានដ្រេក ជិតរួចរាល់ហើយ សូមកុំឲ្យនាងបារម្ភអី។

អ្នកស្រីម៉ាកហ្គូណាហ្គាលនៅតែសម្លឹងមើលវាមិនដាក់ភ្នែក ហើយខណៈដែលហេរីគិតថាគាត់កំពុងតែមានអារម្មណ៍ច្របូកច្របល់ ហើយនៅពេលដែលគាត់និយាយ សម្លេងរបស់គាត់គ្រលរខ្លាំងណាស់។

- ជាការពិតហើយ- គាត់និយាយ ហេរីមានការភ្ញាក់ផ្អើលណាស់ នៅពេលបានឃើញទឹកភ្នែកដែលមានពន្លឺត្រចះត្រចង់នៅក្នុងភ្នែកមូលតូចរបស់គាត់ - ជាការពិតណាស់ ខ្ញុំដឹងថាវាមានការពិបាកខ្លាំងណាស់នៅពេលដែលឃើញមិត្តរបស់ខ្លួនក្លាយទៅ

ជា...ខ្ញុំយល់ខ្លាំងណាស់។ បាន! ផោតផ័រ ឯងអាចទៅមើលកញ្ញាហ្គ្រេនជឺរបាន។ ខ្ញុំនឹងប្រាប់សាស្ត្រាចារ្យប៊ីនថា ពួកឯងនឹងទៅទីនោះ។ ពួកឯងត្រូវប្រាប់អ្នកស្រីផុមហ្វ្រីផង ថាខ្ញុំបានអនុញ្ញាតឲ្យពួកឯងហើយ។

ហេរី និងរ៉ុនបានដើរចេញទៅ។ មិនគួរឲ្យជឿសោះថាពួកគេអាចគេចចេញពីការពិន័យបាននោះ។ ពេលដែលពួកគេដើរមកដល់ផ្លូវកាច់ជ្រុង ពួកគេបានឮសម្លេងសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលហឹតសំបោរយ៉ាងច្បាស់។

- នេះជារឿងទីមួយដ៏ល្អបំផុតដែលឯងបានបង្កើតឡើង- រ៉ុននិយាយយ៉ាងក្លៀវក្លា។

ពួកគេគ្មានជម្រើសនោះទេក្រៅពីទៅគិលានដ្ឋាន ហើយប្រាប់អ្នកស្រី ផុមហ្វ្រី ថាពួកគេទទួលការអនុញ្ញាតពីសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលដើម្បីទៅមើលហឺម៉ាយអូនី។

អ្នកស្រីផុមហ្វ្រីអនុញ្ញាតឲ្យពួកគេចូលទៅទាំងទើសទាល់។

- វាគ្មានតម្លៃនោះទេក្នុងការនិយាយជាមួយមនុស្សដែលត្រូវបង្កកនោះ- គាត់និយាយ។

នៅពេលដែលពួកគេទៅអង្គុយជិតហឺម៉ាយអូនី ពួកគេសារភាពថាគាត់និយាយត្រូវណាស់។ គ្រាន់តែមើលក៏ដឹងថាហឺម៉ាយអូនី មិនមានអារម្មណ៍ដឹងថានាងមានភ្ញៀវមកលេងសូម្បីតែបន្តិច ហើយវាក៏ច្បាស់លាស់ដែរថា ពួកគេបានត្រឹមតែប្រាប់នាង កុំឲ្យបារម្ភពីអ្វីដែលនឹងកើតឡើងអី។

- ខ្ញុំឆ្ងល់ណាស់ ថាតើ នាងពិតជាបានឃើញអ្នកវាយប្រហារមែនដែរឺទេ?- រ៉ុននិយាយទាំងមើលទៅមុខរបស់ហឺម៉ាយអូនីយ៉ាងក្រៀមក្រំ - ដោយសារតែវាបានវាយប្រហារទៅលើគេរាល់គ្នា ហេតុនេះហើយគ្មាននរណាម្នាក់អាចដឹងបាននោះទេ។

ប៉ុន្តែហេរីមិនបានមើលទៅមុខហឺម៉ាយអូនីនោះទេ ផ្ទុយទៅវិញ វាកំពុងតែចាប់អារម្មណ៍ទៅនឹងដៃស្តាំរបស់នាង ដែលសណ្តូកហើយក្តាប់យ៉ាងណែននៅពីលើភួយ។ វាបានអោនទៅជិត ហើយបានឃើញក្រដាសមួយបំនែកតូចនៅជាប់ក្នុងកណ្តាប់ដៃរបស់នាង។

បន្ទាប់ពីប្រាកដថាអ្នកស្រីផុមហ្វ្រីមិននៅក្បែរនោះទេ វាបានបង្ហាញរឿងនេះឲ្យរ៉ុនបានដឹង។

- ព្យាយាមយកវាចេញមក - រ៉ុនខ្សឹបព្រមទាំងបានទាញកៅអីរបស់វាទៅជិតដើម្បីបាំងហេរីពីក្រសែភ្នែករបស់អ្នកស្រីផុមហ្វ្រី។

វាមិនមែនជាការងាយស្រួលទេ ព្រោះដៃហឺម៉ាយអូនីរឹតយ៉ាងតឹងជុំវិញក្រដាសនោះ ដែលធ្វើឲ្យហេរីប្រាកដក្នុងចិត្តថានឹងធ្វើឲ្យក្រដាសនោះរហែក។ ខណៈពេលដែលរ៉ុនកំពុងសម្លឹងមើលនោះ ហេរីបានខំប្រឹងទាញក្រដាសនោះយ៉ាងខ្លាំង។ នៅចុងបញ្ចប់ក្រដាសនោះត្រូវបានទាញចេញមកក្រៅ បន្ទាប់ពីប៉ុន្មាននាទីដ៏តឹងតែង។

វាជាក្រដាសដែលរហែកចេញពីសៀវភៅចាស់មួយក្នុងបណ្ណាល័យ។ ហេរីបានទាញក្រដាសនោះឲ្យរាបស្មើ ដោយចំនង់យ៉ាងខ្លាំង ហើយរ៉ុនបានអោនទៅជិតដើម្បីអានក្រដាសនោះដែរ។ ក្នុងក្រដាសនោះបានសរសេរថា៖

ក្នុងចំណោមសត្វតិរច្ឆាន និងបិសាចដែលគួរឲ្យខ្លាចទាំងអស់ដែលមាននៅក្នុងពិភពរបស់យើង គ្មានអ្វីដែលគួរឲ្យខ្លាចជាងសត្វពស់ដ៏ធំមួយនោះទេ ហើយដែលត្រូវបានគេស្គាល់ថាជាស្តេចនៃសត្វពស់ទាំងឡាយ។ ពស់នេះមានទំហំធំខ្លាំងណាស់ហើយមានអាយុច្រើនរយឆ្នាំហើយ។ វាកើតអំពីស៊ុតមាន់ដែលត្រូវបានភ្ញាស់ដោយសត្វគីង្គក់។ វិធីក្នុងការសម្លាប់របស់វាគឺគួរឲ្យខ្លាចខ្លាំងណាស់។ ក្រៅអំពីចង្កូមដែលមានពិសរបស់វា ពស់នេះអាចសម្លាប់នរណាម្នាក់បាន ដោយគ្រាន់តែសម្លឹងបំមុស្សនោះប៉ុណ្ណោះ។

## **បន្ទប់សម្ងាត់**

*រាល់មនុស្សណាដែលប្រទះនឹងពន្លឺកែវភ្នែករបស់វានឹងត្រូវស្លាប់ភ្លាមមួយរំពេច។ សត្វពីងពាងតែងតែរត់គេចពីពស់នោះ។ ចំណែកសត្វពស់នោះតែងតែគេចពីសម្លេងសត្វបក្សី ដែលអាចធ្វើឲ្យវាស្លាប់បាន។*

នៅពីក្រោមក្រដាសនេះមានពាក្យមួយសរសេរយ៉ាងខ្មៀក ដែលហេរីអាចចំនាំបានច្បាស់គឺជាអក្សររបស់ហឺម៉ាយអូនី ដែលបានសរសេរថា៖ "*បំពង់*"

ហាក់ដូចជាមាននរណាម្នាក់បើកកុងតាក់ភ្លើងនៅក្នុងខួរក្បាលរបស់វាអញ្ចឹង។

- រ៉ុន- ហេរីខ្សឹប - នេះគឺជាចម្លើយ បិសាចដែលនៅក្នុងបន្ទប់សម្ងាត់នោះគឺជាពស់ គឺពស់យក្សមួយក្បាល! មូលហេតុនេះហើយដែលធ្វើឲ្យខ្ញុំបានឮសម្លេងរបស់វានៅគ្រប់ទីកន្លែង ហើយគ្មាននរណាផ្សេងទៀតដែលស្តាប់ឮនោះទេ ពីព្រោះខ្ញុំចេះស្តាប់ភាសាពស់។

ហេរីសម្លឹងមើលទៅគ្រែនៅជុំវិញវា។

- ពស់នោះសម្លាប់មនុស្សដោយគ្រាន់តែសម្លឹងមើលទៅពួកគេតែប៉ុណ្ណោះ។ ប៉ុន្តែគ្មាននរណាម្នាក់ស្លាប់នោះទេ ពីព្រោះពួកគេមិនបានមើលចំភ្នែករបស់វា។ ខូលីន បានឃើញពស់នោះតាមរយៈម៉ាស៊ីនថតរបស់គេតែប៉ុណ្ណោះ។ ពស់នោះបានធ្វើឲ្យឆេះហ្វីលដែលនៅខាងក្នុងទាំងអស់។ ប៉ុន្តែខូលីនគ្រាន់តែត្រូវបានបង្កកតែប៉ុណ្ណោះ។ ចំនែកចាស់ស្ទីនវិញ...នាងប្រាកដជាបានឃើញពស់នោះតាមរយៈនីក-ស្ទើរ-អត់-ក្បាល។ មានតែនីក-ស្ទើរ-អត់-ក្បាលទេដែលបានឃើញសត្វនោះផ្ទាល់។ ប៉ុន្តែគាត់មិនអាចស្លាប់ម្តងទៀតបានទេ។ ហឺម៉ាយអូនី និងសិស្សច្បងរបស់ក្រុមរ៉ាវិនក្លាហ្វត្រូវបានគេរកឃើញជាមួយនឹងកញ្ចក់មួយនៅក្បែរពួកគេ។ ហឺម៉ាយអូនីទើបតែដឹងថាបិសាចនោះគឺជាសត្វពស់។ ខ្ញុំហ៊ានភ្នាល់ថានាងបានរំលឹកប្រាប់មនុស្សទីមួយដែលនាងបានជួបថាពេលដែលគេមើលទៅកន្លែងស្ងាត់ណាមួយត្រូវមើលជាមួយកញ្ចក់។ ក្មេងស្រីនោះបានយកកញ្ចក់ចេញមកហើយ...

រ៉ុនបិទមាត់របស់វាយ៉ាងជិត។

- ហើយចុះចំនែកអ្នកស្រីណូរីសវិញ?- វាខ្សឹបទាំងចង់ដឹង។

ហេរីព្យាយាមគិត ហើយស្រមើស្រមៃពីទិដ្ឋភាពក្នុងយប់នៃពិធីបុណ្យហាឡូវីន។

- គឺទឹក...- វានិយាយយឺតៗ - គឺទឹកដែលហូរចេញពីបន្ទប់ទឹករបស់មីតចល។ ខ្ញុំហ៊ានភ្នាល់ថាអ្នកស្រីណូរីសបានឃើញត្រឹមតែរូបភាពឆ្លុះតែប៉ុណ្ណោះ...

ហេរីសម្លឹងមើលក្រដាសនោះទាំងចង់ដឹងយ៉ាងម៉ត់ចត់។ ហេរីអានជាច្រើនលើកច្រើនសា ធ្វើឲ្យវាយល់ពីអត្ថន័យរបស់ក្រដាសនោះ។

- សំឡេងបក្សីអាចធ្វើឲ្យវាស្លាប់បាន- ហេរីអានឮៗ - មាន់របស់ហាហ្គ្រីដត្រូវបានសម្លាប់។ ទាយាទនៃក្រុម ស្លីតឺរីន មិនចង់ឮសំឡេងមាន់មួយក្បាលណារងាវ នៅកន្លែងណាក៏ដោយនៅជុំវិញប្រាសាទនេះខណៈពេលដែលបន្ទប់សម្ងាត់នោះត្រូវបានបើក។ សត្វពីងពាងគេចចេញពីវា គឺពិតជាត្រឹមត្រូវណាស់។

- ប៉ុន្តែតើពស់នោះអាចទៅមកជុំវិញប្រាសាទនោះបានយ៉ាងម៉េចទៅ?- រ៉ុននិយាយ - វាជាសត្វដ៏ធំ ហើយកខ្វក់ទៀត គេប្រហែលជាអាចឃើញវា...

ទោះបីជាយ៉ាងណា ហេរីបានផ្តោតអារម្មណ៍ទៅលើអក្សរដែលហឺម៉ាយអូនីបានសរសេរយ៉ាងខ្មៀកនៅខាងចុងក្រដាស។

## បន្ទប់សម្ងាត់

- បំពង់- វានិយាយ - គឺបំពង់ រ៉ុន។ វាបានប្រើបំពង់។ ខ្ញុំបានឮសំឡេងរបស់វានៅខាងក្នុងជញ្ជាំង។

ពេលនោះរ៉ុនចាប់ទាញដៃហេរី។

- ច្រកចូលបន្ទប់សម្ងាត់- រ៉ុននិយាយស្អកៗ - ចុះបើវាជាបន្ទប់ទឹក? ចុះបើសត្វនោះនៅក្នុងនោះ?

- ...*បន្ទប់ទឹករបស់ ម៉ុននីង មីតថល-* ហេរីនិយាយ។

ពួកគេនៅអង្គុយទីនោះដដែលជាមួយនឹងភាពភ្ញាក់ផ្អើលដោយសារតែក្រដាសនោះ ហើយវាមានការពិបាកក្នុងការជឿណាស់។

- នេះមានន័យថា- ហេរីនិយាយ - ខ្ញុំមិនមែនជាមនុស្សតែម្នាក់ទេដែលចេះភាសាពស់នៅក្នុងសាលានេះ ប៉ុន្តែទាយាទនៃក្រុមស្លីតឺរីនក៏ចេះដែរ។ ហេតុនេះហើយទើបពួកគេអាចបញ្ជាពស់នោះបាន។

- តើពួកយើងត្រូវធ្វើអ្វីបន្តទៀត?- រ៉ុននិយាយ ភ្នែកកំពុងបញ្ចេញពន្លឺ - តើពួកយើងគួរទៅប្រាប់អ្នកស្រីម៉ាកហ្គូណាហ្គាលដែររឺទេ?

- តោះ! យើងត្រូវទៅបន្ទប់សាស្ត្រាចារ្យ- ហេរីនិយាយព្រមទាំងក្រោកឡើងពីកៅអី - គាត់ប្រហែលជាទៅដល់ទីនោះតាំងពីដប់នាទីមុនម្ល៉េះ។ លឿនឡើង! ជិតដល់ម៉ោងសម្រាកហើយ!

ពួកគេរត់ចុះកាំជណ្តើរយ៉ាងលឿន។ ដោយមិនចង់ឲ្យគេឃើញពួកវានៅក្បែរផ្លូវរបៀង ពួកវាបានទៅដល់បន្ទប់សាស្ត្រាចារ្យយ៉ាងលឿន។ បន្ទប់អាហារគឺជាបន្ទប់ធំមួយដែលត្រូវបិទដោយបន្ទះឈើ និងពោរពេញទៅដោយកៅអីឈើខ្មៅជាច្រើន។ ហេរី និងរ៉ុនបានទៅដល់ទីនោះ។ ពួកគេរំជើបរំជួលចិត្តដល់លែងចង់អង្គុយ ពីព្រោះសំឡេងកណ្តឹងដែលបញ្ជាក់ថាដល់ម៉ោងសម្រាក មិនបានបន្លឺឡើងសោះ។

ពេលនោះ សំឡេងរបស់សាស្ត្រាចារ្យ ម៉ាកហ្គូណាហ្គាល បានបន្លឺឡើងនៅតាមផ្លូវរបៀង ហើយឮកាន់តែខ្លាំងឡើងៗ។

*- សិស្សទាំងអស់ត្រូវត្រលប់ទៅកាន់សយនដ្ឋានរៀងៗខ្លួនវិញភ្លាម។ ចំនែកគ្រូទាំងអស់ត្រូវនាំគ្នាមកកាន់បន្ទប់អាហារជាបន្ទាន់! សូមប្រញាប់បន្តិច!*

ហេរីងាកសម្លឹងមើលរ៉ុន។

- កុំនិយាយថាមានការវាយប្រហារមួយទៀតបានកើតឡើងណា? វាមិនត្រូវកើតឡើងនៅពេលនេះទេ។

- តើពួកយើងត្រូវធ្វើដូចម្តេចទៀតទៅ? - រ៉ុននិយាយទាំងស្រឡាំងកាំង - តើយើងត្រូវត្រលប់ទៅកាន់សយនដ្ឋានវិញរឺ?

- អត់ទេ - ហេរីនិយាយទាំងក្រឡេកមើលជុំវិញវា។ មានទូខោអាវចាស់មួយនៅ ខាងឆ្វេងដៃពួកគេដែលផ្ទុកពេញទៅដោយអាវខ្លូករបស់គ្រូៗ - នៅទីនោះ យើងត្រូវលួចស្តាប់ថាតើពួកគាត់កំពុងនិយាយពីអ្វី។ បន្ទាប់មកយើងអាចប្រាប់ពួកគាត់ពីអ្វីដែលយើងបានដឹង។

ពួកគេបានពួននៅក្នុងទូខោអាវនោះ ចាំស្តាប់សំឡេងកងរំពងនៃមនុស្សរាប់រយនាក់កំពុងធ្វើដំណើរនៅខាងក្រៅ ហើយទ្វាររបស់បន្ទប់នោះត្រូវបានបើកឡើង។ តាមរយៈចន្លោះអាវខ្លូកដែលធុំក្លិនផ្សួរ ពួកគេបានលួចមើលគ្រូៗដែលកំពុងតែដើរទៅមកនៅក្នុងបន្ទប់។ គ្រូខ្លះមើលទៅដូចជាមានអាថ៌កំបាំងអ្វីមួយ ហើយគ្រូខ្លះទៀតមើលទៅដូចជាភ័យខ្លាំងណាស់។ បន្ទាប់មក សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលបានមកដល់។

## បន្ទប់សម្ងាត់

- វាបានកើតឡើងទៀតហើយ- គាត់បាននិយាយទៅកាន់គ្រូទាំងអស់ដែលបានអង្គុយយ៉ាងស្ងៀមស្ងាត់ - សិស្សម្នាក់ត្រូវបានបិសាចចាប់យកទៅ គឺយកទៅក្នុងបន្ទប់សម្ងាត់នោះ។

សាស្រ្តាចារ្យហ្វ្លីតវីកលាន់មាត់។ សាស្ត្រាចារ្យសប្រ៉ោត បានយកដៃទៅខ្ទប់មាត់របស់គាត់។ សាស្ត្រាចារ្យស្នេពចាប់កាន់ខ្នងកៅអីយ៉ាងណែន ហើយនិយាយថា៖

- ហេតុអ្វីបានជាអ្នកស្រីប្រាកដអំពីរឿងនេះម្ល៉េះ?

- ទាយាទនៃក្រុមស្លីតឺរីន - សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយទាំងមុខស្លេកស្លាំង - បានទុកសារមួយទៀតឲ្យយើង គឺនៅចំខាងក្រោមសារទីមួយ ដោយសរសេរថា *"រូបរាងកាយរបស់នាងនឹងនៅ ក្នុងបន្ទប់សម្ងាត់នេះជារៀងរហូត"*។

សាស្ត្រាចារ្យហ្វ្លីតវីកហៀរទឹកភ្នែក។

- តើក្មេងនោះគឺជានរណា?- អ្នកស្រីហ៊ុចនិយាយទាំងបន្ទាបខ្លួនបន្តិចទៅលើកៅអី។ - តើជាសិស្សម្នាក់ណា?

- ជីននី វីស្លី- សាស្ត្រារចារ្យម៉ាកហ្គូណាហ្គាលនិយាយ។

ហេរីព្យាយាមទប់រ៉ុនដែលកំពុងតែទន់ខ្លួនចុះសន្សឹមៗយ៉ាងស្ងៀមស្ងាត់ទៅបាតទូ។

- យើងត្រូវតែបញ្ជូនសិស្សទាំងអស់ទៅផ្ទះរបស់ពួកគេថ្ងៃស្អែកនេះ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយ - នេះគឺជានាទីចុងក្រោយហើយសំរាប់សាលាហុកវ៉ាត។ សាស្ត្រាចារ្យដាំប័លដ័រតែងតែនិយាយថា...

ទ្វារបន្ទប់ត្រូវបានបើកម្តងទៀត។ ហេរីប្រាកដក្នុងចិត្តថាពិតជាលោក ដាំប័លដ័រ ប៉ុន្តែផ្ទុយទៅវិញ គឺជាសាស្ត្រាចារ្យឡក់ហាតសោះ។ គាត់កំពុងតែញញឹមយ៉ាងរីករាយ។

- សុំទោស- គាត់និយាយទាំងមមឹងមមាំង។ - ខ្ញុំមកយឺតរឺ?

គាត់មើលទៅដូចជាមិនបានចាប់អារម្មណ៍ថា គ្រូទាំងអស់កំពុងតែសម្លឹងទៅគាត់ដោយទឹកមុខដូចជាស្អប់ខ្ពើមណាស់នោះទេ។ សាស្ត្រាចារ្យស្នេពបោះជំហានសំដៅទៅគាត់។

- លោកមើលទៅដូចជាគ្មានបានដឹងរឿងអ្វីទាំងអស់។ តើលោកដឹងទេថា ក្មេងស្រីម្នាក់ត្រូវបិសាចចាប់យកទៅ។ គឺចាប់យកទៅក្នុងបន្ទប់សម្ងាត់។ ពេលវេលារបស់លោកបានមកដល់ហើយ- សាស្ត្រាចារ្យស្នេពនិយាយ។

សាស្ត្រាចារ្យឡក់ហាតប្រែទៅជាស្លេកស្លាំង។

- ពិតមែនហើយ លោកហ្គីលដឺរ៉យ- សាស្ត្រាចារ្យសប្រ៉ោតនិយាយ - កាលពីយប់មិញ លោកដូចជាបាននិយាយថា លោកបានស្គាល់ច្រកចូលនៃបន្ទប់សម្ងាត់នោះ តើមែនទេ?

- ខ្ញុំ...អឺ...ខ្ញុំ- សាស្ត្រាចារ្យឡក់ហាតនិយាយទាក់ៗ។

- មែនហើយ! លោកក៏ដូចជាធ្លាប់ប្រាប់ខ្ញុំថា លោកដឹងថាមានអ្វីនៅក្នុងបន្ទប់សម្ងាត់នោះ ពិតមែនទេ?- សាស្ត្រាចារ្យហ្វ្លីតវីកនិយាយដោយសំលេងខ្លាំងៗ។

- តើ...តើខ្ញុំបាននិយាយមែនរឺ? ខ្ញុំដូចជាមិនចាំទេ...

- ខ្ញុំនៅចាំយ៉ាងច្បាស់ លោកបាននិយាយថា លោកមានការសោកស្តាយដែលលោកមិនបានប្រយុទ្ធជាមួយបិសាចនោះមុនពេលដែលហាហ្គ្រីដត្រូវបានគេឃុំឃាំង- សាស្ត្រាចារ្យស្នេពនិយាយ - ក្រែងលោកជាអ្នកថាកិច្ចការទាំងអស់ត្រូវបានធ្វើឲ្យរញ៉េរញ៉ៃនោះអី? ហើយលោកបាននិយាយទៀតថា គួរតែឲ្យលោកចាត់ការដោយខ្លួនឯងតាំងពីដំបូងម្ល៉េះ មែនទេ?

សាស្ត្រាចារ្យឡុក់ហាតសម្លឹងមើលទៅសហការីរបស់គាត់ ដែលម្នាក់ៗមានទឹកមុខមាំ។

- ខ្ញុំ...ខ្ញុំពិតជាមិនដែលនិយាយមែន...លោកប្រហែលជាយល់ច្រលំហើយ...

- យើងនឹងទុករឿងនេះឲ្យលោកធ្វើ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយ - យប់នេះគឺជាពេលវេលាដ៏ល្អសម្រាប់ធ្វើវា។ យើងសង្ឃឹមថាលោកអាចធ្វើបាន។ លោកនឹងត្រូវតទល់ជាមួយនឹងបិសាចដោយខ្លួនឯង។ ឥលូវចាត់ចែងតែឯងចុះ។

សាស្ត្រាចារ្យឡុក់ហាតសម្លឹងមើលជុំវិញខ្លួនគាត់ទាំងអស់សង្ឃឹម គ្មាននរណាម្នាក់អាចជួយគាត់បាននោះទេ។ ពេលនោះគាត់មើលទៅមិនសង្ហាដូចមុនទេ។ បបូរមាត់របស់គាត់ចាប់ផ្ដើមញ័រ ហើយអវត្តមាននៃស្នាមញញឹមរបស់គាត់បានធ្វើឲ្យគាត់មើលទៅទន់ខ្សោយណាស់។

- ល្អ...ល្អណាស់- គាត់និយាយ - ខ្ញុំ...ខ្ញុំនឹងទៅការិយាល័យរបស់ខ្ញុំដើម្បី...ដើម្បីរៀបចំខ្លួនឲ្យហើយ។

បន្ទាប់ពីនិយាយចប់ គាត់ក៏ចាកចេញទៅ។

- ល្អ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយ រន្ធច្រមុះរបស់គាត់ក្ដៅឡើងក្រហម។ - តែប៉ុណ្ណេះអាចកំចាត់គាត់ចោលបាន ហើយកុំឲ្យទើសដៃទើសជើង។ ប្រធានសិស្សទាំងអស់ត្រូវទៅប្រាប់សិស្សរាល់គ្នាពីអ្វីដែលបានកើតឡើង ហើយប្រាប់ពួកគេថាសេវាកម្មរថភ្លើងរបស់សាលាហុកវ៉ាតនឹងនាំពួកគេទៅផ្ទះរៀងៗខ្លួនវិញនៅថ្ងៃស្អែកនេះ។ ចំនែកអ្នកដែលនៅសល់ ត្រូវប្រាកដថាគ្មានសិស្សណាម្នាក់បានចាកចេញពីសយនដ្ឋានទេ។

គ្រូទាំងអស់បានក្រោកឡើង ហើយបានចេញម្ដងម្នាក់ៗ។

★

នេះប្រហែលជាថ្ងៃដ៏អាក្រក់បំផុតនៅក្នុងជីវិតរបស់ហេរីហើយ។ វា រ៉ុន ហ្វ្រេដ និងចចបានអង្គុយជាមួយគ្នានៅក្បែរជ្រុងសហសាលរបស់ក្រុមហ្គ្រីហ្វីនដ័រ។ គ្មាននរណានិយាយអ្វីសោះ។ ពៀរស៊ីមិនបាននៅទីនោះទេ។ វាបានទៅផ្ញើសំបុត្រឲ្យលោក និងអ្នកស្រីវីស្លី ហើយបន្ទាប់មកវាបានទៅសំងំនៅក្នុងសយនដ្ឋានរបស់វា។

គ្មានពេលរសៀលណាដែលយូរជាងរសៀលនេះទេ ហើយអគាររបស់ក្រុមហ្គ្រីហ្វីនដ័រដែលធ្លាប់តែមានភាពអ៊ូអរប្រែទៅជាស្ងៀមស្ងាត់។ នៅពេលដែលព្រះអាទិត្យជិតលិច ហ្វ្រេដ និងចចបាននាំគ្នាទៅគេង ព្រោះពួកគេមិនអាចអង្គុយនៅទីនោះបានទៀតទេ។

- នាងប្រហែលជាបានដឹងរឿងអ្វីមួយ ហេរី!- រ៉ុននិយាយជាលើកដំបូងតាំងពីពេលដែលពួកវាបានចូលទៅក្នុងទូ នៅក្នុងបន្ទប់បុគ្គលិក។ - នេះហើយជាមូលហេតុដែលនាងត្រូវបានគេចាប់ទៅ។ វាមិនមែនជារឿងឆ្កួតៗដែលទាក់ទងនឹងពៀរស៊ីនោះទេ។ នាងបានដឹងរឿងអ្វីមួយដែលទាក់ទងនឹងបន្ទប់សម្ងាត់នោះ។ នោះជាហេតុផលដែលនាងត្រូវបាន...- រ៉ុនញីភ្នែករបស់វាទាំងក្រហល់ក្រហាយ - ខ្ញុំចង់និយាយថា នាងជាស្រីមានឈាមជ័រសុទ្ធ។ គ្មានហេតុផលអ្វីក្រៅពីនេះទៀតទេ។

ហេរីមើលទៅព្រះអាទិត្យដែលកំពុងលិច ដែលជះពណ៌ក្រហមដូចឈាមនៅក្បែរជើងមេឃ។ ហេរីមានអារម្មណ៍មិនល្អទាល់តែសោះ។ ប្រសិនបើមានអ្វីមួយដែលពួកគេអាចធ្វើបាន ពួកវានឹងធ្វើភ្លាម ទោះជាអ្វីក៏ដោយ។

- ហេរី- រ៉ុននិយាយ - តើឯងគិតថានៅមានឱកាសខ្លះទេដែលនាងមិនទាន់...

ហេរីមិនដឹងថាត្រូវឆ្លើយយ៉ាងម៉េចនោះទេ។ វាមិនដឹងថានាងនៅរស់រឺយ៉ាងម៉េចនោះទេ។

- ខ្ញុំគិតថា- រ៉ុននិយាយ - យើងអាចទៅជួបសាស្ត្រាចារ្យឡក់ហាត ហើយប្រាប់គាត់ពីអ្វីដែលយើងដឹង។ គាត់នឹងព្យាយាមចូលទៅក្នុងបន្ទប់នោះ។ យើងអាចប្រាប់គាត់ពីកន្លែងដែលយើងគិតថាជាផ្លូវចូលនៃបន្ទប់សម្ងាត់នោះ និងប្រាប់អំពីសត្វពស់ដែលនៅក្នុងនោះផងដែរ។

ដោយសារតែហេរីមិនអាចគិតឃើញពីអ្វីដែលវាត្រូវធ្វើ ហើយដោយសារតែវាចង់ធ្វើអ្វីមួយដើម្បីជួយជីននី វាក៏យល់ព្រម។ សិស្សទាំងអស់នៅក្នុងក្រុមហ្គ្រីហ្វីនដ័រមើលទៅស្ងៀមស្ងាត់ណាស់។ ពួកគេបានចូលរួមរំលែកទុក្ខដល់បងប្អូនត្រកូលវីស្លី។ គ្មាននរណាម្នាក់ឃាត់ពួកគេទេ នៅពេលគេទាំងពីរបានក្រោកឡើង ហើយដើរកាត់បន្ទប់ និងចាកចេញទៅតាមប្រហោងរូបភាព។

រាត្រីកាលបានចូលមកដល់ នៅពេលដែលពួកគេដើរសំដៅទៅកាន់ការិយាល័យរបស់សាស្ត្រាចារ្យ ឡក់ហាត។ ស្ដាប់មើលទៅ ខាងក្នុងដូចជាមានសភាពមមាញឹកខ្លាំងណាស់។ ពួកគេបានឮសម្លេងកោស សំលេងវាយ និងស្នូរជើងដើរយ៉ាងលឿន។

ហេរីគោះទ្វារ ហើយភ្លាមនោះនៅខាងក្នុងហាក់ដូចជាមានភាពស្ងៀមស្ងាត់។ បន្ទាប់មក ទ្វារត្រូវបានបង្ហើបចន្លោះតូចមួយ ហើយពួកគេបានឃើញភ្នែកម្ខាងរបស់សាស្ត្រាចារ្យឡក់ហាត សម្លឹងមើលតាមចន្លោះនោះ។

- អូ...ផោតធ័រ...វីស្លី- គាត់និយាយព្រមទាំងបើកទ្វារចំហធំជាមុនបន្តិច - ខ្ញុំពិតជារវល់ខ្លាំងណាស់នៅពេលនេះ តើពួកឯងអាចនិយាយឲ្យលឿនបន្តិចបានទេ?

- លោកសាស្ត្រាចារ្យ ពួកយើងមានរឿងខ្លះចង់ប្រាប់លោក- ហេរីនិយាយ - យើងគិតថាវាប្រហែលជាអាចជួយលោកបាន។

- អឺ...បាន...វាដូចជាមិនអស្ចារ្យពេកទេ- មុខមួយចំហៀងរបស់គាត់ដែលពួកគេបានឃើញមើលទៅដូចជាមានទុក្ខព្រួយណាស់ - អឺ...បាន...ពួកឯងអាចចូលបាន។

គាត់បានបើកទ្វារហើយពួកគេបានចូលទៅ។

ការិយាល័យរបស់គាត់ស្ទើរតែទទេរស្អាតទៅហើយ។ វ៉ាលីសធំៗពីរត្រូវបានដាក់ផ្ដេកហើយបើកចំហនៅលើកំរាល។ រ៉ូបគ្រឿងលំអធ្វើអំពីថ្មពណ៌បៃតង ដើមលីឡាក់ (ដើមឈើដែលមានផ្កាពណ៌ស ផ្កាឈូក ស្វាយហើយមានក្លិនក្រអូប) អាវគេងយប់ពណ៌ខៀវ ត្រូវបានបត់យ៉ាងប្រញាប់ប្រញាល់ទៅក្នុងវ៉ាលិសទីមួយ។ សៀវភៅជាច្រើនត្រូវបានដាក់យ៉ាងច្របូកច្របល់នៅក្នុងវ៉ាលិសទីពីរ។ ចំនែករូបថតដែលត្រូវបានព្យួរនៅលើជញ្ជាំង ត្រូវបានញាត់ចូលទៅក្នុងកេសដែលដាក់នៅលើតុ។

- លោកត្រូវទៅកន្លែងផ្សេងរឺ?- ហេរីសួរ។

- ត្រូវហើយ- សាស្ត្រាចារ្យឡក់ហាតនិយាយព្រមទាំងហែកផ្ទាំងរូបភាពដែលមានទំហំប្រហាក់ប្រហែលនឹងគាត់ចេញពីផ្នែកខាងខ្នងនៃទ្វារបន្ទប់របស់គាត់ ហើយចាប់ផ្ដើមមូរវាទុក។

- ជាការបញ្ហាមួយបន្ទាន់ដែលមិនអាចគេចវេសបាន ខ្ញុំត្រូវតែ...

- ចុះចំនែកប្អូនស្រីខ្ញុំ?- រ៉ុននិយាយទាំងខ្លួនញ័រទទ្រើក។

- គឺដោយសារតែរឿងនេះហើយ...គឺជាសំណាងអាក្រក់មួយរបស់ខ្ញុំ- គាត់និយាយទាំងខំប្រឹងគេចចេញពីក្រសែភ្នែករបស់ពួកគេ ពេលដែលគាត់កំពុងតែបើកថតតុ ហើយចាប់ផ្ដើមប្រមូលរបស់ដែលមាននៅក្នុងនោះ ទៅដាក់ក្នុងកាតាបមួយ - គ្មាននរណាម្នាក់ដែលសោកស្ដាយជាងខ្ញុំនោះទេ។

- លោកគឺជាគ្រូបង្រៀនមុខវិជ្ជាការពារនឹងមន្តអាគមងងឹត- ហេរីនិយាយ - លោកមិនអាចទៅណាបានទាំងអស់ជាមួយនឹងរបស់របរទាំងអស់ដែលនៅទីនេះ។

- ល្អ! ខ្ញុំត្រូវតែនិយាយ...នៅពេលដែលខ្ញុំរើសយកការងារនេះ...- គាត់និយាយតិចៗ ដោយកំពុងតែដាក់គស្រោមជើងរបស់គាត់ទៅលើអាវវែង -...គេគ្មាននិយាយអ្វីពណ៌នាអំពីការងារនេះទេ...មិនបានរំពឹងទុកជាមុននោះទេ...

- នេះបានន័យថាលោកចង់រត់ចេញហើយរឺ?- ហេរីនិយាយយ៉ាងភ្ញាក់ផ្អើល - ក្រោយពីបាននិពន្ធរឿងរ៉ាវអស្ចារ្យទាំងនោះនៅក្នុងសៀវភៅរបស់លោក...

- សៀវភៅអាចធ្វើឲ្យយើងយល់ខុសបាន- គាត់និយាយយ៉ាងស្រទន់។

- ប៉ុន្តែលោកបានសរសេរសៀវភៅទាំងអស់នោះ- ហេរីស្រែកឡើង។

- ក្មេងប្រុសដ៏កំសត់អើយ- គាត់និយាយហើយបែរមើលវាចំ និងចងចិញ្ចើមដាក់វា - ចូរព្យាយាមគិតទៅមើល! សៀវភៅរបស់ខ្ញុំប្រាកដជាមិនអាចលក់អស់ពាក់កណ្តាលផង ប្រសិនបើមនុស្សគ្រប់គ្នាគិតថាខ្ញុំមិនបានធ្វើរឿងនោះ! គ្មាននរណាម្នាក់ចង់អានអំពីបុរសជនជាតិអាមេរិកដែលចាស់ហើយអាក្រក់ទៀត ទោះបីជាគាត់បានសង្គ្រោះភូមិមួយពីសត្វចចកកំណាចក៏ដោយ។ គាត់មើលទៅអាក្រក់ខ្លាំងណាស់ ជាមួយនឹងរូបរាងដែលគ្មានសំលៀកបំពាក់របស់គាត់។ ហើយមេធ្មប់ដែលបានកំចាត់បិសាចប៉ែនដុន ប៉ែនស្ទី មានពុកចង្កាវែងៗ...

- ដូចនេះលោកបានទទួលនូវការកោតសរសើរពីអ្វីដែលអ្នកដទៃបានធ្វើអញ្ចឹងរឺ?- ហេរីនិយាយទាំងមិនចង់ជឿ។

- ហេរី! ហេរី!- សាស្ត្រាចារ្យឡក់ហាតនិយាយដោយគ្រវីក្បាលរបស់គាត់តិចៗបែបអន្ទះអន្ទែង - វាមិនមែនងាយស្រួលដូចឯងនិយាយនោះទេ ខ្ញុំក៏មានកិច្ចការត្រូវធ្វើដែរ។ ខ្ញុំត្រូវស្វែងរកពួកគេឲ្យឃើញហើយសួរពួកគេថា ពួកគេបានធ្វើអ្វីខ្លះហើយធ្វើយ៉ាងដូចម្តេច។ បន្ទាប់មកខ្ញុំនឹងសូត្រគាថាបាលីកំទេចការចងចាំទៅលើពួកគេ ដូចនេះ ពួកគេមិនអាចចងចាំពីអ្វីដែលពួកគេបានធ្វើនោះទេ។ អ្វីដែលធ្វើឲ្យខ្ញុំមានមោទនភាពចំពោះខ្លួនឯងជាងគេនោះ គឺបាលីកំទេចការចងចាំរបស់ខ្ញុំ។ វាមិនមែនជាការងារតិចតួចដែលខ្ញុំបានធ្វើនោះទេ។ ប្រសិនបើឯងចង់បានកេរ្តិ៍ឈ្មោះ ឯងត្រូវត្រៀមខ្លួនចំពោះការងារលំបាកផ្សេងៗ។

គាត់បិទគំរបវ៉ាលីស ហើយចាក់សោ។

- ចាំមើលណា!- គាត់និយាយ - ខ្ញុំគិតថានៅមានរឿងមួយទៀត ដែលខ្ញុំមិនទាន់បានធ្វើ។

គាត់បានដកចង្កឹះវេទមន្តរបស់គាត់មកក្រៅ ហើយបែរមករកពួកគេ។

- សុំទោសផង ក្មេងប្រុសដ៏គួរឲ្យអាណិតអើយ ខ្ញុំនឹងសូត្រគាថាបាលីកំទេចការចងចាំទៅលើពួកឯង។ ដូចនេះពួកឯងនឹងមិនអាចនិយាយរឿងសម្ងាត់របស់ខ្ញុំប្រាប់គេបានទេ។ ខ្ញុំប្រហែលជាមិនអាចលក់សៀវភៅដាច់ទៀតទេបើ...

ហេរីបានលូកយកចង្កឹះវេទមន្តរបស់វាភ្លាមនោះដែរ។ សាស្ត្រាចារ្យឡក់ហាតបានធ្វើឲ្យជ្រុះចង្កឹះវេទមន្តរបស់គាត់នៅពេលដែលហេរីស្រែកថា៖

- *អ៊ិចស្ពេលីអាមុស!*

សាស្ត្រាចារ្យឡក់ហាតបានដើរថយក្រោយ ហើយដួលទៅលើវ៉ាលីសរបស់គាត់។ ចង្កឹះវេទមន្តរបស់របស់គាត់បានហោះឡើង។ រ៉ុនបានចាប់វាហើយបោះវាចោលតាមចន្លោះបង្អួចដែលបើកចំហ។

- ចំពោះរឿងនេះ យើងមិនចាំបាច់ឲ្យស្នេពបង្រៀនយើងនោះទេ- ហេរីនិយាយយ៉ាងកំរោល ហើយទាត់វ៉ាលីសរបស់សាស្ត្រាចារ្យឡាក់ហាតទៅម្ខាង។ គាត់សម្លឹងមើលវាដោយភាពភ័យខ្លាចខ្លាំងជាងមុន។ ហេរីនៅតែលើកចង្កឹះវេទមន្តរបស់វាចង្អុលទៅគាត់ដដែល។

- តើពួកឯងចង់ឲ្យខ្ញុំធ្វើអ្វី?- សាស្ត្រាចារ្យឡក់ហាតនិយាយខ្សោយៗ - ខ្ញុំមិនដឹងថាបន្ទប់សម្ងាត់នោះនៅទីណាទេ។ ខ្ញុំមិនអាចធ្វើអ្វីបានទាំងអស់។

- លោកពិតជាសំណាងណាស់- ហារីនិយាយ ទាំងបង្ខំឲ្យគាត់ក្រោកឡើង - យើងគិតថាយើងដឹងថាបន្ទប់នោះនៅទីណា ហើយមានអ្វីនៅក្នុងនោះដែរ។ ទៅ!

ពួកគេបានបណ្ដើរសាស្ត្រាចារ្យឡក់ហាតចេញពីការិយាល័យរបស់គាត់ ហើយចុះតាមជណ្ដើរដែលនៅជិតបំផុត។ ពួកគេបានដើរតាមផ្លូវរបៀងងងឹត ដែលមានផ្លាកនៅលើជញ្ជាំងសម្រាប់បង្ហាញផ្លូវទៅកាន់បន្ទប់ទឹករបស់ ម៉ុននីង មីតចល។

ពួកគេបានឲ្យសាស្ត្រាចារ្យឡក់ហាតចូលទៅមុន។ ហារីសប្បាយចិត្តណាស់នៅពេលដែលដឹងថាខ្លួនគាត់ឡើងញ័រ។

ម៉ុននីង មីតចល កំពុងតែអង្គុយនៅលើអាងទឹកនៅខាងចុងបន្ទប់ទឹក។

- អូ! គឺឯងរឺ?- នាងនិយាយពេលឃើញហារី - តើឯងចង់បានអ្វីដែរ?

- ចង់សួរនាងថាតើនាងស្លាប់យ៉ាងដូចម្ដេច?- ហារីនិយាយ។

ទឹកមុខរបស់មីតចលផ្លាស់ប្ដូរមួយរំពេច។ មើលទៅនាងដូចជាមិនដែលធ្លាប់គេសួរសំនួរនេះទៅកាន់នាងទេ។

- អូ!!! វាអាក្រក់ខ្លាំងណាស់- នាងនិយាយដោយភាពរីករាយ - វាបានកើតឡើងនៅទីនេះ ខ្ញុំបានស្លាប់នៅក្នុងបន្ទប់ទឹកដ៏តូចនេះ ខ្ញុំនៅចាំវាយ៉ាងច្បាស់។ ខ្ញុំបានរត់ពួនព្រោះ អូលីវ ហនបាយ បានចំអកឡកឡឺយខ្ញុំដោយសារតែវ៉ែនតារបស់ខ្ញុំ។ ខ្ញុំបានចាក់សោទ្វារ ហើយបានយំ។ ពេលនោះខ្ញុំបានឮសម្លេងនរណាម្នាក់ដើរចូលមក។ ពួកគេបាននិយាយគ្នាពីរឿងអស់សំណើចដោយប្រើភាសាផ្សេង។ ខ្ញុំគិតថាប្រហែលជាអញ្ចឹងហើយ។ ម្យ៉ាងទៀត ខ្ញុំច្បាស់ណាស់ថាសម្លេងនោះគឺជាសម្លេងរបស់ក្មេងប្រុស។ ដូចនេះខ្ញុំបានបើកទ្វារហើយប្រាប់ពួកគេទៅបន្ទប់ទឹកប្រុសទៅ។ បន្ទាប់មក- នាងនិយាយបន្តទៀត មុខរបស់នាងបញ្ចេញពន្លឺ - ខ្ញុំបានស្លាប់។

- នាងបានស្លាប់យ៉ាងម៉េច?- ហារីសួរ។

- ខ្ញុំក៏មិនដឹងដែរ- មីតចលនិយាយយ៉ាងស្ងៀមស្ងាត់ - ខ្ញុំគ្រាន់តែចាំថាខ្ញុំបានឃើញភ្នែកធំៗពណ៌លឿងមួយគូ។ រាងកាយរបស់ខ្ញុំត្រូវបានចាប់ខ្វាំ ហើយបន្ទាប់មកខ្ញុំបានអណ្ដែតឡើងលើ- នាងមើលទៅហារីទាំងស្រមើស្រមៃ - ហើយខ្ញុំក៏ធ្លាក់មកលើកម្រាលឥដ្ឋវិញ ។ ខ្ញុំប្ដេជ្ញាថានឹងតាមលងអូលីវ ហនបាយ។ ឯងឃើញទេ នាងពិតជាសោកស្ដាយពីព្រោះតែនាងធ្លាប់សើចចំអកឲ្យខ្ញុំអំពីវ៉ែនតារបស់ខ្ញុំ។

- តើកន្លែងណាពិតប្រាកដដែលឯងបានឃើញភ្នែកនោះ?- ហារីសួរ។

- ប្រហែលជាទីនោះ- មីតចលនិយាយព្រមទាំងចង្អុលទាំងស្រពិចស្រពិលទៅកាន់កន្លែងលុបមុខដែលស្ថិតនៅទល់មុខបន្ទប់ទឹករបស់នាង។

មើលទៅវាដូចជាកន្លែងលុបមុខធម្មតាប៉ុណ្ណោះ។ ពួកគេបានពិនិត្យមើលវាគ្រប់ទីកន្លែងទាំងខាងក្នុង ទាំងខាងក្រៅ និងបំពង់បង្ហូរទឹកជាដើម។ បន្ទាប់មក ហារីបានរកឃើញ ស្នាមកូតនៅជ្រុងម្ខាងនៃក្បាលរ៉ូប៊ីនេមួយ ធ្វើអំពីទង់ដែង មានឆ្លាក់រូបពស់តូចមួយ។

- ក្បាលរ៉ូប៊ីនេនេះខូចហើយ- មីតចលនិយាយយ៉ាងរីករាយនៅពេលដែលឃើញហារីព្យាយាមបើកវា។

- ហារី- រ៉ុននិយាយ - សាកនិយាយទៅមើល។ អ្វីក៏ដោយឲ្យតែជាភាសាពស់។

- ប៉ុន្តែ- ហេរីព្យាយាមគិត។ ពេលវេលាតែមួយគត់ដែលវាអាចនិយាយភាសាពស់បានគឺនៅពេលដែលវាកំពុងតែប្រឈមមុខចំពោះសត្វពស់ពិតប្រាកដមួយ។

- បើកភ្លាម!- ហេរីនិយាយ។

ហេរីមើលទៅរ៉ុន ដែលកំពុងតែគ្រវីក្បាល។

- ឯងនិយាយចេញសូរភាសាអង់គ្លេសហ្នឹង- រ៉ុននិយាយ។

ហេរីក្រឡេកមើលទៅរូបពស់នោះម្តងទៀត ហើយព្យាយាមធ្វើឲ្យខ្លួនវាជឿថាពស់នោះមានជីវិត។ ប្រសិនបើហេរីកំរើកក្បាល ពន្លឺភ្លើងទៀននឹងធ្វើឲ្យរូបនោះមើលទៅកំពុងតែធ្វើចលនា។

- បើកឡើង!- វានិយាយ។

វាមិនត្រឹមតែបានឮសម្លេងរបស់វានោះទេ ថែមទាំងមានសម្លេងចំលែកមួយបានបន្លឺឡើងចេញពីមាត់វាផ្ទាល់តែម្តង។ ភ្លាមនោះ ក្បាលរូប៊ីនែនោះចាប់ផ្តើមបញ្ចេញពន្លឺពណ៌សយ៉ាងត្រចះត្រចង់និងចាប់ផ្តើមធ្វើចលនា។ ប៉ុន្មានវិនាទីបន្ទាប់មកទៀត កន្លែងលុបមុខចាប់ផ្តើមធ្វើចលនាផ្លាស់ប្តូររូបរាង។ នៅពេលដែលកន្លែងលុបមុខនោះលិចបាត់ទៅ វាបានបន្សល់ទុកនូវប្រហោងធំមួយ គឺជាបំពង់ធំល្មមសម្រាប់បុរសម្នាក់រអិលចូលទៅក្នុងនោះ។

ហេរីបានឮសម្លេងរ៉ុនដង្ហក់ ហើយវាបានក្រឡេកមើលទៅលើម្តងទៀត។ វាបានសួរខ្លួនឯងថាតើត្រូវធ្វើអ្វីបន្តទៀត?

- ខ្ញុំនឹងចុះទៅក្រោម- វានិយាយ។

វាមិនអាចមិនចុះទៅនោះទេ ព្រោះថាឥលូវពួកគេរកឃើញផ្លូវចូលទៅបន្ទប់សម្ងាត់ទៅហើយ។ មួយវិញទៀត ប្រសិនបើអាចទៅឲ្យទាន់ពេលនោះ ជីននីប្រហែលជានៅមានជីវិតនៅឡើយទេ។

- ខ្ញុំក៏ទៅដែរ- រ៉ុននិយាយ។

មានភាពស្ងៀមស្ងាត់ភ្លាមមួយសន្ទុះ។

- ខ្ញុំគិតថាពួកឯងប្រហែលជាមិនត្រូវការខ្ញុំទេ- សាស្ត្រាចារ្យឡុក់ហាតនិយាយព្រមទាំងបញ្ចេញស្នាមញញឹមបន្តិចរបស់គាត់ - ខ្ញុំគ្រាន់តែ...

គាត់បានដាក់ដៃរបស់គាត់ទៅលើទ្វារទាំងសងខាង ប៉ុន្តែរ៉ុន និងហេរីបានចង្អុលចង្កឹះវេទមន្តទៅកាន់គាត់។

- លោកអាចចុះទៅមុនពួកយើងបាន- រ៉ុននិយាយទាំងកំហឹង។

សាស្ត្រាចារ្យឡុក់ហាតបានខិតទៅជិតច្រកចូលទាំងទឹកមុខស្លេកស្លាំង។

- ពួកឯង!- គាត់និយាយដោយសម្លេងខ្សោយៗ - ពួកឯងធ្វើអញ្ចឹងតើបានផលប្រយោជន៍អ្វីទៅ?

ហេរីបានចាក់ខ្នងគាត់ដោយចង្កឹះវេទមន្តរបស់វា។ សាស្ត្រាចារ្យឡុក់ហាតបានរអិលជើងរបស់គាត់ចូលទៅក្នុងប្រហោងនោះ។

- ខ្ញុំពិតជាមិនបានគិតថា- ហេរីចាប់ផ្តើមនិយាយ ស្រាប់តែរ៉ុនច្រានវាចេញ ហើយទម្លាក់ខ្លួនទៅតាមក្រោយសាស្ត្រាចារ្យឡុក់ហាតលឿនស្លេវបាត់តែមួយពព្រិចភ្នែក។ ហេរីទៅតាមយ៉ាងរហ័សរហួន។ វាបន្ទាបខ្លួនយឺតៗទៅក្នុងបំពង់នោះ បន្ទាប់មកក៏ព្រលែងដៃទម្លាក់ខ្លួនទៅតាម។

## បន្ទប់សម្ងាត់

ប្រហោងនោះរលោង ងងឹតហើយមើលទៅដូចជាគ្មានទីបញ្ចប់ទេ។ វាអាចមើលឃើញប្រហោងមូលជាច្រើនដែលបែកខ្ញែកទៅគ្រប់ទីកន្លែង ប៉ុន្តែមិនធំជាងប្រហោងដែលវាកំពុងតែស្ថិតនៅក្នុងប៉ុន្មានទេ។ ប្រហោងទាំងនោះបត់បែនកាច់ចុះកាច់ឡើង យ៉ាងចោតចុះទៅក្រោម។ ហេរី ដឹងថាវាបានធ្លាក់ចុះយ៉ាងជ្រៅទៅក្រោមសាលាហើយប្រហែលជាជ្រៅជាងគុកងងឹតទៅទៀត។ នៅពីក្រោមវា ហេរីបានឮសូររ៉ុនធ្លាក់មកប៉ះនឹងកន្លែងកោងមួយប៉ុន្តែមិនជាធ្ងន់ធ្ងរប៉ុន្មានទេ។

បន្ទាប់មក នៅពេលដែលវាចាប់ផ្តើមបារម្ភពីអ្វីដែលនឹងអាចកើតឡើងនៅពេលដែលវាទង្គិចទៅនឹងដី បំពង់នោះចាប់ផ្តើមរាបស្មើ ហើយវាក៏ខ្ទាតចេញពីចុងបំពង់នោះ ទៅធ្លាក់នៅលើកំរាលឥដ្ឋសើមក្នុងផ្លូវក្រោមដីសាងពីថ្មធំល្មមនឹងអាចឈរបាន។ សាស្ត្រាចារ្យឡក់ហាតឈានជើងទៅមុខបន្តិចម្តងៗជាមួយនឹងមុខស្លេកស្លាំងដូចខ្មោច។ ហេរីបានឈរទៅម្ខាងនៅពេលដែលរ៉ុនដើរចេញយ៉ាងលឿនពីប្រហោងនោះ។

- យើងពិតជាស្ថិតនៅចម្ងាយរាប់គីឡូម៉ែតពីក្រោមសាលាហើយ- ហេរីនិយាយ សម្លេងរបស់វាខ្ទរពេញរូងថ្មងងឹតនោះ។

- ប្រហែលជានៅក្រោមបឹងហើយមើលទៅ!- រ៉ុននិយាយព្រមទាំងសម្លឹងមើលទៅជញ្ជាំងតូចៗដែលនៅជុំវិញវាក្នុងភាពងងឹត។

ពួកគេទាំងបីបានសម្លឹងមើលទៅភាពងងឹតដែលនៅពីខាងមុខពួកគេ។

- *លូមុស!*- ហេរីនិយាយតិចៗ ទៅកាន់ចង្កឹះវេទមន្តរបស់វាដែលភ្លាមនោះបានចាប់ផ្តើមបញ្ចេញពន្លឺ - ដើរមក!- វានិយាយទៅកាន់រ៉ុន និងសាស្ត្រាចារ្យឡក់ហាត។ នៅពេលដែលពួកគេដើរទៅ ស្នូរជើងរបស់ពួកគេបានបញ្ចេញសម្លេងខ្លាំងនៅពេលដែលប៉ះទៅនឹងកំរាលសើម។

រូងថ្មនោះងងឹតណាស់ធ្វើឲ្យពួកគេមិនអាចមើលឃើញបានឆ្ងាយទេ។ ស្រមោលពួកគេដែលអាចមើលឃើញបានដោយសារពន្លឺរបស់ចង្កឹះវេទមន្តនោះ មើលទៅគួរឲ្យខ្លាចណាស់។

- ត្រូវចាំថា- ហេរីនិយាយតិចៗនៅពេលដែលពួកគេកំពុងតែដើរយ៉ាងប្រុងប្រយ័ត្នឆ្ពោះទៅមុខ - នៅពេលដែលឃើញរឺឮសម្លេងដែលហាក់បីដូចជាមានចលនា ត្រូវបិទភ្នែកភ្លាម។

ប៉ុន្តែរូងថ្មនោះនៅតែស្ងាត់ដូចជាផ្នូរអញ្ចឹង។ សម្លេងទីមួយដែលពួកគេបានឮសូរគឺជាសម្លេងដ៏គ្រលួចមួយនៅពេលដែលរ៉ុនបានបោះជំហានជាន់ទៅលើអ្វីមួយដែលមានសណ្ឋានដូចលលាដ៏ក្បាលកណ្តុរអញ្ចឹង។ ហេរីបានបន្ទាបចង្កឹះវេទមន្តរបស់វាដើម្បីមើលទៅលើកំរាលនោះ។ វាបានឃើញឆ្អឹងសត្វតូចៗជាច្រើន ពង្រាយនៅលើកំរាលឥដ្ឋនោះ។ នៅពេលដែលឃើញឆ្អឹងសត្វទាំងនោះ ពួកគេបានព្យាយាមមិនគិតថាជីននីនឹងស្ថិតនៅក្នុងស្ថានភាពដូចម្តេចទេ នៅពេលដែលពួកគេរកឃើញនាង។ ពួកគេដើរទៅមុខទៀតដោយមានហេរីជាអ្នកនាំមុខ ឆ្លងកាត់កន្លែងបត់បែនដ៏ងងឹតនៅក្នុងរូងថ្មក្រោមដីនោះ។

- ហេរី! មានអ្វីនៅខាងលើយើង នោះ...- រ៉ុននិយាយស្អកៗព្រមទាំងបានយកដៃរបស់វាទៅអង្រួនស្មារបស់ហេរី។

ពួកគេបានឈប់ភ្លាមមួយរំពេច ហើយមើលទៅលើ។ ហេរីបានឃើញរបស់អ្វីមួយដែលធំហើយកោង ហើយវាលាតសន្ធឹងពីជ្រុងម្ខាងទៅជ្រុងម្ខាងទៀតនៃរូបថ្ម។ វាមិនកំរើកនោះទេ។

- វាប្រហែលជាកំពុងតែដេកលក់ហើយ- វានិយាយខ្សឹបៗដោយក្រឡេកមើលទៅអ្នកទាំងពីរទៀត។

សាស្ត្រាចារ្យឡក់ហាតបានយកដៃទៅបិទភ្នែករបស់គាត់។ ហេរីបានត្រលប់ទៅមើលរបស់នោះម្តងទៀត។ វាមានអារម្មណ៍ថាបេះដូងរបស់វាលោតយ៉ាងលឿន។

ហេរីនៅតែសម្លឹងមើលវត្ថុនោះដោយបង្រួមភ្នែករបស់វាឲ្យតូចទៅៗតាមដែលអាចធ្វើបាន។ ហេរីសម្លឹងមើលពីចំហៀង ហើយចាប់ផ្តើមលើកចង្កឹះវេទមន្តរបស់វាឡើងខ្ពស់។

ពន្លឺនៃចង្កឹះវេទមន្តបានបំភ្លឺបន្តិចម្តងៗទៅលើស្បែកពស់ដ៏ធំសំបើមមួយពណ៌បៃតង។ វាជាស្បែកដែលមើលទៅមានភាពរស់រវើកមានពិស ដែលបានក្រាលអង្កាញ់ពីជ្រុងម្ខាងទៅជ្រុងម្ខាងទៀតនៅលើកំរាលនៃរូងថ្ម។ ស្បែកពស់ដែលលេចឡើងនោះមានប្រវែងយ៉ាងតិចណាស់ប្រហែលដប់ប្រាំបីម៉ែត។

- អស្ចារ្យ- រ៉ុននិយាយខ្សោយៗ។

ភ្លាមនោះ អ្វីមួយបានធ្វើចលនាពីក្រោយពួកគេ។ ជង្គង់របស់ហ្គីលដឺរ័យ ឡក់ហាតទ្រខ្លួនគាត់លែងជាប់ទៀតហើយ។

- ក្រោកឡើង- រ៉ុននិយាយភ្លាមៗ ព្រមទាំងលើកចង្កឹះវេទមន្តរបស់វាចង្អុលទៅកាន់គាត់។

សាស្ត្រាចារ្យឡក់ហាតក្រោកឡើង សម្លឹងមើលទៅរ៉ុន ហើយវាយវា។

ហេរីងាកយ៉ាងលឿន ប៉ុន្តែយឺតពេលទៅហើយ។ សាស្ត្រាចារ្យឡក់ហាតក្រោកឡើងដកដង្ហើមដង្ហក់ ដោយមានចង្កឹះវេទមន្តរបស់រ៉ុននៅក្នុងដៃរបស់គាត់។ ស្នាមញញឹមបានត្រលប់មកលើផ្ទៃមុខរបស់គាត់វិញ។

- ដំណើរផ្សងព្រេងគួរតែបញ្ចប់ត្រឹមហ្នឹងហើយ- គាត់និយាយ - ខ្ញុំគួរតែយកស្បែកនេះបន្តិចត្រលប់ទៅសាលាវិញ ប្រាប់ពួកគេថា ខ្ញុំបានទៅជួយក្មេងស្រីនោះយឺតពេលទៅហើយ ហើយប្រាប់ថាជាអកុសល អ្នកទាំងពីរបានបាត់បង់ស្មារតីនៅពេលដែលបានឃើញរាងកាយខ្ទេចខ្ទីរបស់នាង។ និយាយពាក្យលាទៅកាន់ការចងចាំរបស់ពួកឯងទៅ!

គាត់លើកចង្កឹះវេទមន្តបិតស្កុតរបស់រ៉ុនឡើងទៅលើត្រឹមក្បាលរបស់គាត់ហើយស្រែកថា៖

- *អូប្លីវេត!*

ចង្កឹះរបស់រ៉ុនបានផ្ទុះឡើងជាមួយនឹងសម្លេងដូចគ្រាប់បែកតូចមួយផ្ទុះ។ ហេរីបានលើកដៃទៅបាំងក្បាលរបស់វាហើយរត់។ វាបានរអិលដួលទៅលើចង្វាយស្បែកពស់។ ពោលគឺវាបានរត់គេចចេញពីដុំថ្មជាច្រើនដែលបានធ្លាក់ពីខាងលើមកលើកំរាលនៃរូងថ្ម ដោយបន្លឺសម្លេងខ្លាំងៗ។ បន្តិចក្រោយមក វាកំពុងតែឈរម្នាក់ឯង ហើយសម្លឹងមើលទៅជញ្ជាំងថ្មដ៏រឹងមាំដែលកើតឡើងពីថ្មដែលធ្លាក់អំបាញ់មិញនោះ។

- រ៉ុន- វាស្រែក - តើឯងអត់កើតអីទេរឺ? រ៉ុន!

- ខ្ញុំនៅទីនេះ- សម្លេងតិចៗរបស់រ៉ុនបានបន្លឺឡើងពីក្រោយជញ្ជាំងថ្មដែលធ្លាក់នោះ - ខ្ញុំគ្មានបញ្ហាអ្វីនោះទេ ប៉ុន្តែលោកសាស្ត្រាចារ្យដូចជាមានបញ្ហា អាគមនោះដូចជាមកត្រូវគាត់វិញ...

មានសម្លេងគ្រលរខ្លាំងមួយបានបន្លឺឡើង "អូយ" សម្លេងនោះបន្លឺឡើងនៅពេលដែលរ៉ុនទាត់លោកសាស្ត្រាចារ្យឡក់ហាតដោយប្រើស្មងជើងរបស់វា។

- ហើយចុះឥឡូវ- សម្លេងរបស់រ៉ុនបន្លឺឡើង - យើងមិនអាចឆ្លងកាត់ផ្ទាំងថ្មនេះបានទេ យើងប្រហែលជាត្រូវចំណាយពេលយូរដើម្បី...

ហេរី មើលទៅដំបូលនៃរូងថ្ម។ សម្លេងខ្លាំងបានបន្លឺឡើងនៅក្នុងនោះ។ វាមិនដែលសាកល្បងបំបែកអ្វីមួយដែលធំដូចថ្មនេះដោយប្រើវេទមន្តនោះទេ ហើយឥឡូវនេះមិនមែនជាពេលវេលាដ៏ល្អសម្រាប់ព្យាយាមធ្វើវានោះទេ ខ្លាចថាមិនស្រួល ធ្វើអោយរូងថ្មទាំងមូលបាក់ចុះមក។

មានសម្លេងខ្លាំងៗ និងសម្លេងស្រែកបន្លឺឡើងពីក្រោយផ្ទាំងថ្មម្ខាងទៀត។ ពួកគេខាតពេលវេលាអស់ច្រើនណាស់។ ជីននីត្រូវបានចាប់ចូលក្នុងបន្ទប់សម្ងាត់នោះ អស់រយៈពេលជាច្រើនម៉ោងមកហើយ។ ហេរីគិតថាមានរឿងតែមួយគត់ដែលវាអាចធ្វើបាន។

- រង់ចាំនៅទីនេះហើយ- ហេរីស្រែកប្រាប់រ៉ុន - រង់ចាំជាមួយសាស្ត្រាចារ្យឡក់ហាត ហើយប្រសិនបើខ្ញុំមិនបានត្រលប់មកវិញក្នុងរយៈពេលមួយម៉ោងទៀត...

ពួកគេបានឈប់ជជែកគ្នាអស់មួយសន្ទុះធំ។

- ខ្ញុំនឹងព្យាយាមយកថ្មខ្លះចេញ- រ៉ុននិយាយ ដែលស្តាប់ទៅដូចជាព្យាយាមរក្សាសម្លេងរបស់វាឲ្យនៅធម្មតា - ដូចនេះឯងអាច...អាចឆ្លងមកខាងនេះវិញបាន។ ហេរី?

- ជួបគ្នាបន្តិចទៀតនេះ- ហេរីនិយាយ ទាំងព្យាយាមបញ្ចូលភាពជឿជាក់ទៅក្នុងសម្លេងញ័ររបស់វា។

ហេរីចាប់ផ្តើមធ្វើដំណើរតែម្នាក់ឯងឆ្លងកាត់ស្បែកពស់ដ៏ធំនោះ។

នៅពេលដែលដើរបានឆ្ងាយបន្តិច សម្លេងដែលរ៉ុនខំប្រឹងជញ្ជូនថ្មចេញបានរលាយបាត់ទៅ។ រូងថ្មនេះចេះតែវែងបន្តទៅមុខរហូត។ សេចក្តីតាំងចិត្តនៅក្នុងខ្លួនរបស់វាមានច្រើនដែរ។ វាចង់រកឲ្យឃើញចុងបញ្ចប់នៃរូងថ្មនេះក្នុងពេលឆាប់ៗ ប៉ុន្តែវាមានការភ័យខ្លាចចំពោះអ្វីដែលវានឹងឃើញ។ នៅទីបញ្ចប់ នៅពេលដែលវាលូនផុតពីផ្លូវកោងមួយ វាបានឃើញជញ្ជាំងថ្មនៅខាងមុខវាដែលមានរូបពស់ពីរក្បាលកំពុងប្រទាក់ចូលគ្នា ត្រូវបានឆ្លាក់នៅលើនោះ។ ភ្នែករបស់ពស់នោះត្រូវបានឆ្លាក់ឡើងដោយប្រើត្បូងមរកតចាំងភ្លឺផ្លេក។

ហេរីបានចូលទៅជិត ហើយបំពង់ករបស់វាឡើងស្ងួត។ លើកនេះវាមិនចាំបាច់បោកប្រាស់ខ្លួនឯងថាពស់នេះជាពស់ពិតនោះទេ ព្រោះភ្នែករបស់ពស់ទាំងនោះមើលទៅដូចជាមានជីវិតអញ្ចឹង។

វាអាចទាយទុកថាតើវាត្រូវធ្វើអ្វីបន្តទៀត។ វាបានសំអាតបំពង់ករបស់វា ហើយមើលទៅភ្នែកពណ៌បៃតងទាំងនោះដែលកំពុងចោលពន្លឺភ្លឹបភ្លែត។

- បើកឡើងភ្លាម!- ហេរីនិយាយដោយប្រើសម្លេងតិចៗដូចជាមិនសូវពេញចិត្តក្នុងការនិយាយប៉ុន្មានទេ។

សត្វពស់នោះបានបែកចេញពីគ្នានៅពេលដែលជញ្ជាំងបើកឡើង។ ផ្លូវចូលនោះឡើងរលោងស្រិល ហើយហេរីដែលកំពុងតែញ័រខ្លួនតាំងពីក្បាលដល់ចុងជើងនោះ បានដើរចូលទៅ។

## វគ្គ XVII



# ទាយាទស្លីធើរីន

វាកំពុងឈរនៅចុងម្ខាងនៃបន្ទប់មួយដែលមានប្រវែងវែង ហើយរាងងងឹតបន្តិច។ សសរថ្មខ្ពស់ត្រដែតមានឆ្លាក់រូបពស់ជាច្រើនប្រទាក់ចូលគ្នា ត្រូវបានកសាងឡើងដើម្បីទ្រពិតានដែលកប់បាត់នៅក្នុងភាពងងឹត ហើយចោលស្រមោលវែងៗពណ៌ខ្មៅនៅក្នុងស្បែអន្ធការដ៏ចម្លែកដែលជះពណ៌បៃតងស្រាលពេញទីកន្លែងនោះ។

បេះដូងរបស់វាលោតយ៉ាងលឿន។ ហេរី បានឈររង់ចាំស្តាប់ភាពស្ងៀមស្ងាត់ដ៏គួរឲ្យព្រឺក្បាលនោះ។ តើសត្វពស់ដ៏ធំនោះអាចរង់ចាំវាយឆ្មក់វានៅក្បែរជ្រុងងងឹតខាងក្រោយសសរទាំងនោះដែររឺទេ? ហើយចុះឯណាជីននី?

វាបានដកចង្កឹះវេទមន្តរបស់វាចេញ ហើយដើរឆ្ពោះទៅមុខតាមចន្លោះសសរដែលមានរូបពស់នោះ។ រាល់ស្នូរជើងដ៏ប្រុងប្រយ័ត្នរបស់ហេរីឮខ្ទរមកវិញដោយសារជញ្ជាំងថ្មងងឹតទាំងនោះ។ ហេរី បានបង្រួមភ្នែកឲ្យតូច ហើយប្រុងប្រៀបខ្លួនរួចជាស្រេចដើម្បីបិទភ្នែក ឲ្យតែឃើញចលនាកម្រើកណាមួយ។ ភ្នែកដែលមានរន្ធរបស់សត្វពស់ថ្មទាំងនោះមើលទៅដូចជាកំពុងសម្លឹងមើលមកវា។ ក្រៅពីចលនាក្រពះរបស់វា វាគិតថាវាបានឃើញអ្វីមួយកំពុងតែមានចលនា។

ពេលដែលវាដើរមកដល់សសរមួយគូចុងក្រោយ រូបសំណាកមួយដែលមានកំពស់ប្រហែលនឹងបន្ទប់សម្ងាត់នោះបានលេចឡើងស្កុងៗពីមុខវា។ រូបសំណាកនោះត្រូវបានសង់ឡើងនៅជាប់នឹងជញ្ជាំងតែម្តង។

ហេរីត្រូវអើតកដើម្បីមើលទៅមុខដ៏ធំសំបើមនោះនៅខាងលើ។ រូបចម្លាក់នេះមានសភាពចាស់ណាស់ហើយ ព្រមទាំងរាងដូចជាស្វា ជាមួយនឹងពុកចង្កាស្តើងដែលធ្លាក់ស្ទើរតែដល់ចុងនៃអាវវែងសម្រាប់វេទគូធ្វើអំពីថ្ម ព្រមជាមួយនឹងជើងដ៏ធំពីរ កំពុងតែឈរនៅលើកំរាលដ៏រាបស្មើនៃបន្ទប់សម្ងាត់។ នៅចន្លោះជើងទាំងពីរនោះ មានមនុស្សម្នាក់កំពុងតែដេកផ្កាប់មុខ ពាក់រ៉ូបតូចពណ៌ខ្មៅនិងសក់ពណ៌ក្រហម។

- ជីននី- ហេរីនិយាយខ្សាវៗ ហើយរត់យ៉ាងលឿនទៅរកនាង ព្រមទាំងអង្គុយលុតជង្គង់ក្បែរនាង - ជីននី! កុំទាន់ស្លាប់អី! សូមមេត្តាកុំស្លាប់អី!- វាទុកចង្កឹះវេទមន្តរបស់វាទៅលើកំរាល ហើយអង្រួនស្មារបស់ជីននី បន្ទាប់មកទាញឲ្យនាងដេកផ្ងារវិញ។ មុខរបស់នាងស្លេកស្លាំងដូចថ្ម ហើយត្រជាក់ តែភ្នែករបស់នាងបិទជិត សឲ្យឃើញថានាងមិនត្រូវបាលីបង្កកឡើយ។ ប៉ុន្តែអញ្ចឹងមានតែនាង...

- ជីននី ក្រោកឡើង!- ហេរីនិយាយយ៉ាងងងឹតងងុល ហើយអង្រួននាង។ ក្បាលរបស់ជីននីរង្គើពីម្ខាងទៅម្ខាងធ្វើឲ្យហេរីអស់សង្ឃឹម។

- នាងមិនក្រោកនោះទេ- សំឡេងដ៏ស្រទន់មួយបានបន្លឺឡើង។

ហេរីងាកបង្វិលខ្លួនដោយនៅតែលុតជង្គង់ដដែល។

ក្មេងប្រុសម្នាក់ខ្ពស់ សក់ពណ៌ខ្មៅ កំពុងតែឈរផ្អែកទៅនឹងសសរដែលនៅជិតបំផុត ហើយសម្លឹងមើលមកវា។ គាត់មើលទៅចម្លែក ហើយឈរនៅកន្លែងងងឹតព្រាលៗ ហាក់ដូចជាហេរីកំពុងតែសម្លឹងមើលគាត់តាមបង្អួចស្រអាប់មួយអ៊ីចឹង។ ប៉ុន្តែគ្មានអ្វីច្រឡំនោះទេ គឺគាត់ហ្នឹងហើយ។

- ថម...ថម រីតដល?

រីតដលងក់ក្បាលដោយមិនព្រមដកក្រសែភ្នែកចេញពីហេរីសោះ។

- តើលោកចង់មានន័យយ៉ាងម៉េចដែលថានាងមិនក្រោកទេនោះ?- ហេរីនិយាយតិចៗ - នាង...នាងមិន...?

- នាងនៅមានជីវិតនៅឡើយទេ- រីតដលនិយាយ - ប៉ុន្តែគ្រាន់តែ...

ហេរីសម្លឹងមើលគាត់។ ថមរីតដលធ្លាប់រៀននៅសាលាហុកវ៉ាតកាលពីហាសិបឆ្នាំមុន ហើយឥឡូវគាត់កំពុងតែឈរយ៉ាងអាថ៌កំបាំង មានតែពន្លឺបន្តិចបន្តួចប៉ុណ្ណោះដែលបង្ហាញរូបរាងរបស់គាត់។ ឥឡូវនេះ យ៉ាងច្រើនគាត់អាយុត្រឹមដប់ប្រាំមួយឆ្នាំប៉ុណ្ណោះ។

- លោកគឺជាខ្មោចឬ?- ហេរីនិយាយទាំងមិនប្រាកដប្រជា។

- គឺជាការចងចាំ- រីតដលនិយាយយ៉ាងស្ងៀមស្ងាត់ - ដែលរក្សាទុកនៅក្នុងសៀវភៅកំណត់ហេតុអស់រយៈពេលហាសិបឆ្នាំមកហើយ។

គាត់បានចង្អុលទៅកាន់កម្រាលក្បែរម្រាមជើងនៃរូបចម្លាក់យក្ស។ មានសៀវភៅកំណត់ហេតុមួយកំពុងតែបើកចំហ ដែលហេរីធ្លាប់បានឃើញនៅក្នុងបន្ទប់ទឹករបស់ម៉ុននីង មីតថល។ ភ្លាមនោះ ហេរីដូចជាវង្វេងអស់ហើយថា តើវាអាចមកនៅទីនោះបានដោយរបៀបណា? ប៉ុន្តែនៅមានរឿងបន្ទាន់មួយទៀតដែលត្រូវដោះស្រាយ។

- លោកត្រូវតែជួយខ្ញុំ ថម- ហេរីនិយាយ ហើយលើកក្បាលជីននីឡើងម្តងទៀត - យើងត្រូវតែយកនាងចេញពីទីនេះ ព្រោះនៅទីនេះមានពស់មួយក្បាល។ ខ្ញុំមិនដឹងថាវានៅទីកន្លែងណាទេ ប៉ុន្តែវាអាចចេញមកបានគ្រប់ពេល។ សូមជួយខ្ញុំផង...

រីតដលមិនកម្រើកនោះទេ។ ហេរីព្យាយាមលើកជីននីបានពាក់កណ្តាលខ្លួន ហើយងាកមករើសចង្កឹះវេទមន្តរបស់វាម្តងទៀត។

ប៉ុន្តែចង្កឹះវេទមន្តរបស់វាបានបាត់ទៅហើយ។

- តើលោកមានឃើញ...?

ហេរីក្រឡេកមើលទៅលើ។ រីតដលនៅតែសម្លឹងមើលវា ហើយគាត់កំពុងតែកាន់ចង្កឹះវេទមន្តរបស់ហេរី នៅចន្លោះម្រាមដៃវែងៗរបស់គាត់។

- អរគុណ!- ហេរីនិយាយ ហើយព្រមទាំងលាដៃទៅទទួលវា។

ស្នាមញញឹមបានបញ្ចេញលើជ្រុងម្ខាងនៃបបូរមាត់របស់រីតដល។ គាត់នៅតែបន្តសម្លឹងទៅហេរី ហើយកាន់ចង្កឹះផេទមន្ត របស់វាដោយមិនបញ្ចេញសកម្មភាពអ្វីឡើយ។

- ស្តាប់ខ្ញុំសិន!- ហេរីនិយាយយ៉ាងលឿន ជើងរបស់វាត្រូវទេរទៅម្ខាងដោយសារតែទម្ងន់របស់ជីននី - យើងត្រូវតែទៅពេលនេះ។ ប្រសិនបើពស់នោះចេញមក...

- វានឹងមិនចេញមកទេ លុះត្រាតែមានគេហៅវាឲ្យចេញមក- រីតដលនិយាយយ៉ាងស្ងៀមស្ងាត់។

ហេរីបានផ្តេកខ្លួនជីននីទៅលើកម្រាលវិញ ព្រោះវាគ្មានសមត្ថភាពទប់នាងបានយូរទេ។

- តើលោកចង់បានន័យថាម៉េច?- ហេរីនិយាយ - ឲ្យចង្កឹះផេទមន្តមកខ្ញុំវិញ ខ្ញុំប្រហែលជាត្រូវការវា។

ស្នាមញញឹមរបស់រីតដលរីកកាន់តែធំ។

- ឯងនឹងមិនត្រូវការវានោះទេ- គាត់និយាយ។

ហេរីសម្លឹងមើលទៅគាត់។

- តើលោកចង់និយាយពីអ្វី? ខ្ញុំនឹងមិន...

- ខ្ញុំបានរង់ចាំពេលនេះជាយូរមកហើយ ហេរី ផោតធ័រ- រីតដលនិយាយ - រង់ចាំនូវឱកាសដើម្បីបានជួបឯង បាននិយាយជាមួយឯង។

- ឈប់សិន- ហេរីនិយាយដោយបាត់បង់ភាពអត់ធ្មត់ - ខ្ញុំគិតថា លោកមិនត្រូវចាប់ផ្តើមនិយាយពីវានៅពេលនេះទេ។ ពួកយើងកំពុងតែនៅក្នុងបន្ទប់សម្ងាត់។ យើងអាចនិយាយនៅពេលក្រោយទៀតបាន។

- យើងត្រូវតែនិយាយនៅពេលនេះ- រីតដលនិយាយដោយនៅតែញញឹមយ៉ាងច្បាស់ ហើយគាត់បានយកចង្កឹះផេទមន្តរបស់ហេរីដាក់ចូលទៅក្នុងហោប៉ៅ។

ហេរីសម្លឹងមើលទៅគាត់។ រឿងរ៉ាវដែលកើតឡើងទាំងអស់នេះដូចជាចម្លែកខ្លាំងណាស់។

- តើជីននីក្លាយទៅជាយ៉ាងនេះបានយ៉ាងដូចម្តេចទៅ?- ហេរីសួរយឺតៗ។

- នេះជាសំនួរគួរឲ្យចាប់អារម្មណ៍មួយ- រីតដលនិយាយយ៉ាងរីករាយ - ហើយក៏ជារឿងដ៏វែងឆ្ងាយមួយដែរ។ ខ្ញុំគិតថា ហេតុផលពិតប្រាកដដែលធ្វើឲ្យនាងក្លាយទៅជាបែបនេះ គឺដោយសារតែនាងបានបើកចំហបេះដូងរបស់នាង ហើយបានប្រាប់រឿងសម្ងាត់របស់នាងទាំងអស់ដល់ជនចម្លែកម្នាក់ ដែលនាងមើលមិនឃើញ។

- តើលោកកំពុងតែនិយាយពីអ្វីហ្នឹង?

- សៀវភៅកំណត់ហេតុ- រីតដលនិយាយ - ជាសៀវភៅកំណត់ហេតុរបស់ខ្ញុំ។ ជីននីបានសរសេរនៅក្នុងសៀវភៅនេះអស់រយៈពេលជាច្រើនខែមកហើយ។ នាងបានប្រាប់ខ្ញុំនូវរាល់ក្តីព្រួយបារម្ភដ៏គួរឲ្យអាណិត និងទុក្ខសោករបស់នាងដូចជា៖ តើបងប្រុសនាងស្តីឲ្យនាងយ៉ាងដូចម្តេចខ្លះ? តើនាងអាចមកសាលាបានជាមួយនឹងរ៉ូប និងសៀវភៅដែលនៅសល់ពីបងៗរបស់នាងបានយ៉ាងដូចម្តេច? ហើយតើ...- ភ្នែករបស់រីតដលបញ្ចេញពន្លឺភ្លែតៗ - តើនាងគិតថាហេរី ផោតធ័រដ៏ល្បីល្បាញអស្ចារ្យអាចនឹងចូលចិត្តនាងយ៉ាងដូចម្តេច?

រាល់ពេលដែលគាត់និយាយ ភ្នែករបស់គាត់មិនដែលដកចេញពីមុខរបស់ហេរីនោះទេ។ ស្ទើរតែពោរពេញទៅដោយភាពស្រេកឃ្លាននៅក្នុងកែវភ្នែករបស់គាត់។

## នាយានស្ទីតរីន

- វាជារឿងគួរឲ្យធុញទ្រាន់ខ្លាំងណាស់ ក្នុងការរង់ចាំស្ដាប់ពីបញ្ហាតូចតាច និងភ្លីភ្លើរបស់ក្មេងស្រីអាយុដប់មួយឆ្នាំម្នាក់នោះ- គាត់បន្លឺឡើង - ប៉ុន្តែខ្ញុំបានអត់ធ្មត់ ខ្ញុំបានសរសេរតបទៅនាងវិញ ខ្ញុំមានសមានចិត្ត ខ្ញុំមានចិត្តល្អ។ នាងស្រឡាញ់ខ្ញុំខ្លាំងណាស់។ នាងបានសរសេរថា៖ គ្មាននរណាម្នាក់យល់ចិត្តខ្ញុំដូចលោកនោះទេ ថម...។ ខ្ញុំរីករាយណាស់នៅពេលដែលខ្ញុំបានសៀវភៅកំណត់ហេតុនេះ ដើម្បីសរសេររាល់ការសម្ងាត់របស់ខ្ញុំនៅក្នុងនេះ...។ ខ្ញុំហាក់ដូចជាមានមិត្តម្នាក់ដែលខ្ញុំអាចដាក់ចូលក្នុងហោប៉ៅ ហើយយកតាមខ្លួនបាន...។

រីតដលសើចយ៉ាងខ្លាំង និងយ៉ាងសោះកក្រោះ ដែលមិនសក្តិសមនឹងគាត់ឡើយ។ ហារីងើយមើលទៅគាត់ ធ្វើឲ្យសក់របស់វាធ្លាក់ត្រឹមក។

- ប្រសិនបើខ្ញុំនិយាយដោយខ្លួនឯងនោះ ខ្ញុំអាចទាក់ទាញអារម្មណ៍អ្នកណាក៏បានឲ្យតែខ្ញុំត្រូវការ។ ដូចនេះ ជីននីបានប្រគល់វិញ្ញាណរបស់នាងមកខ្ញុំ ហើយវិញ្ញាណនោះគឺជាអ្វីដែលខ្ញុំត្រូវការ។ ខ្ញុំកាន់តែខ្លាំងឡើងៗ ដោយសារតែជម្រៅនៃភាពភ័យខ្លាចរបស់នាង និងរឿងសម្ងាត់របស់នាង។ ខ្ញុំកាន់តែមានកម្លាំងខ្លាំងក្លា ខ្លាំងជាងកញ្ញាវីស្លីទៅទៀត។ គឺកម្លាំងខ្លាំងគ្រប់គ្រាន់ដើម្បីចាប់ផ្ដើមប្រាប់រឿងសម្ងាត់ខ្លះរបស់ខ្ញុំដល់នាង ហើយដើម្បីចាប់ផ្ដើមយកវិញ្ញាណតូចៗខ្លះចូលទៅក្នុងខ្លួនរបស់...

- លោកកំពុងតែនិយាយពីអ្វី?- ហារីនិយាយ មាត់របស់វាកំពុងតែស្ងួតទៅៗ។

- ឯងនៅតែមិនទាន់យល់បានទៀតទេ ហារី ផោតធ័រ?- រីតដលនិយាយយ៉ាងសុភាព - ជីននី វីស្លីបានបើកបន្ទប់សម្ងាត់ នាងបានសម្លាប់មាន់គកទាំងនោះដោយច្របាច់កវា ហើយបានសរសេរពាក្យព្រមាននៅលើជញ្ជាំង។ នាងបានចាត់ឲ្យពស់នោះទៅសម្លាប់ពួក ឈាមកខ្វក់ ទាំងបួននាក់នោះ និងសត្វឆ្មាមួយក្បាល។

- ទេ- ហារីនិយាយខ្សឹបៗ។

- គឺពិតមែន- រីតដលនិយាយយ៉ាងស្ងៀមស្ងាត់ - ជាការពិតណាស់ ដំបូងនាងមិនបានដឹងថា នាងកំពុងតែធ្វើអ្វីនោះទេ។ វាសប្បាយខ្លាំងណាស់។ ខ្ញុំចង់ឲ្យឯងឃើញអ្វីដែលនាងបានសរសេរ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀតគឺ៖ *"ជូនចំពោះថម"* គាត់ចាប់ផ្ដើមសូត្រដោយសម្លឹងមើលទៅមុខភ័យខ្លាចរបស់ហារី - *"ខ្ញុំគិតថា ខ្ញុំបានបាត់បង់ការចងចាំទៅហើយ។ មានពាមមាន់ជាច្រើនបានជាប់នៅរ៉ូបរបស់ខ្ញុំ ហើយខ្ញុំមិនដឹងថាតើវាកើតឡើងបានយ៉ាងដូចម្ដេចនោះទេ។" "ជូនចំពោះថម ខ្ញុំមិនបានចាំថាតើខ្ញុំបានធ្វើអ្វីខ្លះនៅយប់ថ្ងៃបុណ្យហាឡូវីនទេ ប៉ុន្តែឆ្មាមួយក្បាលត្រូវបានវាយប្រហារ ហើយខ្លួនរបស់ខ្ញុំបានប្រលាក់នូវថ្នាំលាបពេញទាំងអស់។" "ជូនចំពោះថម ពើរស៊ីបានប្រាប់ខ្ញុំថា មុខរបស់ខ្ញុំស្លេកស្លាំងណាស់ ហើយមើលទៅខ្ញុំមិនមែនជាម្ចាស់លើខ្លួនឯងទៀតទេ។ ខ្ញុំគិតថា គាត់កំពុងសង្ស័យខ្ញុំហើយ..." "មានការវាយប្រហារមួយទៀតបានកើតឡើងក្នុងថ្ងៃនេះ។ ប៉ុន្តែខ្ញុំមិនដឹងថាតើពេលនោះ ខ្ញុំស្ថិតនៅទីណានោះទេ។ ថម! តើខ្ញុំត្រូវធ្វើអ្វីបន្តទៀត? ខ្ញុំគិតថា ខ្ញុំប្រាកដជាឆ្កួតមិនខាន...ខ្ញុំគិតថា ខ្ញុំជាមនុស្សតែម្នាក់គត់ដែលបានវាយប្រហារទៅលើពួកគេ ថម!..."*

កណ្ដាប់ដៃរបស់ហារីក្ដាប់យ៉ាងណែន ធ្វើឲ្យក្រចកដៃរបស់វាកប់ចូលបាតដៃ។

- ត្រូវការចំណាយពេលយូរណាស់សម្រាប់ក្មេងស្រី ជីននី ដ៏ល្ងង់ ដើម្បីបញ្ឈប់ការទុកចិត្តរបស់នាងទៅលើសៀវភៅកំណត់ហេតុរបស់នាង- រីតដលនិយាយ - ប៉ុន្តែនៅទីបញ្ចប់ នាងបានសង្ស័យ ហើយក៏ព្យាយាមបោះវាចោល គឺចោលនៅកន្លែងដែលឯងចូលទៅនោះ ហារី។ ហើយឯងបានឃើញវា។ ខ្ញុំមិនដឹងជាត្រេកអរយ៉ាងណានោះទេ។ តែក្នុងចំណោមមនុស្សបានរើសវា ឯងគឺជាមនុស្សដែលខ្ញុំចង់ជួបយ៉ាងអន្ទះសាបំផុត...

- ហេតុអ្វីបានជាលោកចង់ជួបខ្ញុំ?- ហេរីសួរ។ វាចាប់ផ្តើមផ្ទុះកំហឹង ហើយលំបាកណាស់ទំរាំតែវាអាចរក្សាសំឡេងឲ្យនៅស្មើគ្នាបាន។

- ឯងដឹងទេថា ជីននីបានប្រាប់អំពីរឿងទាំងអស់របស់ឯងដល់ខ្ញុំ ហេរី!- រីតដលនិយាយ - ប្រាប់ពីរឿងដ៏អស្ចារ្យ និងដ៏គួរឲ្យចាប់អារម្មណ៍របស់ឯង- ភ្នែករបស់គាត់សម្លឹងមើលទៅសម្លាកផ្លេកបន្ទោរលើថ្ងាសរបស់ហេរី ហើយមុខរបស់គាត់មើលទៅកាន់តែស្រេកឃ្លានឡើងៗ - ខ្ញុំគិតថា ខ្ញុំត្រូវតែស្វែងយល់បន្ថែមពីឯងឲ្យបានច្រើនជាងមុន ដោយការនិយាយផ្ទាល់ជាមួយឯង រីក៏ជួបឯងតែម្តងប្រសិនជាអាច។ ដូចនេះ ខ្ញុំក៏សម្រេចចិត្តបង្ហាញឯងអំពីរឿងរបស់មនុស្សភ្លីភ្លើម្នាក់ គឺ ហាហ្គ្រីដ ដើម្បីបង្កើនការទុកចិត្តរបស់ឯងមកលើខ្ញុំ។

- ហាហ្គ្រីដគឺជាមិត្តរបស់ខ្ញុំ- ហេរីនិយាយ សំឡេងវាឡើងញ័រ - ហើយលោកបានមួលបង្កាច់គាត់ មិនថាអញ្ចឹងរឺ? ខ្ញុំគិតថាលោកយល់ច្រលំ ប៉ុន្តែ...

រីតដលបានបញ្ចេញនូវសំណើចដ៏ខ្លាំងរបស់គាត់ម្តងទៀត។

- វាគ្រាន់តែជាអ្វី ដែលខ្ញុំធ្វើដើម្បីកំចាត់ហាហ្គ្រីដចោលតែប៉ុណ្ណោះ។ ឯងនៅចាំទឹកមុខរបស់កញ្ចាស់ អាម៉ានដូ ឌីផេត ទេ? ម្យ៉ាងទៀត ថម រីតដលដែលអភព្វតែឆ្លាត គ្មានឪពុកម្តាយតែ*ក្លាហាន*ណាស់ ជាអនុរក្សក្រុមសិស្សច្បងប្រចាំសាលា ជាសិស្សគម្រូ។ មិនត្រឹមតែប៉ុណ្ណោះ បានធ្វើឲ្យហាហ្គ្រីដធ្លាក់ចូលទៅក្នុងបញ្ហាជារៀងរាល់សប្តាហ៍ដូចជា៖ ព្យាយាមយកកូនចចកទៅដាក់នៅក្រោមគ្រែរបស់ហាហ្គ្រីដ លួចចូលទៅក្នុងព្រៃហាមឃាត់ដើម្បីធ្វើការប្រកួតវិជ្ជាសិល្ប៍។ ខ្ញុំពិតជាមានការភ្ញាក់ផ្អើលណាស់នៅពេលដែលគម្រោងការទាំងនោះដំណើរការយ៉ាងល្អ។ ខ្ញុំគិតថា ប្រាកដជាមាន*នរណាម្នាក់*ដឹងថា ហាហ្គ្រីដមិនមែនជាទាយាទនៃក្រុមស្លីតឺរីននោះទេ។ ខ្ញុំបានប្រើពេលវេលាទាំងប្រាំឆ្នាំរបស់ខ្ញុំ ដើម្បីស្វែងយល់អំពីអ្វីៗគ្រប់យ៉ាង ដែលខ្ញុំអាចធ្វើបានអំពីបន្ទប់សម្ងាត់នោះ ហើយក៏បានរកឃើញច្រកចូលសម្ងាត់...ធ្វើដូចជាហាហ្គ្រីដហ្នឹងឈ្លាសវៃ រឺមានកម្លាំងពិសេសអ្វីម្យ៉ាងអ៊ីចឹង!

- មានតែ គ្រូបង្រៀនវិជ្ជានិម្មិតកម្ម លោកដាំប៊ែលដ័រទេដែលមើលទៅដូចជាគិតថា ហាហ្គ្រីដគ្មានកំហុស។ គាត់បានបញ្ចុះបញ្ចូល ឌីផេត ឲ្យថែរក្សា ហាហ្គ្រីដ និងបង្ហាត់បង្រៀនគេឲ្យធ្វើជាឆ្មាំប្រមាញ់នៅកន្លែងសម្ងាត់មួយ។ ពិតណាស់ ដាំប៊ែលដ័រប្រហែលជាអាចប៉ាន់ស្មានត្រូវ។ ដាំប៊ែលដ័រមើលទៅមិនដែលចូលចិត្តខ្ញុំដូចគ្រូដទៃទេ...

- ខ្ញុំហ៊ានភ្នាល់ថា សាស្ត្រាចារ្យដាំប៊ែលដ័រយល់ឃើញត្រឹមត្រូវចំពោះលោកហើយ- ហេរីនិយាយដោយបញ្ចេញនូវសេចក្តីក្លាហាន។

- ក្រោយពីហាហ្គ្រីដត្រូវបានបណ្តេញចេញពីសាលាមក គាត់តាមឃ្លាំមើលខ្ញុំជាប់រហូត ពិតជាគួរឲ្យម៉ួម៉ៅណាស់- រីតដលនិយាយយ៉ាងធ្វេសប្រហែស - ខ្ញុំដឹងថា វាគ្មានសុវត្ថិភាពនោះទេ ក្នុងការបើកបន្ទប់សម្ងាត់ម្តងទៀត ល្ពឹកណាតែខ្ញុំនៅតែស្ថិតក្នុងសាលានេះ។ ប៉ុន្តែខ្ញុំនឹងមិនខ្ជះខ្ជាយពេលវេលាជាច្រើនឆ្នាំ ដែលខ្ញុំបានខិតខំស្វែងរកវានោះទេ។ ខ្ញុំបានសម្រេចចិត្ត លាក់ខ្លួននៅក្នុងសៀវភៅកំណត់ហេតុមួយ ហើយថែរក្សាអាយុដប់ប្រាំមួយឆ្នាំរបស់ខ្ញុំ ដើម្បីបញ្ជាឲ្យនរណាម្នាក់ដើរតាមគន្លងរបស់ខ្ញុំ ហើយបញ្ចប់កិច្ចការដ៏អស្ចារ្យរបស់សាឡាហ្សា ស្លីតឺរីន។

- ប៉ុន្តែលោកធ្វើមិនបានសម្រេចនោះទេ- ហេរីនិយាយដោយសំឡេងប្រកបដោយជ័យជំនះ - គ្មាននរណាម្នាក់ស្លាប់ទេ នៅពេលនេះ សូម្បីតែសត្វឆ្មាមួយក្បាលក៏ដោយ។ ក្នុងរយៈពេលពីរបីម៉ោងទៀត ដើម ម៉ានដ្រេក នឹងរួចរាល់ហើយមនុស្សដែលត្រូវបង្កក នឹងដឹងខ្លួនឡើងវិញហើយ។

- ខ្ញុំដូចជាមិនទាន់បានប្រាប់ឯងទេថា- រីតដលនិយាយយ៉ាងស្ងៀមស្ងាត់ - មនុស្សដែលត្រូវតាមសម្លាប់នោះមិនមែនជាបញ្ហាសម្រាប់ខ្ញុំនោះទេពេលនេះ។ ក្នុងរយៈពេលប៉ុន្មានខែនេះ គោលដៅថ្មីរបស់ខ្ញុំគឺ ឯង។

ហេរីសម្លឹងមើលទៅរីតដល។

- សាកគិតទៅមើល ថាតើខ្ញុំខឹងយ៉ាងណានៅពេលដែលសៀវភៅកំណត់ហេតុរបស់ខ្ញុំត្រូវបានបើកឡើង ដែលអ្នកសរសេរនោះមិនមែនជារូបឯង ផ្ទុយទៅវិញ គឺជីននី។ នាងបានឃើញឯងនៅជាមួយនឹងសៀវភៅកំណត់ហេតុនោះ។ នាងមានការភ័យខ្លាចណាស់។ ចុះបើឯងដឹងពីរបៀបប្រើប្រាស់សៀវភៅនេះ ហើយខ្ញុំបានប្រាប់នូវរាល់ការសម្ងាត់របស់នាងទៅឯង? ចុះបើអាក្រក់ជាងនេះទៅទៀត ខ្ញុំបានប្រាប់ឯងថា អ្នកណាជាអ្នកច្របាច់កមាន់គកទាំងនោះ? ដូចនេះ ក្មេងស្រីល្ងង់ម្នាក់នេះបានរង់ចាំរហូតទាល់តែសយនដ្ឋានរបស់ឯងស្ងាត់ ហើយនាងបានចូលទៅលួចយកវាមក។ ប៉ុន្តែខ្ញុំដឹងថាខ្ញុំត្រូវធ្វើអ្វីហើយ។ ខ្ញុំដឹងច្បាស់ណាស់ថា ឯងកំពុងតាមដានរកទាយាទស្លីធើរីន។ ដោយសារតែជីននីបានប្រាប់រឿងរបស់ឯងដល់ខ្ញុំ ខ្ញុំដឹងថា ទោះបីជាដល់ណាក៏ដោយ ក៏ឯងនៅតែប្តេជ្ញាដោះស្រាយអាថ៌កំបាំងនេះឲ្យទាល់តែបាន ជាពិសេសនៅពេលដែលមិត្តជិតស្និទ្ធិរបស់ឯងម្នាក់ត្រូវបានវាយប្រហារ។ ជីននីព្រមទាំងបានប្រាប់ខ្ញុំថា សាលទាំងមូលពោរពេញទៅដោយពាក្យចចាមអារ៉ាម ដោយសារតែឯងអាចនិយាយភាសាពស់បាន...

- ដូចនេះ ខ្ញុំក៏បញ្ជាឲ្យជីននីសរសេរពាក្យលាគ្នានៅលើជញ្ជាំង ហើយចុះមករង់ចាំឯងនៅទីនេះ។ នាងបានព្យាយាមរើបំរះព្យាយាមស្រែកដែលធ្វើឲ្យខ្ញុំធុញទ្រាន់ជាខ្លាំង។ ប៉ុន្តែនាងរស់មិនបានយូរទៀតទេ ដោយសារតែនាងបានដាក់ចិត្តដាក់កាយចូលទៅក្នុងសៀវភៅកំណត់ហេតុនេះច្រើនពេក ពោលគឺដាក់ចូលមកក្នុងខ្លួនខ្ញុំតែម្តង។ នៅទីបញ្ចប់ វាគ្រប់គ្រាន់ហើយសម្រាប់ខ្ញុំក្នុងការដកខ្លួនចេញពីសៀវភៅនោះ។ ខ្ញុំបានរង់ចាំឯងតាំងពីពេលដែលខ្ញុំបាននាំនាងមកដល់ទីនេះ។ ខ្ញុំដឹងថាឯងប្រាកដជាមក។ ខ្ញុំមានសំណួរច្រើនណាស់ ចង់សួរដល់ឯង ហេរី ផោតធ័រ។

- សំនួរអីទៅ?- ហេរីបន្លឺឡើងទាំងក្តៅក្រហាយ ហើយដៃរបស់វានៅតែក្តាប់យ៉ាងណែន។

- ល្អ- រីតដលនិយាយ ហើយញញឹមយ៉ាងរីករាយ - តើកូនង៉ែតម្នាក់ដែលគ្មានទេពកោសល្យអ្វីពិសេសបន្តិចសោះ អាចយកឈ្នះលើវេទគូដ៏អស្ចារ្យបំផុតយ៉ាងដូចម្តេចទៅ? តើឯងធ្វើដូចម្តេចទើបអាច រត់គេចបានដោយគ្មានរបួសអ្វីបន្តិចសោះក្រៅពីស្នាមសម្លាកមួយ ខណៈពេលដែលអានុភាពរបស់ ឡត វ៉ុលដឺម៉រ ត្រូវបានបំផ្លាញនោះ?

- ហេតុអ្វីបានជាលោកចាំបាច់ត្រូវខ្វល់ថា តើខ្ញុំអាចគេចរួចបានយ៉ាងដូចម្តេចនោះ?- ហេរីនិយាយយឺតៗ។- រឿងរបស់វ៉ុលដឺម៉រ យើងអាចនិយាយបន្ទាប់ពីរឿងរបស់លោកក៏បាន។

- វ៉ុលដឺម៉រ- រីតដលនិយាយយ៉ាងស្រទន់ - គឺជា អតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់ខ្ញុំ ហេរី ផោតធ័រ!

គាត់បានដកចង្កឹះវេទមន្តរបស់ហេរីពីក្នុងហោប៉ៅ ហើយចាប់ផ្តើមសរសេរអ្វីមួយនៅលើអាកាស គឺសរសេរអក្សរដែលចាំងពន្លឺព្រាតៗបីពាក្យៈ

## TOM MARVOLO RIDDLE

គាត់បានគ្រវីចង្កឹះវេទមន្តភ្លាមៗ ហើយអក្សរឈ្មោះរបស់គាត់បានផ្លាស់ប្តូរទីកន្លែងដោយខ្លួនឯងៈ

# ទាយាទស្លីតឺរីន

# I AM LORD VOLDEMORT

- ឯងឃើញទេ- គាត់និយាយខ្សឹបៗ - វាជាឈ្មោះរបស់ខ្ញុំ ដែលខ្ញុំបានប្រើរួចមកហើយនៅសាលាហុកវ៉ាត គឺប្រើតែជាមួយមិត្តស្និទ្ធិស្នាលរបស់ខ្ញុំតែប៉ុណ្ណោះ។ តើឯងគិតថា ខ្ញុំនឹងប្រើឈ្មោះដ៏កខ្វក់របស់ឪពុកដែលជាពួកលោកិយរហូតរឺ? តើខ្ញុំអាចនឹងប្រើឈ្មោះរបស់មនុស្សលោកិយធម្មតាម្នាក់ដែលឆ្កួត ហើយដែលបានបោះបង់ខ្ញុំចោលតាំងពីមុនពេលខ្ញុំកើត ដោយគ្រាន់តែគាត់ដឹងថាប្រពន្ធរបស់គាត់ជាវេទគូរឺ? ហើយតើខ្ញុំអាចជាប់ឈាមជ័រជាមួយសាឡាហ្សា ស្លីតឺរីនតាមរយៈខ្សែស្រឡាយខាងម្តាយបានយ៉ាងដូចម្តេច? អត់ទេ ហេរី! ខ្ញុំបានបង្កើតឈ្មោះថ្មីមួយទៀតដោយខ្លួនឯង។ ឈ្មោះដែលខ្ញុំដឹងថានឹងល្បីល្បាញនៅគ្រប់ទីកន្លែង ជាឈ្មោះដែលថ្ងៃណាមួយវេទគូគ្រប់គ្នានឹងខ្លាចរអាមិនហ៊ាននិយាយ  គឺនៅពេលដែលខ្ញុំក្លាយខ្លួនទៅជាវេទគូដ៏មហាស្ចារ្យបំផុតនៅលើពិភពលោក។

ខួរក្បាលរបស់ហេរីពេលនេះ ហាក់ដូចជាកំពុងតែកកស្ទះ គិតអ្វីលែងយល់អស់ហើយ។ វាសម្លឹងយ៉ាងយឺតៗទៅរីតដលពោលគឺសម្លឹងមើលទៅក្មេងប្រុសកំព្រីកំព្រាម្នាក់ដែលរស់នៅធំធាត់ឡើងដើម្បីសម្លាប់ឪពុកខ្លួនឯង និងមនុស្សជាច្រើនទៀត។ ទីបំផុត វាបានបង្ខំខ្លួនឯងឲ្យនិយាយ។

- លោកមិនមែនទេ- ហេរីនិយាយយឺតៗ សំឡេងដ៏ស្ងៀមស្ងាត់របស់វាពោរពេញទៅដោយភាពស្អប់ខ្ពើម។

- មិនមែនជាស្អី?- រីតដលបន្លឺឡើងភ្លាមៗ។

- គឺមិនមែនជាវេទគូដ៏អស្ចារ្យបំផុតនោះទេ- ហេរីនិយាយ ហើយដកដង្ហើមយ៉ាងញាប់ - សុំទោសផងទៅចុះ ដែលធ្វើឲ្យលោកខកបំណង ប៉ុន្តែវេទគូដែលធំបំផុតនៅលើពិភពលោកគឺលោក អាលប៊ូស ដាំប័លដ័រ។ អ្នកណាក៏និយាយអញ្ចឹងដែរ។ ទោះបីជាលោកខ្លាំងយ៉ាងណាក៏ដោយ ក៏លោកមិនហ៊ានមកឈ្លានពានសាលាហុកវ៉ាតដែរ។ សាស្ត្រាចារ្យដាំប័លដ័រ មើលដឹងតាំងពីនៅសាលាម៉្លេះ ថាលោកជាមនុស្សបែបណា ហើយគាត់នៅតែធ្វើឲ្យលោកភ័យខ្លាចជានិច្ច ទោះបីជាលោកលាក់ខ្លួននៅកន្លែងណាក៏ដោយ នាពេលសព្វថ្ងៃនេះ។

ស្នាមញញឹមបានត្រលប់មកលើផ្ទៃមុខរបស់រីតដលវិញ ជំនួសឲ្យមុខដ៏អាក្រក់មើលរបស់គាត់។

- ខ្ញុំប្រើតែ*ការចងចាំ*របស់ខ្ញុំ ក៏អាចបណ្តេញគាត់ឲ្យចេញពីសាលានេះបានបាត់ទៅហើយ!- គាត់ឧទានឡើងដោយសម្តែងការមិនពេញចិត្ត។

- វាមិនមែនដូចអ្វីដែលលោកគិតនោះទេ- ហេរីស៊កសម្តី។ វាកំពុងតែនិយាយព្រាវៗដើម្បីបន្លាចរីតដល ដោយព្យាយាមគិតថាអ្វីដែលគាត់និយាយមិនមែនជាការពិត។

រីតដលហៀបតែនឹងនិយាយទៅហើយ តែគាត់បានឈប់វិញភ្លាម។

សំឡេងភ្លេងបានបន្លឺចេញពីកន្លែងណាមួយ រីតដលបានបង្វិលខ្លួន សម្លឹងមើលជុំវិញបន្ទប់ដែលទទេស្អាតនោះ។ សំឡេងភ្លេងកាន់តែឮខ្លាំងទៅៗ។ វាគឺជាសំឡេងចម្លែកដែលគួរឲ្យព្រឺឆ្អឹងខ្នង ពោលជាសំលេងអាថ៌កំបាំងមួយ។ សំលេងនោះបានធ្វើឲ្យសក់របស់ហេរីបះឡើង ហើយធ្វើឲ្យវាមានអារម្មណ៍ថា បេះដូងរបស់វារីកធំជាងទំហំធម្មតាដល់ទៅពីរដងឯណោះ។ នៅពេលដែលសំលេងភ្លេងនោះបន្លឺកាន់តែគ្រលួចឡើងៗ រហូតធ្វើឲ្យហេរីព្រឺឆ្អឹងជំនីរ ស្រាប់តែមានអណ្តាតភ្លើងពណ៌ក្រហមមួយលេចឡើងនៅចុងកំពូលសសរ ដែលនៅជិតជាងគេបំផុត។

បក្សីពណ៌ក្រហមក្រម៉ៅដែលមានទំហំប៉ុនសត្វហង្សមួយបានលេចឡើង ហើយកំពុងតែបន្លឺសំលេងភ្លេងដ៏ចម្លែករបស់វា យ៉ាងគ្រលួច ហើយខ្លាំងរហូតឮដល់ពិតាន។ វាមានកន្ទុយពណ៌មាសភ្លឺចិញ្ចាច ដូចជាកន្ទុយក្ងោក ហើយមានក្រញាំពណ៌មាសភ្លឺចាំង ដែលកំពុងតែខ្ទាំកញ្ចប់ដ៏កញ្ចាស់មួយ។

បន្ទាប់មក បក្សីនោះបានហោះសំដៅមករកហេរី។ វាបានទម្លាក់របស់កញ្ចាស់មួយនៅជិតហេរី រួចទៅទំលើស្មារបស់ហេរី ធ្វើឲ្យហេរីទទួលអារម្មណ៍ថាធ្ងន់។ វាទម្លាក់ស្លាបចុះ ។ ហេរីក្រឡេកមើលទៅវា ហើយឃើញថាវាមានចំពុះពណ៌មាសវែង ហើយមុត និងភ្នែកពណ៌ខ្មៅភ្លឺថ្លា។

បក្សីនោះឈប់ច្រៀង។ វាសំកុកយ៉ាងស្ងៀមស្ងាត់ក្បែរថ្ពាល់របស់ហេរី ហើយសម្លឹងមើលទៅរីតដលយ៉ាងមាំ។

- គឺបក្សីហ្វេនីក (ហង្សភ្លើង)...- រីតដលនិយាយដោយសម្លឹងមើលទៅបក្សីនោះវិញ ដោយទឹកមុខវៃឆ្លាត និងស្ទាត់ជំនាញ។

- *ហ្វ៉ក់ស៍?*- ហេរីនិយាយខ្សឹបៗ ហើយស្ទាបក្រញាំពណ៌មាសរបស់បក្សីដែលកំពុងតែខ្ទាំស្មារបស់វាស្រាលៗ។

- ហើយនោះគឺ- រីតដលនិយាយ ហើយសង្កេតមើលទៅរបស់ចាស់ដែល ហ្វ៉ក់ស៍បានយកមក - វាគឺជាមួកសិល្ប៍ចាស់របស់សាលា។

មែន ពិតជាវាមែន។ មួកសិល្ប៍ស្ថិតនៅក្បែរជើងរបស់ហេរីដោយមានស្នាមដាច់ ស្នាមប៉ះ ហើយកខ្វក់ទៀត។

រីតដលចាប់ផ្ដើមសើចម្ដងទៀត។ គាត់សើចយ៉ាងខ្លាំងដែលធ្វើបន្ទប់ងងឹតនោះរង្គើ ហាក់បីដូចជាមានរីតដលដប់នាក់កំពុងតែសើចព្រមគ្នាអញ្ចឹង។

- នោះគឺជាអ្វីដែលដាំប៉លដ័របញ្ជូនមកឲ្យមនុស្សដែលគេទុកចិត្តរឺ? បក្សីមួយក្បាល និងមួកកញ្ចាស់មួយ។ តើពេលនេះឯងមានអារម្មណ៍ថាក្លាហានហើយរឺនៅ? តើឯងមានអារម្មណ៍ថាកក់ក្ដៅដែររឺទេ?

ហេរីមិនឆ្លើយតបវិញទេ។ ហេរីមិនដឹងថា អ្វីជាអ្វីនោះទេ ហើយក៏មិនដឹងថាគួរប្រើហ្វ៉ក់ស៍ រឺក៏មួកសិល្ប៍ដែរ ប៉ុន្តែវាមិននៅម្នាក់ឯងទៀតទេ។ វាបានរង់ចាំដោយប្រមូលផ្ដុំនូវសេចក្ដីក្លាហាន ទុកត្រៀមខ្លួននៅពេលដែលរីតដលឈប់សើច។

- និយាយសាច់ការវិញម្ដង ហេរី- រីតដលនិយាយដោយនៅតែបញ្ចេញស្នាមញញឹមយ៉ាងច្បាស់ - ពីរដងហើយ ដែលយើងបានជួបគ្នា គឺនៅក្នុងអតីតកាលរបស់ឯង និងនៅក្នុងអនាគតកាលរបស់ខ្ញុំ។ ពីរដងហើយ ខ្ញុំសម្លាប់ឯងមិនបានសម្រេច។ តើឯងធ្វើយ៉ាងណាទើបអាចនៅរស់បាន? ឯងត្រូវប្រាប់ខ្ញុំនូវគ្រប់រឿងរ៉ាវទាំងអស់។ ឯងនិយាយបានយូរប៉ុណ្ណា- គាត់និយាយបន្ថែមយ៉ាងស្រទន់ - ឯងក៏អាចនៅមានជីវិតបានយូរប៉ុណ្ណឹងដែរ។

ហេរីគិតយ៉ាងលឿន ហើយថ្លឹងថ្លែងពីឱកាសរបស់វា។ រីតដលមានចង្កឹះវេទមន្ត។ ចំនែកវា មានហ្វ៉ក់ស៍ និងមួកសិល្ប៍ ដែលសុទ្ធតែមិនសូវជាមានប្រយោជន៍ក្នុងការប្រយុទ្ធតទល់គ្នាប៉ុន្មានទេ។ រីតដលឈរនៅទីនោះកាន់តែយូរ ជីវិតរបស់ជីននីកាន់តែស្ថិតក្នុងសភាពគ្រោះថ្នាក់។ ក្នុងពេលនោះដែរ ហេរីកត់សម្គាល់ភ្លាមថា ទម្រង់ខ្លួនរបស់រីតដលកាន់តែច្បាស់ឡើងៗ ហើយមាំទាំទៀត។ ប្រសិនបើវាត្រូវប្រយុទ្ធគ្នាជាមួយរីតដល វាចង់ប្រយុទ្ធគ្នាក្នុងពេលនេះតែម្ដង ប្រសើរជាងការអូសបន្លាយវេលា។

- គ្មាននរណាម្នាក់ដឹងទេ ថាហេតុអ្វីបានជាលោកបាត់បង់ថាមពលរបស់លោកនៅពេលដែលលោកចង់សម្លាប់ខ្ញុំ- ហេរីនិយាយយ៉ាងទាន់ហន់ - ខ្ញុំក៏មិនដឹងដែរ។ ប៉ុន្តែខ្ញុំដឹងថា ហេតុអ្វីបានជាលោកមិនអាចសម្លាប់ខ្ញុំបាន គឺដោយសារតែម្ដាយរបស់ខ្ញុំបានលះបង់ជីវិតរបស់គាត់ដើម្បីជួយខ្ញុំ គឺម្ដាយដែលមានដើមកំនើតជាពួកលោកិយ- វានិយាយបន្ថែម ទាំងញ័រខ្លួនដោយសារតែខំប្រឹងទប់កំហឹងរបស់វា - គាត់បានរារាំងលោកកុំឲ្យសម្លាប់ខ្ញុំ។ ខ្ញុំបានឃើញមុខមាត់ពិតរបស់លោកហើយ កាលពីឆ្នាំមុន។ សុខ

ភាពរបស់លោកទ្រុឌទ្រោមណាស់ ចង់រស់ក៏មិនបានចង់ស្លាប់ក៏មិនកើត។ នេះហើយគឺជាលទ្ធផលនៃការស្រេកឃ្លានថាមពលរបស់លោក។ លោករស់នៅដោយលាក់ខ្លួន។ លោកមានមុខមាត់អាក្រក់មើល ហើយលោកឆ្កួត!

មុខរបស់រីតដលឡើងជ្រួញ។ ក្រោយមក គាត់បានបង្ខំខ្លួនឯងឲ្យបញ្ចេញនូវស្នាមញញឹមដ៏អាក្រក់មួយ។

- ដូចនេះ ម្តាយរបស់ឯងស្លាប់ដើម្បីតែជួយឯង។ មែន នេះគឺជាថាមពលប្រឆាំងដ៏ខ្លាំងក្លាមួយ។ ខ្ញុំយល់ហើយពេលនេះ។ គ្មានអ្វីពិសេសសោះ អំពីឯង។ ខ្ញុំពិតជាឆ្ងល់ណាស់ ឯងដឹងទេ ដោយសារតែភាពដូចគ្នាយ៉ាងចម្លែករបស់យើងទាំងពីរ។ ប្រសិនបើឯងបានកត់សម្គាល់នោះ ឯងនឹងដឹងថា ពួកយើងទាំងពីរជាក្មេងកំព្រា មានឈាមជំរពាក់កណ្តាល និងត្រូវបានចិញ្ចឹមដោយពួកលោកិយដូចគ្នា។ ប្រហែលយើងជាមនុស្សតែពីរនាក់គត់ដែលចេះនិយាយភាសាពស់នៅក្នុងសាលានេះក្រៅពី លោកស្លីគីរីនដ៏អស្ចារ្យ។ យើងថែមទាំងមានរូបរាងស្រដៀងគ្នាទៀតផង...ប៉ុន្តែទោះជាយ៉ាងណា វាគ្រាន់តែជាសំណាងរបស់ឯងប៉ុណ្ណោះ ដែលអាចគេចផុតពីការតាមសម្លាប់របស់ខ្ញុំ។ បានហើយ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ។

ហេរីឈរយ៉ាងតឹងតែងរង់ចាំឲ្យរីតដលលើកចង្កឹះផេទមន្តរបស់គាត់។ ប៉ុន្តែស្នាមញញឹមរបស់គាត់បានរីកឡើងម្តងទៀត។

- ពេលនេះ ខ្ញុំនឹងបង្រៀនមេរៀនដ៏តូចមួយដល់ឯង។ ចាំប្រៀបធៀបអំពីឥទ្ធិពលរបស់ឡត វ៉ុលដឺម៉រដែលជាទាយាទរបស់សាឡាហ្សា ស្លីគីរីន និងឥទ្ធិពលរបស់ហេរី ផោតធ័រដ៏ល្បីល្បាញ ព្រមទាំងអាវុធដ៏ល្អបំផុតដែលដាំប័លដ័របានផ្តល់ឲ្យគេ។

គាត់សម្លឹងមើលហ្វ៉ក់សេស និងមួកសិល្ប៍យ៉ាងរីករាយ ហើយដើរចេញទៅ។ សេចក្តីភ័យខ្លាចរបស់ហេរី បានសាយភាយដល់ជើងដែលស្ពឹកស្រពន់របស់វា។ ហេរីមើលទៅរីតដលដែលឈប់នៅចន្លោះសសរពីរខ្ពស់ និងសម្លឹងមើលទៅមុខដែលធ្វើអំពីថ្មរបស់ស្លីគីរីន ដែលនៅខ្ពស់ជាងគាត់ក្នុងសភាពងងឹតស្លុងៗ។ រីតដលបើកមាត់របស់គាត់ចំហធំៗ ហើយបន្លឺសូរតិចៗ ប៉ុន្តែហេរីយល់ពីអ្វីដែលគាត់កំពុងតែនិយាយ។

- សូមនិយាយមកកាន់ខ្ញុំមក ស្លីគីរីន មនុស្សដ៏អស្ចារ្យបំផុតក្នុងចំនោមមនុស្សពូកែទាំងបួនរូបរបស់សាលាហុកវ៉ាត។

ហេរីដើរទៅកៀន ហើយសម្លឹងមើលទៅរូបសំណាក ចំនែកហ្វ៉ក់សេសកំពុងតែយោលខ្លួននៅលើស្មារបស់វា។

មុខដ៏ធំសំបើមរបស់ស្លីគីរីនកំពុងតែកំរើក។ ហេរីបានឃើញមាត់នៃរូបសំណាកនោះកំពុងតែបើកធំឡើងៗ បង្កើតបានជារូងពណ៌ខ្មៅដ៏ធំមួយ។

ហេរីបានដើរថយក្រោយ ទាល់តែបុកជញ្ជាំងនៃបន្ទប់នោះ ហើយនៅពេលដែលវាបានបិទភ្នែកវាយ៉ាងជិត វាមានអារម្មណ៍ថាថ្ពាល់របស់វា ត្រូវបានត្រដុសដោយស្លាបរបស់ហ្វ៉ក់សេស ខណៈពេលដែលវាជៀបនឹងហោះឡើង។ ហេរីចង់ស្រែកថា "កុំទៅចោលខ្ញុំ" ប៉ុន្តែ តើសត្វបក្សីមួយក្បាលអាចប្រឆាំងតទល់នឹងស្តេចពស់បានយ៉ាងដូចម្តេចទៅ?

មានអ្វីមួយធំបានប៉ះទៅនឹងកំរាលនៃបន្ទប់សម្ងាត់នោះ។ ហេរីមានអារម្មណ៍ថាវាកំពុងតែញ័រ។ ហេរីដឹងហើយថាមានអ្វីកំពុងតែកើតឡើង។ ហេរីអាចដឹងថាវាជាអ្វី ហើយអាចទាំងមើលឃើញនូវសត្វពស់ដ៏ធំមួយកំពុងតែពន្លាខ្លួនចេញពីមាត់របស់ស្លីគីរីន។ បន្ទាប់មក វាបានឮសំឡេងខ្សឹបៗរបស់រីតដល - សម្លាប់វាទៅ-។

សត្វពស់ធ្វើចលនាសំដៅទៅរកហេរី។ វាអាចឮសំឡេងខ្លួនដ៏ធំរបស់ពស់នោះលូនឃ្លេងឃ្លោងកាត់កំរាលដែលពោរពេញទៅដោយធូលី។ ហេរីចាប់ផ្តើមរត់ទាំងងងឹតងងល់ និងបិទភ្នែកជិត ហើយដៃរបស់វាលោតសន្ទឹងទៅមុខស្រវាស្រវារកផ្លូវ។ រីតដលចាប់ផ្តើមសើច...

ហេរីបានជំពប់ជើងដួល។ វាដួលយ៉ាងខ្លាំងទៅលើកម្រាលថ្ម ហើយចេញឈាម។ វាស្តាប់ដឹងថា សត្វពស់នោះនៅមិនដល់មួយម៉ែតពីខ្លួនវាឡើយ។

មានសំឡេងផ្ទុះយ៉ាងខ្លាំងក្លាមួយបន្លឺឡើង គឺនៅចំពីលើហេរីតែម្តង។ បន្ទាប់មក មានអ្វីមួយវាត់ហេរីយ៉ាងខ្លាំង ដែលធ្វើឲ្យវាត្រូវខ្ទាតទៅបុកជញ្ជាំងយ៉ាងដំណំ។ ខណៈពេលដែលហេរីកំពុងតែរង់ចាំឲ្យចង្កូមរបស់ពស់នោះចាក់ចូលទៅក្នុងខ្លួនរបស់វា វាបានឮសំឡេងបែកបាក់អ្វីម្យ៉ាង។ មានអ្វីមួយកំពុងតែប្រវាយប្រតប់យ៉ាងសំបើមនៅលើសសរ។

ហេរីទប់ចិត្តខ្លួនឯងមិនបាន ក៏បើកភ្នែកព្រឹមៗ សម្លឹងមើលថាមានអ្វីកំពុងតែកើតឡើង។

សត្វពស់ដ៏ធំ មានសំបុរបៃតងភ្លឺឆើត ហើយសំបូរពិស និងមាន កំរាស់ខ្លួនក្រាស់ដូចដើមសែន បានងើបឡើងទៅលើអាកាស ហើយក្បាលដ៏ធំរបស់វាកំពុងតែឆចុះឡើងដូចជាអ្នកប្រមឹកនៅចន្លោះសសរពីរ។ នៅពេលដែលហេរីត្រៀមខ្លួននឹងអាលបិទភ្នែករបស់វា ក្រែងលោពស់នោះបែរមក ស្រាប់តែវាយល់ពីមូលហេតុដែលធ្វើឲ្យពស់នោះមានអារម្មណ៍មិននឹងនរ។

ហ្វ៍វក់បែសកំពុងតែហោះយ៉ាងខ្ពស់ជុំវិញក្បាលរបស់ពស់នោះ ឯពស់នោះក៏ត្របាក់យ៉ាងកំរោលទៅលើហ្វ៍វក់បែសវិញនឹងចង្កូមដ៏វែងស្តើងដូចដាវ។

ហ្វ៍វក់បែសហោះដាំក្បាលចុះលឿនស្លេវ។ ចំពុះវែងពណ៌មាសរបស់វាជាអ្នកនាំមុខ។ ភ្លាមនោះឈាមពណ៌ខ្មៅបានធ្លាក់មកសាចពេញកំរាល។ កន្ទុយរបស់សត្វពស់បានគ្រវីគ្រវាត់ វិះនឹងត្រូវហេរី។ មុនពេលដែលហេរីបិទភ្នែកទាន់ ពស់នោះបានបែរមក។ ហេរីមើលតម្រង់ទៅភ្នែករបស់ពស់កំណាចនោះ ហើយបានឃើញថាភ្នែកពណ៌លឿងរបស់វា ត្រូវបានចោះទម្លុះដោយសត្វបក្សីបាត់ទៅហើយ។ ឈាមបានស្រក់ពេញកម្រាលចំនែកសត្វពស់នោះកំពុងតែស្ថិតក្នុងសេចក្តីឈឺចាប់។

- ទេ- ហេរីបានឮសម្រែករបស់រីតដល - ចេញពីបក្សីនោះទៅ! ចេញពីបក្សីនោះទៅ! ក្មេងប្រុសនោះគឺនៅពីក្រោយឯង។ ឯងនៅតែអាចហិតក្លិនរបស់វាបាន។ សម្លាប់វាទៅ!

ពស់នោះបានយោលយោកខ្លួនដោយភាន់ភាំង ប៉ុន្តែមើលទៅនៅតែសាហាវ។ ហ្វ៍វក់បែសនៅតែហោះជុំវិញក្បាលរបស់ពស់នោះព្រមទាំងបន្លឺនូវចម្រៀងគួរឲ្យព្រឺក្បាល ហើយបានឆូតកន្លែងនេះខ្លះ កន្លែងនោះខ្លះនៅលើច្រមុះដែលពោរពេញទៅដោយស្រកា ខណៈពេលដែលឈាមកំពុងតែហូរចេញពីភ្នែកមានរបួសយ៉ាងធ្ងន់ធ្ងររបស់វា។

- ជួយខ្ញុំផង! ជួយខ្ញុំផង!- ហេរីនិយាយខ្សាវៗយ៉ាងឆ្កួតលីលា - អ្នកណាក៏បានដែរ!

កន្ទុយរបស់ពស់នោះបានធ្វើចលនាយ៉ាងរហ័សកាត់កំរាលម្តងទៀត។ ហេរីបានអោនក្បាលដើម្បីគេច។ មានអ្វីម្យ៉ាងទន់បានប៉ះនឹងមុខរបស់វា។

សត្វពស់បានចោលមួកសិល្ប៍ចូលទៅក្នុងដៃរបស់ហេរី។ ហេរីបានខ្ទាំវាទុក។ វានៅសល់តែមួកសិល្ប៍មួយនេះទៀតទេជាអាវុធ គឺជាសំណាងតែមួយគត់របស់វា។ ហេរីបានពាក់មួកនោះ ហើយបានផ្តួលខ្លួនយ៉ាងរាបស្មើទៅលើកំរាល ខណៈដែលពស់នោះបានគ្រវាត់កន្ទុយមកលើវាម្តងទៀត។

*- ជួយខ្ញុំផង! ជួយខ្ញុំផង!-* ហេរីគិត។ ភ្នែករបស់វាត្រូវបាំងនៅពីក្រោមមួកយ៉ាងតឹង - *សូមជួយខ្ញុំផង!*

គ្មានសំឡេងឆ្លើយមកវិញទេ។ ផ្ទុយទៅវិញមួកនោះបានរួញចុះ ហាក់បីដូចជាមានដៃដែលមើលមិនឃើញមួយកំពុងរឹតវាយ៉ាងតឹង។

មានអ្វីមួយរឹងហើយធ្ងន់បានទង្គិចចំពីលើក្បាលរបស់វា ស្ទើរតែរុញក្បាលរបស់វាចេញពីមួកនោះទៅហើយ។ រូបផ្កាយជាច្រើនបានស្ថិតនៅពីមុខវា។ ហេរីបានទាញមួកចេញ ហើយវាទទួលអារម្មណ៍ថា មានអ្វីមួយរឹង ហើយវែងស្ថិតនៅក្នុងនោះ។

ដាវដែលធ្វើអំពីប្រាក់ដ៏ភ្លឺចែងចាំងមួយបានលេចឡើងនៅក្នុងមួក។ ដងដាវភ្លឺចិញ្ចាច ដោយសារត្បូងទទឹមមានទំហំប៉ុនស៊ុតសត្វ។

*- សម្លាប់ក្មេងនោះទៅ! កុំរវល់នឹងបក្សីនោះ។ ក្មេងនោះនៅពីក្រោយឯង ហិតក្លិនវាទៅ!*

ហេរីបានប្រុងប្រៀបខ្លួនរួចរាល់ហើយ។ ក្បាលរបស់ពស់នោះពេលនេះកំពុងសម្លឹងចុះក្រោម ខ្លួនរបស់វាពន់ពែនគ្រប់ទីកន្លែង។ វាបានវាយបំបាក់សសរពេលដែលវាបែរក្រោយដើម្បីសម្លឹងរកមើលហេរី។ ហេរីអាចមើលឃើញភ្នែកដ៏ធំសម្បើមដែលមានសុទ្ធតែឈាម ព្រមទាំងអាចមើលឃើញមាត់ដែលលាតសន្ធឹងយ៉ាងទូលាយ ពោលគឺទូលាយល្មមដែលអាចលេបខ្លួនវាទាំងមូលបាន នឹងចង្កូមវែងៗដូចដាវស្តើង ដ៏ភ្លឺរលោង និងមានពិស...

ពស់នោះបានវាយប្រហារទាំងខ្វាក់ភ្នែក។ ហេរីគេចទាន់ដែលធ្វើឲ្យពស់នោះវាយត្រូវជញ្ជាំងបន្ទប់។ វាវាយប្រហារម្តងទៀត ហើយអណ្តាតដែលព្រែកជាពីររបស់វាបានវាយចំចំហៀងខ្លួនរបស់ហេរី។ ហេរីបានលើកដាវដោយដៃទាំងពីររបស់វា។

ពស់នោះបានវាយប្រហារម្តងទៀត ហើយលើកនេះ វាបានតម្រង់ចំគោលដៅរបស់វា។ ហេរីបានប្រមូលកម្លាំងទាំងអស់ទៅលើដាវ ហើយបានចាក់ទៅភ្នែកខាងលើនៃមាត់របស់ពស់នោះ។

ប៉ុន្តែនៅពេលដែលឈាមក្តៅឧណ្ហៗបានទទឹកជោកពេញដៃរបស់វា ហេរីមានអារម្មណ៍ថាការឈឺចាប់ដ៏គួរឲ្យភ័យខ្លាចមួយបានកើតឡើងនៅលើកែងដៃរបស់វា។ ចង្កូមដ៏វែងមួយពោរពេញទៅដោយពិសបានកប់យ៉ាងជ្រៅទៅក្នុងដៃរបស់វា ហើយចង្កូមនោះបានបែកជាបំនែកតូចៗនៅពេលដែលពស់នោះដួលក្រញង់ខ្លួនលើកម្រាលឥដ្ឋ។

ហេរីទន់ខ្លួនចុះប្រើបផ្អែកនឹងជញ្ជាំង។ វាក្តាប់ចង្កូមដែលកំពុងតែសាយភាយជាតិពិសទៅក្នុងខ្លួនរបស់វាយ៉ាងជាប់ ហើយដកចេញពីដៃវា។ ប៉ុន្តែវាដឹងថាយឺតពេលទៅហើយ។ ការឈឺចាប់កំពុងតែសាយភាយបន្តិចម្តងៗពីមុខរបួសរបស់វា។ ខណៈពេលដែលវាទម្លាក់ចង្កូមនោះចុះ ហើយបែរទៅមើលឈាមរបស់វា ដែលកំពុងជ្រាបចូលទៅក្នុងអាវ ភ្នែករបស់វាចាប់ផ្តើមស្រពេចស្រពិលជាបណ្តើរៗហើយ។ វាមើលឃើញបន្ទប់សម្ងាត់នោះ ហាក់ដូចជាកំពុងតែវិលចុះឡើង និងចាប់ផ្តើមប្រែពណ៌។

ដុំពណ៌ក្រហមឆ្អៅមួយបានហោះកាត់មុខវិញ ហើយហេរីបានឮសំឡេងក្រញាំជើងទង្គិចគ្នាយ៉ាងស្រទន់នៅក្បែរវា។

- ហ្វ៊ូវយែស- ហេរីនិយាយទាំងស្អកក - ឯងអស្ចារ្យណាស់ ហ្វ៊ូវយែស។ វាទទួលអារម្មណ៍ថា បក្សីនោះបានអោនក្បាលដ៏ស្អាតរបស់វា ទៅលើកន្លែងដែលចង្កូមរបស់ពស់នោះបានចាក់ចូលទៅ។

វាបានឮសំឡេងខ្ទរនៃស្នូរជើង ហើយបន្ទាប់មក ស្រមោលពណ៌ខ្មៅមួយបានមកឈប់នៅពីមុខវា។

- ឯងជិតស្លាប់ហើយ ហេរី ផោតធ័រ- សំឡេងរបស់រីតដលបន្លឺពីលើវា - សូម្បីតែបក្សីរបស់ដាំប័លដ័រក៏ដឹងដែរ។ តើឯងមានឃើញវាកំពុងតែធ្វើអ្វីទេ ផោតធ័រ? វាកំពុងតែយំ។

ហេរីព្រិចភ្នែក។ ក្បាលរបស់ហ្វ៊ូវយែសម្តងលៀនចេញពីក្រសែភ្នែកវា ម្តងចូលមកវិញ។ ទឹកភ្នែកខាប់ដូចគុជខ្យងកំពុងស្រក់ចុះពីលើរោមដ៏រលោងរបស់វា។

- ខ្ញុំនឹងអង្គុយនៅទីនេះ ចាំមើលឯងស្លាប់ ហេរី ផោតធ័រ។ ចំណាយវិនាទីចុងក្រោយនៃជីវិតរបស់ឯងឲ្យបានស្រួលចុះ ខ្ញុំមិនប្រញាប់ទេ។

ហេរីមានអារម្មណ៍ថាងងុយគេង។ គ្រប់យ៉ាងដែលនៅជុំវិញខ្លួនវា ដូចជាកំពុងតែវិល។

- នេះគឺជាចុងបញ្ចប់របស់ឯងហើយ ហេរី ផោតធ័រដ៏ល្បីល្បាញ- សំឡេងដ៏សោះអង្គើយរបស់រីតដលបន្លឺឡើង - ហើយឯងត្រូវនៅម្នាក់ឯងក្នុងបន្ទប់សម្ងាត់នេះ ត្រូវបានមិត្តភក្តិបោះបង់ចោល ហើយទីបំផុតត្រូវស្លាប់ក្នុងដៃរបស់មេវេទគូអាគមងងឹតដែលវាខំប្រឹងប្រែងប្រយុទ្ធតតាំងទាំងល្ងង់ខ្លៅ។ ឯងនឹងអាចទៅរស់នៅជាមួយម្ដាយដ៏ថោកទាបរបស់ឯងក្នុងពេលឆាប់ៗនេះហើយ ហេរី។ ម្ដាយរបស់ឯងបានទិញអាយុដប់ពីរឆ្នាំឲ្យទៅឯង...ប៉ុន្តែនៅពេលនេះ ឡតូ វ៉ុលដឺម៉រ នឹងយកពីឯងទៅវិញ ដូចដែលឯងដឹងស្រាប់ហើយថាគាត់ប្រាកដជាធ្វើបាន។

ចំពោះហេរី ប្រសិនបើស្លាប់មែននោះ ក៏មិនសូវជាអាក្រក់ណាស់ណានោះទេ។ សូម្បីតែការឈឺចាប់ក៏បានចាកចេញពីខ្លួនវាដែរ។

ប៉ុន្តែនេះគឺសេចក្ដីស្លាប់រឺ? ផ្ទុយពីការឈានទៅរកភាពខ្មៅងងឹត បន្ទប់នោះហាក់វិលមករកសភាពដើមវិញហើយ។ ហេរីគ្រវីក្បាលតិចៗ ហើយឃើញហ្វ៊រឃែសនៅតែឱនក្បាលរបស់វាទៅលើដៃរបស់វាដដែល។ តំនក់ទឹកភ្នែកដូចគុជខ្យងកំពុងបញ្ចេញពន្លឺនៅជុំវិញរបួស ប៉ុន្តែគ្មានរបួសទៀតទេ។

- ចេញឲ្យឆ្ងាយទៅ បក្សីចង្រៃ- សំឡេងរបស់រីតដលបន្លឺឡើងភ្លាមៗ - ចេញឲ្យឆ្ងាយពីវាទៅ ខ្ញុំនិយាយថា ចេញភ្លាមទៅ!

ហេរីងើបក្បាលឡើង។ រីតដលកំពុងតែលើកចង្កឹះវេទមន្តរបស់ហេរីចង្អុលទៅហ្វ៊រឃែស។ មានសំឡេងខ្លាំងមួយដូចសំឡេងកាំភ្លើង បានផ្ទុះឡើង ហើយហ្វ៊រឃែសបានហោះឡើងម្ដងទៀត ក្នុងចលនាយ៉ាងរហ័ស ឃើញតែពណ៌មាស និងពណ៌ក្រហមឆ្អៅ។

- ទឹកភ្នែករបស់បក្សីនេះ- រីតដលនិយាយយឺតៗ ហើយសម្លឹងមើលដៃហេរី - ពិតណាស់...កម្លាំងព្យាបាល...ខ្ញុំភ្លេចឲ្យឈឹង!

គាត់សម្លឹងមើលមុខហេរី - ប៉ុន្តែគ្មានអ្វីខុសគ្នានោះទេ។ តាមពិត ខ្ញុំក៏ចង់បានរបៀបនេះដែរ។ មានតែឯង និងខ្ញុំទេ ហេរី ផោតធ័រ...គឺឯង និងខ្ញុំតែប៉ុណ្ណោះ...

គាត់បានលើកចង្កឹះវេទមន្តឡើង។

មួយសន្ទុះក្រោយមក ហ្វ៊រឃែសបានហោះសំកាំងនៅលើអាកាស ហើយបានទម្លាក់អ្វីមួយពីលើភ្លៅរបស់ហេរី៖ *គឺសៀវភៅកំណត់ហេតុ។*

មួយស្របក់ក្រោយមក ហេរី និងរីតដលទាំងពីរនាក់ ដែលកំពុងតែលើកចង្កឹះវេទមន្តឡើង សុទ្ធតែសម្លឹងមើលសៀវភៅនោះមិនដាក់ភ្នែក។ បន្ទាប់មក ដោយមិនគិតគូរ រឺពិចារណាអ្វីច្រើន ហាក់ដូចជាវាចង់ធ្វើរឿងនេះតាំងពីណាពីណីមកហើយអញ្ចឹង ហេរីស្រាប់តែចាប់យកចង្កូមពស់ដែលនៅលើកម្រាលឥដ្ឋក្បែរខ្លួនវាមក ហើយតំរង់ឲ្យចំកន្លែងដែលជាបេះដូងរបស់សៀវភៅនោះ។

មានសម្រែកដ៏គ្រលួចគួរឲ្យរន្ធត់មួយបានបន្លឺឡើង។ ទឹកពណ៌ខ្មៅបានបាញ់ចេញពីសៀវភៅកំណត់ហេតុហូរដូចកំអែភ្នំភ្លើង ប្រឡាក់ពេញដៃរបស់ហេរី ហើយរាលដាលពេញកំរាល។ រីតដលកំពុងតែរមៀលចុះឡើងដោយស្រែកខ្លាំងៗ ហើយបន្ទាប់មក...

## ធាយ៉ាធស្ទីតីរ៉ែន

គាត់ក៏រលាយបាត់ខ្លួនទៅ។ ចង្កឹះវេទមន្តរបស់ហេរីបានធ្លាក់ចុះដោយបន្លឺសំឡេងទង្គិច ហើយភាពស្ងប់ស្ងាត់បានកើតឡើង។ ស្ងៀមស្ងាត់ទាំងអស់លើកលែងតែសំឡេងស្រក់យ៉ាងថេររបស់ទឹកពណ៌ខ្មៅ ដែលនៅតែហូរចេញពីសៀវភៅកំណត់ហេតុនោះដដែល។ ពិសរបស់ពស់បានបំផ្លាញសៀវភៅនោះឲ្យមានប្រហោងមួយដែលអាចអោយទឹកខ្មៅនោះហូរចេញបាន។

បន្ទាប់ពីគ្រវីក្បាលរួច ហេរីបានក្រោកឡើង។ ក្បាលរបស់វាកំពុងតែវិល ហាក់បីដូចជាវាទើបតែបានធ្វើដំណើរអស់ជាច្រើនគីឡូម៉ែតដោយប្រើម្សៅភ្លូ អញ្ចឹង។ វាបានរើសមួកសិល្ប៍ និងចង្កឹះវេទមន្តរបស់វាព្រមគ្នាយឺតៗ ហើយទាញយកដាវដ៏ភ្លឺចិញ្ចាចពីលើមាត់របស់ពស់នោះមួយទំហឹងដៃ។

សំឡេងតិចៗបានបន្លឺឡើងនៅផ្នែកខាងមុខនៃបន្ទប់។ ជីននីកំពុងតែកម្រើក។ នៅពេលដែលហេរីធ្វើដំណើរយ៉ាងប្រញាប់ទៅរកនាង ជីននីបានក្រោកអង្គុយ។ ភ្នែកស្រវាំងរបស់នាងចាប់ផ្តើមមើលទៅខ្លួនដ៏ធំមហិមារបស់ពស់ដែលបានងាប់។ បន្ទាប់ពីនេះ បានមើលទៅហេរី គឺមើលទៅរ៉ូបដែលទទឹកជោកដោយឈាម ហើយមើលទៅសៀវភៅកំណត់ហេតុនៅក្នុងដៃហេរី។ នាងដកដង្ហើមធំញ័រៗ ហើយទឹកភ្នែកចាប់ផ្តើមហូរចុះពីភ្នែករបស់នាង។

- ហេរី ... ហេរី ... ខ្ញុំព្យាយាមប្រាប់បងនៅពេល ... ពេលអាហារពេលព្រឹកដែរ ... ប៉ុន្តែខ្ញុំ ... ខ្ញុំមិនអាចនិយាយវានៅចំពោះមុខពៀរស៊ីបានទេ។ គឺខ្ញុំ...ដែលបានធ្វើរឿងទាំងនោះ ប៉ុន្តែខ្ញុំ...ខ្ញុំបានស្បថថា ខ្ញុំគ្មានបំណងទេ រីតដលបានបញ្ជាខ្ញុំ ហើយ...ហើយបានយកខ្ញុំមកទីនេះ។ តើ...តើបងសម្លាប់...សត្វនេះយ៉ាងដូចម្តេច? តើ...តើរីតដលនៅឯណា? អ្វីចុងក្រោយដែលខ្ញុំនៅ...នៅចាំគឺគាត់បានចេញពីសៀវភៅកំណត់ហេតុ។

- រឿងនេះចប់សព្វគ្រប់ហើយ- ហេរីនិយាយព្រមទាំងកាន់សៀវភៅកំណត់ហេតុ និងបង្ហាញចង្កូមពស់ឲ្យជីននីឃើញ - រឿងរបស់គេត្រូវបញ្ចប់ហើយ។ មើលទៅគាត់ និងសត្វពស់នោះទៅ! តោះ! ជីននី យើងគួរតែចាកចេញពីកន្លែងនេះទៅ។

- ខ្ញុំនឹងត្រូវគេបណ្តេញចេញពីសាលាហើយ មើលទៅ- ជីននីយំ នៅពេលដែលហេរីខំប្រឹងជួយទាញជីននីឲ្យក្រោកឡើងយ៉ាងពិបាក - ខ្ញុំខំទន្ទឹងរង់ចាំថ្ងៃដែលខ្ញុំអាចចូលរៀននៅសាលាហុកវ៉ាតចាប់តាំងពីពេលដែលប៊ីលបានចូលរៀន ហើយឥឡូវនេះខ្ញុំត្រូវចាកចេញពីសាលា តើឪពុកម្តាយរបស់ខ្ញុំនឹងស្តីបន្ទោសឲ្យខ្ញុំយ៉ាងណា?

ហ្វ៉ក់វ៉េសកំពុងតែហោះសំកាំងចាំពួកគេនៅឯផ្លូវចូល។ ហេរីជម្រុញជីននីឲ្យដើរទៅមុខ។ ពួកគេបានដើររំលងខ្មោចពស់នោះ។ ពួកគេដើរកាត់កន្លែងដែលចាំងស្រមោលខ្មៅចម្លែកៗ ហើយបន្តត្រលប់ទៅកាន់រូងថ្មវិញ។ ហេរីឮសំឡេងទ្វារថ្មបិទពីក្រោយពួកគេជាមួយស្នូរដ៏ស្រទន់។

បន្ទាប់ពីដើរក្នុងរូងថ្មដ៏ងងឹតអស់រយៈពេលពីរបីនាទីមក សំឡេងតិចៗនៃការព្យាយាមលើកថ្មចេញបានជ្រៀតចូលទៅក្នុងត្រចៀករបស់ហេរី។

- រ៉ុន!- ហេរីស្រែកឡើងយ៉ាងលឿន - ជីននីមិនកើតអីទេ! ខ្ញុំបាននាំនាងមកហើយ!

ហេរីឮរ៉ុនស្រែកយ៉ាងសប្បាយចិត្ត ហើយពួកគេបានដើរតាមផ្លូវកោងមួយ ឃើញទឹកមុខរ៉ុនពោរពេញដោយសេចក្តីត្រេកអរដែលកំពុងតែសម្លឹងមើលតាមចន្លោះធំបន្តិចៗ ត្រង់កន្លែងវាយកថ្មចេញ។

- ជីននី!- រ៉ុនបានដាក់ដៃរបស់ខ្លួនតាមចន្លោះថ្មដើម្បីចង់ប៉ះនាងមុនគេ - ឯងនៅរស់ទេ! មិនគួរឲ្យជឿទេ! តើមានអ្វីខ្លះបានកើតឡើង?

រ៉ុនព្យាយាមអោបនាង ប៉ុន្តែជីននីមិនចូលទៅជិតវាទេ ហើយនាងបែរជាយំអណ្តឺតអណ្តកទៅវិញ។

- ប៉ុន្តែឯងគ្មានកើតអីឯណា ជីននី- រ៉ុននិយាយទាំងញញឹមយ៉ាងរីករាយទៅរកនាង - រឿងនេះចប់ហើយតើ! វា...តើឯងបានសត្វនេះមកពីណាហ្នឹង?

ហ្វ័រឃែសបានហោះឆាបចន្លោះនោះពីមុខជីននី។

- វាជាបក្សីរបស់លោកសាស្ត្រាចារ្យដាំប័លដ័រ- ហេរីនិយាយ ហើយប្រជ្រៀតខ្លួនទៅមើលតាមចន្លោះនោះ។

- ហើយតើឯងបានដាវនោះមកពីណាដែរ?- រ៉ុននិយាយ ហើយសម្លឹងមើលទៅដាវដែលបញ្ចេញពន្លឺភ្លឺចិញ្ចាចនៅក្នុងដៃរបស់ហេរី។

- ខ្ញុំនឹងពន្យល់ឯងនៅពេលក្រោយ បន្ទាប់ពីយើងចេញពីទីនេះសិន- ហេរីនិយាយ ហើយក្រឡេកមើលទៅជីននីដែលឈរនៅជ្រុងម្ខាង។

- ប៉ុន្តែ...

- ពេលក្រោយ- ហេរីនិយាយយ៉ាងលឿន។ វាគិតថា មិនមែនជាគំនិតល្អនោះទេក្នុងការប្រាប់រ៉ុនថា អ្នកណាជាអ្នកបើកបន្ទប់សម្ងាត់នោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏មិនត្រូវនិយាយនៅចំពោះមុខជីននីដែរ - ចុះឯណាសាស្ត្រាចារ្យឡក់ហាត?

- អង្គុយនៅខាងក្រោយ- រ៉ុននិយាយទាំងសើចញឹមៗ ហើយងាកមើលទៅគាត់ - មើលទៅដូចជាធ្ងន់ធ្ងរហើយ។ មកមើលមក៍!

ពួកគេត្រូវបាននាំផ្លូវដោយ ហ្វ័រឃែស ដែលស្លាបពណ៌ក្រហមឆ្អៅយ៉ាងធំរបស់វាបញ្ចេញពណ៌មាសយ៉ាងសន្ធោសន្ធៅក្នុងភាពងងឹត។ ពួកគេដើរតាមផ្លូវទៅកាន់មាត់រូងតាមពីក្រោយហ្វ័រឃែស។ លោកហ្គីលដឺរ៉យ ឡក់ហាតកំពុងតែអង្គុយនៅទីនោះច្រៀងរហ៊ឹមៗ។

- គាត់បាត់បង់ការចងចាំទៅហើយ- រ៉ុននិយាយ - បាលីកំទេចការចងចាំមិនត្រូវយើង បែរជាខ្ទាតមកត្រូវគាត់វិញ។ គ្មានវិធីណាដើម្បីធ្វើឲ្យគាត់ដឹងថាគាត់ជានរណា រឺក៏ទីនេះជាកន្លែងណា រឺពួកយើងជានរណាទេ។ ខ្ញុំបានប្រាប់គាត់ឲ្យមកទីនេះហើយរង់ចាំ។ គាត់ថែមទាំងអាចបង្កគ្រោះថ្នាក់ដល់ខ្លួនឯងទៀតផង។

ឡក់ហាតសម្លឹងមើលមកពួកគេ ដោយទឹកមុខស្រស់ស្រាយតាមបែបធម្មជាតិ។

- សួស្តី!- គាត់និយាយ - នេះគឺជាកន្លែងដ៏ចម្លែកមួយ មិនថាអ៊ីចឹងរឺ? តើឯងរស់នៅទីនេះរឺ?

- អត់ទេ!- រ៉ុននិយាយ ព្រមទាំងញាក់ចិញ្ចើមដាក់ហេរី។

ហេរីដើរទៅមុខបន្តិច ហើយសម្លឹងមើលទៅរូងដ៏វែង ហើយងងឹត។

- ឯងមានបានគិតទេថា តើយើងត្រូវធ្វើដូចម្តេចដើម្បីអាចចេញពីទីនេះបាន?- ហេរីនិយាយទៅកាន់រ៉ុន។

រ៉ុនគ្រវីក្បាល ប៉ុន្តែហ្វ័រឃែសបានហោះឆាបពីមុខហេរី ហើយកំពុងតែបក់ស្លាបរវិចៗនៅពីមុខវា។ ភ្នែកដ៏តូចមូលថ្លារបស់ហ្វ័រឃែសបញ្ចេញពន្លឺក្នុងភាពងងឹត។ វាកំពុងតែបក់កន្ទុយដ៏វែងពណ៌មាសដែលពោរពេញទៅដោយរោមរបស់វា។ ហេរីមើលទៅវាទាំងភាពមិនច្បាស់លាស់។

- មើលទៅវាដូចជាចង់ឲ្យឯងចាប់កាន់...- រ៉ុននិយាយ ទាំងមិនប្រាកដប្រជា - ប៉ុន្តែឯងធ្ងន់ណាស់សម្រាប់ឲ្យសត្វបក្សីមួយទាញឯងចេញពីទីនេះ។

- ហ្វ៊រយែស- ហេរីនិយាយ - មិនមែនជាបក្សីធម្មតាឯណា- វាបានបែរយ៉ាងលឿនទៅកាន់អ្នកឯទៀត - យើងត្រូវតែកាន់ដៃគ្នា។ ជីននីកាន់ដៃរ៉ុន។ សាស្ត្រាចារ្យឡុក់ហាត...

- គេចង់និយាយពីលោក- រ៉ុននិយាយភ្លាមទៅកាន់សាស្ត្រាចារ្យឡុក់ហាត។

- លោកត្រូវតែកាន់ដៃម្ខាងទៀតរបស់ជីននី។

ហេរីញាត់ដាវ និងមួកសិល្ប៍ឲ្យជាប់ខ្សែក្រវ៉ាត់របស់វា ឯរ៉ុនរៀបចំកាន់ជាយអាវរបស់ហេរី។ ហេរីបានដកដៃទៅកាន់កន្ទុយដែលពោរពេញទៅដោយរោមយ៉ាងចម្លែករបស់ហ្វ៊រយែស។

ពន្លឺដ៏ចម្លែកហាក់សាយភាយជុំវិញខ្លួនពួកគេ ហើយរំពេចនោះជាមួយនឹងចលនាដ៏រហ័ស និងសំឡេងផ្ទុះដ៏ស្រទន់ ពួកគេកំពុងតែហោះទៅខាងលើ ចេញពីបំពង់។ ហេរីអាចស្តាប់ឮលោកសាស្ត្រាចារ្យឡុក់ហាត ដែលកំពុងតែយោលយោកខ្លួននៅពីក្រោមវានិយាយថា៖

- គួរឲ្យភ្ញាក់ផ្អើលមែន! វាហាក់ដូចជាប្រើវេទមន្តអញ្ចឹង។

ខ្យល់ដ៏ត្រជាក់បានជ្រៀតចូលទៅក្នុងសក់ក្បាលរបស់ហេរី ហើយមុនពេលដែលវាចាប់ផ្តើមសប្បាយរីករាយនឹងការធ្វើដំណើរនេះ ការហោះហើរបានបញ្ចប់ទៅហើយ។ ពួកគេទាំងបួនកំពុងតែឈរនៅលើកំរាលដ៏សួតនៃបន្ទប់ទឹករបស់ម៉ុននីង មីតថលហើយនៅពេលដែលសាស្ត្រាចារ្យឡុក់ហាតបែរក្បាលរបស់គាត់ត្រង់ឡើងវិញ កន្លែងលុបមុខដែលលាក់រូងនោះបានរំកិលទៅរកសភាពដើមវិញ។

មីតថលសម្លឹងដោយបើកភ្នែកធំៗទៅកាន់ពួកគេ។

- ឯងនៅរស់ទេ!- នាងនិយាយខ្លាំងៗទៅកាន់ហេរី។

- មិនត្រូវនិយាយហាក់ដូចជាអស់សង្ឃឹមយ៉ាងនេះទេ- ហេរីនិយាយទាំងមុខក្រញូវ ហើយកំពុងតែជូតស្នាមអុចៗនៃឈាមចេញពីវ៉ែនតារបស់វា។

- ល្អហើយ...ខ្ញុំទើបតែបានគិតដែរ។ ប្រសិនបើឯងស្លាប់ ខ្ញុំអាចចែកបន្ទប់ទឹករបស់ខ្ញុំឲ្យឯងនៅបាន។- មីតថលនិយាយដោយបង្ហាញភាពអៀនខ្មាសនៅលើមុខពណ៌ប្រាក់របស់នាង។

- អ៊ាំ!- រ៉ុននិយាយនៅពេលដែលពួកគេចេញពីបន្ទប់ទឹក ហើយដើរទៅកាន់ច្រករបៀងដែលស្ងាត់គ្មានមនុស្សនៅ - ហេរី! ខ្ញុំគិតថាមីតថលដូចជាចូលចិត្តឯងណាស់! ឯងមានអ្នកប្រកួតប្រជែងហើយ ជីននី!

ប៉ុន្តែទឹកភ្នែកនៅតែស្រក់ជោកជាំពេញមុខជីននី។

- តើយើងទៅកន្លែងណាហ្នឹង?- រ៉ុនសួរ ហើយមើលទៅមុខជីននី ដោយក្រសែភ្នែកអន្ទះអន្ទែង។ ហេរីចង្អុល។

ហ្វ៊រយែសជាអ្នកនាំផ្លូវ ហើយបញ្ចេញពន្លឺពណ៌មាសតាមបណ្តោយច្រករបៀង។ ពួកគេបោះជំហានវែងៗតាមពីក្រោយវា។ មួយសន្ទុះក្រោយមក ពួកគេដឹងថា ពួកគេកំពុងតែនៅចំហៀងការិយាល័យរបស់សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល។

ហេរីគោះទ្វារ ហើយរុញទ្វារបើក។

**វគ្គ XVIII**



## អំណោយសំរាប់ដុបប៊ី

ក្នុងរយៈពេលមួយសន្ទុះ ភាពស្ងៀមស្ងាត់បានកើតមានឡើង ពេលដែលរ៉ុន ជីននី សាស្ត្រាចារ្យឡក់ហាត និងហេរីដែល ខ្លួនគេកខ្វក់ ហើយប្រឡាក់សុទ្ធតែឈាមបានឈរនៅផ្លូវចូល។ បន្ទាប់មក មានសម្រែកមួយបន្លឺឡើង៖

- ជីននី!

គឺអ្នកស្រីវីស្លី ដែលកំពុងតែអង្គុយ ហើយលាន់មាត់ស្រែក នៅពីមុខភ្លើងក្នុងចង្ក្រានកំដៅ។ គាត់បានក្រោកឈរ ហើយ លោកវីស្លីឈរពីក្រោយយ៉ាងជិតគាត់។ ពួកគាត់ទាំងពីររត់ទៅអោបជីននី។

ប៉ុន្តែហេរីបានមើលរំលងពួកគេ។ លោកសាស្ត្រាចារ្យដាំប័លដ័រកំពុងតែឈរនៅក្បែរធ្នើរលើចង្ក្រានកំដៅ ហើយបញ្ចេញ ស្នាមញញឹមដ៏រីករាយ។ នៅក្បែរគាត់ គឺសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាល ដែលកំពុងតែដកដង្ហើមធំ ហើយកំពុងតែយកដៃក្តោបទ្រូង គាត់យ៉ាងជាប់។ ហ្វ៉ៃយែសបានបន្លឺសំឡេងស្ទុះយ៉ាងស្រទន់កាត់ត្រចៀករបស់ហេរី ហើយទៅទំលើស្មារបស់លោកដាំប័លដ័រ នៅ ពេលដែលហេរី និងរ៉ុនត្រូវអ្នកស្រីវីស្លីចាប់អោបរឹត។

- ឯងបានជួយនាង! ឯងបានជួយសង្គ្រោះនាង! តើឯងធ្វើដូចម្តេចទៅ?

- ខ្ញុំគិតថា អ្នកទាំងអស់គ្នាពិតជាចង់ដឹងអំពីរឿងនេះ- សាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយខ្សាវៗ។

អ្នកស្រីវីស្លីលែងហេរី ដែលនៅស្ទាក់ស្ទើរមួយស្របក់ បន្ទាប់មក វាដើរទៅកាន់តុ ហើយដាក់មួកសិល្ប៍ ដាវដាប់ត្បូងទទឹម និងអ្វីដែលនៅសេសសល់ពីសៀវភៅកំណត់ហេតុរបស់រីតដល។

បន្ទាប់មក វាចាប់ផ្តើមនិយាយរឿងរ៉ាវគ្រប់យ៉ាងឲ្យអ្នកទាំងអស់គ្នាដឹង។ ប្រហែលជាអស់ដប់ប្រាំនាទី វាចាប់ផ្តើមនិយាយ យ៉ាងអណ្តែតអណ្តូង និងស្ងៀមស្ងាត់៖ វាបានប្រាប់ពីសំឡេងដែលគ្មានរាងពៅ ប្រាប់វិធីដែលហឺម៉ាយអូនីអាចដឹងបានថា វាបាន ស្តាប់ឮសំឡេងរបស់សត្វពស់តាមរយៈបំពង់ ប្រាប់អំពីការលួចតាមសត្វពីងពាងចូលទៅក្នុងព្រៃ ប្រាប់ពីសម្តីរបស់អារ៉ាហ្គក ដែល បានប្រាប់ថា ជនរងគ្រោះដោយសារពស់នោះនៅឯណា ប្រាប់ថាវាបានទាយដឹងថា ម៉ុននីង មីតថល ក៏ធ្លាប់ជាជនរងគ្រោះម្នាក់ដែរ ព្រមទាំងប្រាប់ថា វាបានប៉ាន់ស្មានពី ច្រកចូលទៅក្នុងបន្ទប់សម្ងាត់នោះថាប្រាកដជានៅក្នុងបន្ទប់ទឹករបស់នាង...

- ល្អ!- អ្នកស្រីម៉ាកហ្គូណាហ្គាលបាននិយាយកាត់នៅពេលវាឈប់មួយភ្លែត - អ៊ីចឹង ឯងបានដឹងពីច្រកចូលបន្ទប់សម្ងាត់ នោះ...ឯងបានល្មើសវិន័យរាប់រយរបស់សាលា។ ប៉ុន្តែតើឯងធ្វើដូចម្តេចទើបអាចគេចផុតពីគេបាន ដោតដ៍រ?

## អំណោយសំរាប់ជុំបប៊ី

សំឡេងរបស់ហោរីឡើងស្អក។ វាបានប្រាប់ពួកគេពីការមកដល់យ៉ាងទាន់ពេលរបស់ហ្វ័រយែស ហើយប្រាប់អំពីមួកសិល្ប៍ដែលបានឲ្យដាវទៅវា។ ប៉ុន្តែបន្ទាប់មក វាចាប់ផ្ដើមនិយាយរអាក់រអួល។ វាបានព្យាយាមយ៉ាងខ្លាំងក្នុងការនិយាយពង្វាងពីរឿងសៀវភៅកំណត់ហេតុរបស់រីតដល ឬនិយាយពីជីននី។ ជីននីកំពុងតែឈរផ្អែកក្បាលទៅនឹងស្មារបស់អ្នកស្រីវីស្លី ហើយទឹកភ្នែកនៅតែហូរស្រក់យ៉ាងស្ងៀមស្ងាត់កាត់ថ្ពាល់របស់នាង។ ហោរីកំពុងតែគិតថា តើនឹងមានអ្វីកើតឡើងបើគេបណ្ដេញនាងចេញពីសាលា? ហោរីកំពុងតែព្យាយាមប្រើការស្រមើស្រមៃរបស់វាយ៉ាងខ្លាំង។ សៀវភៅកំណត់ហេតុរបស់រីតដលមិនអាចប្រើការបានទៀតទេ។ ដូចនេះ ពួកគេមិនអាចបញ្ជាក់បានទេថា រីតដលបានបញ្ជានាងឲ្យធ្វើរឿងទាំងអស់នោះ។

ហោរីកំពុងតែសម្លឹងមើលទៅលោកដាំប័លដ័រដែលកំពុងតែញញឹមតិចៗ។ ពន្លឺភ្លើងចាំងប៉ះវ៉ែនតាចំណិតខែរបស់គាត់។

- អ្វីដែលខ្ញុំចាប់អារម្មណ៍បំផុតនោះគឺ- លោកដាំប័លដ័រនិយាយយ៉ាងសុភាព - តើឡូត វ៉ុលដឺម៉រអាចទាក់ទាញអារម្មណ៍របស់ជីននីបានយ៉ាងដូចម្ដេចទៅ? ព្រោះក្នុងកំឡុងពេលនោះ អ្នកយកការណ៍របស់ខ្ញុំបានប្រាប់ខ្ញុំថា គេកំពុងតែសម្ងំខ្លួននៅព្រៃនៅឯ អាល់បានី ឯណោះ។

ភាពធូរស្រាល ភាពកក់ក្ដៅ ដែលមានឥទ្ធិពលយ៉ាងខ្លាំង និងគួរឲ្យរីករាយបានសាយភាពពេញខ្លួនហោរី។

- គឺជាអ្វីទៅ?- អ្នកស្រីវីស្លីបន្លឺឡើងក្នុងសំឡេងដ៏គួរឲ្យចាប់អារម្មណ៍មួយ - អ្នកដែលឯងស្គាល់ បានអូសទាញជីននី? ប៉ុន្តែនាងមិន...នាងមិនបាន...តើពិតជាអ៊ីចឹងរឺ?

- គឺសៀវភៅកំណត់ហេតុ- ហោរីនិយាយយ៉ាងលឿន ព្រមទាំងលើកសៀវភៅនោះឡើង ហើយបង្ហាញទៅលោកដាំប័លដ័រ - រីតដលបានសរសេរសៀវភៅនេះកាលពីគាត់មានអាយុដប់ប្រាំមួយឆ្នាំ។

សាស្ត្រាចារ្យដាំប័លដ័របានយកសៀវភៅកំណត់ហេតុពីដៃរបស់ហោរី ហើយមើលទៅទំព័រដែលឆេះ ហើយទទឹកជោកជាំយ៉ាងចាប់អារម្មណ៍តាមរយៈច្រមុះដ៏វែង ហើយកោងរបស់គាត់។

- អស្ចារ្យ!- គាត់និយាយយ៉ាងស្រទន់ - ជាការពិតណាស់ គេប្រហែលជាសិស្សដ៏ឈ្លាសវៃបំផុតប្រចាំសាលាហុកវ៉ាត ដែលកម្រនឹងរកបានណាស់- គាត់បែរសម្លឹងទៅគ្រួសារវីស្លីដែលកំពុងតែមើលយ៉ាងភាំងស្មារតី។

- មានមនុស្សតែប៉ុន្មាននាក់តែប៉ុណ្ណោះ ដែលដឹងថា ឡូត វ៉ុលដឺម៉រ មានឈ្មោះមួយទៀតគឺ ថម រីតដល។ ខ្ញុំបានបង្រៀនគេដោយផ្ទាល់កាលពីហាសិបឆ្នាំមុននៅសាលាហុកវ៉ាត។ គេបានបាត់ខ្លួនបន្ទាប់ពីចាកចេញពីសាលា។ គេបានធ្វើដំនើរទៅយ៉ាងឆ្ងាយ ហើយបានលង់ខ្លួនយ៉ាងជ្រៅទៅក្នុងមន្តអាគមងងឹត ហើយបានសេពគប់ជាមួយនឹងភាវៈអាក្រក់ ព្រមទាំងអនុវត្តវិជ្ជានិម្មិតកម្មវេទមន្តដ៏គ្រោះថ្នាក់ជាច្រើន។ នៅពេលដែលគេដាក់ឈ្មោះថា ឡូត វ៉ុលដឺម៉រ មិនងាយមានអ្នកចំនាំគេបានទេ។ កម្រនឹងមានគេដឹងថា ឡូត វ៉ុលដឺម៉រ និងក្មេងប្រុសដ៏ស្រស់សង្ហា មានបញ្ញាវៃឆ្លាត ដែលធ្លាប់ធ្វើជាអនុរក្សក្រុមសិស្សច្បង តាមពិតជាមនុស្សតែមួយសោះ។

- ប៉ុន្តែជីននី- អ្នកស្រីវីស្លីនិយាយ - តើជីននីរបស់យើងអាចធ្វើអ្វីបានជាមួយនឹងមនុស្សម្នាក់នោះទៅ?

- សៀវភៅកំណត់ហេតុរបស់គាត់!- ជីននីបន្លឺសំឡេងទាំងអណ្ដឺតអណ្ដក - ខ្ញុំបានសរសេរនៅក្នុងសៀវភៅនោះ ហើយគាត់បានឆ្លើយតបមកវិញពេញមួយឆ្នាំ។

- ជីននី!- លោកវីស្លីនិយាយទាំងស្រឡាំងកាំង - តើប៉ាមិនបានបង្រៀនកូនទេរឺ? តើប៉ាតែងតែប្រាប់អ្វីដល់កូន? មិនត្រូវទុកចិត្តលើអ្វីទាំងអស់។ ហេតុអ្វីបានជាកូនមិនបង្ហាញសៀវភៅកំណត់ហេតុនោះដល់ប៉ាម៉ាក់? វត្ថុដែលគួរឲ្យសង្ស័យដូចនេះ វាប្រាកដជាពោរពេញទៅដោយមន្តអាគមងងឹតហើយ។

- ខ្ញុំមិនបានដឹងទេ- ជីននីនិយាយយ៉ាងអណ្ដឺតអណ្ដក - ខ្ញុំបានឃើញវានៅក្នុងចំនោមសៀវភៅដែលម៉ាក់បានទិញឲ្យខ្ញុំ។ ខ្ញុំគិតថា នរណាម្នាក់បានទុកវាចោល ហើយភ្លេចវានៅក្នុងនោះ...

- កញ្ញាវីស្លីគួរតែទៅគិលានដ្ឋានសិននៅពេលនេះ- លោកដាំប៊័លដ័រនិយាយកាត់ ដោយប្រើសំឡេងយ៉ាងច្បាស់លាស់ - នេះគឺជាបទពិសោធដ៏គួរឲ្យឈឺចាប់សម្រាប់នាងហើយ។ វានឹងគ្មានការដាក់ទោសទេ។ ផេទគូដែលចាស់ជាងនាង ហើយចេះដឹងជាងនាងក៏ធ្លាប់ត្រូវបាន ឡត វ៉ុលដឺម៉រ បោកប្រាស់ដែរ- គាត់បានដើរបោះជំហានវែងៗទៅកាន់ទ្វារ ហើយបើកវាឡើង - គ្រែដែលនៅសល់ប្រហែលជាធំ ហើយបន្ទប់នោះពោរពេញទៅដោយចំហាយនៃសូកូឡាក្ដៅទៀតផង។ ខ្ញុំតែងតែគិតថា វាធ្វើឲ្យខ្ញុំសប្បាយចិត្តណាស់- គាត់និយាយបន្ថែម ហើយងាកយ៉ាងរហ័សទៅរកជីននី - ឯងនឹងដឹងថា អ្នកស្រីផុមហ្ប្រីបានត្រៀមរួចរាល់អស់ហើយ។ គាត់គ្រាន់តែផ្ដល់ទឹកនៃដើមម៉ានខ្ទ្រែក ជនរងគ្រោះដោយសារតែសត្វពស់នោះ នឹងដឹងខ្លួនបានគ្រប់ពេល។

- ដូចនេះ ហឺម៉ាយអូនីមិនកើតអីនោះទេ!- រ៉ុននិយាយយ៉ាងរីករាយ។

- នឹងមិនមានការខូចខាត ឬការរងរបួសទៀតទេ- លោកដាំប៊័លដ័រនិយាយ។

លោកស្រីវីស្លីបាននាំជីននីចេញទៅក្រៅ ហើយលោកវីស្លីបានដើរចេញតាមក្រោយ។ មើលទៅគាត់ ដូចជាញ័រយ៉ាងខ្លាំង។

- អ្នកដឹងទេ អ្នកស្រីមីណែរវ៉ា- លោកដាំប៊័លដ័រនិយាយយ៉ាងល្អិតល្អន់ ទៅកាន់អ្នកស្រីម៉ាកហ្គូណាហ្គាល - ខ្ញុំតែងតែគិតអំពីគុណសម្បត្តិនៃពិធីជប់លៀងនេះ។ តើអ្នកស្រីអាចទៅក្រៅ ហើយត្រួតពិនិត្យចំពោះកិច្ចការនៅក្នុងផ្ទះបាយបានទេ?

- ពិតជាបាន!- អ្នកស្រីម៉ាកហ្គូណាហ្គាលនិយាយយ៉ាងម៉ឺងម៉ាត់ ហើយបានបើកទ្វារ - ខ្ញុំទុកផោតធ័រ និងវីស្លីឲ្យលោកចាត់ការចុះ បានទេ?

- ប្រាកដណាស់!- លោកដាំប៊័លដ័រនិយាយ។

គាត់ក៏បានចាកចេញទៅ ទុកឲ្យហេរី និងរ៉ុនសម្លឹងមើល ដាំប៊័លដ័រ ផ្លៀកៗ។ តើសាស្ត្រាចារ្យម៉ាកហ្គូណាហ្គាលនិយាយថា "*ចាត់ការ*ជាមួយពួកគេ" នេះចង់មានន័យថាម៉េច? តិចលោពួកគេត្រូវទទួលទណ្ឌកម្មទៅ។

រ៉ុនច្រហមាត់របស់វាទាំងភ័យខ្លាច។

- នរណាថា មនុស្សដែលគេតែងគោរពលើកតំកើង មិនអាចនិយាយក្រឡាស់សម្ដីនោះ?- គាត់ចាប់ផ្ដើមញញឹម។ - ឯងទាំងពីរ នឹងទទួលបានអំណោយពិសេសក្នុងការជួយសង្គ្រោះសាលាហើយ...ចាំមួយភ្លែត...ហ្នឹងហើយ! ខ្ញុំគិតថាឯងទទួលបានពីររយពិន្ទុសម្រាប់ក្រុមហ្គ្រីហ្វីនដ័រ។

មុខរបស់រ៉ុនប្រែទៅជាពណ៌ផ្កាឈូកព្រឿងៗ ដូចជាផ្កានៅថ្ងៃបុណ្យនៃសេចក្ដីស្រឡាញ់របស់សាស្ត្រាចារ្យឡក់ហាតអញ្ចឹង ហើយក៏យកដៃខ្ទប់មាត់ម្ដងទៀត។

- ប៉ុន្តែម្នាក់ក្នុងចំនោមពួកឯង ហាក់បីដូចជាស្ងប់ស្ងាត់ណាស់នៅក្នុងការធ្វើដំណើរផ្សងព្រេងដ៏គ្រោះថ្នាក់នេះ- លោកដាំប៊័លដ័រនិយាយបន្ថែម - ហេតុអ្វីបានជាដាក់ខ្លួនម្ល៉េះ ហ្គីលដឺរ៉យ?

ហេរីស្រាប់តែភ្ញាក់ព្រើត។ វាភ្លេចអំពីវត្តមាននៃសាស្ត្រាចារ្យឡក់ហាតឲ្យឈឹង។ វាបែរទៅមើលគាត់ ឃើញថាគាត់កំពុងតែឈរនៅកន្លៀតបន្ទប់ មុខញញឹមជាប់រហូត។ នៅពេលដែលលោកដាំប៊័លដ័រសួរទៅគាត់ គាត់បែរមើលទៅខាងក្រោយខ្នងរបស់គាត់ ដើម្បីចង់ដឹងថាលោកដាំប៊័លដ័រកំពុងនិយាយទៅកាន់នរណា។

- លោកសាស្ត្រាចារ្យដាំប៊័លដ័រ- រ៉ុននិយាយយ៉ាងលឿន - មានគ្រោះថ្នាក់មួយបានកើតឡើងនៅក្នុងបន្ទប់សម្ងាត់ ហើយលោកសាស្ត្រាចារ្យឡក់ហាត...

- តើខ្ញុំជាសាស្ត្រាចារ្យរឺ?- គាត់និយាយដោយភ្ញាក់ផ្អើល - ពិតជារឿងល្អណាស់! ខ្ញុំគិតថា ខ្ញុំអស់សង្ឃឹមទៅហើយ។ តើខ្ញុំពិតជាសាស្ត្រាចារ្យមែនរឺ?

- គាត់បានព្យាយាមសូត្របាលីកំទេចការចងចាំ ហើយចង្កឹះវេទមន្តក៏ស្រាប់តែបាញ់សិល្បិ៍ចំគាត់វិញ- រ៉ុនពន្យល់ដាំប័លដ័រមួយៗ។

- គួរឲ្យសោកស្តាយណាស់!- លោកដាំប័លដ័រនិយាយ ហើយគ្រវីក្បាលរបស់គាត់ធ្វើឲ្យពុកមាត់ពណ៌ប្រាក់របស់គាត់រញ្ជួយ - កាំបិតចិតដងឯងហើយ! ហ្គិលដឺរ័យ!

- កាំបិត?- សាស្ត្រាចារ្យឡក់ហាតនិយាយយ៉ាងងងឹតងងុល - ខ្ញុំគ្មានកាំបិតនោះទេ។ តែក្មេងម្នាក់នោះមានដាវ- គាត់ចង្អុលទៅហេរី - វាអាចឲ្យលោកខ្ចីដាវបាន។

- តើឯងអាចជួយនាំគេទៅកាន់គិលានដ្ឋានបានដែររឺទេ?- លោកដាំប័លដ័រនិយាយទៅកាន់រ៉ុន - ខ្ញុំមានពាក្យខ្លះចង់និយាយជាមួយហេរី។

សាស្ត្រាចារ្យឡក់ហាតដើរចេញទៅក្រៅ។ រ៉ុនបានចោលក្រសែភ្នែកយ៉ាងឆ្ងល់ទៅកាន់លោក ដាំប័លដ័រ និង ហេរី នៅពេលដែលវាបិទទ្វារ។

លោកដាំប័លដ័របានចង្អុលទៅកៅអីមួយក្នុងចំនោមកៅអីជាច្រើននៅក្បែរចង្ក្រានកំដៅ។

- អង្គុយចុះទៅ ហេរី!- គាត់និយាយ ហើយហេរីបានអង្គុយចុះព្រមទាំងមានអារម្មណ៍ថាភ័យខ្លាចដល់ថ្នាក់មិនអាចរៀបរាប់បាន។

- ជាដំបូង ហេរី ខ្ញុំចង់អរគុណដល់ឯង- លោកដាំប័លដ័រនិយាយ ហើយភ្នែករបស់គាត់បញ្ចេញពន្លឺព្រិចៗ - ឯងច្បាស់ជាបានបង្ហាញនូវភាពស្មោះត្រង់យ៉ាងពិតប្រាកដហើយ នៅក្នុងបន្ទប់សម្ងាត់នោះ ព្រោះថាមានតែដូច្នោះទេទើបអាចហៅ ហ្វ៊រឃែសឲ្យទៅជួយឯងបាន។

គាត់សម្លឹងមើលទៅបក្សីហ្វេនីកដែលទទះស្លាបរវិចៗ លើជង្គង់របស់គាត់។ ហេរីញញឹមយ៉ាងឆ្គង នៅពេលដែលលោកដាំប័លដ័រសម្លឹងមើលវា។

- ឯងបានជួបនឹងថម រីតដល- សាស្ត្រាចារ្យដាំប័លដ័រនិយាយយ៉ាងម៉ត់ចត់ - ខ្ញុំគិតថា វាប្រហែលជាចាប់អារម្មណ៍ខ្លាំងទៅលើឯងហើយមើលទៅ...

- សាស្ត្រាចារ្យដាំប័លដ័រ...រីតដលបាននិយាយថា ខ្ញុំដូចគាត់ គឺជាភាពដូចគ្នាយ៉ាងចម្លែក គាត់បាននិយាយ...

- ពិតរឺ?- គាត់និយាយព្រមទាំងសម្លឹងទៅហេរី តាមរយៈចិញ្ចើមពណ៌ប្រាក់ដ៏ក្រាស់របស់គាត់ - តើឯងគិតយ៉ាងម៉េចដែរហេរី?

- ខ្ញុំគិតថា ខ្ញុំមិនដូចគាត់នោះទេ- ហេរីនិយាយដំឡើងសំឡេង- ខ្ញុំបានន័យថា...ខ្ញុំស្ថិតនៅក្នុងក្រុមហ្គ្រីហ្វីនដ័រ ខ្ញុំ...

ប៉ុន្តែវាបានឈប់និយាយ។ មានចម្ងល់មួយបានកើតឡើងនៅក្នុងខួរក្បាលរបស់វា។

- លោកសាស្ត្រាចារ្យ- ហេរីចាប់ផ្តើមនិយាយម្តងទៀតបន្ទាប់ពីឈប់មួយភ្លែត - មួកសិល្បិ៍បានប្រាប់ខ្ញុំថា ខ្ញុំ...ខ្ញុំនឹងខ្លាំងប្រសិនបើខ្ញុំនៅក្នុងក្រុមស្លីតឺរីន។ អ្នកគ្រប់គ្នាគិតថា ខ្ញុំជាទាយាទរបស់ស្លីតឺរីនអស់មួយរយៈពេល...ដោយសារតែខ្ញុំអាចនិយាយភាសាពស់បាន...

- ឯងអាចនិយាយភាសាពស់បាន ហេរី- លោកដាំប័លដ័រមានប្រសាសន៍យ៉ាងស្ងៀមស្ងាត់ - ដោយសារតែ ឡត វ៉ុលដឺម៉រ ដែលជាទាយាទស្នងពី សាឡាហ្សា ស្លីតឺរីន អាចនិយាយភាសាពស់បាន។ បើខ្ញុំស្មានមិនខុសទេ ឥទ្ធិពលខ្លះរបស់គេបានចូលទៅក្នុងខ្លួនរបស់ឯង នៅយប់ដែលគេធ្វើឲ្យឯងមានស្នាមសម្លាកនេះ។ ខ្ញុំប្រាកដណាស់ថា វាមិនមែនជាអ្វីដែលគេចង់ធ្វើនោះទេ។

- វ៉ុលដឺម៉រ មានដាក់វិញ្ញាណរបស់គេបន្តិចចូលទៅក្នុងខ្លួនខ្ញុំ?- ហេរីនិយាយខ្លាំងៗ។

- វាប្រហែលជាអញ្ចឹងហើយ។

- ដូចនេះ ខ្ញុំគួរតែស្ថិតនៅក្នុងក្រុមស្លីតឺរីន- ហេរីនិយាយ ហើយមើលទៅមុខរបស់លោកដាំប័លដ័រ - មួកសិល្ប៍គួរតែអាចមើលឃើញឥទ្ធិពលរបស់ស្លីតឺរីននៅក្នុងខ្លួនរបស់ខ្ញុំ ហើយវា...

- ដាក់ឯងចូលទៅក្នុងក្រុមហ្គ្រីហ្វីនដ័រ- លោកដាំប័លដ័រស្រដីឡើងយ៉ាងស្ងៀមស្ងាត់ដដែល - ស្តាប់ខ្ញុំសិន ហេរី។ ឯងមានឱកាសទទួលបាននូវលក្ខណៈដែល សាឡាហ្សា ស្លីតឺរីន បានចែករំលែកទៅឲ្យសិស្សដែលគេបានជ្រើសរើសយ៉ាងប្រុងប្រយ័ត្ន។ អំណោយដ៏ពិសេសរបស់គេ គឺភាសាពស់ ភាពប៉ិនប្រសប់លៃលក ការប្តេជ្ញាចិត្ត ការមើលស្រាលទៅលើច្បាប់- គាត់និយាយបន្ថែមធ្វើឲ្យពុកមាត់របស់គាត់រញ្ជួយម្តងទៀត - តែមួកសិល្ប៍បានដាក់ឯងចូលទៅក្នុងក្រុមហ្គ្រីហ្វីនដ័រ។ ឯងដឹងថាហេតុអ្វីបានជាអញ្ចឹងដែររឺទេ? សាកគិតមើលទៅ!

- វាបានដាក់ខ្ញុំចូលទៅក្នុងក្រុមហ្គ្រីហ្វីនដ័រ- ហេរីនិយាយមកដោយសំឡេងខ្លាំងៗ - ដោយសារតែខ្ញុំបានសុំកុំឲ្យបញ្ជូនខ្ញុំទៅក្នុងក្រុមស្លីតឺរីន...

- *ពិតណាស់*- លោកដាំប័លដ័រនិយាយ ហើយបញ្ចេញស្នាមញញឹមម្តងទៀត - នោះហើយគឺជាអ្វីដែលធ្វើឲ្យឯងខុសឆ្ងាយពី ថម រីតដល។ ហេរី មានតែជម្រើសរបស់យើងប៉ុណ្ណោះ ដែលអាចបង្ហាញថាយើងជានរណាឲ្យពិតប្រាកដ។- ហេរីអង្គុយដោយគ្មានកម្រើកនៅលើកៅអីរបស់វា ហើយស្តាប់យ៉ាងចាប់អារម្មណ៍ - ប្រសិនបើឯងចង់បានភស្តុតាង ដែលបង្ហាញថាឯងជាសមាជិកក្រុមហ្គ្រីហ្វីនដ័រ ខ្ញុំនឹងបង្ហាញឯងឲ្យបានច្បាស់។

សាស្ត្រាចារ្យដាំប័លដ័របានដើរទៅតុអ្នកស្រីម៉ាកហ្គូណាហ្គាល ហើយលើកដាវប្រាក់ដែលប្រលាក់សុទ្ធតែឈាម ហើយហុចទៅឲ្យហេរី។ ហេរីបានត្រលប់វាឃើតៗ ដែលត្បូងទទឹមនៃដាវនោះឡើងក្តៅឧណ្ហៗដោយសារកំដៅភ្លើងចេញពីចង្ក្រានកំដៅ។ បន្ទាប់មក ហេរីបានឃើញឈ្មោះមួយឆ្លាក់នៅពីក្រោមដង។

*ហ្គូឌ្រីក ហ្គ្រីហ្វីនដ័រ។*

- មានតែសមាជិកហ្គ្រីហ្វីនដ័រដ៏ពិតប្រាកដប៉ុណ្ណោះ ដែលអាចដកដាវចេញពីមួកនេះបាន ហេរី!- គាត់និយាយយ៉ាងធម្មតា។

អស់រយៈពេលមួយសន្ទុះ ពួកគេទាំងពីរមិននិយាយអ្វីសោះ។ បន្ទាប់មក លោកដាំប័លដ័របានទាញថតតុមួយនៃតុធ្វើការរបស់អ្នកស្រីម៉ាកហ្គូណាហ្គាល ហើយបានដកស្លាបប៉ាកា និងដបទឹកខ្មៅចេញ។

- អ្វីដែលឯងត្រូវការនៅពេលនេះគឺអាហារ និងការសម្រាក។ ខ្ញុំចង់ឲ្យឯងចុះទៅរកអ្វីញ៉ាំ ពេលដែលខ្ញុំសរសេរសំបុត្រទៅអាសកាបាន ដើម្បីសុំឆ្មាំប្រមាញ់របស់យើងត្រលប់មកវិញ។ ខ្ញុំនឹងព្រាងធ្វើការផ្សព្វផ្សាយមួយសម្រាប់ "សារពត៌មានវេទគូ" ផងដែរ- គាត់និយាយបន្ថែមយ៉ាងម៉ត់ចត់ - ហើយយើងនឹងត្រូវការគ្រូបង្រៀនមុខវិជ្ជា ការការពារប្រឆាំងនឹងមន្តអាគមងងឹត ថ្មីម្នាក់ទៀត។ ខ្ញុំនឹងត្រូវហត់ទៀតហើយ ក្នុងការសំភាសន៍គ្រូថ្មីនោះ មិនថាអញ្ចឹងរឺ?

## អំណោយសំរាប់ដុបប៊ី

ហេរីបានក្រោកឡើង ហើយដើរសំដៅទៅទ្វារ។ នៅពេលដែលវាហៀបនឹងបើកទ្វារទៅហើយ ស្រាប់តែទ្វារបានរបើកយ៉ាងខ្លាំង ហើយខ្ទាតប៉ះជញ្ជាំងឮសូរគ្រាំង។

លូស៊ីស មេលហ្វ័យ បានឈរនៅពីមុខនោះ ទាំងទឹកមុខក្តៅក្រហាយ។ មានអ្វីមួយកំពុងតែធ្វើក្រញោនៗនៅពីក្រោមដៃរបស់គាត់ ដែលមានបិតបង់រុំរបួសសឹងតែគ្រប់កន្លែង៖ គឺដុបប៊ី។

- សាយ័ណ្ហសួស្តី លូស៊ីស!- លោកដាំប័លដ័រនិយាយយ៉ាងរីករាយ។

លោកមេលហ្វ័យស្ទើរតែបុកហេរីទៅហើយ នៅពេលដែលគាត់ដើរចូលទៅក្នុងបន្ទប់។ ដុបប៊ីបានរត់យ៉ាងត្របាញ់ជើងពីក្រោយគាត់។ ដុបប៊ីបានឈប់ ហើយបន្ទន់ខ្លួននៅក្បែរជាយអាវខ្លករបស់គាត់។ ទឹកមុខដ៏គួរឲ្យវេទនាបំផុតបានបង្កប់នៅលើផ្ទៃមុខរបស់វា។

- អញ្ចឹង!- លោកលូស៊ីស មេលហ្វ័យនិយាយជាមួយនឹងខ្សែភ្នែកដ៏សោះកក្រោះ សម្លឹងទៅសាស្ត្រាចារ្យដាំប័លដ័រ - លោកនៅតែត្រលប់មកវិញទៀត។ អភិបាលបានផ្អាកការងាររបស់លោកជាបណ្តោះអាសន្នហើយ ប៉ុន្តែលោកនៅតែចចេសក្នុងការត្រលប់មកហុកវ៉ាតវិញទៀត។

- លោកដឹងទេ លូស៊ីស- លោកដាំប័លដ័រនិយាយដោយញញឹមយ៉ាងស្ងប់ស្ងាត់ - អភិបាលដប់មួយនាក់ផ្សេងទៀតបានទាក់ទងមកខ្ញុំថ្ងៃនេះ។ វាជារបស់មួយដែលសត្វទីទុយបានពាំកាត់ព្យុះព្រិលដើម្បីបញ្ជាក់ប្រាប់ពីការពិត។ ពួកគាត់បានឮថា កូនស្រីរបស់លោកអស៍សឺ វីស្លីត្រូវបានសម្លាប់ ហើយពួកគាត់ចង់ឲ្យខ្ញុំ ត្រលប់មកទីនេះវិញភ្លាម។ មើលទៅ ពួកគេគិតថា ខ្ញុំជាមនុស្សតែម្នាក់គត់ដែលអាចដោះស្រាយរឿងនេះបាន។ ពួកគេក៏បានប្រាប់ខ្ញុំពីពាក្យចចាមអារ៉ាមដ៏ចម្លែកមួយដែរ។ មនុស្សពីរបីនាក់ក្នុងចំនោមពួកគេត្រូវបានលោកគំរាមកំហែងថា នឹងដាក់បណ្តាសាទៅលើគ្រួសាររបស់ពួកគេ ប្រសិនបើពួកគេមិនយល់ព្រមក្នុងការផ្អាកការងាររបស់ខ្ញុំដំបូងគេនោះ។

លោកមេលហ្វ័យបានប្រែទៅជាស្លេកស្លាំងជាងធម្មតា ប៉ុន្តែភ្នែករបស់គាត់នៅតែបង្កប់ភាពក្តៅក្រហាយ។

- អញ្ចឹង តើលោកបានបញ្ឈប់ការវាយប្រហារទាំងនោះបានហើយរឺនៅ?- គាត់ញញឹមមើលងាយ - តើលោកបានចាប់អ្នកនៅពីក្រោយខ្នងរឿងនេះបានហើយរឺនៅ?

- យើងបានធ្វើរួចហើយ- លោកដាំប័លដ័រនិយាយជាមួយស្នាមញញឹម។

- មែនរឺ?- លោកមេលហ្វ័យនិយាយភ្លាមៗ - តើគេជានរណាទៅ?

- គឺមនុស្សតែមួយ ដូចកាលពីលើកមុនដែរ លូស៊ីស- លោកដាំប័លដ័រនិយាយ - ប៉ុន្តែលើកនេះ ឡត វ៉ុលដឺម៉រ បានលេចឡើងដោយប្រើមនុស្សម្នាក់ផ្សេងៗ និងសៀវភៅកំណត់ហេតុនោះ។

គាត់លើកសៀវភៅកំណត់ហេតុពណ៌ខ្មៅដែលមានប្រហោងនៅចំកណ្តាលទៅជិតលោក មេលហ្វ័យ។ ប៉ុន្តែហេរីវិញ កំពុងតែមើលទៅដុបប៊ី។

ម្រេញគង្វាលនោះកំពុងតែធ្វើអ្វីមួយយ៉ាងចម្លែក។ ភ្នែកធំៗរបស់វាសម្លឹងទៅហេរីដោយចេតនា ដោយវានៅតែចង្អុលទៅសៀវភៅកំណត់ហេតុនោះ ហើយចង្អុលទៅលោកមេលហ្វ័យ ហើយបានវាយខ្លួនឯងយ៉ាងខ្លាំងចំពីលើក្បាលដោយប្រើកណ្តាប់ដៃរបស់វា។

- ខ្ញុំគិតថា...លោកមេលហ្វ័យ- និយាយយឺតៗទៅកាន់លោកដាំប័លដ័រ។

- គឺជាគម្រោងការដ៏ល្អិតល្អន់មួយ- លោកដាំប័លដ័រនិយាយដោយសំឡេងរាបស្មើ និងនៅតែសម្លឹងមើលទៅលោកមេលហ្វ័យ ជាពិសេសគឺភ្នែករបស់គាត់ - ពីព្រោះ ប្រសិនបើមិនមែនហេរីនេះឯង- លោកមេលហ្វ័យងាកទៅរកហេរីយ៉ាងរហ័សជាមួយនឹងការសម្លឹងមើលដ៏គួរឲ្យភ័យខ្លាច - និងមិត្តរបស់គេគឺរ៉ុន ជាអ្នករកឃើញសៀវភៅកំណត់ហេតុនេះទេ ព្រះអើយ អញ្ចឹង កំហុសទាំងអម្បាលម៉ានមិនត្រូវធ្លាក់ទៅលើជីននីទៅហើយ? ច្បាស់ជាគ្មាននរណាម្នាក់នឹងអាចបញ្ជាក់បានថា នាងមិនបានធ្វើដោយមនសិការខ្លួនឯងនោះទេ...

លោកមេលហ្វ័យមិននិយាយអ្វីទាំងអស់។ ទឹកមុខរបស់គាត់បានប្រែភ្លាមដូចជាគេពាក់របាំងមុខអញ្ចឹង។

- សាកគិតទៅមើល!- សាស្ត្រាចារ្យដាំប័លដ័របន្លឺឡើង - តើអ្វីនឹងអាចកើតឡើងទៀត...វីស្លីគឺជាគ្រួសារមានឈាមជ័រជាវេទគូសុទ្ធដែលលេចធ្លោជាងគេរបស់យើង។ សាកស្រមៃអំពីឥទ្ធិពលដែលមានទៅលើលោកអស៍សី វីស្លី ហើយនិង ច្បាប់ការពារពួកលោកិយ ទៅមើល ប្រសិនបើត្រូវបានគេរកឃើញថា កូនស្រីរបស់គេជាអ្នកវាយប្រហារ និងសម្លាប់អ្នកដែលមានឈាមជ័រជាពួកលោកិយនោះ។ ជាសំណាងល្អ សៀវភៅកំណត់ហេតុត្រូវបានរកឃើញ ហើយការចងចាំរបស់រីតដលត្រូវបានជូតសំអាតចេញពីសៀវភៅនោះ។ អ្នកណាទៅដឹងថា លទ្ធផលនឹងចេញមកផ្សេងៗពីនេះនោះ...

លោកមេលហ្វ័យបង្ខំខ្លួនឯងឲ្យនិយាយ។

- សំណាងល្អមែន!- គាត់និយាយយ៉ាងតឹងតែង។

ដុបប៊ី ឈរពីក្រោយខ្នងរបស់លោក មេលហ្វ័យ ចេះតែចង្អុលទៅសៀវភៅកំណត់ហេតុ រួចទៅលោកលូស៊ីស មេលហ្វ័យ ហើយវាយខ្លួនឯងចំពីលើក្បាល។

ភ្លាមនោះ ហេរីយល់ន័យរបស់ដុបប៊ីហើយ។ វាងក់ក្បាលទៅកាន់ដុបប៊ី ហើយដុបប៊ីក៏ត្រលប់ទៅកាន់ជ្រុងម្ខាង និងមួលស្លឹកត្រចៀកខ្លួនឯងដើម្បីធ្វើទណ្ឌកម្ម។

- តើលោកចង់ដឹងទេថា តើជីននីទទួលបានសៀវភៅកំណត់ហេតុនេះយ៉ាងដូចម្ដេចទេ លោកមេលហ្វ័យ?- ហេរីនិយាយ។

លោកមេលហ្វ័យបានបែរមុខទៅរកវា។

- តើហេតុអ្វីបានជាខ្ញុំត្រូវដឹងថា នាងបានសៀវភៅកំណត់ហេតុនោះពីណាមក?- គាត់និយាយ។

- ដោយសារតែលោកបានឲ្យសៀវភៅនោះទៅនាង- ហេរីនិយាយ - គឺនៅក្នុងហាងហ្វ្លារីស និងប្លត់។ លោកបានយកសៀវភៅរៀនវិជ្ជានិម្មិតកម្មដ៏ចាស់របស់នាង ហើយដាក់សៀវភៅកំណត់ហេតុនោះចូល មែនដែរឬអត់?

ហេរីបានឃើញដៃដ៏ស្លេករបស់លោកមេលហ្វ័យក្ដាប់ហើយលាឡើងវិញ។

- ឯងគ្មានភស្តុតាងទេ- គាត់និយាយតិចៗ។

- ទេ! គ្មាននរណាមានភស្តុតាងឡើយ- លោកដាំប័លដ័រនិយាយទាំងញញឹមទៅកាន់ហេរី - រីតដលបានបាត់ខ្លួនពីក្នុងសៀវភៅនេះទៅហើយ។ ម្យ៉ាងទៀត ខ្ញុំគួរតែឲ្យដំបូន្មានទៅលោកខ្លះ គឺមិនត្រូវឲ្យសំភារៈរបស់ ឡូត វ៉ុលដឺម៉រ ទៅនរណាម្នាក់ទេ។ ប្រសិនបើមានអ្វីមួយត្រូវបានរកឃើញនៅក្នុងដៃរបស់អ្នកដែលមិនដឹងអ្វីសោះនោះ ខ្ញុំគិតថា លោក អស៍សី វីស្លី នឹងឲ្យពួកយើងធ្វើការតាមដានលោកម្ដងទៀតហើយ។

លោកលូស៊ីស មេលហ្វ័យឈរមួយសន្ទុះ។ ហេរីឃើញយ៉ាងច្បាស់ថា ដៃស្ដាំរបស់គាត់កំពុងតែកន្ត្រាក់យ៉ាងខ្លាំងហាក់ដូចជាចង់លូកយកចង្កឹះវេទមន្តរបស់គាត់អ៊ីចឹង។ ផ្ទុយទៅវិញ គាត់បានបែរទៅរកម្រេញគង្វាលប្រចាំផ្ទះរបស់គាត់។

- តោះទៅ ដុបប៊ី!

## អំណោយសំរាប់ដុបប៊ី

គាត់បានបើកទ្វារ។ នៅពេលដែលដុបប៊ីបានដើរយ៉ាងប្រញាប់ពីក្រោយគាត់ គាត់បានទាត់វាចេញក្រៅតែម្តង។ ពួកគេអាចស្តាប់ឮសំឡេងរបស់ដុបប៊ីស្រែកជាមួយនឹងសេចក្តីឈឺចាប់នៅតាមបណ្តោយផ្លូវរបៀង។ ហេរីឈរមួយសន្ទុះ ហើយព្យាយាមគិត។ បន្ទាប់មកវាបាននឹកឃើញ។

- លោកសាស្រ្តាចារ្យដាំប័លដ័រ- ហេរីនិយាយយ៉ាងប្រញាប់ - តើខ្ញុំអាចឲ្យសៀវភៅកំណត់ហេតុនេះទៅលោកមេលហ្វ័យវិញបានដែរឬទេ?

- ពិតជាបាន ហេរី- គាត់និយាយយ៉ាងស្ងៀមស្ងាត់ - ប៉ុន្តែឲ្យលឿនបន្តិច កុំភ្លេចពិធីជប់លៀងណា!

ហេរីបានកញ្ចក់យកសៀវភៅកំណត់ហេតុនោះ ហើយរត់ចេញទៅក្រៅការិយាល័យ។ វាឮសំឡេងសម្រែកដ៏ឈឺចាប់របស់ដុបប៊ីបន្លឺពេញផ្លូវរបៀង។ ដើម្បីឲ្យគម្រោងការរបស់វាអាចដំណើរការទៅយ៉ាងល្អ ហេរីបានដោះស្បែកជើងមួយចំហៀងរបស់វា ហើយដកចេញនូវស្រោមជើងដែលតូច និងកខ្វក់មួយ ព្រមទាំងដាក់សៀវភៅកំណត់ហេតុចូលទៅក្នុងនោះ។ បន្ទាប់មកវាបានរត់ចុះតាមផ្លូវរបៀងដ៏ងងឹត។

ហេរីតាមទាន់ពួកគេនៅលើផ្នែកខាងលើនៃជណ្តើរ។

- លោកមេលហ្វ័យ- វាដកដង្ហើមញាប់ៗ ហើយដាច់ៗ - ខ្ញុំមានរបស់មួយសម្រាប់លោក។

ហេរីព្យាយាមញាត់ស្រោមជើងដែលធុំក្លិនបន្តិចចូលទៅក្នុងដៃរបស់លូស៊ីស មេលហ្វ័យ។

- តើវា...

លោកមេលហ្វយបានដកស្រោមជើងនោះចេញ ហើយគ្រវាត់វាទៅម្ខាង។ គាត់បង្វែរកែវភ្នែកយ៉ាងខឹងសម្បាចេញពីសៀវភៅដែលខ្ទេចខ្ទីនោះទៅរកហេរី។

- ឯងនឹងជួបរឿងអាក្រក់ដូចឪពុកម្តាយរបស់ឯងនៅថ្ងៃណាមួយ ហេរី ផោតធ័រ- គាត់និយាយយ៉ាងស្រទន់ - ពួកគេគឺជាមនុស្សឆ្កួតដែលចូលចិត្តជ្រៀតជ្រែកក្នុងរឿងរបស់អ្នកដទៃដូចឯងដែរ។

គាត់បានបន្តដំណើរទៅមុខទៀត។

- តោះទៅ ដុបប៊ី! ខ្ញុំប្រាប់ឲ្យដើរទៅ!

ប៉ុន្តែដុបប៊ីមិនកម្រើកទេ។ វាបានរើសស្រោមជើងដែលគួរឲ្យស្អប់ និងធុំក្លិនរបស់ហេរី ហើយសម្លឹងមើលស្រោមជើងនោះហាក់បីដូចជាស្រោមជើងនោះជារតនៈសម្បត្តិដែលរកតម្លៃដាក់គ្មាន។

- លោកម្ចាស់បានឲ្យស្រោមជើងមកដុបប៊ី- ម្រេញគង្វាលនិយាយក្នុងភាពស្រឡាំងកាំង - លោកម្ចាស់បានឲ្យស្រោមជើងមកដុបប៊ី។

- មានរឿអ្វីហ្នឹង?- លោកមេលហ្វ័យនិយាយ - តើឯងនិយាយស្អី?

- ដុបប៊ីទទួលបានស្រោមជើងមួយ- ដុបប៊ីនិយាយដោយមិនចង់ជឿ - លោកម្ចាស់បោះវាចោល ហើយដុបប៊ីបានរើសវាដូចនេះដុបប៊ី...ដុបប៊ីមានសេរីភាពហើយ!

លោកលូស៊ីស មេលហ្វ័យឈរយ៉ាងនឹង ហើយសម្លឹងមើលទៅម្រេញគង្វាល។ បន្ទាប់មក គាត់បានដើរទៅរកហេរី។

- ឯងបានធ្វើឲ្យខ្ញុំបាត់បង់អ្នកបម្រើម្នាក់ហើយ ហេរី!

ប៉ុន្តែដុបប៊ីបានស្រែកឡើងៈ

- លោកមិនអាចប៉ះពាល់ហេរី ផោតធ័របានទេ!

សំឡេងដ៏ខ្លាំងបានផ្ទុះឡើង ហើយលោកមេលហ្វ៊យបានប៉ើងទៅក្រោយ។ គាត់ធ្លាក់ពីលើកាំជណ្ដើរបីកាំម្ដង ហើយធ្លាក់ទៅលើកម្រាលខាងក្រោមដូចជាពំនូកដ៏ខ្វក់ខ្វីមួយ។ គាត់បានក្រោកឡើងទាំងមុខស្លេកស្លាំង ហើយដកដម្បងវេទមន្តរបស់គាត់ចេញមក តែដុបប៊ីបានលើកម្រាមដៃដ៏វែងរបស់វាគំរាម។

- លោកគួរតែចេញពីទីនេះភ្លាមទៅ!- វានិយាយយ៉ាងក្លាហាន ហើយចង្អុលទៅលោកមេលហ្វ៊យ - លោកមិនគួរប៉ះពាល់ហេរី ផោតធ័រទេ! លោកគួរតែចេញឥឡូវនេះ!

លូស៊ីស មេលហ្វ៊យគ្មានជម្រើសទេ។ ដោយសម្លឹងមើលយ៉ាងក្ដៅក្រហាយជាចុងក្រោយទៅពួកគេទាំងពីរនាក់ គាត់បានរលាស់អាវខ្លុករបស់គាត់ ហើយដើរចេញទៅ។

- ហេរី ផោតធ័របានធ្វើឲ្យដុបប៊ីមានសេរីភាព!- ម្រេញគង្វាលនិយាយយ៉ាងគ្រលួច ហើយសម្លឹងមើលទៅហេរីមិនដាក់ភ្នែក។ ពន្លឺព្រះអាទិត្យបានចាំងចូលទៅក្នុងភ្នែករបស់វា - ហេរី ផោតធ័រធ្វើឲ្យដុបប៊ីមានសេរីភាព!

- នេះជារឿងបន្តិចបន្តួចប៉ុណ្ណោះដែលខ្ញុំអាចធ្វើបាន- ហេរីនិយាយ ហើយសើច - គ្រាន់តែសន្យាថា ឯងនឹងមិនព្យាយាមជួយសង្គ្រោះជីវិតរបស់ខ្ញុំម្ដងទៀតនោះទេ។

មុខរបស់ម្រេញគង្វាលប្រែទៅជាមានស្នាមញញឹម ដែលបញ្ចេញធ្មេញធំៗ។

- ខ្ញុំគ្រាន់តែមានសំនួរចង់សួរឯង- ហេរីនិយាយនៅពេលដែលដុបប៊ីរើសយកស្រោមជើងដោយដៃញ័រៗ - ឯងបានប្រាប់ខ្ញុំថា រឿងទាំងនោះគ្មានអ្វីដែលទាក់ទងនឹងជនដែលគេមិនហ៊ានហៅចំឈ្មោះទេ។ ឯងនៅចាំបានទេ?

- វាគឺជាគន្លឹះមួយ- ដុបប៊ីនិយាយ។ ភ្នែករបស់វាកាន់តែធំឡើងហាក់បីដូចជាស្ដែងខ្លាំងណាស់ - ដុបប៊ីបានផ្ដល់នូវគន្លឹះមួយដល់ហេរី។ មុនពេលដែលគាត់ប្ដូរឈ្មោះរបស់គាត់ទៅជា ឡត វ៉ុលដឺម៉រ គាត់អាចមានឈ្មោះដែលគេហៅធម្មតាមួយទៀតលោកដឹងទេ?

- ត្រូវហើយ!- ហេរីនិយាយយ៉ាងលឿន - ខ្ញុំត្រូវទៅហើយ ព្រោះខ្ញុំត្រូវចូលរួមពិធីជប់លៀងមួយ ហើយមិត្តរបស់ខ្ញុំហឺម៉ាយអូនី ប្រហែលជាដឹងខ្លួនក្នុងពេលបន្តិចទៀតនេះ។

ដុបប៊ីបានលើកដៃដាក់ជុំវិញចង្កេះរបស់ហេរី ហើយអោបវា។

- ហេរី ផោតធ័រគឺជាមនុស្សដ៏អស្ចារ្យជាងអ្វីដែលខ្ញុំធ្លាប់ដឹងធ្លាប់ឮទៅទៀត!- វាបន្លឺសំឡេងអណ្ដឹតអណ្ដក - លាហើយ ហេរីផោតធ័រ!

ដុបប៊ីបានបាត់ខ្លួនទៅជាមួយសំឡេងខ្លាំងមួយ។

★

ហេរីធ្លាប់ចូលរួមក្នុងពិធីជប់លៀងបីបួនដងទៅហើយនៅសាលាហុកវ៉ាត ប៉ុន្តែគ្មានពិធីជប់លៀងណាដែលមានសភាពដូចនេះទេ។ អ្នករាល់គ្នាស្ថិតនៅក្នុងសម្លៀកបំពាក់គេងយប់ ហើយពិធីជប់លៀងប្រារព្ធទៅពេញមួយយប់។ ហេរីមិនដឹងថាតើរឿងមួយណាល្អជាងមួយណានោះទេ នៅពេលដែលហឺម៉ាយអូនីបានរត់តម្រង់ទៅរកវា ហើយស្រែកថា "ឯងបានដោះស្រាយវាហើយ!" រឺក៏ពេលដែលចាស់ស្ទីនរត់យ៉ាងប្រញាប់ប្រញាល់ចេញពីតុរបស់ក្រុមហាហ្វ៊លផហ្វ ដើម្បីចាប់លាក់ដៃរបស់វា ហើយសុំទោសវាសម្រាប់ការចោទប្រកាន់ចំពោះវា រឺមួយក៏ពេលដែលហាហ្គ្រីដបានត្រលប់មកវិញនៅម៉ោងបីកន្លះ ហើយទះស្មាវា និងរ៉ុនយ៉ាងខ្លាំងធ្វើឲ្យពួកគេបុកនឹងចានម្ហូបកំពប់អស់ រឺក៏វាត្រូវរីករាយចំពោះបួនរយពិន្ទុរបស់វា និងរ៉ុន ដែលធ្វើឲ្យក្រុមហ្គ្រីហ្វីនដ័រឈ្នះពានរង្វាន់សម្រាប់ឆ្នាំទីពីរ រឺក៏វាត្រូវរីករាយនៅពេលដែលអ្នកស្រីម៉ាកហ្គូណាហ្គាលបានក្រោកឡើង ហើយប្រាប់ពួកគេថាការប្រលងត្រូវបាន

លុបចោល ដែលជាការសម្រេចចិត្តរបស់សាលា (-មិនគួរទេ!- ហឺម៉ាយអូនីនិយាយ) រីក៏ត្រូវរីករាយនៅពេលដែលលោកសាស្រ្តាចារ្យដាំប័លដ័រប្រកាសថា ឆ្នាំក្រោយនេះ លោកសាស្រ្តាចារ្យឡុក់ហាតមិនអាចត្រលប់មកវិញបានទេ។ គាត់ត្រូវតែចាកចេញទៅឆ្ងាយ ដើម្បីទទួលការចងចាំរបស់គាត់មកវិញ។ គ្រូជាច្រើនបានចូលរួមអបអរសាទរចំពោះដំនឹងនោះ។

- ស៊ិយមែន- រ៉ុននិយាយពេលកំពុងញ៉ាំនំដុតបៀកដំណាប់ - គាត់កំពុងតែចាប់អារម្មណ៍មកលើខ្ញុំហើយ។

★

ពេលវេលានៃរដូវក្តៅដែលនៅសល់ បានកន្លងផុតទៅនៅក្រោមពន្លឺព្រះអាទិត្យយ៉ាងត្រចះត្រចង់។ សាលាហុកវ៉ាតបានត្រលប់មករកសភាពធម្មតាវិញជាមួយនឹងភាពខុសប្លែកតែពីរបីតែប៉ុណ្ណោះ គឺថ្នាក់រៀនមុខវិជ្ជាប្រឆាំងនឹងមន្តអាគមងងឹតត្រូវបានលុបចោល (ប៉ុន្តែពួកយើងនៅតែមានកិច្ចការអនុវត្តជាច្រើន- រ៉ុននិយាយប្រាប់ទៅហឺម៉ាយអូនីទាំងមិនពេញចិត្ត) ហើយលោកលូស៊ីស មេលហ្វ័យត្រូវបានបណ្តេញចេញពីតំនែងជាអភិបាលសាលា។ ដ្រាកូលែងដើរពើងទ្រូងនៅក្នុងសាលាទៀតហើយ ផ្ទុយពីអ្វីដែលវាធ្លាប់ធ្វើរាល់ដង។ ម្យ៉ាងទៀត វាមិនសូវសប្បាយចិត្ត ហើយមានទឹកមុខខឹងរហូត។ ផ្ទុយទៅវិញ ជីននី វីស្លីមើលទៅហាក់ដូចជាសប្បាយចិត្តយ៉ាងខ្លាំងជាថ្មីម្តងទៀត។

បន្តិចទៀតនេះដល់ពេលដែលត្រូវធ្វើដំណើរទៅផ្ទះវាតាមរយៈភ្នាក់ងាររថភ្លើងរបស់ហុកវ៉ាត។ ហេរី រ៉ុន ហឺម៉ាយអូនី ហ្វ្រេដ ចច និងជីននីរកបានបន្ទប់រៀងៗខ្លួនហើយ។ ពួកគេត្រូវបានអនុញ្ញាតឲ្យសាកល្បងវេទមន្តនៅក្នុងសាលារយៈពេលពីរបីម៉ោងចុងក្រោយ មុនពេលវិស្សមកាល។ ពួកគេបានធ្វើបាបស្នេព ដុតកាំជ្រួចដែលនៅសល់របស់ចច និងហ្វ្រេដ ហើយអនុវត្តការដកហូតអាវុធរបស់គ្នាទៅវិញទៅមកដោយប្រើវេទមន្ត។ ហេរីដូចជាពូកែជាងមុនបន្តិច។

ហេរីបាននឹងឃើញនូវអ្វីមួយនៅពេលដែលពួកគេជិតទៅដល់ចំណតរថភ្លើងឃីញ ក្រុស។

- ជីននី! តើឯងបានឃើញពៀរស៊ីធ្វើអ្វីបានជាវាមិនចង់ឲ្យឯងប្រាប់នរណាម្នាក់នោះ?

- អូ! គឺវាអញ្ចេះទេ- ជីននីនិយាយ ហើយសើច - គឺពៀរស៊ីមានមិត្តស្រី។

ហ្វ្រេដបានធ្វើឲ្យធ្លាក់សៀវភៅជាច្រើនទៅលើក្បាលចច។

- ថាម៉េច?

- នាងគឺជាប្រធានសិស្សរបស់ក្រុមរ៉ាវីនក្លាហ្វឈ្មោះ ពេនេឡូប គ្លៀរវ៉ធើរ- ជីននីនិយាយ - នាងគឺជាមនុស្សដែលគាត់បានផ្ញើសំបុត្រឲ្យអស់រយៈពេលពេញមួយរដូវក្តៅឆ្នាំមុន។ គាត់បានណាត់ជួបនាងនៅគ្រប់ទីកន្លែងនៅក្នុងសាលាហុកវ៉ាតយ៉ាងសម្ងាត់បំផុត។ ថ្ងៃមួយនោះ ខ្ញុំបានដើរចូលទៅក្នុងថ្នាក់ទំនេរមួយចំពេលដែលពួកគេកំពុងតែថើបគ្នា។ គាត់មិនសប្បាយចិត្តយ៉ាងខ្លាំងនៅពេលដែលនាងត្រូវបានវាយប្រហារ។

- សូម្បីតែយល់សប្តិក៏នឹកមិនដល់ដែរ- ហ្វ្រេដនិយាយយ៉ាងភ្ញាក់ផ្អើលដូចថ្ងៃខួបកំណើតរបស់វានឹងឈានមកដល់ក្នុងពេលឆាប់ៗនេះអញ្ចឹង។

- ពិតជាហួសពីការស្មានមែន!- ចចនិយាយ ហើយសើចតិចៗយ៉ាងអាថ៌កំបាំង។

រថភ្លើងបានបន្ថយល្បឿន ហើយទីបញ្ចប់ក៏ឈប់។

ហេរីបានដកស្លាបប៉ាកកា និងក្រដាសស្បែកចៀមបន្តិច ហើយបែរមុខទៅរករ៉ុន និងហឺម៉ាយអូនី។

## អំណោយសំរាប់ដុំបបី

- នេះហៅថាលេខទូរស័ព្ទ- វាប្រាប់ទៅរ៉ុន ហើយសរសេរយ៉ាងខ្មៀកពីរដង។ វាបានហែកក្រដាសនោះជាពីរ ហើយហុចទៅឲ្យពួកគេម្នាក់ម្នាក់ - ខ្ញុំបានបង្រៀនឪពុករបស់ឯងឲ្យចេះប្រើទូរស័ព្ទហើយកាលពីរដូវក្តៅឆ្នាំមុននោះ។ ទូរស័ព្ទទៅខ្ញុំតាមរយៈគ្រួសារឌើស្លីបានទេ? ខ្ញុំមិនអាចទ្រាំរស់ដល់ទៅពីរខែជាមួយនឹងដាត់លីដែលតែងតែ...

- មីងពូរបស់ឯងប្រហែលជាមានមោទនភាពចំពោះឯងហើយ មិនថាអ៊ីចឹងរឺ?- ហឺម៉ាយអូនីនិយាយនៅពេលដែលពួកគេចុះពីលើរថភ្លើង ហើយដើរចូលទៅក្នុងហ្វូងមនុស្សដែលកំពុងតែដើរទៅកាន់របាំងវេទមន្ត - នៅពេលដែលពួកគាត់ដឹងថា ឯងបានធ្វើអ្វីខ្លះក្នុងឆ្នាំនេះ។

- មោទនភាព?- ហេរីនិយាយ - ឯងឆ្កួតទេរឺ? កាលពីពេលនោះ ខ្ញុំអាចនឹងស្លាប់បានគ្រប់ពេល។ ប្រសិនបើពួកគេដឹងថា ខ្ញុំបែរជាមិនស្លាប់វិញនោះ ពួកគេច្បាស់ជាខឹងដាច់ក្បាលដាច់កន្ទុយទៀតជាមិនខាន...

ពួកគេបានដើរព្រមគ្នាសំដៅទៅរកច្រកចូលដែលនាំទៅកាន់ពិភពពួកលោកិយ។

**-ចប់-**

# សទានុក្រម

- ✓ ទំព័រទី១៤ បន្ទាត់ទី ៧ ៖ **ប៉ែនស៊ី** - បិសាចមានរូបរាងជាស្រីម្នាក់ ដែលមានសក់អូសដី និងមុខឆ្អឹងពណ៌បៃតងព្រលែត។ សម្រែករបស់បិសាចនេះអាចសម្លាប់មនុស្សបាន។
- ✓ ទំព័រទី៣៣ បន្ទាត់ទី ៧៖ **ក.ប.វ.ក.ស.** - ពាក្យពេញ "ការប្រលងវេទមន្តកម្រិតសាមញ្ញ"។
- ✓ ទំព័រទី១០២ បន្ទាត់ទី ៨ ៖ **ផនអវេទ** - ជនដែលកើតពីត្រកូលវេទមន្ត តែបែរជាមិនចេះប្រើវេទមន្ត។
- ✓ ទំព័រទី១២២ បន្ទាត់ទី ៥ ៖ **អូលីវើ វូដ** - ឈ្មោះពេញរបស់ ដំបង។
- ✓ ទំព័រទី១៣៣ បន្ទាត់ទី ១៤ ៖ **ប៊ូមស្លែង** - សត្វពស់អាព្រិច ដែលមានពិសសាហាវ។ សត្វឈ្មោលភាគច្រើនមានស្បែកពណ៌បៃតង ឯញីភាគច្រើនស្បែកពណ៌ត្នោត ដែលជួយក្នុងការលាក់ខ្លួន។
- ✓ ទំព័រទី១៤៩ បន្ទាត់ទី ៣០ ៖ **ផ្ទាត់បំផ្ទុះ** - ល្បែងម្យ៉ាងលេងដោយវេទគូ។